# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ជីវភាពកសិករខ្មែរ

ឆ្នាំទី ៥១ លេខ ១ ខែ មករា - កុម្ភៈ - មីនា

ព.ស ២៥៤០ គ.ស ១៩៩៧

ភ្នំពេញ

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ឌារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**
លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនា និងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគមានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# មាតិកាអត្ថបទ

I. អក្សរសិល្ប៍ពុទ្ធសាសនា

- ពុទ្ធសាសនា និងសន្តិភាព ( ឥន្ទបញ្ញោភិក្ខុ ហ. មណីចិន្តា ) ........ ១
- ពុទ្ធឱវាទ ( ឱម ខៃម ) ........ ១៩

II. អក្សរសាស្ត្រទូទៅ

- អំពីផែនដី ឬ ធរណី ( ឈន អៀម ) ........ ២៨
- ឋាននន្តរនាម សម័យអង្គរ ( បណ្ឌិត ឡុង សៀម ) ........ ៤១
- បញ្ហានៃសិលាចារឹក សម័យមុនអង្គរ ( វង់ សុធារ៉ា ... ) ........ ៤៨
- ការសិក្សាសម័យថ្មី ( មៀច ប៉ុណ្ណ ) ........ ៧៦
- បទ ក ខ ( ធន់ ហ៊ិន ) ........ ៨៣
- សាស្ត្រាក្រៀត្យក្រម ( មៀច ប៉ុណ្ណ ) ........ ៨៨
- ចម្រៀងឆ្លើយឆ្លង ( ធន់ ហ៊ិន ) ........ ៩៣
- បុណ្យទ្វាទសមាស ( មៀច ប៉ុណ្ណ ) ........ ៩៩
- អនុស្សរណោវាទ ( សម្ដេច ជួន ណាត ) ........ ១០២
- លទ្ធផលនៃចម្លើយ « ប្រស្នាកំណាព្យ » ........ ១០៣
- កិច្ចថ្លែងអំណរគុណចំពោះ ញោម វណ្ណ ស៊ុនហេង ........ ១០៤
- ចម្លើយកំណាព្យប្រស្នា ( វណ្ណ ស៊ុនហេង ) ........ ១០៥
- * កំណាព្យប្រស្នា ( វណ្ណ ស៊ុនហេង ) ........ ១១១

III. កំណត់ និង ប្រវត្តិកាណ៍

- សេចក្ដីរាសការណ៍ស្ដីពី ការងារ របស់ ពុទ្ធសាសនបណ្ឌិត្យ ........ ១១២

# ពុទ្ធសាសនា និង សន្តិភាព

សំដែងដោយ
ឥន្ទបញ្ញោភិក្ខុ ហេង មណីចិន្តា ក្នុងសិក្ខាសាលាជាតិលើកទី ៣ ស្ដីពី
" ពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ "
នៅវត្តអន្លង់វិល ខេត្តបាត់ដំបង

ឆ្នាំនេះជាឆ្នាំទីបីហើយ ដែលសិក្ខាសាលាជាតិ ស្ដីអំពី " ពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ " បានប្រព្រឹត្តទៅ ដោយបានទទួលការយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ។ ក្នុងឆ្នាំទីមួយ យើងបានផ្ដោតការយកចិត្តទុកដាក់អំពីគុណប្រយោជន៍របស់ពុទ្ធសាសនាក្នុងការអភិវឌ្ឍន៍សង្គមខ្មែរ, ឯលើកទីពីរ យើងបានផ្ដោតលើការយកគោលធម៌ពុទ្ធសាសនាមកបដិបត្តិឱ្យចេញជារូបរាងឡើង ដោយយើងបានធ្វើសេចក្ដីសំរេចរួមគ្នាមួយ ដែលមាន ៥ ចំណុច សំរាប់ឱ្យពុទ្ធបរិស័ទទាំងអស់យកទៅអនុវត្តតាមការគួរ ។ ក្នុងលើកទីបីនេះ បាវចនាសំខាន់របស់យើងគឺ " ពុទ្ធសាសនា និង សន្តិភាព " ។

សន្តិភាព ! សន្តិភាព ជាពាក្យដែលយើងគ្រប់គ្នាប្រាថ្នា បន់ស្រន់ អធិដ្ឋានសូមឱ្យកើតមានដល់ពួកយើង និងប្រទេសយើងគ្រប់ពេលវេលា ។ តាំងពីខ្ញុំព្រះករុណា អាត្មាភាពដឹងក្ដីមក យើងនាំគ្នាបន់ស្រន់ជាង ៣០ ឆ្នាំហើយ ។

ចាប់តាំងពីសង្គ្រាមលោកលើកទី ២ បានចប់ទៅ ដោយបានកំទេចនូវអាយុជីវិតរបស់មនុស្ស សរុបជាប្រមាណ ១៥ លាននាក់នោះ អ្នកកត់ត្រាកំណត់ហេតុបានសង្កេតឃើញថា មកទល់នឹងឆ្នាំ ១៩៧៥ មុននេះ មានសង្គ្រាមកើតឡើងប្រហែលជា ៣០០ ដង ហើយអ្នកដែលបានបាត់បង់ជីវិតទៅនោះ មានប្រហែលជា

២៥ លាននាក់ ។ ក្នុងនេះ យើងមិននិយាយអំពីការបាត់បង់ទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបាននោះឡើយ ។ គ្រាន់តែឆ្នាំ ១៩៩៦ មានភ្លើងសង្គ្រាមឆាបឆេះទាំងនៅក្នុងទ្វីបអាស៊ី, អឺរ៉ុប និងអាមេរិក ជាដើម ចំនួន ៣៩ កន្លែង និងជាមធ្យមមានមនុស្សរងគ្រោះ ចំនួន ២.៧៧៤ នាក់ ជារៀងរាល់ថ្ងៃ ដោយ ៩០% ជាប្រជា-ពលរដ្ឋស៊ីវិល និងពាក់កណ្តាលចំនួននេះ ជាកុមារ ។

សំរាប់កម្ពុជាយើង ចាប់តាំងពីប្រទេសជាតិបានទទួលឯករាជ្យ ដោយសារស្នាព្រះហស្តរបស់ព្រះបានសម្តេច នរោត្តម សីហនុ វរ្ម័ន មក យើងបានទទួលសន្តិភាពដែលមិនពេញលេញមួយ ក្នុងរយៈពេលដ៏ខ្លី គឺបានតែពីឆ្នាំ ១៩៥៤ ដល់ ១៩៦៩ តែប៉ុណ្ណោះ ។ ចាប់តាំងពីឆ្នាំ ១៩៧០ មក យើងទទួលនូវសេចក្តីទុក្ខវេទនារហូត គឺរយៈពេល ២៦ ឆ្នាំ : ឆ្នាំ ១៩៧០ - ១៩៧៥ ជាសង្គ្រាមស៊ីវិល, ឆ្នាំ ១៩៧៥ - ១៩៧៩ ជាសង្គ្រាមមនោគមវិជ្ជា, ឆ្នាំ ១៩៧៩ - ១៩៩១ ជាសង្គ្រាម ដើម្បីបូរណភាពដែនដី ។

ចំណុចមួយដែលគួរឱ្យចាប់អារម្មណ៍លើមរណកម្មដ៏ច្រើននេះ គឺប្រទេសយើង ជាប្រទេសដែលមានប្រជាពលរដ្ឋកាន់ព្រះពុទ្ធសាសនាជាង ៩៥% ហើយជឿកាន់តាំងតែជាងមួយពាន់ឆ្នាំមកហើយ ហេតុអ្វី ក៏យើងបែរជាមានសង្គ្រាមជាបន្តបន្ទាប់ដូច្នេះ ? យើងទាំងអស់គ្នា ជាពិសេស បរទេសផ្តល់តម្លៃឱ្យព្រះពុទ្ធសាសនា ថាជាសាសនាតែមួយគត់ ដែលនិយមអហិង្សា និងមានគោលដៅឆ្ពោះទៅរកសន្តិភាពជាងសាសនាណាៗ ទាំងអស់ តើហេតុអ្វីបានជាពុទ្ធសាសនិកជនបែរជានាំគ្នាប្រព្រឹត្តអំពើហិង្សាទៅវិញ ? នេះជាសំណួរដែលយើងទាំងអស់គ្នាត្រូវដោះស្រាយ ។ យើងមិនមែនដោះស្រាយ ដើម្បីត្រឹមតែឆ្លើយឱ្យរួចនឹងសំណួររបស់គេតែប៉ុណ្ណោះទេ ជាពិសេស គឺការយកនូវដំណោះស្រាយដ៏ល្អនោះ មកឆ្លុះបញ្ចាំងលើខ្លួនយើង ដើម្បីរកវិធានការណ៍ការពារកុំឱ្យកើតមានឡើងទៀត និងដើម្បីបាន

ជួបនឹងសន្តិភាពដែលយើងប្រាថ្នានោះមែនទែន ។ ដរាបណាយើងមិនទាល់ខ្លួនយើងស្គាល់ហេតុដែលនាំឱ្យចំរើនវិនាស និងផលដែលកើតពីកម្មរបស់យើងទេ ដរាបនោះយើងនៅតែលិចលង់នៅក្នុងសមុទ្រនៃអវិជ្ជា ដែលជាប្រភពនៃភ្លើងសង្គ្រាម និងសេចក្តីទុក្ខមិចេះចប់ជាពុំខាន ។ សិក្ខាសាលានេះ គឺមានគោលបំណងដើម្បីនឹងដោះស្រាយនូវបញ្ហាទាំងអស់នោះឯង ។

អត្ថបទ " ពុទ្ធសាសនា និងសន្តិភាព " នេះ នឹងនិយាយអំពីសន្តិភាពក្នុងបរិបទព្រះពុទ្ធសាសនា ដែលនឹងអធិប្បាយនូវអ្វីដែលហៅថាសន្តិភាព និងមិនមែនសន្តិភាព តាមនិយមន័យ អត្ថន័យ និងការអនុវត្តជាក់ស្តែង, អ្វីដែលជាហេតុមិននាំឱ្យមានសន្តិភាព ឬអ្វីដែលជាហេតុនាំឱ្យសន្តិភាពបាត់បង់, និងព្យាយាមនាំយកនូវមាគ៌ារបស់ព្រះពុទ្ធអង្គ ដែលនិយាយអំពីដំណើរឆ្ពោះទៅរកសន្តិភាពដ៏ពិតប្រាកដ យកមកជូនតាមពេលវេលាដែលអនុញ្ញាតឱ្យ ។

* * *

## ស្គាល់ទុក្ខសិន ទើបរកសុខបាន

ព្រះពុទ្ធសាសនាមិនអាចនិយាយអំពីអ្វីដែលហៅថាសន្តិភាព ឬសេចក្តីស្ងប់សុខបានទេ បើសិនជាមនុស្សលោកមិនមានសេចក្តីទុក្ខ ឬសង្គ្រាម ហើយព្រះពុទ្ធអង្គក៏លោកមិនចាំបាច់បដិសន្ធិលើលោកនេះដែរ ។ តាមពិត ពួកយើងជាពុទ្ធសាសនិកជន មិនមានការប្លែកនៅក្នុងចិត្តទេ កាលណាឮសូរពាក្យថាទុក្ខ ហើយក៏មិនមានការភ័យខ្លាចដែរ តែបើឮសូរពាក្យថាសង្គ្រាមវិញ តែងតែញ័ររន្ធត់ និងមានសេចក្តីតក់ស្លុតជានិច្ច ។ តាមពិត បើយើងពិនិត្យមើលទៅ ពាក្យនេះមានន័យដូចគ្នា

គ្រាន់តែសង្គ្រាមបង្ហាញនូវរូបភាពជាចំបាំង ការកាប់សម្លាប់គ្នាទៅវិញទៅមក និង ឃើញនូវសេចក្តីស្លាប់នោះផ្ទាល់ភ្នែក ឯសេចក្តីទុក្ខវិញ ជាសង្គ្រាមដែលមានដំណើរ ទៅដោយស្ងៀមស្ងាត់ យឺតៗ មិនឱ្យដឹងខ្លួន តែលទ្ធផលវិញ គឺដូចគ្នា ។ យើងធ្លាប់ឮ ពាក្យថា សង្គ្រាមជីវិត គឺយើងត្រូវប្រយុទ្ធជាមួយធម្មជាតិដើម្បីរស់ ប្រយុទ្ធជាមួយ ខ្លួនយើង ប្រពន្ធកូនយើង គ្រួសារយើង ជារៀងរាល់ថ្ងៃ តែយើងមិនប្រើពាក្យ សង្គ្រាមទេ យើងប្រើពាក្យ តស៊ូ ប្រកែក ឈ្លោះ ប្រដៅ រករឿង ។ នៅក្នុងសង្គម វិញ យើងត្រូវធ្វើសង្គ្រាមជាមួយអ្នកជិតខាង ជាមួយការងារ ជាមួយសហការី សង្គ្រាមដើម្បីអំណាច ដើម្បីឋានៈ សង្គ្រាមជាមួយគោក្របី ដោយហោចទៅ សូម្បី តែជាមួយវត្ថុគ្មានវិញ្ញាណ ក៏យើងអាចធ្វើសង្គ្រាមជាមួយដែរ ដូចជាអ្នកខ្លះត្រូវ ឈ្លោះជាមួយរថយន្ត ជាមួយគ្រឿងប្រើប្រាស់ ជាដើម ។ ជាអន្តរជាតិ យើងធ្វើ សង្គ្រាមសេដ្ឋកិច្ច សង្គ្រាមការពារទឹកដី ឬដណ្តើមទឹកដី សង្គ្រាមពូជពង្ស ឬក៏ សង្គ្រាមសាសនា ជាដើម ។ ទាំងអស់នេះ គឺសុទ្ធតែជាសង្គ្រាមដែលយើងត្រូវប្រយុទ្ធ តស៊ូជារៀងរាល់ថ្ងៃ ពេលខ្លះក៏ឈ្នះ ពេលខ្លះក៏ចាញ់ ជារឿងធម្មតា ។

ក្នុងបឋមទេសនារបស់ព្រះអង្គ ដែលមានឈ្មោះថា ធម្មចក្កប្បវត្តនសូត្រ ព្រះពុទ្ធអង្គបានបង្ហាញអំពីសេចក្តីទុក្ខ ១២ យ៉ាង ដែលមនុស្សជាតិតែងជួបប្រទះជា រៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់ខ្លួន ហើយដែលអាចក្តីសូមលើកយកមកប្រៀប ធៀបនឹងសង្គ្រាមជីវិត ដែលយើងជួបនៅក្នុងសង្គមយើង ដូចតទៅនេះ :

## ប្រៀបធៀបសង្គ្រាម និង ទុក្ខ

| សេចក្តីទុក្ខ | សង្គ្រាម |
|---|---|
| ១. កំណើត | កំណើនប្រជាជន |
| ២. ជរា | សុខភាពទន់ខ្សោយ |

| | |
|---|---|
| ៣. ព្យាធិ | ជំងឺប្រចាំ |
| ៤. មរណៈ | អត្រាមរណៈខ្ពស់ |
| ៥. សោក បរិទេវ ទុក្ខ វិបត្តិផ្លូវចិត្ត | សុខភាពចិត្តមិនល្អ |
| ៦. ទោមនស្ស | ខឹងច្រើន |
| ៧. អប្បិយេហិ សម្បយោគោ | បរិដ្ឋានសង្គមមិនល្អកើតឡើងច្រើន |
| ៨. វិប្បយេហិ សម្បយោគោ | បាត់បង់បរិដ្ឋានសង្គមដែលល្អ |
| ៩. យម្បិច្ឆំ ន លភតិ | តម្រូវការមិនបានដូចចិត្ត ( Excess of Denand ) |

## ១. កំណើត

ការកើត គឺជាសេចក្តីទុក្ខ ជារឿងដែលត្រូវទ្រាំ ត្រូវតស៊ូ ទើបអាចមានជីវិតរស់នៅបាន ។ បញ្ហាដែលកើតឡើងជាមួយនឹងកំណើត គឺបញ្ហាសេដ្ឋកិច្ចដែលត្រូវដោះស្រាយ ។ ព្រះពុទ្ធអង្គទ្រង់សំដែងថា *សព្វេ សត្តា អាហារដ្ឋិតិកា* សត្វទាំងឡាយរស់បានដោយសារអាហារ ។ កំណើនប្រជាជន គឺជាបញ្ហាមួយនៅក្នុងសង្គមដែលមានសេដ្ឋកិច្ចទន់ខ្សោយ គ្រួសារមួយដែលហូបមិនគ្រប់គ្រាន់ ។ ការមានកូនច្រើន សមាជិកគ្រួសារច្រើន ជាកត្តាមួយដែលនាំទៅរកវិបត្តិគ្រួសារ និងវិបត្តិសង្គម ។ សង្គមដែលមានកំណើនសេដ្ឋកិច្ចយឺតជាងកំណើនប្រជាជន ក៏នឹងមានបញ្ហាជាពិតប្រាកដ ។ ដូច្នេះហើយបានជា យើងឃើញរដ្ឋាភិបាលនានា ព្យាយាមបន្ថយនូវអត្រាកំណើនប្រជាជន ដើម្បីឱ្យមានតុល្យភាពជាមួយនឹងកំណើនសេដ្ឋកិច្ច ។ ក្នុងពុទ្ធសាសនា ការរក្សាសីលប្រាំបី ក្នុង ១ ខែបួនដង ក៏រាប់ថាជាវិធានការណ៍ការពារជាប្រយោលដល់កំណើនប្រជាជនដែរ ។

## ២. ជរា

ជរា ឬចាស់ ក៏ជាវិបត្តិសង្គមមួយដែរ ។ ចាស់ជរាតែងមានកម្លាំងខ្សោយ ហើយក្នុងសង្គមដែលមានជនជរាច្រើន កម្លាំងផលិតក៏ទន់ខ្សោយ ហើយបើមានជំងឺច្រើនទៀតផងនោះ ក៏នឹងរឹតតែនាំមកនូវបញ្ហាគ្រួសារ និងសង្គមច្រើនដែរ ។ ក្នុងសង្គមយើង រាងកាយយើងចាស់មុនអាយុ ព្រោះអាស្រ័យពលកម្មធ្ងន់ធ្ងរ និងកង្វះខាតអាហារ ។ យើងឃើញថា អាយុខ័យយើងបានតែ ៤៧ ឆ្នាំ ប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងជប៉ុន ឬអាមេរិក ដែលមានរហូតដល់ទៅ ៧០ ឆ្នាំ ។

## ៣. មរណៈ

មរណកម្មក៏ជាសេចក្តីទុក្ខ ឬបញ្ហាមួយនៅក្នុងសង្គម ។ បញ្ហាអត្រាមរណៈខ្ពស់របស់ទារកយើង ( ១៥% ) អត្រាមរណៈរបស់មាតា ( ១០% ) និងអត្រាមរណៈដោយសារគ្រាប់មីន ៨ នាក់ក្នុងមួយថ្ងៃ គឺជាបញ្ហាសង្គមមួយដែលនឹងនាំទៅរកវិបត្តិទាំងខាងផ្លូវចិត្ត និងផ្លូវកាយ ។

## ៤. សោក បរិទេវ ទុក្ខទោមនស្ស

បញ្ហាវិបត្តិផ្លូវចិត្ត ក៏ជាបញ្ហា ឬសេចក្តីទុក្ខនៅក្នុងសង្គមដែរ ។ ការសោកសៅច្រើន យំច្រើន ពិបាកចិត្តច្រើន ខឹងច្រើន គឺជារោគសញ្ញានៃការថមថយរបស់សុខភាពផ្លូវចិត្ត ។ អាការៈទាំងនេះ នឹងនាំឱ្យបុគ្គលទាំងនោះបាត់បង់នូវសមត្ថភាពកម្លាំងចិត្ត កម្លាំងកាយក៏ចុះថយច្រើន ឬក៏ខឹងច្រើន ក្លាយទៅជាការបៀតបៀនគេដោយមិនសមហេតុសមផល ។ ក្នុងសង្គ្រាមជាង ២០ ឆ្នាំ មកនេះ ពួកយើងជួបនឹងវិបត្តិផ្លូវចិត្តយ៉ាងខ្លាំង : ការលោភលន់ ការមិនទុកចិត្តគ្នា ការច្រណែនឫស្យា

ចងគំនុំ ការគ្មានជំនឿលើខ្លួនឯង ការពឹងពាក់លើគេ គឺជាសញ្ញានៃវិបត្តិផ្លូវចិត្ត ដែលទាមទារនូវភាពព្យាបាលរក្សាជាចាំបាច់ ។

## ៥. អប្បិយេហិ សម្បយោគោ

ការជួបនឹងរបស់ដែលមិនជាទីពេញចិត្ត ឬរបស់មិនគប្បី មិនល្អ មិនជាទីរាប់អាន ក៏នឹងនាំមកនូវបញ្ហាក្នុងជីវិត ឬក្នុងសង្គម ។ អាចក្ដីសូមប្រើពាក្យថា *បរិដ្ឋានសង្គមវិបត្តិ* ដូចជាបញ្ហាភាពកខ្វក់កើតឡើង ពេស្យាចារកើនឡើង ការរំលោភលើភេទកុមារ ចោរកម្ម ឧក្រិដ្ឋកម្ម សំណូកសូកប៉ាន់ បក្សពួកនិយម ការដណ្ដើមអំណាចដោយហឹង្សា បរិយាកាសពិសពុល ជំងឺអេដស៍ អសន្តិសុខជាដើមនេះ សុទ្ធតែជារបស់ដែលយើងមិនចង់ជួប ហើយដែលក្លាយទៅជាបញ្ហាសង្គម ដែលត្រូវតស៊ូដើម្បីដោះស្រាយ ។

## ៦. វិប្បយោហិ សម្បយោគោ

ការបាត់បង់នូវរបស់ដែលជាទីពេញចិត្ត ឬបាត់បង់នូវរបស់ដែលល្អ មានប្រយោជន៍ ដែលជាគុណសម្បត្តិរបស់ជីវិត ឬការបាត់បង់បរិដ្ឋានសង្គមដែលល្អ ដូចជាការបាត់បង់ព្រៃឈើ ធម្មជាតិវេចវិល បាត់បង់ប្រាសាទបុរាណ បាត់បង់សីលធម៌ វប្បធម៌ ប្រពៃណី បាត់បង់អត្តសញ្ញាណជាតិដែលល្អៗ ជាដើមនេះ សុទ្ធតែជាបញ្ហាដែលនាំមកនូវទុក្ខ និង សង្គ្រាម ។

## ៧. យម្បិច្ឆំ ន លភតិ

ប្រាថ្នានូវរបស់ណា មិនបាននូវរបស់នោះ ក៏ជាកត្តានៃទុក្ខ និងសង្គ្រាមតស៊ូ ។ ចង់បានទ្រព្យសម្បត្តិ ចង់បានអាហារហូបគ្រប់គ្រាន់ ចង់បាននូវការរាប់អាន

ក្នុងសង្គម ចង់បានសន្តិភាព ចង់បានប្រជាធិបតេយ្យ សិទ្ធិមនុស្ស សិទ្ធិស្មើគ្នានៅក្រោមអំណាចច្បាប់តែមួយ សិទ្ធិរវាងបុរស និងស្ត្រី ... ការដែលទាមទារមិនបានការតស៊ូក៏នឹងកើតឡើង ។

## ៨- បញ្ហាទានក្ខន្ធា ទុក្ខា

ទុក្ខព្រោះប្រកាន់ថា " អញ " និង " របស់អញ " ជាសេចក្តីសង្ខេបនៃសេចក្តីទុក្ខទាំងពួង ។ បើម្នាក់ៗ សំគាល់ថា អញ របស់អញ សង្គមអញ សុខទុក្ខអញ ពុទ្ធិអញហើយ សេចក្តីទុក្ខក៏កើតឡើងដែរ ។

## ប្រភពបញ្ហា

ក្នុងពុទ្ធសាសនា សេចក្តីទុក្ខមិនមែនកើតឡើងឯងៗ ឬដោយសារអាទិទេពណាមួយដាក់បណ្តាសាឱ្យកើតឡើងនោះទេ ។ ពុទ្ធសាសនា គឺជាសាសនាហេតុផលនិយម និងកម្មនិយម ។ ទុក្ខក្តី កើតឡើងព្រោះអាស្រ័យកម្ម ឬអំពើរបស់មនុស្សទាំងអស់ ។ ប្រភពនៃសេចក្តីទុក្ខ ឬអំពើដែលនាំឱ្យកើតសេចក្តីទុក្ខនោះ អាចចែកទៅជាក្រុម ដូចតទៅ :

## ក្រុមហេតុទី ១ - តណ្ហា

ហេតុដែលនាំឱ្យកើតសេចក្តីទុក្ខទី ១ គឺតណ្ហា ដែលប្រែថា ចំណង់ ឬសេចក្តីប្រាថ្នា ។ គ្រប់ព្រឹត្តិកម្មរបស់យើង សុទ្ធតែត្រូវបើកបរ និងកាច់ចង្កូតដោយតណ្ហាទាំងអស់ ។ តណ្ហា ធ្វើឱ្យយើងជួបនូវអត្ថិភាពថ្មី មានចិត្តត្រេកត្រអាល កាលបើបានធ្វើម្តងហើយ ចេះតែចង់ធ្វើម្តងទៀត និងរីករាយនៅក្នុងអំពើនោះ ដោយ

មិនដឹងខុសដឹងត្រូវ ។ តណ្ហា ឬសេចក្ដីប្រាថ្នា ឬកម្លាំងបើកបររបស់កម្មមនុស្ស មាន ៣ ប្រការ គឺ ៖

*១. កាមតណ្ហា ៖*

គឺសេចក្ដីប្រាថ្នាក្នុងការប្រើប្រាស់ បរិភោគ ប្រមូលយកមកទុកដាក់នូវវត្ថុទាំងឡាយដែលខ្លួនចូលចិត្ត ដែលនាំឱ្យខ្លួនមានសេចក្ដីសុខ ឱ្យបានច្រើនជាទីបំផុត តាមដែលអាចរកមកបាន ។ កម្លាំងនៃតណ្ហានេះ ធ្វើឱ្យមនុស្សប្រព្រឹត្តនូវអំពើផ្សេងៗ ទោះល្អក្ដី ( កុសលកម្ម ) មិនល្អក្ដី ( អកុសលកម្ម ) ។ បច្ចុប្បន្ននេះ យើងអាចហៅមនុស្សប្រភេទនេះ ថាជាអ្នកបរិភោគនិយម ( consumerism ) ឬវត្ថុនិយម ( materialism ) ឬក៏ជាអ្នកប្រមូលផ្ដុំនិយម ( collectism ) ក៏បាន ។

*២. ភវតណ្ហា ៖*

គឺសេចក្ដីប្រាថ្នាក្នុងភព ត្រូវការចង់ក្លាយទៅជានេះ ជានោះ ត្រូវការអំណាច បុណ្យសក្តិ មុខមាត់ ឋានៈ ត្រូវការបង្កើតអ្វីៗ តាមដែលខ្លួនគិតឃើញថាអាចធ្វើឱ្យខ្លួនសប្បាយចិត្ត ត្រេកត្រអាល និងរីករាយ ។ តាមដែលពិនិត្យទៅភវតណ្ហានេះ អាចចែកជាពីរ គឺប្រាថ្នាបង្កើតសំរាប់ខ្លួនឯង និងសម្រាប់អ្នកដទៃតែទាំងពីរនេះសុទ្ធតែបំពេញនូវការត្រេកត្រកាលសម្រាប់តែខ្លួនប៉ុណ្ណោះ ។ ឧទាហរណ៍ ចង់បានអំណាច បុណ្យសក្តិ ឱ្យគេអួតសរសើរ ( សម្រាប់ខ្លួនឯង ) និងចង់បង្កើត អ្វីៗ ដូចជាចង់ឱ្យសង្គមនេះទៅជាស្ថានសួគ៌ ចង់ឱ្យអស់អ្នកក្រចង់ឱ្យមានសង្គមប្រជាធិបតេយ្យ ជាដើម ( craving for existence, craving for father ) ។

*៣. វិភវតណ្ហា ៖*

គឺសេចក្ដីប្រាថ្នាឱ្យបាត់បង់នូវអត្ថិភាពដែលខ្លួនកំពុងមាន និងបាត់បង់នូវអ្វីដែលកំពុងមាន ៖ សេចក្ដីប្រាថ្នាក្នុងការបំផ្លាញដកចេញ ។ ឧទាហរណ៍ សេចក្ដី

ប្រាថ្នាក្នុងការមិនចង់កើតជាមនុស្ស ការចង់សម្លាប់ខ្លួន ចង់ឱ្យគេដកខ្លួនចេញ ធុញទ្រាន់នឹងអត្តិភាពនាបច្ចុប្បន្ន ។ ម្យ៉ាងទៀត គឺប្រាថ្នាចង់បំផ្លាញ ចង់កំទេច ប្រាថ្នាមិនចង់ឱ្យមានប្រជាធិបតេយ្យ ចង់កំទេចខ្មាំងសត្រូវឱ្យអស់ ជាដើម ។

## ផលរបស់តណ្ហា

តណ្ហាជាហេតុនាំមកនូវសេចក្ដីទុក្ខ ។ ក្នុងសង្គមនីមួយៗ មិនមែនមានតែតណ្ហាតែមួយទេ គឺមានរាប់មិនអស់ និងប្រែប្រួលគ្រប់នាទី ។ តណ្ហានេះ រុញទាញយើងឱ្យតស៊ូ ឱ្យប្រឹងប្រែង និងនាំឱ្យមានការប្រកួតប្រជែងរវាងតណ្ហា និងតណ្ហា ។ ការប្រកួតនឹងក្លាយទៅជាទំនាស់ក្នុងសង្គម ។ ឧទាហរណ៍ លោកកោះ ចង់ឱ្យមានប្រជាធិបតេយ្យបែបក្រហម ឯលោកកង់ ចង់ឱ្យមានបែបខ្មៅ ។ ការខុសគ្នានេះនឹងនាំឱ្យមានការតស៊ូផ្សេងគ្នា ហើយទំនាស់ក៏កើតឡើង ។ ស្ត្រី គឺចង់បានរថយន្តមួយគ្រឿង ( កាមតណ្ហា ) ដើម្បីបានសំរេច នាងត្រូវរំអុកស្វាមី ហើយស្វាមីក៏ត្រូវប្រើគ្រប់មធ្យោបាយ ដើម្បីបានលុយយកមកទិញ ។ ការរកលុយដែលខុសច្បាប់អាចនាំឱ្យមានការចោទប្រកាន់ អាចនាំឱ្យកើតគំនុំ ហើយអាចឱ្យមានការតស៊ូដើម្បីកំចាត់ឧបសគ្គចេញ ។ ទាំងអស់នេះ ជាផលរបស់កាមតណ្ហា ឬការចង់បានរបស់យកមកបរិភោគបំពេញទ្វារអារម្មណ៍ទាំងប្រាំរបស់ខ្លួន ។

## ក្រុមហេតុទី ២ . អកុសលមូល

អកុសលមូល គឺឫសរបស់អកុសល ឬប្រភពនៃអំពើអាក្រក់ ប្រភពនៃសេចក្ដីទុក្ខ សង្គ្រាមនៅក្នុងជីវិត និងសង្គម ។ ពាក្យថា ឫស មានន័យថា របស់ដែលមាននាទីចិញ្ចឹម ស្រូបយករសជាតិ ដើម្បីឱ្យអំពើអាក្រក់ សេចក្ដីទុក្ខ សង្គ្រាមស្ថិតស្ថេរ រស់នៅ ។

*១. លោភៈ*

គិតតែពីចង់បាន បានហើយចង់បានទៀត, ចង់បានឱ្យច្រើនជាទីបំផុត ។ កាលបើលោភៈកើតច្រើនឡើងហើយ អ្នកនោះតែងអាចប្រកបនូវកម្មបានគ្រប់បែបយ៉ាង ៖ យោរយៅ សម្លាប់ ព្រៃផ្សៃ ( បាណាតិបាត ) លួច ប្លន់ ( អទិន្នាទាន ), ប្រព្រឹត្តខុសក្នុងកាម ( កាមេសុ មិច្ឆាចារា ) និងនិយាយកុហក ប្រជាភិថុតិ ( មុសាវាទា ) ដើម្បីឱ្យបានទៅដល់គោលដៅដែលខ្លួនប្រាថ្នា ។ ឧទាហរណ៍ ការលោភចង់បានអំណាច នាំឱ្យកើតឡើងនូវការមិនស្មោះត្រង់ បៀតបៀន ស្លូកប៉ាន់ដណ្ដើម និងឈានទៅរកសង្គ្រាមបានគ្រប់ពេលវេលា ។

*២. ទោសៈ*

គឺការមិនប្រទូសរ៉ាយ មានដើមកំណើតមកពីកោធៈ គឺការក្ដៅចិត្ត និងពុះកញ្ជ្រោលក្នុងចិត្ត និងមានឫសមកពីបដិឃៈ គឺការទាស់ចិត្ត និងអគតិ គឺការមិនពេញចិត្ត ។ អ្នកដែលកើតទោសៈហើយ តែងតែរកឱកាសដើម្បីព្យាបាទដល់អ្នកដែលខ្លួនមិនពេញចិត្ត និងដែលខ្លួនចងគំនុំ ។ សេចក្ដីទុក្ខ និងសង្គ្រាម ងាយកើតឡើងណាស់ព្រោះសេចក្ដីទោសៈនេះ ។ ដូច្នេះហើយបានជាខ្មែរយើងនិយាយថា " *គុណ ១០០ សំពៅ ទោសមួយចូលទៅ រលាយគុណអស់* " គឺតែខឹងហើយ តែងបញ្ចេញនូវកម្មអាក្រក់ទាំងឡាយបានគ្រប់បែបយ៉ាង ។ ឧទាហរណ៍ ខឹងគេប្រឆាំងនឹងខ្លួន ក៏រកឱកាសប្រទូស្ត និងចាប់ទោស រំលូសដំណើរជនទាំងនោះឱ្យខាងតែបាន ។ ព្រះពុទ្ធអង្គទ្រង់សំដែងថា ៖ " នត្ថិ ទោសោ សមោ កលិ " គ្មានកំហុសណាស្មើទោសៈទេ ។

*៣. មោហៈ*

គឺការវង្វេងមិនដឹងខុសត្រូវ ល្ងង់ អវិជ្ជា ជាឫសធំជាងគេក្នុងការប្រកបអំពើអាក្រក់ ។ ជនដែលវង្វេង អវិជ្ជា មិនអាចដឹងអ្វីដែលខុស អ្វីដែលត្រូវ ដែលល្អឬដែលមិនគួរទេ អ្វីក៏អាចប្រព្រឹត្តទៅបានដែរ ដើម្បីបំពេញបំណងលោភៈ និង

ទោសៈរបស់ខ្លួន ។ យើងតែងនិយាយថា *មោហ៍បាំង* គឺបាំងមិនឱ្យឃើញការពិតភាពពិតរបស់វត្ថុនោះ ឬអំពើនោះ ។ ក្នុងប្រវត្តិព្រះពុទ្ធសាសនា ព្រះបាទអជាតសត្រូវ ប៉ានសម្លាប់បិតារបស់ខ្លួន ក៏ព្រោះត្រូវមោហ៍បាំងដែរ ។

លោភៈ ទោសៈ និង មោហៈ ទាំង ៣ នេះ ជួយគ្នា សាមគ្គីគ្នាណាស់ គឺបើមួយកើតហើយ មួយទៀតចូលមកបន្ថែមភ្លាម ដែលជាការបន្ថែមទម្ងន់ឱ្យអំពើអាក្រក់កាន់តែមានកិរិតធ្ងន់ឡើង ។ ទាំង ៣ នេះ មិនងាយនឹងគាស់រំលើងវាទេ ព្រោះវាកប់កំបាំងទៅក្នុងដីមើលមិនឃើញ ឬកប់នៅក្នុងសន្តានចិត្តរបស់មនុស្ស ។ មានអ្នកខ្លះ មើលពីក្រៅទៅដូចជាមិនមានអកុសលមូល ឬមានតិចតួចណាស់ តែតាមពិតទៅមានទំហំធំជាងការកាត់ស្មានទៅទៀត ។

## ក្រុមហេតុទី ៣ . អបុញ្ញកិរិយា

ប្រភពដែលនាំឱ្យកើតសេចក្តីទុក្ខ និងដែលអាចនាំទៅរកទំនាស់ក្នុងសង្គម គឺការកើតឡើង និងដុះដាលច្រើនឡើងនូវការឃើញតែប្រយោជន៍ខ្លួន, ការមិនគោរពច្បាប់ដែលមានចែងនៅក្នុងសង្គម, និងការខ្វះខាតអភិវឌ្ឍន៍នៅក្នុងសង្គម ។ ប្រភពទីមួយ ធ្វើឱ្យមនុស្សសម្លឹងមើលតែខ្លួន គ្រួសារខ្លួន បក្សពួកខ្លួន និងគ្រវាត់ចោលនូវសារសំខាន់របស់អ្នកដទៃ ព្រមទាំងបិទភ្នែកចំពោះសេចក្តីទុក្ខដែលជនដទៃកំពុងជួបប្រទះ ។ បញ្ហានេះ មានកើតឡើងទាំងបុគ្គលម្នាក់ៗ និងទាំងជាស្ថាប័នសង្គម រួមទាំងរដ្ឋាភិបាលផងដែរ ។ ផលនៃការឃើញតែប្រយោជន៍ខ្លួន គឺការបែងចែកគ្នាដោយដាច់ស្រឡះ ខ្វះការស្រឡាញ់ ខ្វះមិត្តភាព ដែលធ្វើឱ្យចរន្តសង្គមមានការដាច់ពីគ្នា ។ ព្រះពុទ្ធអង្គទ្រង់មានពុទ្ធដីកាថា " *ទានញ្ច យុទ្ធញ្ច សមានមាហុ* " លោកពោលថា ទាន និងចំបាំងស្មើគ្នា " *ទទំ មិត្តា គន្ថតិ* " អ្នកឱ្យរងែងចងពួកមិត្តបាន ។ ប្រភពទីពីរ ទាក់ទងនឹងរឿងច្បាប់ ដែលបុគ្គលនិមួយៗ ក្នុង

សង្គមគប្បីធ្វើតាម និងគោរពច្បាប់នោះ ព្រមទាំងប្រសិទ្ធភាពនៃច្បាប់នោះ លើសង្គមរបស់ខ្លួន ដែលភាសាច្បាប់ហៅថា The rule of Law ឬនីតិវិធាន ។ ក្នុងសង្គម យើងនិយាយពីច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ ជាដើម ឯក្នុងព្រះពុទ្ធសាសនា លោកនិយាយពីរឿងសីល ៥ ដែលចែកជាបួនប្រការ គឺឥន្រ្ទិយសំវរសីល ការសង្រួមភ្នែក ត្រចៀក មាត់ កាយ និងចិត្ត, បាដិមោក្ខ-សំវរសីល ការកាន់ខ្ជាប់នៅក្នុងសីល ៥ និងការគោរពច្បាប់ដែលមានចែងនៅក្នុងសង្គម, អាជីវបារិសុទ្ធិសីល ការប្រកាន់ខ្ជាប់នៅក្នុងការប្រកបរអាជីវកម្មដែលត្រឹមត្រូវ, និងបច្ចយសន្និស្សិតសីល ការសន្សំសំចៃនៅក្នុងការប្រើប្រាស់ ។ អប្រសិទ្ធិ-ភាពនៃនីតិវិធាន និងនាំទៅរកភាពអនាធិបតេយ្យផ្សេងៗ ដ៏រាប់មិនអស់ និងនាំទៅរកភាពមិនស្មើគ្នានៅក្នុងសង្គម ។ ប្រភពទីបី ទាក់ទងទៅនឹងជីវភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងសង្គមនីមួយៗ ។ ការអភិវឌ្ឍន៍ គឺការផ្លាស់ប្តូរពីការមិនរីកចំរើន ទៅជាការរីកចំរើន ទាំងផ្នែករវត្ថុ និងព្រលឹងវិញ្ញាណ ដោយរក្សានូវនិរន្តរ-ភាពរវាងបុគ្គល សង្គម និងធម្មជាតិ ។ ការអភិវឌ្ឍន៍ដែលខុស មិនមានគោលនយោបាយ ( policy ) មិនមានផែនការ មិនមានការត្រួតពិនិត្យវាយតម្លៃឱ្យបានត្រឹមត្រូវ និងនាំឱ្យសង្គមធ្លាក់ទៅក្នុងភ្លើងសង្គ្រាមបានដោយងាយ ។ ជាឧទាហរណ៍ ការអភិវឌ្ឍន៍ប្រទេសដែលមានគោលនយោបាយមិនសមស្របរបស់យើង ក្នុងរយៈកាលជាង ២០ ឆ្នាំ កន្លងមកនេះ ធ្វើឱ្យប្រទេសជាតិយើងដើរថយក្រោយ និងទទួលនូវសេចក្តីទុក្ខដ៏ច្រើនឥតគណនា ។

## ក្រុមហេតុទី ៤ . អន្តធម៌

ប្រភពនៃសេចក្តីទុក្ខមួយទៀត ដែលនាំទៅរកការកើតឡើងនៃសេចក្តីទុក្ខ និងសង្គ្រាមដែរនោះ គឺការកើតឡើងនៃការយល់ឃើញខុស, ការគិតខុស, ការ

ធ្វើការងារដែលមិនត្រឹមត្រូវ, ការដែលមានសេដ្ឋកិច្ចមិនសមស្រប, ការដែលព្យាយាមមិនត្រឹមត្រូវ, ការតម្កល់ចិត្តមិនត្រឹមត្រូវ, និងការធ្វើសមាធិមិនត្រឹមត្រូវ ។

ការយល់ឃើញ ទស្សនៈ គឺជាចំណុចចម្បង ឬជាកម្លាំងរុញច្រាននៃរំហូរជីវិតរបស់មនុស្សម្នាក់ ឬសង្គមនិមួយៗ ។ មនុស្សយល់យ៉ាងណា គិតយ៉ាងនោះ ។ មានទស្សនៈយ៉ាងណា បញ្ចេញយោបល់យ៉ាងនោះ ។ ការយល់ឃើញជាជំនឿដែលមានឥទ្ធិពលទៅលើដំណើរនៃការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ ។ ឧទាហរណ៍ បើអ្នកនោះជឿថា ការសម្លាប់មិនមែនជាកម្មធំដុំទេ អ្នកនោះអាចសម្លាប់អ្វីៗ ក៏បានដែរ ។ អ្នកដែលមានការយល់ខុស ឬទស្សនៈខុស គឺអ្នកដែលមិនដឹង មិនបានរៀននូវអ្វីដែលជាហេតុជាផល, មិនយល់ថា បញ្ហាទាំងឡាយកើតឡើងពីហេតុ ហើយនឹងអាចរលត់ទៅវិញបាន ក៏ព្រោះការរលត់ទៅនៃហេតុ ( មិនដឹងក្នុងអរិយសច្ចៈ ៤ ) មិនយល់ មិនដឹងថា អ្វីៗ កើតឡើងជាប្រព័ន្ធនៃខ្សែក្រវ៉ាត់បន្តគ្នា គឺបើរបស់នេះកើតឡើងហើយ របស់នោះក៏កើតឡើងដែរ ( មិនដឹងក្នុងបដិច្ចសមុប្បាទ ឬក្នុងឥទប្បច្ចយតា ) និងមិនដឹងថា អ្វីៗ សុទ្ធតែមានការបាក់បែក, វិនាស, ប្រែប្រួលមិនទៀង និងមិនអាចគ្រប់គ្រងបាន ( សាមញ្ញលក្ខណៈ ) ។

អ្វីជាប្រភពនៃការយល់ឃើញខុស ? ការសិក្សាជាប្រភពនៃការយល់ទាំងជាការសិក្សាដែលកើតឡើងតាមរយៈគ្រូ និងសាលារៀនក្តី ទាំងតាមរយៈឥទ្ធិពលនៃបរិដ្ឋានសង្គមក្តី និងទៅតាមអាកាសធាតុក្តី (១) ។ ការសិក្សា ធ្វើឱ្យមនុស្សមានជំនឿ ( សទ្ធា ) ហើយជំនឿនេះ ធ្វើឱ្យយើងកើតឡើងនូវការយល់ យល់ខុស និងយល់ត្រូវ ជាចំណុចដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា ជាប្រភពដែលនាំឱ្យ

(១) ជាឧទាហរ៍ គឺរឿងអង្គុលីមាល៍ ដែលពីដើមជាយុវជនល្អ តែទទួលការអប់រំពីគ្រូដែលអាក្រក់ ក៏ក្លាយទៅជាមហាចោរ ។

មនុស្សគិត និយាយ និងធ្វើ [(២)] ។

ការយល់ខុស នាំឱ្យមនុស្សគិតខុស ។ គិតតែពីស្វែងរកការសប្បាយឱ្យខ្លួន គិតតែបំពេញចំណង់តាមប្រសាទទាំង ៥ ( កាមសង្កប្បៈ ) គិតតែពីរឿងខឹង និងចងគំនុំដល់អ្នកដែលជំទាស់ មិនឱ្យខ្លួនបានសម្រេចនូវបំណង ( ព្យាបាទសង្កប្បៈ ) និងគិតបៀតបៀនដោយគំនិតហឹង្សា គំនិតឃោរឃៅ អមនុស្សធម៌ ដល់អ្នកដែលរារាំងផលប្រយោជន៍ខ្លួន និងគិតនូវវិធីអាក្រក់ទាំងឡាយ ដើម្បីឱ្យបំណងខ្លួនបានសម្រេច ដោយមិនគិតថា អ្នកណាត្រូវទទួលនូវសេចក្តីទុក្ខឡើយ ( វិហឹង្សាសង្កប្បៈ ) [(៣)] ។

គិតខុស នាំឱ្យនិយាយខុស និយាយមិនត្រឹមត្រូវ ( មិច្ឆាវាចា ) និយាយកុហក, និយាយបំបែកបំបាក់, និយាយអាក្រក់, និយាយយកជាការមិនបាន, ដែលជាកត្តានាំទៅរកសេចក្តីទុក្ខ ទាំងចំពោះខ្លួន និងអ្នកដទៃ ដូចពាក្យខ្មែរពោលថា " កុំយកប្រេងសាំងទៅបន្ថែមលើភ្លើងកំពុងឆេះ " ។ នាបច្ចុប្បន្ននេះ សិល្បៈ ការនិយាយ ការឃោសនា បានក្លាយទៅជាមុខវិជ្ជាមួយដ៏សំខាន់ សំរាប់អ្នកស្វែងរកផលប្រយោជន៍ទាំងឡាយ ។ ជាឧទាហរណ៍សំខាន់ គឺការឃោសនា ផ្សព្វផ្សាយតាម

---

(២) ម្នាលភិក្ខុទាំងឡាយ ក្នុងចំណោមអង្គទាំងឡាយរបស់មគ្គ ការយល់ឃើញត្រូវជាប្រធាននាំមុខ ។ ហេតុអ្វី ? ការមានសម្មាទិដ្ឋិ ធ្វើឱ្យយើងស្គាល់ ថាអ្វីជាការយល់មិនត្រឹមត្រូវ ( មិច្ឆាទិដ្ឋិ ) ថាជាការយល់មិនត្រឹមត្រូវ, ហើយយល់ត្រឹមត្រូវ ថាជាការយល់ត្រឹមត្រូវ, យើងដឹងថា ការគិតនេះ ជាការគិតខុស ការគិតនេះ ជាការគិតត្រូវ, យើងដឹងថា សំដីនេះជាសំដីត្រឹមត្រូវ ឯសំដីនោះ ជាសំដីមិនត្រឹមត្រូវ , យើងដឹងថា អំពើនោះ ជាអំពើត្រឹមត្រូវ ឯអំពើនោះ ជាអំពើមិនត្រឹមត្រូវ ។ (៣) រឿងចៅចាក់ស្មុក ក្នុងព្រេងនិទានខ្មែរ ជារឿងដែលបង្ហាញនូវការគិតខុសទាំង ៣ ប្រការ ដោយគ្រប់គ្រាន់ ។ លទ្ធផល គឺទំនាស់ និងវិបត្តិដែលរយើងរយោងគ្នាដូចសម្លូកពីស ។

ទូរទស្សន៍ និងវិទ្យុ ដើម្បីទាក់ទាញទឹកចិត្តអ្នកស្តាប់ និងទស្សនិកជន ។

| | |
|---|---|
| និយាយកុហក | ដើម្បីផលប្រយោជន៍ |
| និយាយបំបែកបំបាក់ | ដើម្បីគំនុំសងសឹក |
| និយាយអាក្រក់ | ដើម្បីបៀតបៀន បំផ្លាញ |
| និយាយយកជាការមិនបាន | ដើម្បីបន្លប់ការពិត |

ការយល់ខុស នាំឱ្យធ្វើអំពើដែលមិនត្រឹមត្រូវ ( មិច្ឆាកម្មន្តៈ ) ដោយខ្លួនឯងផង អ្នកដទៃក៏មិនអាចធ្វើនូវអំពើដែលត្រឹមត្រូវផងដែរ ។ អំពើហឹង្សា, ចោរកម្ម, ពេស្យាកម្ម, ជាអំពើដែលកើតឡើង ដើម្បីតបស្នងទៅនឹងចិត្តដែលគិតខុស ។ ការយល់ខុសកន្លងមករបស់ភាគីជម្លោះក្នុងប្រទេសយើង ធ្វើឱ្យកើតឡើងនូវវិនាសកម្មគ្រប់បែបយ៉ាង ទាំងអាយុជីវិត ទ្រព្យសម្បត្តិ និងសេចក្តីសុខក្នុងក្រុមគ្រួសារ ។ ហើយឥឡូវនេះ យើងក៏មិនទាន់ឆ្លងរួចផុតពីអំណាចខ្មៅនៃចិត្តដែលយល់ខុសដែរ : អំពើហឹង្សាខាងពាក្យសម្តី ការធ្វើទារុណកម្មខាងរាងកាយ និងការបាត់បង់ជីវិតក៏នៅតែមាន ការមិនស្មោះត្រង់ក្នុងការងារ ដោយការលួចទ្រព្យសម្បត្តិជាតិ និងទ្រព្យធម្មជាតិ និងជាពិសេស គឺការកើតឡើងដ៏គួរឱ្យខ្លាចនៃអំពើពេស្យាចារ រួមទាំងការចាប់កុមារ និងនារីលក់ដូរដូចសត្វធាតុ ជាដើម ។ ទាំងអស់នេះគឺសុទ្ធតែជាអំពើដែលខុស និងនាំទៅរកសង្គ្រាមជាពិតប្រាកដ ។

ការយល់ឃើញខុស ជាការនាំទៅរកការធ្វើអាជីវកម្មខុស ( មិច្ឆាអាជីវៈ ) ជំនួញអាវុធគ្រឿងប្រហារ, ជំនួញមនុស្ស, ជំនួញសត្វ, ជំនួញគ្រឿងញៀនស្រវឹង, ជំនួញថ្នាំបំពុល ។

ការយល់ឃើញខុស នាំទៅរកការព្យាយាមខ្នះខ្នែង និងសកម្មភាពដែលខុស : ព្យាយាមមិនឱ្យអំពើល្អកើតឡើង ; អំពើល្អដែលកើតមានហើយ ព្យាយាមកំចាត់អំពើល្អនោះឱ្យសាបសូន្យទៅវិញ, អំពើអាក្រក់ដែលមិនទាន់កើតមាន ក៏នាំ

ឱ្យកើតមានឡើង, បង្កើនរក្សាអំពើអាក្រក់ដែលមានបន្តិចបន្តួចនោះ ឱ្យរីតតែដុះដាលឡើង ។

ការយល់ឃើញខុស តែងនាំឱ្យមនុស្សនោះនឹកឃើញតែពីផ្លូវខុសជានិច្ច មានសេចក្តីប្រមាទក្នុងអំពើល្អ គិតឃើញតែផ្លូវអាក្រក់ និងផ្លូវដែលបៀតបៀន ។

ការយល់ឃើញខុស នាំទៅរកការតម្កល់ចិត្តខុស វង្វេងក្នុងផ្លូវលោភៈ ទោសៈ និងមោហៈ គ្មានថ្ងៃបញ្ចប់ឡើយ ។

អស់លោកអ្នកស្តាប់ជាទីមេត្រី ! ប្រភពនៃបញ្ហាទាំង ៤ ប្រភេទនេះ គឺជាទស្សនៈពុទ្ធសាសនា ដែលអាចក្តីដកស្រង់ចេញពីធម្មៈរបស់ព្រះពុទ្ធអង្គ និងព្យាយាមអធិប្បាយដោយសង្ខេប ។ យើងឃើញហើយថា សេចក្តីទុក្ខ សង្គ្រាម ការបែកបាក់គ្នា មិនមែនកើតឡើង ព្រោះអាស្រ័យតែហេតុម្យ៉ាង១ នោះទេ ដូចបានជំរាបហើយថា វាជាផលនៃការកើតបន្តគ្នារយឹងរយោងដូចសម្លកំពីស ។ ដូច្នេះ ការដោះស្រាយបញ្ហា ក៏មិនមែនត្រឹមតែចង្អុល ហើយដោះរួចភ្លាម១ នោះដែរ ជាពិសេសគឺត្រូវការពារតាំងចិត្តដ៏មុតមាំ ក្នុងដំណោះស្រាយ មានសេចក្តីព្យាយាមមិនលើកលែង , មានការពិចារណាហេតុផល តាមលក្ខណៈអរិយសច្ចៈ ឬវិទ្យាសាស្ត្រ មួយណាដោះមុន មួយណាដោះក្រោយ មួយណាដោះដំណាលគ្នា ត្រឹមក៏រិតប៉ុណ្ណា ដែលទាក់ទងយ៉ាងសំខាន់ទៅនឹងគោលធមិសប្បុរិសធម៌ ៧ យ៉ាង បញ្ហាដែលកំពុងតែកើតក្តៅ១ ក្នុងស្រុកយើងនេះគឺ :

១) បញ្ហាក្រីក្រ ( អទិន្នាទាន )

២) បញ្ហាពេស្យាចារ ( កាមេសុ មិច្ឆាចារ )

៣) បញ្ហាអបាយមុខ ( សុរាមេរយមជ្ជបមាទដ្ឋាន )

៤) បញ្ហាមានមាត់ មានកនឹងគ្នា ( មុសាវាទា )

៥) បញ្ហាមរណកម្ម ( បាណាតិបាតា )

ព្រោះតែក្រ ទើបបានជាប៉ានលួច ប៉ានកេងប្រវ័ញ្ច ស៊ីសំណូកសូក ប៉ាន់ ; ព្រោះតែក្រ ទើបប៉ានលក់កូន លក់ចៅ មិនថាស្រី មិនថាប្រុស ; ព្រោះតែក្រ ទើបលង់លក់ក្នុងអបាយមុខ ស្រី ស្រា ល្បែងកាស៊ីណូគ្រប់បែបយ៉ាង ; ព្រោះតែក្រ ទើបប៉ានកុហក ប៉ានជេរប្រទេចគ្នា ; ហើយព្រោះតែក្រ ទើបបានជាប៉ានសម្លាប់គ្នា ធ្វើទារុណកម្មគ្នាទៅវិញទៅមកបាន ។

* * *

*ម្នាលអាតុលៈ ! រឿងនេះ ធ្លាប់មានជាយូរលង់មកហើយ*
*ពុំមែនជារឿងទើបកើតមានបច្ចុប្បន្ននេះទេ :*
*អ្នកអង្គុយស្ងៀមមិននិយាយស្តីអ្វីសោះ ក៏ត្រូវគេរិះគន់ ។*
*អ្នកនិយាយច្រើន ក៏ត្រូវគេរិះគន់ ។*
*អ្នកនិយាយតិច ក៏ត្រូវគេរិះគន់ ។*
*នៅក្នុងលោកនេះ គ្មាននរណាមួយចៀសផុតពីពាក្យរិះគន់បានទេ ។*

ធម្មបទ - គាថាទី ២២៧ - ឈ.អ.

# ពុទ្ធឱវាទ
## ( SACRED APHORISM )

សេចក្តីស្អប់ មិនអាចបញ្ចប់ដោយសេចក្តីស្អប់បានជាដាច់ខាត, មានតែសេចក្តីស្រឡាញ់ទេ ដែលអាចបញ្ចប់សេចក្តីស្អប់បាន ។ នេះជាច្បាប់ពីបុរាណ ។

ដំបូន្មានរបស់ព្រះពុទ្ធដែលហៅថា « ពុទ្ធសាសនា ឬពុទ្ធវចនៈ ឬក៏ពុទ្ធ-ឱវាទ » មានច្រើនណាស់, ក្នុងគម្ពីរពោលថាមានដល់ទៅ ៨៤.០០០ ព្រះធម្មក្ខន្ធ, តែបើនិយាយចោះយកតែគោលសំខាន់ៗ មានត្រឹម ៣ ប្រការគឺ :

- កុំប្រព្រឹត្តអំពើបាប,
- ចូរសាបព្រោះបណ្តុះអំពើល្អ,
- ចូរធ្វើចិត្តឱ្យបានបរិសុទ្ធ ។

ពុទ្ធឱវាទទាំងបីប្រការនេះ ប្រដៅសង្កត់ទៅលើសច្ចធម៌ ចង់ឱ្យអ្នកសិក្សាដឹងច្បាស់ ឃើញជាក់ តាមហេតុផលនៃសភាពពិតទាំងឡាយ និងប្រដៅក្នុងគោលសំខាន់ សំរាប់ធ្វើជីវភាពឱ្យប្រព្រឹត្តទៅបានស្រួល ដោយឱ្យចេះដឹងដោយខ្លួនឯង ឱ្យចេះសាងខ្លួនដោយខ្លួនឯង ហើយនិងប្រដៅឱ្យចេះស្គាល់អធ្យាស្រ័យអ្នកដទៃ ធ្វើខ្លួនឱ្យចូលនឹងអ្នកដទៃបានស្រួល ជាធម៌ដែលមនុស្សគ្រប់វ័យ គ្រប់ភេទ ក្នុងសង្គមនាំយកទៅបដិបត្តិបានគ្រប់ពេលវេលា ។

ជាការពិត, ព្រះពុទ្ធសាសនា ប្រដៅមនុស្សឱ្យស្គាល់ហេតុ ស្គាល់ផល, ស្គាល់ប្រមាណ, ស្គាល់កាលៈទេសៈ, ស្គាល់បរិស័ទ, ស្គាល់បុគ្គល, នេះជាសេចក្តីចំរើន, នេះជាសេចក្តីវិនាស, នេះគួរធ្វើ, នេះមិនគួរធ្វើ ដូច្នេះជាដើម ។ ក្នុងគម្ពីរធម្មបទ មានពុទ្ធគាថា ជាង ៣០០ ដែលព្រះអង្គទ្រង់សំដែងទាក់ទងនឹងបុគ្គល ឬសង្គមមនុស្ស ។ សូមលោកអ្នកអានសិក្សា ជាមួយនឹងការពិចារណា ដូចតទៅ :

• វាបានជេរអញ, វាបានចំអកឡកឡឺយឱ្យអញ, វាបានវាយអញ ។ ដរាបណា បុគ្គលណានៅតែរក្សាគំនិតទាំងនេះ កំហឹងរបស់គេនឹងមិនចប់ទេ ។

ដរាបណា គំនុំនៅតែមានក្នុងចិត្ត កំហឹងក៏នៅតែមានដែរ ។ ប៉ុន្តែ បើកាលណា គំនុំវិនាសអស់ហើយ កំហឹងក៏វិនាសអស់ទៅដែរ ។

ផ្ទះដែលដំបូលធ្វើមិនល្អ ផ្ទះធ្លាយដោយអន្លើ ទឹកភ្លៀងនឹងលេចចូលទៅក្នុងផ្ទះ ។ ដូចគ្នានេះដែរ ចិត្តដែលបង្ហាត់មិនបានល្អ ហើយដែលមិនអាចត្រួតត្រាបាននោះ គំនិតលោភលន់នឹងចូលទៅញាំញីបាន ។

ការនៅទំនេរស្ងៀម ជាផ្លូវទៅកាន់សេចក្ដីស្លាប់ ។ ការឧស្សាហ៍វៀសវៃ ជាផ្លូវសំរាប់ជីវិតរស់នៅ ។ បុគ្គលឆ្កួតលេលា នៅទំនេរស្ងៀម ។ ចំណែកបុគ្គលជាបណ្ឌិត មានការឧស្សាហ៍វៀសវៃ ។

អ្នកធ្វើព្រួញ ខំធ្វើព្រួញឱ្យបានត្រង់ ។ ដូចគ្នានេះ បុគ្គលជាបណ្ឌិត ខំរក្សាចិត្តរបស់គេឱ្យបានត្រឹមត្រង់ ។

ចិត្តសៅហ្មង កំរើកជានិច្ច លោតពីទីមួយទៅទីមួយ ពិបាកនឹងគ្រប់គ្រងណាស់ ។ ផ្ទុយទៅវិញ ចិត្តស្ងប់ មានភាពសុខស្ងប់ ។ ដូច្នេះ ការរក្សាចិត្តឱ្យបាននៅស្ងប់ ជាគតិបណ្ឌិត ។

ពុំមែនសត្រូវទេ គឺពិតជាចិត្តរបស់ខ្លួនផ្ទាល់តែម្ដង ដែលដឹកនាំទៅកាន់ផ្លូវអាក្រក់ ។

បុគ្គលដែលចេះការពារចិត្តរបស់ខ្លួន ទប់ទល់នឹងសេចក្ដីលោភលន់ សេចក្ដីខឹងក្រោធ អំពើអាក្រក់ នឹងបានប្រកបសេចក្ដីស្ងប់ពិតប្រាកដមិនចេះចប់ ។

• មានវាចាល្អ តែមិនធ្វើតាម អាចប្រៀបបានទៅនឹងផ្កាមានពណ៌ស្រស់ល្អ តែឥតក្លិនក្រអូប ។

គន្ធពិដោរនៃផ្កា មិនក្រអូបបញ្ច្រាសខ្យល់ទេ ។ តែកេរ្តិ៍ឈ្មោះល្អរបស់មនុស្ស ទើបផ្សព្វផ្សាយគ្រប់ទិសទីបញ្ច្រាសខ្យល់បាន ។

រាត្រីកាល ហាក់ដូចជាយូរណាស់ ចំពោះអ្នកដេកមិនលក់, ផ្លូវដើរ ហាក់ដូចជាឆ្ងាយណាស់ ចំពោះអ្នកធ្វើដំណើរដោយលំបាក ។ ដូចគ្នានេះ ពេលវេលានៃការយល់ច្រឡំនឹងទុក្ខព្រួយហាក់ដូចជាវែងឆ្ងាយណាស់ ចំពោះអ្នកមិនយល់សិក្ខាបទពិតប្រាកដ ។

កាលណាគេធ្វើដំណើរ គេគួរតែដើរជាមួយនឹងមិត្តម្នាក់ ដែលមានសតិប្រាជ្ញាស្មើនឹងគេ ឬខ្ពស់ជាងគេ ។ ប៉ុន្តែ គេគួរដើរម្នាក់ឯង ល្អជាជាងដើរជាមួយមនុស្សឆ្កួតលេលា ។

គេខ្លាចសត្វសាហាវ តែគេគួរខ្លាចមិត្តអាក្រក់ច្រើនជាងសត្វសាហាវ ។ សត្វសាហាវបណ្ដាលឱ្យមានរបួសត្រឹមតែរូបកាយ តែមិត្តអាក្រក់បណ្ដាលឱ្យមានរបួសដល់បេះដូង ។

ដរាបណាគេមិនអាចគ្រប់គ្រងចិត្តរបស់គេបាន គេមិនអាចបោះបង់គំនិតថា « នេះជាកូនរបស់អញ » ឬ « នេះជាទ្រព្យកំណប់របស់អញ » បានទេ ។ បុគ្គលល្ងង់ខ្លៅ រងទុក្ខនឹងគំនិតរបៀបនេះ ។

ល្ងង់ហើយដឹងខ្លួនថាល្ងង់ វាប្រសើរជាជាងល្ងង់ ហើយនឹកស្មានថាខ្លួនជាបណ្ឌិត ។

ស្លាបព្រាមិនអាចដឹងរសជាតិនៃម្ហូប ដែលដួសឡើងនុំះទេ ។ ដូចគ្នានេះ បុគ្គលល្ងង់ ( ឆ្កួត ) មិនអាចយល់គតិបណ្ឌិតរបស់អ្នកប្រាជ្ញបណ្ឌិតបានទេ ទោះបីបុគ្គលនោះរស់នៅជាមួយអ្នកប្រាជ្ញបណ្ឌិតនោះក៏ដោយ ។

តាមធម្មតា ដូចជាទឹកដោះស្រស់ ដែលមិនងាយនឹងកកកើងភ្លាម១ អំពើអាក្រក់មិនផ្ដល់ហេតុផលភ្លាម១ទេ ។ អំពើអាក្រក់ ដូចជារងើកភ្លើងដែលកប់ក្នុង

ផេះ ហើយដែលនៅទីបំផុតឆេះឆ្លោឡើង ។

ការសង្វាតរកប្រយោជន៍ឯកសិទ្ធិ រកឋានន្តរសក្តិ រកកម្រៃ រកកិត្តិយស ជាការឆ្កួត ។ ការប្រាថ្នាទៅលើវត្ថុទាំងនេះ មិនអាចនាំមកនូវសុភមង្គលបានទេ ផ្ទុយទៅវិញ វារឹតតែបន្ថែមសេចក្តីទុក្ខព្រួយ ។

មិត្តល្អដែលបង្ហាញសេចក្តីយល់ច្រឡំ និងកំហុសរបស់អ្នក ដល់អ្នកដែលស្តីប្រដៅអ្នកអំពីអំពើអាក្រក់របស់អ្នក គួរជាទីគោរព បីដូចជាមិត្តនោះបានប្រាប់ទីលាក់កំណប់មួយដល់អ្នក ។

● បុគ្គលដែលសប្បាយរីករាយនឹងទទួលការទូន្មានល្អ អាចដេកលក់ដោយសុខស្ងប់ ព្រោះចិត្តរបស់គេត្រូវបានលាងស្អាត ។

ជាងធ្វើផ្ទះ ខំធ្វើធ្នឹមផ្ទះឱ្យបានត្រង់ល្អ ។ អ្នកធ្វើព្រួញ ខំធ្វើព្រួញឱ្យបានត្រឹមត្រូវតាមកំហិត ។ អ្នកជីកបន្លាយបង្ហូរទឹកបញ្ចូលស្រែ ខំធ្វើយ៉ាងណាឱ្យទឹកបានហូរស្រួល ។ ដូចគ្នានេះ បុគ្គលជាបណ្ឌិត ខំគ្រប់គ្រងចិត្តរបស់គេឱ្យមានដំណើរស្រួល ឱ្យមានភាពត្រឹមត្រង់ ។

ដុំថ្មធំ មិនអាចរញ្ជួយដោយសារខ្យល់ទេ ។ ដូចគ្នានេះ ចិត្តរបស់បុគ្គលជាបណ្ឌិត មិនអាចរញ្ជួយដោយសារកិត្តិយស ឬការប្រមាថមើលងាយទេ ។

ជិនះខ្លួនឯងបាន ជាមហាជោគជ័យមួយធំជាងឈ្នះសត្រូវមួយពាន់នាក់ក្នុងលានប្រយុទ្ធទៅទៀត ។

រស់តែមួយថ្ងៃ ហើយបានស្តាប់ឮសេចក្តីប្រៀនប្រដៅវិសុទ្ធល្អ ប្រសើរជាជាងរស់មួយរយឆ្នាំ ហើយពុំបានស្តាប់ឮសេចក្តីទូន្មានល្អវិសុទ្ធ ។

បើស្រឡាញ់ខ្លួន ពោងតែឃ្លាំមើលវាជានិច្ច កុំឱ្យវាធ្លាក់ទៅក្នុងចំណង់អាក្រក់ ។

លោកនេះជាភ្លើងឆេះជានិច្ច ឆេះដោយភ្លើងលោភលន់ ភ្លើងកំហឹង ភ្លើងល្ងង់ខ្លៅ ។ តោងតែរត់គេចពីគ្រោះថ្នាក់ទាំងនេះជាបន្ទាន់ ។

លោកនេះដូចជាពពុះទឹក ដូចជាសរសៃសំបុកពីងពាង ដូចជាក្អែលនៃក្អមកខ្វក់ ។ បុគ្គលរាល់រូប តោងតែរក្សាការពារភាពបរិសុទ្ធនៃចិត្តរបស់ខ្លួនជានិច្ច ។

• ចូរចៀសវាងអំពើអាក្រក់ទាំងអស់ ចូរស្វែងរកអំពើល្អ ចូររក្សាចិត្តឱ្យបានបរិសុទ្ធ ។ ទាំងនេះហើយ ជាសេចក្ដីទូន្មានរបស់ព្រះពុទ្ធ ។

សេចក្ដីអំណត់ ជាវិន័យមួយ ក្នុងចំណោមវិន័យដែលពិបាកជាងគេបង្អស់ ។ ប៉ុន្តែ មានតែអ្នកមានអំណត់ទេ ដែលត្រូវបានទទួលជោគជ័យជាសំរេច ។

កាលណាគេកើតមានគំនុំ គេត្រូវតែកំចាត់គំនុំនោះចោល ។ កាលណាគេមានទុក្ខព្រួយ គេត្រូវតែកំចាត់ទុក្ខព្រួយនោះចោល ។ កាលណាគេមានចិត្តបាក់ទៅលើសេចក្ដីលោភលន់ គេត្រូវតែកំចាត់សេចក្ដីលោភលន់នោះចោល ។ ដើម្បីរស់នៅក្នុងជីវភាពប្រកបដោយសប្បុរសធម៌ ត្រូវតែមើលមកខ្លួនឯងថា គ្មានអ្វីទាំងអស់ដែលជាកម្មសិទ្ធិរបស់ខ្លួន ។

មានសុខភាពល្អ ជាអត្ថប្រយោជន៍ធំមួយ ។ សប្បាយរីករាយនឹងឃើញគេឯទៀតមានបាន វាប្រសើរជាជាងមានសម្បត្តិស្ដុកស្ដម្ភផ្ទាល់ខ្លួនឯង ។ ធ្វើឱ្យអ្នកឯទៀតមានការទុកចិត្ត ជាសញ្ញាមិត្តភាពពិតប្រាកដ ។ បានសម្រេចពន្លឺព្រាស់ដឹង(*) ជាសុភមង្គលខ្ពស់បំផុត ។

កាលណា គេបានវៀរចាកអំពើអាក្រក់ កាលណាគេបានប្រកបអារម្មណ៍ស្ងប់ កាលណាគេបានមានចិត្តរីករាយនឹងទទួលយកដំបូន្មានល្អ គេនឹងបានចាកផុតពីសេចក្ដីបារម្ភខ្លាច ។

(*) ពន្លឺព្រាស់ដឹង : អស់លោភៈ, អស់ទោសៈ, អស់មោហៈ ។

ចូរកុំជំពាក់ចិត្តនឹងអ្វីៗ ដែលអ្នកចូលចិត្ត ចូរកុំរុញច្រានចោលអ្វីៗ ដែលអ្នកមិនចូលចិត្ត ។ សេចក្ដីព្រួយ សេចក្ដីខ្លាច និងសេចក្ដីជាប់ជំពាក់ទាំងនេះ មកអំពីការចូលចិត្ត និងការមិនចូលចិត្តនេះឯង ។

• ច្រេះកើតចេញមកអំពីដែក ហើយស៊ីទម្លុះដែក ។ ដូចគ្នានេះ អំពើអាក្រក់កើតចេញអំពីចិត្ត ហើយស៊ីទម្លុះចិត្ត ។

សៀវភៅដែលគេមិនបើកមើលជារឿយៗ នាប់ជាប់ធូលី ។ ផ្ទះដែលមិនជួសជុលឱ្យទាន់ពេលវេលា មុខជានឹងទ្រុឌទ្រោមបាក់បែក ។ ដូចគ្នានេះ បុគ្គលដែលរស់នៅក្នុងភាពទំនេរខ្ជិល នឹងទៅជាអសោចមួយរំពេច ។

អំពើអាសអាភាស នាំឱ្យខូចកិត្តិនាមនារី ។ ការកំណាញ់ស្វិត នាំឱ្យខូចទាយជ្ជទាន ។ ដូចគ្នានេះ អំពើអាក្រក់នាំឱ្យខូចជីវិតបច្ចុប្បន្ន និងជីវិតអនាគត ។

មន្ទិលសៅហ្មងដែលគួរខ្លាចជាងគេបង្អស់ គឺមន្ទិលសៅហ្មងនៃសេចក្ដីល្ងង់ខ្លៅ ។ គេមិនអាចសង្ឃឹមនឹងធ្វើខ្លួន ហើយនិងចិត្តរបស់គេ ឱ្យបានបរិសុទ្ធទេដរាបណាគេមិនកំចាត់សេចក្ដីល្ងង់ខ្លៅចេញ ។

ការរអិលធ្លាក់ក្នុងអំពើឥតអៀនខ្មាស ការឡើងចិត្តគឃ្លើន ការឡើងឡឹតក្រអឺតក្រអោងដូចមាន់គក ការប្រព្រឹត្តអាក្រក់ទៅលើអ្នកដទៃ ដោយគ្មានចិត្តចេះនឹកស្ដាយក្រោយ ជាការងាយស្រួលណាស់ ។ ប៉ុន្តែ ការធ្វើឱ្យខ្លួនសុភាពរាបសា ការចេះគោរព និងផ្ដល់កិត្តិយសដល់អ្នកដទៃ ការមិនជាប់ជំពាក់ចិត្ត ការរក្សាគំនិតនិងអំពើរបស់ខ្លួនឱ្យបានស្អាតបរិសុទ្ធ ការធ្វើឱ្យខ្លួនបានជាបណ្ឌិត ជាការលំបាក ។

ការមើលឃើញកំហុសអ្នកដទៃ ជាការងាយស្រួល ប៉ុន្តែការមើលឃើញកំហុសរបស់ខ្លួនឯងផ្ទាល់ ជាការពិបាក ។ គេប្រកាសកំហុសអ្នកដទៃយ៉ាងឮរំពងតែគេលាក់កំហុសរបស់គេផ្ទាល់ ដូចជាអ្នកលេងបៀលាក់សន្លឹកបៀ ។

មេឃាមិនទុកដាននៃសត្វបក្សាបក្សី ដាននៃផ្សែង ឬដាននៃខ្យល់ព្យុះទេ ។ សេចក្ដីទុក្ខនានាអាក្រក់ មិនដឹកនាំទៅកាន់ពន្លឺត្រាស់ដឹងទេ ។ នៅក្នុងលោកនេះគ្មានអ្វីដែលមិនប្រែប្រួលទេ ។ ប៉ុន្តែ អ្នកបានសម្រេចពន្លឺត្រាស់ដឹង នឹងបានស្ថិតនៅក្នុងសេចក្ដីសុខស្ងប់ ឥតប្រែប្រួលរហូត ។

• ដូចជាឆ្មាំដែលយាមរក្សាទ្វារវាំងប្រាសាទ បុគ្គលរាល់រូបត្រូវតែរក្សាការពារចិត្តរបស់ខ្លួន ទប់ទល់នឹងសត្រូវទាំងខាងក្រៅទាំងខាងក្នុង ហើយកុំប្រហែសវាឱ្យសោះ ។

យើងជាម្ចាស់លើខ្លួនយើង យើងទីពឹងលើខ្លួនយើង ។ ហេតុនេះ យើងតោងតែគ្រប់គ្រងខ្លួនយើងផ្ទាល់ ។

ជំហានទីមួយក្នុងការរំដោះវិញ្ញាណឱ្យរួចផុតពីច្រវាក់ និងចំណងលោកិយគឺត្រូវតែគ្រប់គ្រងចិត្តរបស់ខ្លួន ត្រូវតែចៀសវាងការនិយាយច្រើនឥតប្រយោជន៍ត្រូវតែមានស្មារតីប្រុងប្រយ័ត្ន ។

ព្រះអាទិត្យបំភ្លឺលោកនៅពេលថ្ងៃ ព្រះចន្ទធ្វើឱ្យរាត្រីកាលមានសម្រស់អាវក្រោះធ្វើឱ្យទាហានរឹតតែបានឡើងខែង ។ ដូចគ្នានេះ ការចម្រើនភាវនាដោយស្ងប់ ជាកិច្ចសំគាល់អ្នកដែលស្វែងរកពន្លឺត្រាស់ដឹង ។

បើកាលណាគេមិនអាចរក្សាការពារវិញ្ញាណទាំងប្រាំរបស់គេ ពោលគឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត និងរូបកាយបានទេនុ៎ះ គេមិនអាចព្យាយាមដើម្បីសំរេចពន្លឺត្រាស់ដឹងបានទេ ។ បុគ្គលណា ដែលចេះរក្សាការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំ ហើយចេះគ្រប់គ្រងចិត្ត បុគ្គលនោះអាចព្យាយាមប្រកបដោយជោគជ័យដើម្បីសំរេចពន្លឺត្រាស់ដឹង ។

• បើកាលណាគេលុះក្នុងអំណាចនៃការចូលចិត្ត និងការមិនចូលចិត្ត គេមិនអាចយល់ឱ្យបានត្រឹមត្រូវអំពីន័យនៃទេសៈកាលៈទេ ហើយដោយហេតុនេះ គេ តែងតែខំដណ្ដើមយកឈ្នះចាញ់ ។ បើកាលណាគេចាកផុតពីការជំពាក់ចិត្ត គេនឹងយល់យ៉ាងត្រឹមត្រូវអំពីទេសៈកាលៈ ហើយអាស្រ័យហេតុនេះ គេនឹងឃើញថា វត្ថុទាំងអស់តែងតែប្រែប្រួល ។

សុភមង្គលតាមក្រោយទុក្ខព្រួយ ទុក្ខព្រួយតាមក្រោយសុភមង្គល ។ ប៉ុន្តែបើកាលណាគេមិនធ្វើការវែកញែករវាងសុភមង្គលនិងទុក្ខព្រួយ រវាងល្អនិងអាក្រក់ ទុំៈ គេមិនអាចបានស្គាល់នូវសុខសិរីពិតប្រាកដ ។

ព្រួយបារម្ភនឹងអនាគត ហើយស្ដាយស្រណោះនឹងអតីត ប្រដូចបានទៅនឹងដើមប្របុសដែលគេកាត់ហាលស្ងួត ។

សេចក្ដីជាអាថ៌ ដើម្បីសុខស្ងួស្ដីនៃរូបកាយនិងវិញ្ញាណ គឺមិនសោកស្រ-ណោះនឹងអតីត មិនព្រួយបារម្ភនឹងអនាគត មិនរឹករវនឹងរឿងដែលនឹងត្រូវមកដល់ផ្ទុយទៅវិញ គឺចេះរស់នៅក្នុងភាពបច្ចុប្បន្ន ប្រកបដោយគតិបណ្ឌិត ក្នុងភាពជាធម្មតា ។

ចូរកុំគិតទាក់ទាមនឹងអតីត ចូរកុំរង់ចាំអនាគត កិច្ចតែមួយគត់គឺ ត្រូវចេះរស់នៅប្រកបដោយចិត្តនឹងនក្នុងបច្ចុប្បន្នកាលនេះ ។

ការបំពេញកិច្ចបច្ចុប្បន្នឱ្យបានល្អ ជាការប្រសើរមួយ ចូរកុំនឹកខំចៀសវាងកិច្ចបច្ចុប្បន្ន ឬទុកវាទៅថ្ងៃស្អែក ។ បើអ្នកបំពេញកិច្ចបច្ចុប្បន្នឱ្យបានសមរម្យល្អបាន គឺអ្នករស់នៅដោយសប្បាយរីករាយបានមួយថ្ងៃ ។

គ្មានអ្នកបំភ្លឺណាប្រសើរជាងគតិធម៌ទេ គ្មានមិត្តណាប្រសើរជាងជំនឿជ្រះថ្លាទេ ។ បុគ្គលទាំងឡាយតោងតែខំរត់គេចចេញពីអន្ធពាលនៃសេចក្ដីល្ងង់ខ្លៅ និងទុក្ខព្រួយ ហើយខំស្វែងរកពន្លឺត្រាស់ដឹង ។

កាលណាគេគ្រប់គ្រងកាយ និងចិត្តរបស់គេបាន នេះជាសញ្ញានៃអំពើប្រកបដោយគុណធម៌ នេះជាករណីយកិច្ចខ្ពង់ខ្ពស់បំផុត ។ ពេលនោះ ជំនឿជ្រះថ្លានឹងបានជាសម្បត្តិ សេចក្តីស្មោះត្រង់នឹងផ្តល់រសជាតិផ្អែមត្រជាក់ដល់ជីវិត ហើយការប្រមូលសន្សំកុសលបុណ្យនេះ នឹងបានជាករណីយកិច្ចមួយ ប្រសើរបំផុត ។

ក្នុងដំណើរនៃជីវិត ជំនឿជ្រះថ្លាជាចំណីអាហារ គុណធម៌ជាទីជម្រក គតិធម៌ជាពន្លឺនៅពេលថ្ងៃ ការចេះប្រុងប្រយ័ត្នដ៏ត្រឹមត្រូវ ជាសម្ភារៈការពារនៅពេលយប់ ។ បុគ្គលណាចេះរស់នៅក្នុងជីវិតស្អាតបរិសុទ្ធ គ្មានអ្វីអាចមកបំផ្លាញគេបានទេ ។ បុគ្គលណាបានឈ្នះសេចក្តីលោភលន់ គ្មានអ្វីអាចកំណត់ព្រំដែននៃសេរីភាពរបស់គេបានទេ ។

គេពោងតែបំភ្លេចខ្លួនគេ ដើម្បីសេចក្តីស្នេហាដល់គ្រួសារគេ ។ គេពោងតែលះបង់គ្រួសារគេ ដើម្បីសេចក្តីស្នេហាភូមិស្រុកគេ ។ គេពោងតែបំភ្លេចភូមិស្រុកគេ ដើម្បីសេចក្តីស្នេហាដល់ប្រទេសជាតិគេ ។ ជាសម្រេច គេពោងតែបំភ្លេចអ្វីៗ ទាំងអស់ ដើម្បីសេចក្តីស្នេហាពន្លឺត្រាស់ដឹង ។

អ្វីៗទាំងអស់ សុទ្ធតែប្រែប្រួល អ្វីៗទាំងអស់ កើតឡើងហើយវិនាសទៅវិញជាធម្មតា ៖ គ្មានសេចក្តីសុខស្ងប់ទេ ដរាបណាគេមិនបានឆ្លងផុតពីដំណើរប្រែប្រួលនៃការរស់ និងការស្លាប់នេះ ។

ដកស្រង់រៀបរៀងដោយ ឱម ខែម

ផ្អែកលើអត្ថបទ ៖ សិក្ខាបទព្រះពុទ្ធ

BOOKKYO DENDO KYOKAI, 1986

# អំពីផែនដី ឬ ធរណី

( តាមទស្សនៈពុទ្ធនិយម )

នៅក្នុងអក្សរសាស្ត្រពុទ្ធនិយម មានពាក្យនិយាយយោងដល់ផែនដីជាញឹកញយ ដូចជាពាក្យថា បឋវី បឋវីធាតុ បុថវី ធរណី មហី . ល . ។ ពាក្យ បឋវី ត្រូវបានគេប្រើញឹកញយណាស់ ដើម្បីសម្គាល់ធាតុមួយ ក្នុងបណ្តាធាតុជាមូលដ្ឋានទាំងបួន ដែលកត្តិជារូបធាតុ ( matter ) ។

មានការនិយាយយោងជាច្រើន នៅក្នុងអត្ថបទអក្សរសាស្ត្រពុទ្ធនិយមទាំងនោះ ដល់ទីតាំង ឬកន្លែងដែលផែនដីដ៏ធំនេះ បានឋិតនៅ ។ យោងតាមអត្ថបទទាំងនោះ, ផែនដីនេះ តាំងនៅ ឬឋិតនៅលើទឹក, ទឹកឋិតនៅលើខ្យល់ ហើយខ្យល់ឋិតនៅក្នុងអាកាស ។ ពុំមានសេចក្តីយោងណាមួយ និយាយដល់ទ្រង់ទ្រាយផែនដីថាតើវាសំប៉ែត ឬមូលទេ, ប៉ុន្តែ មានសេចក្តីយោងបញ្ជាក់ប្រាប់ថា ផែនដីដែលយើងគ្រប់គ្នារស់នៅពីលើនេះ មិនមែនជាផែនដីតែមួយទេ គឺនៅមានផែនដីជាច្រើនទៀតនៅក្នុងលំហអាកាស ឬចក្រវាឡ ។

យោងតាមលោកធាតុវិទ្យារបស់ពុទ្ធសាសនាថា មានភ្នំមួយឈ្មោះ សិនេរុតាំងនៅជាស្នូលនៃផែនដីរបស់យើងនេះ ។ ភ្នំនោះ លិចទៅក្នុងសមុទ្រក្នុងជម្រៅប្រាំបីម៉ឺនបួនពាន់យោជន៍ ( ៨៤.០០០ ) [(១)] និងមានកំពស់ពីផ្ទៃសមុទ្រឡើងលើមានប្រវែងដូចគ្នា ។ ភ្នំសិនេរុ ព័ទ្ធជុំវិញដោយជួរភ្នំប្រាំពីរជាន់ គឺជួរភ្នំយុគន្ធរ, ឦសធរ, ករវិក សុទស្សនៈ, នេមិន្ធរ, វិនតកៈ, និងអស្សកណ្ណៈ ។ ឋានសួគ៌ឈ្មោះ

---

(១) ១ យោជន៍មានចម្ងាយប្រហែល ៣ ម៉ៃល៍ ឬ ៤.៨២០ ម៉ែត្រ ។

តាវតិង្សៈ ឋិតនៅលើកំពូលភ្នំសិនេរុ, ចំណែកពិភពរបស់អសុរ ឋិតនៅក្រោមបាត ភ្នំ ។ ឋាននរកទាំងអស់ត្រូវបានគេយល់ថា ឋិតនៅក្រោមផែនដី ។ មានប្រពៃណី បុរាណមួយ បាននិយាយថា ឋានអវិចិ ដ៏ជានរកមួយគួរអោយព្រឺខ្លាចបំផុត ឋិតនៅ ជម្រៅប្រាំពីររយម៉ែល៍ ពីខាងក្រោមផ្ទាល់នៃដើមពោធិ៍ ( កន្លែងត្រាស់ដឹងរបស់ព្រះ ពុទ្ធ ) នៅឯពុទ្ធគយា ។ យោងតាមស្នាដៃអក្សរសាស្ត្ររបស់អដ្ឋកថាចារ្យជាច្រើន តួយ៉ាង គម្ពីរធម្មបទដ្ឋកថា ជាដើម, អវិចិនរក តាំងនៅក្នុងផ្ទៃនៃផែនដី ពីខាងក្រោម នៃនរកទាំងអស់ ។

ផែនដី ឬប្រថពីនេះ បានដើរតួមួយយ៉ាងសំខាន់ណាស់ ក្នុងឋានៈជាសាក្សី គាំទ្រព្រះពោធិសត្វ ក្នុងឱកាសព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធ ។ មារ មានចិត្តបាប បានខិតខំអស់ពីកំឡាំងកាយចិត្ត គំរាមកំហែងព្រះពោធិសត្វ កុំអោយព្រះអង្គបាន ត្រាស់ដឹង ។ ដោយមានអាវុធយុទ្ធភណ្ឌដ៏គួរអោយខ្លាច, កងទ័ពរបស់មារបានចាប់ ផ្តើមវាយប្រហារមកលើព្រះពោធិសត្វ ដែលកំពុងតែគង់ចម្រើនសមាធិយ៉ាងសុខ ក្សេមក្សាន្ត ទៀបគល់ពោធិព្រឹក្ស, ប៉ុន្តែ ដោយអំណាចបារមីដែលព្រះពោធិសត្វ បានកសាងមក អស់កាលជាអសង្ខេយ្យក្នុងអតីតជាតិ, អាវុធយុទ្ធភណ្ឌទាំងអស់ បានប្រែក្លាយទៅជាភួងផ្កាដ៏មានក្លិនក្រអូប ហើយធ្លាក់ចុះមកនៅទៀបព្រះបា- ទារបស់ព្រះពុទ្ធ ។ នៅទីបំផុត, កាលដែលការប៉ុនប៉ងទាំងអស់របស់ខ្លួន ត្រូវ បរាជ័យហើយ, មារមានចិត្តបាប បានចូលទៅជិតព្រះពោធិសត្វ ហើយតវ៉ាចំពោះ ព្រះអង្គថា " ម្នាលព្រះអង្គម្ចាស់សិទ្ធថិ, អាសនៈដែលព្រះអង្គកំពុងគង់លើ គឺជា របស់យើង មិនមែនរបស់ព្រះអង្គទេ ។ សូមព្រះអង្គក្រោកយាងចេញពីអាសនៈ នេះទៅ " ។ កាលបើទ្រង់ព្រះសណ្តាប់ពាក្យពោលទាមទាររបស់មារហើយ, ព្រះ អង្គក៏មានបន្ទូលតបទៅមារវិញថា " អើហ្ន៎ ! តើអាសនៈដែលព្រះពោធិសត្វ ទាំងឡាយបានប្រើសម្រាប់គង់ ដើម្បីបានត្រាស់ដឹង ជារបស់អ្នកដូចម្តេចកើត,

តើអ្នកមានភស្តុតាងអ្វីខ្លះ សម្រាប់គាំទ្រការទាមទាររបស់អ្នកនោះ ? " កងទ័ពទាំងអស់របស់មារ បានស្រែកព្រមគ្នាយ៉ាងកងរំពងឡើងថា : " យើងខ្ញុំទាំងឡាយជាសាក្សីចំពោះការទាមទារនេះ " ។ បន្ទាប់មក មារក៏បានស្រែកសួរទៅព្រះពោធិសត្វវិញថា : " តើឥឡូវនេះ ព្រះអង្គមានភស្តុតាងអ្វី ដើម្បីគាំទ្រការទាមទារ របស់ព្រះអង្គចំពោះអាសនៈនេះ " ។ តបទៅនឹងពាក្យរបស់មារ ព្រះពោធិសត្វបានយកចុងម្រាមព្រះហស្តស្ដាំស្ទាបព្រះធរណី ហើយមហាប្រថពីក៏ញ័ររញ្ជួយគ្រហឹមឡើង ។ កងទ័ពរបស់មារ ភិតភ័យតក់ស្លុត រត់ចោលសមរភូមិ បោះបង់ចោលអស់យុទ្ធោ-បករណ៍របស់ខ្លួន ។ ដំរីឈ្មោះ គិរិមេខលា ជាជំនិះរបស់មារ ក៏ក្រញែងខ្លួនរលាស់មារមានចិត្តបាបចេញពីខ្នងរបស់ខ្លួន ហើយលុតជង្គង់នៅចំពោះមុខព្រះភក្រ្ត ព្រះពោធិសត្វ ដោយសេចក្ដីគោរព កោតខ្លាចស្ញប់ស្ញែងព្រះចេស្ដារបស់ព្រះអង្គ ។

ក្រៅពីនិយាយយោងទាក់ទងដល់រឿងខាងលើ, អត្ថបទពុទ្ធនិយមជាច្រើន ក៏មានអធិប្បាយញឹកញយអំពីផែនដី តាមពាក្យប្រៀបធៀប កាលបើគុណធម៌ទាំងឡាយដូចជា ខន្តី និងឧបេក្ខា ជាដើម ត្រូវបានគេលើកយកមកពិភាក្សា ។ នៅក្នុងគម្ពីរមជ្ឈិមនិកាយ ព្រះពុទ្ធទ្រង់មានបន្ទូលថា បើទោះជាមនុស្សខិតខំជីកកកាយ រំលាយផែនដីយ៉ាងដូចម្ដេចក្ដី ក៏គេពុំអាចសំរេចបានឡើយ ដោយសារផែនដីមានទំហំធំធេង និងមានជម្រៅជាគម្ភីរភាព ។ យ៉ាងដូចម្ដេចមិញ សាវ័កដ៏ល្អរបស់ព្រះពុទ្ធ រមែងឋិតនៅដោយមានចិត្តនឹងន មិនរំភើបញាប់ញ័រឥតក្ដីរំខាន កាលបើត្រូវប្រឈមមុខចំពោះពាក្យអសុរសមួលបង្កាច់ ជេរប្រទេចផ្ដាសារបស់មនុស្សអាក្រក់ ។ នៅក្នុងគម្ពីរអង្គុត្តរនិកាយ, សាវ័កដ៏ឧត្តមមួយអង្គរបស់ព្រះពុទ្ធបានក្រាបបង្គំទូលព្រះអង្គថា លោកអាចគង់នៅយ៉ាងស្ងប់ស្ងៀម ដោយគ្មានក្ដីកង្វល់ ឬរង្កៀសចិត្ត, ហើយមានតែចិត្តគំនិតប្រកបដោយមេត្តា និងករុណាប៉ុណ្ណោះ ចំពោះសព្វសត្វ ប្រៀបដូចមហាប្រថពីដែលតាំងនៅស្ងប់ស្ងៀម មិន

ញាប់ញ័រដោយចិត្តត្រេកអរ ឬក្រោធខឹង កាលបើវត្ថុស្អាត គួរជាទីប្រាថ្នាគ្រប់បែប យ៉ាង ជះគ្របមកលើផែនដក្តី, ឬកាលបើវត្ថុស្អុយរលួយ កខ្វក់គ្រប់ប្រភេទ ត្រូវបានគេគ្រវែងចោលមកលើផែនដីនេះយ៉ាងដូចម្តេចក្តី ។ នៅក្នុងគម្ពីរមជ្ឈិមនិកាយនេះដែរ ព្រះពុទ្ធទ្រង់ទូន្មាន ព្រះយុវៈ រាហុល អោយខិតខំអប់រំបន្ធំចិត្តយ៉ាងណាកុំអោយចិត្តរំភើប ញាប់ញ័រ ទោះស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ហើយតាមរយៈចិត្តអប់រំតព់មត់បែបនេះ, គេរក្សាបាននូវលំនឹង ឬតុល្យភាពនៃចិត្តទាំងស្រុងបីដូចជាមហាប្រថពីដូច្នោះ ។ នៅក្នុងគម្ពីរជាតក គេបានឃើញថា តើព្រះពុទ្ធទីបង្ករទ្រង់បានទូន្មានតាបសសុមេធបណ្ឌិតយ៉ាងណា ដើម្បីអោយលោកអាចពង្រីក និងធ្វើអោយចំរើនបាន នូវឧបេក្ខាបារមី ដែលអាចជួយអោយលោកមានចិត្តតាំងនៅស៊ប់ ឥតរំភើប ឥតញាប់ញ័រ ក្នុងគ្រប់កាលៈទេសៈ បីដូចប្រថពី ដែលឋិតនៅស្ងប់ស្ងៀម និងថ្កល់ កាលបើវត្ថុល្អ ក៏ដូចជាវត្ថុអាក្រក់ ក្រខ្វក់ គរគ្របលើខ្លួនដូចម្តេចក៏ដោយ ។

## អំពីទេពធីតាធរណី ឬ នាងគង្ហីងធរណី

ការបូជាចំពោះទេពធីតាធរណី កើតមានឡើងក្នុងលោកតាំងពីយូរលង់មកហើយ ហើយត្រូវបានគេទទួលស្គាល់ក្នុងព្រះពុទ្ធសាសនាប្រជាប្រិយ៍ផងដែរ ដោយមានការនិយាយយោងដល់ត្រង់នេះខ្លះ ត្រង់នោះខ្លះ នៅក្នុងអត្ថបទពុទ្ធនិយម តាំងពីបុរាណយូរលង់មកម្លេះ ។

ទេពធីតាធរណី មានតួនាទីដ៏ខ្ពង់ខ្ពស់មួយនៅក្នុងឋានៈជាទេវមាតា ឬព្រះមេ នៅក្នុងការប្រតិបត្តិសាសនារបស់មនុស្សជាតិពីជំនាន់ដើម ។ នៅក្នុងអំឡុងសម័យកាលបុរេប្រវត្តិ ព្រះមេប្រថពី ឬព្រះមេធរណី ត្រូវបានគេឆ្លាក់រូបនៅលើផ្ទាំងដីឥដ្ឋ និងថ្ម ។ ចរិតលក្ខណៈដ៏សំខាន់ជាដំបូងបំផុតរបស់ព្រះមេធរណី គឺសមត្ថភាពខាងការបង្កើតផល ។ ដោយហេតុនេះ និមិត្តរូបខាងមានជីវជាតិ និងសាយភាយ

គ្រាយផលត្រូវបានគេភ្ជាប់ទៅនឹងរូបភាពរបស់ព្រះធរណី នូវនិមិត្តរូបខាងមានជីវជាតិ និងសាយភាយគ្រាយផលដំណាំដាំដុះនេះឯង ។ និមិត្តរូបនេះ គឺជាតំណាងរូបព្រះធរណី ។ នៅក្នុងការធ្វើរូបបដិមាសម័យបុរាណ, ព្រះធរណី ត្រូវបានបង្ហាញអោយឃើញរូបទេពធីតាមួយអង្គ ដោយមានពោះធំ, តាមរយៈរូបភាពនេះ ព្រះនាងធរណីមានផ្ទៃពោះជានិច្ច ។

នៅក្នុងទេវកថាបុរេពុទ្ធនិយមខ្លះទៀត ជាពិសេសទេវកថា ដែលមានប្រភពចេញពីឫគវេទ ព្រះនាងធរណី មានគភ៌ ឬមានផ្ទៃពោះ ដោយសារអាកាសទេព្តា ពោលគឺ ព្រះឥន្ទ្រ ដើម្បីអោយព្រះនាងធរណី ផលិតចេញនូវភោគផលដំណាំយ៉ាងសម្បូរហូរហៀរ ។ តាមពិតទៅ គឺជារូបាធិដ្ឋាន ( an allegory ) នៃការធ្លាក់ភ្លៀងពីមេឃមកដី បង្កើតភោគផលដំណាំល្អសម្រាប់មនុស្ស សត្វ ធម្មជាតិនៅលើផែនដីនេះ ។

ក្នុងចំណោមរូបឆ្លាក់លើដីឥដ្ឋ, លើកំបោរ ឬថ្ម ដែលគេបានរកឃើញក្នុងទីកន្លែងបុរាណ មុនពេលដែលកើតមានពុទ្ធសាសនា នៅប្រទេសឥណ្ឌា និងប្រទេសស្រីលង្កា, រូបសំណាកព្រះនាងធរណី ក៏ត្រូវបានគេរកឃើញដែរ ។ អ្នកខ្លះមានជំនឿថា រូបដែលរកឃើញនោះ គឺកើតមានក្នុងសម័យកាលមុនពុទ្ធសាសនាកើតមាន, ប៉ុន្តែរូបនោះបានបន្តឋិតថេរ រហូតមកដល់សម័យកាលក្រោយពុទ្ធសាសនាថែមទៀត ។ នៅក្នុងប្រពៃណីពុទ្ធនិយមសម័យក្រោយមកទៀត, គំនិតដែលធ្វើអោយផែនដីក្លាយទៅជាមានរូបកាយ និងជាទេវៈ ពោលគឺជា ទេពធីតាធរណី ត្រូវបានគេយោងទៅរកពាក្យថា មហី ឬ បថវី ។

វាជារឿងធម្មតាមួយ ដែលពុទ្ធសាសនិកជនបានផ្តល់តម្លៃដល់ប្រពៃណីដ៏ចំណាស់មួយ ដោយសារការទទួលស្គាល់ផែនដីថាជាតួអង្គរូបវន្តតាមការសន្មត ។ នៅក្នុងមជ្ឈដ្ឋានឥណ្ឌា ផែនដីត្រូវបានគេលើកតម្កើងដល់ឋានៈជាទេវៈ ឬទេព្តាអស់

កាល ជាច្រើនសតវត្សមកហើយ មុនការកើតមានឡើងនៃពុទ្ធសាសនាទៅទៀត ។ ទាំងនៅក្នុងគម្ពីរវេទ ទាំងនៅក្នុងប្រពៃណីរឿងនិរកថា, ព្រះនាងប្រថពី ត្រូវបានគេគួបផ្សំជាញឹកញយជាមួយព្រះទេវបិតា គឺមេឃ ។ ដោយហេតុនេះ ព្រះបិតាចក្រវាឡ ឬបិតាដើមកំណើត តែងទាក់ទងជានិច្ចជាមួយប្រថពីមាតា ។ ទស្សនៈដែលធ្វើអោយផែនដី និងមេឃទៅជាទេវៈ គឺជាទស្សនៈសាកល ហើយគេអាចប្រមើលមើលទៅក្រោយចាប់ផ្ដើមតាំងពីជំនឿ និងការប្រតិបត្តិ ដែលមាននៅក្នុងចំណោមអរិយធម៌បុរេប្រវត្តិ ។ នៅក្នុងវប្បធម៌បុរាណជាច្រើន ផែនដីត្រូវបានគេចាត់ទុកជាមាតាដ៏មានគុណសប្បុរសផងដែរ ។ ឋាមពលខាងការបង្កើត ក៏ត្រូវបានគេទទួលស្គាល់ដែរ, ដោយហេតុនេះ ទើបបានគេទទួលស្គាល់ថាប្រថពី ឬផែនដីថាមានផ្ទៃពោះ ឬមានគភ៌, មានយោនី ដើម្បីបង្កើតជាកូន ដោយទេវបិតាគឺមេឃក្នុងរូបភាពជាទឹកភ្លៀង ។ នៅក្នុងប្រពៃណីឥណ្ឌាជំនាន់ដើម ទិដ្ឋភាពនេះ ក៏ត្រូវបានគេយកចិត្តទុកដាក់ណាស់ ដោយគេគូរូបព្រះធរណីតាមបែបសិល្បៈ ជាព្រះមហាមាតា, *អាទិតិ ឧត្តនបទ*, ដោយបង្ហាញផ្ទៃកយោនីក្រពង់ខ្ពស់ ។ ផ្កាឈូកក៏ជានិមិត្តរូបតំណាងព្រះម៉ែ ធរណីក្នុងទិដ្ឋភាពនេះដែរ ។

ជាមួយនឹងការផ្សព្វផ្សាយ ហើយនឹងការរីកចំរើននៃពុទ្ធសាសនាទៅជាសាសនាប្រជាប្រិយ៍, ពុទ្ធសាសនាក៏ចាប់ផ្ដើមរលាយចូលជាមួយជំនឿបែបនេះ ហើយសម្របខ្លួនទៅនឹងជំនឿនោះ ដែលបានចាក់ឫសយ៉ាងជ្រៅក្នុងបណ្ដាប្រជាជនសាមញ្ញ ។ គឺនៅក្នុងពន្លឺនេះហើយ ដែលគេត្រូវវាយតម្លៃវត្តមាននៃព្រះនាងធរណីនៅក្នុងជំនឿ និងការគោរពបូជាពុទ្ធសាសនានាសម័យកាលក្រោយមក ។

ព្រះនាងធរណី ហាក់ដូចជាមានតួនាទីសំខាន់ណាស់ក្នុងដំណើរត្រាស់ដឹងរបស់ព្រះពុទ្ធ, នេះបើយោងតាមគម្ពីរភាសាបាលី ។ គម្ពីរបាននិយាយថា ព្រះនាងធរណីបានជួយព្រះពោធិសត្វ នៅពេលមានការពិបាកបំផុតមួយ គឺនៅគ្រាដែល

ទេវបុត្រ និងទេវតាទាំងអស់រត់ចោលព្រះពោធិសត្វ ដោយឃើញមារ ព្រមទាំងមារ-សេនា បានចូលសំដៅមករកព្រះពោធិសត្វ ។ តាមរឿងនិទានទាំងនោះថា នៅពេលព្រះពោធិសត្វហៀបនឹងបានសំរេចសម្ពោធិនោះ, មារមានចិត្តបាបក្រឡេកឃើញព្រះពោធិសត្វ កំពុងតាំងសមាធិ នៅក្រោមដើមពោធិព្រឹក្ស ក៏ស្ទុះចូលទៅជិតព្រះអង្គក្នុងបំណងធ្វើអោយព្រះអង្គដាច់សមាធិ ។ នៅពេលដែលការប៉ុនប៉ងនេះមិនបានសំរេច, មារក៏តាំងស្រែកទាមទារ *វជ្រាសនៈ* ( គឺ បល្លង្កពេជ្រ ) ដែលព្រះពុទ្ធកំពុងគង់លើ ។ មារបានស្រែកអំពាវនាវអោយមារសេនា ដ៏ច្រើនសែនកោដិជួយធ្វើជាសាក្សី រួចហើយក៏ដណ្តើងសួរអោយព្រះពុទ្ធបង្ហាញហេតុ - ផល ថា ព្រោះហេតុអ្វីទើបព្រះអង្គមិនប្រគល់អាសនៈ ( បល្លង្ក ) ទៅអោយមារ ។ មកដល់ចំណុចនេះ, គេនិយាយថា ព្រះពុទ្ធបាននំលើកអំពីបារមីទាំងដប់ ដែលព្រះអង្គបានកសាងកាលពីជាតិមុនដ៏ច្រើនអនេក, ហើយព្រះអង្គអំពាវនាវសុំអោយព្រះធរណីជួយធ្វើជាសាក្សី ដោយព្រះអង្គបានយកម្រាម ព្រះហស្តស្តាំចង្អុរទៅរកផែនដី ។ អ្នកតាក់តែងរឿងក្រោយៗមក បានកត់ត្រារឿងនិទានដដែលនេះថា ព្រះនាងធរណីផ្ទាល់ បានកក្រើកញាប់ញ័រប្រាំពីរដង, ហើយក្រុងមារព្រមទាំងពលរេហ៍របស់ខ្លួនបានរត់បាត់អស់ទៅ ដោយក្តីភិតភ័យតក់ស្លុត ។

គេគួរកត់សំគាល់ថា នៅក្នុងអក្សរសាស្ត្រពុទ្ធសាសនាក្រោយៗមក, ការនិយាយយោងដល់រឿងមារផ្ចាញ់ព្រះពុទ្ធកំពុងគង់ក្រោមដើមពោធិព្រឹក្ស ត្រូវបានគេឃើញមានជាលើកដំបូងនៅក្នុង *បធានសូត្រ* នៃសុត្តនិបាត ។

ប៉ុន្តែ រឿងមារ ( ផ្ចាញ់ព្រះ ) មានអត្ថន័យសំខាន់ ពីព្រោះវាជារឿងដើរតួសំខាន់ក្នុងការបញ្ចូលទេពធីតាធរណីក្នុងដំណើរជីវិត នៃព្រះពុទ្ធតាមរយៈអ្នករៀបរៀងក្រោយៗមក ហើយជាសំខាន់នោះ បញ្ចូលទៅក្នុងការតាក់តែងសិល្បៈពុទ្ធ-សាសនាផងដែរ មានរូបគំនូរ រូបចម្លាក់ ជាដើម ។

ដោយហេតុនេះ ព្រះនាងធរណី មានវត្តមាននៅក្នុងរូបលំអ នៃរឿងនិទានអំពីមារ ( ផ្ចាញ់ព្រះ ) នៅក្នុងស្តូប ឬ ចេតិយ៍ពុទ្ធសាសនាជាច្រើនអនេក ទាំងជារូបចម្លាក់ ទាំងជារូបគំនូរនៅបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនា ។ គេបានលើកយករូប គំនូរពណ៌មួយបែបនេះ ( ស.វ. ទី ៧ នៃគ្រិស្តសករាជ ) អំពី *គីហ្ស៊ីល* ( Kyzyl ) ( អាស៊ីកណ្តាល ) ដែលបង្ហាញអោយឃើញស្ត្រីម្នាក់មានអាកប្បកិរិយាទន់ភ្លន់ ផុសចេញអំពីហ្វូងសេនាដ៏ឃោរឃៅ នៅពីក្រោមជើងបល្លង្ក ដែលនៅពីលើបល្លង្កនេះ ព្រះពុទ្ធកំពុងគង់នៅ ។ មារសេនាត្រូវបានគេបង្ហាញអោយឃើញកំពុងតែគ្រវែងសព្វាវុធសំដៅទៅព្រះពុទ្ធ ចំណែកឯព្រះពុទ្ធវិញ គេបានបង្ហាញអោយឃើញព្រះអង្គកំពុងយកម្រាមព្រះហស្តស្តាំស្ទាបព្រះធរណី ( ភូមិស្បសិៈ ) សុំអោយព្រះនាងធរណីជួយធ្វើ ជាសាក្សី ។

មានរូបលំអដ៏ចាស់ទុំមួយទៀត ដែលគេបានរកឃើញនៅ *សញ្ចិ* បង្ហាញពីការវាយប្រហាររបស់មារ ដែលនៅក្នុងរូបលំអនោះ គេបង្ហាញព្រះពុទ្ធកំពុងគង់លើ *វជ្រាសនៈ* ( បល្លង្កពេជ្រ ) ក្រោមដើមពោធិព្រឹក្សដ៏ពិសិដ្ឋ ។ រូបមារ និងពលរេហ៍កំពុងរត់រប៉ាត់រប៉ាយ ត្រូវបានគេបង្ហាញនៅផ្នែកខាងឆ្វេង នៃដើមពោធិ៍, ចំណែកនៅខាងស្តាំដើមពោធិ៍វិញ ( កៀកជាប់ដើមពោធិ៍ ) គឺមានរូបស្ត្រីម្នាក់កំពុងកាន់កំសៀវទឹក ។ គេអាចទាយបានថា ស្ត្រីនោះ គ្មានអ្នកណាក្រៅពីព្រះនាងធរណីនេះទេ ។

ព្រះនាងធរណី ត្រូវបានគេបង្ហាញនៅក្នុងចម្លាក់បាលៈសម័យកណ្តាលយកមកអំពី បេនហ្គាល់ ដែលនៅក្នុងរូបចម្លាក់នោះ, ព្រះនាងធរណី ត្រូវបានគេបង្ហាញអោយឃើញកំពុងកាន់វត្ថុមួយរាងដូចកំសៀវទឹក ( តាមបែបបទដូចរូបស្ត្រីដែលគេគួរនៅក្នុងផ្ទាំងរូបសញ្ចិដែរ ) ហើយផុសចេញមកពីក្រោមបល្លង្ករបស់ព្រះពុទ្ធ ។ ព្រឹត្តិករណ៍ដ៏ធំ ត្រូវបានគេបង្ហាញជានិមិត្តរូប នូវរូបព្រះពុទ្ធកំពុងចង្អុល

ព្រះធរណី ( ដែលគេអោយឈ្មោះឥរិយាបថបែបនេះរបស់ព្រះពុទ្ធថា ភូមិស្បសិ-មុទ្រ្ទ ) ។ ម្កុដនៅលើព្រះកេសរបស់ព្រះពុទ្ធ មានន័យថា ព្រះអង្គបានសំរេចសម្មាសម្ពោធិហើយ, គឺព្រះអង្គទទួលអភិសេកជានិមិត្តរូប នៅក្នុងព្រះរាជាណាចក្រនៃពុទ្ធភូមិ ។

នៅក្នុងរូបចម្លាក់នៃរូងភ្នំ *អជណ្តា* ដែលគេបានពិពណ៌នាអំពីព្រះពុទ្ធបានត្រាស់ដឹងគង់នៅទៀបគល់ពោធិព្រឹក្ស, ព្រះពុទ្ធ ក៏ត្រូវបានគេបង្ហាញអោយឃើញនៅក្នុងឥរិយាបថស្ដាបព្រះធរណី ចំណែកឯស្ត្រីម្នាក់បង្ហាញអោយឃើញ ផុសចេញពីក្រោម *ពុទ្ធាសនៈ* ហើយដៃទាំងពីរកាន់កំសៀវទឹកមួយ ។ នៅក្នុងរូបនោះ, គេបង្ហាញរូបមារកំពុងចោលអាវុធរបស់ខ្លួនទៅលើព្រះពុទ្ធ ។

នៅក្នុងរូបចម្លាក់ ឬរូបគំនូរពណ៌បុរាណ ដែលមាននៅក្នុងប្រទេសស្រីលង្កាវិញ, មានការពិបាកស្រាវជ្រាវរករឿង និទានរបស់មារណាស់, ហើយដោយហេតុនេះ ក៏មានការពិបាកស្រាវជ្រាវរឿងនិទានរបស់ព្រះនាងធរណីផងដែរ ។ ប៉ុន្តែដំណើររឿងនេះ គឺជាប្រធានបទដ៏រស់រវើកមួយ សម្រាប់សិល្បកររបស់ប្រទេសស្រីលង្កា ក្រោយៗមក ដូចដែលឃើញមាននៅក្នុងរូបលំអជាច្រើន ស្ដីពីការវាយប្រហាររបស់ក្រុងមារនៅលើជញ្ជាំងវិហារសម័យកណ្ដាល ដោយមានការបង្ហាញអោយឃើញព្រះនាងធរណី ( មហីកន្ទា ) ផងដែរ ។ ឧទាហរណ៍មួយបែបនេះ គឺរូបនៅជញ្ជាំងវិហារ ដីហ្គាល់ដូរវ៉ា ( Degaldoruwa ) ចិតនៅជិតក្រុងកណ្ឌី, ដែលនៅ ក្នុងរូបនោះ ព្រះនាងធរណី ត្រូវបានគេបង្ហាញអោយឃើញកំពុងកាន់កំសៀវទឹក ហើយផុសចេញមកពីបាតនៃ *ពុទ្ធាសនៈ* ។

ប្រធានបទ " ព្រះនាងធរណី និងទឹកមុខស្លន់ស្លោររបស់មារ " ដែលត្រូវបានគេយកមកពិពណ៌នាយ៉ាងទូលំទូលាយនៅក្នុងសិល្បៈ នៃបណ្ដាប្រទេសអាស៊ីអគ្នេយ៍ : ភូមា, ថៃឡង់, លាវ និងកម្ពុជា អាចមានប្រភពចេញមកពីសិល្បៈពុទ្ធ-

សាសនា នៃសាលាបាលៈ ( the Pala School of Buddhist Art ) នៃរដ្ឋបេនហ្គាលខាងកើត ។ នៅក្នុងប្រទេសអាស៊ីភាគអគ្នេយ៍ ព្រះពុទ្ធរូបក្នុងឥរិយាបទ *ភូមិស្បសិមុទ្រៈ* ត្រូវបានគេនិយមរាប់អានជាទូទៅខ្លាំងណាស់ ទាល់តែមានអ្នកខ្លះបានកត់សម្គាល់ដោយភ័ន្តច្រឡំថា នោះគឺជាប្រភេទព្រះពុទ្ធរូប ដំបូងបំផុតក្នុងពិភព-លោក ។ តាមពិត គេអាចហៅរូបបែប *ភូមិស្បសិៈ* ទាំងនោះ មិនមែនក្នុងឋានៈជារូបភាពព្រះពុទ្ធទេ, ប៉ុន្តែជា បដិមា ( រូបប្រៀប ) ដែលគេសាងឡើងសម្រាប់រំលឹកអព្រឹត្តិការណ៍ពិសេសមួយ នៅក្នុងជីវភាពរបស់ព្រះពោធិសត្វ នៅពេលដែលព្រះអង្គបានហៅរកព្រះនាងធរណី អោយធ្វើជាសាក្សី ដើម្បីអះអាងការទាមទាររបស់ព្រះអង្គយក *វជ្រាសនៈ* ( បល្លង្កពេជ្រ ) ។ រូបភាពដ៏រស់រវើកមួយរបស់សាលា *បាលៈ* បានពិពណ៌នាពីដំណើររឿងនេះ ។ ប្រហែលមកពីដំណើររឿងនេះ ជាដំណើររឿងមួយដែលផ្តល់ការចាប់អារម្មណ៍ខ្លាំងដល់សិល្បករ មកអំពីអាស៊ីអគ្នេយ៍ តាមរយៈការបង្ហាញអោយឃើញព្រះពោធិសត្វទ្រង់គ្រឿងអម្ពរពស្ត្រាជាស្តេច, ពាក់មកុដ ។ គេបានបង្ហាញព្រះនាងធរណីនៅ ផ្នែកខាងក្រោមនៃបល្លង្កចំកណ្តាលតែម្តង, អមដោយរូបពីរ ។ រូបខាងឆ្វេងនៃព្រះនាងធរណី គឺជារូបមារ មានទឹកមុខស្លន់ស្លោ ដោយការបរាជ័យ ។

នៅប្រទេសកម្ពុជា ឆាកព្រះផ្ចាញ់មារ ត្រូវបានពុទ្ធសាសនិកនិយមរាប់អានណាស់ ។ សិល្បករបានបង្ហាញអោយឃើញព្រះពុទ្ធ គង់លើរតនបល្លង្ក ប្រកបដោយឆព្វណ្ណរង្សីដ៏រុងរឿង ដែលផ្សាយចេញព្រះពីកេសា ជាតំណាងបញ្ញាញាណដ៏គ្មានព្រំដែន ។ នៅជើងបល្លង្ក, គេបង្ហាញអោយឃើញរូបស្ត្រីម្នាក់ មានដងខ្លួនពត់ពេន, យកដៃច្បូតសក់ ដែលបណ្តាលអោយកើតទៅជាសមុទ្រ ពន្លិចពន្លង់មារសេនា ព្រមទាំងមារ ។ ស្ត្រីនោះ គឺព្រះនាងធរណី ឬ *នាងគង្ហីងធរណី* នោះឯង បើហៅតាមពាក្យសាមញ្ញរបស់ប្រជាជនខ្មែរ ។

ភ្ជាប់ទៅនឹងជំនឿដែលផ្តល់សារសំខាន់ដល់ព្រះនាងធរណី ឬនាងគង្ហីង ធរណីនេះ, ទើបនៅទីកន្លែងខ្លះ កាលណាគេបានកសាងព្រះពុទ្ធបដិមាថ្មី គេត្រូវរៀបចំធ្វើពិធីពុទ្ធាភិសេក ។ មុនពេលពិធីនេះត្រូវបានប្រារព្ធ គេបានរៀបចំពិធីដោយឡែកមួយ ដោយមានស្លាធ័រ បាយសី នំចំណី ផ្លែឈើ ច្រើនមុខ ដាក់តាំងនៅពីមុខអាសនៈ ដើម្បីសុំជោគ សុំជ័យ សិរីមង្គល និងសេចក្តីសុខគ្រប់ប្រការ អំពីព្រះធរណី សម្រាប់រៀបចំការធ្វើពុទ្ធាភិសេក ។

មានពិធីសុំទឹក សុំដី មួយបែបទៀត តាមបែបព្រហ្មញ្ញសាសនា ដែលប្រជាជនខ្មែរនិយមធ្វើ កាលណាមានធ្វើវិធីបុណ្យទាន ឬមានសំណង់សាសនា នឹងត្រូវសម្ពោធដាក់ឱ្យប្រើប្រាស់ ដូចជា ព្រះវិហារ, សាលាធម្មសភា ឬសាលាឆាន់ជាដើម ។ នៅកន្លែងខ្លះ តំបន់ខ្លះ សូម្បីតែការសង់ផ្ទះសម្បែងសម្រាប់ស្នាក់អាស្រ័យនៅ មុនពេលសរសរផ្ទះត្រូវបានលើក, ក៏គេប្រារព្ធធ្វើពិធីសុំទឹក សុំដីផងដែរ ។ គេហៅពិធីនេះថា ពិធីក្រុងពាលី ។ ប៉ុន្តែ ចំពោះសំណង់តូចតាច ដូចជាសំណង់ផ្ទះសម្បែងនេះ ពិធីក្រុងពាលី ពុំមានអន្តាប់អន្តាច្រើនទេ ហើយពិធីក៏ពុំប្រព្រឹត្តទៅអធិកអធ័ម ដោយមានភ្លេងដូរ្យដន្ត្រីប្រគំដេញដំនោះដែរ គឺគេធ្វើពិធីនោះដោយសង្ខេប ។

ពិធីក្រុងពាលី គឺជាពិធីតាមជំនឿសាសនាព្រាហ្មណ៍ ។ តាមរឿងនិទានក្នុងនរាយណ៍ ទសាវតារ ( គឺអវតារទាំងដប់លើក របស់ព្រះនរាយណ៍ ដើម្បីសង្គ្រោះពិភពលោកនេះអោយផុតពីការរាតត្បាត សង្កត់សង្កិនរបស់ពួកអសុរ ) ថា ក្រុងពាលី គឺជាស្តេចអសុរកំណាច ដ៏មានមហិទ្ធិឫទ្ធិ ដែលបានដើររាតត្បាតលោកទាំងបី ( ទេវលោក, មនុស្សលោក, ឋានបាតាល ), បង្កឱ្យមានសេចក្តីភិតភ័យ តក់ស្លុតជាទូទៅដល់មនុស្ស និងទេវតា ដោយសារអំពើឃោរឃៅដ៏កំណាចរបស់ក្រុងពាលី ។ ដោយទ្រាំពុំបានចំពោះអំពើបៀតបៀននេះ ទេវតាទាំងឡាយក៏នាំគ្នាទៅសុំយាងព្រះ

នរាយណ៍ ដែលកំពុងតែផ្ទំសម្រាកព្រះកាយ លើអនន្តនាគរាជ ក្នុងមហាសាគរ ឱ្យព្រះអង្គកំចាត់ក្រុងពាលី រំដោះភពទាំងបី ពីក្រញាំដៃឃោរឃៅរបស់ក្រុងពាលី ។

ព្រះនរាយណ៍ បានទទួលការនិមន្តន៍របស់ពួកទេព្តាហើយ, ក៏អវតារមកកើតជាមនុស្សតឿ រួចចូលទៅសុំពីក្រុងពាលី នូវដីបីជំហាន ដើម្បីសង់លំនៅឋាន ។ ក្រុងពាលីទតឃើញមនុស្សតឿទាបល្អិត ក៏គិតងាយ យល់ព្រមប្រគល់ដីបីជំហានដល់មនុស្សតឿ តាមសំណូមពរ ។ ភ្លាមនោះ មនុស្សតឿព្រះនរាយណ៍កាឡាសំដែងបាដិហារ្យ ឈានជំហានទីមួយ យកអស់ពិភពមនុស្សទាំងមូល, ឈានជំហានទីពីរ យកអស់ទេវលោកទាំងមូល, នៅសល់ជំហានទីបី ឥតកន្លែងដាក់, លោកក៏ស្រែកសួរទៅក្រុងពាលីថា តើត្រូវអោយលោកដាក់ជំហានទីបីត្រង់ណា ។ ក្រុងពាលីដឹងច្បាស់ថាខ្លួនចាញ់កលព្រះនរាយណ៍ហើយ ក៏ទូលតបព្រះនរាយណ៍វិញថា គ្មានសល់ទីណាទៀតទេ មានតែដាក់ព្រះបាទា លើក្បាលទូលព្រះបង្គំនេះហើយ, ប៉ុន្តែមុនព្រះអង្គសំរេចជំហានចុងក្រោយនេះ ទូលព្រះបង្គំសំណូមពរព្រះអង្គមួយ គឺថាបើមនុស្សលោកធ្វើពិធីបុណ្យ ឬសង់លំនៅឋានផ្សេងៗ សូមអោយគេនឹកដល់ឈ្មោះទូលបង្គំផង ។ លុះក្រុងពាលីនិយាយចប់ហើយ, ព្រះនរាយណ៍ក៏បានទទួលសំណូមពរនោះ ហើយដាក់ជំហានចុងក្រោយលើក្បាលក្រុងពាលី រួចជាន់ពន្លិចក្រុងពាលី អោយទៅនៅឋានបាតាលទៅហោង ។

ដោយយោងតាមរឿងនិទាននេះហើយ ទើបប្រជាជនខ្មែរយើង ដែលជាអ្នកពុទ្ធសាសនា ពុំសូវប្រាកដប្រជា ក៏បានប្រព្រឹត្តរៀបចំពិធីក្រុងពាលី លាយឡំជាមួយពិធីក្នុងពុទ្ធសាសនារៀងរហូតមក ។ អ្នកជឿពុទ្ធសាសនាត្រឹមត្រូវ បានរិះគន់ជំនឿក្នុងពិធីក្រុងពាលី ក៏ដូចជាជំនឿក្នុងការសុំជោគជ័យ សិរីសួស្តី ជ័យមង្គលពីព្រះធរណី មុនការរៀបចំធ្វើពិធីពុទ្ធាភិសេកព្រះពុទ្ធបដិមា ។ ហេតុ - ផល ដែលមិនឯកភាពជាមួយជំនឿខាងលើនេះ គឺពុទ្ធសាសនា ជាសាសនាអទេវនិយម, ជឿលើ

ហេតុ - ផល ។ សេចក្ដីបរិសុទ្ធ ( សុខ ) និងមិនបរិសុទ្ធ ( ទុក្ខ ) គឺបុគ្គលខ្លួនឯងជាអ្នកសាង, គ្មានកលាំងក្រៅខ្លួនណា ញ៉ាំងបុគ្គលអោយបរិសុទ្ធ ឬមិនបរិសុទ្ធនោះឡើយ ។ នេះជាទទ្បីករណ៍ខ្លះៗ ដែលនាំអោយពុទ្ធសាសនិកជនដ៏ពិត រិះគន់ពិធីទាំងនោះ ។

រៀបរៀងដោយ

**ឈន ឈៀម**

ផ្អែកលើអត្ថបទ : W.G Weeraratne p. 1

និងអត្ថបទ : A.D.T.E Perera p. 1 - 3

Encyclopedia of Buddhism Vol. V , 1990.

***

*រស់តែមួយថ្ងៃ ហើយបានយល់សេចក្ដីពិតបំផុត ប្រសើរជាជាងរស់មួយរយឆ្នាំ ហើយមិនបានយល់សេចក្ដីពិតបំផុត ។*

ធម្មបទ

# ឋានន្តរនាមសម័យអង្គរ

តាមការសិក្សាអត្ថបទសិលាចារឹកសម័យអង្គរ យើងអាចសង្កេតឃើញថា ឋានន្តរនាមសម័យអង្គរ បានរក្សាទុកនូវប្រព័ន្ធនៃឋានន្តរនាមសម័យមុនអង្គរ គឺសម័យនគរភ្នំ ។ ហេតុការណ៍ជាកត្តាមួយសំខាន់ ដែលបញ្ជាក់ឱ្យយើងដឹងថារបបគ្រប់គ្រងសម័យអង្គរ ព្រមទាំងជំនឿផ្សេងៗ បានទទួលមរតកគ្រប់គ្រង និងជំនឿផ្សេងៗ ពីសម័យមុនអង្គរ ។ ប្រព័ន្ធនៃឋានន្តរនាមសម័យអង្គរ អាចចែកចេញបានជា ៣ ថ្នាក់ គឺប្រព័ន្ធឋានន្តរនាមរបស់វណ្ណៈអភិជន ( CSS ) ។

*១. ប្រព័ន្ធនៃឋានន្តរនាមក្រុមជាន់ខ្ពស់ CSS*

| ថ្នាក់ A | ថ្នាក់ B | ថ្នាក់ C |
|---|---|---|
| តាញ Tañ | mratāñ<br>mrateṅ | កំស្រតាញ<br>កំស្រតេង |
| តេង Teṅ | ស្តេង steṅ<br>ស្តេញ steñ | កំស្តេង kaṃsteṅ |
| លោញ<br>Loñ | ខ្លោញ khloñ<br>ឆ្លោញchloñ | កំត្វន kaṃtvan<br>កំលោញ kaṃloñ |
| វាប vāp<br>ហ្យង hyaṅ | ស្តច stac<br>អំចាស<br>aṃcās | សំតច saṃtac<br>កុរុង kuruṅ<br>កញ្ហ្យង kanhyaṅ |

| | | | |
|---|---|---|---|
| | | អំទេង | aṃteṅ |
| | | សញ្ញាក | sañjak |

I. ថ្នាក់ A :

នៅក្នុងថ្នាក់ A ឋានន្តរនាមផ្សេងៗ ត្រូវបានសំដែងឡើងដោយពាក្យទោល ហើយពាក្យដើមនេះ ត្រូវបានប្រើប្រាស់ជាពាក្យឫស សំរាប់បង្កើតឋានន្តរនាមនៅក្នុងថ្នាក់ B និង C ដោយបន្ថែមផ្នត់ affixation ដែលជាឋានន្តរនាមមានកិរិតខ្ពស់ជាង នៅក្នុងថ្នាក់ A ។

+ ផ្នត់ទាំងនោះមាន : ផ្នត់ដើម « ក ka » ហើយនិងទំរង់ដទៃទៀត នៃផ្នត់ដើម « ក » គឺ ku កុ kaṃ កំ ផ្នត់ដើម « S ស » ផ្នត់ដើម « mra ម្រ » ។

+ ផ្នត់ជែក « - m - ម » ( affixe : - ម - )

យើងសង្កេតឃើញមានទំនាក់ទំនងគ្នាទៅវិញទៅមក មានកិរិតឧត្តុង្គឧត្តម និងរចនាសម្ព័ន្ធពាក្យ ដែលវាសំដែងនូវឋានន្តរនាមនីមួយៗ ដូចជាឋានន្តរនាមថ្នាក់ B មានកិរិតឧត្តុង្គឧត្តមជាងថ្នាក់ A ។ ជាមួយគ្នានោះ ឋានន្តរនាមថ្នាក់ B គឺជាពាក្យមានទំរង់វែងជាងពាក្យដែលតាងឋានន្តរនាមថ្នាក់ A រីឯឋានន្តរនាមថ្នាក់ C មានទំរង់វែងហើយ ស្មុគ្រស្មាញជាងឋានន្តរនាមថ្នាក់ A និង B ។ ឋានន្តរនាម ថ្នាក់ C នេះ ជាឋានន្តរនាមដែលមានកិរិតឧត្តុង្គឧត្តមខ្ពង់ខ្ពស់ជាងគេ ។

ឋានន្តរនាមទាំងនេះ រមែងមានទំរង់ជាពាក្យ ២ ព្យាង្គយ៉ាងតិច ។ បានសេចក្ដីថា : កាលណាទំរង់នៃពាក្យកាន់តែវែង កាន់តែស្មុគស្មាញ ឋានន្តរនាមមានកិរិតកាន់តែឧត្តុង្គឧត្តមឡើង ។

II. ថ្នាក់ B :

ឋានន្តរនាមថ្នាក់ B គឺជាឋានន្តរនាមទាំងឡាយណាដែលស្ថិតនៅក្នុងស្រទាប់សង្គមខ្ពង់ខ្ពស់ជាងឋានន្តរនាម នៅក្នុងថ្នាក់ A ។

III. ថ្នាក់ C :

ឋានន្តរនាមថ្នាក់ C ជាឋានន្តរនាមបុគ្គលមានតួនាទីខ្ពស់ជាងគេនៅក្នុងប្រទេស ។ ពោលគឺជាឋានន្តរនាមព្រះមហាក្សត្រ មហាក្សត្រិយានី ក្សត្រា ក្សត្រី មហាមន្ត្រី រាជគ្រូ មន្ត្រីជាន់ខ្ពស់ ឬមន្ត្រីសង្ឃ ។ ជាទូទៅ ឋានន្តរនាមទាំងនេះ ភាគច្រើន កើតឡើងដោយសារពាក្យដែលកកើតដោយសារផ្នត់ពិសេស ហើយដែលយើងបានរៀបរាប់រួចមកហើយនៅក្នុងឋានន្តរនាមថ្នាក់ B និងកើតពីពាក្យមានន័យពេញលេញមួយចំនួនផង ។

តទៅមុខនេះ នឹងមានការរៀបរាប់ពីចំណាត់ថ្នាក់ និងអត្ថន័យនៃឋានន្តរនាមនិមួយៗ ។

A 1. តាញ៑ tāñ < តាញ ជាឋានន្តរនាមសំរាប់នារីវណ្ណៈអភិជន ហើយច្រើនមានស្វាមី ដែលមានឋានន្តរនាម « ពោញ » ឬ « វាប » ។

វាប៑ ទា តាញ៑ ធម៌្មា vāp dā tāñ dharmmā **k** 349

ក្វន៑ វាប៑ សទាឝិវ ត ឆ្មះ តាញ៑ ព្រហ្ម នុ តាញ៑ ឧមា **k** 720

kvan vāp sadāçiva ta jmaḥ tāñ vrahma nu tāñ umā

កូនស្រីរបស់ វាប សទាសិវ មានឈ្មោះ តាញ ព្រហ្ម និង តាញ ឧមា

នៅសម័យក្រោយមក តាមភស្តុតាងសិលាចារឹក **k** 956 ឋានន្តរនាម តាញ បានបង្កើតនូវឧត្តមភាពរបស់ខ្លួន ដោយហេតុថា តាមព្រះរាជបញ្ជារបស់ព្រះបាទឥន្ទ្រវរ្ម័នទី ១ នរនាម ( តាញកំម្រតេងអញ ) បានត្រូវប្រើប្រាស់ដើម្បីសំគាល់

នូវនរនាម ដែលមានន័យថា « ព្រះអង្គម្ចាស់ក្សត្រិយ៍ » ។

ឧទាហរណ៍ :

យើងបានដឹងថា ពាក្យ « តាញ » ជាពាក្យដែលមានសំនួរក្លាយចេញពីពាក្យ តាង ឬ តាំង ។ ពាក្យ តាង នៅសម័យនគរភ្នំ ជាឋានន្តរនាមសំគាល់នូវមន្ត្រីជាន់ខ្ពស់របស់ព្រះមហាក្សត្រ ។

B 1 ម្រតាញ.ម្រតេង mratāñ / mrateṅ : ជាពាក្យដែលមានសំនួរចេញពីពាក្យ « ម្រតាង » ហើយនៅសម័យនគរភ្នំ ពាក្យនេះបានត្រូវប្រើប្រាស់សំរាប់សំគាល់មន្ត្រីរបស់ព្រះមហាក្សត្រ ដែលមានឋានៈខ្ពង់ខ្ពស់ជាង « តាង ឬតាងអញ » ។

នៅសម័យអង្គរ ឋានន្តរនាម ម្រតាញ ឬ ម្រតេង ម្រតាញ ជាឋានន្តរនាមសំរាប់មន្ត្រីព្រះមហាក្សត្រ ដែលបំពេញមុខងារក្នុងរាជវាំង ក្នុងប្រាសាទនានា មន្ត្រីទាំងនោះមានមុខងារជាចៅក្រម អភិបាល ឃ្លាំងមាស ឃ្លាំងប្រាក់ អភិបាលខេត្ត ជាមេទ័ព ជាតម្រួត ( អភិបាលកងពល ) ជាមន្ត្រីត្រួតត្រាខាងកិច្ចការធម្មការ ។

ម្រតាញ សភាបតិ K 216 ប្រធានតុលាការ

ម្រតាញខ្លោញ ឃ្លាង K 224 ប្រធានឃ្លាំង

ម្រតាញ ភុទ្ធង K 181 អភិបាលខេត្ត

C 1/ កំម្រតេង / kammrateṅ :

គឺជាឋានន្តរនាមដែលបានក្លាយមកពីឋានន្តរនាម កំម្រតាង សម័យនគរភ្នំ ។ ជាឋានន្តរនាមប្រកបដោយឧត្តមភាពខ្ពង់ខ្ពស់ជាងគេ ។ នៅសម័យអង្គរ ក៏ដូចជាសម័យមុនអង្គរដែរ ឋានន្តរនាម កំម្រតេង អាចក្លាយទៅជាវ្រះកំម្រតេង ហើយឋានន្តរនាមខាងក្រោយនេះ អាចក្លាយទៅជា វ្រះកំម្រតេងអញ ដែលជាឋានន្តរនាម

ប្រកបដោយឧត្តមភាពខ្ពង់ខ្ពស់ សំរាប់សំគាល់នូវមហាមន្ត្រីសង្ឃរាជ ឬរាជគ្រូ ។ ល ។ នរនាមសំរាប់សំគាល់ព្រះមហាក្សត្រសម័យអង្គរ បានកើតឡើងដោយការផ្សំនៃកន្សោមពាក្យ ៖ ធូលីជេង + ធូលីព្រះបាទ + វ្រះកំម្រតេងអញ ។

ធូលីជេង ធូលីវ្រះបាទវ្រះកំម្រតេងអញស្រីជយវម៌្មទេវ

dhūlījeṅ dhūlī vraḥ pāda vraḥ kamַmrateṅ añ srī jaya

១០៦៩ varmma deva

នៅសម័យអង្គរ កន្សោមពាក្យធូលីជេង ធូលីព្រះបាទតែប៉ុណ្ណោះ បានក្លាយទៅជាឋានន្តរនាមមួយ សំរាប់សំគាល់នូវមហាមន្ត្រីដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះមហាក្សត្រ ។ ពាក្យ « វ្រះកំម្រតេង » បានត្រូវគេប្រើប្រាស់នៅសម័យអង្គរដោយប្ញកជាមួយពាក្យ ជគត ( ពិភពលោក, លោកៈ ) ដើម្បីសំគាល់នូវអាទិទេពដ៏សំខាន់ៗ ឬវត្តអារាមសំខាន់ៗ នៅសម័យអង្គរ ។

A 2 / តេង teṅ : ជាឋានន្តរនាមរបស់នារីនៅក្នុងវណ្ណៈអភិជន ។ នារីមានឋានន្តរនាមតេង រមែងមានស្វាមីដែលមានឋានន្តរនាម លោញ ។ នៅសម័យអង្គរ តាមសិលាចារឹកផ្សេងៗ គេតែងប្រទះឃើញឈ្មោះនារីប្រកបដោយឋានន្តរនាម តេង ជាច្រើនឥតគណនា ។ ក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវរ្ម័នទី ១ នារីទាំងឡាយប្រកបដោយឋានន្តរនាម តេង បានបញ្ចុះឋានៈរបស់ខ្លួន ដោយអាជ្ញាព្រះមហាក្សត្រ ឱ្យមកត្រឹមអ្នកបំរើនៅក្នុងវត្តអារាមផ្សេងៗ ទៅវិញ ។ ជាមួយនឹងនារីដែលប្រកបដោយឋានន្តរនាម តេង បុគ្គល ឬបុរសប្រកបដោយឋានន្តរនាម លោញ ក៏ត្រូវបញ្ចុះឋានៈរបស់ខ្លួនឱ្យមកនៅជាអ្នកបំរើក្នុងវត្តអារាមដូចគ្នាដែរ ហើយព្រឹត្តិការណ៍បែបនេះ នៅមិនទាន់ទទួលការដោះស្រាយនៅឡើយ ។ នេះជាព្រឹត្តិការណ៍កើតមានឡើងនៅសតវត្សទី ១២ ។

ពាក្យ តេង ជាពាក្យមានកំណើតចេញពីកន្សោមពាក្យ តេងតាង ( តែងតាំង ) នៅក្នុងភាសាបច្ចុប្បន្ន ពាក្យ តែង និងតាំង មានន័យដាច់ចេញពីគ្នា ហើយជួនកាលគេប្រើជាពាក្យសមាស ដូចជា តែងតាំង ។

ឧទាហរណ៍ : លោញ៑ បរតបតិតេង៑ហ្យង៑ loñ para ta pati teṅ hyaṅ

- អំពីពាក្យ តេង៑ត្វន៑ teṅ tvan : ជាឋានន្តរនាមរបស់ស្ត្រីចំណាស់ ហើយមានប្រភពខ្ពង់ខ្ពស់ក្នុងវណ្ណៈអភិជន ។ ពាក្យ teṅ tvan ជាពាក្យសមាស ចេញមកពីពាក្យ ( តែងតាំង ) តេងតាង និង ( ជីដូន ) តួន

ឧទាហរណ៍ : តេង៑ត្វន៑ តយា កំស្តេង៑ teṅ tvan ta yā kaṃsteṅ

K 257 មានន័យថា : ជំទាវ តេងតួន ជាយាយរបស់មហាមន្ត្រីកំស្តេង

តេង៑ត្វន៑ស៑ នំ teṅ tvans naṃ K 258

មានន័យថា : ជំទាវតេងតួន ជាស្នំរបស់ព្រះមហាក្សត្រ

B 2 / ស្តេង៑ / ស្តេញ៑ steṅ / steñ : ពាក្យ steṅ ឬ steñ មានប្រភពពីពាក្យ teṅ ឬ teṅtāṅ ។ ពាក្យនេះ ជាឋានន្តរនាមរបស់ពួកអភិជនដែលមានក្រុមរាជវង្សានុវង្ស មានព្រះសង្ឃក្នុងព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ។

ឧទាហរណ៍ steṅ añ śrīndrā yudolha

ស្តេង៑ អញ៑ ឝ្រីន្ទ្រា យុទោល្ហ

ព្រះអង្គម្ចាស់, ស្រិន្ទ្រាយុទោល្ហ ជាអ្នកដឹកនាំទ័ព ( ជានាមឈ្មោះរបស់បុត្រព្រះបាទជ័យវរ្ម័នទី ៧ ដែលជាសេនាបតីមានជ័យជំនះលើមហាក្សត្រចាម្ប៉ា) ។

ឧទាហរណ៍ : steñ çivā cāryya K 349

ស្តេញ៑អញ៑ឝិវាចារ្យ ព្រះស្តែងសិវចារ្យ

លោកជាអាចារ្យខាងព្រហ្មញ្ញ សាសនា

ឧទាហរណ៍ : steñ devīki ta kvan steñ rau jā devīy K 939 B

ស្តេញ៑ ទេវីកិ ត ក្វន៑ ស្តេញ៑ រៅ ជា ទេវីយ៑

អ្នកម្នាងទេវីកិ ជាកូនស្រីអ្នកម្នាងរៅ បានឡើងជាមហេសីស្តេច

C 2 /  កំស្តេង kaṃsteṅ : ( kaṃsteṅ < steṅ + kaṃ : préfixe )

គឺជាឋានន្តរនាមសំគាល់បុគ្គលដែលស្ថិតនៅក្នុងវណ្ណៈអភិជន ឬមន្ត្រីជាន់ខ្ពស់ទាំងគ្រហស្ថ ទាំងព្រះសង្ឃ ។

ឧទាហរណ៍ : kaṃsteṅ añ vraḥ guru K 257 កំស្តេង អញ ព្រះគុរុ គម្តែង អញព្រះគុរុ គឺជាសាស្ត្រាចារ្យ និងជាទីប្រឹក្សារបស់ព្រះមហាក្សត្រ ។

ឧទាហរណ៍ : kaṃsteṅ añ rājakula mahāmantrī កំស្តេង អញ រាជកុល មហាមន្ត្រី ( ក្នុងរាជ្យជ័យវរ្ម័នទី ៥ )

kaṃsteñ jāhnavī

កំស្តេញ ជាហ្នវី : គម្តែង ជានារី

- កំត្វន kaṃtvan : គឺជាឋានន្តរនាមសំរាប់សំគាល់ព្រះមហាក្សត្រសម័យអង្គរ ជាពិសេស សំគាល់ព្រះបាទសូរ្យវរ្ម័នទី ១ ។ តាមមតិលោក Georges Coedès ថា ពាក្យនេះមានដើមកំណើតពីពាក្យម៉ាឡេ ។ ឋានន្តរនាមនេះ ក្លាយចេញមកពីពាក្យដើមតួន tvan សំគាល់សាច់ញាតិខាងម្តាយ

ឧទាហរណ៍ : ព្រះ កំម្រតេង កំត្វន ស្រី សូរ្យវម្មទេវ

A 3 / លោញ loñ : ជាឋានន្តរនាមក្រុមជនដែលមានប្រភពពីស្រទាប់អភិជន, របស់កូនប្រុសរបស់មន្ត្រីជាន់ខ្ពស់ មន្ត្រីដែលបំពេញមុខងារជាស្ថាបនករ ជាសេនាបតី ( មេទ័ព ) រមែងមានឋានន្តរនាមជា លោញ ។

ឧទាហរណ៍ : លោញ ស្ថាបនាប្រាសាទ

លោញ ហង្ស ជាឧត្តមសេនីយ៍

- តាមសិលាចារឹក មន្ត្រីដែលមានឋានន្តរនាម លោញ អាចឡើងបុណ្យសក្តិ ដោយទទួលឋានន្តរនាម ជាកំម្រតាងអញ ។

B 3 / ក្លោញ៑ / ខ្លោញ៑ kloñ / khloñ : ( kloñ/khloñ < loñ + ka/kha- )

ជាឋានន្តរនាមដែលសំគាល់តួនាទីខ្ពង់ខ្ពស់នៅក្នុងរដ្ឋបាល ឬក្នុងតំណែងសាសនា ។ ជនដែលមានឋានន្តរនាមនេះ ជានាយក ជាអ្នកដឹកនាំ ជាចាងហ្វាង ជាអ្នកគ្រប់គ្រង ព្រោះ ខ្លោញ មានន័យថា ធំ ឬ មេ ។ ពាក្យនេះស្ថិតនៅក្នុងពាក្យសមាសខ្មែរបច្ចុប្បន្ន « មេខ្លោង » ។ មន្ត្រីដែលមានឋានន្តរនាមបែបនេះ គេតែងប្រទះឃើញជាញឹកញាប់ក្នុងសិលាចារឹក នាសម័យមុនអង្គរ ក៏ដូចជានៅសម័យអង្គរដែរ ។

ឧទាហរណ៍ :

ខ្លោញ៑ ဗល khloñ vala K 291 ជាមេទ័ព ជាសេនាបតី
ខ្លោញ៑ វ្នំ khoñ vnaṃ K 340 ជាអធិការវត្តក្នុងព្រហ្មញ្ញសាសនា
ខ្លោញ៑ស្រុក៑ khloñ sruk K 99 : ប្រធានស្រុក, មេស្រុក
ខ្លោញ៑ឃ្លាង៑ khloñ ghlāṅ K 99 : ប្រធានឃ្លាំងមាសប្រាក់
ខ្លោញ៑សិក្សា khloñ sikṣā K 258 : ប្រធាននិស្សិត
ខ្លោញ៑ស្រូ khloñ sru K 957 : អធិការត្រួតពន្ធស្រូវ
ខ្លោញ៑បយ៌្យង៑ khloñ paryyaṅ K 957 : ប្រធានប្រេងឥន្ធនៈ

B 4 - ម្រតាញ៑ខ្លោញ៑ mratāñ khloñ

នៅក្នុងសិលាចារឹកភិមានាកាស K 292 ឆ្នាំ៩៣៣ çaka ស្ដីអំពីសម្បថពួកតម្រួតពលរបស់ព្រះបាទសូរ្យវរ្ម័នទី ១ មានការប្រើឋានន្តនាម mratāñ

khloñ នៅមុខនាមឈ្មោះមន្ត្រីរាប់រយនាក់ ដែលជាមន្ត្រីជាន់ខ្ពស់ ឬជាចៅហ្វាយស្រុក ចៅហ្វាយខេត្ត នាសម័យនោះ ។ មិនតែប៉ុណ្ណោះ ឋានន្តរនាម ម្រតាញខ្លោញក៏អាចត្រូវបានប្រើប្រាស់សំរាប់សំគាល់នូវគណសង្ឃខាងព្រាហ្មណ៍សាសនា ដែលមានឋានន្តរសក្តិខ្ពស់ ។ នៅសិលាចារឹកស្តុកកក់ធំ K 235 កូនប្រុសរបស់ម្រតាញខ្លោញ មានឋានន្តរនាម ឆ្លោញ chloñ ។

ឧទាហរណ៍ :

មានឋានន្តរសក្តិជា ខ្លោញភ្នំ ឬចៅអធិការរបស់វត្តអារាម ។

C 3 / កំលោញ kaṃloñ :

កំលោញ ជាឋានន្តរនាមរបស់ចៅអធិការជាន់ខ្ពស់នៃវត្តអារាម វាមានន័យ ជាខ្លោញ ជាពិសេស ខ្លោញភ្នំ ហើយក្លោញភ្នំ គឺជាចៅអធិការវត្តអារាម ។

ឧទាហរណ៍ : អ្នក បំរេ ក្លោញវ្នំ anak paṃre kloñ vnaṃ K 327 និង K 324 អ្នកបំរើចៅអធិការវត្ត ឬបានសេចក្តីថា « អ្នកបំរើចៅអធិការនៃប្រាសាទ »

B. C 4 /ស្តាច /សំតាច stāc / saṃtāc : ( stāc < tāc + Préfixe : sa - )

ឋានន្តរនាម សំតាច កើតមកពីពាក្យ « ស្តាច » K 259 ជាពាក្យដែលប្រើជំនួសសព្វនាមនៅក្នុងរាជស័ព្ទ ។ ហើយពាក្យ stāc នេះបានក្លាយមកពីពាក្យ « តាច » K 91 ជាកិរិយាស័ព្ទ ដែលមានន័យថា : របូតចេញផុត ។

ឧទាហរណ៍ : **ទ្រង់ សំតាច ស្តាចបង្គំអកក្លោញតំរោ ...**

ព្រះមហាក្សត្រថ្វាយបង្គំធ្វើសក្ការបូជាដល់ព្រះវិហារ bhimaya

សំតាចព្រះគុរុ K 144 សម្តេចព្រះគ្រូ ( ឋានន្តរនាមរបស់ទីប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ ) ។

B. C 5 / វាប៑ vāp : ជាឋានន្តរនាមរបស់មន្ត្រី ឬអ្នកមុខអ្នកការទាំងឡាយដែលធ្វើការនៅតាមស្រុក តាមខេត្ត និងនៅក្នុងព្រះបរមរាជវាំង ។ ឋានន្តរនាមនេះកើតឡើងនៅសម័យអង្គរ ។ នៅក្នុងចំណោមអ្នក ឬបុគ្គល ដែលមានឋានន្តរនាម វាប គេអាចរាប់បញ្ចូលទាំងអ្នកប្រដាល់ អ្នកចំរៀង អ្នករបាំ ពាណិជ្ជករ ដែលនៅក្នុងនោះ មានទាំងអ្នកលក់ ឬអ្នកទិញដី មានទាំងប្រធានស្រុក ថែមទៀត ។

ពាក្យ « វាប » មានប្រភពពីពាក្យ វបា ឬ វាបា នៅក្នុងសិលាចារឹក K 693 និង K 344 ដែលមានន័យថា « ឪពុក » ។

ឧទាហរណ៍ : វាបិ ហ៊ូ ប្រធានស្រុក៑ vāp hū prathana sruk

វាប អម្ឫត ខ្លោញ៑គ្មាល៑ K 262 vap amṛta khloñ gmāl

វាប អម្ឫត ជានាយកនៃក្រុមអ្នកបំរើព្រះមហាក្សត្រ

. ម្យ៉ាងទៀត ឋានន្តរនាម vāp សំរាប់សំគាល់បុគ្គល ដែលស្ថិតនៅក្នុងស្រទាប់ក្រោម នៃវណ្ណៈអភិជន ។

B. C 6 / កុរុង៑ kuruṅ

កុរុង ជាពាក្យដើម ដែលអាចបង្កើតសន្តានពាក្យយ៉ាងច្រើនបែប ឋានន្តរនាម កុរុង បានត្រូវប្រើប្រាស់ចំពោះចៅហ្វាយខេត្តផង ស្ដេចសមន្តរាជផង និងព្រះមហាក្សត្រផង ។

ពាក្យ kuruṅ មកពីពាក្យដើម ruṅ រុង៑ ដែលមានន័យថា ធំ ជ្រៅ ទូលាយ ឧត្ដុង្គឧត្ដម ។

ឧទាហរណ៍ : ក្សុរុង៑ មលេង៑ K 451 kuruṅ maleṅ

ជាឋានន្តរនាមរបស់ស្ដេចសមន្តរាជ នៅសម័យមុនអង្គរ

ឧទាហរណ៍ : មហាអធិរាជតព្រះនាម kuruṅ dharmmāçok K 966

ដែលជាស្តេចនៃព្រឹក្សាផង hai ta jā kuruṅ ហៃ ត ជា កុរុង ព្រឹក្សាផោង ta vṛksā phoṅ K 484

នៅសម័យអង្គរ បច្ចេកពាក្យសំរាប់សំគាល់នូវឋានន្តរនាមផ្សេងៗនៃជនជាន់ខ្ពស់ មិនមែនជាបាតុភូតដោយចៃដន្យទេ ។ ទាំងអស់នេះ ទាក់ទងទៅនឹងការវិវត្តន៍ខាងសាសនា ខាងសង្គមកិច្ច ដែលមានជាអាទិ៍ ការចាត់ថ្នាក់នៃក្រុមជននីមួយៗទៅតាមការបែងចែកមុខងារ ឬទៅតាមក្រុមគ្រួសារនៅសម័យអង្គរ ឬក៏សន្តាននៃជនជាន់ខ្ពស់នីមួយៗ រមែងគ្រប់គ្រងទៅដោយប្រធាននៃសន្តាន ហើយតែកាលណាប្រធាននៃសន្តានមានឋានន្តរនាម ឬមួយទទួលនូវឋានន្តរនាមណាមួយខ្ពង់ខ្ពស់ពីព្រះមហាក្សត្រ ជាធម្មតា សមាជិកនៃសន្តាន ក៏រមែងទទួលនូវឋានន្តរនាមខ្ពង់ខ្ពស់ទៅតាមនោះដែរ ។

យើងតោងយល់ថា ឋានន្តរនាមសម័យអង្គរ ទោះបីមានភាពស្មុគស្មាញក្តី ក៏ឋានន្តរនាមទាំងនោះ រមែងមានដើមកំណើតពីពាក្យដើមមិនច្រើនប៉ុន្មាន ។

ជាបន្តទៅទៀត មានការបែងចែកឋានន្តរនាមសម័យអង្គរ ទៅតាមរបៀបភាសាវិទ្យា ។

B. C 7 ហេង, ហ្យង, ហ្យាង heṅ, hyaṅ, hyāṅ :

ពាក្យនេះមានន័យថា ខ្លាំង ពូកែ ខ្ពង់ខ្ពស់ ។ hyaṅ ច្រើនត្រូវបានប្រើប្រាស់ជាឋានន្តរនាមរបស់នារី ឬក្សត្រី នៃវណ្ណៈអភិជន ឬរាជវង្សានុវង្ស ។

ម្យ៉ាងទៀត ពាក្យ heṅ ឬ hyaṅ មានន័យថា : ខ្យងស័ង្ខ

B. C 8 កញ្ហេង, កញ្ហ្យាង kanheṅ, kanhyāṅ :

ពាក្យនេះ នៅសម័យមុនអង្គរ ជាឋានន្តរនាមប្រើសំរាប់សំគាល់នូវស្ត្រីក្នុងស្រទាប់វណ្ណៈអភិជន ។ ដូចជា ក្សត្រី, ព្រះអង្គម្ចាស់ក្សត្រី នៅសម័យអង្គរពាក្យនេះ ត្រូវបានប្រើប្រាស់ជាសមាសនាម កញ្ហ្យាង កំស្រតាញ តាញ

kanhyaṅ kaṃmratāñ añ មានន័យថា « ព្រះអង្គម្ចាស់ក្សត្រី »

ដូច្នេះ ឋានន្តរនាមនេះប្រើសំរាប់តែសំគាល់ស្ត្រីភេទប៉ុណ្ណោះ ។ ក្នុងភាសាខ្មែរសម័យទំនើប ពាក្យនេះបានត្រូវរក្សាទុកក្នុងពាក្យដូចតទៅ ៖ នាងគង្ហីងព្រះធរណី, កំហែងហនុមាន, រាមាកំហែង « ស្ដេចសៀម ដែលវាយយកក្រុងអង្គរបានជាលើកដំបូង » ។

B. C 9 អាចស - អំចាស acās, aṃcās :

ជាឋានន្តរនាម មានប្រភពចេញមកពីពាក្យ ចស ឬ អ្ចាស ដែលមានន័យថា ៖ ចាស់ បុរាណ , អាយុច្រើន ត្រូវនឹងពាក្យ ៖ ព្រឹទ្ធ vṛddha និងផ្នត់ដែក « - ក- » ។

នៅក្នុងសម័យអង្គរ ឋានន្តរនាមនេះពុំបានត្រូវគេប្រើប្រាស់សំរាប់សំគាល់បុគ្គលនៅក្នុងវណ្ណៈអភិជនទេ ។ ឋានន្តរនាម amcas បានដល់នូវព្រឹទ្ធាចារ្យនៅស្រុកនិមួយៗ ហើយដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងខាងរដ្ឋបាល ខាងចរិយាសាស្ត្ររបស់ស្រុក ជាពិសេស ជាទីប្រឹក្សារបស់ប្រធានស្រុក ។

នៅសម័យមុនអង្គរ ជួនកាលមានការប្រើពាក្យនេះជាមួយ « វ្រះអ្ចាស » គឺជាឈ្មោះរបស់ព្រះសិវៈ ហើយផ្ទុយនឹង «វ្រះកន្មេង» គឺជាឈ្មោះរបស់ព្រះវិស្ណុ ។

ហើយនៅក្នុងភាសាខ្មែរសម័យ ពាក្យនេះបានប្រកបដោយនិយមន័យដ៏ទូលំទូលាយខ្ពង់ខ្ពស់ បានទៅជាពាក្យសំរាប់សំគាល់សមាជិកនៃរាជវង្សានុវង្ស ។ ដូចជាពាក្យ អម្ចាស់ ព្រះអម្ចាស់ ព្រះអង្គម្ចាស់ នអង្គម្ចាស់ អង្គម្ចាស់ ម្ចាស់ ។

B. C 10 អំតេង aṃteṅ :

ជាឋានន្តរនាមដែលបានប្រើនៅសតវត្សទី ១២ សំរាប់សំគាល់នូវវីរជនដែលបានបាត់បង់ជីវិតនៅសមរភូមិ ។

តាមសិលាចារឹក K 685 : ព្រះអំតេងឆ្មា បានត្រូវចារនៅលើរូបបដិ-

មាយុទ្ធជននៅក្នុងប្រាសាទព្រះខ័ន ដើម្បីរំលឹកដល់សេនាបតីតម្រួតពលមួយរូប ដែលបាត់បង់ជីវិត ក្នុងចម្បាំងប្រឆាំងកងទ័ពចាម្ប៉ា ។

B. C 11 សញ្ជាក sañjak :

ជាគោរម្យងារ ឬឋានន្តរសក្តិនៃមន្ត្រីជាន់ខ្ពស់ ដែលមានភក្តីភាពដ៏ខ្ពង់ខ្ពស់ចំពោះព្រះមហាក្សត្រ

អ្នក សញ្ជាក អ្នកសញ្ជាក់ ច្រើនជាសេនាបតីនៃកងទ័ព ។

*២ - ប្រព័ន្ធឋានន្តរនាមក្រុមជាន់ទាប CSI*

យើងបានឃើញហើយថា នៅសតវត្សទី ៦ ទី ៧ នៅក្នុងប្រព័ន្ធក្រុមជនស្រទាប់ក្រោមនៃសង្គម គេឃើញមានការប្រើពាក្យហៅឈ្មោះតែពីរបែប គឺពាក្យ « va វ ឬ vā វា » សំរាប់បុរស និងពាក្យ « ku កុ » សំរាប់នារី ។ វត្តមាននៃពាក្យតែ ២ ម៉ាត់ សំរាប់ប្រើក្នុងការហៅឈ្មោះនៅក្នុងសង្គម នាសម័យសតវត្សទី៦ ទី៧ ជាភស្តុតាងបញ្ជាក់ឱ្យយើងឃើញថា នៅសតវត្សនោះ វណ្ណៈផ្សេងៗនៅក្នុងសង្គម ពុំមានច្រើនទេ ហើយបើយោងទៅលើវណ្ណៈនៃជនស្រទាប់ក្រោម CSI គឺមានពាក្យតែមួយសំរាប់ហៅភេទប្រុស និងពាក្យតែមួយសំរាប់ហៅ ភេទស្រី ។ ប្រៀបដូចជាពាក្យនៅក្នុងភាសាបារាំង « Monsieur លោក និង Madame អ្នកស្រី » ។

ផ្ទុយទៅវិញ នៅសម័យអង្គរមានឋានន្តរនាមច្រើនបែប ច្រើនយ៉ាង សំរាប់សំគាល់ជននៅក្នុងប្រព័ន្ធក្រុមអភិជន CSS ក៏ដូចគ្នានឹងក្រុមជនស្រទាប់ក្រោម CSI ។ ភស្តុតាងបែបនេះ ឬវត្តមានសំរាប់សំគាល់ឋានន្តរនាមច្រើនបែបច្រើនយ៉ាងបែបនេះ បញ្ជាក់ឱ្យឃើញថា នៅសម័យអង្គរដែលជាសម័យនៃការគោរពបូជាទេវរាជា មានការចាត់ថ្នាក់មនុស្សជាច្រើនថ្នាក់ច្រើនជាន់ មានស្រទាប់ច្រើនបែបច្រើនយ៉ាង ។ គ្រាន់តែនៅក្នុងប្រព័ន្ធនៃក្រុមជនស្រទាប់ក្រោម ឬអនិស្សរជន

personnes dépendantes ក៏មានពាក្យច្រើនបែបច្រើនយ៉ាងសំរាប់សំគាល់នូវជនទាំងនោះដែរ ។ តើជនទាំងនោះ គឺជានរណា ?

គេទាំងឡាយ គឺជាអ្នកប្រើកំលាំងដើម្បីបំពេញការងារ គេជាពលករ គឺអ្នកស្រែ អ្នកឃ្វាលគោ ឆ្មាំច្បារដំណាំ អ្នកស្លាបនា អ្នកជីកស្រះ ត្រពាំង ឆ្មាំមាស ឆ្មាំប្រាក់ ឆ្មាំសាលា អ្នកសំអាត បោសសំអាតវត្តអារាម អ្នកចំរៀង អ្នករបាំ តន្ត្រីករ អ្នកត្បាញ រវៃ អ្នករៀបចំម្ហូបអាហារ និងមនុស្សដទៃទៀត ដែលគេហៅថា « ក្ញុំ knum » ឬមួយជា « បំរើ : pamre » ។

ហេតុនេះហើយបានជានៅតាមសិលាចារឹកនានា គេប្រទះឃើញឈ្មោះអ្នកទាំងនេះចារជាអក្សរដ៏ល្អត្រឹមត្រូវ ទុកនៅក្នុងប្រាសាទដើម្បីទុកជាភស្តុតាងទៅអនាគតកាល ថាខ្លួនជាអ្នកបំរើនៅក្នុងវត្តអារាម ឬនៅក្នុងប្រាសាទណាមួយ ជារៀងតទៅ ជូនកាលតដល់កូនចៅ ។

ខាងក្រោមនេះ គឺជាតារាងនៃនាមរបស់ក្រុមជនស្រទាប់ក្រោម CSI នៅសម័យអង្គរ :

| បុរស | នារី | កុមារា | កុមារី |
|---|---|---|---|
| si sī | tai, taiy | si pau | tai pau |
| si rat | tai a | dersi | der tai |
| si lap | tai rat | | |
| si lvan | tai lap | | |
| lap | tai lvan | | |
| gho | | | |
| gvāl | | | |
| si pau | | | |

តាមតារាងនៃស្រទាប់ជនដែលស្ថិតនៅក្នុង Catégorie Sociale Inférieure គឺជនស្រទាប់ក្រោមនៃសង្គម យើងអាចសង្កេតឃើញថា នៅក្នុងក្រុមក្ញុំបំរើ ឬអ្នកបំរើនារី និងក្នុងក្រុមបុរស ឬអ្នកបំរើបុរស គឺមានការចាត់ថ្នាក់ផ្សេងៗគ្នា ដូចតទៅ ៖

ឧទាហរណ៍ ៖ នៅផ្នែកនារី គឺមាន tai a , tai lvan , tai rat

ចំពោះពាក្យទាំងនេះ គេពុំទាន់បានធ្វើការស្រាវជ្រាវ ដើម្បីឱ្យដឹងច្បាស់អំពីមុខងារនីមួយៗរបស់ពាក្យ តៃអ តៃល្វន តៃរត នៅឡើយ ។

ចំពោះក្រុមអ្នកបំរើជាបុរសវិញ ក៏មានការប្រើពាក្យដើម្បីចាត់ថ្នាក់របស់ក្រុមអ្នកបំរើបុរស ដូចជា lap , si rat , si lvan ។ ក្នុងក្រុមអ្នកបំរើជា បុរសមានការសង្កេតឃើញការប្រើពាក្យ ត្វាលិ ក្វាលិ នៅក្នុងសិលាចារឹកនានានាសម័យអង្គរ ។

ពាក្យ ឃោ gho ចេញមកពីពាក្យសម័យមុនអង្គរ ( ឃោឍ ) ghoḍa ប្រែមកថា « បុរស » ។ ប៉ុន្តែពាក្យ ghoḍa នេះ ពុំមានប្រើនៅក្នុងភាសាសំស្ក្រឹតទេ ។ អ្នកស្រាវជ្រាវខ្លះបានពន្យល់ថា ពាក្យនេះមានឫសគល់ចេញមកពីភាសា តាមីល « ទមិឡ » ។

ពាក្យ tai, taiy សព្វថ្ងៃ គឺគ្មានប្រើនៅក្នុងភាសាខ្មែរទេ ប៉ុន្តែគេអាចធ្វើការសន្និដ្ឋានថា ពាក្យនេះ បានបន្ទុកនូវពាក្យសំណល់របស់ខ្លួនក្នុងពាក្យ « កន្សែ » ( កន្សែសារពេជ្ជ ) មហេសីរបស់ព្រះពោធិសត្វ ។

នៅក្នុងសម័យមុនអង្គរ ( សតវត្សទី ៧ ) មានការប្រើពាក្យ « ភ្ញទិ » មានន័យថា « ស្រី » ហើយពាក្យ ២ ព្យាង្គនេះ បានក្លាយទៅជាពាក្យមួយព្យាង្គ គឺពាក្យ « ទៃ » ដែលគេប្រើប្រាស់នៅសម័យអង្គរសំរាប់សំគាល់ក្រុមនារី ដែលធ្វើការនៅក្នុងប្រាសាទផ្សេងៗ ។

ពាក្យ « សិ » ជាពាក្យពិបាករកប្រភពដើមបន្តិច ។ មានជនជាតិ មន ខ្មែរមួយដែលរស់នៅតាមព្រំប្រទល់រវាងប្រទេសឥណ្ឌា និងភូមា ហើយជនជាតិនេះ គេហៅថា « ខាស៊ី khasi » ។

នៅក្នុងសិលាចារឹក Java បុរាណ មានការប្រើពាក្យ si សំរាប់សំគាល់ បុរសដែលបំពេញការងារនៅតាមប្រាសាទបុរាណ ។

ជាមួយនឹងពាក្យ « វា vā » នេះ នៅក្នុងសិលាចារឹក Java ទាំងនោះ ក៏នៅមានប្រើពាក្យ វាប vāp ដែលជាពាក្យចេញមកពីពាក្យ vāpa / vapa ប្រែមកថា « ឪពុក » ។ ដូចយើងបានឃើញមកហើយ នៅក្នុងសម័យអង្គរ ពាក្យ vap សំគាល់នូវមន្ត្រីធុនមធ្យម ហើយជាអ្នកលក់ទិញដី ឬថ្វាយដី ដើម្បីសំណង់ព្រះវិហារ ។ បញ្ហាចោទឡើងថា តើពាក្យ sī និង vāp នេះ ដែលមានប្រើប្រាស់នៅក្នុងសិលាចារឹកខ្មែរសម័យអង្គរ ជាពាក្យដែលភាសាខ្មែរបានខ្ចីមកពីភាសាជ្វា ( Java ) ឬយ៉ាងណា ឬមួយក៏ពាក្យទាំងនេះជាពាក្យដែលមានតាំងពីបរមបុរាណមកនៅក្នុងភាសាខ្មែរផង និងភាសា Java ផង ?

តារាងប្រៀបធៀបឋានន្តរនាមក្រុម CSI

| | សម័យមុនអង្គរ | សម័យអង្គរ |
|---|---|---|
| មនុស្សប្រុស | va, vā | si , sī |
| មនុស្សស្រី | ku, ku yā | tai, taiy |
| | ame | ame |
| កុមារ | pau va | si pau |
| | pau ku | tai pau |
| | kon va ( vā ) | der si |
| | kon ku | der tai |

តាមតារាងចាត់ថ្នាក់ខាងលើនៃស្រទាប់សាមញ្ញជន ( អ្នកបំរើ ) បើយោងទៅតាមទស្សនៈនៃការសិក្សាភាសាវិទ្យា និងប្រវត្តិវិទ្យា គេអាចធ្វើការសន្និដ្ឋានបានថា

- នៅសម័យនគរភ្នំ ឬសម័យមុនអង្គរ ទោះបីមានស្រទាប់ពួក ក្ញុំ ដែលជាអ្នកបំរើ នៅតាមវត្តអារាមក៏ដោយ ក៏ស្រទាប់នៃសង្គមនៅសម័យនោះ ពុំទាន់មានការចែកថ្នាក់ជាវណ្ណៈខាងវិជ្ជាជីវៈផ្សេងៗឡើយ ។

- នៅក្នុងគ្រប់សិលាចារឹកទាំងអស់នាសម័យនគរភ្នំ ពាក្យសំរាប់សំគាល់ស្រទាប់ជនជាអ្នកបំរើ ឬមួយក៏ស្រទាប់នៃពួកក្ញុំ គឺមានតែការប្រើពាក្យ ( va = ប្រុស ) និងពាក្យ ku ក្វ ( = ស្រី ) តែប៉ុណ្ណោះ ហើយនៅក្នុងភាសាសម័យនេះ ពាក្យទាំងពីរនេះ ជាពាក្យប្រើប្រាស់ក្នុងភាសាធម្មតាសំរាប់មនុស្សប្រុសនិងស្រី បានសេចក្តីថា នៅសម័យនោះពុំទាន់មានកំណាកំណើត ឬការចាត់ថ្នាក់មនុស្សជាប្រភេទផ្សេងៗ នៅក្នុងស្រទាប់នៃអ្នកបំរើនៅឡើយ ។

- នៅក្នុងសម័យអង្គរ តាមតារាងខាងលើយើងបានឃើញថា ក្នុងស្រទាប់សាមញ្ញ ជន គឺជនអ្នកបំរើមានការប្រើប្រាស់នូវពាក្យហៅឈ្មោះ appellatifsច្រើនបែបយ៉ាង ។ គេពុំទាន់ដឹងច្បាស់លាស់ ថាតើបានត្រូវប្រើប្រាស់ឡើង ដើម្បីបញ្ជាក់នូវមុខងារដ៏ប្លែកៗ គ្នាច្បាស់លាស់នៃអ្នកទាំងនោះ ។

ក៏ប៉ុន្តែ តើជាមុខងារអ្វីខ្លះ ?

ការនេះតំរូវឱ្យធ្វើការស្រាវជ្រាវដ៏ល្អិតល្អន់តទៅទៀត ដោយប្រៀបធៀបទៅនឹងសិលាចារឹកដទៃទៀត ដូចជា សិលាចារឹកមន ឬសិលាចារឹកជ្វា ជាដើម ។

តាមការប្រើប្រាស់ពាក្យហៅឈ្មោះសំរាប់សំគាល់អ្នកបំរើជាបុរស ឬក៏អ្នកបំពេញការងារជាបុរស គេសង្កេតឃើញការប្រើពាក្យច្រើនបែបយ៉ាងដែរ ប៉ុន្តែ

ឃើញថា ពាក្យហៅឈ្មោះ si ឬ sī មានច្រើនជាងគេ បានសេចក្ដីថា ក្រុមអ្នកបំរើ si , sī ជាមួយនិងក្រុមអ្នកបំរើជាស្ត្រី tai, taiy មាននៅសឹងគ្រប់សិលា-ចារឹកទាំងអស់ បានសេចក្ដីថា ពួកនេះជាអ្នកប្រកបការងារនៅគ្រប់ទីកន្លែង នៅគ្រប់វត្តអារាម តាមប្រាសាទនានា តាមភូមិឋាន ដែលត្រូវ ( ឬបានបង្កើតឡើងដើម្បី ) បំរើដល់វត្តអារាម ។ នៅក្នុងសិលាចារឹក ពួក si ឬ si បំពេញមុខងារដូចពួកជនសាមញ្ញដទៃទៀតផង ហើយមានឋានៈជាឆ្មាំទ្វារ ឆ្មាំច្បារ ឆ្មាំសាលា ឆ្មាំមាស ឆ្មាំប្រាក់ នៅតាមឃ្លាំងនានា គឺជាមុខងារដែលមានការទទួលខុសត្រូវជាទីបំផុត ។

- អ្នកបំរើប្រកបដោយពាក្យហៅឈ្មោះថា gho បើយោងទៅតាមទំរង់នៃនរនាមជាពាក្យសំស្ក្រឹតរបស់អ្នកបំរើទាំងនេះ គេអាចធ្វើការសន្និដ្ឋានបានថា កិរិតនៃឋានន្តរសក្តិអ្នកបំរើ ឃោ ហាក់ដូចជាមានលក្ខណៈខ្ពស់ជាងបណ្តាអ្នកបំរើដទៃ ។ នៅក្នុងសិលាចារឹកខ្លះ បុរសបំរើ ឃោ មានកូនស្រីដែលមានឋានន្តរនាម ជា ទិ ជា ទេខិ ហើយស្ត្រីដែលមានឋានន្តរនាម teṅ រមែងតែងស្ថិតនៅក្នុងស្រទាប់នៃវណ្ណៈអនុធន ហើយតែងតែមានស្វាមីជាបុរសមានឋានន្តរនាម loñ លោញ ឬ vāp ថាបិ ។ នៅក្នុងសិលាចារឹកខ្លះ ពួកបុរសបំរើ ឃោ ជាអ្នកមានដីធ្លី ហើយមានសិទ្ធិលក់ដីធ្លីរបស់ខ្លួនទៀតផង ។

- ពួក ល្វះ នៅពេលស្លាប់ គេច្រើនមិនរាយការណ៍ដល់មន្ត្រីដែលគ្រប់គ្រង ។ គេមិនចាំបាច់សុំមនុស្សមកជំនួសនាទីរបស់អ្នកស្លាប់ឡើយ ។

- អ្មេ ame សំដៅដល់អ្នកបំបៅ អ្នកថែរក្សាក្មេងតូចៗ ។ មកដល់សម័យអង្គរ ពាក្យនេះ ក្លាយជាពាក្យគួរសម me - mer ដែលត្រូវបានគេគោរពតាមរបៀប មាត្ឫបក្ស matr̥pakṣa ( ខ្សែស្រឡាយខាងម្តាយ ) ។

- គ្វុយា ku yā សំគាល់ស្ត្រីដែលគ្មានប្តី ។ នៅក្នុងវត្តព្រហ្មញ្ញ - មានស្ត្រីភាគច្រើនខុសពីវត្តរបស់ពុទ្ធសាសនា ។ វត្តទាំងឡាយពីបុរាណមានសភាព

គគ្រឹកគគ្រេង ដោយសារវត្តមានកម្មសិទ្ធិដ៏ច្រើន ពិសេស មានក្រុមតន្ត្រី មានតន្ត្រីករ អ្នកច្រៀង អ្នករបាំ អ្នកស្មូត្រស្តុតិ ។ល។ នៅក្នុងនោះ ស្ត្រីមានតួនាទីសំខាន់ ទោះជានៅក្នុងសាសនាព្រាហ្មណ៍ ឬព្រះពុទ្ធ ស្ត្រីជាប្រភពនៃការរីកចំរើន និងជាប្រភពនៃការលើកទឹកចិត្តដល់កិច្ចការទាំងពួង ។

ក្នុងបណ្តាពាក្យហៅឈ្មោះស្រទាប់សាមញ្ញ ជនសម័យអង្គរ គឺនៅសល់តែពាក្យហៅថា ji ជិ , ā អា , me មេ ប៉ុណ្ណោះទេ ដែលគេប្រើប្រាស់នៅក្នុងសិលាចារឹកសម័យក្រោយអង្គរ ។

ដោយយោងទៅលើអក្ខរាវិរុទ្ធ ពាក្យហៅឈ្មោះទាំងនេះសំរាប់កំណត់កាលបរិច្ឆេទនៃសិលាចារឹកខ្លះ ដែលត្រូវបាត់បង់កាលបរិច្ឆេទ ។ ដូចយើងដឹងស្រាប់ហើយថា នៅក្នុងការសិក្សាអក្សរសាស្ត្រ ក៏ដូចជាប្រវត្តិសាស្ត្រ ការកំណត់កាលបរិច្ឆេទសិលាចារឹក ដែលត្រូវសិក្សាវាមានសារសំខាន់ណាស់ ។

យើងបានឃើញហើយថា នៅក្នុងសិលាចារឹកសម័យមុនអង្គរមួយណាដែលមានអក្សរ ձ va អាចចាត់ថា ជាសិលាចារឹកដែលសរសេរឡើងនៅសតវត្សទី៦ ឬ ទី៧ ។

ចំពោះសិលាចារឹកណាប្រើពាក្យ ວา va ជាសិលាចារឹកដែលបានសរសេរឡើងរវាងសតវត្សទី ៦, ៧ ឬទី ៧, ៨ ហើយផ្ទុយមកវិញ គេពុំដែលឃើញមានសិលាចារឹកនាសតវត្សទី ៨ ណាមួយ ដែលសរសេរពាក្យ នៅពីមុខសំរាប់ហៅឈ្មោះឡើយ ។

ចំពោះសិលាចារឹក គ្មានកាលបរិច្ឆេទ នាសម័យអង្គរវិញ សិលាចារឹកណាដែលមានប្រើអក្ខរាវិរុទ្ធ ចំពោះការសរសេរពាក្យអ្នកបំរើប្រុសដែលគេហៅថា si ពាក្យសំរាប់សំគាល់អ្នកបំរើស្រី tai တ៌ អាចចាត់ទុកជាសិលាចារឹកដែលត្រូវបានសរសេរឡើង មុនសិលាចារឹកទាំងឡាយណាដែលប្រើពាក្យហៅឈ្មោះ

ដោយសរសេរតាមអក្ខរាវិរុទ្ធ sī, សី ឬអក្ខរាវិរុទ្ធ taiy ទៃយ៍, tai ទៃ ។

ប្រភេទឬលក្ខណៈនៃការសរសេរអក្សរ នៃការប្រើប្រាស់អក្ខរាវិរុទ្ធបែបនេះគឺជាលក្ខណៈ Paléographiques សំរាប់ការកំណត់សម័យកាលរបស់អត្ថបទសិលាចារឹកទាំងឡាយណាដែលបានបាត់បង់នូវកាលបរិច្ឆេទរបស់ខ្លួន ។

ដោយបណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម
សាស្ត្រាចារ្យអក្សរសាស្ត្រ
សាកលវិទ្យាល័យ ភ្នំពេញ
ព្រឹទ្ធសហការី នៃវិទ្យាស្ថានអាស៊ីបូព៌ាសាស្ត្រ
និងជាបណ្ឌិតសភាវិទ្យាសាស្ត្រសហព័ន្ធរុស្ស៊ី

***

*គេឈ្នះសត្រូវរាប់ពាន់នាក់ ក្នុងលានប្រយុទ្ធរាប់ពាន់កន្លែង ។ តែនរជនណាអាចជំនះខ្លួនឯងបាន ជាជ័យជំនះប្រសើរបំផុត ។*

\- ធម្មបទ ១០៣ -

# បញ្ហានៃសិលាចារឹកពីរ

## សម័យមុនអង្គរ ទើបរកឃើញនៅវត្តព្រៃវែង រាជធានីភ្នំពេញ និងលក្ខណៈប្រវត្តិសាស្ត្រ

( ត )

ដោយ : - លោក វង់ សុធារ៉ា
- លោក ឡឹក សាវណ្ណ
- កញ្ញា អ៊ួន ភគិនី

ដឹកនាំដោយ បណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម, ខែ សីហា ១៩៩៦

## វាក្យស័ព្ទសិលាចារឹកវត្តព្រៃវែង ផ្ទាំងទី ១

- សវ្វ sarvva : សព្វ ( បាលី ) មានន័យថា : ទាំងពួង, ទាំងគ្រប់, ទាំងអស់, ទាំងមូល, គ្រប់, ទូទៅ, រាល់

( កិ. ) : មានន័យថា : ពេញចិត្ត, គាប់, ស្មោះស្ម័គ្រ, ត្រូវ, ឥតទាស់

- វ្រះ កម្រតាង៑ អញ៑ vraḥ kamratāṅ añ : ជាគោរម្យងារដែលមានឧត្តមភាពជាងគេ ។ ពាក្យនេះសំរាប់សំគាល់ : អាទិទេពនៅក្នុងព្រហ្មញ្ញសាសនាត្រីមូត្តិ គឺព្រះសិវៈ ព្រះព្រហ្ម និងព្រះវិស្ណុ, ព្រះសម្មាសម្ពុទ្ធ ឬព្រះពោធិសត្វលោកេស្វរនៅក្នុងពុទ្ធសាសនាមហាយាន, ព្រះមហាក្សត្រជាម្ចាស់ដែនដី,[១] ប្រាសាទ, ព្រះ

(១). ជាធម្មតា ប្រជារាស្ត្រតែងចាត់ទុកស្តេចជាមនុស្សមានបុណ្យ ។ នៅសម័យមុនអង្គរ ឋានន្តរនាមរបស់អាទិទេព និងស្តេចដូចគ្នា ព្រោះគេជឿថា « ព្រះមហាក្សត្រ គឺជាតំណាងអាទិទេពនៅលើផែនដី » ។

វិហារ ឬនិវេសនដ្ឋានជាទីសក្ការបូជា ចំពោះព្រះអាទិទេពនៅសម័យមុនអង្គរ ។

- គុិ gui = គឺ

- កាល kāla : កាល, ពេល, វេលា, នៅពេល

- តាងិអញ tāṅ añ : ជាគោរម្យងារនៃមន្ត្រី នៅបរមរាជវាំង ឬនៅតាមខេត្តធំៗ ផ្សេងៗគ្នា ដែលមានឧត្តមភាពជាង ពួកមានគោរម្យងារ « តាងិ » ។ ហើយតាងអញ គឺជាមន្ត្រី « តាង » ដែលត្រូវជាព្រះរាជតំណាងកាន់នូវរាជបញ្ជាទៅអនុវត្ត នៅតាមទីក្រុង ឬជនបទនៃប្រទេស ។

- ប្រតិឞ្ឋ pratiṣtha : គឺអត្ថន័យនៃសេចក្ដីអធិស្ឋាន ឬឧទ្ទិសកុសលមគ្គផលដែលខ្លួនបានធ្វើដល់បុព្វការីជន ឬនរណាម្នាក់, បន់ស្រន់សុំឱ្យសំរេចបំណងផ្សេងៗ មានការបួងសួងសុំពរពីអាទិទេពជាដើម ។

- ទ្រោងdroṅ : ទាំង, និង, ព្រមទាំង, រួមទាំង[(១)] ឬទ្រូង (chest)[(២)]

- វ្រះមហាគណបតី vraḥ mahāgaṇapatī គឺព្រះគនេសដែលជាបុត្រ របស់ព្រះសិវៈ និងនាងទុគ៌ា ។ មានរូបរាងក្បាលជាដំរី ខ្លួនជាមនុស្សជាអាទិទេពខាងកាត់ក្ដី ឬយុត្តិធម៌ ។

---

(១) សិលាចារឹកក្ដីអង្គ K 54 មានប្រើប្រាស់ពាក្យ « droṅ » នេះដែរ ដើម្បីរៀបរាប់មុខអំណោយរបស់ « ពោញសិវទត្ត » ដល់ម្ចាស់ផ្ដើមបុណ្យ ដូចមានពាក្យថា « ... ទ្រោងិក្លុម្ម ទ្រោងិទំទ្រិងិនិរិាណ តោងិតំព្វត គុិ ១០០ ស្លា ... ស្រេតេលិ បោញ៑ គិវទត្ត ឱយិ អាយិ ត អញ ... » ។

(២) សូមមើល : Saveros POU « វចនានុក្រមខ្មែរចាស់ - បារាំង - អង់គ្លេស » page 261 , l - 48 - 49 . Paris 1992 ។

- ស្រី អំវ្រាតកេឝ្វរ śri amvrātakeçvara : ជាឈ្មោះមួយក្នុងចំណោមឈ្មោះដ៏ច្រើនរបស់ព្រះសិវៈ (១) ។

អំវ្រាត ឬ អម្រោត ឬ អាម្រាត មកពីពាក្យសំស្រ្កឹតថា អម្ឫតះ បាលីថា អមតះ គឺមិនស្លាប់ ។

- ហ្វេរ៑ hver : វេរ, ប្រគេន, ប្រគល់, ថ្វាយ របស់ឬវត្ថុអ្វីមួយឱ្យទៅសង្ឃ ឬអាទិទេព ឬព្រាហ្មណាចារ្យ ។

- កន្តៃ kantai : ខ្ញុំបំរើជាស្ត្រីភេទ (២) នៅសម័យមុនអង្គរ ក្រុម

(១) ឈ្មោះអាទិទេពនេះ យើងឃើញមានសរសេរអក្ខរាវិរុទ្ធបីខុសគ្នា គឺ K 8 សរសេរថា : «វ្រះកម្រតាងិអញ ស្រីអម្រាតកេឝ្វរ» K 493 សរសេរថា : « វ្រះកម្រតាងិអញស្រីអាម្រាតកេឝ្វរ» និងទីបីគឺ អក្ខរាវិរុទ្ធដែលយើងឃើញក្នុងអត្ថបទនេះ ។ ប៉ុន្តែ អាទិទេពទាំងនេះ គឺជានិមិត្តរូបរបស់ព្រះសិវៈតែមួយ ដែលមានន័យថា : ព្រះអម្ឫតះ គឺជាឈ្មោះមួយនៅក្នុងចំណោមឈ្មោះទាំង ៣០ របស់ព្រះសិវៈ ។ បើតាមការដកស្រង់ចេញពីសៀវភៅទាំង ៧ ភាគ ដែលបកប្រែដោយលោក ហ្សក សឺដេស យើងឃើញមានឈ្មោះអាទិទេព ដែលមានពាក្យ « ឥឝ្វរៈ ឬឥសះ » នៅខាងចុង ចំនួនប្រហែល ៦០ សិលាចារឹកសម័យមុនអង្គរ ។

ជាការពិត រាល់ឈ្មោះផ្សេងៗគ្នា របស់ព្រះសិវៈត្រូវបានគេប្រើប្រាស់នៅទីស្ថានផ្សេងៗគ្នាដែរ ។ យោងតាមអត្ថន័យនៃឈ្មោះអាទិទេពទាំងនេះ យើងអាចដឹងអំពីការនិយមផ្សេងៗគ្នារបស់បរិស័ទព្រាហ្មណ៍ទៅលើគុណសម្បត្តិ និងពេលវេលាដែលជាអាទិភាពរបស់អាទិទេព និងបង្ហាញនូវកំណត់ធម្មនិដ្ឋា ( ភក្តិកម្ម ) បូជា ហើយចំពោះបទបញ្ញត្តិកម្មដ៏សំបូរបែបនោះ គឺតំកល់សិវលិង្គលើទម្រយោនីនាងទុគ៌ា ឬឧមា ក្រោមការចាត់ចែងពិធីរបស់ព្រាហ្មណ៍បុរោហិត និងអធិបតីភាពរបស់ព្រះមហាក្សត្រ ។

(២) សូមមើលសិលាចារឹកក្តីអង្គ K 54 បន្ទាត់ ១១ ( IC, CIII, 159 - 161, Paris 1951 ) ដូចជាពាក្យ « .... កន្តៃយ៑ម្រតាញ ឝនៃឝ្ចរ អំណោយ៑ តវ្រះកម្រតាងិអញ កុ វ្នៅ ... » ប្រែថា « .... ខ្ញុំបំរើស្រីរបស់ម្រតាញ សនៃស្ចរ ( ថ្ងៃសៅរ៍ ) បានធ្វើជាអំណោយដល់ព្រះវិហារ ខ្ញុំបំរើស្រីឈ្មោះ វ្នៅ .... » ។

នេះ ជាខ្ញុំបំរើនៅតាមប្រាសាទ និងនិវេសនដ្ឋាននានា ។

- ទេវី អញ devī añ : ឈ្មោះទេវីអញ ឬអាចមានន័យថា ភរិយារបស់ខ្ញុំ (?) ទេវី devi មានន័យថា អាទិទេពស្រី, ក្សត្រី ឬព្រះទេពី គឺជាមហេសីរបស់ព្រះមហាក្សត្រ ( ទេវី > ទេពី : មហេសី, ជាយា ) ។

- យជមាន yajamāna : មានន័យថា បូជា ពលិកម្ម ឬ លះបង់ ( sacrifier ) យជមាន គឺការលះបង់, ការបូជា ឬមានន័យម៉្យាងទៀតថា : បព្វជិតអ្នកទទួលខុសត្រូវរៀបចំពិធីបូជាយញ្ញ ( បូជាយជ្ញ ) គឺបន្ទុកជាក្រឡាក្រមនៃបូជនីយ-ដ្ឋាន(១) ។

- តងៃវ្រះ taṅai vraḥ : ថ្ងៃវ្រះ ឬ ថ្ងៃព្រះ គឺថ្ងៃសីលនៃព្រហ្មញ្ញ-សាសនា គឺអាចត្រូវគ្នានឹងពាក្យបច្ចុប្បន្នថា « ថ្ងៃសីល »(២) ។

- វងេជ្នៅ vaṅe jnau : វេជ្នៅ ឬផ្កាជ្នៅ គឺជាផ្កាមួយប្រភេទ ដែល

(១) ការបូជា ឬសែនព្រេន បើតាមព្រហ្មញ្ញសាសនាប្រព្រឹត្តទៅមានប្រាំយ៉ាងធំៗ :

១ - អស្សមេធ : សំលាប់សត្វ

២ - បុរិសមេធ : សំលាប់មនុស្ស

៣ - និរគ្គឡ : ដាក់ទានឱ្យអស់ទ្រព្យដែលមាន

៤ - សម្មាបាស : យកកន្លែងណាដែលជាទីធ្លាក់នៃកាំនឹម ទៅជាកន្លែងបូជា

៥ - វាជបេយ្យ : ផឹកទឹកផ្អែម

សិលាចារឹកភាគច្រើន បានរៀបរាប់អំពីអំណោយជាអ្នកបំរើទ្រព្យសម្បត្តិសត្វ ដើម្បីបូជាចំពោះអាទិទេព ។ ដូចជាសិលាចារឹក K 664, K 46, K 73, K 137, K 423 etc.

(២) ពាក្យនេះគេឃើញមាននៅប្រើក្នុងវាក្យសព្ទភាសាថៃ « វ៉ាន់ផ្រះ » ( jour férié ) គឺសំរាប់សំគាល់ថ្ងៃឧបោសថទាំង ៤ រៀងរាល់ខែ ក្នុងលទ្ធិពុទ្ធសាសនា គឺថ្ងៃ ៨ កើត ៨ រោច ១៥ កើត និង ១៥ រោច ឬ ១៤ រោច ។ សូមមើល IC , CV, 69 - 70, Paris 1953

គេនិយមកាច់យកទៅបូជាព្រះ នាសម័យមុនអង្គរ ។

វងេ : វ្ងេ > ភ្ញី , ផ្កា ឬ ផ្កាភ្ញី

ជ្មោ : ជាឈ្មោះផ្កាឈើដែលយើងឃើញប្រើជាញឹកញាប់ក្នុងសិលាចារឹកសម័យមុនអង្គរ ។

. ទន្ហុំ danhuṃ : ក្លិនក្រអូប, ធុំក្លិនក្រអូប ឬ ធ្វើឱ្យក្រអូប

. បញ្ចុត pañjut : ជាឈ្មោះអាហារមួយប្រភេទ សំរាប់ព្រហ្មណ៍សាសនិក ថ្វាយព្រះ ឬមានន័យម្យ៉ាងទៀតថា : ជូតសំអាត, បោសសំអាត ឬ ជូត (បញ្ចុត < បញ់ + ជុត = ជូត)[(១)] ។

. ចុះសំវះវ្រះ cuḥ saṃvaḥ vraḥ : ចុះសំពះព្រះ ( អាទិទេព ) គឺជាការនៅតាំងចិត្តឱ្យស្ងប់អារម្មណ៍ ផ្សងសច្ចា ឬធ្វើអធិស្ឋានតាមទម្លាប់នៃសាសនា

. កុបន្លាង ku panlāṅ : ស្រីបំរើឈ្មោះ បន្លាង

. តេលិ tel : ដែល ( ឈ្មាប់ )

. វា កន្ទាស៑ vā kandās : ក្ញុំបំរើប្រុសឈ្មោះ កណ្ដាស

. វា ត្វះ vā tvaḥ : ក្ញុំបំរើប្រុសឈ្មោះ ត្វះ ។

ត្វះ < តវះ មានន័យថា តបះ ឬ ការតាំងសីល[(២)]

. វា វងាមន្សោត vā vaṅāmansot : ក្ញុំបំរើប្រុសឈ្មោះវងាមន្សោត[(៣)]

---

(១) ពាក្យ « បញ្ចុត » នេះ យើងកត់សំគាល់ឃើញមានការអះអាងអំពីអត្ថន័យពីរផ្សេងគ្នារបស់បណ្ឌិតខាងភាសាវិទ្យាជាតិខ្មែរពីររូប ដូចដែលយើងបានពន្យល់ខាងលើ មួយគឺ បណ្ឌិត ឡុង សៀម និងមួយទៀត បណ្ឌិត សាវរស់ ពៅ ; សូមមើល Saveros POU « AN OLD KHMER FRENC-ENGLISH DICTIONARY » op - cit p. 295, l- 43,

(២) សូមមើល ជួន ណាត « វចនានុក្រមភាសាខ្មែរ » ភ្នំពេញ ឆ្នាំ ១៩៥៤ ។

(៣) ខ្ញុំបំរើប្រុសឈ្មោះ វងា មួយផ្សេងទៀត ។

វងា : វ៉ា : ផ្កា

មន្ទោតិ : មនិ + សោតិ = មានម្តងទៀត ឬមានម្តងរួចមកហើយ

- វាវងារអញ្ជកាលអសន្ន : vā vaṅā añ kāla asanna : ក្ញុំបំរើប្រុសឈ្មោះ វងារអញ្ជកាលអាសន្ន

អញ្ជកាលអាសន្ន : ក្ញុំនៅពេលមានអាសន្ន, នៅគ្រាមានអសន្តិសុខ, គ្រាដែលរីករររច្រប្ញកច្របល់ បណ្តាលមកពីសង្គ្រាម ឬគ្រោះធម្មជាតិ ។

- វាកន្សេងិ vā kanseṅ : ក្ញុំបំរើប្រុសឈ្មោះ កន្សេង

កន្សេងិ < កនិ + សេងិ = សែង, លើសែង

- ត្មី tmī : ថ្មី ( នៅសម័យអង្គរ និង បច្ចុប្បន្ន )

- កុសេងិ នាអៃ - ku seṅ nā aai - ក្ញុំបំរើស្រីឈ្មោះ សេង នាអៃ

សេងនាអៃ : សែងនៅឯ ( ? )

- វិនាសិ បន្ហេំ vinās panhem̩ : វិនាស ( ខូចខាត, បាត់បង់ ) បន្ទើម ( ធ្វើឱ្យហើម ? )

- កុប្លសិគុណេ ku plas gune : ក្ញុំបំរើស្រីឈ្មោះ ប្លសគុណេ

ប្លសិ : ផ្លាស់, ផ្លាស់ប្តូរ, ជំនួស

គុណេ < គុណ

- កុបលិហដ្ដ ku pali haṭṭa : ក្ញុំបំរើស្រីឈ្មោះ បលិហដ្ត ( ទីប្រជុំជនរាងមូល )

បលិ : មូល, វង់ . រាងមូល

ហដ្ដ : ផ្សារ, ទីលេងមហោស្រព, ទីប្រជុំជន

- កុ អរសិ ku aras : ខ្ញុំបំរើស្រីឈ្មោះ អរស

អរស : មិនស្លាប់, នៅមានជីវិតនៅឡើយ

- កោនិ II kon 2 : កូនចំនួនពីរនាក់
- វាត្មុលិ vā tmul : ក្ញុំបំរើប្រុសឈ្មោះ ត្មុល
ត្មុលិ : ត្មុរិ មានន័យថា គោ គឺគោឈ្មោលសំរាប់ទឹម
- ស្រី ចណ្ឌកាត្យាយិនី śri candakātyāyinī : គឺជាឈ្មោះទេវីមួយអង្គដែលយើងទើបនឹងឃើញជាលើកទី១ ក្នុងសិលាចារឹកសម័យមុនអង្គរ ។
ស្រី : សិរី
- ចណ្ឌ : សំដែងនូវភាពកាច, កំណាច, ក្តៅក្រហល់ក្រហាយ [(១)]
- កាត្យាយិនី < កាត្យាយនៈ kātyāyana បានដល់ស្ត្រីពោរពេញដោយអំណាចមានរូបសម្បត្តិល្អស្រស់ឆើតឆាយ ( Un corps de katyāyinī plein de beauté K 56 ) ជានិមិត្តរូបជាយា ឬសក្តិ ឬមហេសីរបស់ព្រះសិវៈដែលតំណាង ដោយយាជ្ញិកទេវៈ Yājñikadeva គឺសិវៈ រួមសម្ព័ន្ធមេត្រីវាងឧមា ( ឬទុគ៌ា ) មានទម្រ និងសិវលិង្គ [(២)] ។

---

(១) បើចណ្ឌៈ សំគាល់ភាសាកាច កំណាច ទើបពាក្យ ចណ្ឌាល ជាពាក្យដែលសំគាល់នូវស្រទាប់មនុស្សពួកសូទ្រៈ ឬពួជសូទ្រៈ ។ ចណ្ឌាលី សំគាល់ស្រីពូជចណ្ឌាល ក្នុងចំណោមពួកនេះហើយ ដែលមានឈ្មោះស្រីម្នាក់ថា ឆន្ទា ជាស្រីមានចិត្តអាក្រក់ជួរជាតិ តាមផ្តន្ទា ឈ្នានីសតួអង្គកន្សែសារពេជ្ជ ឬព្រះពោធិសត្វ ។

(២) បច្ចុប្បន្ន ទីស្ថានណាដែលធ្លាប់តែមាននិវេសនដ្ឋានតំកល់លិង្គព្រះសិវៈពីអតីតកាលច្រើនតែប្រែឈ្មោះទៅជា « អង្គ » សំរាប់ភ្ជាប់ជាមួយឈ្មោះទីកន្លែងហៅថ្មីនៅទីនោះ ដូចជា អង្គជ័និក ( ក្តីអង្គ ) អង្គរស្មី ( នៅអង្គស្នួល ) អង្គចក ( អតីតឈ្មោះវត្តព្រៃវែង ដែលយើងកំពុងសិក្សា ) ។ ល ។

## វាក្យស័ព្ទសិលាចារឹកនៅវត្តព្រៃវែង ផ្ទាំងទី ២

- ឝក çaka : ត្រូវគ្នានឹងមហាសករាជ ដែលកើតក្រោយគ្រិស្តសករាជ ចំនួន ៧៨ ឆ្នាំ (១) ។

- អាជ្ញាវ្រះកំម្រតាងអញ ājñā vraḥ kamṃratāṅ añ : អាជ្ញាព្រះមហាក្សត្រ ឬព្រះរាជបញ្ជា ឬព្រះអាជ្ញា ( Royal order ) ។

- វ្រះកំម្រតាងអញ ឝ្រីតិលកេឝ្វរ : vraḥ kamṃratāṅ añ śri tilakeçvara : ព្រះអាទិទេពឈ្មោះតិលកេឝ្វរ

- តិលកៈ tilaka មានន័យថា (Clerodendrum phlomoides) ស្នាមសំគាល់ដោយយកក្រមួនពណិ ឬវត្ថុអ្វីផ្សេងទៀត មកចុចនៅត្រង់ចន្លោះចិញ្ចើម ឬចំកណ្ដាលថ្ងាស ដូចគ្នានឹងស្នាមសញ្ញាសំគាល់របស់ស្ត្រីឥណ្ឌាដែលមានប្ដី ឬសញ្ញាលំអនៃស្ត្រីស្រីលង្កា ជាដើម ។

ន័យម្យ៉ាងទៀត គឺស្បែកមួយប្រភេទដែលមានស្នាមឆ្នូត ឬឆ្នួត ឬអាចម៍រុយ ឬគ្រាប់ល្ង ។

---

(១) : ពាក្យថា សៈកៈ នេះ កើតឡើងអំពីជនមួយពួកហៅថា ពួក « ឝាតិ » នៅក្នុងតំបន់មួយខាងទិសពាយព្យប្រទេសឥណ្ឌា, កាលពុទ្ធសករាជ ៦២១ ឆ្នាំ, ជនពួកនេះបានលុកលុយចូលមកវាតអំណាចក្នុងប្រទេសឥណ្ឌាប៉ែកខាងលិច បានតាំងក្សត្រជាតិរបស់ខ្លួន មានព្រះនាមថា សកៈ ( śaka ) ឬសាលិវាហនៈ ( sālivāhana ) ក៏បានតាំងការរាប់ឆ្នាំចាប់ពីមួយរៀងមក, ហៅរបៀបការរាប់ឆ្នាំនេះជាសកៈ ឬសករាជ ដែលចំណោរតមកហៅថា មហាសករាជ ជាប់មានក្នុងប្រទេសយើងរៀងដល់សព្វថ្ងៃនេះ ។

ក្នុងព្រះរាជពង្សាវតារខ្មែរថា ព្រះបាទសម្ដេចព្រះអរិដ្ឋពលពាហនោ ( ព្រះកេតុមាលា ) បានតាំងមហាសករាជ ១ ក្នុងពុទ្ធសករាជ ៦២១ ។ តាមសាស្ត្រាចារ្យ Pierre Lamand ថាព្រះបាទកន្និស្កៈនៅឥណ្ឌា ជាអ្នកចាប់ផ្ដើមសករាជ çaka ។ សូមមើល ពុទ្ធសាសនបណ្ឌិត្យ « វចនានុក្រម ខ្មែរ » គ.ស ១៩៦៧ បោះពុម្ពលើកទី ៥ ទំព័រ ១២៥៦ ។

- តិលកេគ្វរ គឺព្រះតិថិ ឬតិថិទេវ ជាឈ្មោះមួយក្នុងចំណោមឈ្មោះជាច្រើនរបស់ព្រះសិវៈ (១) ។

- តិលកេគ្វរ អាចសំគាល់ថា ជាតួអង្គព្រះសិវៈ ដែលមានលំអដោយស្នាមចុចមួយនៅចន្លោះចិញ្ចើម ឬចំកណ្តាលថ្ងាស គឺព្រះសិវៈដ៏ឆ្នើម ដ៏ល្អ និងអាចជាអាទិទេព ដែលជួយឱ្យផលល្អបានចំរើន ។

- ម្រតាញ កុមារស្វាមិ mratāñ kumārasvāmi : គឺជាមន្ត្រីថ្នាក់មធ្យមម្នាក់ឈ្មោះ កុមារស្វាមិ

កុមារ kumāra ជាឈ្មោះមួយសំគាល់អាទិទេព ស្កន្ធៈ បុត្ររបស់ព្រះសិវៈដែរ ។

ពាក្យនេះ មានន័យថា កូនក្មេង គឺជាមនុស្សដែលមានវ័យនៅចន្លោះទារក និងមនុស្សពេញវ័យ ឬយុវជន ។

ស្វាមិ svāmi គឺជាភរិយា ឬប្រពន្ធ វាមានអត្ថន័យផ្ទុយគ្នានឹងសម័យបច្ចុប្បន្ន ដែលមានន័យថា « ប្តី » ។

- បុណ្យ ឬបុន្យ puṇya, punya : មានន័យថា « ពេញ » ពេញចិត្តពេញថ្លើមនឹងឱ្យ, អំពើជាកុសល, ការធ្វើទាន, អំណោយ ។

(១) តិថិ ដែលជាឈ្មោះមួយទៀត របស់សិវៈ ក្នុងទីនេះ មានន័យច្រើនយ៉ាង ដូចជា : ការធ្វើដំណើរ, មធ្យោបាយ, ផ្លូវ, ស្ទឹង ឬទន្លេ ដែលមានកន្លែងទឹករាក់អាចធ្វើដំណើរឆ្លងកាត់បានដោយរទេះ, ឬផ្នែរជើង ( ford ) ជណ្តើរសំរាប់ដើរចុះទៅខាងក្រោម ឬទៅកាន់មាត់ទឹក, ជាទីកន្លែងធម្មយាត្រា នៅលើផ្លូវខ្សាច់ ប្រកបដោយហ្វូងមនុស្ស ហៅរជាផ្លូវវែងអន្លាយយ៉ាងឧឡារិក, ផ្លូវទៅកាន់ ឬច្រកទៅកាន់អាសនៈបូជា នាចន្លោះនៃចត្វាលៈ ( catvāla ជាប្រហោងមួយនៅក្នុងដីសំរាប់សំណង់ ឧត្តរវេទិ Uttaravedi ) និងឧត្ករ ( Utkara គឺការកំចាត់បង់ ) see, M. MONIER-WILLIAMS " A SANSKRIT-ENGLISH DICTIONARY " p. 449 ។

- ទោង៑ doṅ : ទាំង, និង, ហើយនិង, ព្រមទាំង

ពាក្យនេះវិវត្តមកពីពាក្យទ្រោង droṅ > ទោង៑ doṅ > ទង៑ daṅ : ទាង៑ > ទាំង

- វ្រះកំម្រតាង៑ អញ៑ ឝ្រីរុទ្រមហាលយ vraḥ kaṃmratāṅ añ çrī rudramahālaya : ព្រះវិហារ ឬប្រាសាទឈ្មោះ រុទ្រមហាល័យ

រុទ្រមហាល័យ rudramahālaya មានន័យថា មហាស្ថានរបស់ព្រះរុទ្រ ឬព្រះសិវៈ

- តាង៑រុទ្រទាស taṅ rudradāsa មន្ត្រីថ្នាក់ទាបឈ្មោះ រុទ្រទាស

រុទ្រទាស៑ rudradāsa : ខ្ញុំបំរើរបស់ព្រះសិវៈ ឬពលរបស់ព្រះសិវៈ

- វ្នោក៑ vnok : ពួក ឬពូក ពាក្យនេះមានការវិវត្តន៍ពី :

វ្នោក៑ > វោក៑ vok > វ្វក៑ vvak > ពូក ឬ ពួក

- ផោង៑ phoṅ : ផង ព្រោះគេសរសេរតាមសំលេង ( ផោង > ផង )

ប៉ុន្តែ ចំពោះពាក្យ « ហោង » គេនៅរក្សារូបស័ព្ទដដែល តែគេតែងតែបញ្ចេញសូរថា « ហាង »

- បោញ៑ឝ្រតកីត៌្តិ poñ çratakīrtti : ជាមន្ត្រីម្នាក់ដែលជាព្រះញាតិវង្សស្ដេចឈ្មោះស្រតកិត្តិ çratakīrtti < ឝ្រត ឬឝ្រត៑

srat : ភាពស្មោះត្រង់ + កិត្តិ kirtti ( incorrectly for kirti ) កេរ្តិ៍ឈ្មោះ, ល្បីល្បាញ ( fame or glory )

- អ្មាមហាវិក្រាន្តកេសរី amā mahāvikrāntakesarī : ឪពុកមារបស់វិក្រាន្តកេសរី ( សត្វតោញីដ៏មានរិទ្ធអំណាច )

មហាវិក្រាន្តកេសរី < មហាវិក្រាន្ត : មានអំណាចខ្លាំងក្លា + កេសរី : សត្វតោញី ( កេសរ មានន័យថា លំអងផ្កា )

. បំរេ paṃre : អ្នកបំរើ, ក្ញុំបំរើ, ( servant )

. មុហ្ហនិ muh han < មុហ + ហន

មុហ muh : ច្រមុះ, នៅទល់មុខ ឬនៅខាងមុខ

. ប្រសាទ prasāda : សេចក្ដីជ្រះថ្លាក្នុងហឫទ័យ វត្ថុប្រទានរបស់ព្រះមហាក្សត្រដោយភក្ដិភាព ឬព្រះអំណោយ ( clearness or brightness )

. អំវិ aṃvi : អំពី ( ពេលឥទ្ធិពលភាសាបាលីផ្សព្វផ្សាយទូទៅ ភាគច្រើននៃតួព្យញ្ជនៈ « វ » ត្រូវជំនួសដោយ « ព » )

. កន្លោង្ង kanloṅṅa : ម្ដាយ, មាតា, ព្រះមាតា, ឬប្រាសាទ

. មឡ្យម maddhyama : មធ្យម, ពាក់កណ្ដាល, មជ្ឈិម

. នុ nu : និង, នៅ, នូវ

. បរិចារក paricāraka : អ្នកជំនួយការ, ឧបការី ( assistant ) ឆ្មាំ ( attendant )

. ស្រេបិងិអំលចិលេ លោនវ្រញៃ sre piṅ aṃ lac le lon vrañai

ស្រេបិង sre piṅ : ស្រែបឹង

អំលចិលេ aṃ lac le : អំលចលើ

លោន lon : ពណ៌ក្រហមស្រស់ ( vermillion ) ឬលាបលនដោយលាក់ ( to coat with lac )

. វ្នុរ vnur : ថ្នូរ, ថ្នក, ដីទួលសណ្ដកតាមមាត់ទឹក ឬទន្លេ ឬជាថ្នកខ្សាច់

. បុមង៉ិ pu maṅ : មនុស្សដែលមានឋានន្តរនាម បុ ឈ្មោះ ម៉ង់ (១)

---

(១) : បុ pu . បូ pū បោ po ( បច្ចុប្បន្នទៅជាពាក្យ « ពូ » = ឪពុកមា ) មានន័យថា ម្ចាស់, ព្រះជាម្ចាស់ ជាពាក្យសំគាល់នូវមនុស្ស ដែលគេគោរពនៅមុនសម័យអង្គរ ជាពាក្យមានដើមកំណើតពីពួក អូស្ត្រូអាស៊ីយ៉ាទិក Austro-Asiatique ) ។

- ស្តុកិកន្លេងិប្រសានិ stuk kanleṅ prasān : បឹង (១) កន្លែងឈ្មោះប្រសាន

កន្លេងិ kanleṅ : កន្លែង, ស្ថាន

ប្រសានិ prasān : ដែលសុខសាន្ត, ទីស្ងប់ស្ងាត់

- ស្រេច្ចិងិ sre cdiṅ : ស្រែស្ទឹង

ច្ចឹង cdiṅ : ស្ទឹង

- ពិងិពោញិវ្រៅ piṅ poñ vrau : បឹងរបស់ពោញឈ្មោះវ្រៅ (២)

វ្រៅ vrau ជាឈ្មោះរបស់ជនជាតិមួយក្នុងអំបូរមន-ខ្មែរ

- ស្រេវះវុណ sre vaḥ vuṇ ស្រែឈ្មោះ វះវុណ

វះ : ពុះញែក, បំបែក, វាស់ (៣) វាស់ប្រវែង, វាស់ដី

- ស្រេត្រេយិវ្រៃក្រាយិ sre trey vrai krāy ស្រែនៅឯត្រើយនៃព្រៃដ៏ធំ

ត្រេយិ trey : ត្រើយ

---

(១) ស្តុក : បឹង ឬពេញ ។ ពាក្យនេះ មានទំនាក់ទំនងខាងសេម៉ង់ទិក ( និរុត្តិវិទ្យា ) ជាមួយនឹងពាក្យ « មនបុរាណ » ថា « sduk » និង « sduk pin » ដែលមានន័យថា «ពេញ» សព្វថ្ងៃ ពាក្យនេះមានន័យពីរយ៉ាង មួយគឺ រឹងប៉ឹង, មាំ, ធំ, មានស្តុកស្តម្ភ, ពីរគឺ ព្រៃ, ព្រៃក្រាស ។

(២) សព្វថ្ងៃ ពាក្យ : « វ្រៅ » ទៅជា « ព្រៅ » ដើម្បីសំគាល់ស្ត្រីក្រមុំចាស់, ស្ត្រីមានអាយុច្រើន ហើយនៅតែគ្មានប្តី មួយទៀតឃើញនៅក្នុងសមាសពាក្យ « ច្រះព្រៅ » ដែលជាឈ្មោះ រុក្ខជាតិម្យ៉ាង គេនិយមបេះយកត្រួយបង់ក្នុងសម្លម្ជូរ ។ ម្យ៉ាងទៀត ជាឈ្មោះជនជាតិមួយនៅក្នុងអំបូរមន-ខ្មែរ ដែលរស់នៅភាគខាងជើងកម្ពុជា ។

(៣) គ្រាមភាសានៅឃុំប្រដាក ខេត្តសៀមរាប ( ០៥ វិច្ឆិកា ឆ្នាំ ១៩៩៥ ) គេហៅពាក្យ វាស់ថា វះ ដូចជាពាក្យ : វះដីស្រែចែកគ្នា ។

វ្រៃក្រាយ៑ vrai krāy : ព្រៃដ៏ធំសំបើម ( a huge forest )

. ស្តុក៑ស្លាង៑ stuk slāṅ : ស្តុកស្លែង, ស្តុកដើមស្លែង ឬបឹងដែលមានដើមស្លែង

. ស្រេវ្រះសុវណ្ណលិង្គ sre vraḥ suvarṇna liṅga ស្រែឈ្មោះព្រះសុវណ្ណលិង្គ គឺព្រះលិង្គមាស

. តាង៑ឥឝ្វរ tāṅ içvara : មន្ត្រី ឈ្មោះឥស្វរៈ

ឥឝ្វរ ( សំ. ) > ឥស្សរៈ ( បា. ) មានន័យថា ភាពជាធំចំបង, មិននៅក្រោមបង្គាប់ independant

. ស្រេកន្ទច sre kandac : ស្រែឈ្មោះ កន្ទច ឬកន្ទួច ( កន្ទួត )(១)

. បោញ៑ឝាបត្វេស្រេ poñ çāp tve sre មន្ត្រីឈ្មោះសាប ធ្វើស្រែ

ឝាប៑ çāp < çāpa : បណ្តាសា, បញ្ញត្តិដាច់អហង្ការ ដោយប្រើពាក្យជេរប្រទេច

ត្វេ tve : ធ្វើ ដោយមានការវិវត្តន៍ « ត្វេ - ថ្វេ - ធ្វើ »

. ស្រេជេង្តោច៑ sre jeṅ toc ស្រែឈ្មោះ ជើងតោច

ជេង៑ jeṅ : ជើង

តោច៑ toc : មានន័យថា ដាច់ពីគេ, ម្នាក់ឯង, ឯក ( តូច ? )

---

(១) នៅសម័យក្រោយអង្គរ អក្សរសាស្ត្រខ្មែរ ត្រូវទទួលឥទ្ធិពលពីសៀមមកវិញ ជាពិសេសខ្មែរបាននាំយកអតីតពាក្យរបស់ខ្លួនមកប្រើប្រាស់ ដោយផ្លាស់ប្តូរស្នូរអំណានតាមសំនៀងសៀម ។ ដូចជាព្យញ្ជនៈ « ច » នៅខាងចុងព្យាង្គ សៀមអានទៅស្នូរ « ត » ដូចជាពាក្យ «តម្រាច» សម័យអង្គរ សៀមខ្ចីយកទៅប្រើអានឮស្នូរថា តម្រួត ពេលខ្មែរខ្ចីត្រឡប់មកវិញមិនប្រើ taṃmrvāc បែរជាសរសេរតាមសំនួរសៀម អានថា តម្រួតវិញ ។ ដូចគ្នានេះដែរពាក្យ កន្ទច អាចអានថា កន្ទួត ឬកន្ទួត ។ សព្វថ្ងៃ អតីតស្រែគុរុភ័ណ្ឌមានពីរ ឈ្មោះស្រដៀងនេះគឺ ស្រែកន្ទក់ និងស្រែកន្ទួត ។

- ស្តុកក្រចបិ stuk kracap : បឹងឈ្មោះក្រចាប់
ក្រចបិ kracap គឺឈ្មោះរុក្ខជាតិទឹក ហៅថា ក្រចាប់ (១)

- ច្ទិងមំសារ cdiṅ maṃsār : ស្ទឹងឈ្មោះមំសារ
មំសារ ( សំ ) សាច់ ( la viande, meat )

- រហ្វតមនិ rahvata man : មកអំពីមាន, រហូតមកដល់, មកតាំងអំពី
រហ្វត : រហូត, មកអំពី ....

- វ្រះកំម្រតាង៑អញ៑តទៅឝិវបុរ vraḥ kaṃmratāṅ añ ta dau çivapura : ព្រះមហាក្សត្រដែលត្រូវបានស្តេចយាងទៅកាន់សិវបុរ ឬស្ថានព្រះសិវ គឺត្រូវគ្នានឹងព្រះបាទជ័យវរ្ម័នទី ១ លោក សឺដេស ថា
ពាក្យនេះជាមរណនាម ( posthume ) របស់ព្រះអង្គ (២)

- ឝិវបុរ çivapura : គឺភ្នំបាយ៉ង់ ឬបាយ៉ង់កោ ខេត្តតាកែវ ស្រុកអង្គរបុរី (៣)

- រុទ្រទាស rudradāsa : ក្ញុំបំរើរបស់ព្រះរុទ្រ ឬព្រះសិវៈ ( esclaves de çiva = rudra )

- អជិ aji អ្ជី ajī ជីតា ឬជីដូន ជាគោរម្យងារសំរាប់ហៅមនុស្ស

---

(១) ក្រចាប់ ជាសេវាលជាតិមួយប្រភេទ ដុះតែក្នុង ( បឹង ) ទឹក មានដើមវារដូចកញ្ឆែត ស្លឹកស្តន់ តែមាននែក១ជុំវិញ ផ្កាស ផ្លែមានបន្លា ៤ ស្រួច ដូចស្នែង មានទងជាប់គ្នាស្អេកស្អះ រាយដូចសំណាញ់នៅក្នុងទឹក ។ ផ្លែចាស់មានពណ៌ខ្មៅ គេបេះយកមកស្ងោរហូប, សាច់វាពណ៌ស ផុស១ ។

(២) cf. IC. IC. VII , 64. l 28; **K** 45 IS. IC. C.V 49; **K** 726 A, op-cit, 75; **K** 904B, IC . C . VII , 70 -

(៣) cf. IC . C . VII , op - cit , l 22

ដែលធ្លាប់បួសរៀនចេះដឹងក្នុងសាសនា

មានក្នុង ព្រាហ្មណ៍សាសនា និងពុទ្ធសាសនា

ជិ - ចិ - ឆី អាចមានន័យមួយទៀតថា : ស៊ី, ហូប, ភោគ្គា

- ស្រេបិង៍តំបះ sre piṅ taṃ paḥ : ស្រែ ឈ្មោះ បឹងតំបះ

តំបះ taṃ paḥ < តំ taṃ : វាយ, វាយពីលើ + បះ paḥ : កំរើកឡើង, បះឡើង

ធូលិជេង៍ វ្រះកំម្រតាង៍ អញ duli jeṅ vraḥ kaṃmrataṅ aṅ ជាឋានន្តរនាមរបស់ព្រះនាងជ័យទេវី

ពីព្រោះជាលើកទី ១ ហើយ នៅក្នុងសិលាចារឹកសម័យមុនអង្គរ គេកត់សំគាល់ឃើញប្រើពាក្យ ធូលិជេង៍ នៅខាងមុខឋានន្តរនាមធម្មតារបស់ព្រះមហាក្សត្រ ( វ្រះកំម្រតាង៍អញ )(១)

ទបិ dap : រារាំង ( to hinder ), ឃាមឃាត់ ( obstructs )

សកិ sak : យកចេញ ( to take away ) លួច ( to steal )

ប្រេរោះ pre roḥ : នៅពេលដែលគេកំពុងបំរើ ឬកំពុងប្រើ

ចោកិ cok : ផ្តន្ទាទោស

ឱយិ oy : ឱ្យ, អោយ

ទណ្ឌ daṇḍya : ដាក់ទោស, ករិតទម្ងន់ទោស ។

*( នៅមានត )*

(១) សូមមើល សិលាចារឹកបារាយណ៍ទឹកថ្លា **K 904 B. op-cit**

# ការសិក្សាសម័យថ្មី

## សាលាវត្ត នវសិក្សា ( Ecoles des pagodes sénovées )

នៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៩៥ ខ្ញុំបានជម្រាបជូនអំពីការសិក្សា សម័យបុរាណ [១] ។ ថ្ងៃនេះ ខ្ញុំសូមលើកយកការសិក្សាសម័យថ្មីមកពណ៌នាជូនជាបន្តទៀត ។

ក្រោយឆ្នាំ ១៨៨៤ រាជការអាណានិគមបារាំង មិនគ្រាន់តែធ្វើការកែទម្រង់រចនាសម្ពន្ធគ្រប់គ្រងប្រទេស តែផ្នែកនយោបាយ និងសេដ្ឋកិច្ចសង្គមប៉ុណ្ណោះទេ សូម្បីតែខាងវិស័យសិក្សាធិការ ក៏មានការប្រែប្រួលយ៉ាងជ្រាលជ្រៅផងដែរ ។ តាំងតែពីដើមរៀងមក កូនចៅរបស់ប្រជានុរាស្ត្រទូទៅ បានទទួលការសិក្សាតែពីសំណាក់វត្តអារាមប៉ុណ្ណោះ ។ សូម្បីមកដល់ពេលនេះហើយក៏ដោយ ក៏ការសិក្សាថ្នាក់បឋមរបស់រដ្ឋ នៅពុំទាន់បានរីកសាយទៅដល់ភូមិ ឃុំ ទូទាំងប្រទេសនៅឡើយដែរ ។ ដូច្នេះ កូនចៅអ្នកស្រុក នៅតែបន្តទៅសិក្សានៅវត្តដូចមុនដដែល ។ ប៉ុន្តែ ការសិក្សាតាមបែបគរុកោសល្យថ្មីនេះ មានការខុសប្លែកពីរបៀបរបបរៀនសូត្រពីជំនាន់មុនឆ្ងាយណាស់ ។ សិស្សមានថ្នាក់រៀន មានតុ ជើងម៉ាសំរាប់អង្គុយ មានក្ដារឈ្នួន មានក្ដារខៀន ដីស សៀវភៅអាន សៀវភៅសរសេរ ស្លាបប៉ាក្កា ទឹកខ្មៅ ខ្មៅដៃ ។ ល ។ គ្រូបង្រៀនជាព្រះសង្ឃ សុទ្ធតែត្រូវបានបញ្ជូនឱ្យទៅសិក្សាកិច្ចការគរុកោសល្យ ចិត្តសាស្ត្រ វិធីសាស្ត្រថ្មី នៅតាមមជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូ ដែលបានបង្កើតឡើងនៅស្ទើរតែគ្រប់ខេត្តទាំងអស់ ។ ព្រះសង្ឃ

(១) គិតចាប់តាំងពីសម័យមហានគរណាចក្រភ្នំ រហូតដល់ដើមសម័យអាណានិគមបារាំង ។

ជាគ្រូបង្រៀន ស្ទើរតែទាំងអស់បានទទួលប្រាក់និច្ចភត្ត ( បៀវត្ស ) ខ្លះៗ ពីរដ្ឋ ។

ក្នុងការគ្រប់គ្រង គេមានចាត់តាំងជាខ្សែរយៈ តាំងពីលើរហូតដល់ក្រោម គឺ :

- អគ្គាធិការដ្ឋានទូទាំងប្រទេស តាំងនៅរាជធានី,
- អធិការដ្ឋានប្រចាំខេត្តនិមួយៗ,
- អធិការដ្ឋានប្រចាំស្រុក,

ស្ថាប័នទាំងនេះ មានភារៈមើលការខុសត្រូវទៅតាមមុខការរៀងៗ ខ្លួន ។ កម្មវិធីសិក្សាទូទៅ ត្រូវបានក្រសួងសិក្សាធិការ ចាត់ឱ្យផ្នែកគរុកោសល្យ រៀបរៀងសៀវភៅសិក្សាផ្ញើទៅគ្រប់វត្ត ។ លោកគ្រូបង្រៀនមានភារៈត្រូវបែងចែកពង្រាយកម្មវិធីរួមនេះ ជាឆមាស ត្រីមាស និងប្រចាំខែ ដោយខ្លួនឯងផ្ទាល់ ។ ខុសពីសាលាសិក្សារដ្ឋ សាលាវត្តនវសិក្សា រៀនក្នុងមួយថ្ងៃ តែមួយពេលប៉ុណ្ណោះ គឺចាប់ពីម៉ោងមួយរសៀល រហូតដល់ម៉ោងប្រាំល្ងាច ។ សិស្ស(១) តូចៗ ត្រូវបានអនុញ្ញាតឱ្យវិលទៅដេកឯផ្ទះ ជាមួយគ្រួសាររៀងៗ ខ្លួន ។ ចំណែកឯសិស្សធំៗ (២) លោកគ្រូឃាត់ឱ្យនៅបរិភោគបាយ ហើយដេកនៅវត្ត ដើម្បីរៀនធម៌(៣) អាថ៌ នៅពេលយប់ ព្រមទាំងរៀនលេខនព្វន្តផ្សេងៗបន្ថែមទៀត ។ ម្យ៉ាងទៀតសិស្សថ្នាក់បដិញ្ញាណដ្ឋាន នឹងត្រូវប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ដំបូងដូច្នេះ គ្រូត្រូវខំប្រឹងប្រែងបង្រៀនសិស្សបន្ថែមនៅពេលយប់ ដើម្បីឱ្យសិស្សប្រឡងជាប់ច្រើន ។

---

(១) តាមការសង្កេត កាលនោះពុំសូវមានកូនសិស្សស្រីទៅរៀននៅសាលាវត្តទេ ព្រោះគេយល់ថាស្រីៗ មិនចាំបាច់ចេះអក្សរក៏បាន ។

(២) សិស្សដែលមានអាយុ : លើសពី ១០ ឆ្នាំឡើងទៅ ។

(៣) រៀនសូត្រធម៌ថ្វាយបង្គំព្រះ គឺពុទ្ធគុណ ធម្មគុណ សង្ឃគុណ ជាដើម ។

សាលាបឋមសិក្សា ( សាលាវត្ត ) ចែកជាបីថ្នាក់សិក្សា [១] គឺ :

- ថ្នាក់កុមារដ្ឋាន ( Cours enfantin )
- ថ្នាក់បរិវច្ឆនដ្ឋាន (Cours prépratoire )
- ថ្នាក់បដិញ្ញាណដ្ឋាន ( Cours élémentaire )

លោកគ្រូបង្រៀនសាលាវត្ត អនុញ្ញាតឱ្យសិស្សចូលរៀនចាប់ពីអាយុ ៧ ឆ្នាំ ឡើងទៅដល់អាយុ ១៥ ឆ្នាំ ។ វត្តមួយចំនួនតូច មានគ្រូបង្រៀនគ្រប់ទាំងបីថ្នាក់ ។ វត្តខ្លះទៀត មានគ្រូបង្រៀនតែមួយអង្គ ។ ក្នុងករណីនេះ គេត្រូវប្រមូលសិស្សទាំងបីថ្នាក់មកអង្គុយរៀនរួមគ្នា ក្នុងថ្នាក់តែមួយ ដែលគេហៅថា ថ្នាក់បង្រួម ( Classes réunies ) ។ ថ្នាក់បង្រួមរបៀបនេះ ធ្វើឱ្យលោកគ្រូមានការលំបាក និងនឿយហត់ច្រើន ព្រោះត្រូវបង្រៀនដូរវិលជាប់ ពីថ្នាក់មួយទៅថ្នាក់មួយ ពុំមានពេលសំរាកឡើយ ។ ជួនកាលលោកគ្រូ បានចាត់សិស្សពូកែណាម្នាក់ នៅថ្នាក់បដិញ្ញាណដ្ឋាន ជាជំនួយក្នុងការបង្រៀន និងគ្រប់គ្រងថ្នាក់កុមារដ្ឋាន ។

សំរាប់ថ្នាក់កុមារដ្ឋាន លោកគ្រូចាប់ផ្តើមបង្រៀនព្យញ្ជនៈរៀងតាមលំដាប់មុនក្រោយ តាំងពី ក. ខ. គ. ឃ. ង. រហូតដល់ ស. ហ. ឡ. អ. [២] ។ បន្ទាប់មក ត្រូវរៀនស្រៈនិស្ស័យទាំង ២១ តួ គឺស្រៈ ា ិ ី រហូតដល់ស្រៈ ាំ ះ ុះ េះ ោះ ។ បន្ទាប់ពីស្រៈនិស្ស័យ លោកគ្រូបង្រៀនស្រៈពេញតួ គឺស្រៈ អ អា

---

(១) ដូចគ្នា និងសាលាបឋមសិក្សាជាន់ដំបូងរបស់រដ្ឋដែរ ប៉ុន្តែ ខុសគ្នាតែកម្មវិធីសិក្សាខាងភាសាបារាំង និងមុខវិជ្ជាឯទៀតៗ ដែលសាលាវត្តពុំបានសិក្សាស៊ីជំរៅឡើយ ព្រោះសាលារដ្ឋរៀនពីរពេល ( ព្រឹក - ល្ងាច ) ឯសាលាវត្ត រៀនតែមួយពេល ។ ឯការបណ្តុះបណ្តាលគ្រូក៏ធ្វើពុំសូវបានហ្មត់ចត់ ដូចសាលារដ្ឋដែរ ។

(២) កាលណោះ លោកគ្រូបង្គាប់ឱ្យថា ( អ្នំ = អាំង ) មិនមែន ស. ហ. ឡ. អ. ដូចឥឡូវនេះទេ ។

ឥ ... រហូតដល់ ឯ ឰ ឱ ឪ អុំ អំ អាំ អះ ។ ទាល់តែរៀនចប់ចាំអស់ព្យញ្ជនៈ ៣៣ តួ ស្រះនិស្ស័យ ស្រះពេញតួ ទើបលោកគ្រូបង្រៀនបំបែក (១) ទៅតាមលំដាប់រៀង ពី :

ក កា កិ កី ..... កុំ កំ កាំ កះ កុះ កេះ កោះ

ខ ខា ខិ ខី ..... ខុំ ខំ ខាំ ខះ ខុះ ខេះ ខោះ

គ គា គិ គី ..... គុំ គំ គាំ គះ គុះ គេះ គោះ

ឃ ឃា ឃិ ឃី ..... ឃុំ ឃំ ឃាំ ឃះ ឃុះ ឃេះ ឃោះ

... រហូតដល់ អ អា អិ អី ... អុំ អំ អាំ អះ អុះ អេះ អោះ គឺរៀនរៀងតាមលំដាប់យ៉ាងនេះ មិនហ៊ានផ្លោះរំលងមុនជាក្រោយឡើយ ។ កាលណារៀនបំបែកចប់ហើយ លោកគ្រូ បន្តបង្រៀនផ្ញើជើង (២) ។ ការរៀនពីផ្ញើជើងក៏តែងតែគោរពទៅតាមលំដាប់ស្រះនិស្ស័យ តាំងពីដើមដល់ចប់ដែរ ។

ឧ. ខ្ល ខ្លា ខ្លិ ខ្លី ; ក្រ ក្រា ក្រិ ក្រី ; ខ្ច ខ្ចា ខ្ចិ ខ្ចី ។ល។ ការបង្រៀនប្រកប (៣) ត្រូវធ្វើជាបន្ត បន្ទាប់ពីសិស្សបានរៀនផ្ញើជើងបានចេះចាំស្ទាត់ហើយ ។ សូមជម្រាបថា ការផ្លាស់ពីដំណាក់មួយ ទៅដំណាក់មួយទៀតនោះ ត្រូវតែឆ្លងកាត់ការសាកល្បង គឺ លោកគ្រូរកពាក្យឱ្យសិស្សសរសេរនៅក្ដារឈ្នួន ជាពួក ឬហៅសិស្សមកប្រដៅម្ដងម្នាក់ៗ ដោយឱ្យសរសេរពាក្យណាមួយ នៅក្ដារខៀននៅចំពោះមុខសិស្សឯទៀត ឬក៏ឱ្យសិស្សអាននូវពាក្យដែលបានរៀនរួចហើយ ។ កាលណាគ្រូពិនិត្យឃើញថា សិស្សភាគច្រើនដាច់ខាត ចាប់បាន តាមទាន់ នូវចំណេះដែលបានបង្រៀននោះ ហើយទើបអនុញ្ញាតឱ្យបន្តការរៀនទៅក៏រិតលើទៀត ។ នៅ

(១) គឺយកព្យញ្ជនៈ មកផ្សំនឹងស្រះនិស្ស័យ ។

(២) គឺយកជើងព្យញ្ជនៈខ្លះ ទៅដាក់ពីក្រោមព្យញ្ជនៈផ្សេងទៀត ដើម្បីផ្សំសូរពីរបង្រួមបញ្ចូលគ្នាឱ្យកើតជាសំឡេងបញ្ចុះ ដែលមានតែ ១ព្យាង្គ ឧ. ស្វ ខ្វ ក្រ ភ្ល ។ល ។

(៣) គឺយកព្យញ្ជនៈមួយ ទៅផ្សំនិងព្យញ្ជនៈមួយទៀត ដើម្បីបង្កើតឱ្យបានជាសំឡេងមួយ ។

ដំណាច់ឆ្នាំសិក្សា សិស្សថ្នាក់កុមារដ្ឋានត្រូវចេះអានបានរត់មាត់ ( Lecture courante ) ។ ខាងវិជ្ជាលេខនព្វន្ត សិស្សត្រូវចេះសរសេរ និងរាប់ពីចំនួន ១ ដល់ ១០០ និងចេះធ្វើលេខ បូក លេខសង [១] មាន ឬគ្មានត្រាទុក ពីរខ្ទង់ និងចំណោទងាយៗ ។ ហើយសិស្សក៏ត្រូវចាំមេលេខ ពីមេ ២ ដល់មេ ៩ យ៉ាងស្ទាត់ដែរ ។ សូមជម្រាបថា ការបង្រៀនមេលេខនេះ មិនមែនធ្វើតាមសិស្សម្នាក់ៗ ទេ គឺបង្រៀនរួមគ្នាតែម្តង ដោយឱ្យសិស្សទាំងអស់សូត្រមេលេខចាប់ពីមេ ២ រហូតដល់មេ ៩ រៀងរាល់ល្ងាច មុននឹងឱ្យសិស្សចេញទៅផ្ទះ ។ ធ្វើយ៉ាងនេះដដែលៗ រៀងរាល់ថ្ងៃ សិស្សតូចៗ អាចចាំបានដោយឯងៗ ពុំចាំបាច់ទន្ទេញរៀងៗខ្លួនដូចសព្វថ្ងៃនេះឡើយ ។

នៅសាលាវត្ត សិស្សមិនឈប់ថ្ងៃអាទិត្យ ឬថ្ងៃព្រហស្បតិ៍ ដូចសាលារដ្ឋទេ គេឈប់សំរាករាល់ថ្ងៃសីល [២] ( មួយខែ ៤ ដង ) និងរាល់ថ្ងៃបុណ្យសាសនាផ្សេងៗ ដូចជា បុណ្យកឋិន បុណ្យផ្កា មាឃបូជា វិសាខបូជា ភ្ជុំបិណ្ឌ ជាដើម ។ នៅចុងឆ្នាំសិក្សា លោកគ្រូពិនិត្យវាយតម្លៃ ដើម្បីរៀនបន្តទៅថ្នាក់លើទៀត ។ នៅចុងឆ្នាំសិក្សា សិស្សថ្នាក់បឋមញ្ញាណដ្ឋាន ត្រូវប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សាជាន់ដំបូង [៣] ( Certtificat d'étude primaire élémentaire ) ។ គេតែងយកវត្តដែលព្រះអនុគណគង់នៅ ជាមជ្ឈមណ្ឌលប្រឡង ។ សម័យប្រឡង សិស្សថ្នាក់បឋមញ្ញាណដ្ឋានគ្រប់វត្ត [៤] ក្នុងស្រុកទាំងមូលនាំគ្នាមកដេកស្នាក់នៅក្នុងវត្តអនុគណ ដើម្បីរង់ចាំប្រឡង ។ វិញ្ញាសារប្រឡង មាន ៣ គឺ : តែងសេចក្តី

---

(១) សព្វថ្ងៃគេហៅថាលេខ ដក ។ (២) ថ្ងៃ ៨ កើត, ៨ រោជ, ពេញបូណ៌, ខែដាច់, គឺមិនមែនឈប់រាល់ថ្ងៃអាទិត្យ, ព្រហស្បតិ៍ ដូចសាលារដ្ឋឡើយ ។ (៣) កាលណោះគេនិយមហៅថា សញ្ញាប័ត្រសាលាវត្ត ។ (៤) ជំនាន់នោះ សិស្សត្រូវធ្វើដំណើរតាមរទេះគោ រទេះសេះ ជិះដំរី ពីវត្តឆ្ងាយៗ មកកាន់វត្ត

សរសេរតាមសូត្រ ( សរសេរតាមអាន ) និងចំណោទ ( ចំណោទពីរ ) ដែលត្រូវការពេលវេលាពេញមួយថ្ងៃ ។ ពេលព្រឹក សិស្សត្រូវធ្វើវិញ្ញាសា : តែងសេចក្តី និងសរសេរតាមអាន ។ ឯវិញ្ញាសាចំណោទពីរ ត្រូវធ្វើនៅពេលរសៀល ។ នៅថ្ងៃប្រឡង លោកប្រធានបុស្តិ៍រដ្ឋបាលប្រចាំស្រុក ដែលជាវេស៊ីដង់ប្រចាំស្រុក និងជាតំណាងលោកវេស៊ីដង់ខេត្ត អញ្ជើញមកជាអធិបតីក្នុងពិធីប្រឡង ។ លោកអញ្ជើញដើរមើលបេក្ខជនធ្វើវិញ្ញាសា នៅតាមបន្ទប់ប្រឡងដោយផ្ទាល់ ដោយមានមន្ត្រីសាលាស្រុកជាតិខ្មែរ និងអាវុធហត្ថ (១) ជាតិបារាំង ហែរហមមកជាមួយផង ។ កាលណោះ សិស្សសាលាវត្តណាប្រឡងជាប់សញ្ញាប័ត្រនេះ គេចាត់ទុកជាកិត្តិយសធំណាស់ ។ សាម៉ីខ្លួន និងឪពុកម្តាយ រីកមុខរីកមាត់ដោយសារមានសញ្ញាប័ត្រនេះព្យួរនៅជញ្ជាំងផ្ទះ ។ សិស្សសាលាវត្តណាបានប្រឡងជាប់សញ្ញាប័ត្រនេះ អាចចាត់ថា បានបញ្ចប់ការសិក្សាជាន់ដំបូងជាស្ថាពរហើយ ។

នៅពេលនេះ សិស្សអាចមានច្រកបី :

ក/ ទៅបន្តការសិក្សានៅសាលារៀបរយរបស់រដ្ឋ (២)

ខ/ សិស្សអាចបួសជាសាមណេរក្នុងវត្តដែលខ្លួនរៀន

គ/ សិស្សអាចផ្អាកការសិក្សាត្រឹមនេះ ហើយវិលមកប្រកបការងារស្រែចំការ ជាមួយឪពុកម្តាយវិញ ។

កាលណោះ ពិតមែនតែយើងបានកែទម្រង់ខ្លះៗ អំពីរបៀបរបបសិក្សាពីសម័យបុរាណ ក៏ប៉ុន្តែ អាស្រ័យដោយព្រះសង្ឃជាគ្រូបង្រៀន ត្រូវបំពេញភារកិច្ច

---

(១) ខ្មែរហៅ សង់ដាម ( Gendarme ) ។

(២) សិស្សសាលាវត្ត ប្រឡងជាប់សញ្ញាប័ត្របឋមសិក្សាជាន់ដំបូង ត្រូវបានអនុញ្ញាតឱ្យរៀនត្រឹមថ្នាក់ បរិវច្ឆនដ្ឋាន ( Coms préparatione ) ព្រោះសិស្សសាលារដ្ឋ ( កាលណោះគេហៅថា សា លាបារាំង ) មានកម្មវិធីសិក្សាភាសាបារាំងចាប់ពីថ្នាក់នេះទៅ ។

ផ្សេងៗ ក្រៅពីធ្វើគ្រូបង្រៀន ហើយការបំពាក់អំពីកិច្ចការគរុកោសល្យទៀតសោត ក៏នៅមានកំរិត ម្ល៉ោះហើយ យើងនៅពុំទាន់បានទទួលលទ្ធផលខ្ពស់នៅឡើយ ។ តែទោះជាយ៉ាងនេះក្តី ក៏យើងបានបោះជំហានមួយយ៉ាងវែង ឆ្ពោះទៅរកការសិក្សាមួយទំនើបជាបង្គួរ ។ យើងអាចមានមោទនភាពម្យ៉ាងទៀតថា : កូនខ្មែរមានវាសនាបានទទួលឋានៈជាអក្ខរជនជិតទៅ ៩០% ( កៅសិបភាគរយ ) អាស្រ័យដោយគុណដ៏ថ្លៃថ្លានៃសាលាវត្តនេះឯង ។ បច្ចុប្បន្ន មន្ត្រីរាជការតាំងពីថ្នាក់តូច រហូតដល់ថ្នាក់រដ្ឋមន្ត្រី សុទ្ធតែមានអតីតកាលជាសិស្សសាលាវត្ត មានគ្រូបង្រៀនជាព្រះសង្ឃ ។ សិស្សគណទាំងអស់នៅតែគោរពដឹងគុណគ្រូព្រះសង្ឃសាលាវត្ត ទុកដូចជាអ្នកដឹកដៃ ជាអ្នកបើកភ្នែកឱ្យខ្លួនបានភ្លឺស្វាង បានដើរត្រង់ទៅតាមផ្លូវនៃអរវឌ្ឍនភាព ។

ដោយ **មៀច ប៉ុណ្ណ**
ប្រធានការិយាល័យទំនៀមទំលាប់ខ្មែរ

*មនុស្សល្ងង់ដែលគិតថាខ្លួនល្ងង់ ជាបណ្ឌិត ។ តែមនុស្សល្ងង់ដែលគិតថាខ្លួនជាបណ្ឌិត ពិតជាមនុស្សល្ងង់ ។*

. ធម្មបទ ៦៣ .

# បទ ក ខ

## វាចារំលឹក

នៅក្នុងកម្ពុជសុរិយាលេខនេះ ខ្ញុំមានសេចក្ដីរីករាយនឹងចម្លងជូនអត្ថបទកំណាព្យពីរទៀតរបស់លោក អៀង សាយ ដែលមានឈ្មោះថា " បទ ក ខ " ។

ដូចខ្ញុំបានបញ្ជាក់រួចមកហើយ នៅក្នុងកម្ពុជសុរិយាលេខ ៤ ឆ្នាំ ១៩៩៦ អំពីបទ " ន មោ " ការរៀនអាន និងរៀនសរសេរអក្ខរក្រមខ្មែរ ក៏ដូចគ្នាដែរ ។ កុមារត្រូវរៀនរាប់ព្យញ្ជនៈទាំង ៣៣ តួ គឺរាប់ពី ក ទៅដល់ អ ។ ជួនកាលលោកឱ្យរាប់ពី អ រហូតមក ក វិញ ។ លោកឱ្យធ្វើរបៀបនេះ លុះត្រាតែកុមារចាំស្ទាត់ គឺស្គាល់ព្យញ្ជនៈនីមួយៗអស់ ទើបលោកឱ្យរៀនបំបែក ។

លោក អៀង សាយ បានយកអក្ខរក្រមខ្មែរយើងមកលើកជាកំណាព្យដាក់ក្នុងសៀវភៅរបស់លោកឈ្មោះ " មេកាព្យ " ។ ក្នុងការចងជាកំណាព្យនេះ លោកយកព្យញ្ជនៈនីមួយៗ តាមលំដាប់របស់វា មកផ្ដើមឃ្លានីមួយៗនៃកំណាព្យ ដោយពាក្យបន្ទាប់ពីដើមឃ្លា ត្រូវកើតចេញពីព្យញ្ជនៈដដែល ។

ខ្ញុំបានអានកំណាព្យនេះ នៅក្នុងពាក់កណ្ដាលទសវត្សទី ៦០ ។ តាំងពីនោះមកជាង ៣០ ឆ្នាំហើយ ខ្ញុំនៅតែចាំស្ទាត់រហូតមក ។

ព្រមជាមួយនឹងសេចក្ដីកតញ្ញូ កតវេទី និងសេចក្ដីឧទ្ទិសដ៏ខ្ពស់ របស់ខ្ញុំចំពោះបុព្វបិតាយើងដែលបានចែកឋានទៅហើយ ខ្ញុំសូមចុះស្នាដៃរបស់លោកទុកជាឯកសារគំរូ និងគ្រាន់ជាការអានកំសាន្តផង ។

**ឆន់ ហ៊ិន**

## បទ ក ខ ( ទី១ )

ក កើតជាមនុស្សក្នុងលោកិយ
ខ ខំឃ្នាតខ្មីរករៀនធ្វើ
គ គិតឱ្យគ្រប់សព្វអន្លើ
ឃ ឃើញអំពើពេញជាមនុស្ស ។
ង ងាកឆ្វេងស្តាំមើលគេឯង
ច ចេះចាត់ចែងបែងឱ្យផ្តុះ
ឆ ឆើតកើតការយ៉ាងណានោះ
ជ ជាតិជាមនុស្សឱ្យដូចគេ ។
ឈ ឈានជើងដើរគិតរំពឹង
ញ ញើតរិលរឹងបើទំនេរ
ដ ដើរទៅណាឥតការទេ
ឋ ឋិតឋានថេរវិលមកផ្ទះ ។
ឌ ឌិនអង្គាំមាសកែវកង
ឍ ឍនធានផងបើមានខ្លះ
ណ ណា១ល្អកុំប្រើណាស់
ត តិចទុកផ្លាស់ប្តូរម្តង១ ។
ថ ថប់ចំប្រប់ចំពោះពាល
ទ ទើបមិនរោលរាលសៅហ្មង
ធ ធៀបពួកពាលដូចពស់ផង
ន នឹកប៉ុនប៉ងជៀសឱ្យឆ្ងាយ ។

ប បើមនុស្សល្អមានធម៌ពិត

ផ ផុតគំនិតពាលទាំងឡាយ

ព ពិតជាពុំឱ្យអន្តរាយ

ភ ភឿនជិតឆ្ងាយជាមិត្តស្និទ្ធ ។

ម មាមីងក៏ដូចឪម៉ែ

យ យើងគួរតែរួបរួមរឹត

រ រកវៀនច្បាប់ខ្មែរឱ្យល្អិត

ល លៃលកចិត្តគិតផ្គូរផ្គង ។

វ វង្សាល្អត្រូវដើរតាម

ស ហ សុំហាមរឿងឆ្គាំឆ្គង

ឡ ឡើងស័ក្តិយសឈ្មោះល្អផង

អ ឥតឱ្យហ្មងនឹងច្បាប់ខ្មែរ ។

* * *

## បទ ភខ ( ទី ២ )

ក កាន់ដងប៉ាកកាជញ្ជីង

ខ ខំរំពឹងតែងសេចក្តី

គ គិតគួរឱ្យគួរគប្បី

ឃ ឃើញឃ្លាឃ្លីសេចក្តីល្អ ។

ង ងឹតងិតជិតភ្លើងចង្កៀង

ច ចាត់ចែងព្រាងផ្ទៀងអក្សរ
ឆ ឆាប់ចាប់យករកពាក្យត
ជ ជាប់ចូនល្អក្រធ្វើបាន ។
ឈ ឈោងជ្រលក់ទឹកខ្មៅថែម
ញ ញឹមញញែមដោយដឹងដាន
ដ ដាក់ស្រោមស្រេចផ្ញើមកថ្កាន
ឋ ឋិតដល់ឋានអូនពិសី ។
ឌ ឌីដងលេងក្រែងអាណិត
ឍ ធៀបមើលចិត្តក្រែងមេត្រី
ណ ណែនសែនឆ្ងល់ស្ងួមប្អូនស្រី
ត តបសេចក្ដីឱ្យបងដឹង ។
ថ ថាបើខ្លួនបងស្ងួមស្ម័គ្រ
ទ ទួលរាក់ទាក់ឬមួយខឹង
ធ ធុញថប់អ្វីស្រីព្រលឹង
ន នាងរំពឹងឱ្យវែងឆ្ងាយ ។
ប បើបងនៅកំលោះស្អាត
ផ ផុតបទបាទបែបបរិយាយ
ព ពេញជាប្រុសដែលស្រីស្ដាយ
ភ ភូមិនៅអាយជិតអូនផង ។
ម មានតែអូនសណ្ដានចិត្ត
យ យកជាមិត្តឥតមានហ្មង
រ រកប្រុសណាក្រៅពីបង

ល លែងនូនល្អងឱ្យមេម៉ាយ ។
វ វង្សត្រកូលបណ្ដូលវៀម
ស សូមប្ដូរឈាមឱ្យវែងឆ្ងាយ
ហ ហេតុហ្នឹងហើយគួរឱ្យស្ដាយ
ឡ អ ឡើងរវាយមករកអ្វូន ។

* * *

*មិនមែនដោយសារមានក្បាលកោរ, ប៉ុន្តែ មានចិត្តក្រឡិចក្រឡុច, និយាយកុហកបោកប្រាស មានឈ្មោះថា « អ្នកបួស » នោះទេ ។ ធ្វើជាអ្នកបួសយ៉ាងម៉េចកើត បើសន្ដានចិត្តខ្លួនពោរពេញដោយ ឥច្ឆាឈ្នានីស និងលោភៈនោះ ។*

ធម្មបទ គាថាទី ២៦៤ . ឈ. អ.

# សាស្ត្រាក្រឹត្យក្រម

ក.ក.ន. ពុទ្ធសាសនបណ្ឌិត្យបានទទួលសាស្ត្រាក្រឹត្យក្រមនេះពីវត្តកំពង់សំបួរ ស្រុកកោះធំ ខេត្តកណ្តាល ។ គួរឱ្យស្តាយណាស់ ដោយកវីដែលបានសរសេរកំណាព្យនេះ មិនបានប្រាប់ឈ្មោះឱ្យអ្នកជំនាន់ក្រោយបានស្គាល់ ទាំងកាលបរិច្ឆេទនៃការតែងនិពន្ធ ក៏ពុំបានប្រាប់ ។ យើងបានដឹងត្រឹមតែឈ្មោះសាមណេរកាំងជាអ្នកចារចម្លងប៉ុណ្ណោះ ។ សូម្បីតែអ្នកចារចម្លងទុក ក៏ពុំបានបញ្ជាក់កាលបរិច្ឆេទផងដែរ ។ កំណាព្យនេះ ទោះបីមានពក់ មានខ្វក កប់ជួន និងផ្លោះរំលងជើងកាព្យដោយអន្លើ ក៏យើងបានពិនិត្យឃើញថា សាស្ត្រាក្រឹត្យក្រមនេះ ជាដំបូន្មានដ៏ល្អដោយបានដាស់តឿន ក្រើនរំលឹកបច្ឆាជនឱ្យខំប្រព្រឹត្តតែអំពើល្អ ឱ្យវៀរចាកអំពើអាក្រក់ ឱ្យស្គាល់គុណ ស្គាល់ទោស ចេះសម្របសម្រួលរស់នៅឱ្យបានសុខដុមរមនាក្នុងសង្គម ។

យើងនឹកស្តាយ ដោយយល់ថាមិនគួរខាន ក៏បានចម្លងកំណាព្យនេះយកមកចុះផ្សាយទុកក្នុងទស្សនាវដ្តីនេះដើម្បីពិចារណា, មិនមានសេចក្តីវែងឆ្ងាយណាស់ណាទេ, ដូចតទៅនេះគឺ :

## បទពាក្យ ៧

ពណិនាចងជាច្បាប់ប្រដៅ ទុកឱ្យកូនចៅនៅឯក្រោយ
ចូរចាំគ្រប់គ្នាកុំឱ្យធ្លោយ ពាក្យនេះទុកឱ្យកូនមាសស្ងួន ។
កុំឱ្យលួចគេវាធ្លាប់ដៃ កុំឱ្យដេកថ្ងៃវាធ្លាប់ខ្លួន
កុំឱ្យស្តីញាប់វាធ្លាប់ផ្លូន កុំឱ្យថ្នមខ្លួនវាធ្លាប់ខ្ជិល ។
កុំឱ្យស្មោកគ្រោកវាថោកការ កុំឱ្យផឹកស្រាវាដាច់សីល

កុំឱ្យស៊ីច្រើនវាច្រើនខ្ជិល កុំឱ្យកកិលវាធ្លាប់ឫក ។
កុំឱ្យស្លៀមដៃវាធ្លាប់លួង កុំឱបជង្គង់វាធ្លាប់ស្តីក
កុំឱ្យឃឹតពេកវាទ្រមឹក កុំឱ្យឆ្មើងឫកគេស្អប់ខ្លួន ។
កុំឱ្យរួសពេកវាបែកបាក់ កុំឱ្យថ្មមថ្នាក់វាបាត់ស្នួន
កុំខ្ជិលជោរជោកវាថោកខ្លួន កុំឱ្យវេះពួនវាបាត់មុខ ។
កុំឱ្យម្នះពេកវាបាត់មិត្ត កុំទ្រូស្តស្នាលស្និទ្ធវាបាត់សុខ
កុំឱ្យលើកពេកវាជួនទុក្ខ កុំឱ្យបាត់មុខវាអប្រិយ ។
កុំឱ្យធ្វើស្នេហ៍វាបែរឃ្លាត កុំឱ្យទ្រូស្តញាតិវាអប្រិយ
កុំឱ្យហ៊ានហួសអាយុខ្លី កុំឱ្យជឿស្រីវាបង់ទ្រព្យ(១) ។
កុំឱ្យចង់ពេកវាវែងឃ្លាត កុំឱ្យប្រមាទវាខូចឆាប់
កុំឱ្យស្ទួរជនវាអន់អាប់ កុំឱ្យប្រញាប់វាបែរយូរ ។
កុំឱ្យព្រហើនវាច្រើនទុក្ខ កុំឱ្យជ្រេងក់វាបាត់គួរ
កុំឱ្យចងតឹងវាបានធូរ កុំឱ្យមុខមួរវាខានគាប់ ។
កុំឱ្យស៊ីពេកវាបែកពោះ កុំឱ្យឡេះឡោះវាខ្សត់ទ្រព្យ
កុំឱ្យខុសរឿយវាអភ័ព្វ កុំឱ្យលេលោប់វាធ្លាប់ចិត្ត ។
បើចេះក៏ចេះឱ្យគេកោត បើម៉្ងៃនឹងឆោតគេអាណិត
បើម៉្ងៃនឹងហ៊ានឱ្យមានចិត្ត បើម៉្ងៃនឹងគិតឱ្យបានការ ។
បើម៉្ងៃនឹងកាចឱ្យពេញវង់ បើម៉្ងៃនឹងល្ងង់គេមេត្តា
បើម៉្ងៃនឹងខូចឱ្យចេះការ បើម៉្ងៃគេថាឱ្យបានខ្នាត ។
ឱ្យរៀនអត់ឱនពាក្យជួនតា ឱ្យរៀនវិជ្ជាសិល្ប៍ប្រសាទ
ឱ្យរៀនចិត្តល្អកុំប្រមាទ ឱ្យខំសង្វាតរកទ្រព្យធន ។

---

(១) « ជឿស្រី » ប្រហែលមកពី « ជេរស្រី » ទេដឹង !

ឱ្យខំរៀនរាប់សណ្ដាប់ដី ឱ្យខំរកស៊ីកុំលួចប្លន់
ឱ្យសង្គ្រោះញាតិមានអាសន្ន ឱ្យចេះអត់ធន់កុំគ្រេវគ្រោធ ។
ឱ្យចេះត្រង់ណាឱ្យមាំមួន ឱ្យចេះច្បាប់ក្បួនលោកិយសោត
ឱ្យពេញជាប្រាជ្ញលោកិយកោត ឬកសោតឱ្យសមជាប្រាជ្ញប្រាយ ។
ឱ្យចាំទំនៀមទំនងព្រេង ឱ្យចេះចាត់ចែងបទបរិយាយ
ឱ្យរាប់ព្រេងលានទោះជិតឆ្ងាយ ឱ្យផ្សារមេត្តានឹងជនផង ។
ឱ្យស្គាល់ខ្ពស់ទាបដរាបទៅ ឱ្យស្គាល់ប្រាជ្ញខ្លៅនូវរៀមច្បង
ឱ្យចងចិត្តចាំគិតខ្លាចហ្មង ឱ្យត្រងឱ្យត្រាប់ច្បាប់ធម្មា ។
ឱ្យមានមេត្តាប្រយ័ត្នទោស ឱ្យមានសន្ដោសលះវេរា
ឱ្យមានមេត្រីប្រណិត្អា ឱ្យជាឱ្យជាប់ខាងខន្ដី ។
បើបងមានបុណ្យកុំពឹងបង បើស្រីជន្លងកុំមេត្រី
លាភបាត់ដ្បិតយោរព្រោះសំដី បើស្រីចិត្តស្រើបកុំឱ្យយក ។
បើស្អប់ត្រង់ណាកុំឱ្យបាញ់ បើចិត្តស្រឡាញ់កុំឱ្យរក
បើស្រីប្ដីលែងកុំឱ្យយក ឆ្កែបង់ម្ចាស់មកកុំរក្សា ។
កុំឱ្យគប់ភៀនច្រើនខាតធន កុំយកប្រពន្ធឥតកិរិយា
កុំលលេងលេតិះដៀលថា អាប់អន់ប្រាជ្ញាឥរិយាគាប់ ។
បើរនាបបាក់គ្រាន់នឹងជួស បើសំដីហួសវាបង់ទ្រព្យ
កុំកាចទោសោឱ្យគេស្អប់ កុំឱ្យអន់អាប់ពូជពង្សា ។
បើសិស្សគ្រូបីកុំធ្វើភៀន បើសេះលុនលឿនប្រុងហាត្ថា
បើធ្វើទាហានពានអាសា ឱ្យខំគិតការឱ្យជាក់ស្បាន់ ។
បើមួយម៉ឺនសែនដួងតារា មិនភ្លឺជ្រះថ្លាដូចព្រះច័ន្ទ

ដែកសព្វ[១] ផ្ដឹមម្ដេចនឹងព្រះចន្ទ ពិដោរខ្លឹមចន្ទន៍ជាប់ក្រស្នា ។
កុំឱ្យលេងច្រើនវាច្រើនឈ្លោះ កុំឱ្យឡេះឡោះវាខូចការ
ស្រឡាញ់ពេញប្រាសពីឧរា បើស្អប់ត្រង់ណាវាជិពប់[២]។
បើស្រីគ្មានលក្ខណ៍កុំឱ្យយក បើប្រុសអ្នកផឹកកុំប្រសព្វ
ស្នាបាក់ចាក់ច្បោសនោះពុំគាប់[៣] បើមនុស្សជាប់ទោសកុំដើរបៀត ។
វានាំអន្តរាយដល់ខ្លួនទេ អំពល់ឪម៉ែឱ្យចង្អៀត[៤]
អ្នកលេងថៃច្ចូវចិត្តគ្រោតគ្រាត ត្រូវថយឱ្យឃ្លាតកុំដើរចូល[៥] ។
ឯអ្នកពាលោចោរទុច្ចរិត កុំឱ្យស្នេហ៍ស្និទ្ធគិតមិត្តមូល
វាខូចខ្លួនទេកុំដើរចូល បើចិត្តស្និទ្ធចូលនៃបនឹងប្រាជ្ញ ។
មនុស្សល្ងង់ខ្លៅកុំចង់ជួន មុខរឹងរាល់ខ្លួនច្រើនខូចកាច
កុំឱ្យលេងច្រើនទាបអំណាច កុំឱ្យខ្លាចពេកវាថោកឫក ។
កុំជក់អាភៀនវាញៀនជាប់ វាញៀនដល់ងាប់កុំឱ្យនឹក
កុំសេពសុរាវាមមឹក[៦] រកស៊ីល្ងាចព្រឹកមិនមានទេ ។

---

(១) បើកែដាក់ « សោត » វិញដូចជាសមជាង ។

(២) ក្នុងច្បាប់ដើមដាក់ថា « ជិតប់លើ » បើដាក់ដូចនេះកំណាព្យកប់ជួន ទើបខ្ញុំកែដាក់ជិពប់ដូច្នេះវិញ ។

(៣) ក្នុងច្បាប់ដើមដាក់ថា « បើស្នាវាបាក់កុំចាក់ច្បោស » ដោយឃើញថាមិនជួនល្អ ខ្ញុំក៏កែដូរដូចឃ្លាខាងលើវិញ ។

(៤) ក្នុងច្បាប់ដើមដាក់ថា : « វានាំចង្អៀតដល់ម៉ែឪ » ដើម្បីឱ្យចាប់ចុងជួន ខ្ញុំកែដាក់ដូចខាងលើស្រាប់ ។

(៥) ក្នុងច្បាប់ដើមដាក់ថា : « មនុស្សអ្នកលេងវែងថៃច្ចូវ វានាំខូចទេកុំដើរចូល » ដោយដាច់ចុងចួនអស់ ទើបខ្ញុំកែដូចឃ្លាខាងលើ ។

(៦) មមឹក - ប្រមឹក

កុំលេងល្បែងពាលមានបៀរប៉ោ លេងហើយស្រែកប៉ោឥតទំនេរ
វិល្បែងអស់នោះមិនកើតទេ ចូរគ្មេរគិតតាមច្បាប់សាស្ត្រា ។
កើតមកជាមនុស្សទោះស្រីប្រុស ក្រដឹងត្រូវខុសរាល់វេលា
ក្រគិតក្រគួរក្រចេះការ ក្រស្តីក្រថាឱ្យសមគួរ ។
ក្រគិតគំនិតឱ្យយល់ឆ្ងាយ ក្រចេះនិយាយច្រើនយឺតយូរ
ក្រយល់ពាក្យពេចន៍គិតតឹងធូរ ក្រគិតឱ្យគួរនឹងព្រេងលាន ។
សេចក្តីឬបទបរិយាយ អធិប្បាយចែងចងនិទាន
ព្រេងព្រឹទ្ធអតីត[១] ច្បាប់ទូន្មាន សូរេចស្រេចតែប៉ុណ្ណេះអើយ ។

« សាមណេរកាំង ចារ **បច្ចយោ ហោតុ** ។ ខ្ញុំសូមប្រាថ្នាឱ្យទាន់ព្រះសិរអារ្យមេត្រីពោធិសត្វ ត្រាស់ឯក្រោយ ។ មួយទៀត សូមឱ្យជួបមាតាបិតាញាតិកាទាំងប្រាំពីរសន្តាន និព្វានបច្ចយោ ហោតុ » ។

ចម្លងចេញពីសាស្ត្រាស្លឹករឹត
ដោយ មៀច ប៉ុណ្ណ

(១) អានថា អាឌិត

# ចម្រៀងឆ្លើយឆ្លង

*វាចារំលឹក*

នៅដើមទសវត្សទី ៦០ ខ្ញុំទើបនឹងចូលរៀននៅអនុវិទ្យាល័យ ។ នៅផ្ទះជីតាខ្ញុំឯស្រែ ជួនជាមានសៀវភៅចម្រៀងអាយ៉ៃឆ្លើយឆ្លងមួយ ដែលជាស្នាដៃរបស់ឯកឧត្តម សម ញាណ កាលលោកធ្វើជារដ្ឋមន្ត្រីក្រសួងធម្មការ ។ ចម្រៀងឆ្លើយឆ្លងនោះ បានត្រូវលោកចងក្រងឡើងដើម្បីអប់រំ ទូន្មាន សិល្បករ ផ្នែកចម្រៀងអាយ៉ៃខ្មែរយើងឱ្យផ្តោតន័យនៃចម្រៀង ទៅលើការអប់រំ ការរៀនសូត្រឱ្យបានចេះដឹង ឱ្យយល់ពីសង្គមដែលយើងកំពុងរស់នៅ ជាជាងការច្រៀងដោយប្រើពាក្យមិនគប្បី ដើម្បីគ្រាន់តែជាការកំសាន្ត សើចលេងសម្រាប់មនុស្សខ្លះប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ជាការពិរោះដល់ត្រចៀក មិនជាទីចូលចិត្តសម្រាប់មនុស្សខ្លះទៀត ។

សៀវភៅចម្រៀងអាយ៉ៃឆ្លើយឆ្លងនេះ ក៏មិនខុសពីស្នាដៃអក្សរសាស្ត្រខ្មែរឯទៀតៗដែរ គឺត្រូវរងនូវការបំផ្លិចបំផ្លាញគ្មានសល់ ។ ជាអកុសលមួយទៀត គឺខ្ញុំបានអានសៀវភៅតែពីរ - បី ដង ដោយមិនបានអានឱ្យចប់ដល់ខាងចុងឡើយ ។ តាំងពីនោះមក ជាង ៣០ ឆ្នាំហើយ ខ្ញុំនៅតែចាំបានខ្លះ នូវភាគខាងដើមនៃចម្រៀងឆ្លើយឆ្លងនោះ ។ ក្នុងអារម្ភកថាជាកំណាព្យ មានសេចក្តីជាសំខាន់ដូចតទៅនេះ :

*ឃើញថាជាជាតិខ្មែរជាន់ចាស់ មានប្រាជ្ញាឆ្លាសខាងវោហារ*
*ចេះច្រៀងគួរឱ្យសវនាការ ពិរោះអស្ចារ្យខ្លាំងឥតស្បើយ ។*
*ទាំងពួកអ្នកច្រៀងទំនើបថ្មី ប្រុសស្រីច្រៀងតល្អគ្រាន់ហើយ*
*តែប្រើតែពាក្យអូន-បងអើយ ក្រិនយូរឆ្នាំហើយពុំទៅមុខ ។*
*ច្រៀងបែបនេះនាំប្រទេសជាតិ ឱ្យវង្វេងឃ្លាតចាកក្តីសុខ*
*ច្រៀងតែផ្លូវកាមពេញបន្ទុក នាំជាតិអាប់មុខទាំងប្រុសស្រី ។*

*ហេតុនេះបានជាឯកឧត្តម*
*តែងតាំងគណៈកម្មការថ្មី*
*សម ញាណខិតខំប្រឹងឃ្មាតខ្មី*
*ឱ្យរៀបសម្តីតាមសណ្តាប់ ។*

នេះជាការសំដែងនូវយោបល់ទិតៀនយ៉ាងខ្លីរបស់លោក ។ បន្ទាប់ពីនេះទៅ លោកបានបង្ហាញនូវគំរូនៃចម្រៀងអាយ៉ៃ ដែលមានន័យជាការទូន្មានប្រៀនប្រដៅដល់កូនខ្មែរ ឱ្យបានយល់ជ្រួតជ្រាបពីរបៀបរបបរស់នៅក្នុងសង្គម ឱ្យរក្សាសេចក្តីថ្លៃថ្នូរតាមប្រពៃណីដ៏ល្អរបស់ខ្មែរ ។

ថ្វីបើខ្ញុំមិនបានចាំចម្រៀងនោះឱ្យចប់ទាំងស្រុងក៏ដោយ ប៉ុន្តែ មួយភាគដែលខ្ញុំបានចាំនេះ វាមានខ្លឹមសារសំខាន់ជាងគេ ។

សូមឧទ្ទិសកុសលដែលកើតចេញមកពីស្នាដៃដ៏ថ្លៃថ្លានេះ ជូនចំពោះវិញ្ញាណក្ខន្ធរបស់ឯកឧត្តម សម ញាណ ដែលជាកុលបុត្រខ្មែរម្នាក់ ស្នេហាជាតិមាតុភូមិ ស្នេហាវប្បធម៌ អារ្យធម៌ អក្សរសាស្ត្រ និងប្រពៃណីខ្មែរដ៏មោះមុត គួរជាទីគោរពនៃប្រជារាស្ត្រខ្មែរគ្រប់រូប ។

ថ្ងៃទី ០៩ វិច្ឆិកា ១៩៩៦

**ធន់ ហ៊ិន**

## ចម្រៀងឆ្លើយឆ្លង

ប្រុស

ស្រីអើយស្រីស្រស់ល្អអស់អង្គ
រង់ភ័ក្ត្រផូរផង់ឥតហ្មងសៅ
ចូរនាងចេញមកណាឆោមឆ្មៅ
ព្រមច្រៀងទេពៅឬយ៉ាងណា ។
បើព្រមមិនព្រមសូមឆ្លើយមក
បងនឹងលែលកទៀតកន្និដ្ឋា
ទាន់អស់លោកអ្នកនៅត្រៀបត្រា
ស្រីកុំសារ៉ារង់យូរឡើយ ។

ស្រី

ខ្ញុំឮសំដីប្រុសផ្ដោះផ្ដង ទ្រង់មានបំណងឱ្យខ្ញុំឆ្លើយ
ប្អូនពុំប្រកែកទេបងអើយ សុខចិត្តតែឆ្លើយតាមចំណោះ ។
ប៉ុន្តែខ្ញុំសូមសួរប្រុសថ្លៃ ឱ្យអស់សង្ស័យក្នុងពេលនេះ
ឱ្យញាតិផងដឹងស្គាល់ចាំចេះ តើអ្នកបងនេះនាមឈ្មោះអ្វី ? ។

ប្រុស

បងឈ្មោះភូមិន្ទពិតប្រាកដ តាមដោយកំណត់ហោរាស្ដី
ដាក់ឈ្មោះយ៉ាងនេះទើបគប្បី ឱ្យញាតិប្រុសស្រីគេចូលចិត្ត ។

ស្រី

ចុះបងអាយុប៉ុន្មានឆ្នាំ ? ចូរឆ្លើយតាមចាំតាមពាក្យពិត
កុំភូតកុហកខុសក្រមក្រឹត្យ ឱ្យប្អូនស្នេហ៍ស្និទ្ធជឿបានផង ។

ប្រុស

អាយុម្ភៃប្រាំឆ្នាំជាក់ ជឿចុះវររលក្ខណ៍ពិតកន្លង
មិនភូតភរទេណាន្ចនល្អង មាសបងជឿចុះកុំសង្ស័យ ។

ស្រី

បងនៅភូមិណា ឃុំណាក្ដី ស្រុកខេត្តឈ្មោះអ្វីនៅសព្វថ្ងៃ
សូមប្រាប់មកទៀតណាប្រុសថ្លៃ ឱ្យប្អូនដឹងក្ដីតាមតម្រា ។

លុះប្រុសឆ្លើយរ៉ាយរ៉ាប់ប្រាប់ស្រីពីឈ្មោះ និងអាយុរបស់គេ ពីឈ្មោះភូមិ - ឃុំ ឈ្មោះស្រុក និងឈ្មោះខេត្ត ដែលគេនៅរួចហើយ ស្រីក៏ច្រៀងសួរបន្តទៅទៀត ពីឈ្មោះឪពុក ម្ដាយរបស់ប្រុស ។ កាលបើបានច្រៀងទៅវិញហើយ ប្រុសក៏ច្រៀងតទៅស្រីវិញថា :

មាតាបងឈ្មោះសិរីវឌ្ឍន៍ ជាក់ពិតប្រាកដមិនមែនក្លាយ

សាវតារជាតិតពូជវែងឆ្ងាយ ជាប់សែស្រឡាយពីនាយមក ។
បងឆ្លើយមកនេះសព្វគ្រប់ហើយ ណាប្អូនត្រាណត្រើយពៅពន្លក
ពេលនេះបងបែរសួរសៀតសឹក ឆ្លើយឆ្លងទៅមករកប្អូនស្រី ។
សួរឈ្មោះអាយុលំនៅផង សូមមាសស្នេហ៍ស្នងប្រាប់មកខ្ញី
នាងនៅភូមិណា ឃុំណាក្តី ស្រុក ខេត្ត ឈ្មោះអ្វីប្រាប់ផងណា ។
សូមប្អូននិម្មលពៅពិសី មុខស្រស់ប្រិមប្រិយប្រាប់រៀមរ៉ា
ចំណែកបិតានិងមាតា មាននាមយ៉ាងណាប្រាប់រៀមផង ។
មួយទៀតសញ្ជាតិនាងជាអ្វី ចូរប្រាប់ឆាប់ខ្មីកុំផ្សងផ្សង
ប្រាប់ទាំងសាវតារជាតិទៀតហោង សោះនឹងសួរសងជាច្រើនគ្រា ។

ស្រី

ប្អូនស្តាប់សំដីប្រុសវរមិត្ត សាកសួរពិនិត្យរឿងនាមា
ប្អូនសូមឆ្លើយប្រាប់ឥតរួញរា តាមវគ្គតាមឃ្លាណារៀមរ័ក្ស ។
ប្អូនឈ្មោះថុល្លាពិតប្រាកដ បិតាសន្មតឱ្យជៀងជាក់
សព្វថ្ងៃខ្ញុំនៅក្នុងសំណាក់ បិតាពំនាក់ពុំឃ្លៀងឃ្លាត ។
ខ្ញុំមានអាយុដប់ប្រាំឆ្នាំ ត្រូវតាមចំណាំបញ្ជីជាតិ
នៅភូមិថ្មសជួបជុំញាតិ ឥតមុសាវាទគេចកែប្រែ ។
ក្នុងឃុំស្វាយជ្រំ ស្រុកស្វាយរៀង ខេត្តសោតទាក់ទៀងស្វាយរៀងដែរ
មានស្ទឹងទន្លេនៅជិតកៀ្សរ ពីដើមយើងខ្មែរហៅវៃដូល ។
បិតាខ្ញុំឈ្មោះធម្មសិរី ចេះពាក្យសំដីពិរោះស្រួល
វាចារាបសាមិនរអាក់រអួល ស្តីតាមទំនួលមានវោទវគ្គ ។
មាតាខ្ញុំឈ្មោះសុបិយា ត្រូវតាមតម្រាប្រាកដជាក់
ខ្ញុំជាតិជាខ្មែរសែដូចអ្នក ឥតភូតឥតលាក់ឥតក្លែងក្លាយ ។

ប្រុស

បងស្តាប់បានហើយចម្លើយស្រី ឆ្លើយមកខ្លីៗ មិនវែងឆ្ងាយ
តែបងសេរីសួរឆោមឆាយ ឱ្យប្អូនបរិយាយប្រាប់សេចក្តី ។
ដែលនាងសាកសួរដេញដោលខ្ញុំ សព្វស្រុក ខេត្ត ឃុំ គ្មានសល់អ្វី
គឺនាងក្រមុំចង់បេតី ឱ្យងាយប្អូនស្រីទៅរកបង ។

ស្រី

ខ្ញុំសូមជម្រាបដល់អ្នកប្រុស អ្នកស្មាននេះខុសទេស្នេហ៍ស្នង
គឺស្រីចោទសួរដោយបំណង គ្រាន់នឹងអ្នកផងពិចារណា ។
ពីព្រោះរាស្ត្រខ្មែរយើងសព្វថ្ងៃ នៅល្ងង់ច្រើនក្រៃអប្បប្រាជ្ញា
អ្នកខ្លះលំនៅនៃអាត្មា ពុំដឹងយ៉ាងណាឱ្យប្រាកដ ។
ជួនកាលរាជការមានការគួរ ត្រូវហៅខ្លួនសួរដោយសន្មត
ប្រាប់ផ្តុយត្រឡប់ខុសបែបបទ មិនត្រូវសន្មតតាមតែស្មាន ។
យកស្រុកជាភូមិ ភូមិជាស្រុក ខេត្ត ឃុំ អ្នកឡុកប្រាសដើមដាន
នឹងយកជាការផងពុំបាន នាំឱ្យរំខានខាតវេលា ។
ជួនកាលសរសេរសំបុត្រខុស ផ្ញើតាមផ្លូវប៉ុស្តិ៍ទៅគ្នីគ្នា
កាន្លងសំបុត្រដាក់នាមា ឃុំ ស្រុក វត្តឃ្លាខុសទំនង ។
ប៉ុស្តិ៍រកមិនឃើញតាមឈ្មោះពិត ទាល់អស់បើគិតតាំងដេរផង
អាអន្តរធាននាំមួហ្មង បែហកចោលតែម្តងកុំឱ្យធ្លាប់ ។
ខ្ញុំសួរសៀតសឹកដោយឧបាយ ដេញដោលឡៃបខាយឱ្យងាយស្តាប់
ឱ្យអស់អ្នកផងយកតម្រាប់ គ្រាន់ទុកជាច្បាប់ពិចារណា ។

ប្រុស

សាធុ ! ប្អូនស្រីស្រដីប្លែក ពិរោះចម្លែកឥតឧបមា

ហេតុតែនួនល្អងបានសិក្សា
ស្តីនេះចំជាត្រូវប្រាកដ
គួរអស់អ្នកផងយកតម្រាប់
រឿងសួរអាយុរហូតជាតិ
ចង់សួរអ្វីទៀតណាស្រីពៅ

ស្តីឡើងកាលណាបានជាច្បាប់ ។
តាមដោយបែបបទរាជប្រញ្ញត្តិ [១]
គ្រាន់ទុកជាច្បាប់តរៀងទៅ ។
បងប្រាប់នាងនាថគ្មានសល់នៅ
សួរចុះឆោមឆ្នៅកុំរួញរា ។

ស្រី

ខ្ញុំសូមជម្រាបដល់អ្នកបង
ឃើញថាពូជពង្សជាតិដូចគ្នា

ដែលបានឆ្លើយឆ្លងរឿងនាមា
បងជាពលរដ្ឋប្រទេសអ្វី ? ។

ប្រុស

បងជាពលរដ្ឋប្រទេសកម្ពុជា
កូនខ្មែរមានពូជមានឈ្មោះល្បី

មិនមែនចាមជ្វាទេណាស្រី
ចេះអត្ថបាលីបកប្រែបាន ។

---

(១) អានថា រាជប្រញ៉ាប់ មកពីពាក្យ រាជបញ្ញត្តិ ។

# បុណ្យចូលឆ្នាំ

( បទពាក្យ ៧ )

• មិគសិរខ្យល់បក់ពីឧត្តរ
អ្នកស្រុកស្រីប្រុសទាំងប៉ុន្មាន
• ខែបុស្សដាំបាយអង្ករត្រាំ
ប្រគេនព្រះសង្ឃទ្រង់ស្វះស្វែង
• ខែមាឃតែងធ្វើតាមទម្លាប់
បូជាភ្នំស្រូវទាំងក្មេងចាស់
រំលឹកសន្និបាតសង្ឃសាវ័ក
ទ្រង់នឹងលាចាកភពភារា
• ផល្គុណផលកម្មពីឆ្នាំចាស់
តាមរយៈការរាំរបាំត្រុដិ
ហៅថាពិធីបញ្ជាន់ត្រុដិ
ព្រាយខ្មោចអារក្សអ្នកតាគ្រប់
• ខែចេត្រខែចែកបែកឆ្នាំចាស់
ផ្លាស់ចិត្តឆ្នាំចាស់ឱ្យភ្លឺថ្លា
ទៅតាមបែបបទពីបូរាណ
តន្ត្រីរបាំលេងរាំវង់
ពីថ្ងៃទីមួយថ្ងៃទីពីរ

រងាញាប់ញ័រសព្វអង្គប្រាណ
នាំគ្នាកំសាន្តបង្ហើរខ្លែង ។
ហៅបាយតម្រាំទុកចាត់ចែង
ទៅកាន់កន្លែងចូលបរិវាស ។
ពិធីដែលធ្លាប់ប្រារព្ធច្បាស់
ខ្លះធ្វើបុណ្យមាឃបូជា ។
ព្រះពុទ្ធទ្រង់ដាក់ព្រះជន្មា
ក្នុងគ្រាខាងក្រោយបីខែគត់ ។
ត្រូវកាត់ជំរះឱ្យចេញផុត
រំលាយរំលត់ឧបទ្រព ។
បណ្ដេញឱ្យអស់យក្សគន្ធព
ឱ្យចេញពីភពដែនមនុស្សា ។
ប្ដូរផ្លាស់ឆ្នាំថ្មីតាមតម្រា
កសាងវាសនាឱ្យផ្លូវផង់ ។
នាំគ្នាកំសាន្តតាមចិត្តចង់
ខ្លះអុកចត្រង្គ ឬទាត់សី ។
សប្បាយមូលមីរដល់ទីបី

នាំគ្នាទៅវត្តទាំងប្រុសស្រី
ឬក៏ផ្លូតទឹកជូនចាស់ៗ
ជូនជូនខោអាវលុយក្រម៉ា
• ពិសាខធ្វើបុណ្យតាមលំអាន
ពិធីបើកឆាកបង្កើតផល
ពួកពុទ្ធបរិស័ទចាត់ទុកថា
រំលឹកកាលអង្គព្រះជិនស្រី
រំលឹកកាលអង្គទ្រង់បានត្រាស់
សម្ពោធិញាណដ៏អស្ចារ្យ
រំលឹកកាលអង្គព្រះទ្រង់ញាណ
ចោលពុទ្ធបរិស័ទផុតអាល័យ
• ខែជេស្ឋជូនតាធ្លាប់ជឿជាក់
ទ្រទ្រង់សាសនាព្រះឈ្មោះមារ
• អាសាឍព្រះសង្ឃចូលវស្សា
កំណត់បីខែជៀងជាក់ច្បាស់
តាមប្រពៃណីពីបូរាណ
ត្រាច់តាមជលយានបេះបុប្ផា
• ភទ្របទភ្លៀងធ្លាក់ផ្គររងំ
វេរភត្តាហារនំចំណី
• អស្សុជទឹកស្រកកុកក្រកយំ
ចាស់ក្មេងធ្វើបុណ្យតាមលំអាន
• កត្តិកអុំទូកអកអំបុក

ឃ្មាតខ្មីស្រង់ព្រះយកផលា ។
ខែចៃត្រក្តៅណាស់ក្មេងជ្រះថ្លា
ម៉ែឪយាយតាឱ្យមគ្គផល ។
មិនដែលខកខានច្រត់នង្គ័ល
អ្នកស្រែរវល់ភ្ជួររាស់ដី ។
វិសាខបូជាប្រពៃណី
ប្រសូតចាកផ្ទៃព្រះមាតា ។
សម្រេចជាក់ច្បាស់នូវសម្មា
ប្រោសមនុស្សទេវតាទាំងភពត្រៃ ។
យាងចូលនិព្វានចាកលោកិយ
លាចាកភពបីផែនភារា ។
ហែបំបួសនាគសាងបព្វជា
ហៅថានាគខ្មានបុរាណចាស់ ។
មិនអាចយាត្រាក្រៅអាវាស
ទើបផុតស្រឡះចេញវស្សា ។
• ខែស្រាពណ៍ក្សត្រក្សាន្តទ្រង់យាត្រា
យកមកបូជារតនត្រ័យ ។
យើងធ្វើបុណ្យភ្ជុំភ្ជាប់និស្ស័យ
ឧទ្ទិសឃ្មាតខ្មីញាតិចែកឋាន ។
ធម្មជាតិព្រៃភ្នំស្រស់ចំណាន
អង្គកឋិនទានពេញមួយខែ ។
ទន្លេបួនមុខនាវាហែ

ប្រទីបថ្វាលាកាត់មុខផែ ឱ្យបជារាស្ត្រខ្មែរមើលកំសាន្ត ។
បុណ្យទ្វាទសមាសសង្ខេបខ្លី ថៃងចប់សេចក្តីតាមដើមដាន
បុព្វបុរសពីបូរាណ បានធ្វើទុកតតំណាមក ។

ដោយ មៀច ប៉ុណ្ណ
ប្រធានការិយាល័យទំនៀមទម្លាប់ខ្មែរ
នៃពុទ្ធសាសនបណ្ឌិត្យ

***

*មិនមែនដោយសារមានសក់ក្បាលពណ៌ប្រផេះ*
*ទើបមានឈ្មោះថា « ព្រឹទ្ធបុរស » ( មនុស្សចាស់ ) នោះទេ ។*
*មនុស្សនេះ ទោះរស់ដល់ចាស់ស្លាប់ ក៏ជា « ចាស់ឥតន័យ » ដែរ ។*
*អ្នករស់នៅមានសច្ចធម៌, ប្រកបដោយធម៌, មានចិត្តស្ងប់,*
*គ្រប់គ្រងលើខ្លួនឯងបាន ហើយមានវិន័យ, មនុស្សនេះ*
*ឥតមានមន្ទិលសៅហ្មង ជាធីរជន ( អ្នកប្រាជ្ញ ) ទើបមាន*
*ឈ្មោះថា « ព្រឹទ្ធបុរស » ដោយពិតប្រាកដ ។*

ធម្មបទ . គាថាទី ២៦០-២៧១- ឈ.អ.

# អនុស្សរណាខាធ (*)

## ចំពោះយុវជនអ្នកនៅវត្ត

ហៃពួកយុវជនអ្នកកំសត់
សមអ្នកនឹងឥតមានតម្លៃ
គួរអ្នកកុំភ្លេចវត្តលំនៅ
គួរដឹងគុណវត្តកុំបង្អោច
បើមានគេសួរពីកាលរៀន
អ្នកកុំនិយាយបង្វែងដាន
កុំពោលបង្អួតពួកស្រីៗ
បំផ្លែងបំភ្លើសបំភ្លេចវត្ត
បាយវត្តជាភោជន៍មានព្រលឹង
នាម៉ឺនមន្ត្រីមកពីរាស្ត្រ
បាយផ្ទះ បាយវត្ត ដូចជាតា
ឆ្អែតហើយរៀនសូត្រចេះខ្មែចខ្ចី
សាធុ ! សូមឱ្យអ្នកបានសុខ
ជាជនសប្បុរសរបស់រដ្ឋ

បើកុំបានវត្តជ្រកអាស្រ័យ
យប់ថ្ងៃហួសទៅឥតប្រយោជន៍ ។
ទោះអ្នកចេញទៅទៅឆ្ងាយស្រឡោច
ប្រយោជន៍ និងផលផ្ដល់ពុំខាន ។
ចំណេះរបៀនទាំងប៉ុន្មាន
ត្រូវប្រាប់ថាបានចេះព្រោះវត្ត ។
ត្រូវស្ដីតាមត្រង់កុំបីភ្លាត់
ក្រែងទោសទាញទាត់ឱ្យវិនាស ។
គួរនឹករំពឹងកុំទីសទាស
ពីរាស្ត្រឡើងទៅជាមន្ត្រី ។
ចំអែតអាត្មាមានជីវី
មុនីកើតមានដោយសារវត្ត ។
នីរទុក្ខ នីរភ័យ សិរីភ័ទ្រ
មានបែបមានបទប្រសើរហោង !

សម្ដេចព្រះមហាសុមេធាធិបតី

**ជួន ណាត ( ជោតញ្ញាណោ )**

(*) ដកស្រង់ចេញពី " ប្រវត្តិនៃវត្តឧណ្ណាលោម " ទំព័រ ១៥

# លទ្ធផលនៃចម្លើយ « ប្រស្នាកំណាព្យ »

ដែលបានចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៣ - ១៩៩៦

---

គណៈកម្មការនិពន្ធ មានកិត្តិយសសូមជំរាបជូនដំណឹងចំពោះអស់លោកអ្នកអានជាទីគោរពថា នៅក្នុងទស្សនាវដ្ដីលេខ ១ - ១៩៩៧ នេះ គណៈកម្មការនិពន្ធបានទទួលលិខិត ៧ ដែលបានរួមចំណែកដល់ការឆ្លើយប្រស្នា ។ ក្នុងចំណោមលិខិតទាំង ៧ នោះ ពុំមានខិលិតណាមួយឆ្លើយត្រូវនឹងបំណងប្រាថ្នារបស់សំណួរទេ ប៉ុន្តែគណៈកម្មការបានសំរេចប្រគេន-ជូនរង្វាន់លើកទឹកចិត្តចំពោះការយកព្រះទ័យ-ចិត្តទុកដាក់របស់ព្រះអង្គ អស់លោក ចំពោះទស្សនាវដ្ដីកម្ពុជសុរិយា គឺ ៖

១- ភិក្ខុ ព្រហ្ម សុជាតិ (អគ្គចិត្តោ) វត្តអង្គរយាប ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំនួនពីរម៉ឺនរៀល ( ២០.០០០៖០០ ) ។

២- ភិក្ខុ ឋានរក្ខិតោ អាង ជាតិឡោម សមណសិស្ស នៃពុទ្ធកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី ៣, ចំនួន ប្រាំពានរៀល ( ៥.០០០៖០០ ) ។

៣- លោក ង៉ៃ វិបុល និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកអក្សរសាស្ត្រខ្មែរ ចំនួន ប្រាំពាន់រៀល ( ៥.០០០៖០០ ) ។

៤- លោក ហេង ដេត និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកអក្សរសាស្ត្រខ្មែរ ចំនួន ប្រាំពាន់រៀល ( ៥.០០០៖០០ ) ។

៥-លោក ហេង ប៊ុនរ៉ា និស្សិតគណិតសាស្ត្រ ឆ្នាំទី ៤ ចំនួន ប្រាំពាន់រៀល ( ៥.០០០៖០០ ) ។

៦- លោក សុងសៀង និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកអក្សរសាស្ត្រខ្មែរ ចំនួន ប្រាំពាន់រៀល ( ៥.០០០៖០០ ) ។

៧. លោក ទេព ឈុនវីរៈ និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកអក្សរសាស្ត្រខ្មែរ ចំនួន ប្រាំពាន់រៀល ( ៥.០០០៛០០ ) ។

សូមនិមន្តព្រះតេជព្រះគុណ និងអញ្ជើញអស់លោក ដូចមានឈ្មោះខាងលើ ទៅបើករង្វាន់លើកទឹកចិត្តនេះ នៅពុទ្ធសាសនបណ្ឌិត្យ ផ្នែកទស្សនាវដ្ដី រៀងរាល់ម៉ោងធ្វើការ ។

ឆ្លៀតឱកាសនេះដែរ គណៈកម្មការ សូមលើកយកកំណាព្យចម្លើយរបស់ភិក្ខុ ព្រហ្ម សុជាតិ ដែលបានឆ្លើយកំណាព្យប្រស្នា ចុះក្នុងទស្សនាវដ្ដីលេខ ៣-១៩៩៦ មកចុះផ្សាយ ដើម្បីជាការលើកទឹកចិត្តចំពោះការយកព្រះទ័យទុកដាក់ជាពិសេសរបស់ព្រះអង្គចំពោះទស្សនាវដ្ដីកម្ពុជសុរិយា ។ តាមពិត កំណាព្យចម្លើយរបស់ព្រះអង្គ ពុំត្រូវនឹងបំណងប្រាថ្នារបស់សំណួរទេ ប៉ុន្តែកំណាព្យនោះ មានខ្លឹមសារគួរឱ្យពិចារណា ។

អត្ថបទកំណាព្យ មានដូចខាងក្រោមនេះ :

## « បកស្រាយប្រស្នាកំណាព្យ »

បទភុជង្គលីលា

ជំនោរបោកបក់ប៉ីប៉ើង លើមាតុភូមិយើង ដំណែលខមា [១] ។
ហេមន្តគិម្ហះវស្សា បរិណាមា យាត្រាប្ដូរផ្លាស់ ។
ផ្ដោតនេត្រទៅឆ្វអាកាស នភកេតន៍ចាំងជះ ប្រទានរង្សី ។
ភ្លេចភ្លឹកហាក់យន់រត្តី [២] ព្យុះពិរុណី ប្រល័យឆពណ្ណ ។
ដុំពពកខ្មៅអប្បអន្ធ ញ៉ាំងកាលឱ្យស៊ុន ស្ទុនអ័ព្ទរស្មី ។
គណនាបរិស្ថានព្រឹក្សព្រៃ សុញ្ញិតម្លៃ ខណ ខយ [៣] វិបរិត ។

(១) ខមា មកពីពាក្យ " ខម " ជាឈ្មោះខ្មែរសម័យបុរាណ ។ (២) រាត្រី ( បា. រត្តិ ) ។
(៣) សំ. ក្សិណក្ស័យ, បា. ខណ, ខយ ។

បេះដូងស្លុតថ្លើមប្រមាត់ ត្រូវឆ្កៀលឆ្កឹះកាត់ ដោយហត្ថមិច្ឆា(១) ។
លំនាំវាក្យស្រាយអត្ថា ព្រោះនឹកអនិច្ចា វុទ្ធាព្រឹក្សព្រៃ ។
នាបច្ចុប្បន្នសម័យ បុត្រខ្មែរមួយល្អី ចិត្តគេស្អុយក្នុង(២) ។
ផ្សៀងច្បាប់ឃើញផ្កាល់មំសំ ចក្ខុត្រឡាំង បាំងដីរីសា ។
សែនសង្វេគអច្ឆរិយា(៣) ព្រោះឃើញខេមរា ត្រូវស្នាពិសពៃរ៍ ។
បោះពាក្យព្រោះអាណោចក្រៃ ដួងចិត្តស្វាមី ភក្តីដីទឹក ។
ឈានចូលសន្ទិះរកនឹក ប្រស្នារំលឹក ជូនជនប្រុសស្រី ។
ស្តាប់ទៅហាក់ជ្រៅសេចក្តី ដូចអាទិកោសិយ(៤) ពួតេត្តីសា ។
ញាណកោសល្លប្លែងប្រាជ្ញា ជូនគោរម្យងារ ជាច្បងលើសលន់ ។
ល្បិចល្បងល្បោយក្រងនិពន្ធ កប់អត្ថសាន់វណ្ណ ក្រមាច់ក្រមាល់ ។
អក្ខរាសាស័ព្ទបន្ទាល់ បន្សាត់កង្វល់ ជូនម្ចាស់សេណី(៥) ។
បណ្ឌិតបង្ហាញសក្ខី ឱ្យខ្មែរប្រុសស្រី ចាំការណ៍ព្រេងព្រឹទ្ធ ។
រឿងមួយទោះប្រាជ្ញប្រឌិត ខ្លឹមសារសុកដ(៦) និត្យនៅកើតមាន ។
ប្រវត្តិរឿងព្រេងនិទាន ថាឋានមួយមាន បុរសពីរនាក់ ។
បានលាភភស្តុខាទនីយះ កើតរឿងអបលក្ខណ៍ ដាល់ធាក់វិវាទ ។
ទ្រឹស្តទ្រុស្តព្រួសឈាមព្រោងព្រាត ត្រូវអ្នកម្នាក់ទៀត ក្រហាមភក្ត្រា ។
ក្តុងក្តាំងឥតក្តីវិចារណ៍ បង្កហិង្សា ដ៏មហាមហិមា ។
ទ្រេតទ្រោតវិរោធកោធា ក្រទិក្រទា អធម្មិកា ។
ជេរស្តីពេចន៍អសីលា ញុំាងចិត្តឥស្សា ហានក្លាល្បិចស្បៀត ។

(១) ស្នាដៃមនុស្សទុច្ចរិត, អំពើរបស់ជនទុច្ចរិត ។ (២) អាចផ្លាស់ជាស្អុយខ្លាំងវិញ ក៏បាន ដើម្បីឱ្យចួនល្បះ ... ។ (៣) បា. អច្ឆរិយ, សំ. អស្ចារ្យ ។ (៤) ប្រស្នារបស់ព្រះឥន្ទ ។ (៥) សេណី - អ្នកមានចំណោះវិជ្ជា យសសក្តិដូចគ្នា ស្មើគ្នា ។ (៦) សំ. សុក្រឹត, បា. សុកដ

អញ្ចងងខែងរែងចោលម្សៀត ពន្លាតសង្គ្រាម ឈោមជាបអង្គា ។
នាំផលដល់ជនផងគ្នា រងទុក្ខវេទនា អផាសុកា ។
បាននាំឈ្លុយឆ្នាញ់អស្ចារ្យ កើតទោមនស្សា ឡើងសាលាក្តី ។
កលហរិគ្គហាយកជ័យ នាំដល់វិនិច្ឆ័យ ពីអង្គចៅក្រម ។
ឈ្លោះគ្នាពីរឿងលាភនំ បង្កទុក្ខធំ នាំដល់គ្រោះថ្នាក់ ។
នំនោះសាស័ព្ទបញ្ជាក់ ជូនអស់លោកអ្នក ជ្រាបគ្រប់អាត្មា ។
ពោលបែបជាគ្រាមភាសា និទានបានចារ ថា « នំកើតក្តី » ។
បើពោលឱ្យត្រូវអត្ថន័យ ថានំផ្លែអាយ ឬ « បំពួនស្កុរ » ។
ទូលការផលិតយ៉ាង ទាក់ទាញសង្ហរណ៍ នាំមកជូនថ្កាន ។
ម្យ៉ាងបងប្អូនគ្រប់មជ្ឈដ្ឋាន ចេះចាំយល់បាន សន្តានប្រាណនំ ។
ស្ងួន្យម្សៅបង្កប់ស្កុរជុំ លញ់មូលត្រទ្បុំ បង់ក្នុងឧណ្ហោទក៍ ។
ស្ងោរគ្រានំកញ្ច្រោលលោត វេលាកំណត់ បក្កប្ចូវា ។
រួចក្លួចកន្ទោងភាជនា ដាក់នំក្នុងវា តាមការគិតគ ។
មាននាមនំបង្កប់ស្កុរ ដូចទទ្បីករណ៍ សំអាងក្បោះក្បាយ ។
មានឈ្មោះជានំផ្លែអាយ ព្រោះមិននៅនាយ ដោតឈើនៅក្បែរ ។
ស្នេះកិច្ចផលិតនំខ្មែរ ប្រៀបឈើមានផ្លែ គិតកែឈើព្រៃ ។
កំបង់ឆ្នោះជនប្រុសស្រី ត្រូវយល់តម្លៃ បរិស្ថានធម្មជាតិ ។
ជីវិតពុំអាចឃ្លៀងឃ្លាត ពីភាពរវាត ធម្មជាតិជុំវិញ ។
ព្រៃឈើយោបំទោម្មេញ ខ្ទះរូហ៍ [1] ពេញលេញ ខ្ទះសិទ្ធិសេរី ។
ខ្យល់ព្រឹក្សទទាមាន់ព្រៃ ខ្ទេះខ្ទីងជីវី រចល់ក្សែយពង្ស ។
ស្រងោចត្រមោចត្រមង់ ស្រងេះប្រាណអង្គ សញ្ចឹងត្រើយត្រាណេ ។

---

(១) រូហ៍ - ការដុះដាល, ការលូតលាស់ ។

ព្រៃឈើល្អល្ហេវហោស្ថាន ហេងហាងលែងបាន ស្រណានព្រលឹង ។
ព្រៃស្បាតហ័តហោងស្រោងស្រីង រំលោងដាំបឹង រនាមរបោះ ។
ឈើអស់ក្រៀមក្រោះកើតគ្រោះ ទ្វីបលោកបង់ឈ្មោះ លែងស្រស់ទៀតហើយ ។
ចេះមនុស្សជាតិទាំងឡាយអើយ ចូរកុំពោះតើយ រៀនរក្សរុក្ខា ។
ដាំដុះឱ្យច្រើនក្ដាត់ក្ដា សម្រួលវាសនា ឱ្យលោកាយើង ។
បៃតងដង្គោលទ្រោលឡើង ដង្គុំថ្មីថ្មើង តម្កើងទឹកដី ។
សូមអធិដ្ឋានស្មារតី ស្រឡាញ់ព្រឹក្សព្រៃ ប្រតិស្ឋព្ធសន្ដាន ។
រុក្ខាទ្រុបទ្រេលគ្រប់ស្ថាន ឈប់ល្មើសបំពាន ឃ្លានតាមកាមទោស ។
តទៅខ្មែររុងរោចន៍ឈ្មោះ រួចពៃរ៍រួចទោស ពីគ្រោះធម្មជាតិ ។
បង្គំលាលាតញោមញាតិ ស្រឡាញ់រុក្ខជាតិ គ្រប់ៗគ្នាហោង ។

យុវសមណសិស្ស អគ្គចិត្តោ **ព្រហ្ម សុជាតិ**
វត្តអង្គរយាប ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

***

*កាលណាសេចក្ដីស្លាប់មកដល់ហើយ កូនក៏ដោយ ឪពុកក៏ដោយ*
*សាចញាតិក៏ដោយ មិនអាចជួយឱ្យរួចផុតពីការស្លាប់នេះបានទេ ។*

# កិច្ចថ្លែងអំណរគុណ

គោរពជូនញោម វណ្ណ ស៊ុនហេង ដ៏ខ្ពង់ខ្ពស់ !

អាត្មាភាព យើងខ្ញុំ សូមទទួលនូវទេយ្យទានូបត្ថម្ភអំណោយដ៏ខ្ពង់ខ្ពស់ របស់ញោម ដែលបានបរិច្ចាគហើយនោះ, ដោយកិរិយាអនុមោទនាដ៏ប្រពៃថ្លៃថ្នូរ ។ អាត្មាភាព យើងខ្ញុំ ពុំបានសម្គាល់ថា នោះជារង្វាន់រង្វាស់អ្វីឡើយ ប៉ុន្តែគឺជាវិភាគទានមួយដ៏សែនសប្បុរសរបស់ញោម ដែលបានជួយឧបត្ថម្ភអាត្មាភាព យើងខ្ញុំ ក្នុងគ្រាទុរគតភាពគ្របសង្កត់ក្នុងសម័យ កាលនៃការសិក្សាសព្វថ្ងៃនេះឯង ។

សូមញោមបង្អោនហឫទ័យទទួលអនុមោទនានូវអំពើល្អ ដែលញោមធ្វើហើយនេះ ទុកក្នុងសន្តានដោយល្អប្រពៃចុះ ។ អាត្មាភាព យើងខ្ញុំ នឹងចាត់ចែងទានដែលញោមថ្វាយហើយនេះ ឱ្យបានជាទានមានផលច្រើនតទៅ ។ ហើយឯការចេះតែងកាព្យបន្តិចបន្តួចនេះ គឺមកពីញោម, « ញោម គឺជាគ្រូរបស់អាត្មាភាព » ។

អាត្មាភាពមានបំណងចងក្រងជាអត្ថបទផ្សេងៗ តាមសមត្ថភាព ដើម្បីជាវិភាគទានជួយស្ថាបនាស្មារតីកូនខ្មែរខ្លះៗ ប៉ុន្តែហាក់ពុំទាន់មានឱកាសពេញលេញដើម្បីបំពេញនូវភារកិច្ចនេះ, ម្យ៉ាងពុំដឹងប្រាជ្ញប្រាយបណ្ឌិតមានសុឆន្ទៈអធ្យាស្រ័យយ៉ាងណាក្នុងសេចក្តីនេះ ។ អាត្មាភាព ពុំមានបំណងប្រឡងប្រណាំងអ្វីទេ ប៉ុន្តែជាបញ្ហាជីវភាព, បញ្ហាធំ គឺចង់បំពេញប្រយោជន៍ឱ្យប្រជាជាតិមាតុភូមិជាចំណែកខ្លះផង ទើបសម្រេចព្រះទ័យចូលខ្លួនក្នុងឆាកដោះប្រស្នានេះ ... ។

សូមផ្តល់អភ័យចំពោះអាត្មាភាពផង ក្រែងជាកម្មពុំគួរ ចំពោះញោមក្នុងការបរិយាយនេះ ។

សូមទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅបំផុត អំពីសមណសិស្សអាត្មាភាពយើងខ្ញុំ ។

ភិក្ខុ ព្រហ្ម សុជាតិ

# ចម្លើយកំណាព្យប្រស្នា

ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយា លេខ ៣ . ១៩៩៦

បទកាកគតិ

- ឱនអង្គអភិវាទ ឆ្ពោះព្រះលោកនាថ បរមសាស្ដា
ព្រះអង្គជាគ្រូ មនុស្សសត្វទេព្ដា បង្កើតសាសនា
ទុកឱ្យប្រតិបត្តិ ។

- សូមក្រាបអភិវន្ទ ព្រះធម៌សោភ័ណ ឱវាទលោកនាថ
សូមធ្វើអភិវន្ទន៍ ព្រះសង្ឃសីលស្អាត ប្រតិបត្តិឱបាត
ទ្រទ្រង់សាសនា ។

- ចប់ត្រៃប្រណាម ចិន្ដាជិតដាម ជាសរីមំសា
ពិនិត្យចម្លើយ កំណាព្យប្រស្នា សឹងល្អក្រៃណា
គ្រប់ៗអង្គា ។

- កាព្យឃ្លោងណែងណង ទឹកដៃចំបង សងវិសជ្ជនា
រសផលរៀបរាប់ គួរគាប់ទ័យា ផ្លែឈើកម្ពុជា
នៅនាលោកិយ ។

- វីផ្លែប្រស្នា អាណាក្រិត្តិកា រស់ធម៌គម្ពីរ
ព្រះរាជសម្ភារ ជាមហាកវី ព្រះអង្គបានស្ដី
ផ្លែប្រាំនោះណា ។

* ពិសាផ្លែប្រាំ ពិសា **រសធម្ម** ពិសា **សត្យា**
ពិសា **សីលទាន** ទ្រើសទ្រង់ **ករុណា** ពិសា **រសវា-**

៦. ចេញមធូរ ។

- ពិសាផ្ដែប្រាំ ពិតជាងាយនាំ ឥន្រ្ទីយ៍ទៅចូល
ត្រីពិធសម្បត្តិ ទិព្វរ័តន៍អនុកូល ចំណោរទៅចូល
មោក្ខមគ្គាល័យ ។

- ធមិនេះជាច្បាប់ ប្រសើរមហាគាប់ ឧត្ដមពេកក្រៃ
ក្រអ្នកណាមាន ប្រាជ្ញាឈ្លាសវៃ អាចដឹងដោយន័យ
រសធមិគាថា ។

- គួរចេះគួរចាំ គួរតាមបណ្ដាំ ទូលទុកសិរសា
ធមិនេះស្មើក្សីរ អម្រិតធារា សម្ដេចភគវា
សាធុប្រោសប្រាណ ។

- អ្នកណាបានស្ដាប់ អ្នកណាបានត្រាប់ អ្នកណាបានធ្យាន
រសធមិនេះគាប់ ជាច្បាប់ទូន្មាន អ្នកនោះស្មើបាន
ដល់និព្វានហោង ។

- នេះចម្លើយពិត ព្រេងប្រាជ្ញបណ្ឌិត លោកបានចងក្រង
ព្រះរាជសម្ភារ ករីចម្បង ខ្ញុំគ្រាន់ចម្លង
ព្រះរាជនិពន្ធ ។

- ពិសាផ្ដែប្រាំ ព្រះរាជបណ្ដាំ ដល់សាធុជន
ច្បាប់រាជនេតិ ប្រសើរពេកពន់ ខ្មែរគ្រប់ជំនាន់
ត្រូវរៀនចេះចាំ ។

ថ្ងៃទី ១៨ មីនា ១៩៩៧

**ខណ្ឌ ស៊ុនហេង**

# កំណាព្យប្រស្នា

គណៈកម្មការនិពន្ធ មានកិត្តិយសចុះផ្សាយកំណាព្យប្រស្នាមួយទៀត របស់ឯកឧត្តម **ចណ្ណា ស៊ុនហេង** អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង នៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ១ . ១៩៩៧ នេះ ។

ចម្លើយទាំងឡាយណា ដែលត្រូវនឹងខ្លឹមសារប្រស្នា នឹងបានទទួលរង្វាន់តាមកំរិតនៃចំណាត់ថ្នាក់ ។

គណៈកម្មការនិពន្ធ សូមអញ្ជើញលោកអ្នកអានទាំងឡាយដែលស្រឡាញ់អក្សរសាស្ត្រខ្មែរ មេត្តាចូលរួមសាកល្បងឆ្លើយអោយបានច្រើនជាអតិបរមា ។

## បទនាគកៀវក្រវាត់

* ចាស់ៗចូលចិត្តកាព្យប្រស្នា ប្រស្នាកាព្យការណ៍បង្កប់ន័យ
ន័យកប់បន្លប់លាក់លកលៃ លៃលកបំភ្លៃឱ្យក្មេងគិត ។
* គិតក្មេងជាន់ក្រោយចេះដោះកល់ កល់ដោះអស់ខ្វល់អ្នកប្រាជ្ញពិត
ពិតប្រាជ្ញពុំខ្លាចគេចូលជិត ជិតចូលមូលមិត្តរួមមេត្រី ។
* សូមបែរសំណួរសួរញាតិមិត្ត មិត្តញាតិឆ្ងាយជិតទាំងប្រុសស្រី
ស្រីប្រុសបញ្ជិតទោះចាស់ថ្មី ថ្មីចាស់មិនថ្វីអាចឆ្លើយឆ្លង ។
* ឆ្លងឆ្លើយសំណួរពីបាយស៊ី ស៊ីបាយអលង្គីជាន់នេះម្តង
ម្តងនេះត្រិះរិះឱ្យហ្មត់ហ្មង ហ្មងហ្មត់បាយផងដែលឈ្មោះមាន ។

** « មានឈ្មោះជាបាយគេស៊ីបាន បានស៊ីប៉ុន្មានពោះតែងឃ្លាន*
*ឃ្លានតែងស៊ីទៀតតាមតែបាន បានតែបំពានពោះទទេ ។*
** ទេតើបាយនោះឈ្មោះបាយអី អីបាយចំណីខុសឯងគេ*
*គេឯងតែស៊ីពោះឆ្អែតទ្វេ បាយមួយខុសគេស៊ីមិនឆ្អែត » ។*

**ចណ្ណា ស៊ុនហេង**

## សេចក្ដីរាយការណ៍ របស់

ឯកឧត្ដម ឈន អៀម អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា
ក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៦
ថ្ងៃទី ១៩ កុម្ភៈ ១៩៩៧ នៅខេត្តសៀមរាប
ស្ដីពី

## ការងារ របស់ ពុទ្ធសាសនបណ្ឌិត្យ

ខ្ញុំព្រះករុណា ខ្ញុំ សូមសំដែងនូវមនោសញ្ចេតនាសប្បាយរីករាយ ចំពោះកិត្តិយសដែលខ្ញុំព្រះករុណា ខ្ញុំ បានទទួលនៅពេលនេះ ដើម្បីអោយថ្លែងយោបល់មួយចំនួន លើប្រធានបទ ស្ដីពី ការងាររបស់ពុទ្ធសាសនបណ្ឌិត្យ, ដែលនឹងត្រូវបែងចែកជាបីផ្នែក ដូចតទៅនេះ :

១. ការពិនិត្យមើលឡើងវិញ នូវការវិវត្ដន៍ និងសមិទ្ធផលរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងអតីតកាល,

២. ស្ថានភាព និងការងាររបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងពេលបច្ចុប្បន្ន,

៣. ទស្សនវិស័យអនាគតនៃសកម្មភាពការងាររបស់ពុទ្ធសាសនបណ្ឌិត្យ,

ដោយសំអាងលើឯកសារផ្សេងៗ ដែលសេសសល់ពីការបំផ្លាញ និងដោយផ្អែកលើការយល់ដឹង និងការចងចាំខ្លះៗ អំពីការងាររបស់ពុទ្ធសាសនបណ្ឌិត្យ ។ ខ្ញុំព្រះករុណា ខ្ញុំ សូមសេចក្ដីអនុញ្ញាត លើកយកចំណុចខាងលើ មករៀបរាប់ដោយសេចក្ដីសង្ខេបតាមផ្នែកនីមួយៗ ជាលំដាប់លំដោយ ដូចតទៅនេះ :

I. *ការពិនិត្យមើលឡើងវិញ នូវការវិវត្ដន៍ និងសមិទ្ធផល របស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងអតីតកាល :*

*ក. ការវិវត្តន៍របស់ពុទ្ធសាសនបណ្ឌិត្យ :*

ពុទ្ធសាសនបណ្ឌិត្យ គឺជាស្ថាប័នជាតិមួយដ៏ចាស់ទុំ ដែលបានដើរតួជាមជ្ឈមណ្ឌលសម្រាប់ការសិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយពុទ្ធសាសនាថេរវាទ, អក្សរសាស្ត្រ, ប្រពៃណី, ទំនៀមទម្លាប់ខ្មែរ, ហើយបានបោះពុម្ពផ្សាយ និងបានរក្សាទុកនូវក្បួនច្បាប់ គម្ពីរដីកាជាភាសាបាលី និងស្នាដៃអក្សរសាស្ត្រ ព្រមទាំងប្រពៃណីទំនៀមទម្លាប់ជាតិ តរៀងមក ។ ពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្ន គឺជាកេរដំណែលវិវត្តចេញមកពី *ខេមរបណ្ណាល័យ* ( la bibliothèque Cambodgienne ) ដែលបានបដិសន្ធិឡើង តាមអំណាចព្រះរាជក្រមមួយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ១៩២១ [១] ។ បួនឆ្នាំក្រោយមក, ខេមរបណ្ណាល័យ បានប្តូរឈ្មោះថ្មី ទៅជាព្រះរាជបណ្ណាល័យ តាមអំណាចព្រះរាជក្រមមួយទៀត ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩២៥ ។ ព្រះរាជក្រមនេះបានលុបចោលបទបញ្ញត្តិទាំងអស់ របស់ព្រះរាជក្រមមុន ហើយបានជំនួសដោយបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជក្រមក្រោយនេះវិញ ។ នៅឆ្នាំបន្ទាប់មានព្រះរាជក្រមមួយផ្សេងទៀត ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩២៦ បានកំណត់ភារកិច្ច, មូលនិធិពិសេស, ការចាត់តាំង, ការបោះពុម្ព, ថវិកា និងបទបញ្ជាផ្ទៃក្នុងរបស់ព្រះរាជបណ្ណាល័យ, ដែលជាបទបញ្ញត្តិបំពេញបន្ថែមទៅលើព្រះរាជក្រម មុននេះ ។

នៅទីបំផុត ដោយយោងតាមព្រះរាជតម្រិះរបស់ព្រះចៅក្រុងកម្ពុជា និងព្រះចៅក្រុងហ្លួងប្រាបង និងតាមសេចក្តីស្នើរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់បារាំង

(១) នៅឆ្នាំ ១៩២១ ប្រជាជនខ្មែរមានពីរលានកន្លះ, មានសាលាថ្នាក់បំពេញវិជ្ជា ( Complementary schools ) ១៤ ជាមួយសិស្ស ៣.៣៤៥ នាក់ ; មានសាលាថ្នាក់ដំបូង (Elementary schools ) ៤៣ ជាមួយសិស្ស ១.៦៣៨ នាក់ ។ Chalrs Bilodeau, Compulsory Education in Cambodia, Laos and Viet-Nam, 1995 Unesco p. 19.

នៅកម្ពុជា និងវ៉េស៊ីដង់ជាន់ខ្ពស់នៅឡាវ ហើយនិងសេចក្តីស្នើរបស់លោកទេសា-ភិបាល នៅកូសាំងស៊ីនផង, លោកអគ្គទេសាភិបាលប្រចាំឥណ្ឌូចិន បានចេញ ¤hTAsnHo ( un arrêté ) ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៣០ ស្តីពីការបង្កើត " វិជ្ជាស្ថានអន្តេវាសិកមួយ សម្រាប់ការសិក្សាពុទ្ធសាសនាថេរវាទ ( Institut indigène d'études du Bouddhisme du Petit Vehecule ) ។ វិជ្ជាស្ថាននេះ ឋិតនៅក្រោមព្រះរាជាធិបតីភាពព្រះចៅក្រុងកម្ពុជា និងព្រះចៅក្រុងហ្លួងប្រាបង ។ ឯតំណែងជាប្រធាននៃវិជ្ជាស្ថាន ត្រូវរ៉ាប់រងដោយមន្ត្រីជាន់ខ្ពស់ពីររូប គឺខ្មែរម្នាក់ និងលាវម្នាក់ ដែលត្រូវបានតែងតាំងឡើងដោយលោកអគ្គទេសាភិបាលបារាំង ។ មានលេខាធិការម្នាក់ ដែលតែងតាំងឡើងដោយប្រកាសរបស់លោកអគ្គ-ទេសាភិបាលបារាំង, និងមានក្រុមប្រឹក្សាភិបាលមួយបានដឹកនាំ និងគ្រប់គ្រងការងាររបស់ " វិជ្ជាស្ថាន " ។ ប៉ុន្តែ ជាគោលការណ៍អនុវត្តជាក់ស្តែង, មុខងាររបស់លេខាធិការ ត្រូវបានប្រគល់ទៅអោយលោកអភិរក្សនៃព្រះរាជបណ្ណាល័យជាអ្នកបំពេញ ។

មាត្រា ៣ នៃប្រកាស បានចែងថា គោលដៅរបស់វិជ្ជាស្ថាន គឺការសិក្សាពុទ្ធសាសនាថេរវាទ ដែលកំពុងត្រូវបានគោរពប្រតិបត្តិក្នុងបណ្តាប្រជាជននៃប្រទេសលាវ និងប្រទេសកម្ពុជា ហើយនិងក្នុងបណ្តាក្រុមជនជាតិខ្មែរ នៅប្រទេសកូសាំង-ស៊ីន ។ មាត្រា ៥ បានកំណត់ស្ថាប័នទាំងឡាយ ដែលឋិតក្រោមសកម្មភាព ឬការត្រួតពិនិត្យរបស់វិជ្ជាស្ថាន គឺ :

១. ពុទ្ធិកបណ្ណាល័យ នៅភ្នំពេញ, នៅហ្លួងប្រាបង, នៅវៀងចន្ទ និងអាចនៅកូសាំងស៊ីនផងដែរ ។

២. ពុទ្ធិកសារមន្ទីរក្នុងស្រុក នៅភ្នំពេញ, នៅហ្លួងប្រាបង និងនៅវៀងចន្ទ ។

៣. សាលាបរិវច្ឆណដ្ឋានបាលី ( សាលាបាលីរង ) នៅកម្ពុជា, នៅលាវ និងកូសាំងស៊ីន និងសាលាបាលីជាន់ខ្ពស់ នៅភ្នំពេញ ។

៤. លំនៅស្នាក់អាស្រ័យ បង្កើតឡើងសម្រាប់ទាហាន «ទីរ៉ៃយ័រ» (១) ឆ្នាំក្នុងស្រុក និងជីវពលខ្មែរ និងលាវ ។

យោងតាមមាត្រានេះ និងមាត្រាដទៃទៀតនៃប្រកាស ព្រះរាជបណ្ណាល័យ ដែលបានដំណើរការមកដោយឯករាជ្យ អស់រយៈពេលច្រើនឆ្នាំហើយនោះ ក៏ត្រូវបានក្លាយជាផ្នែកមួយ ឋិតក្រោមការគ្រប់គ្រងរបស់វិជ្ជាស្ថានអន្តោគ្រាមសម្រាប់ការសិក្សាពុទ្ធសាសនាថេរវាទ ។ មិនតែប៉ុណ្ណោះ វិជ្ជាស្ថាននេះ បានគ្រប់គ្រងទាំងសារមន្ទីរ ទាំងសាលាបឋមសិក្សាបាលី នៅក្នុងផ្ទៃប្រទេសកម្ពុជាទាំងអស់ និងសាលាបាលីជាន់ខ្ពស់ នៅក្រុងភ្នំពេញទៀតផង ។ នេះបើយើងនិយាយតែអំពីប្រទេសកម្ពុជាមួយប៉ុណ្ណោះ ដោយមិននិយាយដល់ប្រទេសលាវ ប្រទេសកូសាំងស៊ីន ( ដែនដីកម្ពុជាក្រោម របស់ខ្មែរពីមុន ) ផងទេ ។

យោងតាមព្រះរាជប្រកាស លេខ ១០៦ ចុះថ្ងៃ ១៤ ធ្នូ ១៩២៩ ក្រុមជំនុំព្រះត្រៃបិដក ត្រូវបានបង្កើតឡើង ។ ក្រុមជំនុំនេះ បានជួបជុំជានិច្ចកាល នៅក្នុងមន្ទីរព្រះរាជបណ្ណាល័យ ហើយបានប្រែព្រះត្រៃបិដកជាមុន ជូនជាបណ្តើរៗទៅលោក កុងស៊ុយសេនាបតី សម្រេចជាមួយនឹងលោករ៉េស៊ីដង់ជាន់ខ្ពស់ ជាអធិបតី ។

ដើមឡើយ ក្រុមជំនុំព្រះត្រៃបិដក គឺជាក្រុមដោយឡែក កើតឡើងតាមការផ្តើមគំនិតរបស់វរជនខ្មែរមួយក្រុម រួមជាមួយលោកហ្វ្រង់ស័ួ ឡូវិត រ៉េស៊ីដង់ជាន់ខ្ពស់នៃសាធារណរដ្ឋបារាំង ប្រចាំនៅក្រុងកម្ពុជាធិបតី ។ ក្នុងចំណោមវរជនខ្មែរទាំងនោះ, មានសម្តេចចៅហ្វាវាំងវរៈវៀងជ័យ អធិបតី ជួន សេនាបតីទី១ សេនាបតី

(១) ទាហានថ្មើរជើង ជ្រើសរើសយកពីចំណោមប្រជាជនក្នុងស្រុក របស់ផែនដីឋិតក្នុងសហភាពបារាំងសេស : ទីរ៉ៃយ័ររអាល់ ហ្សេរី, សេណេហ្គាល់, ខ្មែរ, លាវ ... ។

ក្រសួងព្រះបរមរាជវាំង ព្រះឃ្លាំង និងរចនា ជាអ្នកពន្យល់ផ្ទាល់ ហើយព្រាងព្រះរាជ-ប្រកាសជូនពិនិត្យសំរេច រួចទើបថ្វាយព្រះរាជាឡាយព្រះហស្ថលេខា ។ លុះដល់ពេលកើតមាន " វិជ្ជាស្ថានអន្តោគ្រាម សម្រាប់ការសិក្សាពុទ្ធសាសនាថេរវាទ " តាមប្រកាសចុះថ្ងៃ ២៥ មករា ១៩៣០ របស់លោកអគ្គទេសាភិបាលនៃប្រទេសឥណ្ឌូ-ចិន, ក្រុមជំនុំព្រះត្រៃបិដក ក៏កាន់តែមានកម្លាំង និងពន្លឺថែមទៀត ក្នុងការបំពេញការងារ ។ ឯក្រុម " វិជ្ជាស្ថានអន្តោគ្រាម សម្រាប់ការសិក្សាពុទ្ធសាសនាថេរវាទ " ក្នុងសម័យនោះ គឺមាន :

- សម្ដេចក្រុមព្រះ វរចក្ររណរិទ្ធិ នរោត្តមសុធារស អធិបតីក្រុមសង្គហៈព្រះរាជវង្សានុវង្ស ។

- កញ្ញា ស៊ុយហ្សាន កាប៉ីឡែស ជាអគ្គលេខាធិការ និងជាអភិរក្សនៃព្រះរាជបណ្ណាល័យ តែងតាំងដោយព្រះរាជក្រម លេខ ២៤ ចុះថ្ងៃទី ១៨ មីនា ១៩២៦, ប្រកាសអោយប្រើដោយប្រកាស លេខ ៩៣៥ ចុះថ្ងៃទី ២០ មេសា ១៩២៦ របស់លោករ៉េស៊ីដង់ជាន់ខ្ពស់ ។

នៅពេលដែលវិជ្ជាស្ថានអន្តោគ្រាម សម្រាប់ការសិក្សាពុទ្ធសាសនា ថេរ-វាទ ត្រូវបានគេកែសម្រួលយ៉ាងណានោះ ហើយត្រូវបានផ្ទេរមកអោយព្រះរាជរដ្ឋា-ភិបាលកម្ពុជា កាន់កាប់ ចាប់ពីឆ្នាំ ១៩៥០ មក, វិជ្ជាស្ថាននេះ ក៏មាននាមថា " ពុទ្ធ-សាសនបណ្ឌិត្យ [(១)] " ហើយឋិតក្រោមឱវាទនៃក្រសួងធម្មការ ។ មន្ត្រីដែលបានដឹកនាំ " ពុទ្ធសាសនបណ្ឌិត្យ " ជាបន្តបន្ទាប់ គឺមាន :

---

(១) ឈ្មោះ " វិជ្ជាស្ថានអន្តោគ្រាម សម្រាប់ការសិក្សាពុទ្ធសាសនាថេរវាទ " ( Institute Indigène des Etudes du Bouddhisme du Petit Véhécule ) បានក្លាយមកជាឈ្មោះខ្មីថា " ពុទ្ធសាសនបណ្ឌិត្យ " ( Institut Bouddhique ) តាមនីតិវិធីបែបណានោះ មិនទាន់អាចពន្យល់បាននៅឡើយ ដោយហេតុគ្មានអត្ថបទច្បាប់ច្បាប់ជាទីសំអាង ។

- លោក យឿន ចឹម ជាអគ្គលេខាធិការ មកដល់ឆ្នាំ ១៩៦៤
- លោក វ៉ាយ ប៊ុក ជាអគ្គលេខាធិការ ពីឆ្នាំ ១៩៦៤ ដល់ ១៩៦៥
- លោក លាង ហ៊ាបអាន ជានាយក ពីឆ្នាំ ១៩៦៥ ដល់ ១៩៧៣
- លោក អ៊ុក សាម៉ន ជានាយក, កាន់ការបន្តពីលោក លាង ហ៊ាបអាន ពីឆ្នាំ ១៩៧៣ ដល់ថ្ងៃ១៦ មេសា ១៩៧៥ ក្នុងសម័យកាលសាធារណរដ្ឋខ្មែរ ។

គួរតកត់សម្គាល់ថា ការផ្លាស់ប្តូរឋានៈនៃអ្នកដឹកនាំ ពុទ្ធសាសនបណ្ឌិត្យ ពី " អគ្គលេខាធិការ " មកជា " នាយក " បញ្ជាក់អោយយើងយល់ថា ត្រូវបានធ្វើឡើងដោយអត្ថបទច្បាប់ណាមួយហើយ ។ ប៉ុន្តែ គួរអោយស្តាយ, អត្ថបទច្បាប់នោះពុំទាន់បានរកឃើញទេ ។ អត្ថបទនោះ អាចនឹងមានចែងពីការចាត់តាំង, ពីការរៀបចំរចនាសម្ពន្ធថ្មី ឬក៏ពីវិសាលភាពនៃការងាររបស់ពុទ្ធសាសនបណ្ឌិត្យ ទៀតផង ?

*ខ. សមិទ្ធិផលដ៏ធំធេងដែលពុទ្ធសាសនបណ្ឌិត្យសំរេចបាន :*

តាមការរៀបរាប់សង្ខេបៗខាងលើ គេបានកត់សម្គាល់ឃើញថា ព្រះរាជបណ្ណាល័យក្តី ក្រុមជំនុំព្រះត្រៃបិដកក្តី និងពុទ្ធសាសនបណ្ឌិត្យ ខាងក្រោយនេះក្តី ត្រូវបានចងក្រងជាក្រុមតែមួយ ឋិតក្រោមដំបូល " ពុទ្ធសាសនបណ្ឌិត្យ " ។ ក្រៅពីការងារស្វែងរក, ប្រមូលផ្តុំ, និងរក្សាទុកឯកសារ ហើយនិងការបោះពុម្ពផ្សាយសៀវភៅធម៌ - អក្សរសាស្ត្រជាតិ ជាមួយនឹងការចេញផ្សាយទស្សនាវដ្តី " កម្ពុជសុរិយា ", ការងារដ៏ចំបងលេចធ្លោមួយរបស់ពុទ្ធសាសនបណ្ឌិត្យ គឺការប្រែព្រះត្រៃបិដកពីភាសាបាលី មកជាភាសាខ្មែរ ។ នេះជាព្រឹត្តិការណ៍មួយដ៏ធំ ជឿនលឿនបដិវត្តន៍ខ្ពស់ ដែលពុំធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពុទ្ធសាសនា ។ ពីព្រោះថា តាំងអំពីព្រះពុទ្ធបរមគ្រូបានយាងចូលបរិនិព្វានទៅ រហូតមកដល់ពេលដែលគម្ពីរព្រះត្រៃបិដកត្រូវបានបកប្រែជាភាសាខ្មែរចប់ និងបោះពុម្ពរួចហើយសព្វគ្រប់ ក្នុងឆ្នាំ ១៩៦៨

( ១៩២៩ - ១៩៦៩ ) គេមិនទាន់បានឃើញ, បានដឹង, បានឮ ទោះជានៅក្នុងគម្ពីរដីកា ឬក្បួនច្បាប់ ឬក៏ពង្សាវតារណា ថាមានគេប្រែព្រះត្រៃបិដកជាភាសាជាតិណាមួយ បានចប់សព្វគ្រប់ ដូចជាអ្នកប្រាជ្ញខ្មែរបានធ្វើនោះឡើយ ។ សូម្បីរឿងដំណាលនៅក្នុងគម្ពីរបាលី មានគម្ពីរមហាវង្ស ជាដើម តាំងពីពុទ្ធសករាជទី ១ គឺក្រោយពេលព្រះពុទ្ធចូលបរិនិព្វានទៅបានប្រមាណ ៣ ខែ ព្រះអរហន្តទាំង ៥០០ អង្គ មានព្រះមហាកស្សបត្ថេរ ជាប្រធាន បានប្រជុំគ្នាធ្វើសង្គាយនាជាដំបូង សូធ្យផ្ទៀងផ្ទាត់ព្រះពុទ្ធ-វចនៈ អោយតាំងនៅត្រឹមត្រូវដូចដើម តាមការចងចាំរត់មាត់ ដែលហៅថា *មុខបាឋ*, ក៏សង្គាយនានេះ ពុំបានធ្វើការបកប្រែពុទ្ធវចនៈ ទៅជាភាសាជាតិណាមួយឡើយ ដោយគ្រាន់តែបានសូធ្យផ្ទៀងអោយត្រូវគ្នា ហើយចងចាំទុកក្នុងស្មារតីតែប៉ុណ្ណោះ។

តពីនោះមក មានសង្គាយនា ៤ លើកទៀត ។ សង្គាយនាលើកទីពីរ ធ្វើឡើងក្រោយព្រះពុទ្ធបរិនិព្វានទៅបាន ១០០ ឆ្នាំ ក្រោមអធិបតីភាពព្រះសព្វកាមិ-ត្ថេរ, សង្គាយនាទីបី ធ្វើឡើងក្រោយពុទ្ធបរិនិព្វានបាន ២១៨ ឆ្នាំ ក្រោមអធិបតីភាពព្រះមហាមោគ្គលិបុត្តតិស្សត្ថេរ, សង្គាយនាទីបួន បានប្រារព្ធឡើងក្នុង ព.ស. ២៣៦ ក្រោមការចាត់ចែងរបស់ព្រះមហិន្ទត្ថេរ ។ សង្គាយនាទាំងបីលើកនេះ មិនបានធ្វើអ្វីប្លែកពីសង្គាយនាទីមួយនោះទេ គឺគ្រាន់តែបានសូធ្យផ្ទៀងផ្ទាត់ពុទ្ធវចនៈ អោយបានត្រឹមត្រូវដូចបឋមសង្គាយនាប៉ុណ្ណោះ ។ លុះដល់មកសង្គាយនាទីប្រាំ ធ្វើនៅប្រទេសស្រីលង្កា ក្នុង ព.ស ៥១៨ ទើបមានការប្លែកបន្តិច ដោយហេតុថា ពុទ្ធវចនៈដែលបានសូធ្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានគេចារឹកដាក់លើស្លឹករឹត ជាលាយលក្ខណ៍អក្សរមុនគេបង្អស់ក្នុងប្រវត្តិពុទ្ធសាសនា, ប៉ុន្តែ ពុំមានដំណាលថា បានប្រែពុទ្ធវចនៈចាកភាសាបាលីមកជាភាសាក្នុងស្រុក សូម្បីតែមួយក៏ទេដែរ គឺគ្រាន់តែបានផ្ទៀងផ្ទាត់ពុទ្ធវចនៈ គឺព្រះត្រៃបិដកនេះអោយត្រឹមត្រូវដូចដើម ហើយចារឹកទុកលើស្លឹករឹត ។ ចំណេរក្រោយមក ព្រះពុទ្ធឃោសាចារ្យ បាននិមន្តទៅចម្លងព្រះត្រៃបិដក

នៅឯលង្កាទ្វីប យកមកផ្សាយក្នុងជម្ពូទ្វីប គឺប្រទេសឥណ្ឌា ដោយគ្រាន់តែចម្លងតាមច្បាប់ដើម តាមការប្រែពីភាសា (អក្សរ) សីហឡ ទៅជាមគធភាសាប៉ុណ្ណោះ ។ ក្រៅពីនេះ លោកបានព្យាយាមប្រែអដ្ឋកថា ចាកសីហឡភាសា មកជាមគធភាសា គឺភាសាបាលី ក្នុងរវាងពុទ្ធសករាជ ៩៥៦ ផងដែរ ។

ចំណេរកាលក្រោយមកទៀត ក៏មានសង្គាយនារាយរងបន្តបន្ទាប់មក, ធ្វើនៅប្រទេសស្រីលង្កា, ប្រទេសភូមា, នៅប្រទេសសៀម ។ នៅប្រទេសភូមា បន្ទាប់ពីការធ្វើសង្គាយនារួចហើយ គេបានចារឹកពុទ្ធវចនៈជាលាយលក្ខណ៍អក្សរ នៅលើផែនថ្មកែវច្រើនរយផ្ទាំង នៅក្រុងមណ្ឌលេ នៅក្រុងប៉េគូ នៅថាទង ( ស្រុកមាស )។ ( ប្រពៃណីជនជាតិមន កំណត់ថា ថាទងនេះហើយជា " សុវណ្ណភូមិ " នោះ ។

នៅប្រទេសកម្ពុជា តាំងពីពេលដែលព្រះពុទ្ធសាសនា បានមកប្រតិស្ឋាននៅលើទឹកដីនេះ គេពុំដែលបានឮ បានដឹង ថាមានធ្វើសង្គាយនាព្រះត្រៃបិដក ម្តងណាឡើយ ។ ទើបតែក្នុងរាជ្យព្រះបាទស៊ីសុវត្ថិមុនីវង្ស ព្រះបរមខត្តិយកោដ្ឋ ទើបមានសង្គាយនាព្រះត្រៃបិដក គឺការពិនិត្យផ្ទៀងផ្ទាត់ ប្រែពុទ្ធវចនៈចាកភាសាបាលីមកជាភាសាខ្មែរនេះឡើង ។ អ្នកប្រាជ្ញ បណ្ឌិតខ្មែរ បានចាត់ទុកការងារប្រែព្រះត្រៃបិដកនេះ ថាជាសង្គាយនារបស់ខ្មែរ ដែលស៊ីពេលវេលាអស់ ៤០ ឆ្នាំគត់ គឺចាប់ដំណើរការតាំងពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៦៩ ទើបប្រែចប់ និងបានបោះពុម្ពជាសៀវភៅចំនួន ១១០ ក្បាល រួចរាល់សព្វគ្រប់ ។ គេបានចាត់ទុកសង្គាយនាព្រះត្រៃបិដកជាពុទ្ធវចនៈនៅប្រទេសកម្ពុជា ជាសង្គាយនាទីប្រាំមួយ ឬជា " សង្គាយនាដ៏ឧត្តម " ពីព្រោះ មានលក្ខណៈពិសេសមួយដែលមិនធ្លាប់មាននៅក្នុងប្រវត្តិពុទ្ធ.សាសនា នោះគឺការប្រែពុទ្ធវចនៈជាភាសាបាលី ដែលមានរាប់ពាន់ឆ្នាំមកហើយ ទៅជាភាសាជាតិខ្មែរ ។ នេះជាលក្ខណៈពិសេស លើសសង្គាយនាទាំងឡាយ ដែល

បានធ្វើពីពេលមុនៗ ហើយក៏ជាការងារធំធេងលើសគេ ដែលប្រទេសកាន់ពុទ្ធ-សាសនាក្តី មិនកាន់ពុទ្ធសាសនាក្តី មិនទាន់ធ្វើបាននៅឡើយ មកដល់អំឡុងទសវត្សឆ្នាំ ៦០ [១] ។

ការងារដ៏សំខាន់មួយទៀត នៅក្នុងរង្វង់ជាតិរបស់ពុទ្ធសាសនបណ្ឌិត្យនោះគឺ ការស្វះស្វែងរក, ប្រមូលចងក្រង, រក្សាទុកនូវរាល់ឯកសារសរសេរដៃពីបុរាណនៅលើក្រាំង លើស្លឹករឹត លើក្រដាស ហើយចាត់ចែងបោះពុម្ពផ្សាយនូវស្នាដៃទាំងឡាយនោះៗជាភាសាខ្មែរ ជាភាសាបាលី ភាសាសំស្ក្រឹត និងភាសាបរទេស ដែលទាក់ទងដល់អក្សរសាស្ត្រ វប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ខ្មែរ ព្រមទាំងលទ្ធិ, អក្សរសាស្ត្រ និងវប្បធម៌ ពុទ្ធសាសនា ។ តាំងពីពេលកកើតមក ពុទ្ធសាសនបណ្ឌិត្យបានបំពេញភារកិច្ចទាំងនេះស្ទើរតែផ្តាច់មុខ ដែលជាហេតុនាំអោយពុទ្ធសាសនបណ្ឌិត្យមានកេរ្តិ៍ឈ្មោះថា *ជាមជ្ឈមណ្ឌលរក្សាទុកនូវឯកសារកម្រៗ ដ៏មានតម្លៃរបស់ជាតិ និងជាមជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌ អក្សរ-សាស្ត្រ ប្រពៃណី និងចំណេះដឹងរបស់ជាតិ* ។ ក្នុងន័យនេះហើយ ទើបពុទ្ធសាសន-បណ្ឌិត្យ ត្រូវបានអ្នកសិក្សា អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ជាច្រើន ចាត់ទុកថាជាមជ្ឈមណ្ឌលជាតិមួយដ៏សំខាន់ នៃឯកសារសមោធាន ។

សារសំខាន់នៃតួនាទីរបស់ពុទ្ធសាសនបណ្ឌិត្យ ចំពោះសង្គមជាតិ នៅមានច្រើនចំណុចណាស់ ។ ចំណុចសំខាន់លេចធ្លោមួយចំនួនតិចប៉ុណ្ណោះ ត្រូវបានលើកយកមករៀបរាប់អោយមើលឃើញគុណសម្បត្តិរបស់ពុទ្ធសាសនបណ្ឌិត្យ ដែលបានរួមចំណែកធ្វើអោយសង្គមជាតិខ្មែរ បានរីកចំរើនខាងបញ្ញាស្មារតី និងដែលបាន

(១) សូមអាន : " ឧប្បត្តិហេតុនៃព្រះត្រៃបិដកប្រែ " ប្រមូលចងក្រងដោយពុទ្ធសាសន-បណ្ឌិត្យ បោះពុម្ពឆ្នាំ ១៩៦៩, និង " ព្រះត្រៃបិដកជាភាសាខ្មែរ " រៀបរៀងដោយព្រះភិក្ខុវិរិយបណ្ឌិតោ ប៉ាង ខាត, ឆ្នាំ ១៩៧០ ។

សន្សៃសន្សំប្រមូលទុកនូវទ្រព្យសម្បត្តិខាងបញ្ញា . ស្មារតី សេសសល់តិចតួចរបស់ជាតិខ្មែរ បន្ទាប់ពីការរលំរលាយនៃអរិយធម៌អង្គរ ។ ទ្រព្យសម្បត្តិខាងបញ្ញា . ស្មារតីរបស់ជាតិ ដែលពុទ្ធសាសនបណ្ឌិត្យបានរក្សាទុកកាលនោះ មានចំនួនតិច និងមានគុណភាពទាបជាងវប្បធម៌ . អរិយធម៌អង្គរឆ្ងាយណាស់ ។ ប៉ុន្តែ សមិទ្ធផលខាងបញ្ញា . ស្មារតីដ៏តិចតួច ខ្សត់គុណភាពទាំងប៉ុន្មាននោះទៀត ស្រាប់តែត្រូវបានគេជាន់ពន្លិច, បំផ្លាញកំទេច នៅក្នុងរយៈពេលគ្រប់គ្រងប្រទេស ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ នៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រល័យពូជសាសន៍ ដឹកនាំដោយមហាឧក្រិដ្ឋជន ប៉ុល ពត ។ ពុទ្ធសាសនបណ្ឌិត្យ ដ៏ជាមជ្ឈមណ្ឌលវប្បធម៌ជាតិ ផ្នែកស្មារតី ឬហៅម្យ៉ាងទៀតថា ជាមជ្ឈមណ្ឌលខួរក្បាលរបស់ជាតិនោះ ត្រូវរលំរលាយ រលើងឫសគល់ បាត់បង់ជីវិតសូន្យសុង ក្នុងអំឡុងពេលកាន់អំណាចនៃរបបទមិឡ អន្យតិរ្ថិយ៍ បីឆ្នាំប្រាំបីខែ ម្ភៃថ្ងៃ ។

ដោយមើលឃើញគុណប្រយោជន៍ដ៏ឧត្តុង្គឧត្តម របស់ពុទ្ធសាសនបណ្ឌិត្យដ៏ថ្លៃថ្នោះហើយ . បើទោះជាមានតែបាតដៃទទេ . ក៏យើងត្រូវតែពុះពារគ្រប់ការលំបាក អត់ធ្មត់ជាអតិបរមា ស្តារលទ្ធភាព និងសមត្ថភាពការងាររបស់បុគ្គលិក ដើម្បីកសាងពុទ្ធសាសនបណ្ឌិត្យ អោយបានរុងរឿងឡើងវិញជាដាច់ខាត ។

## II. *ស្ថានភាព និងការងារ របស់ពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្ន*

### *ក. ការស្តារស្ថាប័ន និងសកម្មភាពការងារ*

នៅក្នុងឆ្នាំ ១៩៧៩ ពុទ្ធសាសនបណ្ឌិត្យ បានត្រដររស់ឡើងវិញ ឋិតនៅក្រោមការគ្រប់គ្រងរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា, ហើយបានមកជ្រកកោននៅក្នុងអតីតធម្មសភា វត្តឧណ្ណាលោម ជាមួយនឹងសៀវភៅចាស់ៗ ប្រមូលបាន សេសសល់ពីការបំផ្លាញ ប្រមាណមួយរយចំណងជើងប៉ុណ្ណោះ ដោយពុំមាន

សកម្មភាពអ្វីធំដុំគួរកត់សម្គាល់ទេ ។ ស្ថានភាពត្រដររស់នោះ បានបន្តរហូតមកដល់ឆ្នាំ ១៩៩២ ជាឆ្នាំដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តច្បាប់បង្កើតអោយមានក្រសួងធម្មការឡើងវិញ, ដើម្បីអោយក្រសួងនេះគ្រប់គ្រងកិច្ចការពុទ្ធសាសនា និងពាហិរសាសនា, គ្រប់គ្រងពុទ្ធិកសិក្សា និងគ្រប់គ្រងពុទ្ធសាសនបណ្ឌិត្យ តាមលំអានការគ្រប់គ្រងដែលមានមុនឆ្នាំ ១៩៧៥ ។

ចាប់តាំងពីដើមឆ្នាំ ១៩៩២ រៀងមក ពុទ្ធសាសនបណ្ឌិត្យ បានខិតខំស្តារសមត្ថភាព និងលទ្ធភាពរបស់ខ្លួនឡើងវិញ សំដៅចាប់យកនូវភាពរុងរឿងរបស់ខ្លួនឡើងវិញ ដោយបានសំរេចការងារដ៏ជោគជ័យ គួរអោយកត់សំគាល់ ៖

១. បានរៀបចំរចនាសម្ពន្ធរបស់ខ្លួនឡើងវិញ តាមរចនាសម្ពន្ធចាស់របស់ខ្លួនពីសម័យមុន គឺមាន ៖

- ការិយាល័យរដ្ឋបាល ;
- ក្រុមជំនុំព្រះត្រៃបិដក ;
- ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ;
- បណ្ណាល័យ ;
- គណៈកម្មការ " កម្ពុជសុរិយា " និងបោះពុម្ពផ្សាយ ;

បុគ្គលិកបំរើការក្នុងផ្នែកនានា នៃរចនាសម្ពន្ធថ្មីនេះ បានទទួលការបណ្តុះបណ្តាលជំនាញ និងការឧបត្ថម្ភលើកទឹកចិត្តពីមូលនិធិហិនរិសបីល អាល្លឺម៉ង់ និងអង្គការជំនួយសូត្តស៊ូជប៉ុន ( JSRC ) ផងដែរ ហើយមានសមត្ថភាពធានាការងារបានជាមូលដ្ឋាន ដូចជាបោះពុម្ពត្រឹមត្រូវ មិនភ្លាំងភ្លាត់បាលី - សម្រាយ, ចេញផ្សាយទស្សនាវដ្តី " កម្ពុជសុរិយា " ឡើងវិញ, ដំណើរការស្រាវជ្រាវប្រពៃណី ទំនៀមទម្លាប់ និងបន្តការបកប្រែគម្ពីរពីភាសាបាលី មកជាភាសាជាតិ គឺបកប្រែគម្ពីរមង្គលត្ថទីបនីទាំងបួនភាគ, ដោយធ្វើតាមលំនាំការបកប្រែព្រះត្រៃបិដក គឺបាលីនៅ

ទំពីរម្ខាង និងម្ខាងទៀត ជាសេចក្តីបកប្រែ ។

២. ដោយសារការឧបត្ថម្ភជាថវិកា អំពីអង្គការសាសនា និងមនុស្សធម៌ពីប្រទេសជប៉ុន និងការឧបត្ថម្ភបោះពុម្ពពីអង្គការជំនួយស្ងួតស្ង៉ ជប៉ុន ( JSRC ), ពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពឡើងវិញ នូវសៀវភៅសិក្សាភាសាបាលី សៀវភៅធម៌ សៀវភៅអក្សរសាស្ត្រ មានចំនួនជិត ៦០ ចំណងជើងហើយ និងមានចំនួនច្រើនម៉ឺនក្បាល អាចបំរើបានសំណូមពរពុទ្ធិកសិក្សា និងសំណូមពរចង់ចេះដឹងរបស់ព្រះសង្ឃ ព្រមទាំងពុទ្ធសាសនិកជនទូទៅបានឡើងវិញជាបណ្តើរៗ ។ ការបោះពុម្ពដ៏សំខាន់មួយ គឺការបោះពុម្ពគម្ពីរព្រះត្រៃបិដកឡើងវិញ ចំនួន ១.០០០ ចប់ ដែលឧបត្ថម្ភឡើងដោយក្រុមអង្គការសាសនា និងមនុស្សធម៌ជប៉ុន ។ ការឧបត្ថម្ភនេះបានជួយអោយអក្សរសាស្ត្រពុទ្ធសាសនា មានស្ថិរភាពយ៉ាងល្អ, បើទោះជាចំនួនបោះពុម្ពប៉ុណ្ណេះ មិនទាន់បំរើសំណូមពរព្រះសង្ឃ និងពុទ្ធសាសនិកជនបានគ្រប់វត្តអារាមក៏ដោយ ។ ពុទ្ធសាសនបណ្ឌិត្យ នឹងបន្តសុំការឧបត្ថម្ភបោះពុម្ពព្រះត្រៃបិដកជាថ្មីទៀតនៅពេលខាងមុខ កាលណាមានឱកាសមួយសមស្រប និងអនុគ្រោះ ។

៣. ដោយសារការឧបត្ថម្ភជាសម្ភារៈ អំពីអង្គការសាសនា និងមនុស្សធម៌ជប៉ុន និងអង្គការហ៊ានរិសបីល អាល្លឺម៉ង់ ពុទ្ធសាសនបណ្ឌិត្យ មានឧបករណ៍ប្រើប្រាស់គ្រប់គ្រាន់ សម្រាប់ការងារបោះពុម្ព សម្រាប់ការងារសោត-ចក្ខុទស្សន៍ សម្រាប់ដំណើរការងារការិយាល័យ និងមានថវិកាសមល្មម ធ្វើអោយកិច្ចការរបស់ពុទ្ធសាសនបណ្ឌិត្យ ប្រព្រឹត្តទៅស្រួល ។ រីឯថវិកាសម្រាប់ដំណើរការប្រចាំថ្ងៃ, សម្រាប់ប្រមូលផ្តុំឯកសារមួយផ្នែកផ្ទុកក្នុងបណ្ណាល័យ, សម្រាប់រៀបចំបង្កើតបណ្ណាល័យសាខា ពីចំនួន ១៨ ទៅ ២៥ កន្លែង នៅក្នុងខេត្ត-ក្រុង នានា, និងសម្រាប់បំផុសសកម្មភាពវប្បធម៌ ដូចជា ឧទ្ទេសកថា - សាកច្ឆាប្រចាំខែ ជាដើម គឺជាថវិកាឧបត្ថម្ភដោយមូលនិធិហ៊ានរិសបីល អាល្លឺម៉ង់ ។

៤. ដោយសារការឧបត្ថម្ភរបស់អង្គការហិនរិសបឺល អាល្លឺម៉ង់ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៩៣ រៀងមក, ពុទ្ធសាសនបណ្ឌិត្យ បានទទួលឋាមពលថ្មីមួយទៀត គឺការជួយលើកស្ទួយកិរិតចេះដឹងរបស់បុគ្គលិក នៅពុទ្ធសាសនបណ្ឌិត្យ ខាងគណនេយ្យ, ខាងភាសាអង់គ្លេស, និងខាងជំនាញកុំព្យូទ័រ ព្រមទាំងជំនាញខាងការគ្រប់គ្រងបណ្ណាល័យ និងខាងការគ្រប់គ្រងទូទៅ ផងដែរ ។

អ្វីដែលជាការយកចិត្តទុកដាក់ខ្ពស់ របស់មូលនិធិហិនរិសបឺល នោះគឺការកសាងឡើងវិញ នូវសម្បត្តិវប្បធម៌ខ្មែរដែលបាត់បង់ទៅ ។ នេះហើយជាមូលហេតុនាំអោយមូលនិធិហិនរិសបឺល ទទួលបន្ទុកកសាងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យស្ទើរតែទាំងស្រុង ដោយបានចំណាយថវិកាយ៉ាងច្រើន ថតចម្លងបោះពុម្ពឡើងវិញនូវទស្សនាវដ្តី " កម្ពុជសុរិយា " ដែលមានពីមុន ទិញសៀវភៅ និងឯកសារចាំបាច់ទាំងឡាយពីក្រៅប្រទេស និងក្នុងប្រទេស សម្រាប់តម្កល់ទុកក្នុងបណ្ណាល័យ របស់ពុទ្ធសាសនបណ្ឌិត្យ និងបណ្ណាល័យសាខា ។ សារពត៌មាន និងទស្សនាវដ្តីក្នុងស្រុកស្ទើរតែទាំងអស់ ក៏ត្រូវបានជាវជាប្រចាំឡើងវិញ ហើយចងក្រងទុកទៅតាមក្រុមតាមមពួក យ៉ាងរៀបរយ ។ បណ្ណាល័យសាខារបស់ពុទ្ធសាសនបណ្ឌិត្យ ចំនួន ១៨ កន្លែង ដែលបានរៀបចំហើយ កំពុងដំណើរការនៅក្នុងវត្ត តាមខេត្តមួយចំនួនហើយ និងបន្តពង្រីកថ្មីទៀត រហូតដល់ ២៥ កន្លែង ។

ក្រៅពីនេះ, បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ បានទទួលការឧបត្ថម្ភយ៉ាងសំខាន់មួយផ្នែកទៀត ពីមូលនិធិជប៉ុន សម្រាប់អាស៊ី តាមរយៈការប្រឹងប្រែងរបស់លោកសាស្ត្រាចារ្យ ម៉ាសាគី អូណូប៊ីរ្យាវ៉ា នៃវិជ្ជាស្ថានប្រវត្តិសាស្ត្រ និងនរវិទ្យា នៅសាកលវិទ្យាល័យ ត្សឹគូបា ប្រទេសជប៉ុន ។ សៀវភៅប្រមាណ ១.២០០ ចំណងជើងត្រូវបានទិញ និងបញ្ជូនមកអោយរួចហើយ ។ បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ រង់ចាំទទួលសៀវភៅច្រើនទៀត ដែលនឹងត្រូវបញ្ជូនមកពេលក្រោយ ។ រហូតដល់ពេល

នេះ បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានសៀវភៅ . ឯកសារ សំខាន់ៗ មិនតិចជាង ៦.០០០ ចំណងជើងឡើយ ហើយបានបើកទ្វារបំរើសាធារណជនទាំងសង្ឃ ទាំងគ្រហស្ថ រៀងរាល់ថ្ងៃធ្វើការ ។ ទំនាក់ទំនងផ្លាស់ប្តូរឯកសារបោះពុម្ព រវាងពុទ្ធ-សាសនបណ្ឌិត្យ និងបណ្ណាល័យសភាជាតិ ( the National Diet Library ) របស់ប្រទេសជប៉ុន ក៏កំពុងប្រព្រឹត្តទៅយ៉ាងល្អ ។ ទំនាក់ទំនងជាមួយវិជ្ជាស្ថាន, បណ្ណាល័យ ឬស្ថាប័នសិក្សា . ស្រាវជ្រាវ ក្នុងប្រទេស ឬអន្តរជាតិ កំពុងត្រូវបានពង្រីកបន្តបន្ទាប់ ដើម្បីប្តូរឯកសារគ្នាទៅវិញទៅមក សំដៅចែករំលែកចំណេះដឹង និងបទពិសោធន៍ទៅវិញទៅមក ។

៥. ដោយសារមានប្រភពធនធានឧបត្ថម្ភ ដូចបានរៀបរាប់ខាងលើ, ពុទ្ធសាសនបណ្ឌិត្យ កាន់តែមានលទ្ធភាពធំទូលាយ បំពេញការងាររបស់ខ្លួន ក្នុងស្ថានភាពល្អបង្គួរ . ដោយមិនលើកយកបញ្ហាចម្រូងចម្រាសគ្មានហេតុ . ផលខ្លះៗ ដែលបានកើតមានឡើង មកធ្វើជាឧបសគ្គផងទេ ។ ពុទ្ធសាសនបណ្ឌិត្យ កំពុងធ្វើដំណើរទៅចាប់យកនីតិឋាន ( Legal status ) ចាស់របស់ខ្លួនឡើងវិញ ដើម្បីពង្រីកវង្វង់សកម្មភាពការងាររបស់ខ្លួនអោយបានប្រសើរ ។ ផ្អែកលើប្រភពធនធាននេះ ពុទ្ធសាសនបណ្ឌិត្យ មានលទ្ធភាពជំរុញការគោរពប្រតិបត្តិធម៌អាថ៌ និង ការសិក្សារបស់ព្រះសង្ឃ តាមរយៈការចុះដល់មូលដ្ឋាន ចែកផ្សាយដោយឥតគិតថ្លៃ នូវសៀវភៅធម៌ និងសៀវភៅសិក្សាភាសាបាលីមួយចំនួន ដែលបោះពុម្ពនៅក្នុងស្រុក និងក្រៅស្រុក ( តៃវ៉ាន់ ) ដល់គ្រប់វត្តទូទាំងប្រទេស ។ សៀវភៅទាំងនោះ មានជាអាទិ៍ សត្តបរិត្ត, ភាណវារៈបាលី, ប្រស្នាវិន័យបិដក, បទានុក្រមបាលីអភិធានប្បទីបិកា, បទានុក្រមធម្មបទ, ... ។

ការពង្រីកសកម្មភាពបណ្ណាល័យ នៅតាមវត្តអារាមសំខាន់ៗ នឹងបន្តយកចិត្តទុកដាក់ជាអាទិភាព ដើម្បីរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស ទាំងបព្វជិត ទាំង

គ្រហស្ថ ។

*ខ. ការវាយតម្លៃលើសកម្មភាពការងារ និងការគ្រប់គ្រង :*

តាមការរៀបរាប់ពីសកម្មភាពការងារខាងដើម, គេអាចមានសេចក្តីពេញចិត្តចំពោះការរស់ឡើងវិញដ៏ឆាប់ របស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងរយៈពេលដ៏ខ្លីគឺក្នុងអំឡុងពេលប្រមាណបួនឆ្នាំ ។ ពុទ្ធសាសនបណ្ឌិត្យ បានដើរតួយ៉ាងសំខាន់ ក្នុងដំណើរកសាង និងជួសជុលឡើងវិញ នូវវប្បធម៌ជាតិ និងពុទ្ធសាសនា ។ ទោះបីសមិទ្ធផលទាំងនោះ របស់ពុទ្ធសាសនបណ្ឌិត្យ បានកកើតឡើងយ៉ាងយឺត១ ហើយមានចំនួនតិចតួចក្តី, ក៏គេបានចាត់ទុកថា នោះគឺជាជំហានដ៏សំខាន់ ឆ្ពោះទៅរកការកសាងគ្រឹះរបស់ពុទ្ធសាសនបណ្ឌិត្យឡើងវិញ ដែលត្រូវបានគេកំទេចដល់ឫសកែវហើយនោះ ។

អំណោយថវិកាបោះពុម្ពសៀវភៅឡើងវិញ ព្រមទាំងសម្ភារៈ . បរិក្ខារឧបករណ៍ផ្សេង១ បានមកពីអង្គការសាសនា និងអង្គការមនុស្សធម៌ប្រទេសជប៉ុនហើយនិងវិភាគទានដ៏សំខាន់ របស់មូលនិធិហិនរិសបឺល ក្នុងការជួសជុលអគារទាំងពីរ សម្រាប់ប្រើជាបណ្ណាល័យ និងជាការិយាល័យ ជាមួយនឹងសាលប្រជុំផង ប្រកបដោយសម្ភារៈប្រើប្រាស់ជាច្រើន ដូចជា កុំព្យូទ័រ, ទូរស័ព្ទ, ទូរសារ, ម៉ាស៊ីនថតចម្លង, ម៉ាស៊ីនថតរូប . ថតវីដេអូ, ម៉ាស៊ីនភ្លើង ជាដើម ... ធ្វើអោយពុទ្ធសាសនបណ្ឌិត្យមានសមត្ថភាពបំពេញមុខងាររបស់ខ្លួន ជាការិយាល័យរដ្ឋបាល និងបោះពុម្ពផ្សាយ, ជាបណ្ណាល័យ និងជាវិជ្ជាស្ថានស្រាវជ្រាវ រក្សាទុកឯកសារ ថែមទៀត ។

ការរីកចំរើនរបស់បណ្ណាល័យ គឺជាក់ស្តែងជាងការងារស្រាវជ្រាវ ។ ចំនួនសៀវភៅ កើនពី ១.០០០ ចំណងជើង ក្នុងឆ្នាំ ១៩៩៤ ដល់ ៦.០០០ ចំណងជើង ក្នុងដំណាច់ឆ្នាំ ១៩៩៦ ។ ទស្សនាវដ្តីកម្ពុជសុរិយា ត្រូវបានបោះពុម្ពឡើងវិញ

ជាបន្តបន្ទាប់ និងបានចេញលេខថ្មីបន្ត ។ បណ្ណាល័យសាខា ចំនួន ១៨ កន្លែង ត្រូវបានរៀបចំហើយ, សៀវភៅទាំងឡាយសម្រាប់បណ្ណាល័យទាំងនោះ ក៏បានបញ្ជូនទៅអោយរួចហើយដែរ ។

ការងារស្រាវជ្រាវ ធ្វើបានតិចតួចណាស់ ហើយខ្វះទាំងបរិមាណ និងគុណភាពថែមទៀត ។ សៀវភៅថ្មីៗ ផ្អែកលើការស្រាវជ្រាវថ្មី ពុំទាន់មានបោះពុម្ពច្រើនទេ ថ្វីបើមានអត្ថបទចុះផ្សាយក្នុងកម្ពុជសុរិយា បានផ្អែកលើការស្រាវជ្រាវមានគុណភាពមធ្យមក៏ដោយ ។ ការផ្សព្វផ្សាយអំពីបណ្ណាល័យអោយបានទូលំទូលាយ ចូលជ្រៅក្នុងសាធារណជន មិនទាន់ធ្វើបាននៅឡើយ ។ ការធ្វើផែនការដើម្បីបង្កើនការប្រើបណ្ណាល័យ និងការប្រើសម្ភារៈស្រាវជ្រាវ ចង់ក្រងបានជាអត្ថបទសរសេរ, ជាខ្សែអាត់ ឬជាខ្សែវីដេអូ ក៏ពុំទាន់បានអនុវត្តអោយបានទូលំទូលាយដែរ ។

រីឯរចនាសម្ពន្ធ និងនីតិឋាន ឬទីតាំងច្បាប់ ( legal status ) របស់វិទ្យាស្ថាន ក៏ពុំទាន់បានរៀបចំច្បាស់លាស់ ដើម្បីឆ្ពោះទៅកាន់ភាពឯករាជ្យម្ចាស់ការមានលក្ខន្តិកៈជាវិទ្យាស្ថានស្វ័យ័ត និងមានក្រុមប្រឹក្សាភិបាលមួយទូលំទូលាយសម្រាប់ជួយតម្រង់ទិសសកម្មភាព របស់ពុទ្ធសាសនបណ្ឌិត្យ ។ ការប្រព្រឹត្តទៅរបស់ពុទ្ធសាសនបណ្ឌិត្យ ត្រូវការអោយមានការប្រជុំទៀងទាត់ ដើម្បីដោះស្រាយការងារដាក់ចេញជាផែនការ សកម្មភាព, រៀបចំគោលនយោបាយ, កម្មវិធីការងារ និងដំណើរការអនុវត្តបានល្អ ។ ការខិតខំរៀបចំបែបនេះ ត្រូវប្រព្រឹត្តទៅដំណាលគ្នានឹងការបណ្តុះបណ្តាលធនធានមនុស្ស, ដែលកិច្ចការនេះជាចំណុចទន់ខ្សោយមួយរបស់ពុទ្ធសាសនបណ្ឌិត្យ ។

### III. *ទិដ្ឋភាពអនាគត សម្រាប់ការងារ របស់ពុទ្ធសាសនបណ្ឌិត្យ*

ក្នុងឆ្នាំខាងមុខ, ពុទ្ធសាសនបណ្ឌិត្យ នឹងមានអគារថ្មីសម្រាប់ធ្វើការងារ។

សំណូមពរ និងសេចក្តីត្រូវការថ្មីៗរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងស្ថានភាពថ្មី ប្រាកដជានឹងកើតមាន ។ ដោយហេតុនេះ ពុទ្ធសាសនបណ្ឌិត្យ កំពុងយកចិត្តគិតគូរអភិវឌ្ឍន៍នូវវិស័យ ដូចតទៅនេះ :

១. រៀបចំនីតិឋាន ឬទីតាំងច្បាប់ ( legal status ) សម្រាប់ពុទ្ធ-សាសនបណ្ឌិត្យ ឡើងវិញ ។ ផ្អែកលើអត្ថបទច្បាប់នេះ, ខិតខំរៀបចំការគ្រប់គ្រង និងរចនាសម្ពន្ធស្ថាប័នជាថ្មី អោយមានថ្នាក់ដឹកនាំមានសមត្ថភាពខ្ពស់ និងមានក្រុមប្រឹក្សាភិបាលមួយ ( Administrative Board ) និងគណៈកម្មការផ្សេងៗទៀត រួមចំណែកដឹកនាំការងាររបស់ពុទ្ធសាសនបណ្ឌិត្យ ។

២. លើកកំពស់សមត្ថភាព និងមុខជំនាញធ្វើការងាររបស់បុគ្គលិក ( Re-source Base ) តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លី ឬមធ្យម ។ ជ្រើសរើសបន្ថែមបញ្ជរន្តថ្មី និងអ្នកមានពិសោធន៍ និងមានសមត្ថភាព ( មន្ត្រីចូលនិវត្តន៍ ) ចូលរួមក្នុងការងារស្រាវជ្រាវ, ចងក្រងឯកសារ សម្រាប់បោះ ពុម្ពផ្សព្វផ្សាយ ។

ពុទ្ធសាសនបណ្ឌិត្យ ត្រូវត្រៀមខ្លួនរួមចំណែកផ្តល់ឯកសារ, និងសៀវភៅសិក្សាចាំបាច់, ផ្តល់ទិន្នន័យ, ចំណេះដឹងវិទ្យាសាស្ត្រ និងមនុស្សសាស្ត្រ បានមកពីការស្រាវជ្រាវ សម្រាប់ការអភិវឌ្ឍន៍ពុទ្ធិកសិក្សា ( Buddhist education ) មានជាអាទិ៍ ផ្នែកភាសាបាលី, សំស្ក្រឹត, អក្សរសាស្ត្រ, ទស្សនវិជ្ជា, សាសនាប្រៀបធៀប, ប្រវត្តិសាស្ត្រ, សង្គមវិជ្ជា, ... ។

៣. ខិតខំរកមូលនិធិ ដើម្បីបោះពុម្ពឡើងវិញ អោយអស់លទ្ធភាព នូវសៀវភៅធម៌, អក្សរសាស្ត្រ, រឿងព្រេង, ... ដែលជាសម្បត្តិកម្មសិទ្ធិរបស់ពុទ្ធ-សាសនបណ្ឌិត្យ ឬជាសម្បត្តិកម្មសិទ្ធិឯកជន ប៉ុន្តែជាស្នាដៃនិពន្ធរបស់ព្រះសង្ឃ ឬអតីតសង្ឃមានកិត្តិសព្ទ ។ សៀវភៅ ឬស្នាដៃខាងក្រោយនេះ យ៉ាងហោចណាស់ក៏ត្រូវបានបោះពុម្ពចំនួនតិច ឬថតចម្លងទុកក្នុងបណ្ណាល័យរបស់ពុទ្ធសាសនបណ្ឌិត្យ

ជាសម្បត្តិមនុស្សជាតិ តទៅ ។

៤. ខិតខំបង្កើន និងពង្រឹងទំនាក់ទំនងអន្តរជាតិ ជាមួយវិជ្ជាស្ថានបរទេស ឬស្ថាប័ន និងអង្គការបរទេសទាំងឡាយ ដែលមានគោលបំណង និងកម្មវត្ថុស្របគ្នា តាមរយៈការប្តូរសៀវភៅ ឯកសារ ទស្សនកិច្ច ឬកិច្ចសហប្រតិបត្តិការណាមួយ ដែលមានប្រយោជន៍ទាំងសងខាង ។

ពុទ្ធសាសនបណ្ឌិត្យ យកចិត្តទុកដាក់ជាពិសេស ថែរក្សាទំនាក់ទំនងកំពុងមានស្រាប់ ជាមួយមូលនិធិហិនរិសបឹល អាល្លឺម៉ង់, ជាមួយអង្គការជំនួយស្ងួត្ត ស៊ូ ជប៉ុន ( JSRC ) និងជាមួយបណ្តាអង្គការសាសនា អង្គការសប្បុរសប្រទេសជប៉ុន ដែលបានផ្តល់ការឧបត្ថម្ភយ៉ាងធំធេង រួមចំណែកធ្វើអោយវប្បធម៌ពុទ្ធសាសនា និងវប្បធម៌ខ្មែរ មានជីវិតស្រស់បំព្រងជាថ្មី ។

៥. ផ្អែកលើអត្ថបទច្បាប់ ដែលនឹងសំរេចបាន, ពុទ្ធសាសនបណ្ឌិត្យ នឹងបន្តខិតខំពង្រីកតួនាទី និងភារកិច្ចរបស់ខ្លួន អោយបានឋានៈដូចដើមឡើងវិញ គឺដូចនៅក្នុងសម័យកាលមុនឆ្នាំ ១៩៧៥ ។ កាលនោះ ពុទ្ធសាសនបណ្ឌិត្យ មានឋានៈប្រហាក់ប្រហែលគ្នាអគ្គនាយកដ្ឋាន, ដឹកនាំដោយថ្នាក់អគ្គលេខាធិការ, មានស្វ័យភាពថវិកា និងស្វ័យភាពគ្រប់គ្រង និងចាត់ចែងការងារ ឋិតក្រោមឱវាទក្រសួងធម្មការ ។ ល័ក្ខខ័ណ្ឌបែបនេះ អនុញ្ញាតអោយពុទ្ធសាសនបណ្ឌិត្យ មានសេរីភាពក្នុងការបំពេញការងារ និងគិតគូរសំរេចការងារបានល្អជាង ។

ដើម្បីបញ្ចប់សេចក្តីរាយការណ៍នេះ ខ្ញុំព្រះករុណា ខ្ញុំ សូមស្វាគមន៍រាល់មតិ យោបល់ស្ថាបនាទាំងឡាយ អំពីសម្តេច ព្រះតេជព្រះគុណ អស់លោក លោកស្រី ដែលបានចូលរួមក្នុងអង្គមហាសន្និបាតនេះ មកលើទស្សនៈអនាគតសម្រាប់ពុទ្ធសាសនបណ្ឌិត្យ ដូចបានរៀបរាប់ខាងលើនេះ ។ មតិ យោបល់ស្ថាបនាទាំងនោះ សម្រាប់ពុទ្ធសាសនបណ្ឌិត្យ កំពុងដំណើរការងារបច្ចុប្បន្ននេះក្តី

ឬសម្រាប់ពុទ្ធសាសនបណ្ឌិត្យនាពេលអនាគតក្ដី នឹងត្រូវបានកត់ត្រាទុកជាពន្លឺសម្រាប់ការពិចារណា ត្រិះរិះ រៀបចំ " ពុទ្ធសាសនបណ្ឌិត្យ " ដើម្បីបំពេញការងារធំធេងជាងបច្ចុប្បន្ននេះទៀត ស្របទៅតាមការរីកចំរើននៃសង្គមជាតិយើង ។ ខ្ញុំព្រះករុណា ខ្ញុំ សូមធ្វើការកត់សំគាល់ថា " *ពុទ្ធសាសនបណ្ឌិត្យ* " *មិនអាចត្រេកអរនៅត្រឹមតែសភាពដូចសព្វថ្ងៃនេះទេ, ហើយក៏មិនអាចពេញចិត្តបានត្រឹមតែសភាពដូចមុនឆ្នាំ ១៩៧៥ នោះដែរ ។ លើសនេះទៀត " ពុទ្ធសាសនបណ្ឌិត្យ " អាចបន្តដំណើរវិវត្តន៍ ប្រែប្រួល ទៅជាវិជ្ជាស្ថានសិក្សា ស្រាវជ្រាវមួយរបស់ជាតិ មានឋានៈខ្ពស់ជាង មានតួនាទី ភារកិច្ចប្រសើរជាង មានឯករាជ្យភាពជាងក្នុងការគ្រប់គ្រង និងចាត់ចែងការងារ, ...* ។

ឯកសារពិគ្រោះ :

១_ Ordonnance Royal N° 2, du 15 Janvier 1925.

២_ Ordonnance Royal N° 23, du 18 Mars 1926.

៣_ L' Arrêté N° 635, du Gouverneur Général de l' Indochine du 25 Janvier 1930.

៤_ " ឧប្បត្តិហេតុនៃព្រះត្រៃបិដកប្រែ " ចងក្រងដោយពុទ្ធសាសនបណ្ឌិត្យ ១៩៦៩

៥_ " ព្រះត្រៃបិដកជាភាសាខ្មែរ " រៀបរៀងដោយព្រះវិរិយបណ្ឌិតោ ប៉ាង ខាត់, ១៩៧០

៦_ Centres d'études bouddhique du Cambodge 1961.

៧_ Compulsory Education in Cambodia, Laos and Viet - Nam by Charles Bilodeau, Somolith Pathammavong, Lê Quang Hông. Unesco 1955.

---

គណៈកម្មការទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ប្រាសាទភិមានអាកាស កសាងក្នុងរវាងសតវត្សទី ១០ នៃគ.ស
ស្ថាបនាហើយក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី ១ ( ១០០២ - ១០៥០ គ.ស )


ឆ្នាំទី ៥១ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស ២៥៤១ គ.ស ១៩៩៧

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ឌារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងាររបស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាពរវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្ប-ធម៌ និងសម្បត្តិសាសនារបស់ប្រជាជនកម្ពុជា ។

## Acknowledgement

The Kambuja Suriya Magazine is specilly printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

I. អក្សរសិល្ប៍ពុទ្ធសាសនា

- ហីនយាន " ពុទ្ធសាសនាហីនយាន " ( ឈន អៀម ) ............ ១
- ឱវាទចុងក្រោយរបស់ព្រះពុទ្ធ ( ឱម ខែម ) ............ ១០

II. អក្សរសាស្ត្រទូទៅ

- ទំរង់ខាងវេយ្យាករណ៍ នៃ នរនាម ( បណ្ឌិត ឡុង សៀម) ............ ១៦
- អំពីលទ្ធិហិណ្ឌូ ( ឈន អៀម ) ............ ៣៥
- ពាក្យរណ្ដំបរិវាស័ព្ទក្នុងភាសាអក្សរសិល្ប៍ខ្មែរ (បណ្ឌិត ឡុង សៀម)... ៤៦
- ចន្ទគ្រាស - សូរ្យគ្រាស ( ឈន អៀម ) ............ ៧៣
- បញ្ហានៃសិលាចារឹក សម័យមុនអង្គរ ត-ចប់ ( វង់ សុធារ៉ា ... ) ............ ៨០
- អំពីល័ក្ខខ្មែរ ( មៀច ប៉ុណ្ណ ) ............ ៩៥
- ទំនៀមទម្លាប់ និង រឿងទាក់ទងភ្នំក្រោម ( វង់ សុធារ៉ា ) ............ ៩៩
- បទអក្សរល្បូន ( ធន់ ហ៊ិន ) ............ ១១០
- សាស្ត្រាក្រមច្បាប់ ( វត្តកំពង់សំបួរ ) ............ ១១៣
- សិល្បៈចម្រៀងចាប៉ី ( មៀច ប៉ុណ្ណ ) ............ ១២២

III. កំណាត់ និង ប្រវត្តិកាណ៍

- ពិធីទទួលសៀវភៅពីមូលនិធិជប៉ុន សំរាប់មជ្ឈមណ្ឌលអាស៊ី នៅ
ពុទ្ធសាសនបណ្ឌិត្យ ............ ១២៥

# ហីនយាន
## ( ពុទ្ធសាសនា ហីនយាន )

*ហីនយាន* « យានថ្នាក់ទាប » ជាស័ព្ទមួយដែលមានន័យបញ្ជិតបញ្ជៀង ដោយមើលស្រាល ត្រូវបានពួកអ្នកកាន់តាម មហាយាន ប្រើប្រាស់ដើម្បីកត់សម្គាល់ និកាយពីដំបូង១ នៃពុទ្ធសាសនា ដែលរួមមាន ពួកថេរវាទៈ, ពួកមហាសង្ឃិកៈ, ពួកសម្មិតិយៈ និងពួកសរ្វាស្តិវាទៈ ។ « យាន » ដែលជាពាក្យរួមផ្សំនៅក្នុងពាក្យ « ហីន-យាន » នេះ មានន័យតាមអក្សរសាស្ត្រថា យានដែលផ្ទុកអ្នកបើកបរ ឬអ្នកដំណើរទៅកាន់គោលដៅជាទីប្រាថ្នាចង់បានរបស់គេ ។ និយាយមួយបែបទៀត, ពាក្យ « យាន » យោងទៅរកន័យថា ផ្លូវ ( មគ្គៈ ឬមាគ៌ៈ ) ឬបដិបទា ( ការប្រតិបត្តិ ) ដែលនាំអ្នកប្រព្រឹត្តតាមទៅកាន់គោលដៅទីបំផុតរបស់គេ គឺព្រះនិព្វាន ។ ដើម្បីបានទៅដល់ព្រះនិព្វាន, សាវ័កទាំងឡាយរបស់ព្រះពុទ្ធ ត្រូវដើរតាម « យាន » នៃអរិយៈអដ្ឋង្គិកមគ្គ ( មគ្គដ្ឋង្គិកយាន ) ដែលមានពេលខ្លះ គេឱ្យឈ្មោះថា *ព្រហ្មយាន* និង *ធម្មយាន* ។

ថ្វីបើ អរិយៈ អដ្ឋង្គិកមគ្គៈ មិនត្រូវបានគេនិយាយយោងដល់ញឹកញាប់ថាជា « យាន » ក៏ដោយ, ក៏អដ្ឋង្គិកមគ្គៈ គឺជា *បដិបទា* ( ផ្លូវ ) ដែលសាវ័កត្រូវដើរតាម ឬជា *សាវកយាន* ដែលគេនិយាយយោងដល់ ទុកដូចជា « យានថ្នាក់ទាប ក្នុងន័យផ្ទុយទៅនឹងការសំរេចបាន « ពោធិ » ដែលជា « យានថ្នាក់ខ្ពស់ » ឬ « មហាយាន » ។ « យាន » នៃការសំរេចបាននូវព្រះនិព្វាននេះ ក្នុងឋានៈជាសាវ័ក ត្រូវបានពួកអ្នកកាន់តាមមហាយាន ចាត់ទុកថា « ថ្នាក់ទាប » ( ហីនៈ ) ។ ឧត្តមគតិរបស់អ្នកជឿតាមមហាយាន គឺការសំរេចបាន « ពោធិ » ( ការត្រាស់ដឹង ) តាមការ

បំពេញករណីយកិច្ចរបស់ព្រះពោធិសត្វ ។ អ្នកកាន់តាមមហាយាន អះអាងថា *ហីនយាន* អាចឈានដល់កំរិតខ្ពស់បំផុតត្រឹម អរហន្តភាព ( អរហត្ត ), ចំណែក *មហាយាន* ឡើងដល់កំរិតខ្ពស់បំផុតត្រឹមពុទ្ធភាព ហើយគេបាននិយាយយោង ដោយបន្ថយតម្លៃចំពោះហីនយានថា អហិត្យាន ឬ ស្រាវកយាន ( *អរហត្តយាន* ឬ *សាវកយាន* ), រីឯមហាយានវិញ ត្រូវបានគេអោយឈ្មោះថា *ពុទ្ធយាន* ឬ *ពោធិសត្វយាន* ។

សព្ទទាំងឡាយនេះ គឺ*ហីនយាន* និង*មហាយាន* រួមទាំងវេវចនសព្ទ នៃសព្ទទាំងពីរនេះផង គេមិនដែលឃើញមានប្រើនៅក្នុងអត្ថបទនៃគម្ពីរទាំងឡាយជាភាសាបាលី ឬនៅក្នុងគម្ពីរអាគមៈរបស់ចិនទេ, ប៉ុន្តែ គម្ពីរមហាយានស្ទើរតែទាំងអស់ប្រើសព្ទទាំងនេះ ។ សេចក្តីយោងពីដំបូងៗ ទាក់ទងដល់អ្នកប្រតិបត្តិតាមស្រាវកយាន ដែលមាននិយាយនៅក្នុងអត្ថបទពុទ្ធសាសនាជាភាសាសំស្ក្រឹតនោះ គឺហីនាធិមុក្តិកៈ គឺមានន័យថា អ្នកដែលរំដោះផុតទុក្ខដោយមធ្យោបាយថ្នាក់ទាប ។

កំណើតដើមនៃសព្ទ *ហីនយាន* រួមទាំងបញ្ញត្តិ ( Concept ) ដែលសព្ទនេះ ( ហីនយាន ) តំណាងផង គឺឋិតនៅក្នុងអន្ធការភាព ពោលគឺ ភាពពុំច្បាស់លាស់ ក៏ដូចជាកំណើតនៃសព្ទ *មហាយាន* នេះផ្ទាល់ផងដែរ ។ នៅក្នុងព្រះសូត្រ ពីដំបូងៗរបស់មហាយាន ដូចជា ប្រជ្ញាបារមីតា, សទ្ធមិបុណ្ឌរីកៈ, អវតំសិកៈ, គេបានប្រទះសព្ទអហិត្យានៈ និងស្រាវកយានៈ ជាញឹកញយណាស់, ប៉ុន្តែចំពោះសព្ទ *ហីន-យាន* វិញ គឺកម្រប្រទះឃើញណាស់ ។ នៅក្នុងបញ្ចវិសតិសាហាស្រិកា-ប្រជ្ញាបារ-មីតា, គេឃើញមានប្រើសព្ទនេះតែម្តងគត់, ចំណែកនៅក្នុងសទ្ធមិបុណ្ឌរីកសូត្រ សព្ទនេះឃើញមានប្រើតែពីរដងគត់ ។ ការប្រើសព្ទនេះ ( ហីនយាន ) ត្រូវបានឃើញជាញឹកញយនៅក្នុងមហាយានសូត្រ ដែលគេបានចាត់ទុកជាការតែងនិពន្ធក្នុងកាលជាខាងក្រោយមកទេ ។

បើទោះជាស័ព្ទ *ស្រាវកយាន* និង*អហិត្យាន* ឃើញមានប្រើនៅក្នុងព្រះសូត្រមហាយានពីដំបូងៗ ដើម្បីបញ្ជាក់អោយឃើញនូវហីនភាព ( inferiority ) នៃគំនិតដែលស័ព្ទទាំងនោះសំដែងឡើងក៏ដោយ, ក៏ស័ព្ទទាំងនោះ នៅតែមិនសមស្របក្នុងការបង្ហាញគំនិតអោយបានពេញលេញ សព្វគ្រប់ដែរ ។ ស័ព្ទ *ហីនយាន* ហាក់ដូចជាបានបង្កើតឡើងដោយមានបំណងច្បាស់លាស់ ដើម្បីថ្កោលទោសមកលើការសំរេចបាននូវនិព្វាន ដោយព្រះអរហន្តតែប៉ុណ្ណោះ ។ ចំពោះអ្នកជឿតាម *មហាយាន* គេយល់ថា ការក្លាយខ្លួនជាព្រះអរហន្ត គឺជាច្រកចេញដ៏ងាយមួយ ដើម្បីដោះដៃអោយផុតពីការទទួលខុសត្រូវចំពោះមនុស្សជំនាន់ក្រោយៗ ។ គេមានអារម្មណ៍ថា ព្រះអរហន្ត គឺជាអ្នកខ្វះមេត្តាធម៌ ។

តាមមហាយាន ការត្រាស់ដឹងមិនមានន័យយ៉ាងសាមញ្ញថា ការយល់ដឹងនូវអរិយសច្ចៈទាំងបួននោះទេ ។ ព្រះពុទ្ធមិនមែនបានត្រាស់ដឹងក្នុងន័យដ៏សាមញ្ញនេះទេ, ប៉ុន្តែព្រះអង្គគឺជា សព្វញ្ញុពុទ្ធ ។ ការត្រាស់ដឹងរបស់សាវ័កទាំងឡាយ មិនមានអ្វីលើសពីការត្រាស់ដឹងដោយឡែក ដែលគ្រប់គ្រាន់សម្រាប់រំដោះខ្លួនឯងដោយផ្ទាល់នោះឡើយ ។ គំនិតនៃការត្រាស់ដឹង ( ពោធិចិត្ត ) នៅក្នុងព្រះសូត្រមហាយាន ត្រូវបានកំណត់ត្រឹមគំនិតចង់ក្លាយខ្លួនជាព្រះពុទ្ធ ។ ដោយហេតុនេះ, គំនិតនេះ គឺជាគំនិតពិសេសផ្ទាល់របស់ពោធិសត្វ ។ គំនិតនេះកើតមានឡើង ដើម្បីធ្វើអោយព្រះពោធិសត្វមានគុណសម្បត្តិលើសសាវ័ក និងបច្ចេកពុទ្ធទាំងអស់ ។ គឺនៅក្នុងស្មារតីនេះហើយ ទើបនៅក្នុងរត្នកូដសូត្រ ( ឬ កស្សបបរិវត៌ះ បោះពុម្ពដោយ Von Stael Holstein, Shanghai, 1926 p. 116 ) គេបាននិយាយថា ស្រាវ័ក ( សាវ័ក ) ទាំងឡាយ មិនមែនជាបុត្រដ៏ពិតរបស់ព្រះពុទ្ធទេ ។ ជាទូទៅ ព្រះសូត្រមហាយានទាំងអស់ តែងលើកឡើងនូវពាក្យរិះគន់ដល់មាគ៌ាអន់ថយ ( ហីន ) នេះ របស់សាវ័កទាំងឡាយតាមពាក្យសំដីធ្ងន់ៗ និងមានប្រវែងអត្ថបទប្រែប្រួលតាមការប្រៀប

ធៀបមិនពិរោះពិសា ផ្ទុយគ្នាទៅនឹងការអត់ឱន និងការយោគយល់ ដែលមាននៅក្នុងគម្ពីរពុទ្ធសាសនាដ៏ចាស់ទុំបំផុត ។

ទស្សនៈទាំងឡាយរបស់ព្រះសូត្រមហាយាន ចំពោះហីនយាន បានកើតជារូបរាងច្បាស់លាស់ នៅក្នុងកណ្ដាប់ដៃសាស្ត្រាចារ្យមហាយាន ដែលបានបង្កើតអោយមានភាពផ្សេងគ្នារវាង*យាន*ទាំងពីរ រួមទាំងការអនុវត្តន៍ជាទ្រឹស្ដី និងការជាក់ស្តែងផង ។ យោងតាមលោកសាស្ត្រាចារ្យទាំងនោះ, មានទិដ្ឋភាពប្រាំមួយយ៉ាងដែលនៅក្នុងនេះ ហីនយាន ត្រូវបានអន់ថយជាងមហាយាន ៖

១ . ភាពផ្សេងពីគ្នាជាមូលគ្រឹះមួយ ពាក់ព័ន្ធជាមួយធម្មជាតិនៃសត្វ ( the nature of beings ) ។ សត្វទាំងអស់ទាំងមានបញ្ញា ទាំងល្ងង់ខ្លៅ យោងតាមគម្ពីរ *វសុពន្ធុ,* គឺមានតាំងតែពីកំណើតនូវអ្វីដែលគេហៅថា *ពុទ្ធសូភាវៈ* ឬ *ពុទ្ធធម្មជាតិ,* ដ៏ជាពន្លក ឬសក្ដានុភាព ( potentiality ) ដែលអាចអភិវឌ្ឍទៅជា ពុទ្ធសូភាវៈ ឬជាពុទ្ធភូមិបាន ។ ពុទ្ធសូភាវៈនេះ គឺដូចគ្នានឹង *សូន្យតា* ហើយមនុស្សគ្រប់វណ្ណៈទាំងអស់កកើតបានជាជីវិត រូបកាយ ចេញមកពីសូន្យតាដដែលនេះ ។ គម្ពីរ *វសុពន្ធុ* បន្ថែមថា ពួកសរិវាស្ដិវាទៈ ( ពោលគឺពួកហីនយាន ) មានយោបល់ថា មនុស្សទាំងអស់មិនមានពុទ្ធសូភាវៈពីកំណើតមកទេ, ប៉ុន្តែ បានពុទ្ធសូភាវៈនេះ ដោយការប្រតិបត្តិសាសនា ។ ( Buddhasvabhāva Sāstra, Sha Bundle, Vol -2- p. 466 of Chinese Tripitaka; Kimura, p. 151 ) ។

២ . ចំណុចផ្សេងគ្នាទីពីរពាក់ព័ន្ធនឹងឧត្តមគតិ ។ ដោយហេតុថា មនុស្សទាំងអស់ជាអ្នកមានពុទ្ធសូភាវៈនេះ, ឧត្តមគតិ គឺត្រូវសំរេចអោយបាននូវពុទ្ធសូភាវៈ ។ មនុស្សទាំងអស់ត្រូវបំផុសគំនិត ដើម្បីបានការត្រាស់ដឹង ( ពុទ្ធចិត្ត ) តាមរយៈនេះ មនុស្សទាំងអស់ក្លាយទៅជាពោធិសត្វ ហើយប្រកាន់យកភារកិច្ចនៃពោធិសត្វ ( ពោធិសត្វចរិយា ) ដែលរួមមានបារមីតា យានដល់ប្រជ្ញាបារមីតា

ដែលជាពុទ្ធស្វភាវៈ ។ មហាយានសូត្រមានសេចក្តីបោងដ៏សម្បូរណាស់ត្រង់ចំណុច នេះ ។ ភាពផ្សេងគ្នា គឺថា, ហីនយាន មិនចាត់ទុកនេះជាកាតព្វកិច្ចទេ, ពួកហីនយាន តាមការចោទប្រកាន់នោះ . គឺពេញចិត្តតែត្រឹមការបានសំរេចអរហត្ត ដែលតាម ទស្សនៈមហាយានថា គឺជាឧត្តមគតិដែលប្រកាន់យកដោយពួកអ្នកមានប្រាថ្នាទាប ( ហីនាធិមុត្តិកៈ ) ដែលគោលដៅរបស់គេ គឺការសំរេចបាននិព្វានតែប៉ុណ្ណោះ ។

ព្រះនាគាជុន ( Nāgarjuna ) ចង្អុលប្រាប់ថា ពុទ្ធយាន ដែលជាយាន ថ្នាក់ខ្ពស់ គឺសម្រាប់អត្ថប្រយោជន៍សាកល ចំណែកស្រាវកយាន ដែលជាយានថ្នាក់ ទាប គឺសម្រាប់អត្ថប្រយោជន៍បុគ្គល ។ ពុទ្ធយាន ត្រូវបានទេសនាផ្សព្វផ្សាយសម្រាប់ ទាំងពោធិសត្វ ទាំងស្រាវក, ចំណែកស្រាវកយាន គឺសំដៅផ្សព្វផ្សាយសម្រាប់ ស្រាវកតែប៉ុណ្ណោះ, ហើយមិនសម្រាប់ពោធិសត្វទេ ( Prājñapāramita Sastra, commentary to Prājñapāramitā - sūtra, Wan Bundle, Vol I, p. 29a of Chinese Tripitaka ) ។

គឺភាពប្លែកគ្នានេះហើយ ដែលបង្ហាញអោយឃើញទិដ្ឋភាពអនុវត្ត និង ចរិយានៃ*យាន*ទាំងពីរ ដូចដែលពួកមហាយានប្រកាសថា « អត្តទត្ថភាពរបស់ព្រះ អរហត្ត និងបរទត្ថភាពរបស់ព្រះពោធិសត្វ » ហើយដោយហេតុនេះ ពួកមហាយាន ខិតខំរៀបចំបង្ហាញអោយឃើញហីនភាព ( inferiority ) នៃនិកាយហីន យាន ។

៣ - ចំណុចផ្សេងគ្នាទីបី ហូរចេញមកពីចំណុចផ្សេងគ្នាទាំងពីរ ដែល បាននិយាយខាងលើ ពាក់ព័ន្ធនឹងការរំដោះ ( freedom ) ដែលសំរេចបាននៅ ក្នុងយានទាំងពីរ ។ នៅក្នុងហីនយាន ការរំដោះត្រូវសំរេចបានតាមការកំចាត់បង់នូវ កិលេស នីវរណធម៌ ( ក្លេសាវរណវិមុត្តិ ) ដែល នៅក្នុងមហាយានត្រូវបានសំរេច ដោយការបន្សាត់បង់ទាំងកិលេស - នីវរណធម៌ ទាំងញាណនីវរណធម៌ (ជ្ញេយាវរណ

វិមុត្តិ ) ។ ការបន្សាត់បង់កិលេស . នីវរណធម៌ត្រូវសំរេចបានដោយស្រាវក ចំណែក ព្រះពោធិសត្វសំរេចបានទាំងពីរ ( Yogäcārabhumi Sāstra Lai Bundle, Vol. 2, p. 67 of Chinese Tripitaka; Kimura, p. 170 ) ។

នៅទីបំផុត យើងបានឈានមកដល់ភាពផ្សេងគ្នាខាងទ្រឹស្តី ដែលឃើញមាននៅក្នុងប្រព័ន្ធទាំងពីរ ។ ព្រះនាគាជុននិយាយថា ទ្រឹស្តីផ្សព្វផ្សាយនៅក្នុង*ស្រាវកយាន* គឺសុញ្ញតា, ជាអតថភាពនៃបុគ្គល ( pudgala nairatmya ), ចំណែកនៅក្នុងពុទ្ធយាន វិញ, សុញ្ញតារបស់បុគ្គលក៏ដូចជារបស់ធម៌ះ (dharmanairatmya-tā) ត្រូវបានគេផ្សព្វផ្សាយ ។ ( Prājñapāramita sastra, Wang Bundle, Vol. I p. 29 of Chinese Tripitaka ) ។ នេះចង់សំដៅន័យថា ការយល់អំពីអតថភាពរបស់បុគ្គល ដែលពុំមែនជាសច្ចៈទាំងស្រុង គឺវាគ្រប់គ្រាន់សម្រាប់សំរេចបានអរហត្តភាព ចំណែកឯការយល់អំពីអតថភាពនៃបុគ្គល និងធម៌ះទាំងពីរ ដែលជាសច្ចៈទាំងស្រុង គឺមានសារសំខាន់ណាស់សម្រាប់ការសំរេចបានពុទ្ធសភាវៈ ។

ជាគោលការណ៍, ទ្រឹស្តីនៃពោធិសត្វ ស្តីពីមាគ៌ាទៅកាន់ពុទ្ធសភាវៈ មិនមែនជាទ្រឹស្តីថ្មីទេ ។ ទស្សនាទាន ( the conception ) នេះ ឃើញមាននៅក្នុងអត្ថបទបាលីជំនាន់ដើម ដោយនិយាយយោងដល់ព្រះពុទ្ធមុនពេលបានត្រាស់ដឹង ( មហាបទានសុត្ត ) ។ បន្ថែមលើនេះ ជាតកទាំងឡាយទាក់ទងដល់ជីវិតពីជាតិមុនរបស់ពោធិសត្វ ក៏ត្រូវបានព្រះពុទ្ធលើកយកមកនិទានដោយព្រះអង្គឯង ។ អ្វីដែលផ្សេងគ្នានោះគឺ, សម្រាប់និកាយពីដំបូង១, រឿងជាតក ត្រូវបានគេនិយាយថាជារឿងពិពណ៌នាសុទ្ធសាធ សម្រាប់បង្កើតជំនឿទុកចិត្តក្នុងព្រះពុទ្ធ, សម្រាប់មហាយានវិញ ការហ្វឹកហ្វឺនរបស់ពោធិសត្វ គឺជាបញ្ញត្តិ ឬបញ្ញា, មាគ៌ារបស់ពោធិសត្វ គឺអាចត្រូវបានជំនួស ឬយ៉ាងហោចណាស់ត្រូវបានចាត់ទុកថា ប្រសើរជាងអរិយៈអដ្ឋង្គិកមគ្គ ។ បព្វជិតមិនគប្បីតម្រង់ទៅរកនិព្វានដោយត្រង់ទេ, ប៉ុន្តែ ជាបឋម ត្រូវក្លាយទៅជា

ព្រះពុទ្ធមួយអង្គសិន, ដ៏ជាការសម្រេចបានយ៉ាងខ្ពស់បំផុត, លោកត្រូវជួយសង្គ្រោះមនុស្សជាតិ ។

គ្រប់និកាយនៃពុទ្ធសាសនា យល់ស្របគ្នាថា ព្រះអរហន្តទាបជាងព្រះពុទ្ធ ។ ដោយហេតុនេះ, ជីវភាពរបស់ព្រះពោធិសត្វខ្ពស់ជាងជីវភាពរបស់ព្រះអរហន្ត, ប៉ុន្តែ ក្នុងទីនោះ ការរីកចំរើនក្នុងមាគ៌ាត្រូវបានគេមើលរំលង ។ ភាពផ្សេងគ្នាជាមូលដ្ឋាន រវាងយានៈទាំងពីរ ឋិតក្នុងការប្រកាសរបស់មហាយាន អំពីជីវភាពរបស់ពោធិសត្វ ទុកដូចជាឧត្តមគតិតែមួយគត់ដែលត្រូវប្រកាន់យកដោយពុទ្ធសាសនិកដ៏ពិតប្រាកដ ហើយការមើលស្រាលរបស់គេចំពោះការបានសំរេចនិព្វាន ដោយព្រះអរហន្ត ទុកដូចជាការខ្វះបរទត្ថភាពដែលគេសង្ឃឹមដើម្បីបានទទួលពីពោធិសត្វ ។

យោងតាមព្រះសូត្រជំនាន់ដើមសរសេរជាភាសាបាលី ហើយនិង អាគមៈរបស់ចិន, គោលបំណងរបស់សាវ័កព្រះពុទ្ធ គឺការជំនះបានលើ ទុក្ខៈ ដែលត្រូវបានវាប់រងតាមការសំរេចបានជាព្រះអរហន្ត ដែលអាចបំរើគោលបំណងនេះបានយ៉ាងត្រចះត្រចង់ ។ វាពុំមានចំណោទអ្វីអំពីហីនភាព ( inferiority ) ឬឧត្តមភាព ( superiority ) នៃផ្លូវត្រូវដើរ ឬនៃគុណភាពត្រូវសំរេចបាននោះទេ ។ គោលដៅដែលទៅដល់តាមការសំរេចបានអរហត្តភាព ក៏ពុំអន់ជាងតាមការសំរេចបានពុទ្ធភាពដែរ ។ ឧត្តមគតិ គឺនៅត្រង់ការធ្វើអោយសំរេចបានដោយខ្លួនឯង នៅក្នុងជាតិនេះតែម្តងនូវការរំដោះផុតនៃចិត្ត និងបាប្ញទ័យ *( ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា )*។

នេះគឺជាខ្លឹមសារដែលយើងប្រមូលបានពីព្រះសូត្រជំនាន់ដើម ។ ព្រះសូត្រទាំងនោះពុំបាននិយាយពីឧត្តមគតិពោធិសត្វដែលថា មនុស្សទាំងអស់គប្បីខិតខំអោយបានក្លាយខ្លួនជាពោធិសត្វទេ ។ អ្វីដែលបានចែងនៅក្នុងព្រះសូត្រទាំងនោះអាចស្រង់ចេញបានពីវគ្គទាំងឡាយរបស់ព្រះសូត្រ ដែលបានកំណត់នីតិវិធី ហើយ

នៅក្នុងរង្វង់នីតិវិធីនេះ មនុស្សសំរេចបាននិព្វាន ឬសំរេចបានអរហត្តភាព ។ នីតិវិធី ចាប់ផ្ដើមពីការបង្កើតសទ្ធាក្នុងព្រះបរមសាស្ត្រាចារ្យ ( ព្រះពុទ្ធ ) តាមរយៈការស្ដាប់ ព្រះធម៌របស់ព្រះអង្គ រួចហើយត្រូវអនុវត្តតាមដំណាក់កាលសំខាន់ដូចតទៅនេះគឺ ទទួលបព្វជ្ជាដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌, សីល, សមាធិ, បញ្ញា, វិមុត្តិ និងវិមុត្តិញាណទស្សនៈ ។ អ្នកដែលបានបំពេញអភិក្រមនេះ ត្រូវបានគេពោលថា ជាអ្នកបានយល់ថា ការកើតទៀត ត្រូវបានបញ្ចប់ហើយ, ជីវិតជាន់ខ្ពស់ត្រូវបានដឹកនាំ, អ្វីដែលត្រូវធ្វើត្រូវបានបំពេញរួចហើយ, ហើយក៏គ្មានទំនោរវែងឆ្ងាយណាមួយ ដើម្បីឱ្យត្រឡប់មករកជីវិតក្នុងសង្សារវដ្តនេះទៀតឡើយ ។ អភិក្រមនេះ ត្រូវបានអធិប្បាយយ៉ាងទូលំទូលាយនៅក្នុងព្រះសូត្រពីដំបូងៗ ដូចជា សាមញ្ញផលសូត្រ ជាដើម ( សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ បាលី )។

ឧត្តមគតិ ដែលមានចែងនៅក្នុងព្រះសូត្រពីដំបូងៗ នោះគឺការបញ្ចប់ទុក្ខ ដោយការបានសំរេចអរហត្តភាព ។ កត្តាកំណត់នៅក្នុងចរិតលក្ខណៈ នៃនិកាយពុទ្ធ-សាសនាផ្សេងៗគ្នា ដូចជាហីនយាន ឬមហាយាន ចំពោះបញ្ហានោះ គឺការទទួលយកសភាវៈនៃការពិតរបស់មហាយានសូត្រ ។ អ្នកទាំងឡាយណា ផាត់ចោលសភាវៈនៃការពិតរបស់ព្រះសូត្រទាំងនោះ រួមទាំងការប្រៀនប្រដៅរបស់ព្រះសូត្រនោះផង ដែលថា ម្នាក់ៗគប្បីក្លាយទៅជាពោធិសត្វ, អ្នកទាំងឡាយនោះត្រូវបានគេចាត់ចូលក្នុងប្រភេទដ៏ធំទូលាយនៃហីនយាន រួមទាំងថេរវាទ ឬស្ថាវិរវាទផង ។ និកាយធំៗបី រួមទាំងក្រុមសម្ពន្ធភាពរបស់និកាយធំៗបីនេះផង, ក៏ត្រូវរួមបញ្ចូលក្នុងប្រភេទនេះដែរ : និកាយថេរវាទមាននៅក្នុងប្រទេសស៊ីរីលង្កា និងនិកាយរលត់រលាយទៅហើយ នៅប្រទេសឥណ្ឌា, ជាអាទិ៍ សព្វាស្តិវាទ និងសៅត្រាន្តិកៈ ។ ដូចលោក អ៊ីត្សុីង ( I Tsing ) បានពោលថា អ្នកទាំងឡាយដែលគោរពបូជាពោធិសត្វ ហើយអានមហាយានសូត្រ មានឈ្មោះថា អ្នកកាន់តាមមហាយាន, ចំណែកអ្នក

ទាំងឡាយណាដែលមិនធ្វើតាមការប្រតិបត្តិនោះទេ អ្នកទាំងឡាយនោះមាន ឈ្មោះថា អ្នកកាន់តាមហីនយាន ។

ប្រែសម្រួល : **ឈន អៀម**
ចាកអត្ថបទរបស់ ឧបាលិ ករុណារត្នេ
Encyclopaedia of Buddhism
Vol. V. p. 453 - 455 - 1990

-----------

*មនុស្សណាបានធ្វើអំពើអាក្រក់ ( បាប ) ហើយ ទោះជាខំលាក់ខ្លួនក្នុងអាកាសក្តី, ក្នុងកណ្តាលសមុទ្ទក្តី, ចូលទៅពួនក្នុងជ្រលងភ្នំក្តី ឬនៅក្នុងទីណាមួយ លើផែនដីនេះ, មនុស្សនោះ មិនអាចគេចផុតអំពី ( ផល ) នៃអំពើអាក្រក់បានឡើយ ។*

ធម្មបទ - បាបវគ្គ
គាថាទី ១២៧ - ឈ.អ

# ឱវាទចុងក្រោយរបស់ព្រះពុទ្ធ
## ( THE LAST TEACHING OF THE BUDDHA )

សិទ្ធត្ថៈ ជានាមរបស់ព្រះពុទ្ធ កាលនៅជាគ្រហស្ថ ។ ក្នុងព្រះជន្ម ២៩ វស្សា គឺនៅក្រោយពេលរាហុលកុមារ ដែលជាព្រះរាជបុត្រតែមួយរបស់ព្រះអង្គ ទ្រង់បានប្រសូតឡើង ព្រះសិទ្ធត្ថបានលះបង់រាជសម្បត្តិ ដើម្បីប្រកាន់យកជីវភាពជាសមណៈ ដែលជាអ្នកឥតមានទីលំនៅ ។ ព្រះសិទ្ធត្ថបានសំរេចពោធិញ្ញាណ នៅក្នុងព្រះជន្មាយុ ៣៥ ព្រះវស្សា បន្ទាប់ពីព្រះអង្គបានបំពេញទុក្ករកម្មអស់ពេល ៦ ឆ្នាំរួចមក ។ ចាប់ពីពេលនោះមក ព្រះសិទ្ធត្ថ ត្រូវបានគេស្គាល់ព្រះអង្គក្នុងនាមផ្សេងៗជាច្រើន ។ អ្នកខ្លះហៅព្រះអង្គថា ព្រះពុទ្ធ, អ្នកខ្លះដាក់ព្រះនាមព្រះអង្គថា ព្រះសក្យមុនី, អ្នកខ្លះទៀតហៅព្រះអង្គថា លោកវិទូ, អ្នកខ្លះផ្សេងទៀត ថ្វាយព្រះនាមព្រះអង្គថា បុគ្គលជាទីគោរពក្នុងលោក[(១)] ។

ក្នុងរយៈពេល ៤៥ ឆ្នាំ នៃព្រះពុទ្ធកិច្ច, ព្រះសមណគោតមទ្រង់និមន្តទៅគ្រប់ទិសទីក្នុងភូមិប្បទេសនានា ដោយមានអានន្ទជាឧបដ្ឋាកអមព្រះដំណើរ ដើម្បីសំដែងធម្មទេសនាពន្យល់ប្រជាជនអោយយល់ ហើយប្រតិបត្តិតាមរបៀបរស់នៅរបស់ព្រះអង្គ ។ ក្នុងព្រះជន្មបាន ៨០ ព្រះវស្សា នៅពេលដែលព្រះអង្គស្តេចយាងទៅដល់វេសាលី ក្នុងលំដាប់ផ្លូវដែលព្រះអង្គនិមន្តពីរាជគ្រឹះទៅសាវត្ថី ព្រះអង្គទ្រង់ប្រឈួន ហើយព្រះអង្គទ្រង់ទស្សទាយទុកមុនថា ក្នុងបីខែទៅមុខទៀត ព្រះអង្គនឹងចូលព្រះនិព្វាន ។ ព្រះអង្គទ្រង់បន្តដំណើរទៅទៀត ទៅដល់នគរបាវា ។ នៅទីនោះ

(១) សូមមើលពុទ្ធគុណទាំង ១០ ព្រះនាម ក្នុងគិហិបដិបត្តិ ត្រង់ **ឥតិបិ សោ ភគវា** ..

ព្រះអង្គទ្រង់អាពាធរឹតតែខ្លាំងឡើង។ នៅក្រោយពេលដែលព្រះអង្គបានឆាន់ចង្ហាន់ ដែលជាងមាសម្នាក់ឈ្មោះ ចុន្ទ បានប្រគេន ។ ទោះបីជាមានការឈឺចាប់ និង ការខ្សោយព្រះកាយពលជាខ្លាំងដោយអាពាធនោះក៏ដោយ ក៏ព្រះអង្គបានខិតខំបន្ត ដំណើរនិមន្តទៅដល់ព្រៃ ដែលឋិតនៅជាយក្រុងនគរកុសិនារា ។

នៅទីនោះ ព្រះអង្គទ្រង់ទម្រេតព្រះកាយ ត្រង់ចន្លោះសាលព្រឹក្សទាំងគូ ហើយទ្រង់មានព្រះពុទ្ធដីកាទូន្មានដាស់តឿនរំលឹកចុងក្រោយទៅកាន់អានន្ទ និង សាវ័ក ថា ៖

- « អានន្ទ ! ធម៌និងវិន័យណា ដែលតថាគតបានសំដែងហើយ បានបញ្ញត្ត ហើយ សំរាប់អ្នកទាំងឡាយ លុះអំណើះតពីតថាគតទៅ ធម៌និងវិន័យនោះឯង ជា គ្រូរបស់អ្នកទាំងឡាយ !

- « ចូរអ្នកជាប្រទីបបំភ្លឺខ្លួនឯង ចូរអ្នកជួយខ្លួនឯង ចូរយកការប្រៀន ប្រដៅរបស់តថាគតជាប្រទីបបំភ្លឺផ្លូវដើរ និងជាទីពឹងរបស់អ្នក ។ ចូរកុំយោលទៅ តាមការប្រៀនប្រដៅរបស់អ្នកផ្សេងទៀត ។

- « ដោយអនុលោមទៅតាមការប្រៀនប្រដៅរបស់តថាគត ចូរអ្នក ចេះគោរពគ្នាទៅវិញទៅមក ចូរអ្នកចៀសវាងការឈ្លោះប្រកែកគ្នា ។ ចូរកអ្នកកុំធ្វើ ត្រាប់ទឹកនិងប្រេង ដែលរុញច្រានគ្នាទៅវិញទៅមកជានិច្ចនោះ តែចូរអ្នកធ្វើត្រាប់ ទឹកនិងទឹកដោះ ដែលអាចរលាយចូលគ្នាបាន ។

- « ចូរក្រឡេកមើលទៅរូបរបស់អ្នក តើវាមានសភាពមិនបរិសុទ្ធយ៉ាង ណា ! ដឹងច្បាស់ហើយថា សេចក្តីសប្បាយរីករាយ និងសេចក្តីទុក្ខគ្រាំគ្រានៃរូប កាយ ជាមូលហេតុនៃការឈឺចាប់នោះ តើអ្នកបណ្តោយអោយរូបកាយនេះ វា បំពេញបំណងវា ដោយសេរីឬ ? ចូរក្រឡេកមើលទៅវិញ្ញាណរបស់អ្នក តើវាផ្លាស់ ប្តូរប៉ុន្មានដង ? ក្នុងពេលដែលដឹងថា មនោសញ្ចេតនាទាំងនោះ វានឹងនាំអ្នកទៅកាន់

សេចក្ដីវេទនា តើអ្នកអាចបណ្ដោយខ្លួនអោយធ្លាក់ទៅក្នុងសេចក្ដីភ័ន្តច្រឡំគំនិត ហើយប្រកាន់យកអស្មិមានះ និងអត្តទត្ថភាពបានឬទេ ? ចូរក្រឡេកមើលទៅវត្ថុធាតុទាំងអស់នៅលើលោកនេះចុះ តើអ្នកអាចសំគាល់ឃើញមានវត្ថុណាដែលឋិតថេរដែរឬទេ ? តើអ្នកសំគាល់ឃើញវត្ថុទាំងនោះ វាគ្រាន់តែប្រមូលផ្ដុំភ្ជាប់គ្នានៃវត្ថុឯទៀតៗ ដែលយូរឬឆាប់ វានឹងត្រូវបែកបាក់ ហើយបែកខ្ញែកគ្នាជាពុំខាននោះដែរឬទេ ? ប៉ុន្តែ ចូរកុំមានការភិតភ័យ ដោយសារតែសំគាល់ឃើញថាវត្ថុអ្វីៗ ក៏ជាទុក្ខវេទនានោះ, ចូរធ្វើតាមការប្រៀនប្រដៅរបស់តថាគតជានិច្ច ទោះបីក្រោយពេលតថាគតអស់សង្ខារទៅហើយក្ដី ។ បើអ្នកប្រតិបត្តិតាមឱវាទតថាគត អ្នកមុខជាបានចាកផុតអំពីទុក្ខ ហើយអ្នកនឹងពិតជាសាវ័ករបស់តថាគត ជាពុំខាន ។

នែ សាវ័ករបស់តថាគតទាំងឡាយ ! សេចក្ដីប្រៀនប្រដៅរបស់តថាគតដែលបានផ្ដល់អោយអ្នកទាំងប៉ុន្មាន ចូរអ្នកកុំភ្លេចអោយសោះ ហើយនិងកុំអោយបាត់បង់អោយសោះ ។ អ្នកត្រូវតែសញ្ជឹងគិតចំពោះការប្រៀនប្រដៅទាំងនោះជានិច្ច ហើយត្រូវតែប្រតិបត្តិតាមជានិច្ចនិរន្តរ៍ ។ បើអ្នកធ្វើតាមការប្រៀនប្រដៅរបស់តថាគត អ្នកនឹងបានប្រកបដោយសុភមង្គល ជានិច្ចកាល ។

- « សារសំខាន់ក្នុងការប្រៀនប្រដៅរបស់តថាគត គឺអ្នកត្រូវតែត្រួតត្រាពត់ចិត្តរបស់អ្នកអោយនៅក្នុងគន្លងល្អ ។ អ្នកត្រូវតែលះបង់ការលោភលន់ ហើយធ្វើខ្លួនអ្នកអោយលុះក្នុងធម្មវិន័យ ជាទីជ្រះថ្លា ពេញចិត្តនៃជនទាំងពួង ធ្វើចិត្តអ្នកអោយបរិសុទ្ធ និងប្រកាន់ពាក្យសំដីអ្នកអោយស្មោះត្រង់ ។ បើអ្នកសញ្ជឹងគិតជានិច្ចថា ជីវិតរបស់អ្នកវាមានសភាពមិនឋិតថេរ នោះអ្នកនឹងអាចចៀសផុតពីការលោភលន់ និងការមានកំហឹង ហើយអ្នកនឹងអាចចៀសផុតពីទុក្ខគ្រប់យ៉ាងបាន ។

- « បើអ្នកសង្កេតឃើញថា ចិត្តរបស់អ្នកវាមានចំណង់ ហើយធ្លាក់ទៅក្នុងសភាពលោភលន់ អ្នកត្រូវតែបំបាត់ចោលសេចក្ដីលោភលន់នោះ ហើយត្រួត

គ្រោទប់ចំណង់នោះ, ចូរអ្នកតាំងខ្លួនអ្នកជាគ្រូនៃចិត្តរបស់អ្នក ។

- « គឺចិត្តរបស់យើងផ្ទាល់នេះហើយ ដែលធ្វើអោយយើងបានជាព្រះពុទ្ធមួយអង្គ ឬក៏ធ្វើអោយយើងទៅជាសត្វធាតុមួយ ។ បើយើងយល់ច្រឡំក្នុងការខុស យើងនឹងទៅជាបិសាច តែបើយើងភ្លឺស្វាង យើងនឹងបានជាព្រះពុទ្ធ ។ ហេតុនេះ ចូរអ្នកត្រូតត្រាទប់ចិត្តរបស់អ្នក កុំអោយវាឃ្លាតចាកពីមាគ៌ាថ្លៃថ្នូរ ។

- « ចូរអ្នកសិក្សារៀនទាំងអស់គ្នា ជួយដាស់តឿនគ្នាទៅវិញទៅមក ចូរអ្នកធ្វើវត្តប្រតិបត្តិទាំងអស់គ្នា ។ ចូរអ្នកកុំបំផ្លាញសតិរបស់អ្នក ហើយធ្វើអោយខាតពេលវេលារបស់អ្នកក្នុងភាពទំនេរ និងការឈ្លោះទាស់ទែងគ្នា ។

- « សេចក្តីប្រៀនប្រដៅទាំងប៉ុន្មាន ដែលតថាគតបានផ្តល់ដល់អ្នក គឺជាសតិអារម្មណ៍ដែលតថាគតបានមក ដោយតថាគតបានដើរតាមផ្លូវនោះឯង ។ ចូរអ្នកធ្វើតាមការប្រៀនប្រដៅទាំងនោះ ហើយចូរអ្នកអនុវត្តតាមអោយបានល្អ គ្រប់កាលៈទេសៈទាំងអស់ ។

- « បើអ្នកមិរវល់យកចិត្តទុកដាក់នឹងការប្រៀនប្រដៅទាំងនេះ បានន័យថា អ្នកមិនដែលបានជួបនឹងតថាគត ដោយពិត គឺអ្នកនៅឆ្ងាយពីតថាគត ទោះបីនៅពេលនេះ អ្នកកំពុងអង្គុយជិតបង្កើយនឹងតថាគតក៏ដោយ ។ តែផ្ទុយទៅវិញ បើអ្នកទទួល និងប្រតិបត្តិតាមការប្រៀនប្រដៅរបស់តថាគត ទោះបីអ្នកនៅដល់ចុងម្ខាងទៀតនៃពិភពលោកក៏ដោយ ក៏អ្នកហាក់ដូចជានៅជិតបង្កើយនឹងតថាគតដែរ ។

- « សាវ័កទាំងឡាយ ! អវសានជីវិតរបស់តថាគត ជិតមកដល់ហើយ ការបែកគ្នារវាងយើង និងយើង ក៏កាន់តែជិតមកដល់ដែរ ។ តែចូរអ្នកកុំមានទុក្ខសោកឡើយ ។ ជីវិត គឺជាការផ្លាស់ប្តូរជានិច្ចនិរន្តរ៍ ហើយគ្មានអ្វីដែលចៀសផុតអំពីការរលាយទៅវិញនៃរូបកាយទេ ។ តថាគតនឹងបង្ហាញអ្នកទាំងឡាយអោយឃើញក្នុងរឿងនេះ នៅពេលបន្តិចទៀតនេះ ដោយមរណៈផ្ទាល់របស់តថាគតនេះឯង រូប

កាយរបស់តថាគតនឹងរលាយទៅ ដូចជារទេះដែលទ្រុឌទ្រោម ដូច្នេះឯង ។

- « ចូរកុំសោយសោកដោយឥតប្រយោជន៍នោះ ចូរអ្នកយល់អោយច្បាស់ថា គ្មានអ្វីដែលឋិតថេរទេ ដូច្នេះហើយ ជីវិតមនុស្សក៏វាជាសភាពទទេ គ្មានអ្វីសោះ យ៉ាងនោះដែរ ។ ចូរកុំរក្សាចំណង់ដែលគ្មានទំនង ដោយសារតែយល់ឃើញថា អ្វីៗដែលមិនឋិតថេរ វាអាចទៅជាឋិតថេរនោះ ។

- « បិសាចនៃចំណង់ទាំងឡាយក្នុងលោកនេះ រកគ្រប់មធ្យោបាយដើម្បីនឹងបំភាន់សតិអ្នក ។ បើសិនជាមានពស់វែករស់នៅក្នុងបន្ទប់របស់អ្នក អ្នកអាចដេកលក់ដោយសុខសាន្តបាន លុះត្រាតែអ្នកបានដេញពស់វែកនោះអោយចេញផុតពីបន្ទប់អ្នករួចហើយ ។

- « អ្នកត្រូវតែផ្ដាច់ចំណងនៃចំណង់លោកិយ ហើយបញ្ចេញវាចេញ ដូចជាអ្នកបានបណ្ដេញពស់វែកអោយចេញពីបន្ទប់យ៉ាងនោះដែរ ។ អ្នកត្រូវតែការពារសតិរបស់អ្នកអោយមធ្យ័ត ។

- « សាវ័កទាំងឡាយ ! ទីអវសានជីវិតរបស់តថាគតមកដល់ហើយ តែចូរកុំភ្លេចថា មរណភាព វាគ្រាន់តែជាការរលាយនៃរូបកាយប៉ុណ្ណោះទេ ។ រូបកាយកើតឡើងពីមាតាបិតា ធំធាត់ឡើងដោយសារចំណីអាហារ តែដែលចៀសមិនផុតសំរាប់រូបកាយនោះ គឺ ឈឺនិងស្លាប់ ។

- « ព្រះពុទ្ធពិតប្រាកដនោះ ពុំមែនជារូបកាយមនុស្សទេ ប៉ុន្តែ គឺជាការបានត្រាស់ដឹងនោះឯង ។ រូបកាយមនុស្ស ត្រូវតែរលាយបាត់បង់ជាធម្មតា តែព្រហ្ម-ចរិយធម៌នៃការត្រាស់ដឹង ឋិតថេរជានិច្ចនិរន្តរ៍នៅក្នុងការពិតនៃព្រះធម៌ និងការប្រតិបត្តិព្រះធម៌ ។ អ្នកដែលឃើញតែរូបកាយរបស់តថាគត មិនបានឃើញតថាគតដោយពិតទេ ។ មានតែអ្នកទទួលយកការប្រៀនប្រដៅរបស់តថាគតទេ ដែលបានឃើញតថាគត ដោយពិតៗ ។

- « ក្រោយពេលដែលតថាគតអស់សង្ខារទៅ ព្រះធម៌និងវិន័យ នឹងទៅជាគ្រូរបស់អ្នក ។ ចូរប្រតិបត្តិតាមព្រះធម៌វិន័យ លុះតែធ្វើយ៉ាងនេះ ទើបអ្នកនឹងបានទៅជាសាសនិកម្នាក់ដែលជឿតាមតថាគត ។

- « ក្នុងជីវិតតថាគតជាង ៤៥ ឆ្នាំនេះ តថាគតគ្មានបានលាក់ទុកអ្វីបន្តិចបន្តួចក្នុងការប្រៀនប្រដៅរបស់តថាគតទេ ។ គ្មានអ្វីដែលជាការប្រៀនប្រដៅជាសម្ងាត់ទេ ក្នុងន័យលាក់លៀម ក៏គ្មានដែរ ។ អ្វីៗទាំងអស់ ត្រូវបានប្រៀនប្រដៅទៅដោយស្មោះត្រង់ និងច្បាស់លាស់ ។

- សាវ័កជាទីស្រឡាញ់របស់តថាគតទាំងឡាយ,

អ្នកទាំងឡាយ ចូរញាំងករណីយកិច្ចទាំងពួងអោយសំរេច ដោយមិនធ្វេសប្រហែសចុះ !

នេះជាវាចាចុងក្រោយបង្អស់ របស់តថាគត !

**ឱម ខែម**

ដកស្រង់រៀបរៀង

ប្រភពដកស្រង់ :

- ពុទ្ធប្បវត្តិកថា
- មហាបរិនិព្វានសូត្រ ទីឃនិកាយ
- សិក្ខាបទព្រះពុទ្ធ បោះពុម្ពផ្សាយដោយ Bukkyo Dendo Kyokai, ជប៉ុន

# ធំរង់ខាងវេយ្យាករណ៍ នៃ នរនាម

ដូចយើងបានឃើញរួចមកហើយ ឋានន្តរនាមនៅក្នុងក្រុមអភិជន CSS បានត្រូវចែកចេញជាបីផ្នែក ដោយយោងទៅតាមកិរិតឧត្តុង្គឧត្តមនៃឋានន្តរនាមនិមួយៗ បានត្រូវសំដែងឡើង ឬត្រូវបង្កើតឡើងដោយពាក្យដើម ឬពាក្យតែមួយព្យាង្គ ហើយពាក្យទាំងនេះ អាចចាត់ទុកបានថាជាពាក្យឫស ដែលត្រូវប្រើប្រាស់សំរាប់បង្កើតឋានន្តរនាមនៅក្នុងថ្នាក់ B និងក្នុងថ្នាក់ C ដោយអនុវត្តនូវបុព្វបទនីយកម្ម ។

បុព្វបទទាំងនោះ មានប្លែកៗពីគ្នា ក៏ប៉ុន្តែបុព្វបទសំខាន់ជាងគេគឺ ព្យញ្ជនៈគល់អណ្តាត k : ក ហើយនិង variantes ឬ រូបប្រភេទផ្សេងៗនៃបុព្វបទនេះ :

ឧទាហរណ៍ : កុ ku - កុរុង៑ kuruṅ

កំ kaṃ - កំម្រតាង៑ kaṃmratāṅ

ដូចយើងបានឃើញរួចមកហើយថា បុព្វបទអក្សរ " ក " និងរូបប្រភេទនៃបុព្វបទនេះ បានត្រូវប្រើប្រាស់នៅក្នុងភាសាខ្មែរ ។ មិនមែនគ្រាន់តែដើម្បីបង្កើតឋានន្តរនាមប៉ុណ្ណោះទេ ប៉ុន្តែ ដើម្បីបង្កើតនរនាម នៅក្នុងភាសាបុរាណ ក៏ដូចជាក្នុងភាសាសម័យទៀតផង ។

កលាប្រភេទ Variantes នៃបុព្វបទ " ក " គឺ :

k - ក, ka - ក, kaṅ - កង៑, kañ - កញ៑, kan - កន៑

kaṃ - កំ, kra - ក្រ

ក្នុងករណីភាគច្រើននៅក្នុងភាសាខ្មែរបុរាណ ក៏ដូចជាភាសាខ្មែរបច្ចុប្បន្នពាក្យនិមួយៗមិនអាចមានព្យាង្គលើសពី ២ ឡើយ ។ ហើយពាក្យទ្វេព្យាង្គទាំងនោះ

( ឬមួយព្យាង្គ ) គឺជាពាក្យសមាស ដែលមានរចនាសម្ព័ន្ធប្លែកៗគ្នា កើតឡើងដោយវិធីសមាស ឬមួយជាពាក្យកម្លាយ ដែលកើតឡើងដោយការប្រើវិធីផ្នត់និយកម្ម (affixation) ។ ការបង្កើតនរនាម ឬឋាននួរនាម ដែលជាពាក្យសមាស ឬពាក្យកម្លាយ ក៏ត្រូវបានធ្វើឡើងតាមបែបដូចគ្នានឹងការបង្កើតពាក្យធម្មតា នៅក្នុងភាសាដែរ ។ បានសេចក្តីថា ការបង្កើតនរនាម ឬ ឋាននួរនាម ត្រូវបានធ្វើឡើងស្របទៅតាមក្បួនវេយ្យាករណ៍ និងន័យសូរវិទ្យានៃភាសា ដោយឈរលើមូលដ្ឋាននៃការបែងចែកនិយមន័យទៅតាមដែនសេម៉ង់ទិកនីមួយៗ (Champ Sémantique) ។

នៅតាមសិលាចារឹកសម័យមុនអង្គរ និងអង្គរ គេប្រទះឃើញនរនាមដែលកកើតឡើងពីពាក្យទោលផង ពីពាក្យសមាសផង និងកន្សោមពាក្យផង ។ ដូចយើងបានឃើញមកហើយ នរនាម គឺជាឯកតានៃភាសា ដែលជួនកាលបំពេញមុខងារជាសព្វនាម ដូច្នេះ គឺជាពាក្យដែលចេញមកពីនាមនាម (Substantif) គុណនាម កិរិយាស័ព្ទ បកតិសំខ្យា (numiraux) ។

នរនាម តាមសិលាចារឹករាចបំបែកតាមបែបវេយ្យាករណ៍ ដូចតទៅ :

- *នរនាមកកើតដោយ នាម នាម :*

ឧទាហរណ៍ :



K 327 tai sumalla " ផ្កាល្អ "
K 138 vā cau " ចៅ "
K 22 ku kaṅval " កង្វល់ "
K 878 tai paṃnaṅ " បំណង "
K 352 si gandha " គន្ធា "
K 115 ku mālā " កំរងផ្កា "
K 995 tai phkā " ផ្កា "

| | | |
|---|---|---|
| ពា ស្នេហ | K 115 vā sneha | " ប្រេង, ស្នេហា " |
| ទៃ ប្រសាទ | K 809 tai prasād | " ប្រាសាទ " |
| ទៃ ឫទ្ធិ | K 254 tai ṛddhi | " ឫទ្ធិ " |
| កុ សុវណ៌្ណ | K 18 ku suvarṇṇa | " សុវណ្ណ " |
| វ វ្លេង | K 24 va vleṅ | " ភ្លើង " |
| សិ ស្វស្តិ | K 240 si svasti | " សួស្តី " |

- *នរនាមកកើតដោយគុណនាម :*

ឧទាហរណ៍ :

| | | |
|---|---|---|
| វ មេង | K 51 va meṅ | " ក្មេង " |
| វ ក្លាង | K 562 va klāṅ | " ខ្លាំង " |
| វ ច្ពោង | K 149 va cpoṅ | " ច្បង " |
| វ ក្ចិ | K 139 va kci | " ខ្ចី " |
| ឃោ ទុំ | K 143 gho duṃ | " ទុំ " |
| តេង សាន | K 348 teṅ sān | " សាន្ត " |
| សី ស្វន | K 366 sī svan | " សួន " |
| វ អម្ឫត | K 590 va amṛta | " អមត, មិនស្លាប់ " |
| សិ កំវ្រា | K 99 si kaṃvrā | " កំព្រា " |
| វាប វិមល | K 669 vāp vimala | " ល្អ, គ្មានសៅហ្មង " |
| លោញ ឯំ | K 72 loñ eṃ | " ផ្អែម, ស្រស់, ស្រទន់ " |
| វាប ធំ | K 207 vāp dhaṃ | " ធំ " |

- *នរនាមកកើតដោយកិរិយាស័ព្ទ :*

តាមសិលាចារិកសម័យមុនអង្គរ និងអង្គរ គេសង្កេតឃើញនូវនរនាម

ទាំងឡាយ ដែលតំណាងអោយភេទប្រុស និងស្រី ជាអ្នកធ្វើការនៅក្នុងព្រះវិហារ និងនៅក្នុងប្រាសាទនានា ។ នរនាមជាកិរិយាស័ព្ទទាំងនោះ ច្រើនមានប្រភពចេញមកពីពាក្យខ្មែរ ហើយមានទំរង់ជាពាក្យមួយព្យាង្គ ។ តាមទំរង់សេម៉ង់ទិច របស់ពាក្យទាំងនោះ គេអាចសង្កេតឃើញនូវមុខរបរ កិច្ចការរបស់មនុស្ស ដែលមានឈ្មោះបង្កបង្កើតឡើងដោយកិរិយាស័ព្ទ ។

ឧទាហរណ៍ :

| | | |
|---|---|---|
| ក្ញុ រ្ហល៑ | K 480 ku rhval | " រវល់ " |
| ក្ញុ ត្វាយ៑ | K 516 ku tvāy | " ថ្វាយ " |
| ក្ញុ ត្បញ៑ | K 18 ku tpañ | " ត្បាញ " |
| វ ចង៑ | K 248 va coṅ | " ចង ឬ សង់ " |
| ក្ញុ ជុល៑ | K 810 ku jul | " ជល់ " |
| វ ស្រេក៑ | K 133 va srek | " ស្រែក " |
| តៃ សិរ៑ | K 137 tai sir | " សរសេរ " |
| លោញ៑ កេត៑ | K 219 loñ ket | " កើត, ប្រសូត " |
| តៃ បន្ទន៑ | K 327 tai pandan | " បន្ទន់ " |
| គ្វាល៑ ប្រវាត៑ | K 327 gvāl pravāt | " កំសាន្ត, ក្រសាល " |

- *នរនាម កកើតដោយសំខ្យាស័ព្ទ ( ចំនួន ) :*

នរនាមកកើតឡើងដោយសំខ្យាស័ព្ទ ច្រើនជានរនាមសំរាប់សំគាល់នូវក្រុមមនុស្ស នៅស្រទាប់ក្រោម CSI ។

សំខ្យាស័ព្ទ ដែលគេបានប្រើប្រាស់សំរាប់បង្កើតនរនាម គឺសំខ្យាស័ព្ទក្នុងភាសាសំស្រ្កឹត ។

ឧទាហរណ៍ :

| | | |
|---|---|---|
| វាប ឯក | K 207 vāp ek | " មួយ " |
| វ បញ្ចមី | K 451 va pañcamī | " ប្រាំ " |
| វា ឆត្តី | K 149 vā chattī | " ប្រាំមួយ " |
| វ សប្តមី | K 910 va saptamī | " ប្រាំពីរ " |
| វ ទឝមី | K 51 va daçamī | " ដប់ " |
| វ ត្រយោទឝី | K 54 va trayodaçī | " ដប់បី " |
| ក្វាល ត្រៃ | K 324 gvāl trai | " បី " |

នៅតាមសិលាចារឹកសម័យមុនអង្គរ និងអង្គរខ្លះទៀត គេសង្កេតឃើញមានឈ្មោះជាច្រើន ដែលមានការប្រើសំខ្យាស័ព្ទ សំរាប់សំគាល់ឈ្មោះមនុស្សបែបនេះ ឬក៏តួលេខជាភាសាសំស្ក្រឹត អាចមានន័យទាក់ទងទៅនឹងមន្តអាគមគាថា ឬទាក់ទងទៅនឹងឈ្មោះថ្ងៃ ឬខែ នៅក្នុងព្រហ្មញ្ញសាសនា ឬមួយក៏បាតុភូតបែបនេះបានកើតមានឡើងដោយសារកង្វះខាតនៃពាក្យ សំរាប់ប្រើប្រាស់ក្នុងនរនាម ។

ក្នុងកាលៈទេសៈដទៃទៀត នរនាម មិនមែនគ្រាន់តែកើតឡើងដោយសព្វនាម គុណនាម កិរិយាស័ព្ទ ដែលមានរូបរាងជាពាក្យមួយព្យាង្គ ឬពីរព្យាង្គប៉ុណ្ណោះទេ ។ ជារឿយៗ គេសង្កេតឃើញថា នរនាមបានកកើតឡើង ឬមួយបានត្រូវបង្កបង្កើតឡើងដោយកន្សោមពាក្យដ៏វែង ដែលជាសមាសពាក្យ ឬក៏ជាឃ្លាប្រយោគដ៏តូច ដែលកកើតឡើងដោយការប្រើប្រាស់នាមស័ព្ទ + កិរិយាស័ព្ទ ឬមួយក៏ កិរិយាស័ព្ទ + នាមស័ព្ទ ដែលជាបុព្វបទ ឬមួយក៏ជាឃ្លាដ៏តូចប្រកបដោយប្រធានកិរិយាស័ព្ទ និងបុព្វបទ ។

នៅក្នុងភាសាខ្មែរ ក៏ដូចជានៅក្នុងភាសាដទៃទៀត កាលណានរនាម ឬ ឋាននន្តរនាម មានទំរង់កាន់តែវែង នោះគេសង្កេតឃើញថា នរនាម ឬ ឋាននន្តរនាម ទាំងនោះ ត្រូវបានប្រកបដោយឧត្តមភាពកាន់តែខ្ពង់ខ្ពស់ កាន់តែរុងរឿង ។

• *នរនាមកកើតឡើងដោយនាមនាម :*

ឧទាហរណ៍ :

កុ ប្កា ឈេ K 66 ku pkā jhe " ផ្កាឈើ "
តៃ ថ្មោ រត្ន K 352 tai thmo ratna " ថ្ម រ័ត្ន "
ខ្លោញ តេំ មុលិះ K 258 khloñ teṃ muliḥ " ដើមម្លិះ "

• *នរនាមកកើតឡើងដោយនាម + គុណនាម :*

ឧទាហរណ៍ :

តៃ ស្លា ខ្ចី K 669 tai slā khcī " ស្លាខ្ចី "
តៃ ជេង ក្រេស K 270 tai jeṅ kres " ជើងតៀ "
វា មុក៑ ក្រហម៑ K 41 vā muk kraham " មុខក្រហម "
វា ស្វា ក្មៅ K 220 vā svā kmau " ស្វាខ្មៅ "

• *នរនាមកកើតឡើងដោយនាម + កិរិយាស័ព្ទ :*

ឧទាហរណ៍ :

កុ ទិក៑ ផិក៑ K 353 ku dik phik " ទឹកផឹក "
លោញ ថ្ងៃ កេត៑ K 353 loñ thṅai ket " ខាងកើត ឬថ្ងៃរះ "
លោញ ថ្ងៃ លុច៑ K 766 loñ thṅai luc " ខាងលិច "
វ កញ្ចិ រំ K 138 va kañci raṃ " ពាំដែលរាំ "

ជាទូទៅ សមាសនាមដែលមានរូបមន្ត នាម + នាម + គុណនាម, មានទំនាក់ទំនងជាកម្មបំពេញបទរវាងធាតុផ្សំ ហើយធាតុផ្សំទី ២ " ពាក្យទី ២ " គឺជាធាតុកំណត់ធាតុផ្សំទី ១ ។

ចំណែកសមាសនាម ដែលមានរូបមន្ត នាម + កិរិយាស័ព្ទ ទំនាក់ទំនងរវាងធាតុផ្សំ ( គឺរវាងពាក្យទាំង ២ ដែលជាសមាសភាពនៃនរនាម ) គឺជាទំនាក់ទំនង

តាមរូបមន្តកម្មបំពេញបទ ឬ ក៏ជាទំនាក់ទំនងបញ្ជាក់រវាងធាតុទី ១ និងធាតុទី ២ ដោយមានការបញ្ជាក់លក្ខណៈ ឬគុណសម្បត្តិនៃនរនាម ។

តាមសិលាចារឹកសម័យមុនអង្គរ និងសម័យអង្គរ គេអាចប្រទះឃើញនូវនរនាមជាច្រើន ដែលត្រូវបង្កបង្កើតឡើងតាមរូបមន្តនៃពាក្យរណ្ដំ ជួនកាលមានរណ្ដំព្យញ្ជនៈ ជួនកាលមានការរណ្ដំស្រៈ ។ ហើយលក្ខណៈពិសេសបែបនេះ តាមពិតទៅ ក៏គេអាចសង្កេតឃើញនៅក្នុងភាសាខ្មែរបច្ចុប្បន្នផងដែរ ។

ឧទាហរណ៍ :



| | |
|---|---|
| K 127 va tal tol | " តលតោល " |
| K 361 va cak cek | " ចកចេក " |
| K 357 ku har her | " ហរហេរ " |
| K 18 ku dap dip | " ទបទិប " |
| K 877 ku mañ moñ | " មញមោញ " |
| K 327 tai can cān | " ចនចាន " |

ដូចយើងបានឃើញរួចមកហើយ នៅលើមូលដ្ឋាននៃវេយ្យាករណ៍ ឋាននន្តរនាមនៅសម័យមុនអង្គរ និងអង្គរ បានត្រូវបង្កបង្កើតឡើងដោយវិធីប្រើបុព្វបទ ( prefixe ) ឬដោយពាក្យសមាស ឬ " ពាក្យផ្សំ " ។

ប៉ុន្តែ គេសង្កេតឃើញថា វិធីប្រើបុព្វបទ មានលក្ខណៈខ្លាំងក្លាញឹកញយជាងវិធីប្រើបទសមាសនៃពាក្យ ។ ជួនកាលនោះ បញ្ជាក់ឱ្យយើងយល់ថា នៅក្នុងភាសាខ្មែរបុរាណ ការបង្កបង្កើតពាក្យ ឬការបង្កើតឋាននន្តរនាម តាមបទសមាសជាវិធីសំខាន់នៅក្នុងភាសា តាមការប្រើបុព្វបទ គឺការប្រើផ្ទុត់ ជាវិធីសំខាន់ជាងគេ ហើយដែលមានលក្ខណៈខុសអំពីភាសាថៃ ឬវៀតណាម ។ មិនតែប៉ុណ្ណោះ នៅក្នុងការបង្កបង្កើតនរនាមក្នុងក្រុមមនុស្សសាមញ្ញ CSI មានកិរិតកាន់តែខ្ពស់ជាងការ

បង្កបង្កើតឋាននូវនាម ។

នរនាមក្នុងក្រុមមនុស្សសាមញ្ញ CSI បានត្រូវបង្កបង្កើតឡើងដោយវិធីប្រើបុព្វបទ ។ ជួនកាល ពាក្យដើមតែមួយ បានត្រូវបង្កបង្កើតនរនាមពីរ ឬ បី ផ្សេងៗទៀត ។ កាលណាយើងឃើញនរនាមណាមួយប្រកបដោយបុព្វបទ ( préfixe : ផ្នត់ដើម ) នោះយើងអាចសន្និដ្ឋានបានថា នរនាមនោះ ស្ថិតនៅក្នុងក្រុមមនុស្សសាមញ្ញ CSI ។

ឧទាហរណ៍ :

| | | |
|---|---|---|
| វាប៑ មៅវ | K 165 vāp mauv | " ម៉ៅ " |
| សិ ខ្មៅ | K 262 si khmau | " ខ្មៅ " |
| វាប៑ ជា | K 269 vāp jā | " ជា " |
| តៃ កញ្ជា | K 99 tai kañjā | " កញ្ញា " |
| ម្រតាញ៑ ឥ | K 198 mratāñ i | " ឥ " |
| ឃោ កន៑ ឥ | K 291 gho kan i | " កន្និ " |

ការយល់ដឹងច្បាស់អំពីប្រព័ន្ធនៃការបង្កបង្កើតនរនាម សំរាប់មនុស្សសាមញ្ញធម្មតា អាចអោយយើងធ្វើការវិភាគរកពាក្យដើម ដែលគេបានយកមកប្រើនៅក្នុងនរនាម ។ តាមធម្មតា នរនាមជនសាមញ្ញធម្មតា គេឥតមកពីពាក្យកម្លាយ ដែលមានទំរង់ពាក្យពីរព្យាង្គ :

ព្យាង្គទី ១ គឺ បុព្វបទ ឬ ជាផ្នត់ដើម រីឯព្យាង្គទី ២ គឺជាពាក្យធម្មតានៃភាសា គឺពាក្យដើម ។

ឧទាហរណ៍ :

| | |
|---|---|
| ជ្រៃ | K 198 ( < jrai : K 106 ជ្រៃ ) |
| យសិ | K 343 ( < yasa : យស ) |

ឝ្រី K 258 ( < çrī : " សោភណភាព " )
ព្រះ K 11 ( < vraḥ K 600 ; ព្រះ )
ចិន K 221 ( * cīna ចីន, ចិន )
យ្វន K 682 ( * yvan យួន " យវន " )

យើងបានឃើញរួចហើយថា ភាគច្រើននៃនរនាមខ្មែរ បានត្រូវបង្កបង្កើតឡើងនៅលើមូលដ្ឋាននៃនាមស័ព្ទ គុណស័ព្ទ កិរិយាស័ព្ទ សំខ្យាស័ព្ទ ដែលជា Catégories grammaticales គឺជាផ្នែកខាងវេយ្យាករណ៍ ដើម្បីសំគាល់ពាក្យនៅក្នុងភាសាខ្មែរ ។

នៅក្នុងការសិក្សានរនាម ពាក្យទាំងនេះ បានត្រូវប្រើប្រាស់ មិនមែនសំរាប់តែសំគាល់ឈ្មោះមនុស្សប៉ុណ្ណោះទេ ប៉ុន្តែ សំរាប់សំគាល់នូវរូបសម្បត្តិ គុណ. សម្បត្តិ ជំនឿ វិជ្ជាជីវៈ លក្ខណៈផ្សេងៗ និងព្រឹត្តិការណ៍ដ៏សំខាន់ៗ ដែលទាក់ទងទៅនឹងបុគ្គល ដែលគេត្រូវផ្តល់នូវនាមឈ្មោះ ។

ជាទូទៅ ក្នុងការបង្កបង្កើតនរនាម មានប្រើវិធីប្រៀបធៀប រវាងអ្នកដែលត្រូវគេឱ្យឈ្មោះ ទៅនឹងវត្ថុដែលស្ថិតនៅក្នុងពិភពខាងក្រៅណាមួយ ហើយដែលមានជាប់ទាក់ទិនទៅនឹងបុគ្គលនោះ ។ មិនតែប៉ុណ្ណោះ នរនាមភាគច្រើន បានត្រូវបង្កបង្កើតឡើងនៅលើវិធីប្រើពាក្យរណ្តំ គឺរណ្តំទាំងស្រៈ ទាំងព្យញ្ជនៈ ទាំងព្យាង្គ ហើយទោះបីវិធីនេះ មិនសូវត្រឹមត្រូវតាមសេម៉ង់ទិកក៏ដោយ ក៏នៅក្នុងភាសាខ្មែរ នៅក្នុងភាសាមន-ខ្មែរ ដទៃទៀត មានការប្រើប្រាស់វិធីផ្គូនពាក្យរណ្តំ កាន់តែញឹកញាប់ឡើង ។

ជាទូទៅ យើងអាចចែកប្រភេទនៃនរនាម តាមបែបសេម៉ង់ទិកដូចតទៅ :

- *នរនាមដែលបង្កបង្កើតឡើងនៅលើរូបលក្ខណៈ ដែលមានជា*

*អាទិ៍ ពណ៌សម្បុរ ទំហំ កំពស់ ក្លិន សុខភាព ។ ល ។*

ឧទាហរណ៍ ៖

| | | |
|---|---|---|
| គុ ខ្មៅ | K 129 ku kmau | " ខ្មៅ " |
| វ សោ | K 01 va so | " ស " |
| វ កន្ត្រាង | K 748 va kantrāṅ | " កន្ត្រាង " |
| វ វេង | K 149 va veṅ | " វែង " |
| គុ សង្វិត៑ | K 129 ku saṅvit | " សង្វិត, ស្វិត " |
| ពញ៑ កន្តិល៑ | K 54 poñ kantil | " កន្ទិល " |
| ឃោ សុគន្ធ | K 669 gho sugandha | " ក្លិនក្រអូប " |
| វាប៑ ជា | K 269 vāp jā | " ជា, សុខ " |
| វ តំវេក៑ | K 352 va taṃvek | " ទំពែក " |
| វ ត្លោស៑ | K 127 va tlos | " ថ្លោស " |
| តៃ ថ្នេ | K 889 tai thṅe | " ខ្មៅស្រអែម " |

• *នរនាមដែលត្រូវបង្កបង្កើតឡើង នៅលើមូលដ្ឋាននៃគុណសម្បត្តិរបស់បុគ្គល ឬនៅលើលក្ខណៈចរិតខាងក្រៅ ៖*

តាមធម្មតា នរនាមបែបនេះ មានចំនួនច្រើន ហើយនៅក្នុងភាសាខ្មែរបច្ចុប្បន្ន ក៏កាន់តែមានចំនួនច្រើន ។

ឧទាហរណ៍ ៖

| | | |
|---|---|---|
| វ កំរុ | K 138 va kaṃru | " គំរូ " |
| គុ កំវុត៑ | K 127 ku kaṃvut | " មានពុត " |
| វ ជ្មេង | K 24 va jmeṅ | " ឆ្មើង " |
| គុ វៃ | K 14 ku vai | " វៃ, វាងវៃ " |

| | | |
|---|---|---|
| ក្ញុ រ្ហល៑ | K 929 ku rhval | " រវល់ " |
| ក្ញុ ក្មាស៑ | K 129 ku kmās | " ខ្មាស " |
| វ ប្រសប៑ | K 175 va prasap | " ប្រសប់ " |
| លោញ៑ សម៑ | K 270 loñ sam | " សម " |
| ឃោ បន្ទន៑ | K 270 gho pandan | " បន្ទន់ " |

• *នរនាមដែលត្រូវបង្កបង្កើតឡើងនៅលើមូលដ្ឋាននៃរុក្ខជាតិ :*

នរនាមបែបនេះ មានច្រើននៅក្នុងសិលាចារឹកខ្មែរ ហើយនៅក្នុងភាសាខ្មែរបច្ចុប្បន្ន គេតែងប្រទះឃើញមាននរនាម ដែលកកើតឡើងនៅលើមូលដ្ឋាននៃបរិដ្ឋានដែលជារុក្ខជាតិ ។

ឧទាហរណ៍ :

| | | |
|---|---|---|
| ក្ញុ ស្វាយ៑ | K 129 ku svāy | " ដើមស្វាយ " |
| ក្ញុ អំវិល៑ | K 57 ku aṃvil | " ដើមអំពិល " |
| ក្ញុ ស្មៅ | K 163 ku smau | " ស្មៅ " |
| ក្ញុ ស្រង៑ | K 310 ku sraṅe | " ដើមស្រង៉ែ " |
| ក្ញុ អំវៅ | K 155 ku aṃvau | " ដើមអំពៅ " |
| ក្ញុ ក្រហ្វាញ៑ | K 561 ku krahvāñ | " ដើមក្រវ៉ាញ " |
| វ ចន្ទន | K 155 va candana | " ដើមខ្លឹមច័ន្ទ " |
| វ ត្រាហ្វ | K 151 va trāhva | " ដើមព្រាវ " |
| ក្លោញ៑ ត្រសក៑ | K 561 kloñ trasok | " ត្រសក់ " |
| តៃ ខ្នោរ៑ | K 873 tai khnor | " ខ្នុរ " |
| តៃ ឧលិក៑ | K 808 tai ulik | " ឪឡឹក " |
| លោញ៑ ជ្រៃ | K 143 loñ jrai | " ជ្រៃ " |



K 76 ku slā " ស្លា "

K 480 ku srū " ស្រូវ "

K 153 tai krvac " ក្រូច "

ក្នុងចំណោមឈ្មោះដែលមានស្រង់ចេញពីពិភពរុក្ខជាតិ ដែលសំរាប់បង្កើតនរនាម គេតែងប្រទះឃើញឈ្មោះផ្កា ឬឈ្មោះផ្កាឈើដែលមានប្រើប្រាស់សំរាប់យកទៅដាក់ឈ្មោះ " នារី " ។

ពាក្យ " ត្រសក់ < ត្រសោក " បានត្រូវប្រើប្រាស់សំរាប់តែដាក់ឈ្មោះ " បុរស " ហើយមិនមែនជាការប្លែកអ្វីទេ ដែលគេបានប្រទះឃើញតាមប្រវត្តិសាស្ត្រ មានព្រះមហាក្សត្រមួយអង្គ ព្រះនាម " ត្រសក់ផ្អែម " ។

ឈ្មោះដើមឈើ ច្រើនតែប្រើប្រាស់ដើម្បីបង្កើតនរនាម ដែលជាឥស្សរៈជនដ៏សំខាន់ ហើយដែលមានកិរិតឧត្ដមភាពដ៏ខ្ពង់ខ្ពស់ គឺកិរិតនៃឧត្ដមភាពស្របទៅតាមទំហំ ប្រភេទ និងកិរិតនៃការគោរពទាក់ទងទៅនឹងដើមឈើទាំងនោះ ។

ឧទាហរណ៍ ៖ នរនាមដែលមានប្រើប្រាស់ឈ្មោះដើមឈើ " ជ្រៃ " ដែលគេតែងតែចាត់ទុកជាដើមឈើជាទីសក្ការៈ ហើយដើមជ្រៃនេះ ត្រូវបានគេប្រើប្រាស់សំរាប់ដាក់ឈ្មោះដល់បុគ្គល ដែលមានឋានន្តរនាមដ៏ខ្ពង់ខ្ពស់ ។

• *នរនាមដែលត្រូវបង្កបង្កើតឡើង ដោយការប្រើឈ្មោះសត្វ ៖*

ឧទាហរណ៍ ៖



K 109 va anrok " គោព្រៃ "

K 765 va trases " ត្រសេស "

K 447 va klā " ខ្លា "

K 54 va jleṅ " ឈ្លើង "

K va bhe " ភេ "

| | | | |
|---|---|---|---|
| ក្ញុំ អន្តេក | K 129 | ku antek | " អណ្តើក " |
| ក្ញុំ ឆ្មា | K 711 | ku cmā | " ឆ្មា " |
| វ ចកេ | K 66 | va cake | " ឆ្កែ " |
| សិ តុវៅ | K | si tuvau | " តាវៅ " |
| តៃ តង្កេ | K 809 | tai taṅke | " តុកកែ " |
| សិ ពៅ ស្ការ | K 327 | si pau skār | " ស្កា " |
| លោញ គោ | K | loñ go | " គោញី " |
| លោញ ហង្ស | K | loñ haṅsa | " យានជំនិះព្រះវិស្ណុ : ហង្ស " |

ឈ្មោះសត្វដែលគេបង្កើតនរនាម សម័យមុនអង្គរ និងនៅក្រោយសម័យអង្គរ គឺត្រូវបានគេប្រើប្រាស់ជាញឹកញយ ដើម្បីបង្កើតនរនាមនៃជនជំពូក CSI " សាមញ្ញ ជន " តែប៉ុណ្ណោះ ។

នៅក្នុងករណីខ្លះ នរនាមនៃអភិជន បានត្រូវបង្កើតឡើងដោយដាក់តាមឈ្មោះសត្វ ជាភាសាសំស្ក្រឹត ។

នៅក្នុងសិលាចារឹក គេតែងប្រទះឃើញនរនាម " cke, cake " ។ ការប្រើប្រាស់ជាញឹកញាប់នូវឈ្មោះនេះ ដើម្បីដាក់ប្រើនូវឈ្មោះមនុស្ស គឺមិនមែនជាការថោកទាបដល់ជនដែលមានឈ្មោះបែបនេះទេ ។ ប្រហែលជានៅសម័យបរមបុរាណ មាននៅប្រពៃណីប្រកបដោយការគោរពសត្វ ។

ដោយមានការពន្យល់ថា សត្វក៏ជាអ្នកមានដើមកំណើតដូចមនុស្សដែរ ឬក៏របស់ជនជាតិ ។ ហើយគំនិតបែបនេះ រមែងស្ថិតនៅក្នុងសន្តានចិត្តជនជាតិអូស្ត្រូ -អាស៊ីយ៉ាទិក ជនជាតិ មន - ខ្មែរ ។

នៅក្នុងសិលាចារឹកខ្មែរ មាននរនាម ដូចតទៅ :

ឧទាហរណ៍ :

ទៃ អជិ ឆ្កេ K 134 tai aji chke នារី អ្ជី ឆ្កេ " នារីមានជីតាជីដូន មានឈ្មោះថាឆ្កែ " ។

• *នវនាមដែលត្រូវបង្កបង្កើតឡើងដោយឈ្មោះកាល ឈ្មោះថ្ងៃ ខែៈ*

ឧទាហរណ៍ :

តេង ចន្ទ្រ K 373 teṅ candra " ចន្ទ "

លោញ អង្គារ K 348 loñ aṅgara " អង្គារ "

វា សៅ K 22 vā sau " សៅរ៍ "

កុ ផ្កាយ K 127 kuphkāy " ផ្កាយ "

ខ្លោញ អាទិត្យ K 143 khloñ aditya " អាទិត្យ "

លោញ វ្រហស្បតិ K 230 loñ vrahaspati " ព្រហស្បតិ៍ "

វ បូណ្ណមី K 54 va purṇṇamī " បូណមី "

• *នវនាមដែលបង្កបង្កើតដោយការប្រើប្រាស់នូវឈ្មោះទេវៈ ឈ្មោះវីរបុរសនៅក្នុងទេវកថា :*

គេតែងសង្កេតឃើញថា ការដាក់ឈ្មោះមនុស្សតាមនាមនៃទេវៈ ឬនាមវីរជននៅក្នុងទេវកថា រមែងទាក់ទងជំនឿតាមព្រហ្មញ្ញសាសនា ឬពុទ្ធសាសនា ។ ប៉ុន្តែគេតែងសង្កេតឃើញថា នាមនៅក្នុងព្រហ្មញ្ញសាសនា បានត្រូវប្រើប្រាស់យ៉ាងញឹកញាប់នៅក្នុងពុទ្ធសាសនា ។ ការដាក់ឈ្មោះតាមទេវៈ ឬមួយតាមឈ្មោះនៃពេលវេលា ឬរមែងយោលទៅតាមការទស្សន៍ទាយ នៃថ្ងៃកំណើតរបស់បុគ្គល ដែលគេត្រូវដាក់ឈ្មោះ ហើយរបត់បែបនេះ គឺមាននៅក្នុងភាសាខ្មែរបច្ចុប្បន្ន ។

ឧទាហរណ៍ :

តេង ក្ឫឞ្ណា K 61 teṅ krṣṇā " ក្រឹស្ណា "

តេង សិតា K 809 teṅ sitā " សិតា "

លោញ៑ រាម K 221 loñ rāma " រាមា "
លោញ៑ កាម K loñ kāma " ព្រះកាមៈ "
សិ វារុណ K si vāruṇa " ភ្លៀង "
តេង៑ លក្ស្មី K 938 teṅ lakṣmī " លក្ស្មីណ៍ "
តេង៑ សរស្វតី K 852 teṅ sarasvatī " សរស្វតី : មហេសី ព្រះព្រហ្ម "
ម្រតាញ៑ខ្លោញ៑វិស្ណុ K 143 mratāñ khloñ viṣṇu " ព្រះវិស្ណុ "
តាង៑ វ្រាហ្ម K 720 tāṅ vrāhma " ព្រះព្រហ្ម "
កម្រតាង៑ អញ៑ ឥន្ទ្រ K 91 kaṃmratāṅ añ indra " ព្រះឥន្ទ្រ "

*• នរនាមដែលត្រូវបង្កបង្កើតឡើង លើមូលដ្ឋាននៃវិជ្ជាជីវៈ :*

នរនាមបែបនេះមានសារសំខាន់ ដោយហេតុថា ការសិក្សានាមឈ្មោះទាំងនេះ តាមរយៈនៃការពន្យល់ពាក្យ អាចបង្ហាញអោយយើងឃើញនូវអ្នកប្រកបការងារ នាសម័យនោះ ។

ឧទាហរណ៍ :

កុ ត្មាញ៑ K 24 ku tmañ " អ្នកត្បាញ "
កុ ចំរេង៑ K 66 ku caṃreṅ " អ្នកចំរៀង "
កុ ច្មាំ K 786 ku cmāṃ " អ្នកចាំ "
កុ ច្បារ K 877 ku cpar " អ្នករក្សាច្បារ "
វ ចំលក K 138 va caṃlak " អ្នកចំលាក់ "
វ រំ K 115 va raṃ " អ្នករាំ "
វ តំនំ K 904 va taṃnaṃ " អ្នកដាំដំណាំ "
វ ចប្បិ ហៅ K 155 va cappi hau " ចាប់ + ដើម្បី +

ហៅ ៖ អ្នកត្រួត "

សិ ក្នេត K 650 si knet " ខ្នើត "

ពាក្យខាងចុង " si knet " អាចពន្យល់បានថាជានរនាម ឬមួយជារហស្សនាម សំរាប់សំគាល់នូវមនុស្សប្រុស ដែលត្រូវធ្វើការ តាំងពីថ្ងៃ ១ កើត រហូតដល់ថ្ងៃ ១៥ កើត ។

ផ្ទុយពីពាក្យនេះ គឺពាក្យ " រនោច " ដែលគេបានប្រើជានរនាម សំរាប់សំគាល់នូវអ្នកធ្វើការ ពីថ្ងៃ ១ រោជ រហូតដល់ ១៥ រោជ ។ បានសេចក្ដីថា នៅមុនសម័យអង្គរ និងសម័យអង្គរ អ្នកបំរើទាំងប្រុសទាំងស្រី មានភារៈនឹងបំពេញការងាររបស់ខ្លួននៅវត្តអារាម ឬបំពេញការងារដទៃទៀត ជាប្រយោជន៍រួម ឬបំពេញការងាររាជការ ជាកិច្ចការរបស់រាជ្យ តាមកំណត់ពេល គឺ ខ្នើត និងរនោច ។

• *នរនាមបង្កបង្កើតឡើងនៅលើមូលដ្ឋាននៃស្ថាននាម ឬមួយលើមូលដ្ឋានរបស់ឈ្មោះនៃជនជាតិ ៖*

ឧទាហរណ៍ ៖

កុ បាង្ រាង្ K 66 ku pāṅ rāṅ " នារីមកពីស្រុកប៉ាងរ៉ាង " ទីក្រុងប៉ាងរ៉ាង នៅស្រុកចាម្ប៉ា

កុរេក៑ ជវា K 165 kurek javā " នាហ្នឹន ៖ មានកំណើតជាជ្វា "

វ លវោ K 557 va lavo " បុរស (មកពីស្រុក) ល្វោ "

វ រមញ K 926 va ramañ " បុរស (ជនជាតិ) មន "

វ ស្យាំ K 79 va syāṃ " បុរស (ជនជាតិ) សៀម "

វ ក្លិង្ K 24 va kliṅ " បុរស (ជនជាតិ) ក្លិង "

កុរាក៑ ទន្លេ ក្រោហ្វ K 561 kurāk danle krohva " ស្ដេចក្រាញ់

ទន្លេក្រៅ "

ឝំស្តេង៑ វ្រៃទំពោង៑ K 207 kaṃsteṅ vrai taṃpoṅ " មហាមន្ត្រី ព្រៃដំបង "

នរនាមទាំងឡាយ ដែលត្រូវបានបង្កបង្កើតឡើង ដោយការប្រើពាក្យទាក់ទងនឹងនាមឈ្មោះរបស់ជនជាតិ ឬទាក់ទងទៅនឹងឈ្មោះទីកន្លែង នរនាមទាំងអស់នោះ មានអត្ថន័យដ៏សំខាន់ នៅក្នុងការសិក្សាពីស្រទាប់ប្រជាជន ដែលបានរស់នៅលើទឹកដី នៃប្រទេសកម្ពុជា សម័យមុនអង្គរ និងសម័យអង្គរ ហើយដែលកំពុងរស់នៅតទៅទៀត រហូតដល់សព្វថ្ងៃ ។

តាមសិលាចារឹកមុនអង្គរ នៅលើមូលដ្ឋាននៃនរនាម យើងបានឃើញថាជនជាតិ ក្លិង្គ ចាម មន ( រមញ ) ប្រៅ ( ប្រាវ ៖ ព្រៅ ) ហើយជាពិសេស ជនជាតិសៀម ( ស្យាម ៖ ស្យាំ ) ព្រមទាំងជនជាតិឡាវ ។ ហើយនៅសម័យអង្គរមូលដ្ឋានសិក្សាសិលាចារឹក នរនាមដែលគេបានប្រទះឃើញនូវការប្រើពាក្យ ៖

ចិន cina ចិន

យ្វន៑ yvan យួន នៅក្នុងឈ្មោះកញ្ញ យួន

តាមសិលាចារឹកមុនអង្គរ រកឃើញនៅខេត្តកំពង់ស្ពឺ មានការរៀបរាប់អំពីអ្នកបំរើ " រមញ " គឺជាភស្តុតាងបញ្ជាក់ថា ជនជាតិមនមានរស់នៅតាំងពីសតវត្សទី ៦ ហើយរស់នៅរហូតដល់ខេត្តកំពង់ស្ពឺ រហូតដល់សព្វថ្ងៃ គេមិនទាន់ស្រាវជ្រាវឃើញនូវស្រទាប់ចាស់នេះនៅឡើយ ។ ប៉ុន្តែ នៅក្នុងខេត្តកំពង់ស្ពឺសព្វថ្ងៃ ក៏នៅបន្សល់ឈ្មោះស្រុកមួយថា " ស្រុកច្បារមន " ដែរ ។

ឯកសារបែបនេះសំខាន់ណាស់ ហើយអាចប្រើប្រាស់នៅក្នុងក្របខណ្ឌនៃជាតិពន្ធុវិទ្យា ដើម្បីស្រាវជ្រាវរកប្រវត្តិនៃជនជាតិ មន-ខ្មែរ ជាជនជាតិដែលមានគំនិត សាច់ញាតិ ជាបងប្អូនបង្កើត ឬនិយាយឱ្យខ្លីទៅជាជនជាតិតែមួយ ។

បញ្ហាធំដែលចោទឡើងគឺថា មន-ខ្មែរ ដែលមានជនជាតិតែមួយបានកើតឡើង នៅសម័យប្រវត្តិសាស្ត្រ គឺ ពីរពាន់ ឬ មួយពាន់ឆ្នាំ មុន គ.ស. ឬក៏នៅសម័យប្រវត្តិសាស្ត្រ ដើម គ.ស. រហូតទៅដល់ការបាក់បែកនៃនគរភ្នំ ។

នៅតាមសិលាចារឹកសម័យមុនអង្គរ មានអ្នកបំរើ ឬអ្នកជា ដែលមានឈ្មោះថា " ស្យាម " ហើយអ្នកទាំងអស់នេះ ច្រើនមានឈ្មោះនៅតាមសិលាចារឹកតាមមាត់ទ្វារ តាមអាស្រម ។

យើងមិនអាចសន្និដ្ឋានបានថា ពាក្យ " ស្យាម " ឬ " សៀម " ជាពាក្យសំរាប់សំគាល់ជនជាតិថៃបានទេ ដោយហេតុថា នៅក្នុងភាសាសំស្ក្រឹត ពាក្យ " ស្យាម " មានន័យច្រើនយ៉ាង ។ ក៏ប៉ុន្តែ ន័យដ៏សំខាន់ គឺ " ពណ៌ខ្មៅ, ស្រអែម " ។

ក៏ប៉ុន្តែ យោងទៅលើសិលាចារឹក យើងអាចសន្និដ្ឋានបានថា នៅសម័យមុនអង្គរ និងអង្គរ មានកុលសម្ព័ន្ធ " ស្យាម " ( ថៃ ឬ ឡាវ ) ដែលបានភៀសខ្លួនពីតំបន់យូណាន មកដែនដីសណ្ដទន្លេមេគង្គប៉ែកខាងក្រោម ដែលត្រូវនឹងទឹកដីឥណ្ឌូចិនសព្វថ្ងៃ ។ ហើយសមាជិកភាគច្រើននៃកុលសម្ព័ន្ធនេះ នៅក្នុងវត្តអារាម ហើយមកដល់រជ្ជកាលព្រះបាទសូរ្យវរ្ម័ន មានពួកសៀមចូលមកធ្វើការនៅក្នុងជួរកងទ័ពខ្មែរ ដូចមានរូបភាពតាមប្រាសាទអង្គរវត្ត ។ ហើយមានអក្សរចារឹកថា សៀមម្នាក់ឈ្មោះ ស្យាំកុក syāṃ kuk ។

នរនាមដែលយកឈ្មោះទីកន្លែងមកប្រើ បញ្ជាក់អោយយើងដឹងថា នរនាមនោះ មានលក្ខណៈជាឋានន្តរនាមផង ជានាមឈ្មោះរបស់មនុស្ស ហើយដែលស្ថិតនៅក្រោមស្រទាប់ជាន់ថ្នាក់ខ្ពស់នៃសង្គម ។

តាមធម្មតា នៅក្នុងភាសាខ្មែរ កាលណាបុគ្គលណាមួយរូប មានឋានន្តរសក្តិខ្ពង់ខ្ពស់តាមប្រពៃណី គេមិនសូវប្រើឈ្មោះ ឬក៏មិនសូវហ៊ានហៅឈ្មោះបុគ្គល

នោះឱ្យចំតែម្តងទេ ។ ប៉ុន្តែ គេយកឋាននួរនាម និងឈ្មោះទីកន្លែងដែលបុគ្គលនោះនៅគ្រប់គ្រង មកប្រើជំនួសតាមឈ្មោះផ្ទាល់របស់បុគ្គលនោះទៅវិញ ។

ឧទាហរណ៍ :

ᨀᨒᨓ kaṃsteṅ vrai taṃpoṅ

K 107 " ចៅហ្វាយខេត្តព្រៃតំបង "

ហើយនៅក្នុងពាក្យនោះ គេសង្កេតឃើញថា " ព្រៃតំបង " ជាតំបន់នៅតាមសិលាចារឹក សម័យមុនអង្គរ និងអង្គរ ។ មាននរនាមនៃបុគ្គលជាន់ខ្ពស់ជាច្រើន ហើយនរនាមទាំងនេះ ជានរនាមជាភាសាសំស្ក្រឹត គឺជានាមឈ្មោះព្រះមហាក្សត្រ រាជក្សលមហាមន្ត្រី ព្រះគ្រូ បានត្រូវគេប្រើប្រាស់សំរាប់បង្កបង្កើតឈ្មោះរាជធានី ឈ្មោះខេត្ត ស្រុក ព្រះវិហារ និងសំណង់ទំនប់ទឹកដ៏សំខាន់ៗ ជាដើម ។ ទំលាប់យកឈ្មោះមនុស្សទៅដាក់ឈ្មោះទីកន្លែង មិនមែនមានជាទំលាប់សំរាប់តែជនជាតិខ្មែរទេ ប៉ុន្តែ សំរាប់ជនជាតិដទៃជាច្រើន ដូចជា ជនជាតិឥណ្ឌូអឺរ៉ុប ជាដើម ។

ហើយបញ្ហានេះ នឹងត្រូវសិក្សានៅក្នុងផ្នែកភាសាវិទ្យាមួយទៀត ដែលទាក់ទងទៅនឹងប្រវត្តិវិទ្យាផង ភូមិវិទ្យាផង និងស្ថាននាមវិទ្យាផង Toponymie ។

ដោយសាស្ត្រាចារ្យ បណ្ឌិត **ឡុង សៀម**
ព្រឹទ្ធសហការី នៃបណ្ឌិត្យសភាវិទ្យាសាស្ត្រ
( វិទ្យាស្ថានបូពិសាស្ត្រ ) សហព័ន្ធរុស្ស៊ី

# អំពីលទ្ធិហិណ្ឌូ ( HINDUISM )

ពាក្យ « **Hinduism** » (លទ្ធិហិណ្ឌូ) គឺជាស័ព្ទប្រើដោយពួកអ្នកនិពន្ធលោកខាងលិច ដើម្បីសំគាល់សាសនា ដ៏ធំបំផុតរបស់ប្រទេសឥណ្ឌា រួមទាំងប្រព័ន្ធនិងស្ថាប័នសង្គម ដែលបានស្ថាបនាឡើងអនុលោមតាមមតិ និងជំនឿផ្សេងៗ ផ្សាយចេញពីសាសនានេះ ។ មិនដូចសាសនាដទៃជាច្រើនទៀតទេ, លទ្ធិហិណ្ឌូ មិនមែនជាសាសនាមួយស្ថាបនាឡើងដោយបុគ្គលម្នាក់ ហើយដោយហេតុនេះ សាសនានេះ ពុំមានអ្នកស្ថាបនាពិតប្រាកដទេ, ឯប្រភពដើមនៃសាសនានេះ ក៏ពុំអាចកំណត់បានថាកើតមាននៅសម័យកាលណាដែរ ។ ដូចដែលមានសព្វថ្ងៃ, លទ្ធិហិណ្ឌូ គឺជាលទ្ធផលនៃដំណើរវិវត្តបន្តិចម្តងៗ តាមរយៈការយកមកធ្វើជារបស់ផងខ្លួន (The assimilation) នូវធាតុផ្សេងៗ របស់និកាយសាសនាដទៃ, ទស្សនវិជ្ជាឯទៀតៗ, មជ្ឈដ្ឋានវប្បធម៌ផ្សេងៗ, លក្ខខណ្ឌសង្គម-សេដ្ឋកិច្ច, ទំនៀមទម្លាប់, ស្ថាប័នសង្គមនានាឯទៀត . ល . ។ ដោយហេតុតែមិនដឹងសម័យកាលចាប់ផ្តើមពិតប្រាកដ, ដូច្នេះគេក៏ពុំអាចដឹងទីបញ្ចប់នៃលទ្ធិហិណ្ឌូនេះបានដែរ ។ ប្រហែលមកពីហេតុនេះហើយ ទើបគេសន្និដ្ឋានថា លទ្ធិហិណ្ឌូជា *សនាតនធម៌* : . ពោលគឺជាទ្រឹស្តីអមតៈ ( The perpetual doctrine ) ។

កាលណា គេត្រឡប់ទៅមើលការចាប់ផ្តើមនៃលទ្ធិហិណ្ឌូ, គេហាក់ដូចជាយល់ថា លទ្ធិហិណ្ឌូ មានលទ្ធិព្រាហ្មណ៍សម័យវេទជាស្នូល និងជាគ្រឹះរបស់ខ្លួន ។ វាច្បាស់ណាស់ថា លទ្ធិហិណ្ឌូ ទទួលយក និងទ្រទ្រង់នូវលក្ខណៈចម្បងទាំងអស់ដែលមាននៅក្នុងលទ្ធិព្រាហ្មណ៍ ។ ក្នុងចំណោមនេះ មានលក្ខណៈគ្រឹះពីរយ៉ាង ក) ការទទួលយកគម្ពីរវេទ ទុកជាស្រុតិដ៏ពិសិដ្ឋ (The devine revelation), និង

ខ) ការប្រតិបត្តិយ៉ាងតឹងរ៉ឹងតាមពាក្យប្រដៅទាក់ទងនឹងរចនាសម្ពន្ធសង្គម ដែលកត្តិជាការបែងចែកសង្គមជាបួន ដែលហៅថា វណ្ណធម៌ ។ ដូចគ្នានេះដែរ លទ្ធិហិណ្ឌូទ្រទ្រង់ទ្រឹស្តីទាក់ទងនឹងដំណាក់កាលបួននៃជីវិត ដែលហៅថា *អាស្រមធម៌* បើទោះបីបច្ចុប្បន្ននេះ ពុំសូវមានអ្នកប្រតិបត្តិតាមដោយម៉ត់ចត់ក៏ដោយ គេក៏ឃើញផងដែរថា លទ្ធិហិណ្ឌូប្រមូលយកអាទិទេពសំខាន់ៗភាគច្រើនអំពីសម័យវេទ ។ លទ្ធិហិណ្ឌូ ទទួលយកផងដែរនូវពិធីយញ្ញ ( យជ្ញៈ ) ទោះបីមានការកែសម្រួលខ្លះៗ ក៏ដោយ ។ គេបានចាត់ទុកការធ្វើពិធីយញ្ញនេះ ជាពិធីសាសនាដ៏សំខាន់ និងសក្តិសិទ្ធិ ។ និយាយជារួម ទម្រង់គោរពបូជាទាំងអស់ ដែលមាននៅក្នុងលទ្ធិហិណ្ឌូ, រួមទាំងការប្រៀនប្រដៅចរិយាធម៌, ទេវកថា, លោកធាតុវិទ្យា, ពិធីបុណ្យសាសនា, សកម្មភាពប្រតិបត្តិសាសនា មានប្រភពចេញមកពីលទ្ធិព្រាហ្មណ៍សម័យវេទ ។

លទ្ធិហិណ្ឌូជាប្រព័ន្ធទស្សនសាសនាមួយឋិតថេរ, រីកចំរើនក្នុងដំណាក់កាលផ្សេងៗ ចេញពីសម័យវេទ រហូតមកដល់សព្វថ្ងៃ, បានស្រូបយកដោយសេរី នូវជំនឿសាសនា, ទ្រឹស្តីទស្សនវិជ្ជា, ការប្រតិបត្តិ និងពិធីផ្សេងៗ ដែលមានក្នុងសាសនាដទៃ ។ ជំនឿសាសនា, ទ្រឹស្តីទស្សនវិជ្ជា, ការប្រតិបត្តិ និងពិធីខ្លះៗ បំពេញអោយគ្នាទៅវិញទៅមក និងខ្លះទៀត ប្រឆាំងគ្នាទៅវិញទៅមក ។ ដូច្នេះ គេឃើញនៅក្នុងលទ្ធិហិណ្ឌូ មានការនិយមរៀបចំពិធី (Ritualism), ការនិយមប្រកាន់ឋានៈអ្នកបួស (Sacerdotalism) ក៏ដូចជាការនិយមប្រព្រឹត្តតបៈ ( Ascétism ) និងការស្ទើងស្មាធិយោគៈ, អននុគុណនិយម (absolutism) ក៏ដូចជាអទេវនិយម (Atheism) ។ ចរិតបញ្ចុះជ្រុំនៃលទ្ធិហិណ្ឌូ គឺជាការធ្វើអោយទិដ្ឋភាពផ្សេងៗគ្នាទាំងអស់នោះ ឋិតនៅជាមួយគ្នាយ៉ាងសុខដុម ហាក់ដូចជាប្រព័ន្ធឯកភាពមួយ ។ ការនិយមបញ្ចូលធាតុផ្សេងៗទាំងអស់ជាមួយគ្នានៃលទ្ធិហិណ្ឌូនេះ បានរួមចំណែកយ៉ាងធំធេងដល់ឋាមភាព, ការដុះដាល និងនិរន្តរភាពនៃលទ្ធិនេះ ។

លទ្ធិហិណ្ឌូ គឺជា " អភិក្រម " បន្ត, ធំធាត់ជានិច្ច ហើយក៏ជាលទ្ធិចំរុះក្នុងពិធីដោះស្រាយ, មិនមែនជាសាសនាមួយបិទជិតដោយមានទ្រឹស្តីទាំងអស់របស់ខ្លួន មិនអាចកែប្រែបាននោះឡើយ ។ ហេតុនេះ នៅក្នុងលទ្ធិហិណ្ឌូ ពុំមានអញ្ញទិដ្ឋិ (Heresies) ; អ្វីទាំងអស់ ដែលលទ្ធិនេះស្រូបយកបាន ក៏ក្លាយទៅជាផ្នែករួមរបស់លទ្ធិនេះ ។ លក្ខណៈនេះ ត្រូវបានគេមើលឃើញនៅក្នុងទិដ្ឋភាពនីមួយៗ នៃលទ្ធិហិណ្ឌូ ។

ទស្សនវិជ្ជារបស់សាសនាហិណ្ឌូ គឺទស្សនវិជ្ជារបស់ឥណ្ឌាទាំងស្រុង ។ ទស្សនវិជ្ជានោះ ត្រូវបានស្រង់យកមកយ៉ាងសន្ធឹកសន្ធាប់ អំពីគម្ពីរ *ឧបនិស័ទ*, អំពី *ភគវ័ទគីតា* ក៏ដូចជា អំពីប្រព័ន្ធទស្សវិជ្ជា ( ឥណ្ឌា ) ទាំងប្រាំមួយ, ហើយធ្វើអោយទស្សនវិជ្ជាហិណ្ឌូនេះសម្បូរបែប ។ ជាឧទាហរណ៍, គេបានស្រង់យកតក្កវិជ្ជា និងវិទ្យាវិជ្ជា ( Epistemology ) អំពីទស្សនវិជ្ជាន្យាយៈ ។ សម្រាប់អស្សិរូបវិទ្យា (Metaphysics) គេបានដកស្រង់ចេញពីទស្សនវិជ្ជា វៃសេសិកៈ ។ គេបានដកស្រង់ចេញពីទស្សនវិជ្ជាសង្ខ្យានូវការប្រៀនប្រដៅទាក់ទងនឹងបុរុសៈ ( Spirit ) ហើយនិងប្រកូតិ ( កំលាំងបង្កើត ) ។ ឋានៈ ឬទីតាំដែលត្រូវផ្តល់អោយ *វេទៈ* ឬយជ្ញៈ នៅក្នុងលទ្ធិហិណ្ឌូ ត្រូវបានគេលើកតំកើង ដោយសារឥទ្ធិពលនៃ បូវិមិ-មាង្សៈ និងឧត្តរៈ-មិមាង្សៈ ។ យោគៈ នៅក្នុងលទ្ធិហិណ្ឌូ ត្រូវបានគេយកតាមទស្សនវិជ្ជាយោគៈ ។

លទ្ធិហិណ្ឌូបានធ្វើអោយទស្សនវិជ្ជារបស់ខ្លួនសម្បូរដោយការប្រមូលផ្តុំបញ្ចុះជ្រើនូវពាក្យប្រៀនប្រដៅរបស់ទស្សនវិទូឥណ្ឌាសម័យមធ្យម ដូចជាលោក សង្ករៈ, លោក រាមនុជៈ, លោក មាធវៈ, លោក វល្លភៈ និងទស្សនវិទូឯទៀតៗ ។ លទ្ធិហិណ្ឌូទទួលយកទស្សនៈ *អទ្វៃតវាទ* របស់លោក សង្ករៈ ដែលយល់ថាមានព្រហ្មន តែមួយគត់ដែលពិត, ចំណែកអាត្មន ( ព្រលឹងបុគ្គលម្នាក់ៗ ) ក៏ពុំផ្សេងៗគ្នា

ពីព្រហ្ម័ន្ន ដែរ ។ យោងតាមលោក សង្ករៈ , និគុំណព្រហ្ម័ន ( ពោលគឺតួអង្គគ្មានបុគ្គលភាព = The impersonal ) ប្រែក្លាយជាសគុណព្រហ្ម័ន ( តួអង្គមានបុគ្គលភាព = The personal ) តាមរយៈការជួបប្រទះជាមួយ *មាយា* ។ ដោយហេតុនេះ, និគុំណព្រហ្ម័នក្តី សគុណព្រហ្ម័នក្តី គឺជាព្រហ្ម័នតែមួយដដែល, គ្រាន់តែនិគុំណព្រហ្ម័ន ស្តែងឡើងជាអាទិទេពគ្មានបុគ្គលភាព ចំពោះពួកអ្នកទើបកាន់សាសនាថ្មីៗ, ហើយសគុណព្រហ្ម័ន ស្តែងឡើងជាអាទិទេពមានបុគ្គលភាពចំពោះអ្នកគោរពប្រតិបត្តិជាមធ្យម ។ ទស្សនះនេះ បានផ្តល់គ្រឹះទស្សនវិជ្ជា សម្រាប់កំណត់អត្តសញ្ញាណកម្ម នៃអាទិទេពគ្មានបុគ្គលភាព និងអាទិទេពមានបុគ្គលភាព នៅក្នុងលទ្ធិហិណ្ឌូ ។ ជំនឿក្នុងអាទិទេពមានបុគ្គលភាព ( the personal God ) បានទទួលការអភិវឌ្ឍន៍វែងឆ្ងាយ ក្រោមឥទ្ធិពលនៃពាក្យប្រៀនប្រដៅរបស់លោក រាមៈនុជះ ដែលបានផ្តល់សនិទានភាពអរូបិយ ( the metaphysic rationale ) សម្រាប់ចលនាភក្តិនៃលទ្ធិ វៃស្ណវៈ ។ ខុសពី អាទ្វៃតវាទៈ របស់លោក សង្ករៈ, វិសិស្តាទ្វៃតវាទៈ ( qualified monism ) ដែលបានវែកញែកនូវការប្លែកគ្នារវាងអាត្ម័នជាបុគ្គលម្នាក់ និងអាទិទេព, បានសង្កត់ធ្ងន់លើផ្លូវប្រតិបត្តិ ( ភក្តិមាគ៌ា ) និងសេចក្តីត្រូវការនូវការសន្តោសរបស់អាទិទេព ដើម្បីបានការសង្គ្រោះ នៅពេលទទួលយកទស្សនះនេះ លទ្ធិហិណ្ឌូ ក៏បានសម្របសម្រួល ទ្រឹស្តីនិយមរបស់លោកមាធវៈ ដែលបានធ្វើការវែកញែកយ៉ាងច្បាស់ " អត្យន្តភេទ " រវាងជីវៈ ( អាត្ម័ន ) ( ហើយនិងលោក ) និងអាទិទេព ។ ចលនាលទ្ធិ វៃស្ណវៈ ដែលឋិតនៅជុំវិញការបូជាចំពោះព្រះក្រឹស្ណះ, ហើយនិងចលនាលទ្ធិសៃវសិធាន្តៈ គឺជាផលវិបាកចេញមកពីការប្រៀនប្រដៅទាំងនោះ ។

នៅក្នុងដំណើរប្រមូលផ្តុំបញ្ចូះជ្រែនេះ លទ្ធិហិណ្ឌូបានសម្របសម្រួលទ្រឹស្តីទស្សនវិជ្ជារបស់លោក *និម្ពាករៈ* ដែលសង្កត់លើភាពផ្សេងគ្នា និងភាពមិន

ផ្សេងគ្នា ( ភេទាភេទៈ ) ក៏ដូចជាទ្រឹស្តី អទ្វៃតបរិសុទ្ធ ( pure monism ) របស់លោក វល្លភៈ ដែរ ។ ទ្រឹស្តីមួយប្រកាន់ថា ភាពផ្សេងគ្នា និងភាពមិនផ្សេងគ្នាទាំងពីរនេះគឺពិត ។ ដើម្បីពន្យល់បំភ្លឺទស្សនៈនេះ លោកនិម្ពាករៈ និយាយថា *ជីវៈ* ( អាត្មន ) ហើយនិង*លោកៈ* ផងដែរ គឺផ្សេងគ្នាពីព្រហ្មន ដោយសារ ជីវៈ និងលោកៈ មានធម្មជាតិ និងគុណសម្បត្តិផ្សេងគ្នាពីធម្មជាតិ និងគុណសម្បត្តិរបស់ព្រហ្មន ។ ប៉ុន្តែថា ធម្មជាតិ និងគុណសម្បត្តិទាំងនេះ មិនផ្សេងគ្នាទេវិញ ពិព្រោះធម្មជាតិ និងគុណសម្បត្តិទាំងពីរនេះ មិនអាចមានអត្ថិភាពដោយខ្លួនឯងបានទេ, ព្រោះហេតុនេះធាតុទាំងពីរនេះ ត្រូវពឹងផ្អែកលើព្រហ្មនទាំងស្រុង ។ លោក *វល្លភៈ* អះអាងថា ព្រហ្មន ក៏ដូចជាលោកៈទាំងមូលដែរ ដែលព្រហ្មនបានបង្កើតដោយអំណាចនៃឆន្ទៈព្រះអង្គ គឺ ពិត ។

ដំណើរសមីករណ៍ ( ការធ្វើអោយដូច ) និងដំណើរបញ្ចុះជ្រឹ កំពុងតែប្រព្រឹត្តទៅជាបន្ត ហើយអភិក្រមនេះ បានពន្យល់បកស្រាយ នូវអត្ថិភាពស្របគ្នានៃអនន្តគុណានិយម ( Absolution ) និងទេវនិយម ( theism ), នៃនិគុណព្រហ្មន និងសគុណព្រហ្មន ។ លទ្ធិហិណ្ឌូពន្យល់ថា គឺព្រហ្មនដដែល, អរូបវន្ត ( im-person ), អនន្តគុណ ( absolute ), ជាប្រភព *ពិតតែមួយគត់* នៃអ្វី១ទាំងអស់ ដែលកើតមាន, ជាអាទិទេពរូបវន្ត, មានសព្វានុភាព, មានសព្វវត្តមាន, មានសព្វញ្ញូណ កាលណាគេប្រមើលមើល ពីថ្នាក់ទាបដោយការប្រៀបធៀប ។ ព្រហ្មនគឺជាព្រះអម្ចាស់, អ្នកត្រួតត្រា, អ្នកគ្រប់គ្រង ដែលគេតែងថ្វាយព្រះនាមថា ជាឥស្វរៈ ឬភគវាន្តៈ ។

ជំនឿក្នុងព្រះអាទិទេព រូបវន្តតែមួយ, នៅពេលរីកចំរើនក្រោយមក, បានប្រែក្លាយទៅជាបញ្ញត្តិនៃត្រីមូរ្តិ (Trinity ) ដែលមានអាទិទេពរូបវន្តបីអង្គ គឺព្រះព្រហ្ម, ព្រះវិស្ណុ និងព្រះសិវៈ ។ លទ្ធិហិណ្ឌូបានពិពណ៌នាអាទិទេពទាំងបីអង្គ

នេះថា ជាអ្នកបង្កើត, អ្នកថែរក្សា និងអ្នកបំផ្លាញ ។ ក្នុងចំណោមព្រះទាំងបីអង្គនេះ ព្រះព្រហ្ម មិនសូវលេចមុខមាត់ទេ, ប្រហែលមកពីលោកគ្មានចរិតលក្ខណៈ ដែលនាំអោយកើតកើនឡើងនៃការបូជា ។ និកាយពីរដ៏មានសារសំខាន់ដូចគ្នា បានវិវត្តទៅជុំវិញអាទិទេពពីរផ្សេងទៀតគឺ ព្រះវិស្ណុ និងព្រះសិវៈ ហើយអាទិទេពទាំងពីរ បានក្លាយជាការនិយមថា វៃស្ណវៈ និងសៃវៈ ។

សកលភាពនៃលទ្ធិហិណ្ឌូ ជួយធ្វើអោយអ្នកជឿនៃនិកាយទាំងពីរនេះ ប្រកាន់ជឿថា អាទិទេពរបស់គេរៀងៗខ្លួន គឺជាអាទិទេពកំពូល, ទន្ទឹមនឹងទ្រទ្រង់ការគោរពកោតខ្លាចចំពោះអាទិទេពផ្សេងៗទៀត ។ អាទិទេពទាំងពីរនេះ ត្រូវគេចាត់ទុកថាពុំមានឋានៈជាបដិបក្ខនឹងគ្នាទេ, ប៉ុន្តែត្រូវគេប្រកាន់ជឿថា អាទិទេពទាំងពីរអង្គនេះ ជួយបំពេញអោយគ្នាទៅវិញទៅមក ។ វិស្ណុ និងសិវៈ ត្រូវបានគេស្គាល់ផងដែរថា ជាព្រះ *ហរិ-ហរៈ*, កំពុងបានក្លាយជាអាទិទេពដ៏សំខាន់ពីរអង្គ រួមចំណែកគ្នាទទួលនូវគោរពបូជាពីពួកហិណ្ឌូ ។ ក្នុងបណ្តាព្រះអាទិទេពពីរអង្គនេះ តាមពិតទៅ ការគោរពការបូជាចំពោះព្រះវិស្ណុ ត្រូវបានទទួលប្រជាប្រិយភាពជាង, ជាពិសេស ក្នុងរូបភាពរបស់ព្រះជាព្រះក្រឹស្ណៈ ។ ការរីកចំរើននេះ ត្រូវបានទ្រឹស្តី *អវតារ* ជួយសម្រួលយ៉ាងធំធេង ។ យោងតាមទ្រឹស្តីនេះ គេបាននិយាយថា ព្រះវិស្ណុបានអវតារមកកើតក្នុងរូបភាព ផ្សេងៗដោយយោលទៅតាមកាលៈទេសៈតម្រូវ ហើយមកនៅក្នុងលោកយើងនេះ ដើម្បីផ្ចាញ់អំពើអាក្រក់ ហើយស្ថាបនាអំពើល្អអោយឋិតថេរនៅ ។ ពួកហិណ្ឌូអ្នកកាន់និកាយវៃស្ណវៈ បានចាត់ទុកព្រះពុទ្ធអង្គថាជាអវតារមួយរបស់ព្រះវិស្ណុ(១) ។

(១) លោក R.C.Majumdar និយាយថា ទស្សនៈនេះគឺជា « ការវាយប្រហារខាងនយោបាយមួយគិតគូរយ៉ាងម៉ត់ចត់ និងដ៏ក្លាហាន ដែលកាត់ផ្តាច់ជើងព្រះពុទ្ធសាសនា ក្នុងពេលដែលព្រះពុទ្ធសាសនា កំពុងតែបាត់ទីតាំងស្រាប់ផងនោះ ហើយផលវិបាកចុងក្រោយ គឺពុទ្ធសាសនា ត្រូវបានលុបបំបាត់ទាំងស្រុងចេញពីប្រទេសឥណ្ឌា ក្នុងឋានៈជានិកាយសាសនាដោយឡែកមួយ » ។ Cultural History of India, 2nd Ed. Volume IV, Culcutta, 1956, p.48 ។

ក្នុងការអនុលោមអោយស្របតាមការរីកចំរើនខាងទស្សនវិជ្ជា និងទេវវិជ្ជាដែលយោងខាងលើ, លទ្ធិហិណ្ឌូបានប្រកាន់យកមាគ៌ាបីយ៉ាង ដើម្បីសិក្សាទេវអនន្តគុណអរូបវន្ត ( The Impersonal Absolute ) ឬទេវរូបវន្ត ( The Personal Divinity ) ។ មាគ៌ាទាំងបីយ៉ាងនោះគឺ ជ្ញានមាគ៌ា ឬ ជ្ញានយោគ ពោលគឺ មាគ៌ានៃចំណេះដឹង, គមិមាគ៌ា ( គមិយោគះ ) មាគ៌ានៃសកម្មភាព និងភក្តិមាគ៌ា ( ភក្តិយោគះ ) មាគ៌ានៃជំនឿ ។ គោលបំណងនៃជ្ញានមាគ៌ាគឺ ដើម្បីយល់ឯកភាពនៃអាត្មនបុគ្គលម្នាក់ៗ ដោយប្រៀបធៀបទៅនឹងមហា-អាត្មន, ជគ័ទ-អាត្មន ( the Absolute Universal soul ) ។ រីឯគមិមាគ៌ា គឺជាមាគ៌ានាំទៅរកគោលដៅតាមរយៈការបំពេញករណីយកិច្ចរបស់ខ្លួន ដោយឥតគិតពីប្រយោជន៍ផ្ទាល់ខ្លួនតាមបែបបទជាបរទត្តបុគ្គល, ពិព្រោះគេប្រកាន់ថា គឺការជាប់ជំពាក់ចិត្តចំពោះផលនៃការងាររបស់ខ្លួននេះហើយ ដែលចងក្រៀកបុគ្គលនៅក្នុងសេចក្តីទុក្ខ ។ ប៉ុន្តែក្នុងបណ្តាមាគ៌ាទាំងបី, មាគ៌ាដ៏ប្រជាប្រិយបំផុតគឺ ភក្តិមាគ៌ា ។ នេះគឺជាការប្រតិបត្តិដែលប្រគល់អាត្មាទាំងស្រុង ដើម្បីបានការអនុគ្រោះរបស់ព្រះអាទិទេព មានភក្តិ-ភាពជាប្រចាំចំពោះព្រះអាទិទេព និងមានអារម្មណ៍ជក់ជាប់ព្រះអាទិទេពជានិច្ច, ថ្វាយសេចក្តីស្រឡាញ់ ដ៏បរិសុទ្ធ និងថ្វាយខ្លួនទាំងស្រុងចំពោះព្រះអាទិទេព ។

នៅខាងក្រោមមាគ៌ាទាំងបីយ៉ាង គឺមានក្រមចរិយាធម៌របស់ពួកហិណ្ឌូដែលជានិយាម សម្រាប់ការប្រព្រឹត្តដោយផ្អែកលើ *ធមិះ* ដូចដែលគេបានបង្កើតឡើងនៅក្នុងលទ្ធិហិណ្ឌូ ។ ការប្រៀនប្រដៅចរិយាធម៌របស់លទ្ធិហិណ្ឌូ មានចំណងយ៉ាងជិតស្និទ្ធជាមួយជំនឿ ក្នុង *កមិះ* និង *ការកើតជាថ្មី*(១) ។ ជំនឿនេះ ពន្យល់ថា

(១) នៅក្នុងពុទ្ធសាសនា ក៏មានការប្រៀនប្រដៅដូចគ្នាដែរ ។ ប៉ុន្តែ ចរិយាធម៌ ក៏ដូចជាទ្រឹស្តីអំពីកម្មះ និងការកើតទៀតនៅក្នុងពុទ្ធសាសនា ផ្សេងគ្នាយ៉ាងច្រើនអំពីកមិះ និងការកើតទៀត នៅក្នុងលទ្ធិហិណ្ឌូ ។

វាសនារបស់បុគ្គលម្នាក់ៗនៅក្នុងជាតិក្រោយ ត្រូវបានកំណត់ដោយអំពើរបស់ខ្លួននៅក្នុងជាតិនេះ គោលការណ៍ទូទៅដែលអនុវត្ត គឺថា អំពើល្អនាំអោយកំណើតថ្មីទៀតនៅក្នុងស្ថានភាពល្អ ហើយអំពើអាក្រក់នាំអោយកើតទៀតនៅក្នុងស្ថានភាពអាក្រក់ ។ *អហិង្សា* ( ការមិនរំលោភបំពាន ), *សត្យៈ* ( សច្ចធម៌ ), *ឥន្ទ្រីយនិគ្រហៈ* ( ការគ្រប់គ្រងឥន្ទ្រីយបានល្អ ), *ទានៈ* ( ការអោយ ), *អស្តេយៈ* ( ការវៀរចាកអំពើលួច-ប្លន់ ), *វិសយត្យាគៈ* ( ការលះបង់ ), ទយា ( មេត្តា ), *អាជិវៈ* ( ភាពត្រឹមត្រូវតាមគន្លងធម៌ ), *សៅចៈ* ( ភាពបរិសុទ្ធ, ការវៀរចាកអំពើអកុសល ), *ក្សមា* ( ភាពអំណត់ចំពោះមុខការលំបាក ) គឺជាគុណសម្បត្តិមួយចំនួននៃចរិយាធម៌ដែលគេមានជំនឿខ្ពស់នៅក្នុងលទ្ធិហិណ្ឌូ[១] ។ ការបណ្តុះបណ្តាលអោយកើត *ស្រាទ្ធា* ( ជំនឿ ), ហើយនិងការប្រព្រឹត្ត *តបៈ* ( ការបួសជាតាបស ) ទាំងពីរនេះត្រូវបានគេអោយតម្លៃណាស់ ។ ចរិយាធម៌របស់ហិណ្ឌូទាំងមូល ត្រូវបានគ្របដណ្តប់ដោយស័ព្ទ *ធម៌ៈ* ។ គោលបំណង និងវត្ថុបំណងនៃសីលធម៌ហិណ្ឌូ គឺធ្វើអោយអ្នកជឿចេះដឹកនាំជីវិតក្នុងការបំពេញករណីយកិច្ច ( ធម៌ៈ ) ។ គេបានបង្រៀននៅក្នុងលទ្ធិហិណ្ឌូថា ការបណ្តុះអោយកើតសីលធម៌ គឺជាលក្ខខ័ណ្ឌដំបូងមួយ ដើម្បីទម្លុះទម្លាយស្បៃអវិជ្ជា (មាយា) ។ ចំពោះជនហិណ្ឌូ, ជីវិតបំពេញករណីយកិច្ច គឺប្រព្រឹត្តទៅមិនមែនសម្រាប់តែអត្តប្រយោជន៍ ចេះដឹកនាំជីវិតបំពេញករណីយកិច្ចសុទ្ធសាធនោះទេ, ប៉ុន្តែ តាមការជាក់ស្តែង គឺសម្រាប់ព្រះអាទិទេព ផងទៀត ។ ដោយហេតុនេះ, ការមិនយកចិត្ត ទុកដាក់បំពេញករណីយកិច្ច (ធម៌) គឺជាការប្រឆាំងនឹងបន្ទូលរបស់ព្រះអាទិទេព, ដែលគេចាត់ទុកអំពើនេះ ជាបាប ។

---

(១) បញ្ញត្តិ និងសិក្ខាបទចរិយាធម៌ជាមូលដ្ឋាន គឺមានដូចគ្នាទាំងនៅក្នុងលទ្ធិហិណ្ឌូ ទាំងនៅក្នុងពុទ្ធសាសនា ។ ប៉ុន្តែ វត្ថុបំណងក៏ដូចជាមាគ៌ាដែលនាំទៅដល់ឧត្តមគតិចរិយាធម៌ទាំងនោះ មានការខុសគ្នាយ៉ាងខ្លាំងនៅក្នុងប្រព័ន្ធទាំងពីរនេះ ។

លក្ខណៈលេចធ្លោនៃទស្សនវិជ្ជាសង្គមរបស់លទ្ធិហិណ្ឌូគឺ *វណ៌ាស្រមៈធមិ* ដែលទាក់ទងនឹងចំណាត់ថ្នាក់នៃសមាជិកសង្គមទៅជាបួនស្រទាប់ ( វណ្ណធមិ ) ហើយនឹងការបែងចែកជីវិតរបស់បុគ្គលម្នាក់ៗ ជាបួនដំណាក់ ( អាស្រមធមិ ) ។ ប្រភពនៃទ្រឹស្តីនេះ ត្រូវបានគេឃើញដានចេញមកពីគម្ពីរ *វេទ* ។ គម្ពីរ *បុរុសសូក្តៈ* នៃ*មណ្ឌល* ទីដប់របស់ឫគវេទ ក៏បាននិយាយយោងដល់ការបែងចែកមនុស្សក្នុងសង្គមជាបួនយ៉ាងដែរ ។ នេះគឺជាច្បាប់របស់អាទិទេព, ដោយហេតុនេះ, ពុំអាចត្រូវគេបំពារបំពានបានឡើយ ។ នៅក្នុងលទ្ធិហិណ្ឌូក្រោយៗមកទៀត, ចំណាត់ថ្នាក់មនុស្សជាបួនវណ្ណៈនេះ ត្រូវបានគេបកស្រាយតាមបែបផ្សេង ។ គេនិយាយថា មនុស្សទាំងអស់អាចត្រូវបានគេចែកជាប្រភេទបានបីបែប យោងទៅតាមលក្ខណៈសម្បត្តិនៅក្នុងមនុស្សទាំងនោះ ។ អ្នកទាំងឡាយណា មានបរិសុទ្ធភាព ( សត្វ ) ខ្លាំងជាង ត្រូវបានគេនិយាយថា គឺជាព្រាហ្មណៈ ។ ក្សត្រិយៈ គឺជាអ្នកទាំង ឡាយណាដែលមានកិរិតលោកិយភាព (រាជៈ) ខ្ពស់, ចំណែកឯវៃស្យៈមានអន្ធការភាព (តមះ) ទុកជាលក្ខណសម្បត្តិគ្របដណ្តប់ ។ មនុស្សទាំងអស់ផ្សេងទៀត ដែលគ្មានលក្ខណៈសម្បត្តិលេចធ្លោនោះ ត្រូវបានគេប្រមូលផ្តុំដាក់នៅក្នុងប្រភេទមួយទូលំទូលាយមានឈ្មោះថា សូទ្រៈ ដែលត្រូវបែងចែកបន្ថមកទៀតជា សមាជិកមួយនៃវណ្ណៈ ។ នេះគឺជាការរៀបចំឋានានុក្រមមួយ ដែលនៅពីលើកំពូលឋានានុក្រម គឺពួកព្រាហ្មណ៍ ហើយនៅឯខាងបាតឋានុក្រម គឺពួកសូទ្រៈ ។ គេទទួលស្គាល់ផងដែរ នៅក្នុងលទ្ធិហិណ្ឌូថា គឺគុណសម្បត្តិលេចធ្លោទាំងនោះហើយ ដែលអោយកំណើតដល់ចរិត, សម្បទា និងវិជ្ជាជីវៈផងដែរ ដល់បុគ្គលម្នាក់ៗ ។ បុគ្គលណាមួយក្លាយទៅជាមានគុណសម្បត្តិលេចធ្លោទាំងនោះដោយសារកំណើត, ហើយចាប់ពីនោះតទៅ, កំណើតបានក្លាយទៅជាកត្តាសំរេចមួយនៃឋានៈសង្គមរបស់គេ [១] ។

(១) ពុទ្ធសាសនាទាត់ចោលទាំងស្រុងនូវឋានៈនេះ ហើយប្រកាន់ថា ឋានៈសង្គមរបស់បុគ្គល ➡

ដំណាក់កាលទាំងបួននៅក្នុងជីវិត ( អាស្រមធម៌ ) គឺ *ព្រហ្មចរិយៈ* ( ភាពជាសិស្ស ឬ និស្សិត ), *គ្រហស្ថ* ( ភាពជាអ្នកនៅគ្រប់គ្រងផ្ទះ ), *វានប្រស្ថ* ( ជាអ្នកបួស ឬជាតាបស ), និង *សន្យាសិន* ( ជាអ្នកលះបង់ជ្រះស្រឡះ ) ។

លទ្ធិហិណ្ឌូទទួលយកឧត្តមគតិ ឬវត្ថុបំណងបួនយ៉ាងនៃជីវិតផងដែរ ដែលអោយឈ្មោះថា *បុរុសាថៈ* ។ *បុរុសាថ* ទាំងបួនយ៉ាងនោះគឺ *ធម៌ៈ* (ការបំពេញត្រឹមត្រូវនូវករណីយកិច្ចរបស់ខ្លួន), *អថ* (ការធានារ៉ាប់រងនូវសុខុមាលភាពសេដ្ឋកិច្ចរបស់ខ្លួន), *កាមៈ* (ការសេពសោយនូវសេចក្តីសប្បាយលោកិយ), និង*មោក្សៈ* (ការសំរេចបាននូវការរំដោះ) ។ ការបំពេញបាននូវឧត្តមគតិទាំងនេះដោយជោគជ័យ ត្រូវបានគេចាត់ថាជាគោលបំណងនៃជីវិត(*) ។

ជីវិតប្រចាំថ្ងៃរបស់ជនហិណ្ឌូម្នាក់ៗ គឺពោរពេញដោយពិធីបុណ្យសាសនាអធិកអធម និងសកម្មភាពគោរពបូជាយ៉ាងច្រើនក្នុងផ្នែកសាសនា ហើយនឹងពិធីបួងសួងប្រសិទ្ធិ, ភាគច្រើននៃពិធី និងសកម្មភាពទាំងអស់កើតមានមកពីសម័យវេទ ។ ពិធី និងសកម្មភាពខ្លះ ក្នុងចំណោមពិធី និងសកម្មភាពទាំងនោះ គឺជាកាតព្វកិច្ចឬជាការតម្រូវ ( និត្យៈ ), ខ្លះទៀត គឺធ្វើតាមការជ្រើសរើស ឬការចូលចិត្ត (កាម្យៈ) ។ ប៉ុន្តែ នៅពេលបច្ចុប្បន្ន នៅមានតែពិធី និងសកម្មភាពសាសនា មួយចំនួនប៉ុណ្ណោះ

---

←

ណាមួយត្រូវបានគេវិនិច្ឆ័យ មិនមែនដោយសារកំណើតរបស់បុគ្គលនោះទេ ប៉ុន្តែ ដោយសារចរិយាមារយាទ ឬ អំពើរបស់គេ ។

(*) ឧត្តមគតិប្រសើរបំផុតរបស់ពុទ្ធសាសនា គឺការសំរេចបាននូវព្រះនិព្វាន ។ ឧត្តមគតិដទៃទៀតទាំងអស់ គឺរណបក្រោមព្រះនិព្វាននេះទេ ។ ឧត្តមគតិទាំងនោះ គប្បីនាំឆ្ពោះទៅរកការសំរេចបាននូវព្រះនិព្វាន ។

ដែលបានមិតថេរ ។ ពិធីយញ្ញ[១] ( យជ្ញ ) មិនមានទៀតទេ, ប៉ុន្តែ ពិធីយញ្ញតូចតាច ដោយមានការកែសម្រួលដ៏ចាំបាច់ផងនោះ នៅមានអនុវត្តខ្លះដែរ ។ ឥឡូវនេះ ពិធីយញ្ញ ( យជ្ញ ) គឺធ្វើឡើងប្រហាក់ប្រហែលនឹងពិធីបូជាដែលគ្រាន់តែជាការថ្វាយគ្រឿងសក្ការៈប៉ុណ្ណោះ ។

ពិធីបួងសួង ឬប្រសិទ្ធិ ដែលគេហៅថាណៃមិត្តិកៈ ( Naimittikas ) ឬដែលគេធ្លាប់ហៅជាទូទៅថា *សំស្ការៈ* ( Samskaras ) បានដើរតួសំខាន់នៅក្នុងជីវភាពរបស់ជនហិណ្ឌូ ។ ពិធីបុណ្យអធិករអធមលាងបាប មានអត្ថន័យជាសង្គមផង សាសនាផង ហើយបង្កើតបានជាព្រឹត្តិការណ៍ដ៏មានសារសំខាន់នៅក្នុងជីវភាពរបស់បុគ្គលម្នាក់ៗ, ជាពិធីបុណ្យសាសនា និងជាតម្លៃបញ្ញាស្មារតី ដែលគេចង់បាន[២] ។

ដោយ **ឈន អៀម**

ផ្អែកលើអត្ថបទ : S K. Nanayakkara

Encyclopaedia of Buddhism

Vol. V, pp. 456 - 459. 1990

---

(១) ពិធីយញ្ញ ( យជ្ញ ) ដែលទាក់ទងដល់ការសម្លាប់ជីវិតមនុស្សសត្វ ត្រូវបានពុទ្ធសាសនាបដិសេធចោល ។ ចំពោះអាកប្បកិរិយារបស់ពុទ្ធសាសនាចំពោះការធ្វើពិធីបូជា, សូមអានកូដទន្តសូត្រ - សុត្តន្តបិដក, ទីឃនិកាយ ។ ទម្រង់ខ្លះនៃការបូជាក្នុងន័យថ្វាយបង្គំ និងថ្វាយគ្រឿងសក្ការៈ ចំពោះព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ - ល - ក៏មានសេចក្តីបញ្ជាក់នៅក្នុងពុទ្ធសាសនាដែរ ។

(២) នៅក្នុងពុទ្ធសាសនា ពុំមានពិធីអធិករអធមលាងបាបច្បាស់លាស់ទេ ។ ប៉ុន្តែ ការទទួលពរអំពីព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ត្រូវបានគេខិតខំស្វែងរក នៅក្នុងឱកាសសំខាន់ៗ ដែលទាក់ទងជីវិតរបស់គេម្នាក់ៗ ។

# ពាក្យរណ្ដំបរិវារស័ព្ទ
# ក្នុងភាសាអក្សរសិល្ប៍ខ្មែរ

បណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម
ព្រឹទ្ធសហការី បណ្ឌិត្យសភាវិទ្យាសាស្ត្រ
សហព័ន្ធរុស្ស៊ី ( វិទ្យាស្ថានបូព៌ាវិទ្យា )
សាស្ត្រាចារ្យសិលាចារឹកវិទ្យា និងភាសាវិទ្យា
នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ភាសានីមួយៗ តែងមានមរតកនៃឧបករណ៍ និងមធ្យោបាយរបស់ខ្លួនសម្រាប់សម្ដែងគំនិតចេញឱ្យបានរស់រវើក ។ ទាំងនេះគឺជាលទ្ធផលដែលសម្រេចចេញបានមកពីសហឥទ្ធិពលនៃកត្តាផ្សេងៗជាច្រើនក្នុងភាសា ។ បុគ្គលដែលនិពន្ធអក្សរសាស្ត្រ នៅពេលដែលគេជ្រើសរើសមធ្យោបាយភាសាមកប្រើប្រាស់ រមែងជាអ្នកតំណាងសង្គមមួយជាក់លាក់ នៅក្នុងសម័យកាលកំណត់មួយ ។

នៅក្នុងភាសាអក្សរសិល្ប៍ខ្មែរ ពាក្យរណ្ដំបរិវារស័ព្ទ ពិតជាឧបករណ៍នៃរចនាបថនិពន្ធមួយដ៏សំខាន់ ក្នុងចំណោមឧបករណ៍ នៃរចនាបថនិពន្ធទាំងឡាយដែលគេប្រើប្រាស់ ។ អ្នកនិពន្ធមួយចំនួន ប្រើប្រាស់ពាក្យរណ្ដំបរិវារស័ព្ទយ៉ាងទូលំទូលាយក្នុងគោលបំណងធ្វើឱ្យការបង្ហាញបុគ្គលិកលក្ខណៈតួអង្គរបស់ខ្លួន ឱ្យមានភាពស្រស់បំព្រងថែមទៀត ក្នុងនោះគេបានយកចិត្តទុកដាក់ពិសេស ទៅលើការចាប់យកស្នូរស័ព្ទ គឺថា គេយកចិត្តទុកដាក់ទៅលើការទទួលសំឡេងរណ្ដំប្រកបទៅដោយអត្ថន័យ ក្នុងការត្រងត្រាប់ចាប់យកសំឡេងដែលរណ្ដំគ្នាជាញឹកញាប់ គេសង្កេត

ឃើញថា ជាដំបូង វាមានលក្ខណៈនិម្មិត និងអត្ថនោម័តសុទ្ធសាធ ។ ដោយអនុលោមទៅតាមសង្វាក់ និងការចាប់ចុងចួនរបស់កំណាព្យ ។ ប៉ុន្តែ ពីកាលនេះតទៅអនាគតនឹងអាចទៅជាគ្រឹះសម្រាប់ការបង្កបង្កើតពាក្យ ដែលមានលក្ខណៈពេញលេញក្នុងភាសា ។

ដូច្នេះហើយបានជា គេចោទសំណួរមួយ អំពីតួនាទីនៃអត្ថរូប សូរសំឡេងក្នុងទស្សនៈនៃការវិភាគភាសាតាមបែបវចនស័ព្ទ និងរចនាបថនិពន្ធឡើងថា ៖ តើហ្វូណែម " សុទ្ធ " ទាំងឡាយ ដែលផ្ទួនក្នុងសមាសភាពនៃពាក្យរណ្តំសំនួនបរិវាស័ព្ទ អាចសំដែងនូវបញ្ញត្តិ ឬមនោសញ្ចេតនាណាកំណត់បានដែរឬទេ ?

សំណួរនេះ ធ្វើឱ្យភាសាវិទូនៃលោកខាងលិចមួយចំនួន ធ្វើចំណាប់អារម្មណ៍ខុសៗគ្នា ឧទាហរណ៍ ដូចជាលោក ស. បាលី ( Charles Bailly ) ចាត់ទុកថា " មានការភ័ន្តច្រឡំខ្លះៗ ទៅលើបំណកស្រាយស្តីពីផលនៃការព្រាប់សូរស័ព្ទរបស់សំឡេងនឹងពាក្យជាក់លាក់មួយ ។ នេះគឺជាការភ័ន្តច្រឡំមួយសុទ្ធសាធ ៖ ន័យរបស់ពាក្យធ្វើឱ្យយើងមានការផ្តោតអារម្មណ៍ទៅលើវា ព្រមជាមួយនឹងលទ្ធផលនៃសំឡេង " ( ៥.៥៤ ) ។

ចំណែកលោក ម. ក្រែស្សូ ( Marcel Cressot ) បានយល់ផ្ទុយពីលោក Bailly គឺគាត់ទទួលស្គាល់ថា សំឡេងមានទំនាក់ទំនងទៅនឹងអត្ថន័យនៃភាសា ( ៦.៣ ) ។ តាមមតិរបស់លោក សំឡេងជាក់លាក់មួយដែលស្ថិតនៅក្នុងសំណុំសូរស័ព្ទនានា អាចបង្កើតឱ្យមាននូវរូបារម្មណ៍ក្នុងសោតវិញ្ញាណ ចក្ខុវិញ្ញាណ ព្រមទាំងកាយវិញ្ញាណផង ។ ទស្សនៈរបស់លោក Cressot នេះ អាចបញ្ជាក់បានដោយកត្តានានាមានក្នុងភាសាខ្មែរ ។ យើងជឿជាក់ថា ពេលដែលគេអាន ឬស្តាប់ពាក្យរណ្តំបរិវារស័ព្ទ អ្នកដែលអានភាសាខ្មែរជាភាសាកំណើត តែងទទួលវេទនារម្មណ៍មួយរួចទៅហើយ មុនពេលដែលគេយល់វចនន័យរបស់ពាក្យ ។

ពាក្យរណ្តំបរិវារស័ព្ទ តែងកើតមានក្នុងគ្រប់ភាសាក្នុងលោកនេះ ។ នៅក្នុងភាសាខ្មែរ ក៏ដូចជាក្នុងភាសាដទៃទៀតដែលស្ថិតក្នុងចំណាត់ថ្នាក់ថា មានរចនាសម្ព័ន្ធស្រដៀងគ្នាទ្វេនីយកម្ម គឺវិធីរណ្តំស័ព្ទ ( redoublement ) មានតួនាទីសំខាន់ក្នុងការបង្កើតពាក្យ ។ តែការបង្កើតពាក្យតាមបែបទ្វេនីយកម្មក្នុងភាសាមានច្រើនសណ្ឋាន និងមានលក្ខណៈពិសេស ព្រមទាំងពិបាកស្មុគស្មាញទៀតផង ។ បាតុភូតជាច្រើនក្នុងចលនានៃកំណាកំណើតបរិវារស័ព្ទក្នុងភាសាខ្មែរ រហូតបច្ចុប្បន្នកាលនេះ គេមិនទាន់ស្រាវជ្រាវឱ្យជ្រាលជ្រៅនៅឡើយទេ ។ ចំណែកឯន័យរបស់ពាក្យរណ្តំបរិវារស័ព្ទ មានគេរក្សាតិចតួចនៅឡើយ ។ គឺក្នុងករណីនេះហើយដែលធ្វើឱ្យការវិភាគពិសេសរបស់យើងនៅពេលនេះ ទៅលើពាក្យរណ្តំបរិវារស័ព្ទខ្មែរ មានសារសំខាន់ ។ យើងយល់ថា បញ្ហាពាក្យរណ្តំបរិវារស័ព្ទក្នុងភាសាខ្មែរ គឺជាបញ្ហារចនស័ព្ទវិទ្យាមួយសំខាន់ ។

យើងសូមពណ៌នាត្រួសៗ អំពីប្រវត្តិនៃបញ្ហានេះ ។ លោក ហ្ស. ម៉ាស្ប៉េរ៉ូ បានចែកពាក្យរណ្តំបរិវារស័ព្ទ ជាពីរប្រភេទ ៖

១. ពាក្យរណ្តំបរិវារស័ព្ទដែលកើតមកពីទ្វេនីយកម្មទ្បេងទាត់នៃព្យញ្ជនៈដើមពាក្យ ជាមួយនឹងស្រះ ( អ ) ឬ ( អ៊ ) ។

ឧទាហរណ៍ ៖

- កាយ > កកាយ ( > អ.ឫ. ជា )
- លក់ > លលក់
- ទះ > ទទះ
- លើ > លលើ
- ល្វក > លល្វក

២. ពាក្យរណ្តំបរិវារស័ព្ទ ដែលកើតឡើងដោយធាតុពីរ ដែលក្នុងនោះ

ធាតុមួយ មានវចននីយរបស់ខ្លួន និងធាតុមួយទៀត ឬមួយជាវេវចនស័ព្ទរបស់ធាតុទីមួយ ឬមួយជាវិធីរណ្ដំនៃស្វរស័ព្ទ ដែលគេមិនប្រើប្រាស់ដាច់ដោយឡែកតែឯកឯងក្នុងភាសា នាបច្ចុប្បន្នកាល ។

ឧទាហរណ៍ :

- ប្រើប្រាស់ ; ផ្សព្វផ្សាយ ; ឆ្លើយឆ្លង ;
- ខ្ចាត់ខ្ចាយ ; រាវែក ; រុងរឿង ;

លោក ហ្ស. ម៉ាស្ល្វេ៉ មិនបានសិក្សាគ្រប់ទិដ្ឋភាពនៃទ្វេនីយកម្មទេ ។ ចំពោះបញ្ហានៃការប្រើប្រាស់ពាក្យរណ្ដំបរិវារស័ព្ទវិញ លោកបានបង្ហាញត្រឹមកត្តាមួយថា ពាក្យបែបនេះ គឺជាឧបករណ៍មួយ សម្រាប់បង្កើតសំនួនសេចក្ដីដែលមានចុងចួន ( កម្រងកែវ ) ដែលគេប្រើប្រាស់ក្នុងសំដីរបស់វាគ្មិន ឬក្នុងចម្រៀងសម្ពស្សសៀវភៅមហាវេស្សន្តរ ស្ថិតនៅលើការប្រើប្រាស់ពាក្យរណ្ដំបរិវារស័ព្ទដ៏បរិបូរ ដោយអ្នកនិពន្ធ ញ៉ុក ថែម ។

លោកស្រី សាវរស ពៅ បានបន្តគំនិតរបស់លោក ហ្ស. ម៉ាស្ល្វេ៉ ។ លោកស្រីបានបញ្ជាក់ថា ពាក្យរណ្ដំបរិវារស័ព្ទ គឺជាឯកតាមួយដែលកើតឡើងដោយសេរីនៅក្នុងសកម្មភាពនៃសំដី ហើយនៅក្នុងនោះ ពាក្យនីមួយៗសុទ្ធសឹងអាចមានទ្វេនីយកម្ម ។ ទាំងនេះគឺថាបណ្ដាលមកពីមូលហេតុមួយគឺ ក្នុងវចនានុក្រមមានពាក្យដែលកើតឡើងដោយទ្វេនីយកម្ម (១០.៧០) ។ គួរកត់សម្គាល់ថា ថ្វីត្បិតពាក្យរណ្ដំបរិវារស័ព្ទមានច្រើនពាសពេញក្នុងភាសាមហាជន និងក្នុងរឿងប្រលោមលោកក៏ដោយ ក៏នៅក្នុងការប្រើប្រាស់ពាក្យរណ្ដំបរិវារស័ព្ទ គេសង្កេតឃើញមានក្រឹត្យក្រម ដូចតទៅ :

- អ្នកប្រើប្រាស់ពាក្យរណ្ដំបរិវារស័ព្ទ គឺជាជនម្ចាស់ភាសា ដែលទទួលការអប់រំ និងមានចំណាស់គួរសម ព្រមទាំងមានកំរិតយល់ដឹងខ្ពស់អំពីការប្រើប្រាស់

ឧបករណ៍នៃភាសា ។ ភាសាដែលសំបូរទៅដោយពាក្យរណ្ដំបរិវារស័ព្ទ គឺភាសារបស់មនុស្សចំណាស់ៗ ជាពិសេស អ្នកដែលចេះដឹង និងមានការពិសោធន៍ក្នុងជីវភាពរស់នៅ ។

តាមការសង្កេតរបស់យើង មិនមែនពាក្យទាំងអស់ទេ ដែលអាចមានលទ្ធភាពធ្វើទ្វេនីយកម្ម ។ ក្របខ័ណ្ឌនៃការកម្រិតនេះ គឺមានការទាក់ទងទៅនឹងនាម និងពាក្យដទៃទៀតជាច្រើនផងដែរ ។ រីឯពាក្យដែលមានលទ្ធភាពជាអតិបរមាក្នុងទ្វេនីយកម្ម គឺ គុណនាម កិរិយាស័ព្ទ និងកិរិយាវិសេស " គុណកិរិយា " ។

នៅក្នុងវចនានុក្រមធំៗ ជាមូលដ្ឋាន ដូចជា វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន ណាត (៤) និង ហ្គេស ដុង (៧) ( J. Guesdon ) គេសង្កេតឃើញសំនួនបរិវារស័ព្ទមួយចំនួនធំ ដែលគេឧស្សាហ៍ប្រើប្រាស់ក្នុងភាសា ។

ឧទាហរណ៍ ៖ នៅក្នុងវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត មានពាក្យរណ្ដំបរិវារស័ព្ទប្រហែល ១.៥០០ ។

លោក យូរី ហ្គរហ្គោញីយ៉ែវ បានធ្វើការសិក្សាទៅលើពាក្យរណ្ដំបរិវារ-ស័ព្ទក្នុងភាសាខ្មែរដែរ (១.៧១-៨៧) ។ លោកបានយកចិត្តទុកដាក់ទៅលើវចនាសម្ព័ន្ធ និងចលនាការក្នុងការបង្កើត ព្រមទាំងលក្ខណៈពិសេសនៃការប្រើប្រាស់ ។ អំពីវចនាសម្ពន្ធទ្វេនីយកម្ម យើងបានសិក្សារួចហើយ (២) ហេតុដូច្នេះហើយបានជាពេលនេះយើងមិនលើកយកមកសិក្សាទៀតទេ ។

ក្នុងអត្ថបទនេះ យើងនឹងបង្ហាញជូនអំពីការប្រើប្រាស់ពាក្យរណ្ដំបរិវារ-ស័ព្ទនៅក្នុងស្នាដៃអក្សរសិល្ប៍ច្រើនប្រភេទ អំពីន័យដែលកើតឡើង មកពីពាក្យរណ្ដំបរិវារស័ព្ទ អំពីបញ្ហា ថាតើពាក្យរណ្ដំបរិវារស័ព្ទត្រាប់តាមសូរស័ព្ទ និងបែបបទនៃការសំដែងដោយច្រើនសំឡេង កកើតឡើងយ៉ាងដូចម្ដេច និងបញ្ហា ថាតើវាមានលំនាំនៃអត្ថន័យ ( nuance ) យ៉ាងណា ខុសពីពាក្យធម្មតា ។

# ពាក្យរណ្ដំបរិវារស័ព្ទនៅក្នុងភាសាអក្សរសិល្ប៍

ដើម្បីបង្ហាញតួនាទីរបស់រណ្ដំបរិវារស័ព្ទក្នុងអក្សរសិល្ប៍ឱ្យកាន់តែច្បាស់ យើងនឹងធ្វើការវិភាគទៅលើការប្រើប្រាស់របស់វា នៅក្នុងភាសានៃស្នាដៃអក្សរ-សិល្ប៍សំខាន់ៗ ទៅតាមសម័យកាល ហើយនឹងធ្វើការសង្កេតផងដែរ ទៅលើការវិវត្តន៍នៃបាតុភូតទ្វេនិយកម្ម និងការប្រើពាក្យរណ្ដំបរិវារស័ព្ទជាឧបករណ៍សម្រាប់លំអចនាបថនិពន្ធរបស់កវី និងអ្នកនិពន្ធស្នាដៃពាក្យកម្រងកែវ និងពាក្យរាយ ។ ស្នាដៃអក្សរសិល្ប៍គ្រប់សម័យកាលជាសក្ខីភាព បង្ហាញឱ្យយើងដឹងនូវការយកចិត្តទុកដាក់ទៅលើការប្រើប្រាស់ពាក្យរណ្ដំបរិវារស័ព្ទ ដែលជាប្រភពមិនរីងស្ងួតសម្រាប់ការកកើតឧបករណ៍រចនាបថពិពន្ធ ។

វីរកថា " រាមកេរ្តិ៍ " ដែលសរសេរឡើងជាភាសាខ្មែរបុរាណ គឺជាកម្មវត្ថុសិក្សាមួយគួរឱ្យចាប់អារម្មណ៍ សម្រាប់ការស្រាវជ្រាវភាសាក្នុងសម័យនោះប្រហាក់ប្រហែលជាក្នុងសតវត្សទី ១៥ - ១៦ ( ១១ ) ។ គួរកត់សំគាល់ភ្លាមថាក្នុងគ្រប់ទំព័រ គ្រប់បន្ទាត់នៃស្នាដៃនេះ គេប្រទះឃើញពាក្យរណ្ដំបរិវារស័ព្ទក្នុងការពិពណ៌នាផ្សេងៗ " អំពីលក្ខណៈ, ទេសភាព, សមរភូមិប្រយុទ្ធ, រូបរាង " ។ ការប្រើប្រាស់ដ៏ទូលំទូលាយនូវពាក្យរណ្ដំបរិវារស័ព្ទក្នុងស្នាដៃនេះ បញ្ជាក់ឱ្យយើងឃើញថា នៅសតវត្សទី ១៦ ទ្វេនិយកម្ម គឺជាមធ្យោបាយបង្កើតពាក្យថ្មីមួយ ដែលគេនិយមច្រើនជាងបច្ចុប្បន្នកាល ។

ក្នុងយុគសម័យកណ្ដាល " សតវត្សទី ១៦ - ទី ២១ " គេសង្កេតឃើញមានឥទ្ធិពលទៅមករវាងភាសាខ្មែរ និងភាសាថៃ ជាពិសេស ក្នុងវិស័យវចនស័ព្ទ ។ ម្យ៉ាងទៀត ភាសាទាំងពីរនេះ បានទទួលឥទ្ធិពលពីភាសាបាលី តាំងពីពុទ្ធសាសនាហីនយានបានចូលមក ឥទ្ធិពលនៃភាសាសំស្ក្រឹត ភាសាបាលី និងភាសាថៃ បានជ្រួតជ្រាបចូលដល់គ្រប់ស្រទាប់នៃវចនស័ព្ទខ្មែរ ។ ភាគច្រើននៃពាក្យដែលបានកកើត

មានទម្រង់ប្រហាក់ប្រហែលនឹងពាក្យរណ្ដំបរិវារស័ព្ទ ហើយក្នុងសមាសភាពរបស់វា ទន្ទឹមនឹងធាតុផ្សំដែលជាពាក្យខ្មែរ គេសង្កេតឃើញមានធាតុផ្សំ ជាពាក្យដែលមានដើមកំណើតពីភាសាទាំងបីខាងលើនេះផងដែរ ។

ក្នុងស្នាដៃដទៃទៀត ដូចជា " សេកសារិកា, កាកី និងទុំទាវ " ក៏គេសង្កេតឃើញមានការប្រើប្រាស់ពាក្យរណ្ដំបរិវារស័ព្ទញឹកញាប់ដែរ ។ សូម្បីតែចំណងជើងនៃស្នាដៃទាំងនេះ ក៏ជាពាក្យរណ្ដំបរិវារស័ព្ទដែរ ។ ក្នុងចំណោមឧបករណ៍សម្រាប់ពណ៌នា ដែលបង្កើតសម្រាប់រចនាបថនិពន្ធទាំងនេះ គេសង្កេតឃើញមានការចួនព្យញ្ជនៈ, ស្រៈ និងចួនព្យាង្គ ។ ជួនកាល អ្នកនិពន្ធបានប្រើប្រាស់ជាអតិបរមានៃសង្វាក់ និងពាក្យរណ្ដំបរិវារស័ព្ទ ដែលជួនកាលអាចធ្វើឱ្យខូចឡូស៊ិចខ្លះ ក្នុងការសំដែងគំនិត ក៏ព្រោះតែគេចង់បំផុសឱ្យមានសន្ទុះនៃមនោសញ្ចេតនាខ្ពស់ ។ ការនិយមប្រើពាក្យរណ្ដំបរិវារស័ព្ទលេចធ្លោជាងគេ មាននៅក្នុងការពណ៌នាធម្មជាតិ ។ ជាញឹកញាប់ ក្នុងការចាប់ចុងចួន អ្នកនិពន្ធបានបង្កើតពាក្យ " ផ្ទាល់ខ្លួន " ដោយភ្ជាប់ព្យាង្គថ្មីទៅនឹងពាក្យដែលកើតមានរួចមកហើយ ។ ព្យាង្គថ្មីដែលគេបង្កើតឡើង មិននៅស្ងាប់នឹងកន្លែងទេ ព្រោះវាបានទទួលន័យដំណូចខ្លះក្នុងទីសេចក្ដីនៃអត្ថបទ " Contexte " ។ ព្យាង្គទាំងនេះ អាចមានទម្រង់ច្បាស់លាស់ នឹងក្លាយទៅជាពាក្យពេញលក្ខណៈ ។

ឧទាហរណ៍ ៖

១. ថាហើយសារិកាកែវ បែបបែរបៀងឈ្មងឈ្មៀង មៀងមើលសេកពីឆ្ងាយ " សេកសារិកា " ។ ដូច្នេះ ព្យាង្គ ឈ្មងឈ្មៀង មៀង មានន័យមិនច្បាស់លាស់ទេ ក៏ប៉ុន្តែ ព្យាង្គទាំងនេះអាចផ្ដល់នូវបំរែបំរួលន័យផ្សេងៗនៃកិរិយាស័ព្ទ " មើល " គឺថា មៀងមើល - មើលពីចំហៀង, ឈ្មៀងមៀងមើល - មើលពីទីខ្ពស់, ឈ្មងឈ្មៀងមៀលមើល - មើលដោយក្ដីមោទនភាព ។

២. ទុក្ខម្នោទោម្នេញ ក្អាញ់ឆុលឆាវ កន្ត្រាក់បានដាវ ស្ទុះចូលជុំ ចូលចាប់ កាប់ចាក់ឥតជំនុំ ចងរុំក្រញើតស្ញើតស្លាបសេក ( ទុំទាវ ៨៣ ) ។ ក្នុងវគ្គនេះ ពាក្យ "ម្នោម្នេញ " ច្បាស់ជាមិនទទួលសម្រស់ទេ ប្រសិនបើធាតុផ្សំរបស់វាមិនស្ថិតក្នុង រង្វង់ពាក្យមួយចំនួនដែលផ្ដើមដោយព្យញ្ជនៈក្រអូម ( ច ) ដែលបង្កើតនូវសម្រស់ ក្នុងការពណ៌នាឆាកសកម្មភាពដែលគេប្រហារទុំ ៖ ឆុលឆាវ, ចូលជុំ, ចាប់, ចង, ចាក់ ។

៣. " កេងកងត្រយ៉ងក្រូចក្រសា ទទាវទទះស្លាបហើរឆ្លង " ( សេក សារិកា ៣០ ) ក្នុងឧទាហរណ៍នេះ យើងសង្កេតឃើញមានពាក្យបរិវារស័ព្ទបួន ។

យើងសង្កេតឃើញថា ក្នុងករណីជាច្រើន អ្នកនិពន្ធចូលចិត្តប្រើទម្រង់ ទ្វេរបស់ពាក្យដែលតាងឈ្មោះបក្សី, រុក្ខជាតិ, បាតុភូតធម្មជាតិ, សូរសំឡេងនៃ សត្វ, និងរុក្ខជាតិទាំងនេះ ។

ឧទាហរណ៍ ៖ ចចាត ពពេច ពពួលេ ពពៃ ពពក គគីរ ទទឹម ព្រៃព្រឹក្សា សារិកាកែវ គ្រលីងគ្រលោង ។

ក្នុងកំណាព្យ គេតែងប្រើទ្វេនីយកម្មនៃពាក្យ ដែលសំដែងអំពីអារម្មណ៍ សេចក្ដីរំភើប ។

ឧទាហរណ៍ ៖ ស្នេហ៍ស្នង ថ្នាក់ថ្នម ថៃថើប ។

យើងស្គាល់ពាក្យដែលជាពាក្យរណ្ដំបរិវារស័ព្ទ ចំនួន ១២ ដែលបកស្រាយ អំពីបញ្ញត្តិ សម្គាល់នាមនារីជាទីស្រឡាញ់ ។ រីឯពាក្យនីមួយៗ សុទ្ធសឹងគួសបញ្ជាក់ នូវលក្ខណៈនៃសម្រស់របស់ស្ត្រី នូវទឹកចិត្តស្រឡាញ់រាប់អានដល់អ្នកដែលជាទី ស្រឡាញ់ ។

ឧទាហរណ៍ ៖ ស្រស់ស្រី ឆោមឆាយ ពាលពៅ មាសមេ ស្នេហ៍ស្នង នួននាង នីមនួន ថ្លើមថ្លៃ ត្រាណត្រើយ នាងនាថ អូនអើយ ទងវង ។

ក្នុងភាសាខ្មែរ ក៏ដូចជាភាសាដទៃជាច្រើនទៀតដែរ គេសង្កេតឃើញមានវចនស័ព្ទពិសេសរបស់កវីនិពន្ធ ។ លក្ខណៈពិសេសមួយរបស់គេគឺ លក្ខណៈពោរពេញទៅដោយពាក្យរណ្ដំបរិវារស័ព្ទ ។ ទោះជាប្រើក្នុងវិស័យដែលខុសពីកំណាព្យ ក៏ដោយ ក៏ពាក្យរណ្ដំបរិវារស័ព្ទទាំងនេះ នៅតែរក្សាខ្លឹមសារមួយបែបក្នុងកំណាព្យដដែល ។ ពាក្យរណ្ដំបរិវារស័ព្ទដែលជាឧបករណ៍សម្រាប់សំដែងនូវវចនាបថនិពន្ធ ត្រូវអ្នកនិពន្ធ ឬកវីសម័យថ្មីយកមកប្រើប្រាស់យ៉ាងទូលំទូលាយផងដែរ ។

ឧទាហរណ៍ ៖ ក្នុងកំណាព្យរបស់សាស្ត្រាចារ្យ និងកវីដ៏ឆ្នើម កេង វ៉ាន់សាក់ " គុកកាមកិលេស ឆ្នាំ ១៩៦៣ " បានបង្ហាញច្បាស់អំពីរឿងនេះ ។ អត្ថបទកំណាព្យនោះមាន ២៦៩ វគ្គ ដែលក្នុងនោះ មានពាក្យរណ្ដំបរិវារស័ព្ទ ចំនួន ៣២៨ ។ ដូច្នេះ ក្នុងវគ្គនីមួយៗ គិតជាមធ្យម មានពាក្យរណ្ដំបរិវារស័ព្ទចំនួនមួយ ។

វចនាសម្ពន្ធនៃកំណាព្យខ្មែរ គឺទាមទារនូវការគោរពដ៏ទៀងទាត់ដល់សង្វាក់ និងចុងចួន ។ ចុងចួនជាទូទៅមានពីរ ៖ ចុងចួនព្យាង្គក្នុងវគ្គទៅនឹងព្យាង្គក្នុងវគ្គ និងចុងចួនជាមួយនឹងព្យាង្គដែលនៅចុងវគ្គមុន ។ ដើម្បីជាឧទាហរណ៍ យើងនឹងលើកបទកាកគតិមកពិនិត្យ ។ ការគោរពសង្វាក់ និងការចាប់ចុងចួននៃបទនេះ ជាការលំបាកណាស់ ប្រសិនបើមិនប្រើពាក្យរណ្ដំបរិវារស័ព្ទឱ្យទូលំទូលាយ ។ គេអាចអះអាងដោយក្លាហានថា ដើម្បីក្លាយខ្លួនជាកវីខ្មែរ គឺបានសេចក្ដីថា អ្នកនោះចេះចលនាការបង្កើតពាក្យបរិវារស័ព្ទឱ្យបានច្បាស់ ។ យើងក៏អាចសន្និដ្ឋានបានថែមទៀតថា ក្នុងយុគសម័យកណ្ដាល អក្សរសិល្ប៍ភាគច្រើន ច្រើនជាអត្ថបទកំណាព្យដូចនោះ តួនាទីរបស់ពាក្យរណ្ដំបរិវារស័ព្ទ គឺរឹតតែចាំបាច់ទៅទៀត ។

នៅក្នុងអក្សរសិល្ប៍នៃយុគសម័យកណ្ដាល ដែលសរសេរជាពាក្យរាយ គេសង្កេតឃើញភាគច្រើនសុទ្ធសឹងជារឿងនិទាន និងរឿងព្រេង ។ អត្ថបទទាំងនេះ

ត្រូវវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយ និងរៀបរៀងជាពាក្យនៃកម្លាយភាសាខ្មែរបច្ចុប្បន្ន ។ ចំណែកក្នុងភាសាខ្មែរបច្ចុប្បន្ន អត្ថបទអក្សរសិល្ប៍ភាគច្រើន គេសរសេរជាពាក្យរាយ ។

ក្នុងរឿង " កុលាបប៉ៃលិន " របស់លោក ញ៉ុក ថែម ( ១៩៣៨ ) គេសង្កេតឃើញមានការប្រើប្រាស់ពាក្យរណ្តំបរិវារស័ព្ទជាញឹកញាប់ដែរ ក្នុងការពិពណ៌នា ។ នេះជាការពណ៌នាអំពីចរិយាសម្បត្តិរបស់តួអង្គស្រីម្នាក់ក្នុងរឿង ដែលក្នុងនោះ មានសំនួនបរិវារស័ព្ទចំនួនបួន :

ឃុននារី មានឫកពារឆ្មើងឆ្មៃបន្តិច មានកិរិយាក្អិកក្អក់ ញ៉ៀងញ៉ង ល្វាសល្វៃ ល្អល្អះ ( កុលាបប៉ៃលិន ២៦ ) ។

មានអត្ថបទអក្សរសិល្ប៍មួយប្រភេទទៀត គឺរឿងជាអត្ថបទកម្រងកែវ ។ រឿងប្រភេទនេះ ដែលគេសម្គាល់ជាងគេ គឺរឿង " មហាវេស្សន្តរ " ( ១៩៦៨ ) របស់លោក ញ៉ុក ថែម ។ អ្នកនិពន្ធ ញ៉ុក ថែម កើតនៅខេត្តបាត់ដំបង ដែលជាខេត្តមានគ្រាមភាសាទន់ភ្លន់ និងពីរោះ ។ ភាពរស់រវើក និងពីរោះដូចតូរ្យតន្ត្រីរបស់រឿង " មហាវេស្សន្តរ " ដែលធ្វើឱ្យអ្នកអានពីរោះលន្លង់លន្លោច និងចូលចិត្ត ក៏ព្រោះតែអ្នកនិពន្ធប្រើពាក្យរណ្តំបរិវារស័ព្ទដែរ ។

គួរកត់សម្គាល់ដែរថា នៅពេលចុងក្រោយនេះ គេសង្កេតឃើញនិន្នាការប្រើពាក្យរណ្តំបរិវារស័ព្ទ សម្រាប់ធ្វើឱ្យអត្ថបទនយោបាយមានភាពរស់រវើកឡើង ។ អត្ថបទបែបនេះ គឺអត្ថបទប្រភេទកំប្លែងស្ងួត ដែលមានរចនាបថនិទាន បន្តុះបង្អាប់ រិះគន់ ។ ពាក្យរណ្តំបរិវារស័ព្ទទាំងនោះ ច្រើនជាពាក្យមានន័យបន្តុះបង្អាប់ ។

ឧទាហរណ៍ : ក្អេងក្អាង ឆេវឆាវ ត្រេនត្រូន ឡប់ឡប់ ឡេមឡឺម ច្រងេងច្រងាង ឆ្គេមឆ្គម ក្រឡិកក្រឡុច ... ។

គេតែងប្រើពាក្យរណ្តំបរិវារស័ព្ទក្នុងអត្ថបទអក្សរសិល្ប៍ និងនយោបាយ

ក៏ពិតមែន ប៉ុន្តែ ក្នុងភាសានិយាយដ៏រស់រវើកនៃមហាជន ពាក្យរណ្តំបរិវារស័ព្ទទាំងនេះ កាន់តែមានចំនួនច្រើន និងប្រកបដោយន័យផ្សេងៗ ធ្វើឱ្យវាក្លាយជាប្រភពវចនស័ព្ទឥតរីងស្ងួតសម្រាប់កវីនិពន្ធ ។

បច្ចុប្បន្នកាលនេះ មានពាក្យរណ្តំបរិវារស័ព្ទ និងសុភាសិត ឬពាក្យទំនៀមជាច្រើន បានកើតឡើង ដោយយកគំរូបែបឲ្វនីយកម្មនេះ ។

ឧទាហរណ៍ : តក់ៗ ពេញបំពង់ ឆុងៗ កំពប់អស់ ។

សន្សឹមៗ កុំបំបោល

ច្រឹមច្រុមជាន់ចានជ្រក់

ហ៊ឹហា ហិនហោច ។

## លក្ខណៈសេម៉ង់ទិកនៃពាក្យរណ្តំបរិវារស័ព្ទ

តទៅនេះ យើងនឹងសិក្សាអំពីពាក្យរណ្តំបរិវារស័ព្ទខ្មែរ ក្នុងតួនាទីវាជាវិធី ឬមធ្យោបាយម៉្យាងនៃការបង្កើតពាក្យ ។

នៅក្នុងអត្ថបទភាសាវិទ្យា គេសង្កេតឃើញមានទស្សនៈខ្លះៗ អំពីបញ្ហានេះ ។ តាមទស្សនៈរបស់លោក អឺ.មេនេទ្រីយេ ( E.Ménétrier ) ( ១៣. ១៤៧ ) នៅក្នុងភាសាខ្មែរ ពាក្យដែលកើតឡើងដោយវិធីផ្ទួន ច្រើនមានន័យអវិជ្ជមាន មានន័យមើលស្រាល ស្អប់ខ្ពើម ឬបន្ទាបបន្ថោក ។

ឧទាហរណ៍ : អាក្រក់ - អាក្រក់អាក្រី

ច្បិច - ច្បិចច្បើម

តាមទស្សនៈយើង គឺគេមិនអាចកំណត់ន័យឱ្យស្ថិតក្នុងភាពចង្អៀតត្រឹមន័យបែបអវិជ្ជមានទេ គឺមានន័យជាវិជ្ជមាន មានន័យបញ្ជាក់នូវភាសាខ្ពង់ខ្ពស់ ឬឧត្តមភាព ។ ពាក្យរណ្តំបរិវារស័ព្ទ អាចមានន័យផ្សេងទៀត មានជាអាទិ៍ ន័យផ្លាស់ប្តូរ

" បន្ថែម ឬបន្ថយ និងកំរិតនៃគុណភាព ជាដើម " ។

ឧទាហរណ៍ ៖ ស្អាត - ស្អាតស្អំ - ស្អាតបាត ។

ល្អ - ល្អល្អះ - ល្អល្អាច់ ។

យើងនឹងពិនិត្យអំពីបញ្ហានេះឱ្យបានស៊ីជំរៅ តទៅទៀត ។

ជាបឋម យើងសិក្សាអំពីពាក្យរណ្តំបរិវារស័ព្ទទាំងឡាយ ដែលមានពាក្យមេជានាម " នាមនាម ឬគុណនាម " ។

ក្នុងពាក្យរណ្តំបរិវារស័ព្ទបែបនេះ តួនាទីក្នុងការសំដែងន័យកំរិតនៃគុណភាពស្រដៀងនឹងតួនាទីនៃផ្នត់និយកម្ម ដើម្បីឱ្យតំលៃដូចក្នុងភាសាវិភត្តិដែរ ។ គេអាចចែកពាក្យរណ្តំបរិវារស័ព្ទឱ្យតំលៃដែលភាគច្រើនកើតបានពីគុណនាមជាបីពួកធំៗ គឺ ៖

១. ពាក្យរណ្តំបរិវារស័ព្ទប្រភេទទី ១ សំដែងន័យបន្ថែម ឬបន្ថយកំរិតនៃគុណនាម ឬសកម្មភាព ។

| | | |
|---|---|---|
| ឧទាហរណ៍ ៖ | កម្រិតធម្មតា | កម្រិតខ្ពស់ |
| | ក្រ | ក្រីក្រ |
| | វង្វេង | វង្វេងវង្វាន់ |
| | ស្គម | ស្គមស្គាំង |
| | ក្បាច់ | ក្បាច់ក្បូរ |
| | ធំ | ធំធាត់ |
| | ភ័យ | ភិតភ័យ |
| | ភ្លូត | ភ្លូតភរ |

ជួនកាលពាក្យដើមតែមួយ អាចបង្កើតពាក្យរណ្តំបរិវារស័ព្ទបានពីរ គឺមួយមានន័យបន្ថែម ឬពង្រីក និងមួយទៀត មានន័យបន្ថយ ឬបង្រួម ដោយអាស្រ័យ

ទៅលើការផ្លាស់ប្តូរលក្ខណៈសូរស័ព្ទ ។

ឧទាហរណ៍ៈ

| ពាក្យដើម | ពាក្យមានន័យបង្រួម | ពាក្យមានន័យពង្រីក |
|---|---|---|
| តឹង | តានតឹង | តឹងរ៉ឹង |
| ខូច | ខិលខូច | ខូចប្រឡូច |
| មាំ | មាំមួន | មាំទាំ |
| ស្នេហ៍ | ស្នេហ៍ស្នង | ស្នេហ៍ស្និទ្ធ |

ពាក្យរណ្តំបរិវារស័ព្ទទាំងឡាយដែលផ្គួនត្រឹមព្យញ្ជនៈដើមពាក្យ ក៏អាចមានន័យពង្រីក ឬបង្រួមដែរ ។

ឧទាហរណ៍ : ស្ងើត - សស្ងើត

ញ័រ - ញញ័រ

ភ្លើ - ពភ្លើរ

ក្នុងករណីពាក្យរណ្តំបរិវារស័ព្ទមានសភាពមិនទាន់នឹងននៅឡើយ នៅក្នុងភាសា ធ្វើឱ្យលំបាកបែងចែកន័យតាមការឱ្យតំលៃ ដោយមកពីទីតាំងនៃពាក្យមេ និងពាក្យបរិវារស័ព្ទមិននឹងន នៅនឹងមួយកន្លែង ។

ឧទាហរណ៍ : ថៃថើប - ថើបថៃ

ថ្នាក់ថ្នម - ថ្នមថ្នាក់

ឆ្លើយឆ្លង - ឆ្លងឆ្លើយ

២. រណ្តំបរិវារស័ព្ទផ្តល់តំលៃអវិជ្ជមាន ដែលសំដែងអំពីបាតុភូត គុណភាពមិនគួរពេញចិត្ត ( diminutif ) មិនទៀងទាត់ ដោយយោលទៅតាមទំនោរចិត្តនៃអ្នកដែលនិយាយ ។

ឧទាហរណ៍ :

| ពាក្យណាត " ធម្មតា " | ពាក្យអរិជ្ឈមាន " មានន័យបង្អន់ " |
|---|---|
| ក្មេង | ក្មេងក្មាង |
| ភ្លេង | ភ្លេងភ្លាត់ |
| ស្មៀន | ស្មៀនស្មេរ |
| នាហ្មឺន | នាហ្មឺននាសៃន |
| ល្ងើ | ល្ងីល្ងើ |
| ចិន | ចិនព្រិន |
| បារាំង | បារាំងបារោ |
| ជ្វរ | ជ្វរជាតិ |
| ស្រលើ | ស្រលើកី |
| តូច | តូចតាច |
| ល្អិត | ល្អិតល្អោច |
| ផ្តាស | ផ្តេសផ្តាស |
| ឡប់ | ឡិបឡប់ |
| ទទឹង | ទទឹងទទែង |
| ប្រាជ្ញ | ព្រោកប្រាជ្ញ |
| ហីន | ហីនហោច |

នៅក្នុងករណីខ្លះ ពាក្យណ្តាំបរិវារស័ព្ទផ្សេងៗគ្នា ដែលកើតចេញពីពាក្យដើមតែមួយ អាចសំដែងកម្រិតនៃភាពអរិជ្ឈមានខុសគ្នាដែរ ដូចជា : - ភ្លើ - ភ្លីភ្លើ - ពន្លីពន្លើ - ពន្លាក់ពន្លើ ។

៣- ពាក្យណ្តំបរិវារស័ព្ទមានន័យសរសើរ ( laudatif ) សំដែងទំនាក់

ទំនងជាវិជ្ជមានរបស់អ្នកនិយាយទៅកាន់សកម្មភាព វត្ថុ បាតុភូតផ្សេងៗ ។

ឧទាហរណ៍ :

| ពាក្យណីត ឬធម្មតា | ពាក្យសរសើរ |
|---|---|
| ទន់ | ទន់ភ្លន់ |
| ក្លំ | ក្លៀវក្លំ |
| ស្តុក | ស្តុកស្តម្ភ |
| ឧត្តម | ឧត្តុង្គឧត្តម |
| ស្វែង | ស្ងប់ស្វែង |
| ផ្អែម | ផ្អែមល្ហែម |
| ស | សស្គូល |
| ឈ្ងុយ | ឈ្ងុយឈ្ងប់ |
| ថ្លៃ | ថ្លៃថ្លា |
| ហាំ | ហាំហួន |
| ចំរើន | ចំរុងចំរើន |
| សស្រាក់ | សស្រាក់សស្រាំ |

ពាក្យរណ្តំបរិវារស័ព្ទដែលបានរៀបរាប់ខាងលើ មានតួនាទីសំខាន់ជាអតិបរមា ក្នុងការបង្កើតវចនស័ព្ទនានា ដែលសម្រាប់សំដែងគុណភាព កម្រិតខុសៗគ្នានៃចលនា ឬសកម្មភាពដែលស្តែងចេញ ។

*I. ការសិក្សាលើលក្ខណៈសេម៉ង់ទិក នៃពាក្យរណ្តំបរិវារស័ព្ទ ដែលពាក្យមេ ជាកិរិយាស័ព្ទ :*

យើងបានអធិប្បាយរួចមកហើយថា ពាក្យរណ្តំបរិវារស័ព្ទភាគច្រើនគឺកើតចេញពីកិរិយាស័ព្ទ ។ ទ្វេនីយកម្មទម្រង់នៃកិរិយាស័ព្ទ សំដែងនូវសកម្មភាព

ដែលប្រកបរចនាបថនិពន្ធ ។ យើងអាចចែកពាក្យរណ្ដំបរិវារស័ព្ទ កិរិយាស័ព្ទ ជា ៥ ក្រុមសេម៉ង់ទិក សំខាន់ៗ :

១. ទ្វេនីយកម្មទម្រង់នៃកិរិយាស័ព្ទដែលសំដែងសកម្មភាពលឿន ឬញឹកញយ ក្នុងរយៈពេលមួយ ។

| | | | |
|---|---|---|---|
| ឧទាហរណ៍ : | សសិត | < | សិត ( < អ.ថ. មកពី ) |
| | កកិត | < | កិត |
| | កកាយ | < | កាយ |
| | ទទះ | < | ទះ |
| | បបៀត | < | បៀត |
| | សសាប់ | < | សាប់ |
| | បបោស | < | បោស |
| | ញញាក់ | < | ញាក់ |
| | កកូរ | < | កូរ |
| | ជជុះ | < | ជុះ |
| | លលក់ | < | លក់ |

នៅក្នុងភាសាខ្មែរ គេអាចសន្មតថា កិរិយាស័ព្ទបែបនេះ ជាកិរិយាស័ព្ទប្រៀកង់តាទិស ជាប្រភេទខាងវេយ្យាករណ៍មួយយ៉ាងសំខាន់ ដែលស្ថិតនៅរស់រវើកក្នុងភាសាបច្ចុប្បន្ន ។

២. ទ្វេនីយកម្មទម្រង់នៃកិរិយាស័ព្ទ អាចសំដែងនូវចលនាវិលវល់ ចលនាទឹករលក ចលនាពីលើទៅក្រោម ឬពីក្រោមទៅលើ ដែលក្នុងអារម្មណ៍របស់ជនជាតិខ្មែរ គេតែងផ្សារភ្ជាប់ទៅនឹងគំនិតខ្វល់ខ្វាយ គំនិតឃ្លាតចាកសណ្ដាប់ធ្នាប់ធម្មតា ។

ឧទាហរណ៍ : ផ្ទៀងផ្ទង ឃ្លេងឃ្លោង ងេងងោង ទ្រេតទ្រោត ។

នៅក្នុងក្រមនេះ គេអាចបញ្ចូលពាក្យរណ្ដំបរិវារស័ព្ទ ដែលមានព្យញ្ជនៈពាក់កណ្ដាលស្រៈទៅខាងដើម ( យ ) និងមានន័យយោល ( មិននឹងន ) និងបន្លាយ ។

ឧទាហរណ៍ ៈ យីតយ៉ាវ យេកយោក យង់យល់ យំយែក រយីករយាក យីនយូវ រយេងរយោង ។

៣. ទ្វេនីយកម្មទម្រង់នៃកិរិយាស័ព្ទ ដែលអាចតាងន័យបញ្ជាក់ទំនាក់ទំនងទៅវិញទៅមក ។

ឧទាហរណ៍ ៈ ទាក់ទង សាសង យោគយល់ ឆ្លើយឆ្លង ប៉ុនប៉ង ។

៤. ទ្វេនីយកម្មទម្រង់នៃកិរិយាស័ព្ទសំដែងនូវសភាពជំរុញពិសេសនៃសកម្មភាពដែលកើតមានឡើងក្នុងករណីចលនាកាយ ចិត្ត ដ៏រហ័ស និងខ្លាំង ។

ឧទាហរណ៍ ៈ ស្ទុះស្ទា ហៀវហោះ ផ្លេកផ្លោះ ប្រញ៉ាប់ប្រញាល់ ក្រូញក្រាប ។

៥. ទ្វេនីយកម្មនៃកិរិយាស័ព្ទខ្លះ សម្រាប់សំដែងអំពីការចាប់ផ្ដើមនៃចលនា ដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗ ។

ឧទាហរណ៍ ៈ លោលោត លិលា ច្រូចច្រៀង ហិចហោះ ផ្ដួចផ្ដើម ។

មានពាក្យរណ្ដំបរិវារស័ព្ទខ្លះទៀត ដែលមានធាតុជ្រៀតដោយចុណ្ណស័ព្ទ ( អី ) ឬ ( អុី ) ពេលដែលគេនិយាយញាប់នៅកណ្ដាល ។ ពាក្យរណ្ដំបរិវារស័ព្ទទាំងនេះ សំដែងន័យពង្រីក ។

| | | | |
|---|---|---|---|
| ឧទាហរណ៍ ៈ | ស្អាត | - | ស្អាតអីស្អាត |
| | ខ្ជិល | - | ខ្ជិលអុីខ្ជិល |
| | ចាំ | - | ចាំអីចាំ |
| | យឺត | - | យឺតអុីយឺត |

• ពាក្យរណ្ដំបរិវារស័ព្ទត្រាប់សំណូរ ( Mots onomatopéiques )

លោក ម៉ាស្សូ បានឱ្យនិយមន័យការត្រាប់សូរថា ជាពាក្យដែលកើតឡើងដោយយកតម្រាប់ និងការសំដែងសំឡេងខ្លះៗ សម្រាប់ហៅវត្ថុ ឬសកម្មភាពផ្សេងៗ ធ្វើជាបង្អែក ។

( ៣.១១០ ) ក្នុងភាសាវិទ្យាប្រទេសបស្ចឹម នាបច្ចុប្បន្នកាលនេះ គេមិនសូវយកចិត្តទុកដាក់ប៉ុន្មានទេ ទៅលើទ្រឹស្ដីកំណាកំណើតពាក្យតម្រាប់សំណូរ ។ ការវិភាគឱ្យបានល្អិតល្អន់ទៅលើពាក្យតម្រាប់សំណូរខ្មែរ អាចឱ្យគេធ្វើសេចក្ដីសន្និដ្ឋានថា វាជាប្រភពមួយយ៉ាងសំខាន់នៃការបង្កើតវាក្យស័ព្ទ ហើយការបង្កើតពាក្យបែបនេះ ផ្ដល់នូវឯកតាពាក្យកម្លាយទាំងឡាយ ។ អំពីរឿងនេះ លោក ហ្សឺវ្វ មានទស្សនះថា " ពាក្យទាំងអស់ដែលស្ថិតចំពោះមុខយើង មានដើមកំណើតជាពាក្យកម្លាយ ជួនកាលជាពាក្យកម្ចី ពាក្យតម្រាប់សូរ ឬពាក្យសមាស " ( ៨.១២ ) បន្ទាប់មក គាត់បន្ថែមទៀតថា ពាក្យតម្រាប់អាចជាសំណូរ ជាអាគូស្ទិក ( លទ្ធផលនៃសំឡេង ) អាចជាហ្វូណូស៊ីណេទិក " ប្រដាប់បន្លឺសំដីត្រាប់តាមចលនា " អាចជាហ្វូណូមេតាហ្វរិក ( សូរ ឬសំឡេងនានា ឬមួយចលនាត្រូវទទួលមុនផលិតកម្ម ដោយប្រដាប់បន្លឺសំដីសម្រាប់តាងទម្រង់ ពណ៌ អារម្មណ៍ ) ( ៨.១០២ ) ។

នៅក្នុងភាសាខ្មែរ ដំណាក់កាលទី ១ នៃការឆ្លងកាត់ពីការត្រាប់សូរ ទៅពាក្យធម្មតា គឺឆ្លងកាត់ដំណាក់កាលនៃកំណាកំណើតពាក្យរណ្ដំបរិវារស័ព្ទ ។ ក្នុងកំណាកំណើតនៃពាក្យតម្រាប់សំណូរ គេយកការបែងចែកស្រះជាស៊េរី ( អ ) និងស៊េរី ( អ៊ ) ជាគ្រឹះ គឺពពួកស្រះ ( អ ) តាងសូរសំឡេងខ្ពស់រហ័ស ។

ឧទាហរណ៍ ៖ តឹង តូង តាង ផាំង ឆាំង ។ ល ។

រីពួកស្រះ ( អ៊ ) វិញ តាងសំឡេងទាប ឬយឺតខ្ជះខ្ជា ។

ឧទាហរណ៍ ៖ គ្រាំ គ្រាំង គ្រឹម ឃ្យូ រ វ្វូ រ្វូ ។ ល ។

នៅក្នុងប្រព័ន្ធតម្រាប់សូរ ក្រៅពីសូរតិច ខ្លាំង ភាពវែង ឬខ្លីនៃស្រះក៏មានសារសំខាន់ដែរ ។ ពពួកស្រះខ្លី ( អ អិ អុ អុ អ៊ុ ) អាចតាងសំឡេងខ្លីដាច់ៗ ឬសំឡេងខ្សាវៗ ។

ជាទូទៅ គេតែងប្រទះឃើញនៅក្នុងការផ្សំជាមួយព្យញ្ជនៈប្រកបចុងពាក្យ ។

ឧទាហរណ៍ ៖

| ពាក្យតម្រាប់សូរ | ពាក្យរណ្ដំបរិវារស័ព្ទ | ន័យរបស់ពាក្យរណ្ដំបរិវារស័ព្ទ |
|---|---|---|
| តក់ | តក់ៗ | សូរតំណក់ទឹក |
| ប៉ាច់ | ប៉ាច់ៗ | សូរសំឡេង |
| ហោះ | ហោះៗ | សូរសំណើច |
| តឹក | តឹកៗ | សូរសំឡេងខ្យល់ |
| តិប | តិបៗ | សូរសំឡេងពូថៅ |
| ទុប | ទុបៗ | សូរជើង |
| ខុល | ខុលៗ | សូរស្រមុក |
| អាក់ | អាក់ៗ | ការអានដាច់ៗ |
| ឡុល | ឡុលៗ | សូរសំឡេងមិនច្បាស់ |
| ទីប | ទីបៗ | សូរវាយ |
| ភឹប | ភឹបៗ | សូររលាស់សំពត់ |
| ប្រ៊ុច | ប្រ៊ុចៗ | សូរស្លាបហើរ |
| ស្រិច | ស្រិចៗ | សូរតំណក់ភ្លៀងរលឹម |
| គ្រឹម | គ្រឹមៗ | សូរផ្គរលាន់ |
| គ្រាំ | គ្រាំៗ | សូរទឹករលក |

| | | |
|---|---|---|
| ព្រឹប | ព្រឹប១ | សូរជើងដើរ |
| គ្រួល | គ្រួល១ | សូរផ្គរ |

វិពព្ទកស្រះវែង ( អ អូ អ៊ូ អេ អៃ អោ អ៊ោ អៅ ) អាចតាងសូរខ្លាំង និងវែង ។ ស្រះទាំងនេះអាចផ្សំជាមួយព្យញ្ជនៈចុងព្យាង្គ ។

ឧទាហរណ៍ :

| ពាក្យតម្រាប់សូរ | ពាក្យរណ្ដំបរិវារស័ព្ទ | ន័យរបស់ពាក្យរណ្ដំបរិវារស័ព្ទ |
|---|---|---|
| ឈូ | ឈូ១ | សូរទឹកធ្លាក់ |
| វ៉ី | វ៉ី១ | សូរខ្យល់ |
| វ៉ាវ | វ៉ាវ១ | សូរមែកឈើ |
| អូច | អូច១ | សំឡេងខ្សិប |
| ង៉ឺត | ង៉ឺត១ | សូរប្រាំង |
| ផស់ | ផស់១ | សូរផ្ទុះ |
| ឆា | ឆា១ | សូរទឹកធ្លាក់ |
| វូ | វូ១ | សូរខ្យល់ |
| អ៊ូ | អ៊ូ១ | សំឡេងមិនប្រាកដ |
| ផែត | ផែត១ | សូរខ្យល់ |
| អូយ | អូយ១ | សូរសម្រែកឈឺ |
| អៅ | អៅ១ | សូរបង្អោផ្អែ |
| ឆា | ឆា១ | សំឡេងទឹកខ្ចាត |
| ញ៉ើច | ញ៉ើច១ | សូរសំឡេងសុនខ |
| ឡៃ | ឡៃ១ | សំឡេងយំ |
| កោក | កោក១ | សូរត្រដោក ឬការប្រកែក |

| | | |
|---|---|---|
| ងោច | ងោច១ | សំឡេងអង្វរ |
| ប៉ោច | ប៉ោច១ | ស្នូរជជែកខ្លាំង |
| ប្រោក | ប្រោក១ | ស្នូរស្លឹកឈើ |
| ច្រេក | ច្រេក១ | ស្នូរកញ្ចែ |
| ប្រាវ | ប្រាវ១ | ស្នូរមែកឈើ |
| ច្រាវ | ច្រាវ | ស្នូរចាន ឬកែវ |

គួរចាប់អារម្មណ៍ផងដែរថា ព្យញ្ជនៈ ( ង ) គេឃើញញឹកញាប់ណាស់ក្នុងការបង្កើតពាក្យតម្រាប់ស្នូរ ។ នៅដើមព្យាង្គ ( ង ) តាងសំឡេងដាច់ៗ និងរហ័ស ។ ឧទាហរណ៍ :

| ពាក្យតម្រាប់ស្នូរ | ពាក្យរណ្ដំបរិវារស័ព្ទ | ន័យរបស់ពាក្យរណ្ដំបរិវារស័ព្ទ |
|---|---|---|
| ង៉ាង | ង៉ាង១ | ស្នូរសម្រែកខ្លាំង |
| ង៉ក | ង៉ក១ | ស្នូរកង្កួរ |
| ង៉ា | ង៉ា១ | ស្នូរសម្រែកកូនង៉ា |
| ង៉ិត | ង៉ិត១ | ស្នូរកិត |
| ង៉ុល | ង៉ុល១ | ស្នូរសំឡេងតាមច្រមុះ |
| ង៉េច | ង៉េច១ | ស្នូរសម្រែកសុនខ |
| ង៉ូវ | ង៉ូវ១ | ស្នូរសំឡេងរអ៊ូ ឬរង៉ូវ |
| ង៉េះ | ង៉េះ១ | ស្នូរសំឡេងថប់ខ្យល់ |
| ង៉ិច | ង៉ិច១ | ស្នូរសម្រែកឈើចាប់ |

រីចុងពាក្យវិញ ( ង ) តាងស្នូរ ឬសំឡេងខ្ពស់ ក្រអៅ ស្នូរដែកទង្គិចដែលឮឆ្ងាយក្នុងលំហ ។

ឧទាហរណ៍ :

| ពាក្យតម្រាប់សូរ | ពាក្យរណ្តំបរិវារស័ព្ទ | ន័យរបស់ពាក្យរណ្តំបរិវារស័ព្ទ |
|---|---|---|
| ឆាង/ឆាំង | ឆាងៗ/ឆាំងៗ | សូរលោហធាតុ |
| តូង | តូងៗ | សូរខ្លាំងរហ័ស |
| តឹង | តឹងៗ | សូរខ្សែតឹង |
| ទឹង | ទឹងៗ | សូរស្គរ |
| ម៉ឹង | ម៉ឹងៗ | សូរជួង |
| ផូង | ផូងៗ | សូរសំឡេងផ្ទុះ |
| ទូង | ទូងៗ | សូរសំឡេងស្គរ |
| ក្ដែង | ក្ដែងៗ | សូរសម្រែកអំពាវនាវ |

ពាក្យតម្រាប់ដែលសំដែងនូវសំឡេងផ្សេងៗ អាចធ្វើឱ្យអ្នកស្ដាប់ មានចំណាប់អារម្មណ៍ប្លែកៗ ។ ពាក្យទាំងនេះ ឆ្លើយទៅនឹងសំឡេងទាំងឡាយប្រកបដោយបំលែងន័យផ្សេងៗ ក្នុងសំនួនវោហារតម្រាប់ដែលគេមិនអាច ឬអាចដោយពិបាកកំណត់ឱ្យបានច្បាស់លាស់ ដោយប្រើមធ្យោបាយភាសាផ្សេងៗ ។ ក្នុងចំណោមពាក្យរណ្តំបរិវារស័ព្ទទាំងនោះ គេអាចបែងចែកជា :

១. ពាក្យតម្រាប់ស្នូរ ដែលឆ្លើយទៅនឹងសញ្ញាមានទម្រង់មិនច្បាស់លាស់ និងចលនាឃើញ ហើយទាក់ទងនឹងចក្ខុវិញ្ញាណ ។

| | | | |
|---|---|---|---|
| ឧទាហរណ៍ : | លើម | - | លើមៗ |
| | ផ្លឹម | - | ផ្លឹមៗ |
| | ភ្លន | - | ភ្លនៗ |
| | ភ្លើក | - | ភ្លើកៗ |
| | ព្រិច | - | ព្រិចៗ |
| | ព្រឹម | - | ព្រឹមៗ |

ព្រឺល - ព្រឺលៗ

ប្រុយ - ប្រុយៗ

ព្រោក - ព្រោកៗ

*II. ពាក្យតម្រាប់ឆ្លើយនឹងសញ្ញាតាមលក្ខណៈ និងស្ថានភាព ហើយមានន័យលំបាក ហត់នឿយ ។ ល ។*

ឧទាហរណ៍ : ម្ហេត - ម្ហេតៗ

ម្ហូប - ម្ហូបៗ

ភ្លៀក - ភ្លៀកៗ

ផ្អែះ - ផ្អែះៗ

ផ្អែត - ផ្អែតៗ

ពាក្យខ្មែរមួយចំនួនធំ មានលក្ខណៈជាពាក្យតម្រាប់ស្នូរ ។ ក្នុងវចនានុក្រមសម្ដេចសង្ឃ ជួន ណាត យើងពិនិត្យឃើញមានពាក្យតម្រាប់ស្នូរច្រើនបែបយ៉ាងណាស់ មានចំនួនរហូតដល់ទៅជាង ១៥០ ពាក្យ ។ ពាក្យតម្រាប់ស្នូរដើម អាចចាត់ទុកថាជាពាក្យឫស ដែលចេញពីនោះ គេអាចបង្កើតពាក្យថ្មីៗ ដោយវិធីផ្សេងៗ ដូចជាវិធីផ្នត់ ឬវិធីផ្សំពាក្យ ។ ដូចនេះ បើសិនជាយើងគិតថា ពាក្យតម្រាប់ស្នូរនីមួយៗ អាចបង្កើតពាក្យកម្លាយ និងពាក្យសមាសផងដែរ ទន្ទឹមនឹងការបង្កើតពាក្យរណ្ដំបរិវារស័ព្ទនោះ ចំនួនពាក្យដែលមានទំនាក់ទំនងទៅនឹងប្រភេទនេះ រឹតតែកើនចំនួនទៅទៀត ពាក្យតម្រាប់ស្នូរទាំងឡាយ អាចបង្រួមបញ្ចូលគ្នាជាពាក្យរណ្ដំបរិវារស័ព្ទដែលមានពីរ ឬបីព្យាង្គ ។

ឧទាហរណ៍ : អ៊ូអែ អ៊ឹកអ៊ាក់ ក្អាកក្អាយ កោកកាក ខ្សៀវខ្សារ ឈូឆរ តិបតុប តូងតាង ប៉ាច់ប៉ោច ង៉ោកង៉ាក ផូងផាង វ៉ូសវ៉ាស ឡិបឡប់ ច្រេវច្រាវ ព្រាត់ប្រាស់ ចេចចាច ចេចចូច អេចអូច ញ៉ែចញ៉ាច គឹកគាក់ គ្រាំគ្រេង ក្រៀមក្រំ

ក្រក្រី ព្រឹព្រួច ប្រួលប្រែ ព្រឹមព្រាង គុំគួន កៀកកើយ ញិកញ៉ក់ ញ៉ែងញ៉ង ញ៉ែមញ៉ុម ... ។

ដើម្បីបង្ហាញឱ្យច្បាស់ អំពីផលិតភាពក្នុងការបង្កើត ដោយឈរលើមូលដ្ឋានពាក្យតម្រាស់សួរ យើងនឹងលើកយកឧទាហរណ៍មួយនៃការបង្កើតពាក្យនានា ចេញពីពាក្យតម្រាប់សួរ " តក់, តក់ៗ " (វិធីទ្វេនីយកម្ម ) " ផ្តក់ " ( វិធីផ្នត់ដើម )" បន្តក់ " ( វិធីផ្នត់ដែក ) " តំណក់ " ។ " ស្រក់ " ( តាមវិធីប្តូរព្យញ្ជនៈដើមព្យាង្គ )" សស្រក់ " ( វិធីរណ្តំ ) " សម្រក់ " ( តាមវិធីផ្នត់ដែកទៅលើពាក្យកម្លាយ ) " សស្រាក់សស្រាំ " ( តាមវិធីបន្លាស់សំណួរ និងរូបារម្មណ៍នីយកម្ម ) ។

ដោយវិធីទ្វេនីយកម្មតម្រាប់សួរ គេបង្កើតបានពាក្យមួយចំនួនធំ ដែលស្ថិតក្នុងចំណាត់ថ្នាក់នៃផ្នែកផ្សេងៗ របស់សំដី គឺ គុណនាម កិរិយាស័ព្ទ កិរិយា-វិសេស ដូចមានឧទាហរណ៍រួចមកហើយ ។

ដូចដែលយើងបានបញ្ជាក់រួចមកហើយ ក្នុងភាសាខ្មែរ មានពាក្យជាច្រើនដែលទាក់ទងទៅនឹងសូរស័ព្ទនៃពាក្យ និងសេម៉ង់ទិករបស់វា ឬន័យបន្ថែមបញ្ជាក់ពីមនោសញ្ចេតនាក្នុងរចនាបថនិពន្ធ ។ ទាំងនេះ គេសង្កេតឃើញមាននៅក្នុងពាក្យរណ្តំបរិវារស័ព្ទ ដែលក្នុងសមាសភាពរបស់វា មានវិធីផ្លូនព្យញ្ជនៈ ។

១. ផ្លូនព្យញ្ជនៈគល់អណ្តាត ( ក ) បង្កើតបាននូវរូបភាព អាគូស្ថិច នៃសួរ និងសំឡេង សម្រែក ដែលបញ្ជាក់នូវអារម្មណ៍ខិតខំប្រឹងប្រែង ឬលំបាកលំបិនអ្វីមួយ ដែលមិនគួរជាទីពេញចិត្ត ។

ឧទាហរណ៍ : កោកកាក ខ្ញាកខ្ញាក ក្អាកក្អាយ ក្អេងក្អាង ខ្ទះខ្ទែងខ្ញែសខ្ញាស គ្រហិចគ្រហុក គ្រោតគ្រាត កន្ត្រែកកន្ត្រាក ខ្ញិកខ្ញក់ ក្រវេមក្រវាមក្រឡិចក្រឡុច ក្រមិចក្រមើម ក្រមីក្រមា ។

២. ផ្លូនព្យញ្ជនៈ ( ញ ) អាចបង្កើតនូវសញ្ចេតនាភ័យខ្លាច មិនច្បាស់

លាស់ក្នុងខ្លួន ឬមួយមិនដាច់ស្រេច ។

ឧទាហរណ៍ : ញញឹមញញែម ញ៉ិមញ៉ុម ញឹមញាញ ញើតញើម ញ៉ុកញ៉ាក់ ញាំញី ញ៉េចញ៉ាច ។

៣. ផ្ចួនព្យញ្ជនៈក្រអូម ( ច ) មានទំនាក់ទំនងទៅនឹងន័យរៀបរយ អាការៈមួរម៉ៅ ការអត់ទ្រាំមិនបាន សេចក្ដីព្រេកត្រអាល ។

ឧទាហរណ៍ : ចេចចាច ចេចចូច ច្រិមច្រុម ច្រេលច្រាល ច្រាសច្រាល់ ឆ្វងឆាំង ឆេវឆាវ ច្រងើងច្រង៉ាង ឈូឆរ ឆ្វាត់ឆ្វែង ជ្រួលជ្រើម ឆ្វេចឆ្វាច ។

៤. ផ្ចួនព្យញ្ជនៈ ធ្មេញ ( ត ) ទាក់ទងទៅនឹងន័យមិនរហ័សរហួន មិនច្បាស់លាស់ មិនហ្នឹងហ្ន៎ ។

ឧទាហរណ៍ : ត្រេះត្រុះ ព្រែកត្រក ទ្រែលទ្រល ទឹមទាម ទឹងទាំង តិបតុប តិញតុញ តេះតះ ទទ្រិបទទ្រាប ទទ្រឹមទទ្រម ទទ្រេតទទ្រោត ។

៥. ផ្ចួនព្យញ្ជនៈ បបូរមាត់ ( ប៉ ) ជាញឹកញាប់មាននៅក្នុងពាក្យដែលមានន័យ អ្វីដែលស្រាល មិនទៀងទាត់ មិនជាប់លាប់ ទន់ភ្លន់ ឬមួយសំរាប់សំដែងនូវអ្វីដែលសើម ជ្រាយ ។

ឧទាហរណ៍ : ប៉េលប៉ាល ពើតពើង ប៉េងប៉ោង រប៉ាត់រប៉ាយ ប៉ាក់ប៉ើក ភ្លើតភ្លើន ពព្រើកពព្រោច ប៉ផ្លាច់ប៉ផ្លៀច ប៉ប៉ិចប៉ប៉ាច់ ប៉ផ្លេះប៉ផ្លោះ ប៉ប្អេច ប៉ប្អាច់ ។

៦. ផ្ចួនព្យញ្ជនៈ ររិល ( រ ) អាចសំដែងន័យរស់រវើក មិនទៀងទាត់ ខ្វល់ខ្វាយ ។ ខ្យល់ ( រ ) នៅក្នុងភាសាខ្មែរ គឺមាននៅខាងដើម ខាងកណ្ដាល និងខាងចុងព្យាង្គ ដូចជាខ្យល់ ( រ ) នៃភាសាសំស្ក្រឹត ។ ខ្យល់ ( រ ) ផ្ដល់នូវថាមពលថ្មីដល់ពាក្យបុរាណ ហើយធ្វើឱ្យកិរិយាស័ព្ទមានចលនារស់រវើក ឬមានកិរិតខ្លាំងក្លា ។

ឧទាហរណ៍ : អឺមរវាម រង្កិករង៉ក់ រងើករង៉ាក រងាក់រងើ របិញរបុញ

រញ៉ើចរញ៉ាច រសេចរសាច រសាប់រសល់ រសេមរសាម រលីងរលោង រលីមរលាម ។

៧. ផ្នូនពាក់កណ្ដាលស្រៈ ឬព្យញ្ជនៈ ( រ ) អាចមានទំនាក់ទំនងទៅនឹងន័យទន់ភ្លន់ មានចលនាចល័ត ។

ឧទាហរណ៍ : រឹមរាម រាងរៃ រិលរល់ រីកររ រីររ រឹរក់ ។

៨. ផ្នូនព្យញ្ជនៈ ( ហ ) សំដែងន័យហោះហត់ ហត់នឿយ គ្មានទីពឹង ។ ទីតាំងព្យញ្ជនៈនេះ ផ្នូននៅខាងដើមព្យាង្គ ផ្នូននៅទីតាំងទីពីរ ក្នុងកន្សោមព្យញ្ជនៈដើមព្យាង្គ ព្យញ្ជនៈខ្យល់ ( ហ ) បញ្ជាក់នូវបញ្ញត្តិទាក់ទងនឹងភាពស្រាលទៅនឹងដង្ហើម ឬខ្យល់ ដូចមានកិរិយាស័ព្ទហោះហើរ ។

ឧទាហរណ៍ : ហោងហាង ហោលហាល ហាក់ហាក់ ហោសហាស ម្ហេបម្ហូប ម្ហេត១ ។

៩. ចំពោះព្យញ្ជនៈ ( ល ) គឺត្រូវធ្វើការបែងចែកវាទៅតាមការប្រើប្រាស់ជាមួយនឹងស្រៈសេរី ( អ ) ឬ ( អ៊ ) ។

ក/ ( ល ) ជាមួយស្រៈសេរី ( អ ) ច្រើនសំដែងន័យអរិជ្ឈមានរបស់ជនណាមួយ ព្រមទាំងចរិយារបស់ជននោះផងដែរ ។

ឧទាហរណ៍ : ឡេះឡោះ ឡិកឡក់ ឡេមឡីម ឡិបឡប់ ឡិងឡង់ ឡូឡា ឡូងឡាង ឡិបឡុប ឡប់ឡប់ ។

ខ/ ( ល ) ជាមួយព្យញ្ជនៈសេរី ( អ៊ ) ច្រើនជួបនៅក្នុងពាក្យដែលមានន័យទន់ភ្លន់ គ្មានព្រំដែន ចលនាទីករលក ។

ឧទាហរណ៍ : លីម១ លលាម លលក លលៃ លលេញ លលេលលាំ ល្ពេញល្ពៃ ល្វាសល្វន់ ល្វឹងល្វើយ ល្ហាចល្ហឹម ល្ហល្ហេវ ល្ហឹមល្ហែ ល្វេតល្វត ។

ពាក្យរណ្ដំបរិវារស័ព្ទដែលមានការផ្សំសំឡេងបែបនេះ ក្នុងអត្ថបទកំណាព្យ អាចបង្កើតសព្ទេតនាកំសត់ ទុក្ខព្រួយ ។ ក្នុងចំណោមន័យសព្ទេតនា

ទាំងនោះ យើងអាចសង្កេតឃើញន័យមួយចំនួនដែលជួបប្រទះជាញឹកញយ គឺន័យក្នុងការឱ្យតំលៃលើសកម្មភាពនៃការចំណាត់ថ្នាក់ នៃលំដាប់គុណភាព ព្រមទាំងន័យសំរាប់លក្ខណៈបរិមាណ និងគុណភាពនៃសកម្មភាព ។ ដូចនេះហើយបានជា កវី ឬអ្នកនិពន្ធ តែងតែប្រើពាក្យទាំងនេះក្នុងស្នាដៃរបស់ខ្លួន ប្រសិនបើគេយល់អំពីរចនាបថនៃពាក្យរណ្ដំបរិវារស័ព្ទ ។

សេចក្ដីដែលយើងលើកយកមកពណ៌នាខាងលើ អាចបញ្ជាក់ឱ្យយើងឃើញថា ពាក្យរណ្ដំបរិវារស័ព្ទក្នុងភាសាខ្មែរ មិនត្រឹមតែជាវិធីវេយ្យាករណ៍ប៉ុណ្ណោះទេ ថែមទាំងជាវិធីបង្កើតពាក្យមួយដែលប្រកបដោយសម្រស់ សម្ផស្ស សោភណ-ភាព និងដោយសញ្ចេតនា ហើយការប្រើពាក្យទាំងនេះ នាំឱ្យអត្ថបទមានរចនាបថនិពន្ធពិសេស ។

* * *

> *បើបណ្ឌិតដឹងថាខ្លួនជាទីស្រឡាញ់ហើយ ត្រូវតែខំថែរក្សាខ្លួន*
> *នោះអោយបានល្អ , ត្រូវតម្កល់ខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយ ។*
>
> ធម្មបទ - អត្តវគ្គវណ្ណនា

# សូរ្យគ្រាស - ចន្ទ្រគ្រាស
## ក្នុងទំនាក់ទំនងនឹងទេវកថា និងទំនៀមខ្មែរ

ដោយ **ឈន អៀម**

វចនានុក្រមខ្មែរ រៀបរៀងដោយ សម្តេចព្រះសង្ឃរាជ ជួន ណាត សរសេរថា គ្រាស ឬ គ្រាះ ( សំស្ក្រឹត : គ្រាស, គ្រាហ = គ្រាះ ; បាលិ : គហ ប្រែថា ដំណើរចាប់, កិរិយាចាប់ ឬកាន់ ) បានសេចក្តីថា : " ដំណើរដែលរាហូចាប់ ឬបាំងពន្លឺព្រះអាទិត្យ, ព្រះចន្ទ្រ " ។ គេច្រើននិយាយថា ចន្ទ្រគ្រាស ឬគ្រាះ, សូរ្យគ្រាស ឬគ្រាះ ។ គេនិយាយផងដែរថា ថ្ងៃមានគ្រាស ឬថ្ងៃមានរាហ៊ុ ឬក៏ថ្ងៃរាហ៊ុ ; ខែមានគ្រាស ឬខែមានរាហ៊ុ ឬក៏ខែរាហ៊ុ ។ ខ្មែរយើងចូលចិត្តនិយាយតាមបែបខាងក្រោយនេះ ដោយគេសំដៅដល់ដំណើររឿងរបស់អសុរម្នាក់ ជាបុត្ររបស់ វេបចិត្តិអសុរិន្ទ និងនាង សិង្ហិកា ។ អសុរនោះ ឈ្មោះ រាហុ ឬរាហូ, ប៉ុន្តែជាញឹកញយ ខ្មែរហៅថា រាហូអសុរិន្ទ ដែលមានខ្លួនដាច់ពាក់កណ្តាល ដោយត្រូវកងចក្ររបស់ព្រះវិស្ណុ ( ព្រះនារាយណ៍ ) តែមិនស្លាប់, ក្នុងគ្រាដែលរាហូអសុរិន្ទនេះបានកាឡាខ្លួនជាទេពតា បន្លំចូលទៅលួចផឹកទឹកអម្រឹត ( ក្នុងរឿងរាមាយណៈ ) ។ រាហូអសុរិន្ទ ជាសត្រូវរបស់ព្រះអាទិត្យ ព្រះចន្ទ្រ, តែងគ្រប ឬបាំង, ចាប់ ឬលេប ព្រះអាទិត្យ ព្រះចន្ទ្រ ។

តាមនិយមន័យផ្សេងទៀត នៅក្នុងវចនានុក្រមភាសាអង់គ្លេស, ពាក្យ គ្រាស ( Eclipse ) មានសេចក្តីពន្យល់ថា : ដំណើរបាំង ឬដំណើររលុបបាត់ពន្លឺ

មួយរយៈពេលខ្លី នៃព្រះអាទិត្យ, ព្រះចន្ទ្រ ឬផ្កាយដទៃទៀត ដោយសារមាន អន្តរាគមន៍នៃដួងផ្កាយមួយផ្សេងទៀត មកនៅចន្លោះផ្កាយនោះៗ ហើយនិងផែ្នក ឬមកនៅចន្លោះផ្កាយនោះៗ ហើយនិងប្រភពផ្តល់ពន្លឺរបស់ផ្កាយនោះៗ * ។




តាមពិត សូរ្យគ្រាស និងចន្ទ្រគ្រាស គឺជាបាតុភូតធម្មជាតិសុទ្ធសាធ ។ ប៉ុន្តែ មនុស្សជំនាន់ដើម បានពន្យល់ និងចាត់ទុកបាតុភូតនេះភ្ជាប់ទៅនឹងទេវៈ ឬ ភ្ជាប់នឹងសកម្មភាពរបស់ទេវៈ តាមរយៈទេវកថា ( Myths ) ។ ជនជាតិឥណ្ឌាជំនាន់ ដើម បានជឿថា : ថ្ងៃ ឬព្រះអាទិត្យ, ខែ ឬព្រះចន្ទ្រ គឺជាទេពតា ដែលមានឈ្មោះ ហៅផ្សេងទៀត ដើម្បីសំគាល់ទេពតាថា សុរៈ ។ ពួកទេពតា ឬសុរៈ នេះ មានសត្រូវ គឺពួកអសុរៈ ( យក្ខ, បីសាច ) ហើយគេជឿថា សូរ្យគ្រាស និងចន្ទ្រគ្រាស កើតមានឡើងនោះ គឺជាអំពើ ឬសកម្មភាពរបស់អសុរៈ ឈ្មោះ រាហូ ។ យូរៗ ម្តង, រាហូតែងមកធ្វើទុក្ខបុកម្នេញព្រះអាទិត្យ ឬព្រះចន្ទ្រ, នោះក៏ព្រោះតែហេតុបណ្តាល មកពីគំនុំផ្ទាល់ខ្លួន ក្នុងគ្រាដែលខ្លួនក្លែងភេទជាទេពតា ចូលទៅបន្លំផឹកទឹកអម្រឹត ហើយត្រូវបានព្រះអាទិត្យ និងព្រះច័ន្ទ ដឹងរឿងនេះទាន់ រួចនាំយកដំណឹងនេះ ទៅ ថ្វាយព្រះវិស្ណុ ដូចមានសេចក្តីនៅក្នុងរឿង " កូរសមុទ្រទឹកដោះ " ដែលជារឿងមួយ ល្បីល្បាញ នៅក្នុងទេវកថាវិជ្ជាឥណ្ឌា ។

* New Webster's Dictionary of the English Language College Ed. Surjeet Publications - India - 1998.

ដំណើររឿងបាននិទានថា ៖ ក្នុងគ្រាមួយនោះ, ពេលដែលទេពតាទាំងឡាយ កំពុងកួរសមុទ្រទឹកដោះ ហើយចម្រាញ់យកបានទឹកអម្រឹត, រាហូ ដែលជាអសុរ បានក្លែងភេទជាទេពតាមួយអង្គ ហើយបានចូលទៅបន្លំខ្លួនក្នុងហ្វូងទេពតា រួចផឹកទឹកអម្រឹតបានមួយចំណែក ។ ប៉ុន្តែ រំពេចនោះ ព្រះអាទិត្យ និងព្រះចន្ទ្រ ដែលជាទេពតាបំភ្លឺលោក បានដឹងនូវការបន្លំនេះរបស់រាហូ ក៏បាននាំដំណឹងទៅក្រាបទូលព្រះវិស្ណុដ៏ជាទេពតាសង្គ្រាមមួយអង្គ ។ ព្រះវិស្ណុ ក្នុងឋានៈជាអាទិទេពថែរក្សា និងការពារលោកផង បានចោលកងចក្រទៅកាត់ពាក់កណ្ដាលខ្លួនរាហូ ហើយបន្ទាប់មកក៏បានដោតកំណាត់ខ្លួនរាហូភ្ជាប់ទៅនឹងគោលតារា ( Stellar sphere ) នៅក្នុងនភាកាស ។ អសុររាហូ បានក្លាយជាមានជីវិតអមតៈ ដោយសារបានផឹកទឹកអម្រឹត ហើយមានចិត្តចងគំនុំចំពោះព្រះអាទិត្យ និងព្រះចន្ទ្រ តាំងពីពេលនោះមក ។ អំពើដែលរាហុបានធ្វើដើម្បីជាការសងសឹក ទៅលើព្រះអាទិត្យ និងព្រះចន្ទ្រនោះ គឺការចាប់ ឬការលេបព្រះអាទិត្យ ឬព្រះចន្ទ្រម្ដងម្កាល * ។ នេះគឺជាការបកស្រាយនូវបាតុភូតធម្មជាតិ ៖ គឺ សូរ្យគ្រាស ឬចន្ទ្រគ្រាស តាមទេវកថាវិជ្ជារបស់ឥណ្ឌា ។

ដំណើររឿងនេះបានក្លាយទៅជារឿងប្រជាប្រិយ៍ នៅក្នុងចំណោមមនុស្សជំនាន់ដើម នៃប្រទេសឥណ្ឌា ដែលប្រភពដើមនៃរឿងដំណាលនេះ កើតមានតាំងពីសម័យមុនពុទ្ធកាលទៅទៀត, ពិព្រោះ នៅក្នុងព្រះសូត្រជាភាសាបាលី ក៏មានឧទាហរណ៍មួយចំនួន ដែលបាននិយាយយោងដល់ឧប្បត្តិហេតុនេះ ។ រាហូចាប់ចន្ទ្រ និងការរត់គេចអោយផុតពីរាហូ ត្រូវបានគេប្រើធ្វើជាការប្រៀបប្រដូចនៅក្នុងព្រះ

* តាមរឿងដំណាលផ្ទាល់មាត់ប្រជាប្រិយ៍ត១គ្នាមកថា រាហូអសុរិន្ទ, ព្រះអាទិត្យ និងព្រះចន្ទ្រ គឺជាបងប្អូនគ្នា ។ គេបានជួបគ្នា យូរ១ម្តង ។ ដោយសេចក្តីស្រឡាញ់ និងការនឹករលឹកខ្លាំងពេក រាហូ អសុរិន្ទ បានប្រឡែងលេង ឬបានលេបព្រះចន្ទ្រ ឬព្រះអាទិត្យ ។

សូត្រ ( សុត្តនិបាត ..... ) ។ រាហូ គឺជាគ្រឿងសៅហ្មងមួយ ក្នុងបណ្តាគ្រឿងសៅ-ហ្មងទាំងបួនរបស់ព្រះអាទិត្យ និងព្រះចន្ទ្រ, ដោយហេតុដែលរាហូបានបាំងព្រះចន្ទ្រ និងព្រះអាទិត្យ មិនឱ្យចែងចាំងរស្មីដ៏រុងរឿងរបស់លោកទាំងអស់បាន ( អង្គុត្តរ-និកាយ វិន័យបិដក ) ។

គម្ពីរសំយុត្តនិកាយ បាននិយាយយោងដល់ឱកាសពីរដង ក្នុងគ្រាដែលរាហូបានចាប់ព្រះចន្ទ្រ និងព្រះអាទិត្យ ។ ដោយសារព្រះចន្ទ្រទេវបុត្របានសំបូងសង្រូងសុំការជួយសង្គ្រោះអំពីព្រះពុទ្ធ, ទើបព្រះអង្គបញ្ជាអោយរាហូអសុរិន្ទលែងព្រះអាទិត្យ និងព្រះចន្ទ្រ អោយមានសេរីភាពឡើងវិញ ។ ភ្លាមនោះ រាហូក៏បានធ្វើតាមបញ្ជារបស់ព្រះពុទ្ធ ។ ដោយសេចក្តីភិតភ័យខ្លាំងពេក រាហូក៏បានរត់ទៅជ្រកក្នុងផ្ទះសំណាក់ វេបចិត្តិ ដែលជាឪពុក និងជាមេក្លោងនៃពួកអសុរ ។ ឧប្បត្តិហេតុនេះ តាមការពិតជាក់ស្តែង គឺជាការនិទានយោងទៅរកទេវកថាឥណ្ឌា ស្តីពីរឿងគ្រាស ( eclipse ), ហើយរឿងនិទាននេះ ត្រូវបានអ្នកកាន់ពុទ្ធសាសនា រើសទុកសម្រាប់ធ្វើជាឧទាហរណ៍បំភ្លឺនូវអានុភាព និងមេត្តាធម៌របស់ព្រះពុទ្ធ ។

យោងតាមអដ្ឋកថា ( ទីឃនិកាយ អដ្ឋកថា សុមង្គលវិលាសនី ), រាហូអសុរិន្ទ មានដងខ្លួនកំពស់ ៤.៨០០ យោជន៍, មានដើមទ្រូងទំហំ ១.២០០ យោជន៍ និងមានជម្រៅមាត់ ១០០ យោជន៍ ។ រាហូមានចិត្តច្រណែនឈ្នានីសចំពោះព្រះអាទិត្យ និងព្រះចន្ទ្រ ដែលមានពន្លឺរស្មីរុងរោចន៍បំភ្លឺលោក, ដោយហេតុនេះ រាហូក៏បានឈរពាំងផ្លូវគោចររបស់ព្រះអាទិត្យ ព្រះច័ន្ទ ដោយមានមាត់ហាយ៉ាងធំ ។ កាលណាធ្លាក់ចូលក្នុងមាត់របស់រាហូអសុរិន្ទហើយ, ព្រះអាទិត្យ និងព្រះចន្ទ្រ ក៏កើតមានសេចក្តីភិតភ័យតក់ស្លុត ហើយក៏រត់ចោលវិមានរបស់លោក * ដោយសារតែការរត់

---

* នៅក្នុងគម្ពីរពុទ្ធសាសនាខ្លះ ( ធម្មបទដ្ឋកថា ? ) និងក្នុងអក្សរសាស្ត្រខ្មែរ ( រឿងក្លូលោបប៉ៃលិន - ញ៉ុក ថែម ) គេបានរៀបរាប់ថា ព្រះអាទិត្យ និងព្រះចន្ទ្រ ជាទេវបុត្រ ទ្រង់គង់ក្នុង ➡

គេចវេះនេះ ទើបពន្លឺរស្មីព្រះអាទិត្យ ព្រះចន្ទ្រ ត្រូវស្រទំ ឬស្រអាប់មួយរយះពេលខ្លី ។ មានពេលខ្លះ រាហូគ្រាន់តែកាន់អង្អែលវិមានព្រះអាទិត្យ ព្រះចន្ទ្រ ដោយដៃ ឬដោយចង្កា ឬក៏ដោយអណ្តាតរបស់ខ្លួនតែប៉ុណ្ណោះ ។ ពេលខ្លះទៀត រាហូអសុរិន្ទបានចាប់ព្រះអាទិត្យ ព្រះចន្ទ្រលើកឡើង ហើយយកមកដាក់ផ្ទឹបនឹងថ្ពាល់របស់ខ្លួន ។ សកម្មភាពប្លែកៗ គ្នាទាំងអស់នេះ ត្រូវបានគេពន្យល់បញ្ជាក់ថា ជាគ្រាសតែលើផ្នែកខ្លះៗ ( partial eclipses ) ហើយបកស្រាយទៅតាមស្រមោលបាំងមើលឃើញនៅលើផ្ទៃព្រះអាទិត្យ ព្រះចន្ទ្រ ។ ប៉ុន្តែ ទោះជាក្នុងករណីណាក៏ដោយ រាហូពុំអាចបញ្ឈប់ដំណើរគោចរបំភ្លឺលោករបស់ព្រះអាទិត្យ ព្រះចន្ទ្របានទេ ពិព្រោះថា បើការប៉ុនប៉ងរបស់រាហូក្នុងការបាំងបិទពន្លឺរស្មី ឬបញ្ឈប់ដំណើរគោចររបស់ព្រះអាទិត្យ ព្រះចន្ទ្របាននោះ មហន្តរាយច្បាស់ជានឹងកើតមានក្នុងសកលលោក ។ ដោយហេតុនេះ រាហូអសុរិន្ទ ក៏ត្រូវបន្តដំណើរគោចររបស់ខ្លួនក្នុងឋានៈជាទេពតា ព្រះគ្រោះមួយជាមួយព្រះអាទិត្យ ព្រះចន្ទ្រ ដែលជាទេពតាព្រះគ្រោះដែរ តទៅទៀត ។ គួរកត់សម្គាល់ថា នៅក្នុងហោរាសាស្ត្រ រាហូអសុរិន្ទ ត្រូវបានគេរាប់ថាជាទេពតាព្រះគ្រោះទីប្រាំបី ក្នុងពពួកទេពតានព្វគ្រោះ ( = ទេពតាព្រះគ្រោះទាំងប្រាំបួន ) ដែលមានអម្ពរនិងពាហនៈ សុទ្ធតែខ្មៅ ។

សេចក្តីខាងលើនេះ គឺជាការពិពណ៌នាប្រជាប្រិយ៍របស់អ្នកកាន់ពុទ្ធ.សាសនា នៅក្នុងទេវកថាវិជ្ជា ស្តីពីគ្រាស ។ ទោះបីជានៅក្នុងការរៀបរាប់ល្អិតល្អន់មានចំណុចខ្លះផ្សេងគ្នាពីការបកស្រាយរបស់អ្នកកាន់លទ្ធិហិណ្ឌូក៏ដោយ ក៏វាគ្មានការខុសគ្នាជាសារវន្ត រវាងទេវកថាទាំងពីរនោះទេ លើកលែងតែហេតុការណ៍ដែលថា អ្នកកាន់ពុទ្ធសាសនា បានរៀបរាប់រឿងនិទានស្តីពីសូរ្យគ្រាស ចន្ទ្រគ្រាស តាមវិធី

---

◆ វិមានកែវផលិកភ្លឺផ្លេក មានភារកិច្ចបំភ្លឺលោក ។ កន្លែងខ្លះនិយាយថា សុរិយទេវបុត្រគង់ក្នុងវិមានកែវផលិកជារាជរថ អូសដោយសេះរាជានេយ្យ ។

បែបណា ដែលអាចជួយលើកឥទ្ធិពល ឬអានុភាពរបស់ព្រះពុទ្ធបាន ។

ចាប់តាំងពីព្រះសូត្រ នៅក្នុង សីលក្ខន្ធវគ្គ នៃគម្ពីរទីឃនិកាយ, គេបានកត់សំគាល់ឃើញថា មានការអនុវត្តដ៏ទូលំទូលាយទូទៅមួយ នៅក្នុងចំណោមមនុស្សជំនាន់ដើម ទាំងនៅក្នុងប្រទេសឥណ្ឌា ទាំងនៅក្នុងប្រទេសកាន់ពុទ្ធសាសនាឯទៀតដែលរួមមានប្រទេសកម្ពុជាផងដែរ នោះគឺការទស្សន៍ទាយអំពីផលវិបាក ចេញមកពីសូរ្យគ្រាស ចន្ទ្រគ្រាស ។ ការទស្សន៍ទាយនេះ គឺជាផ្នែកមួយនៃហោរាស្រ្ត ដែលត្រូវបានពុទ្ធសាសនា ថ្កោលទោសថាជាសិល្បៈថ្នាក់ទាប ហើយអោយឈ្មោះថាជាតិរច្ឆានវិជ្ជា ។ ភិក្ខុសង្ឃត្រូវចៀសវាងការប្រព្រឹត្តនូវមុខវិជ្ជានេះ ដែលគេបានចាត់ទុកជាមធ្យោបាយចិញ្ចឹមជីវិតដ៏ខុសឆ្គង ( មិច្ឆា អាជីវៈ ) ។

ផលវិបាកចេញមកពីបាតុភូតសូរ្យគ្រាស ចន្ទ្រគ្រាស បានបង្កើតជាប់មកជាទំនៀមមួយ នៅក្នុងសង្គមខ្មែរ ។ តាំងពីបុរាណកាល សឹងមាននៅជាប់មកដល់សព្វថ្ងៃនេះ, មានមនុស្សខ្លះ នៅតែយល់ថា ស្ត្រីដែលមានគភ៌ ឬមានផ្ទៃពោះ កាលបើប្រទះលើថ្ងៃមានគ្រាស ត្រូវអោយយកអកកំបោរមកដក់នឹងថ្ពក់ *ជាដំណើរអបទេសថា អោយគ្រាសកន្លងអកកំបោរចុះ កុំអោយកន្លងកូនក្នុងឧទរ ឬផ្ទៃ* ។ បើមានគ្រឿងផ្ទះថ្មី ដែលមិនទាន់បានសង់ ឬផ្ទះដែលកំពុងសង់នៅមិនទាន់ ហើយ, កាលបើមានគ្រាស, ត្រូវអោយយកស្បូវភ្លាំង មកចងនឹងបង្គោល ឬដាក់លើគ្រឿងផ្ទះ ឬក៏ចងនឹងមេដំបូលផ្ទះថ្មីនោះ, កុំអោយគ្រាសកន្លង ខ្លាចចង្រៃ ដោយគេយកតាមរឿងនិទានពីព្រេងនាយមកថា រាហូរអសុរិន្ទ ខ្លាចស្បូវភ្លាំងណាស់ ។

នៅក្នុងទំនៀមខ្មែរ *មនុស្សគ្រាសកន្លង* ត្រូវបានគេជឿថា ជាមនុស្សដែលល្មេញល្មើពីកំណើត ដោយហេតុតែមនុស្សនោះ កាលនៅក្នុងផ្ទៃម្តាយ គាប់ជួនឆ្នាំនោះមានគ្រាសក្នុងថ្ងៃណាមួយ ឬកាលដែលមនុស្សនោះ សម្រាលមកជួនលើថ្ងៃមានគ្រាស, អ្នកទាំងពួងច្រើនយល់ថា *មនុស្សនោះល្មេញល្មើព្រោះគ្រាសកន្លង* ។

ប៉ុន្តែ បើមនុស្សនោះ កាលនៅក្នុងផ្ទៃម្តាយ ឬកាលសម្រាលមក មិនប្រទះលើគ្រាស ដូច្នោះទេ, បើទោះមនុស្សល្ងេញល្ងើពីកំណើត, ក៏អ្នកទាំងពួងហៅមនុស្សនោះថា *មនុស្សល្ងេញល្ងើ* ត្រឹមប៉ុណ្ណោះ ។

នៅមានទំនៀមផ្សេងៗ ទៀត នៅតាមជនបទ និងនៅតាមទីកន្លែងខុសៗគ្នា ដែលមានអ្នកខ្លះជឿថា កាលណាមានចន្ទ្រគ្រាស ឬសូរ្យគ្រាស គេត្រូវយកដំបងទៅវាយលើដើមឈើផ្តល់ផ្លែ ដូចជាដើមខ្នុរ ស្វាយ ល្មុត ដូង ជាដើម ដើម្បីអោយដើមឈើទាំងនោះមានផ្លែច្រើន ។ ដោយមានការយល់ដឹងវិទ្យាសាស្ត្រ ជំនឿមិនត្រឹមត្រូវពីមុនមក កាន់តែបាត់បង់ទីតាំងរបស់ខ្លួនហើយ ។

ឯកសារពិគ្រោះ :


- វចនានុក្រមខ្មែរ ជួន ណាត បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ១៩៦៧
- Encyclopaedia of Buddhism vol. V pp 6-7
- New Webster's Dictionary of the English language-India 1988


*បើទោះជាការពោលពាក្យមួយពាន់ម៉ាត់ តែជាពាក្យគ្មានប្រយោជន៍ , ពាក្យនោះៗ មិនប្រសើរឡើយ ; បុគ្គលស្តាប់ពាក្យពោលណាតែមួយម៉ាត់ ហើយនាំអោយមានសេចក្តីស្ងប់ , ពាក្យពោលមួយម៉ាត់នោះប្រសើរជាង ។*

ធម្មបទ . សហស្សវគ្គវណ្ណនា

គាថាទី ១០០ . ឈ.អ.

# បញ្ហានៃសិលាចារឹកពីរ សម័យមុនអង្គរ
# ដែលរកឃើញនៅវត្តព្រៃវែង
# រាជធានីភ្នំពេញ និងលក្ខណៈប្រវត្តិសាស្ត្រ

( ត ចប់ )

ដោយ : - លោក វង់ សុធារ៉ា
- លោក ឡឹក សាវណ្ណ
- កញ្ញា អ៊ួន ភគិនី
ដឹកនាំដោយ បណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម, ខែ សីហា ១៩៩៦

## អំពីកាលបរិច្ឆេទ និងលក្ខណៈប្រវត្តិសាស្ត្រ

យើងបានបង្ហាញរួចមកហើយថា សិលាចារឹកនៅវត្តព្រៃវែងទាំងអស់គឺចារក្នុងរជ្ជកាលស្ដេចផ្សេងៗគ្នា ។

សិលាចារឹកដែលលោកសឺដេស សិក្សារួចនោះ គ្មានអ្វីអាថិកំបាំងទៀតទេ ចំពោះកាលបរិច្ឆេទ ព្រោះសិលាចារឹកនេះមានឈ្មោះព្រះបាទឥសានវរ្ម័ន ។ ប៉ុន្តែអ្វីដែលជាការស្មុគស្មាញនោះ គឺការរកកាលបរិច្ឆេទ នៃសិលាចារឹកថ្មីទាំងពីរ ដែលជាកម្មវត្ថុនៃការស្រាវជ្រាវរបស់យើង ។

*ចំពោះសិលាចារឹកផ្ទាំងទី ១* : ដែលមាន ២ អត្ថបទ គឺអត្ថបទខាងមុខជាភាសាសំស្ក្រឹត ( មាន ១២ បន្ទាត់ ) និងខាងខ្នង ( មាន ២០ បន្ទាត់ ) ជាភាសាខ្មែរ ។

អត្ថបទនេះ បើយើងសំអាងលើភាសា និងឈ្មោះអាទិទេព គ្រី អំព្រាត

កេត្វរ មានកាលបរិច្ឆេទក្នុងអំលុងពាក់កណ្ដាលសតវត្សទី VII គឺអាចក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ១ ។

+ លក្ខណៈភាសា :

- សិលាចារឹកនេះ ពិតជាចារក្រោយរាជ្យព្រះបាទឥសានវរ្ម័នទី ១ លើបញ្ហានេះយើងសង្កេតលើតួអក្សរានីមួយៗមានជើងវែងៗ សក់ស្ដួចវែងឡើងលើ ។

- អក្សរ gui ពិតជាមានចំណាស់ជាង gui និងកាន់តែចាស់ជាង gi ។ gui ជាព្យាង្គដែលប្រើប្រាស់ក្នុងអត្ថបទក្នុងរជ្ជកាលគ្រឹឥសានវរ្ម័ន រីឯ gui ជាព្យាង្គដែលប្រើប្រាស់ក្នុងអត្ថបទ ដែលយើងកំពុងសិក្សា ហើយព្យាង្គ gi វិញមានប្រើប្រាស់នៅអត្ថបទនៃផ្ទាំងទី ២ ។

មួយទៀតពាក្យ dron ដែលមានន័យថាទាំងឬ ព្រមទាំង គេសង្កេតឃើញប្រើប្រាស់ច្រើនតែនៅរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១ ប៉ុណ្ណោះ ។

+ អំពីរអាទិទេព គ្រឹ អំរ្រាតកេត្វរ :

សិលាចារឹកដែលគេរកឃើញ និងបោះពុម្ពផ្សាយរួចមានតែបីប៉ុណ្ណោះដែលនិយាយរៀបរាប់អំពីការបូជា ចំពោះអាទិទេព គ្រឹអំម្រាតកេត្វរ ហើយសិលាចារឹកទាំងនោះ សុទ្ធសឹងមានកាលបរិច្ឆេទក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១ ដូចជា K493 នៅទួលគោកព្រះ, កំពង់ឫស្សី ខេត្តព្រៃវែង មានកាលបរិច្ឆេទឆ្នាំ ៦៥៧ គ.ស ។ នៅក្នុងអត្ថបទកំណាព្យសំស្រ្កឹតស្លោកទី ៤ បន្ទាត់ទី ៧, ៨ ថា « តេនេហស្ថាបិតោ ភក្ត្យា គ្រីមានាម្រាតកេត្វរៈ, យថាមមកិវេភក្តិះ ប្រតិជន្មភវេទិតិ » ប្រែថា « ទីនេះ បង្កើតឡើងដោយសារភក្តីភាពដល់ព្រះអំម្រាតកេត្វរ ជាទីគោរពរបស់អ្នកបួងសួងព្រះអាទិទេព ភក្តីភាពរបស់ខ្ញុំ ចំពោះព្រះសិវ ត្រូវបានផ្លាស់ជាថ្មីដោយសារប្រសូត្រកម្មរបស់យើងខ្ញុំតែម្នាក់ឯង » ( Celui érigea avec dévotion le vénérable Amratakeçvara, en disant : " Puisse ma

dévotion à Çiva se renouveler dans chacune de mes naissances ! ) (១)

K 8 ប្រាសាទប្រាំល្វែងនៅកម្ពុជាក្រោមលោក សឺដេស ថាសតវត្សទី VII. VIII អត្ថបទចាប់ផ្ដើមដោយពាក្យថា « ក្ញុំវ្រះកម្រតាង៑ អញ្ គ្រឹអម្រាតកេឝ្វរ បុណ្យ បោញ៑ ក្ឫឞ្ណទត្ត ... » ប្រែថា « ក្ញុំបំរើរបស់អាទិទេព គ្រឹអម្រាតកេឝ្វរ អំណោយ របស់បោញក្រឹស្នទត្ត ... » (២)

K 54, 55 ក្ដីអង្គចំងាយ ១៥ គ.ម ខាងត្បូងបាភ្នំ ខេត្តព្រៃវែង កាល បរិច្ឆេទសតវត្សទី VII រាជ្យព្រះបាទជ័យវរ្ម័នទី ១ ។ នៅក្នុងអត្ថបទកំណាព្យសំស្ក្រឹត ស្លោកទី V នៃ K 55 បន្ទាត់ទី ១, ២ ថា « បុនស្សស្ថត្យេតនៃវ ឝ្រី [ មទា ] ម្រាតកេឝ្វរេ យោជិតាកេបរិភវិ គិរ [ លិ ] ង្គទ្វយំក្ឫតម៑. » ប្រែថា « មានអ្នក គោរពបូជាថ្មីទៀតជាច្រើន ការកសាងដូចគ្នានេះដោយសារពួកអ្នកមានទ្រព្យធន ( អ្នកបញ្ញា ) លិង្គពីរនៅក្នុង ( ប្រាសាទរបស់ ) អាទិទេព អម្រាតកេឝ្វរ » ( Les ayant consacrés à nouveau. le même érigea avec toute la richesse ( requise ), deux lingas dans ( le temple du ) vénérable Amratakeçvara ) (៣)

ចំណែក K 115 នៅស្វាស ឬវត្តស្វាសឫស្សី កំពង់ចាម ចុះកាល បរិច្ឆេទ ៦៦៥គ.ស អត្ថបទសរសេរជាភាសាសំស្ក្រឹត និងភាសាខ្មែរ ។ ផ្នែកសរសេរ ជាភាសាខ្មែរនិយាយពីខ្ញុំបំរើ ជាជំនូនរបស់ម្ដាយបោញ និជិត សឹហ Nirjtasiṃha ដល់ព្រះអាទិទេពឝ្រីមទាម្រាត çrī mad Āmrāta ។ នាមរបស់លិង្គ çri mad

---

(១) : Inscription du Cambodge par G. Coedès volume II, 149, Paris 1951

(២) : cf. idem Volume II, 79. Paris 1951

(៣) : Idem Volume II, 157-162, Paris 1951

Āmrāt ត្រូវបានដាក់នៅក្រោមរូបភាពអាទិភាព អាម្រាតកេគួរដោយលិង្គដទៃទៀតភាគច្រើននៅសម័យមុនអង្គរ (១) ។

ដូច្នេះរួមទាំងសិលាចារឹករកឃើញថ្មីមួយទៀតដោយសារវត្តមាននៃឈ្មោះអាទិទេពត្រី អំប្រាតកេគួរសិលាចារឹកនេះពិតជានៅអំលុងព្រះបាទជ័យវរ្ម័នទី I ដូចគ្នាព្រោះរជ្ជកាលព្រះអង្គពីឆ្នាំ ៦៥៧-៦៨១ (២) ឬ៦៥៧-៦៨០ (៣) ។

*ចំពោះសិលាចារឹកផ្ទាំងទី ២* : គឺអត្ថបទជាភាសាខ្មែរ មាន ១៦ បន្ទាត់ យើងធ្វើការកំណត់កាលបរិច្ឆេទ នៃសិលាចារឹកនេះបានដោយសង្កេតទៅលើបញ្ហាពីរដូចសិលាចារឹកផ្ទាំងទី ១ ដែរ គឺបញ្ហាភាសា និងគោរម្យងារព្រះមហាក្សត្រ

+ ផ្នែកភាសា :

- តួអក្សរមានជើងខ្លីៗ ខុសពីសិលាចារឹកទី ១

- ភាសាឃើញមានការវិវត្តន៍ ដូចជាពាក្យ « គ៌ុ » វិវត្តទៅជា « គិ » ពាក្យ « ទ្រោង៑ » វិវត្តទៅជា « ទោង៑ »

+ ផ្នែកគោរម្យងារព្រះមហាក្សត្រ :

- សិលាចារឹកនេះ យើងឃើញមានពាក្យមួយឃ្លាថា : មន៑ វ្រះកំម្រតាង៑ អញ៑ តទៅ ឝិវបុរ... man vraḥ kaṃmratāṅ añ dau Çivapura... » ពាក្យ « Çivapura » គឺជាមរណនាមរបស់ព្រះបាទជ័យវរ្ម័នទី ១ ព្រោះថា ពាក្យនេះយើងឃើញមានប្រើនៅក្នុងសិលាចារឹកចំនួន ៣ រួចមកហើយមួយគឺ K451S នៅបន្ទាត់ទី ១៣ (៤) មានឃ្លាថា : .... aṃnoy vraḥ kamratāṅ añ ta

(១) : cf, Idem Volume VI, 10-11, Paris 1954

(២) : ត្រឹង ងា « ប្រវត្តិសាស្ត្រខ្មែរ » ភ្នំពេញ គ.ស ១៩៧៣ ទំព័រ ១១៩

(៣) Inscription du Cambodge par G. Coedès Volume VIII, 5 Paris 1966

(៤) cf. Inscription du Cambodge par Georges Cœdés, Volume V page 49-50 Paris 1953

dauçivapura ... ( Traduction : don le vraḥ kamratāṅ añ qui est allé à çivapura ) ពាក្យ çivapura នៅទីនេះអ្នកនិពន្ធពន្យល់ថា ជាមរណនាមរបស់ស្តេចមួយអង្គ ពេលព្រះអង្គមានព្រះជន្មនៅឡើយ គឺប្រកបដោយសុខភាពល្អ ព្រះនាមថា ជ័យវរ្ម័ន និងដែលបានបញ្ជាក់នៅក្នុងសិលាចារឹកតាំងក្រង់ ( Tāṅ kraṅ ) ។ សិលាចារឹកនេះចុះកាលបរិច្ឆេទ ៦៨០ គ.ស ។

ពីរគឺ K726 នៅបន្ទាត់ទី ៣, ៤ មានឃ្លាថា : ... ta gi rājya vraḥ kamratāṅ añ ta dau svarga çivapura kāla gi sre tel jāhv sre aṃvi ta dharmmajñāna kvuṅ ... ( Traduction : Sous le règne du roi qui est allé au ciel çivapura, a cette époque-la voici les rizières acquises ( par voie d' échange ) : Rizière provenant des gens connaissant leur devoir kvuṅ ... )

ពាក្យសិវបុរ çivapura ពេលនេះអ្នកនិពន្ធពន្យល់ថា : ការបង្ហាញនេះមិនត្រូវយកមកប្រើនៅក្នុងអត្ថបទថា « មរណៈនៅសិវបុរ » ទេ ។ ភាពអវត្តមាននៃកំទេចកំទីតូចៗទៅនៃវិញ្ញាណ គឺមានទីតាំងនៅពីមុខ çivapura ( L' absence de particule a sens locatif devant çivapura ) ហើយរាល់ការប្រៀបធៀបជាមួយការបញ្ជាក់នៃពាក្យ « តទៅឝិវបុរ » នៅក្នុងសិលាចារឹកបារាយណ៍ខាងលិចបង្ហាញថា : វាគឺជាមរណនាម មួយ[(១)] ។

បីគឺ K 904 B នៅបន្ទាត់ទី ១១, ១២, ១៣ មានឃ្លាថា : ... vraḥ kamratāṅ añ ta dau çivapura gi tel ge kloñ tve puṇya saṃ daṅ mratāñ çakrasvāmi agrāsana gi neḥ vnok phoṅ ... Traduction : vraḥ kamratāṅ añ qui est allé à çivapura, ( troupe ) dont la Ge

(១) cf. IC. op-cit, page 75

kloñ fait une donation pieuse de concert avec Mratāñ çakrasvāmi agrāsana. C'est toute cette troupe ...(១) ។ សិលាចារឹក នេះចុះកាលបរិច្ឆេទ គ.ស ៧១៣ ដែលគេរកឃើញនៅតំបន់បារាយណ៍ខាងលិច ។

ដូច្នេះ តាមអំណះអំណាងនៃសិលាចារឹកទាំងបីនេះ យើងអាចដឹងបាន ថា អត្ថបទទី ២ នៃសិលាចារឹកវត្តព្រៃវែង គឺចារនៅក្រោយពេលព្រះបាទជ័យវរ្ម័ន ទី ១ ចូលទិវង្គត ហើយបើតាមលក្ខណៈ ភាសា យើងដឹងបានទៀតថា សិលាចារឹក នេះចារមុន គ.ស ៧១៣ ព្រោះអត្ថបទ K 904 B ពាក្យ « ទោង៑ » បានប្តូររូបទៅ ប្រើជា « ទង៑ » ដែលកាន់តែមានរូបរាងប្រហាក់ប្រហែល « ទាំង » សព្វថ្ងៃ ។

មួយទៀតនោះ មានគោរម្យងារព្រះមហាក្សត្រជ័យទេវី តែមួយព្រះអង្គ គត់នៅសម័យមុនអង្គរ ដែលប្រើពាក្យ « ធូលិជេង៑វ្រះកំម្រតាង៑អញ » មុនគេគឺ K 904 A ( ចុះកាលបរិច្ឆេទ គ.ស ៧១៣ ដូចខាងលើដែរ ) ដោយនៅបន្ទាត់ទី ១៥, ១៦ មានឃ្លាថា : ... អាយ៑ កន្លោង៑កាម្យារាម ធូលិជេង៑វ្រះកម្រតាង៑ អញ ឝ្រីជយ ទេវី ឱយ៑ ករោំ ត ម្រតាញ៑ ឝក្រស្វាមិ អគ្រាសន អវធិ ... បន្ទាត់ទី ២៧ ថា : ... ស្រេ ប្រង៑ មនិ ធូលិជេង៑វ្រះ កំម្រតាង៑ អញ ឝ្រី ជយទេវី ប្រសាទតម្រតាញ៑ (២៨) ឝក្រស្វាមិ ...(២) ។

ពាក្យ « ធូលិជេង៑ វ្រះកំម្រតាង៑អញ ឝ្រីជយទេវី » គឺជាព្រះនាមព្រះមហា ក្សត្រិយានី ជ័យទេវី ដែលព្រះនាងឡើងសោយរាជ្យបន្ទាប់ពីព្រះបាទឝិវបុរ ឬព្រះ បាទជ័យវរ្ម័នទី ១ ។

ចំណែកនៅក្នុងអត្ថបទដែលយើងកំពុងសិក្សានៅបន្ទាត់ទី ១២, ១៣

(១) cf, IC. Volume IV page 59-62, Paris 1952

(២) : cf, IC. Volume IV, page 58, Paris, 1952

ឃើញចារឹកគោរពម្យងាររបស់ព្រះនាងជ័យទេវីដែរគឺ « ធូលិជេង៏ វ្រះកំម្រតាង៏អញ ប្រសាទ តរអជិមហាវិក្រាន្តកេសរី » ។

បញ្ហានេះបានញ៉ាំងឱ្យការកំណត់កាលបរិច្ឆេទនៃសិលាចារឹកកាន់តែ សុក្រឹត្យថែមទៀត ហើយយើងក៏លែងស្រពិចស្រពិលទៀតក្នុងការដែលហ៊ានអះ អាងថា វាត្រូវបានចារឹកក្នុងរាជ្យព្រះនាងជ័យទេវី ។

ជាបន្តទៅទៀត យើងសាកល្បងធ្វើការសិក្សាបកស្រាយ ឆ្លុះបញ្ចាំងនូវ លក្ខណៈប្រវត្តិសាស្ត្រ ដែលជាអត្ថន័យដ៏មានសារសំខាន់នៃសិលាចារឹកទាំងពីរ ។

*សិលាចារឹកទី ១* ថ្វីត្បិតមិនបាន បង្ហាញនូវការចូលរួមចំណែកកសាងពី សំណាក់ព្រះរាជា ប៉ុន្តែអ្នកកសាងជាព្រះអង្គម្ចាស់ ឬព្រះអង្គម្ចាស់ក្សត្រិណាមួយនៃ រាជវង្សានុវង្ស ។

តាមរយៈនរនាមមួយចំនួន បង្ហាញនូវវាក្យស័ព្ទ ដែលគេប្រើប្រាស់នា សម័យកាលនោះ ជាងនេះទៀតវាក្យស័ព្ទដែលជានរនាមទាំងនេះ ឆ្លុះបញ្ចាំងនូវ លក្ខណៈប្រវត្តិសាស្ត្រ ។ ដូចជាពាក្យថា ៖ កុ បលិហដ្ឋ កុ អរស៊ [ កុ ] វិនាសបន្ទុំ, វាវងាមនេ្យាតិដែលពាក្យ « វងាមនិសោតិ ៖ ឈ្មោះវងាដែលមានរួចហើយ » ។ ចំណែកនរនាមមួយទៀតថា វាវងាអញ្ចកាលអសន្ន ដែលពាក្យថា « វងា » គឺជា ឈ្មោះ ក្ញុំបំរើជាបុរស ឯពាក្យ « អញ្ចកាលអសន្ន » ចង់បញ្ជាក់នូវព្រឹត្តិការណ៍មួយ ប្រកបដោយសន្តិសុខ ហើយម្ចាស់របស់ឈ្មោះវងានេះ មានអនុស្សាវរីយ៍បែបណា មួយជាមួយគ្នា ។ ពីព្រោះថា នៅក្នុងអត្ថបទនេះ ឈ្មោះអ្នកបំរើប្រុសមានដល់ទៅពីរ ដូចគ្នា « វងា » ដូច្នេះ ដើម្បីសំគាល់ថា ជាមនុស្សផ្សេងពីគ្នា គេត្រូវតែបន្ថែមនូវ វាក្យស័ព្ទសំគាល់ចុងក្រោយ ។

រីឯ *សិលាចារឹកទី ២* ធ្វើឱ្យយើងដឹងថា ស្ថាបនកម្ម ដើម្បីឧទ្ទិសដល់ព្រះ អាទិទេព ដោយសារមានអាជ្ញាព្រះមហាក្សត្រ ហើយនិងអំណោយនានារបស់ពួក

មន្ត្រីដល់ព្រះវិហារ « មកអំពីមាន » ព្រះមហាក្សត្រយាងទៅកាន់ស្ថានព្រះសិវ គឺព្រះមហាក្សត្រចូលទិវង្គត ។

ដូចមានឃ្លាមួយថា : « វហូតមនិវ្រះកំប្រតាងិអញ តទៅឝិវបុរ » [១]

ចំពោះស្ថាននាម ធ្វើឱ្យគេដឹងបានអំពីស្ថានភាពភូមិសាស្ត្រនៃតំបន់ជុំវិញ មានដូចជា ទួល ( វ្នំ ) ស្ទឹង បឹង ស្តុក ព្រៃ ( វ្រៃ ) ។ ដីអំណោយដល់ព្រះវិហារមានចំនួន២ ស្តុក ( មានន័យប្រហាក់ប្រហែលបឹង ) [២] មានចំនួន៣ ស្រែស្ទឹងមានចំនួន២ ទួលមួយ ។

តាមរយៈស្ថាននាមនៃទីកដី អំណោយ ទាំងនេះបង្ហាញឱ្យឃើញនូវទីទួលទំនាបដ៏ធំធេងព្រមទាំងបឹងជាច្រើននៅជុំវិញតំបន់វត្តព្រៃវែងសព្វថ្ងៃ ។ ម្យ៉ាងទៀតមានស្ថាននាមមួយទៀតឈ្មោះស្រែត្រើយវ្រៃក្រាយ ដែលមានន័យត្រើយនៃព្រៃដ៏ធំ ។ ពាក្យថាព្រៃដ៏ធំ ( a huge forest ) តើវានេះនៅឯណា ?

សព្វថ្ងៃនេះ យើងមិនអាចរកឃើញទីតាំងបឹង និងព្រៃទាំងនោះឃើញឡើយ ។ ប៉ុន្តែបើយើងសាកសួរចាស់ៗ នៅក្នុងតំបន់នេះ យើងនឹងបានដឹងថា តំបន់នេះពីដើមឡើយត្រូវលិចទឹកជារៀងរាល់ឆ្នាំ កន្លែងដែលគេចផុតពីជំនាន់ មានតែតាមទួលនានាជាពិសេសកន្លែងអាសនៈគោរពបូជានេះឯង ។

នៅរដូវទឹកឡើង បរិស័ទអាចឆ្លងពីអាសនៈមួយទៅអាសនៈមួយបានដោយប្រើទូក ។ កាលពីវត្តព្រៃវែងនៅជាឈ្មោះវត្តអង្គចក នារដូវភ្ជុំបិណ្ឌ ឬពិធីបុណ្យផ្សេងៗទៀត ព្រះសង្ឃនិងបរិស័ទត្រូវតែឆ្លងទូក ដើម្បីមកកាន់ទីអាសនៈបុរាណដែលតាំងនៅត្រង់ម្តុំព្រះវិហារសព្វថ្ងៃ ។ ហេតុនេះហើយទើបវត្តព្រៃវែងក៏មានទូកងមួយ ដូចជាវត្តនានាតាមមាត់ទន្លេ ឬមាត់បឹងដូចនោះដែរ ។ ទូកនោះ ទើប

---

(១) ទស្សនៈបណ្ឌិត ឡុង សៀម នៅគេហដ្ឋានរបស់លោកថ្ងៃទី ២៣ សីហា ១៩៩៦ (ឆ្នាំជូត)

(២) មេរៀនរបស់បណ្ឌិត ឡុង សៀម « ស្ថាននាមវិទ្យា » Toponymies.

តែត្រូវបានបរិស័ទកប់ចោលជាមួយសពដ៏រីនាទសវត្សឆ្នាំ ១៩៧០ ប៉ុណ្ណោះ ។

នាមស្រែមួយទៀតក៏នៅរក្សារហូតដល់សព្វថ្ងៃនេះដែរ ដូចជាស្រែកន្ទួត ( យើងអះអាងថាជាឈ្មោះ ស្រែកន្ទួចក្នុងសិលាចារឹក ) និង ស្រែកន្តក់ ស្រែស្ទឹង ( នាមនេះនៅក្នុងសិលាចារឹកពីរគឺ ស្រេច្ចិង៏បិង៏បោញ៊ជ្រៅ និង ស្រេច្ចិង៏មំសារិ ) ។

ចំណែកឈ្មោះវៃ្រក្រាយ៉ គឺប្រហែលជាត្រូវគ្នានឹងព្រៃដែលលាតសន្ធឹងលើទួលនៃភូមិករសព្វថ្ងៃសណ្តូកទៅទិសខាងលិចជាប់នឹងជើងភ្នំនៃខេត្តកំពង់ស្ពឺ ។ ព្រៃនេះ នៅសម័យសង្គមរាស្ត្រនិយមពិសេសសម័យអាណានិគមបារាំងមិនទាន់បាត់បង់នៅឡើយទេ ហើយកម្រមានមនុស្សម្នាដើរកាត់ណាស់ ជាងនេះទៀតពេលថ្ងៃរសៀលម៉ោង ៣ ឬ ៤ តំបន់នេះ ត្រូវងងឹតដូចជាពេលព្រលប់ ។ គេបដ្ឋានរបស់អ្នកស្រុកមានតាំងនៅតែជាយព្រៃប៉ុណ្ណោះ (១) ។

ម្យ៉ាងវិញទៀតឈ្មោះវត្តព្រៃវែងត្រូវបានគេប្រតិស្ថានឡើងបន្ទាប់ពីព្រៃដ៏ធំនេះឈានទៅរកភាពបាត់រូបរាង ។ ប្រហែលមិនមែនជាការចៃដន្យទេមើលទៅដែលអ្នកស្រុកនេះគេបានផ្លាស់ប្តូរឈ្មោះ « វត្តអង្គចក » មកជា « វត្តព្រៃវែង » វិញ ។ នេះគឺជារបត់ប្រវត្តិមួយដែលអ្នកភូមិនៅតំបន់នេះចង់រក្សាទុកអនុស្សាវរីយ៍នៃស្ថានភាពភូមិសាស្ត្រពីធម្មជាតិមួយ ។ វាគឺជាភស្តុតាងមួយនៅក្នុងប្រវត្តិសាស្ត្រ ហើយព្រឹត្តិការណ៍បែបនេះក៏មិនមែនមានតែនៅទីនេះមួយដែរ ពោលគឺស្ទើតែពាសពេញដែនដីខ្មែរបុរាណ និងបច្ចុប្បន្នដែលស្ថាននាមបានបង្កប់នូវព្រឹត្តិការណ៍ប្រវត្តិរបស់ខ្លួន ។

ផ្នែកជំនឿសាសនា ៖ សង្កេតឃើញមានការវិវត្តន៍ពីប្រពៃណីគោរពពហុទេវ ( ព្រះសិវ និងក្រុមគ្រួសារ ) មកឯកទេវ ដូចមាននៅក្នុងសិលាចារឹកទី ១

(១) ពុទ្ធដីកាព្រះសង្ឃ នាម ឃុំ ឈុន និងសំដីឧបាសក ឧបាសិកាជើងវត្ត និទាននៅល្ងាចថ្ងៃ ០៧ សីហា ១៩៩៦ វេលាម៉ោង ៤ ៖ ៣០ ល្ងាច

និយាយពីការស្ថាបនាព្រះវិហារ អាសនៈអាទិទេពសំរាប់ព្រះត្រីចណ្ឌកាត្យាយិនី ជាមហេសីរបស់សិវ ព្រះមហាគណបតី គឺព្រះគណេស ទេវដែលមានខ្លួនមនុស្ស និងក្បាលជាក្បាលដំរីជាបុត្ររបស់ព្រះសិវនិងព្រះត្រីអំវ្រាតកេត្វរ ( ដូចគ្នានឹងត្រីអំម្រាតកេត្វរ ) គឺជាឈ្មោះមួយក្នុងចំណោមឈ្មោះទាំង ៣០ របស់ព្រះសិវ ។

ចំណែកសិលាចារឹកទី ២ និយាយអំពីការកសាងព្រះវិហារឧទ្ទិសចំពោះអាទិទេពត្រីតិលកេត្វរ តែមួយគត់ ហើយអាទិទេពនេះក៏ជាឈ្មោះមួយក្នុងចំណោមឈ្មោះទាំង ៣០ របស់ព្រះសិវដែរ ។

សព្វថ្ងៃនៅខេត្តព្រៃវែងបានបន្សល់ទុកនូវស្នាបប្រណាល គឺជាទំរ (ស្នូក) សិវលិង្គដែលគេតែងនិយមហៅថា « យោនីឧមា » ចំនួន ៩ ក្នុងនោះ មានមួយធំជាងគេ ។ តាមធម្មតាស្នូកប្រណាលមួយគឺ សំរាប់ដាក់ក្នុងប្រាង្គប្រាសាទមួយ ដូច្នេះបើស្នូកនេះដល់ទៅ ៩ គឺពិតជាសំរាប់ប្រាង្គប្រាសាទ ៩ ដែរ ។

ម្យ៉ាងទៀត ប្រជារាស្ត្រខ្មែរនៅសម័យនោះបានជឿថា ក្រោយពេលចូលទិវង្គតព្រះបាទជ័យវរ្ម័នទី ១ នឹងយាងទៅកាន់ស្ថានព្រះសិវ ព្រោះព្រះអង្គគឺជាសាសនិកសិវនិយម ឬសិវសាសនូបត្ថម្ភ ។

នេះគឺជាសក្ខីភាពនៃប្រពៃណីនិរន្តរភាព ពីសម័យហ្វូណាន ចេនឡា អង្គរ និងក្រោយអង្គរដែលប្រជារាស្ត្រខ្មែរធ្វើបុណ្យដាក់ទាន កសាងបូជនីយដ្ឋាន ទីសក្ការៈបូជា ហើយតោងវេរនូវទ្រព្យសម្បត្តិផ្សេងៗ សំរាប់ជាមូលនិធិនៃសមិទ្ធិផលរបស់ខ្លួន ព្រមទាំងផ្ទេរក្ញុំបំរើសំរាប់ធ្វើការថែរក្សា និងបង្កបង្កើនផលសំរាប់ចិញ្ចឹមជីវភាពនៅទីនោះផង ។

ហេតុនេះហើយទើបគេសង្កេតឃើញវត្តអារាមពីសម័យនោះ និងសម័យក្រោយៗ មកទៀត គឺជាស្ថាប័នស្វយ័តមួយ ។

ដោយសារការរៀបរាប់អំពីស្ថាននាមដែលជាអំណោយសំរាប់វត្តអារាម

នេះហើយធ្វើឱ្យយើងដឹងអំពីវិសាលភាពនៃទឹកដីជាកម្មសិទ្ធ ។

តាមរយៈការប្រៀបធៀបជាមួយសិលាចារឹកមួយផ្ទាំងទៀត ដែលរកឃើញនៅវត្តសំបួរក្នុងតំបន់ស្ទឹងមានជ័យសព្វថ្ងៃឃើញឈ្មោះអ្នកធ្វើអំណោយ និងអាទិទេពដែលគេគោរពបូជា ព្រមទាំងស្ថាននាមមួយចំនួនទៀតបញ្ជាក់នូវភាពជាប់គ្នានៃព្រំប្រទល់ទឹកដីកម្មសិទ្ធរបស់វត្តអារាមទាំងពីរ ។

ឧទាហរណ៍ : សិលាចារឹកសំបួរ K664 (១) និយាយអំពីអំណោយរបស់ម្រតាញកុមារស្វាមិដល់អាទិទេព ត្រីតិលកេត្វរ និងអំណោយរបស់មន្ត្រីអភិជនដទៃទៀត រីឯស្ថាននាមមួយចំនួនដែលជាអំណោយរបស់វត្តអារាមមានដូចជា ស្រែវ្រៃក្រាយ៉, ស្រែ ប្រសានិ និងស្ថាននាមវះវុណ៌ា ចំណែកខាងសិលាចារឹកវត្តព្រៃវែងវិញមានស្ថាននាមបីនេះដែរ គឺស្រែត្រោយ៉វ្រៃក្រាយ៉, ស្តុកិកន្លេង៑ប្រសានិ និងស្រែវះវុណ៌ា ។ បើយើងធៀបទៅនឹងទីតាំងបច្ចុប្បន្ន ។ ស្ថាននាមបង្ហាញជូនខាងលើនេះសឱ្យឃើញថា ទឹកដីអំណោយនៃទីសក្ការៈទាំងពីរ ពិតជាជាប់ព្រំប្រទល់គ្នា ហើយទំហំរបស់វាវិញធំធេងណាស់ ។

ផ្នែកអក្សរសាស្ត្រ : ក៏មានការអភិវឌ្ឍន៍ខុសប្លែកគ្នាច្រើនដែរទាំងតួអក្ខរា និងភាសា

តួអក្ខរាសិលាចារឹកទីមួយមានលក្ខណៈ បុរាណជាង ជើងវែងៗ សក់ស្តួចកវែងៗ

ភាសាសង្កេតឃើញមានការវិវត្តន៍ច្រើនដូចជា :

គុ៎ gui > គិ gi = គី, ទ្រោង៑ droṅ > ទោង៑ doṅ ( > ទង daṅ: ទាង dāṅ > ) = ទាំង

វ្រះកំម្រតាង៑អញ vraḥ kaṃmratāṅ añ > ធូលិជេង៑វ្រះកំម្រតាង៑

---

(១) cf. Inscription du Cambodge par G. Coedés Vol V, 69, Paris 1953 op cit

អញ dhūlijeṅ vraḥ kamṃratāṅ añ ៖ ព្រះមហាក្សត្រ ( គោរមងារ )

អត្ថបទឃើញលាយឡំនូវពាក្យសំស្ក្រឹតជាច្រើនសំរាប់បំពេញនូវកង្វះខាតនៃភាសាខ្មែរ រីឯវាក្យស័ព្ទនរនាម និងស្ថាននាម ក៏ដូចគ្នានេះដែរដូចជាពាក្យ ៖ បរិចារក, កុមារស្វាមិ, គ្រុតកីត្តិ, មហាវិក្រាន្តកេសរិ, ចំសារិ, សុវណ្ណលិង្គជាដើម ។

អត្ថបទក៏បានយកពាក្យសំស្ក្រឹតមួយចំនួនដែលភាសាខ្មែរសម័យនោះមានដែរមកប្រើដូចជា « បុណ្យ ឬបុន្យ » ដែលមានន័យដូចគ្នានឹង « អំណោយ »

« ប្រសាទ » ដែលមានន័យដូចគ្នានឹង « រាជអំណោយ » ឬ « រាជ.ប្រទាន »

« មធ្យម ឬមទ្ធ្យម » ដែលមានន័យថា « កណ្ដាល » ជាដើម ។

កាលបរិច្ឆេទ នៃសិលាចារឹកសម័យមុនអង្គរភាគច្រើនតែងតែចារជាភាសាសំស្ក្រឹត ។ ប៉ុន្ដែ សិលាចារឹកនេះបែរជាចារជាលេខវិញ តែគួរឱ្យស្ដាយដោយសារលេខនេះមិនច្បាស់ មិនអាចឱ្យយើងបានសន្និដ្ឋានជាក់លាក់ គ្រាន់តែថាប្រហែលជាឆ្នាំ៧០៣ គ.ស. ។ ម្យ៉ាងទៀត វាក្យស័ព្ទភាសាខ្មែរមួយចំនួនថ្មីៗ មិនអាចឱ្យយើងយល់ន័យបានដូចជា « មុហ្វានិ, បុមង៉ិ, អំលចិ, ជ្រញែ, វះរុណ៌, តំបះ » ។

សិលាចារឹកទាំងពីរនេះ ចារជាភាសាខ្មែរ អក្សរខ្មែរ ប៉ុន្ដែមានតំលៃជាប្រវត្តិសាស្ត្រមិនចាញ់អត្ថបទជាភាសាសំស្ក្រឹត ដែលអ្នកសិក្សាស្រាវជ្រាវបារាំងចាត់ទុកថា ជាអត្ថបទពិសិដ្ឋដ៏មានសារៈសំខាន់នោះឡើយ ។ អត្ថបទទាំងពីរនេះយ៉ាងហោចណាស់មានផ្ដល់ពតិមានពីព្រះសកម្មភាព និងសកម្មភាពរបស់ព្រះមហាក្សត្រមន្ត្រីៗ និងជីវភាពរបស់ប្រជារាស្ត្រខ្មែរផង ។

ម្យ៉ាងទៀត អត្ថបទបង្ហាញឱ្យឃើញថា វត្តអារាមនៃព្រាហ្មណ សាសនាគឺជាមជ្ឈមណ្ឌលវប្បធម៌ និងអភិវឌ្ឍន៍ជនបទ ដែលត្រូវត្រាយឡើងថ្មីៗ ដោយព្រះមហាក្សត្រ ព្រមគ្នានឹងដែនដីនៃទីប្រជុំជនជាប្រវត្តិសាស្ត្រ ។

# សេចក្ដីសន្និដ្ឋាន

ដោយវត្តព្រៃវែងជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់ សិលាចារឹកបីផ្ទាំងចារក្នុងរជ្ជកាលស្ដេចបីអង្គ ស្នូកប្រណាលសល់រហូតសព្វថ្ងៃដល់ទៅ ៩ ឃើញថាទីនេះពីសម័យនោះ គឺជាកន្លែងទេវស្ថានដ៏ធំមួយ ។ បើយើងក្រឡេកមើលទៅតំបន់ប្ញជនីយដ្ឋាន ឬទេវស្ថានធំៗនៅសម័យកាលជាមួយគ្នានោះឃើញថា វត្តព្រៃវែងស្ថិតនៅកណ្ដាលគេ ។ ដូច្នេះក្នុងរាជដំណើររបស់ព្រះមហាក្សត្រពីរាជធានីឥសានបុរ មកធ្វើសក្ការៈបូជាចំពោះព្រះអាទិទេពនៅតំបន់ប៉ែកខាងត្បូងដូចជា ភ្នំប្រសិទ្ធិ ស្រែអំពិលទន្លេបាទី ភ្នំតាម៉ៅ ប្រាសាទនាងខ្មៅ ភ្នំជីសូរ អង្គរបុរី និងភ្នំបាយ៉ង់ ( នៅប៉ែកខាងក្រោម ) ព្រះអង្គពិតជាត្រូវឈប់សំណាក់ធ្វើពិធីបូជាដូចគ្នានេះដែរនៅទេវស្ថាននៃវត្តព្រៃវែង ។

អត្ថបទសិលាចារឹកនេះ បានបង្ហាញនូវលក្ខណៈនីយកម្មផ្នែកភាសាខ្មែរដោយមិនពឹងផ្អែកទាំងស្រុងទៅលើភាសាសំស្ក្រឹត ។

ជាចុងក្រោយនេះ យើងមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើទីស្ថានភូមិករនិងទីប្រជុំជនជាច្រើនដែលគេបានរកឃើញក្នុងអំលុងពេលនៃសតវត្សទី ៧ នៅតំបន់ជុំវិញជិតៗភ្នំពេញសព្វថ្ងៃដូចជា នៅវត្តសំបួរ ជើងឯក ព្រៃកល្បៀប ទួលក្រសាំងតាខ្មៅ ស្រែអំពិល ភ្នំប្រសិទ្ធ អង្គស្នួល ហើយចុងក្រោយនេះ គឺវត្តព្រៃវែងដែលប្រការនេះ ធ្វើឱ្យយើងសន្និដ្ឋានថា តំបន់ភ្នំពេញសព្វថ្ងៃពិតជាមានទីប្រជុំជន ឬយ៉ាងហោចណាស់ត្រឹមភូមិករអ្នកស្រុកសាមញ្ញ រស់នៅ ចាប់តាំងពីសម័យកាលជាមួយគ្នានោះជាមិនខាន មិនមែនតំបន់នេះទើបតែមានភូមិករមកដល់សតវត្សទី XV រជ្ជកាលព្រះបាទពញាយ៉ាតនោះទេ ។

# BIBLIOGRAPHIE

## ឯកសារពិគ្រោះ

1. Georges Coedès " Inscription du Cambodge " Vol.I Paris 1951
2. G. Coedès " Inscription du Cambodge " Vol. II Paris1951
3. G. Coedès " Inscription du Cambodge " Vol. III Paris 1951
4. G. Coedès " Inscription du Cambodge " Vol. IV Paris 1952
5. G. Coedès " Inscription du Cambodge " Vol. V Paris 1953
6. G. Coedès " Inscription du Cambodge " Vol. VI Paris 1954
7. G. Coedès " Inscription du Cambodge " Vol. VIII Paris 1966
8. Long Seam « ឯកសារបង្រៀននៅមហាវិទ្យាល័យប្រវត្តិវិទ្យា ជំនាន់ទី ១៣ និងទស្សនៈនៅក្រៅពីម៉ោងបង្រៀន » ១៩៩៤ - ៩៦
9. Monier monier Willams " A SANSKRIT ENGLISH DICTIONARY "
10. Oxford Advanced " Learner's Dictionary 1992 " Best seller New Edition
11. P. H. Collin " HARRAP'S MINI ENGLISH DICTIONARY " G. B. 1993.
12. Rhys Davids and Stade "Pali-English Dictionary" Palitext Society

13. Saveros Pouv " Dictionaire vieux Khmer-Français-Anglais "
14. Theng Leang " English-Khmer Dictionary " 1995
15. ត្រឹង ងា « ប្រវត្តិសាស្ត្រខ្មែរ » ភ្នំពេញ គ.ស ១៩៧៣
16. នួន ប៊ុត « វចនានុក្រមខ្មែរ » ការផ្សាយរបស់បណ្ណាគារ នួន ប៊ុត ភ្នំពេញ ១៩៥៤
17. បទសម្ភាសន៍ជាមួយចៅអធិការវត្តព្រៃវែងព្រះនាម ឈុំ ឈុន និង ឧបាសក ឧបាសិកាចំណុះជើងវត្តនៅថ្ងៃទី ៧ សីហា ១៩៩៦
18. ពុទ្ធសាសនបណ្ឌិត្យ « វចនានុក្រមខ្មែរ » បោះពុម្ពលើកទី ៥ តាមច្បាប់ដើមឆ្នាំ ១៩៦៧

# អំពីល័ក្ខខ្មែរ

ល័ក្ខខ្មែរ ជាឈ្មោះជ័រខះរឹង គឺជ័រដែលកើតអំពីសត្វល្អិតពួកមួយ មានសម្បុរក្រហម ។ ល័ក្ខខ្មែរ ត្រូវបានគេយកទៅប្រើការជ្រលក់សូត្រ, អំបោះ ត្បាញធ្វើហូល ផាមួង សារុង ក្រម៉ា ជាដើម ។

សូមលើកយកបទពិសោធន៍ធ្វើល័ក្ខខ្មែរ តាមរយៈការជួបសម្ភាសន៍ដោយផ្ទាល់ពីគ្នា ជាមួយលោកតា គីម ផង់ អាយុ ៨០ ឆ្នាំ នៅភូមិខ្វាវកណ្ដាល ឃុំព្រៃអំពក ស្រុកគិរីវង្ស ខេត្តតាកែវ និងលោកតា ហាក់ នាក់ អាយុ ៦២ ឆ្នាំ នៅភូមិព្រៃបន្ទាំ ស្រុកបន្ទាយមាស ខេត្តកំពត ជូនលោកអ្នកអានក្រឡេមើលអតីតកាល ដើម្បីយល់បច្ចុប្បន្ន ។ លោកតាទាំងពីរនាក់ បានអធិប្បាយរៀបរាប់ប្រាប់យើង ដូចតទៅនេះ :

១/ អំពីរបរចងល័ក្ខខ្មែរ :

*ក. ការជ្រើសរើសពូជ :* ពូជល័ក្ខខ្មែរ ត្រូវបានជ្រើសរើសយក ក្នុងចំណោម*ស្រម៉ល័ក្ខជុំកន្លង់* (១) ដែលមាន :

- ទំហំថ្លោស សាច់ក្រាស់ល្អ,
- នៅស្រស់ថ្មី ( មិនបាលឱ្យត្រូវកំដៅយូរថ្ងៃ )
- មិនបែកបាក់ជាកំណាត់
- មិនទុកយូរលើសខួប ។

*ខ. អំពីការចងល័ក្ខ ឬបន្ទំល័ក្ខ :* គេយកស្រម៉ល័ក្ខជុំកន្លង់ គឺស្រម៉ល័ក្ខដែលនៅមានសត្វល្អិតជាមេ ដាក់ក្នុងសំបកកាតំស្លឹកត្នោត, ឬក្នុងព្រួលឫស្សីប៉ោង

(១) ស្រម៉ល័ក្ខដែលដុះព័ទ្ធស្រោបជុំវិញមែកឈើ ។

កណ្តាល ចងភ្ជាប់មែកឈើរស់ មានដើមសង្កែ, ដើមត្រាង, ដើមស្នួល ជាដើម ដើម្បីឱ្យមេនោះចេញមកវារលើមែកឈើ កកើតបានជាស្រម៉ល័ក្ត តទៅទៀត ។

ដើមឈើទាំងនេះ ត្រូវនៅមិនឆ្ងាយពីភូមិ ដើម្បីងាយស្រួលរាំងមើលថែទាំ ។ ដើមឈើដែលត្រូវចងល័ក្តនោះទៀត ត្រូវមានមែកច្រើន, មិនត្រូវឱ្យមានអង្រ្កង និងត្រូវមានសញ្ញាហាមឃាត់ ដើម្បីកុំឱ្យអ្នកស្រុកកាប់ឆ្ការដើមឈើដែលចងល័ក្តនោះ ។

*ត. ពេលវេលា និងការកកើតនៃល័ក្តខ្មែរ :* តាមធម្មតា គេចងល័ក្តនៅរដូវប្រាំង ។ នៅខែជេស្ឋ ឬអាសាឍ មេជីវិត [(១)] ដែលសិងនៅក្នុងស្រម៉ល័ក្តនេះ វារចេញពីសំបកកាតំ ឬពីព្រលឫស្សី ទាំងខ្សែៗ បណ្តើរគ្នាទៅតាំងទីនៅតាមមែកផ្សេងៗ នៃដើមឈើនោះ ។ តាមផ្លូវដែលវាវារនោះ វាបន្សល់ទុកនូវស្នាមពន្លឺ ចាំងដូចទឹកប្រាក់ ។ គឺស្នាមពន្លឺនេះហើយ ដែលនឹងបង្កបឱ្យកើតទៅជាស្រម៉ល័ក្ត ។ ក្នុងរយៈពេលជាច្រើនខែកន្លងមក មេជីវិតសត្វល្អិតៗទាំងនេះ បង្កកើតបានជាស្រម៉ល័ក្តយ៉ាងច្រើន នៅពាសពេញគ្រប់មែកឈើដែលចងល័ក្តនោះ ។

២/ អំពីការបេះល័ក្ត :

ក្នុងរយៈពេលប្រមាណពី ៧ ខែឡើងទៅ ល័ក្តខ្មែរបានល្អតលាស់ធំធាត់ អាចបេះយកទៅប្រើការបាន ។ គេបេះល័ក្តនៅពេលដែលគេទំនេរពីការងារច្រូតកាត់ បោកបែន ។ ល័ក្តបេះហើយថ្មីៗ មានពណ៌ក្រហមក្រម៉ៅ ស្រស់ល្អណាស់ ។ គេយកល័ក្តស្រម៉ ទៅចាក់លើកន្ទេល ហាលថ្ងៃឱ្យស្ងួតល្អ ។

អ្នកចិញ្ចឹមល័ក្ត តែងរក្សាទុកពូជល័ក្តជុំកន្លងល្អៗ នៅលើមែកឈើនោះ

---

(១) គេអាចមើលឃើញមេជីវិតនោះដោយភ្នែកទទេ ខ្លួនវាមានទ្រង់ទ្រាយប្រហែលនឹងស្រះមោច តែតូចៗណាស់ ។ វាមានពណ៌ស តែពេលញីចឱ្យបែក គេនឹងឃើញពណ៌ក្រហម ។

ពីបួនទៅប្រាំមែក ដើម្បីឱ្យវាបង្កបង្កើតល័ក្តនៅឆ្នាំបន្ទាប់ទៀត ។ អ្នកដែលមានល័ក្តច្រើនលើសពីសេចក្តីត្រូវការក្នុងគ្រួសារ គេអាចលក់ទៅឱ្យអ្នកជិតខាង ឬលក់ទៅឱ្យឈ្មួញនៅទីផ្សារ ។

៣/ អំពីការស្ងោររំងាស់ចំរាញ់យកជ័រល័ក្ត ៖

ដើម្បីជ្រលក់ស្បូត្រ, អំបោះ ឬក្រណាត់ផ្សេងៗបាន គេត្រូវស្ងោររំងាស់ចំរាញ់យកជ័រល័ក្ត ។ ដំបូង គេយកស្រមំល័ក្តដែលបាលស្ងួត ទៅបុកបំបែកក្នុងត្បាល រួចហើយគេយកទឹកដាំពុះទៅចាក់ក្នុងត្បាល់ ។ ធ្វើយ៉ាងនេះស្រម៉ល័ក្តនោះក៏ក្លាយទៅជាទន់ជ្រាយដូចម្សៅក្របៅនំបញ្ចុក ។ គេយកអង្រែទៅបុក ជ្រំ ញៀតស្រម៉ល័ក្តនោះ ឱ្យចេញជាតិជ័រល័ក្តពីក្នុងបន្ទប់តូចៗនៃស្រម៉ល័ក្ត ។ គេបុកញីញៀតនឹងអង្រែ ប្រែត្រឡប់ចុះឡើង ទាល់តែសព្វកន្លែង ធ្វើយ៉ាងណាឱ្យជាតិជ័រល័ក្តនោះចេញអស់មកលាយជាមួយទឹកក្នុងត្បាល់ ឡើងពណ៌ក្រហមក្រម៉ៅ ។ បន្ទាប់មកគេដងទឹកល័ក្តនេះ យកទៅដាក់ក្នុងថ្លាងដែលមានសាច់ជូរ និងស្លឹកជើងគោ ។ គេដាក់សាច់ជូរ និងស្លឹកជើងគោនេះ ដើម្បីឱ្យល័ក្តកាន់ជាប់ល្អ ។ រួចហើយទើបគេយកស្បូត្រ ឬអំបោះ ទៅជ្រលក់ក្នុងទឹកល័ក្តនោះ ។

៤ / អំពីកាកល័ក្ត និងផលប្រយោជន៍របស់វា ៖

កាករបស់ល័ក្តស្រម៉ដែលស្ងោររំងាស់អស់ជាតិហើយ, គេយកទៅប្រើការបានច្រើនយ៉ាងគឺ ៖ ប្រើក្នុងពិធីបុកល័ក្ខធ្វើធ្មេញបំពេញល័ក្ខណ៍ ក្នុងពេលរៀបអាពាហ៍ពិពាហ៍ ឬចូលម្លប់, ប្រើសំរាប់បិទ ឬភ្ជរភ្ជាប់អ្វីផ្សេងៗ និងប្រើធ្វើជាឱសថផឹកព្យាបាលជំងឺគ្រាំក្នុងទៀតផង ។

បច្ចុប្បន្ននេះ នៅតំបន់ជនបទស្រែចំការខ្មែរយើង គេលែងឃើញមាន

ធ្វើល័ក្តខ្មែរ គេលែងប្រើកាកល័ក្តសំរាប់បិទនង្គ័លទៀតឡើយ ។ ក្មេងជំនាន់ក្រោយ មិនស្គាល់ល័ក្តខ្មែរទេ ហើយក៏ពុំដឹងថា គេប្រើវាសំរាប់ធ្វើអ្វីផង ។ យើងក៏ដឹងដែរថា វត្ថុមួយ វាសមស្របតែនឹងពេលវេលាមួយ ឥឡូវពេលវេលាបានដូរហើយ ។ សព្វថ្ងៃនេះ ល័ក្តវិទ្យាសាស្ត្រផលិតនៅបរទេស បានហូរជោរជន់ចូលមកស្រុកយើងយ៉ាងសំបូរហូរហៀ ។ ខ្មែរយើងបោះបង់ល័ក្តរបស់ខ្លួន ហើយបែរមកប្រើល័ក្តវិទ្យា-សាស្ត្រនេះវិញ ដែលគេយល់ថា មិននាំឱ្យមានការរំពល់រវល់ធ្វើ នាំខាតពេលឥតអំពើ ។ តែទោះជាយ៉ាងណាក្តី កុលបុត្រកុលធីតាខ្មែរ គប្បីស្វែងយល់នូវអ្វី ដែលចាស់ទុំយើងធ្លាប់បានប្រើប្រាស់ក្នុងជីវភាពរស់នៅក្នុងយុគសម័យរបស់គាត់ ដើម្បីឆ្លុះបញ្ចាំងមើលនូវការវិវត្តន៍ប្រែប្រួលរបស់សង្គមខ្មែរយើង ពីជំនាន់មួយទៅជំនាន់មួយ ។ យើងមិនអាចយល់បច្ចុប្បន្ន និងអនាគតបានទេ ប្រសិនបើយើងមិនស្គាល់អតីតកាល ។

ដោយ ម៉ៀច ប៊ុណ្ណ
ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ
នៃពុទ្ធសាសនបណ្ឌិត្យ

# ទំនៀមទម្លាប់ និងរឿង ទាក់ទងភ្នំក្រោម

ភ្នំក្រោមបច្ចុប្បន្ន ជាទីតាំងកំពង់ផែនាវាចរណ៍នៃខេត្តសៀមរាប ។ អ្នកដំណើរទាំងឡាយអាចកត់សំគាល់ថា ខ្លួនបានទៅជិតដល់ខេត្តសៀមរាប ដោយសារគេមើលឃើញភ្នំដ៏ធំមួយ មានលក្ខណៈទំពែក ស-ខ្មៅដោយអន្លើ ព្រោះកន្លែងខ្លះមានរុក្ខជាតិដុះទ្រុបទ្រុល និងកន្លែងខ្លះជាដីរលីងពណ៌សក្បុស ។ ភ្នំនេះនៅចំពីមុខអ្នកដំណើរទាំងឡាយដែលត្រូវទៅកាន់ខេត្តសៀមរាប ។

នៅតំបន់ភ្នំក្រោមមានភូមិពីរ មួយឈ្មោះភូមិចុងឃ្នាស និងមួយទៀតឈ្មោះភូមិជើងភ្នំក្រោម ។ បច្ចុប្បន្ន អ្នកភូមិចុងឃ្នាស ក្រៅពីប្រកបរបរលក់ដូរនៅត្រង់កំពង់ផែ គេប្រកបរបរនេសាទ និងធ្វើស្រូវប្រាំងនៅលើផ្ទៃដីទំនាបលិចទឹកនៃបឹងទន្លេសាប ។ ប្រជាជនរស់នៅក្នុងភូមិនេះចំរុះជាតិសាសន៍គ្នា គឺខ្មែរប្រហែល ៤០% វៀតណាម ៣០% និងចាម ៣០% ដែលពួកសាសន៍ពីរខាងក្រោយនេះច្រើនប្រកប របរនេសាទ និងលក់ដូរបន្តិចបន្តួច ។

ចំណែកប្រជារាស្ត្ររស់នៅភូមិជើងភ្នំក្រោមវិញ ភាគច្រើនលើសលប់ជាជនជាតិខ្មែរ ជាខ្មែរដែលរក្សានូវប្រពៃណីទំនៀមទម្លាប់វប្បធម៌អង្គរពិត។ ពួកគេប្រកបរបរនេសាទ និងធ្វើស្រូវប្រាំង ដើម្បីផ្គត់ផ្គង់ជីវភាព ។ នៅរដូវទំនេរខ្លះទៀត បានប្រកបរបរជាកម្មករវាយថ្ម គាស់ថ្មលក់ ។

នៅតំបន់នេះដដែល មានវត្តចំនួនពីរ មួយគឺ វត្តជើងភ្នំក្រោម ដែលស្ថិតនៅជើងភ្នំភាគខាងជើង និងពីរគឺ វត្តខ្នងភ្នំក្រោម ។

អ្វីជាការរក្សានូវទំនៀមទម្លាប់ពីបរមបុរាណ រហូតមកដល់សព្វថ្ងៃ របស់

អ្នកស្រុកនេះ ក៏មិនខុសគ្នាពីអ្នកស្រុកនៅតំបន់ស្រះស្រង់ របាល់ និងតំបន់ផ្សេងទៀត នៅអង្គរដែរ ។

នោះគឺប្រពៃណីដ៏ប្លែកមួយនៅក្នុងពិធីរៀបមង្គលការ ដែលមានពិធីមួយចំនួនចំឡែកពីទំនៀមទម្លាប់របស់ប្រជារាស្ត្រខ្មែរនៅភ្នំពេញ កំពង់ចាម កំពង់ធំ ព្រៃវែង ស្វាយរៀង កណ្ដាល តាកែវ កំពត ។ ល ។

ពិធីអាពាហ៍ពិពាហ៍ ប្រព្រឹត្តទៅក្នុងរយៈពេលបីថ្ងៃ ឬមួយថ្ងៃ ដោយអនុលោមទៅតាមធនធានរបស់សាមីជន ។ កិច្ចផ្សេងៗក្នុងអាពាហ៍ពិពាហ៍ កូនក្រមុំ និងកូនកំលោះ ត្រូវបានរៀបពិធីកាត់សក់ដាច់ដោយឡែកពីគ្នា បង្វិលពពិលដាច់ដោយឡែកពីគ្នា ហើយនៅរាត្រីបង្ហើយនៃថ្ងៃរៀបមង្គលការ គេមានប្រារព្ធពិធីមួយទៀតហៅថា « ដេកអង្កររៀប » ពិធីនេះធ្វើដាច់ដោយឡែកពីគ្នាដែរ ចំពោះកូនប្រុសណាមិនធ្លាប់បួស និងកូនស្រីណាមិនធ្លាប់ធ្វើពិធីកោរជុក និងមិនបានចូលម្លប់ ។

ពិធីដេកអង្កររៀបមានដូចតទៅ :

អាចារ្យកាន់ពេលា បានយកត្រឡោកដូងពីរ (កាត់តូចៗ) សំពៅពីរ (ធ្វើពីត្រឡោក ឬឈើមានទំហំតូចល្មម) សំប៉ានពីរ កញ្ចប់ថ្នាំ ១៨ កញ្ចប់ (យើងមិនដឹងថានៅក្នុងកញ្ចប់នោះ មានដាក់អ្វីទេ) ខ្ចប់តូចៗប៉ុនមេដៃ ស្រោបដោយស្លឹកត្នោតក្រៀម ដេរភ្ជិតដោយអំបោះ នៅលើកញ្ចប់តូចៗនិមួយៗ មានដាក់ឈ្មោះទិសទាំង ៨ និងទិសចំកណ្ដាល ។ ទាំងអស់នេះជាសម្ភារៈសំរាប់សាមីខ្លួនម្នាក់ ។ រួចហើយអាចារ្យយកវត្ថុដូចបានរៀបរាប់ខាងលើទៅធ្វើជារង្វាល់អង្ករសរិតតាមកំណត់ : ៨០ សំពៅ, ៣០ សំប៉ាន, ៣០ ត្រឡោក, ៣០ ត្រល់ ប៉ុន្តែ នៅរង្វាល់ទី ៣០ អាចារ្យមិនចាក់អង្ករចេញពីត្រល់ទេ រួចយកស្លឹកឈូកមកបិទ ព្រមទាំងចងចិញ្ចៀនភ្ជាប់នឹងត្រល់នោះ ស៊កចូលក្នុងពំនូកអង្ករចុងក្រោយ អាចារ្យបានវាល់អង្ករដោយក្ដាប់នឹងដៃ

ទៅតាមចំនួនអាយុរបស់សាម៉ីជន រួចហើយបន្ថែមពន្លឺសមួយក្តាប់ ។ ឧទាហរណ៍ បើសាម៉ីកូនកំលោះអាយុ ៣០ ឆ្នាំ អាចារ្យត្រូវវាល់អង្ករ នឹងក្តាប់ចំនួន ៣១ ដង ។

អង្ករដែលវាល់រួចនេះ គេយកទៅចាក់ដាក់លើស្លឹកឈូកប្រាំបួនសន្លឹក ដែលមានដាក់ស្បូវជាមុន រួចគេយករង្វាស់រង្វាល់ របស់របរទាំងអស់ខាងលើមកកប់ចូលក្នុងពំនូកអង្ករ ។ បន្ទាប់មក គេវេចអង្ករ និងឧបករណ៍មួយបង្វេច អោយទៅកូនកំលោះ និងមួយបង្វេចទៀត ដែលមានរៀបចំដូចការរៀបរាប់ខាងលើ អោយទៅកូនក្រមុំ ដើម្បីយកទៅដេកពីលើ ។

វេលាដែលគេដេកអង្កររៀប ក្នុងកំលុងពេលពីម៉ោង ១០ យប់ ដល់ម៉ោង ៤ ភ្លឺ ។ លុះក្រោកពីដំណេក មុនដំបូងបង្អស់ កូនកំលោះ និងកូនក្រមុំជាសាម៉ីខ្លួន ត្រូវតែលូកដៃរាវទៅក្នុងកញ្ចប់អង្ករ ដែលខ្លួនបានដេកលើ គេចាប់ចំរបស់អ្វី យករបស់នោះ ដោយអាចារ្យហាមមិនអោយជ្រើសរើស ឬក្រឡេកមើលរបស់ទាំងនោះមុនពេលចាប់យកឡើយ ។ រីឯវត្ថុដែលគេចាប់កាន់បានមកនោះ ញ្ញាក់ នូវជោគជតារាសី ឬព្រេងវាសនាទៅតាមក្បួនទំនាយរបស់អាចារ្យ ។

គឺដូចជាគេចាប់បានសំពៅ ទំនាយថាល្អ បើបានកញ្ចប់ថ្នាំ ទំនាយថាឈឺច្រើន មិនសូវល្អ បើប៉ះចំចិញ្ចៀន ឬត្រល់ទំនាយថា អាយុវែង ។ ល ។

ការអធិប្បាយនេះ គឺជាពិធីដ៏ប្លែកមួយរបស់អ្នកស្រុកនៅតំបន់ភ្នំក្រោម ចំណែកពិធីផ្សេងៗទៀត ដែលមាននៅក្នុងមង្គលការ មិនខុសគ្នាពីទំនៀមទម្លាប់ទូទៅរបស់ជនជាតិខ្មែរទូទាំងប្រទេសដែរទេ ដូច្នេះយើងមិនបាច់និយាយក្នុងទីនេះឡើយ ។

ជាបន្តទៅទៀត យើងនឹងលើកយកប្រវត្តិទាក់ទងទៅនឹងឈ្មោះភ្នំក្រោម តាមការសិក្សាស្រាវជ្រាវពីប្រភពពតិមានបី មកបង្ហាញជូនលោកអ្នកអាន ។

ដំបូង យើងបង្ហាញជូនតាមរយៈស្នាដៃរបស់លោកព្រិន្ទបាលឯក ជា ប៊ូរ

ធ្វើការនៅការិយាល័យទី ៥ នៃអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ដែលលោកបានចុះផ្សាយ នៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយាលេខ ៣៨ (៣) ឆ្នាំ ១៩៦៦ ។

លោកថា តាមរឿងព្រេងនិទានដំណាលតៗគ្នាមកថា ក្នុងសម័យដែលព្រះរាមកសាងថ្នល់ឆ្លងកាត់សមុទ្រទៅកាន់កោះលង្កា ដើម្បីច្បាំងដណ្ដើមយកនាងសីតាពីក្រុងរាពណ៍មកវិញនោះ សេនារបស់ព្រះអង្គមានហនុមាន និងអង្គទ ជាដើម បាននាំគ្នាជញ្ជូនថ្មមកកសាងថ្នល់នេះ ដោយចាត់អោយអង្គទ និងពួកពលឯទៀតទៅជញ្ជូនថ្មមក ឯហនុមាន និងពិភេក ជាអ្នកចាំទទួលយកទៅរៀប ។

ពួកអ្នកជញ្ជូនមានកំលាំងខ្សោយ មិនអាចនឹងនាំយកថ្មអោយបានច្រើនធូនល្មមនឹងកំលាំងរបស់ហនុមាន ដែលទទួលយកទៅរៀបយ៉ាងរហ័សនោះ នាំអោយហនុមាន មានពេលទំនេរច្រើន ក៏បបួលពិភេកលេងចត្រង្គ ( អុក ឬ វែក ? ) កំដរពេលវេលាទៅ ។ នៅពេលគេបញ្ជូនថ្មមកដល់ គាត់គ្រាន់តែយកដៃឆ្វេងទៅទទួលប៉ុណ្ណោះ ម្ល៉ោះហើយអង្គទក៏ស្ដីអោយថា គេខំធ្វើការស្ទើរស្លាប់ បងឯងនាំគ្នាលេងចត្រង្គ យកតែដៃឆ្វេងមួយមកទទួលថ្ម គ្មានគិតជួយខំធ្វើការសោះ ។ ឮដូច្នេះ ហនុមានក៏ចាត់អង្គទ និងពួកពលអោយនៅចាំទទួលរៀបវិញម្ដង ខ្លួនគាត់ជាអ្នកទៅជញ្ជូនយកមកអោយ ។

ដោយហេតុហនុមាន ជាសេនាដែលមានកំលាំងខ្លាំងមហិមា មានឫទ្ធានុភាពពូកែអស្ចារ្យផង គាត់ក៏យកថ្មធំៗជាច្រើនមកចងនឹងរោមរបស់គាត់ ហើយដៃទាំង ២ ទ្រភ្នំមួយម្នាង យកមកប្រគល់អោយ ។ អ្នកចាំទទួល រវល់តែខំស្រាយយកថ្មពីរោមគាត់ មិនទាន់បានទទួលយកភ្នំពីដៃ គាត់ធុញទ្រាន់នឹងពួកគេធ្វើការយឺតពេក ក៏បោកភ្នំទៅនឹងដៃខាងឆ្វេងផ្ទប់ទៅនឹងផែនដី ដើម្បីជាការបញ្ឆោះអោយអ្នកចាំទទួល ភ្នំនោះក៏ត្រឡប់កំពូលចុះក្រោម បាតផ្ងារឡើងលើទៅ ។

ដោយមានរឿងរ៉ាវដូចពណ៌នាមកនេះ ទើបគេសន្មតហៅភ្នំនេះថា « ភ្នំ

ក្រោម » ព្រោះកំពូលធ្លាក់ទៅនៅក្រោម ហើយដោយហេតុបាតភ្នំផ្ទារឡើងលើ បាន ជាមិនសូវមានដើមឈើធំៗ ដូចភ្នំឯទៀត ព្រោះឈើធំៗដែលដុះនៅលើភ្នំនេះពីមុន ជ្រមុជធ្លាក់ចុះទៅក្រោម ត្រូវភ្នំសង្កត់អស់ទៅ ។

ចំណែករឿងព្រេងមួយទៀត ស្ដីពីប្រវត្តភ្នំនេះ ដែលបានស្រាវជ្រាវ ដោយនិស្សិតប្រវត្តិវិទ្យាជំនាន់ទី ១៣ មួយក្រុម កាលពីខែវិច្ឆិកា ឆ្នាំ ១៩៩៥ ក៏មាន ការទាក់ទងនឹងរឿងរាមកេរ្ដិ៍នេះដែរ ។ ប៉ុន្តែ ខុសប្លែកគ្នាត្រង់វត្ថុនៃសាច់រឿងដែល ធ្វើអោយកើតមានភ្នំនេះ និងបញ្ញត្តិនៃឈ្មោះរបស់វា ។

រឿងនិទាននោះនិណាលថា កាលដែលព្រះលក្សណ៍ ជាព្រះអនុជរបស់ ព្រះរាម ត្រូវរបួសដោយសររបស់ឥន្ទ្រជិត នៅពេលខ្លួនចេញច្បាំងជាមួយពួកយក្ស ជណ្ដើមយកនាងសីតាជាបងថ្លៃនោះ គ្មានថ្នាំអ្វីអាចនឹងព្យាបាលបង្កាត់សរសិល្ប៍ នេះបានឡើយ ។ ក្រោយមក ពិភេកហោរាដឹងថា មានតែពេទ្យហ្លួងរបស់ក្រុង រាពណ៍ទេ ទើបអាចមើលរបួសនេះបាន ។ ហនុមានជាសេនា ក៏ទៅលើកយក គេហដ្ឋានរបស់ពេទ្យហ្លួងនោះពីក្រុងលង្កា មកដាក់ក្នុងជំរំទ័ពរបស់ខ្លួន ដើម្បីអោយ ពេទ្យនោះព្យាបាលរបួសព្រះលក្សណ៍ ។ ពេទ្យហ្លួង ក៏ព្រមព្យាបាលអោយ តែត្រូវ អោយហនុមានជាអ្នកទៅរកថ្នាំដែលដុះនៅឆ្ងាយ ។ ក្នុងការទៅរកនេះ មិនអោយ លើសពីមួយយប់ឡើយ តែកាលណាភ្លឺ ព្រះលក្សណ៍នឹងត្រូវស្លាប់ ។ ហនុមានហោះ វឹងទៅរកភ្លាមតាមភិនភាគដើមថ្នាំដែលពេទ្យផ្ដាំ ដោយពេទ្យមិនប៉ានប្រាប់ឈ្មោះ ដើមថ្នាំនោះ ។ ចំណែកព្រះរាមព្រួយព្រះទ័យណាស់ ដោយបារម្ភក្រែងហនុមានខឹង ក៏មិនប៉ានប្រាប់ឈ្មោះដើមថ្នាំអោយត្រង់ ដូចពេទ្យហ្លដែរ ។

ជាច្រើនលើកច្រើនសារ ដែលហនុមានបេះយក ឬដកយកដើមថ្នាំទាំង ឡាយពីព្រៃភ្នំ ដែលពេទ្យបានបង្ហាញប្រាប់នោះ មិនចំមុខថ្នាំសំរាប់ព្យាបាលរបួស នោះទេ ។

ហនុមានខឹង ក៏ត្រឡប់ទៅជាលើកចុងក្រោយ ខ្វះលើកព្រៃភ្នំនោះហោះយកមកទាំងអស់ ដាក់អោយពេទ្យរើសរកខ្លួនឯង ។ ពេទ្យហ្លួង ក៏ដើរទៅកាច់ដើម « ជណ្តើរស្វា » មកផ្សំជាឱសថឡើង ។ ហនុមាននឹកហួសចិត្ត និយាយថា គ្រាន់តែដើមថ្នាំជណ្តើរស្វាប៉ុណ្ណឹង មិនព្រមប្រាប់អោយដឹងទេ ! ។ តាមពិត ពេទ្យហ្លួង និងព្រះរាម យល់ថា ហនុមានជាពូជស្វា ទើបមិនហ៊ាននិយាយឈ្មោះដើមថ្នាំដោយត្រង់ព្រោះខ្លាចហនុមានខឹង មិនប្រតិបត្តិតាមបញ្ជា ។

ព្រះរាមក៏ប្រើហនុមានអោយលើកភ្នំទាំងនោះទៅដាក់នៅកន្លែងដើមវិញ ហនុមានអនុវត្តតាមបញ្ជាភ្លាម ក៏ហោះនាំភ្នំត្រឡប់ទៅវិញ ដោយចងនឹងរោមជើង តែដោយគាត់ខ្ជិលក្នុងការធ្វើដំណើរឆ្ងាយ ក៏ស្រាយភ្នំពីរោមជើង បោះចោលទៅក្នុងសមុទ្រ ។ ប៉ុន្តែ ភ្នំនេះត្រូវដាច់ជាពីរ មួយកំណាត់ធ្លាក់ចុះមកដោយកំពូលផ្កាប់ចុះក្រោម បាតភ្នំផ្ងារឡើងលើ ហេតុដូច្នេះហើយ ទើបគេសន្មតហៅភ្នំនោះថា « ភ្នំក្រោម » ព្រោះកំពូលភ្នំធ្លាក់ចុះក្រោម ដែលភ្នំនេះគឺជាភ្នំក្រោម នៅក្នុងស្រុកសៀមរាបសព្វថ្ងៃ ។ ចំណែកភ្នំមួយកំណាត់ទៀត បានធ្លាក់ចុះទៅតាមសភាពធម្មតា ទើបគេហៅថា « ភ្នំទ្រង់បាត » ព្រោះបាតភ្នំធ្លាក់ចុះក្រោមធម្មតា ។ ភ្នំនេះ សព្វថ្ងៃនៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាបដែរ ។

ប្រវត្តិនៃភ្នំក្រោមនេះ មិនខុសពីឈ្មោះភ្នំដទៃៗទៀត នៅក្នុងប្រទេសកម្ពុជាទេ សុទ្ធសឹងមានសាវតារទាក់ទងទៅនឹងរឿងព្រេងអភិនិហារ មហិទ្ធិឫទ្ធិរបស់វីរបុរសទេព ក្នុងរឿង ដែលជាការមួយមិនអាចអោយជឿយកជាការបាន ។

រឿងរាមកេរ្តិ៍នេះជាដើម ជារឿងមួយដែលខ្មែរចម្លងពីរឿងរាមាយណៈរបស់កវីវាល្មិកិ ជាភាសាសំស្ក្រឹតរបស់ឥណ្ឌាតាំងពីរាប់ពាន់ឆ្នាំមុន គ.ស ។ ដូច្នេះប្រទេសកម្ពុជា មិនទាន់បានកកើតជារដ្ឋមួយនៅឡើយផងទេ ។

ចុងក្រោយនេះ ខ្ញុំលើកយកភស្តុតាងនៃឈ្មោះភ្នំនេះ តាមរយៈសិលា.

ចារឹក មកបង្ហាញ គឺសិលាចារឹករបស់ព្រះបាទយសោវរ្ម័ន I គ.ស 889 - 900 បាន និយាយ ពីការស្ថាបនាប្រាសាទភ្នំក្រោម ដែលក្នុងសិលាចារឹក ហៅថា «ទ្វីករោមឹ» (១) ហើយប្រាសាទនេះបានបន្សល់ទុកនៅរហូតដល់សព្វថ្ងៃ ដែលជាប្រាសាទភ្នំ មាន ប្រាង្គបី ឧទ្ទិសដល់អាទិទេពត្រីមូរតិ គឺព្រះវិស្ណុ ព្រះព្រហ្ម និងព្រះឥសូរ ។ នៅសម័យ ព្រះអង្គដដែល ក៏មានការកសាងប្រាសាទភ្នំពីរទៀត ដែលមួយឈ្មោះភ្នំកណ្តាល ធ្វើ ជាស្នូលនៃចក្រវាឡ ឬជាទីក្រុង សំរាប់ជាស្ថានទេវរាជរបស់ព្រះអង្គ ដែលលោក ហ្គោឡូបេវ ថាត្រូវនឹងភ្នំបាខែង រីឯប្រាសាទភ្នំមួយទៀត គឺប្រាសាទភ្នំបូក ដែល ឧទ្ទិសចំពោះអាទិទេពត្រីមូរតិ ដូចគ្នានឹងភ្នំក្រោម ព្រោះប្រាសាទនេះ មានប្រាង្គបី ដូចគ្នាដែរ ។

ផ្អែកតាមលក្ខណៈភូមិសាស្ត្រនៃប្រាសាទភ្នំទាំងបី របស់ព្រះបាទយសោ-វរ្ម័ន I ឃើញថា ភ្នំក្រោម ស្ថិតនៅលើទីតាំងមួយ ទំនាបជាងគេ ដោយត្រូវទឹកលិច ព័ទ្ធជុំវិញជានិច្ចកាលនៅរដូវវស្សា ព្រមទាំងស្ថិតនៅក្នុងវិសាលភាពផ្ទៃបឹងទន្លេសាប ទៀតផង ។

ដូច្នេះ ពាក្យថា « ភ្នំក្រោម » នេះ បុព្វបុរសខ្មែរបានបញ្ញត្តិឡើងទៅតាម លក្ខខណ្ឌភូមិសាស្ត្រជាក់ស្តែង នៅក្នុងតំបន់សៀមរាបនោះតែម្តង ។

ចំពោះរឿងព្រេងដែលទាក់ទងនឹងឈ្មោះនេះ គ្រាន់តែជាការប្រឌិតឡើង តាមរឿងប្រជាប្រិយរបស់ខ្មែរសុទ្ធសាធ ។

## ទាក់ទងនឹងជំនឿនៅភ្នំក្រោម

យោងតាមពុទ្ធដីការបស់ព្រះតេជព្រះគុណចៅអធិការវត្តខ្នងភ្នំក្រោម ព្រះនាម គ្រុឌ ស្ងួន និងលោកយាយ សាំង រស់នៅភូមិជើងភ្នំក្រោម អាយុ ៧៩ ឆ្នាំ

(១) « ស្តេញ៊អញ៊បុរោហិត ស្តេញ៊អញ៊បូជាភ្នំករោមិ គោល់ឱយិត កម្រតេង៑អញ៊ទ្វិជេន្ទ្រ » k 262s - l.15 - 16 ។

(ថ្ងៃ ៩ ខែ ១១ ឆ្នាំ ១៩៩៥) ដែលមានដើមកំណើតកើតជានៅភូមិនេះតែម្តង ព្រម ទាំងប្រជារាស្ត្រ នៅក្នុងភូមិជាច្រើនទៀត ដែលយើងខ្ញុំមិនអាចរៀបរាប់ឈ្មោះ អោយអស់បាន ។

កាលដើមឡើយ តំបន់ភ្នំនេះមានព្រៃដុះស៊ុបទ្រុបខ្លាំងណាស់ មិនសូវ មានអ្នកណាហ៊ានដើរឆ្លងកាត់តំបន់នេះទេ ។ ផ្ទះសំបែងរបស់អ្នកស្រុក មានមួយៗ នៅឆ្ងាយពីគ្នា ខុសប្លែកពីសព្វថ្ងៃ ។

ទាក់ទងនឹងជំនឿផ្សេងៗ របស់ប្រជារាស្ត្រនៅក្នុងតំបន់ ក៏ដូចជាអ្នកមកពី ចម្ងាយ រហូតមកដល់បច្ចុប្បន្ននេះ គេចាប់អារម្មណ៍តែទៅលើបូជនីយដ្ឋាន ដ៏សក្តិ សិទ្ធបួនកន្លែងនៅលើភ្នំនេះ ដែលធ្វើអោយគេមិនភ្លេចធ្វើការគោរពបូជាជាប្រចាំ កាលណាគេឡើងមកលេងលើភ្នំនេះ ។

១. អ្នកតាដំបងដែក ៖ អ្នកតានេះ គេបានសាងជារូបសំណាកធំមួយ ទ្រង់ ឈរដោយមានទំហំធំជាងមនុស្សធម្មតាបន្តិច ដាក់នៅក្នុងអាសនៈមួយ នាចុងទីធ្លា វត្ត ប៉ែកខាងត្បូងព្រះវិហារសព្វថ្ងៃ គឺនៅជិតជណ្តើរឡើងទៅលើទីធ្លាវត្តនេះតែ ម្តង ។

អ្នកស្រុក ឬពុទ្ធបរិស័ទជិតឆ្ងាយ រមែងចូលទៅបន់ស្រន់ទីនេះមុនគេ នៅ ពេលណាគេឡើងទៅកាន់វត្តខ្នងភ្នំក្រោម ឬទស្សនាប្រាសាទ ។ អ្នកតានេះ ត្រូវបាន គេជឿជាក់ថា ជាតួអង្គមួយមានមហិទ្ធិរិទ្ធពូកែអស្ចារ្យជាងគេ នៅលើភ្នំនេះ ។

២. តួប្រាសាទលើខ្នងភ្នំក្រោម ៖ ក្រោយពីពុទ្ធបរិស័ទ ឬភ្ញៀវទេសចរណ៍ នានា គេធ្វើគារវកិច្ចចំពោះអ្នកតាដំបងដែករួចហើយ គេតែងបន្តដំណើរឡើងទៅ លើទីទួលមួយគន្លាក់ទៀត នៅផ្នែកខាងលិច ដើម្បីទៅទស្សនាប្រាសាទ ។ ពេលទៅ ដល់ប្រាសាទ ពុទ្ធបរិស័ទ ឬភ្ញៀវទេសចរណ៍ មិនភ្លេចយកទៀនធូបមកដុតឧទ្ទិស ដល់បារមីនៃវត្ថុសក្តិសិទ្ធដែលនៅថែរក្សាប្រាសាទនេះឡើយ ។ ប្រាសាទដែលកសាង

ដើម្បីឧទ្ទិសដល់អាទិទេពត្រីមូរ្តិនេះ នៅតែត្រូវបានគេគោរព និងកោតស្ញប់ស្ញែងជានិច្ច ព្រមទាំងបួងសួងសុំអោយជួយប្រទានពរជ័យដល់គេទៀតផង ។

៣. អណ្តូងប្រេង : អណ្តូងនេះ ស្ថិតនៅចម្រេះភ្នំភាគខាងលិច ។ បើធ្វើដំណើរទៅកាន់អណ្តូងប្រេងនេះ ត្រូវដើរតាមផ្លូវខាងលិចប្រាសាទត្រង់ ចុះទៅកាន់ចម្រេះភ្នំចម្ងាយប្រមាណ ១០ ម យើងនឹងឃើញមានរូងតូចមួយ ។ សព្វថ្ងៃ រូងតូចនេះ មានទឹកដក់នៅរដូវវស្សា ចំណែកនៅរដូវប្រាំង រូងនេះស្ងួតហួតហែង ។

តាមការនិទានរបស់ព្រះតេជព្រះគុណ គ្រូឧ សួន ដែលជាចៅអធិការវត្តព្រះអង្គព្រះជន្ម ៣២ ព្រះវស្សា ( ឆ្នាំ ១៩៩៥ ) ថា : អណ្តូងនេះ ជាកន្លែងសក្តិសិទ្ធិមួយដែរនៅលើភ្នំក្រោម ដោយសារមនុស្សម្នាទូទៅអាចបន់ស្រន់សុំទឹកអាស្រ័យបានគ្រប់ពេលវេលា ទោះបីជារដូវប្រាំងរាំងស្ងួតយ៉ាងណា ។

ព្រះអង្គមានពុទ្ធដីកាថា អណ្តូងនេះមានរូងជ្រៅណាស់ ។ កាលព្រះអង្គនៅវ័យកុមារ បានដើរតាមឪពុកទៅរកកាប់អុសនៅលើភ្នំនេះ នៅពេលឪពុក និងកូនស្រេកទឹកខ្លាំងបានមកបន់ស្រន់សុំទឹកអណ្តូងនេះផឹក ។ គ្រាន់តែចប់ពាក្យបំណន់សន្ទឹកទឹកជោរតាមរន្ធឡើងមកពេញប្រៀបលើកំផែងថ្ម ដែលរាំងកណ្តក់សំរាប់អោយទឹកដក់នៅ ។

ផ្ទុយទៅវិញ បើយើងពោលពាក្យអសុរស ត្មះតិះដៀលចំពោះអណ្តូងនេះដោយប្រការណាមួយ ទឹកអណ្តូងដែលមានរូបរាងជាកូនរូងតូចនេះ នឹងនាចចុះរីងស្ងួតទៅវិញភ្លាមដែរ ។ ម្យ៉ាងវិញទៀត បើនៅមុនពេលបន់សុំទឹកអណ្តូងនេះផឹក យើងបានពោលពាក្យពុំពិរោះ មើលងាយ ឬពុំគប្បីដោយប្រការណាមួយ នោះទឹកអណ្តូងក៏មិនជោរចេញមកដែរ ។

ដូច្នេះ បញ្ហាសំខាន់ គឺពុទ្ធបរិស័ទត្រូវតែតមចំពោះពាក្យសំដីរបស់ខ្លួនគ្រប់ៗគ្នា ទើបការបន់ស្រន់សុំទឹកពីអ្នកតាសច្ចំបង់បត់ ដែលថែរក្សាទីកន្លែងនេះ

ត្រូវតាមសេចក្តីប្រាថ្នាបាន ហើយទោះបីជាអ្នកផឹកមានចំនួនច្រើនយ៉ាងណាក៏ទឹកដែលដក់នៅលើក្រហូងថ្មនេះមិនរីងអស់ដែរ ។

ដោយសារតែប្រជារាស្ត្រនៅតំបន់នេះ នៅតែមានជំនឿលើទីកន្លែងនេះ អង្គការនៃរបប ប៉ុល ពត បានយកមេរ៉ា TNT ទៅកប់ ធ្វើអោយផ្ទុះបំផ្លាញអណ្តូងនេះចោល ។ ចាប់តាំងពីពេលនោះមក កន្លែងនេះ ក៏លែងមានមហិទ្ធិរិទ្ធដូចមុនទៀត ដោយសារតែគេបន់ស្រន់សុំមិនបានដូចបំណង ។ ប៉ុន្តែ ទោះជាយ៉ាងណានេះក្តី ក៏សព្វថ្ងៃ មនុស្សម្នានៅតែទៅគោរពបូជានៅមាត់អណ្តូងនេះជាដរាប នៅពេលឡើងទៅកំសាន្តលើភ្នំនេះ ដោយនាំយកទៀនធូបផ្កាភ្ញីទៅជុតបូជា ជាធម្មតា ។

៤. រូងភ្នំភាគខាងត្បូង ៖ រូងនេះស្ថិតនៅត្រង់ចង្កេះភ្នំភាគខាងត្បូង តាមជំនឿរបស់អ្នកស្រុកថា មានជំរៅជ្រៅណាស់ និងជាផ្លូវក្នុងសំរាប់ទាក់ទងទៅកន្លែងផ្សេងៗ ។

រូងនេះ ពីដើមឡើយ កម្រមានមនុស្សណាហ៊ានចូលណាស់ ។ តាមប្រសាសន៍របស់លោកយាយ សាំង អាយុ ៧៩ ឆ្នាំ នៅភូមិជើងភ្នំក្រោម ប្រហែល ៧០ ឬ ៨០ ឆ្នាំមុន នៅក្នុងរូងភ្នំនេះ អ្នកស្រុកអាចខ្ចីចាន ឆ្នាំង យកមកប្រើប្រាស់ក្នុងពិធីបុណ្យទានបាន ដោយគ្រាន់តែទៅធ្វើការបួងសួងសុំខ្ចីពីម្ចាស់អ្នកថែរក្សាទីរូងនេះ ។ ចំណេរកាលក្រោយមក អ្នកដែលទៅខ្ចីរបស់ពីក្នុងរូងនេះមកប្រើច្រើនតែមិនគោរពពាក្យសច្ចៈរបស់ខ្លួន សងវិញមិនគ្រប់ចំនួន ឬជួនកាលបំបាត់យកទុកប្រើប្រាស់ផ្ទាល់ខ្លួនតាមតែចិត្តលោភលន់ ធ្វើអោយកន្លែងនេះសាបរលាបបន្តិចម្តងៗ ហើយអ្នកស្រុកមិនអាចខ្ចីវត្ថុប្រើប្រាស់ដែលខ្លួនត្រូវការមកប្រើប្រាស់បាន ដូចពេលមុនទៀត ។

ម្យ៉ាងទៀត នៅក្នុងកំឡុងពេលដែលរូងនេះនៅមានបារមីខ្លាំងពូកែ នៅឡើយ រៀងរាល់ថ្ងៃសីល ឬថ្ងៃពេញបូរមី ឬក៏ថ្ងៃខែដាច់ អ្នកស្រុកតែងតែឮសូរ

សំលេងភ្លេងពិណពាទ្យ ប្រគំរងំរសាត់ចេញពីរូងនេះ ។ ឧបាសក ឧបាសិកា ឬអ្នកធ្វើកម្មដ្ឋាន ចេះដឹងធម៌អាថ៌ ជ្រៅក្នុង ក្រៅច្រើន គេអាចចូលទៅក្នុងរូងភ្នំនេះបានចំនួនមួយយប់, ពីរ ឬបីថ្ងៃ ឬប្រាំថ្ងៃ ក៏មាន ។

នៅសម័យអាណានិគមបារាំង រូងនេះត្រូវបានរាជការអាណាព្យាបាលបញ្ជាអោយសន្ធប់ចោលបំបាត់រូងនេះ រហូតមកដល់សព្វថ្ងៃ កម្រមានអ្នកណាគេស្គាល់ ឬបានទៅទស្សនាដោយផ្ទាល់ណាស់ សូម្បីតែអ្នកស្រុកក្នុងតំបន់នោះ ។ ចាប់តាំងពីសម័យកាលសង្គ្រាមឆាបឆេះនៅកម្ពុជា តំបន់នេះក្លាយជាទីតាំងបន្ទាយទាហានរហូត ដូច្នេះ ស្នូរសន្ធឹកនៃគ្រាប់កាំភ្លើងតូចធំ ដែលគេបានបាញ់ រីងរឹតតែធ្វើអោយអច្ឆរិយភាពនៅទីនោះ កាន់តែឈានទៅរកភាពសាបសូន្យ ដែលមានតាំងពីការដាក់មេរ្យ TNT កំទេចយកថ្មក្រាលផ្លូវថ្នល់ជាដើម ។

រូងនេះសព្វថ្ងៃ មានសភាពរាក់ទាល់ មិនមានរូបភាពដូចកាលពីសម័យបារាំង ទើបតែដាក់អាណានិគមថ្មីៗ នៅកម្ពុជាទេ ។

សេចក្តីដូចបានរៀបរាប់ជូនខាងលើនេះ គ្រាន់តែជាការរំលឹកឡើងវិញនូវជំនឿអរូបិយរបស់ជនជាតិខ្មែរនៅតំបន់ភ្នំក្រោមប៉ុណ្ណោះ ។ ត្រង់ការដែលអះអាងថាពិត ឬមិនពិត ស្ថិតនៅលើការវិនិច្ឆ័យរបស់មិត្តអ្នកអាន ព្រោះគោលបំណងរបស់យើងនៅពេលនេះ បានត្រឹមតែសរសេរពតិមាន ដែលបានផ្តល់អោយដោយអ្នកស្រុកនៅតំបន់ភ្នំក្រោម ដើម្បីតំកល់ទុកជាឯកសារ សំរាប់ជនានុជនខ្មែរទាំងអស់ តែប៉ុណ្ណោះ ។

ដោយ **ចង់ សុធារ៉ា**

អតីតនិស្សិតមហាវិទ្យាល័យប្រវត្តិវិទ្យា

ជំនាន់ទី ១៣

# បទអក្សរល្បួន

## *វាចារំលឹក*

បទអក្សរល្បួនដែលលោកអ្នកនឹងបានអាននៅក្នុងទំព័រជាបន្តទៅនេះ ត្រូវបានលោកកវីនិពន្ធ អៀង សាយ ចងក្រងឡើងនៅក្នុងសៀវភៅរបស់លោក ឈ្មោះ " មេកាព្យ " ។ ខ្ញុំបានអានកំណាព្យនេះ នៅក្នុងទសវត្សទី ៦០ រួចមកហើយក៏នៅចាំបទនេះរត់មាត់ តាំងពីរពេលនោះរហូតមកដល់សព្វថ្ងៃ ។

ដើម្បីកុំអោយបាត់បង់នូវស្នាដៃដ៏មានតម្លៃនេះ ខ្ញុំសូមកត់កំណាព្យបទអក្សរល្បួនរបស់លោកកវីនិពន្ធ អៀង សាយ ទុកក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខនេះ គ្រាន់ជាគំរូនៃបទ និងជាការអានកំសាន្ត សំរាប់ជនានុជនស្នេហាវប្បធម៌ជាតិ ។

បទអក្សរល្បួន គឺជាបទកំណាព្យខ្មែរ ដែលព្យាង្គនីមួយៗរបស់ឃ្លា កើតចេញពីព្យញ្ជនៈតែមួយដូចគ្នា ពោលគឺ បើឃ្លាណាកើតចេញពីអក្សរ « ក » ព្យាង្គទាំងប៉ុន្មាននៅក្នុងឃ្លានោះ កើតចេញពីអក្សរ « ក » ទាំងអស់ បើកើតចេញពីអក្សរ « ខ » ព្យាង្គទាំងអស់ ត្រូវកើតចេញពីអក្សរ « ខ » ដូចគ្នា ។

ព្រមជាមួយនឹងកំណាព្យបទអក្សរល្បួននេះ ខ្ញុំសូមចម្លងទុកនូវប្រស្នាមួយ និងចម្លើយដែលលោក អៀង សាយ បានចងក្រងពាក់តែងឡើង គ្រាន់ជាការកំសាន្ត និងល្បងប្រាជ្ញាផងដែរ ។

ថ្ងៃទី ១៥ ឧសភា ១៩៩៧

ធន់ ហ៊ិន

## បទអក្សរល្បូន ទី១

រិះរេរុលរករៀនរៀបរាប់ គយគន់គួរគាប់គិតគងគេ
ដែលដឹងដើមដានដោយដាសដេរ ចេះចប់ចាកចេរចេញចែងចាយ ។
ពែងតតបតាមពែតួចតឹង ប្រុងប្រែប្រានប្រឹងប្រែងប្រាជ្ញប្រាយ
កើតការកកកុញកុំកាន់កាយ ស្តាប់ស្តូកស្តឹងស្តាយស្តីស្តាស្តែង ។

## អក្សរល្បូនទី ២

បងបានបីបមបោសបោចបិច មើលមុខមូលមិចមិនមានមួរ
សាច់សសើចសមស្មូមសុំសួរ គិតគួរគាប់គួរគេងគៀកគង ។
ឱនឱបអង្អែលអូនអៀនអង្គ ចរចាចែចង់ចិត្តចាប់ចង
ដាក់ដៃដល់ដោះដេកដោយដង កៀកកាយកែរកងកាន់កៀនកោះ ។



***

ទំព័រកំសាន្ត

# ប្រស្នា

មានស៊ីក្លូមួយ និងរទេះសេះមួយ តែងតែចេញដំណើរទៀងរាល់ព្រឹក នៅម៉ោង ៨ ព្រឹក ដំណាលគ្នា តាមបណ្តោយផ្លូវ វែរដង (Verdun) ដែលបច្ចុប្បន្ននេះគឺ មហាវិថីព្រះមុនីវង្ស ហើយតែងមកដល់ផ្លូវត្រឡែងកែងកាច់ជ្រុងពេទ្យចិននៅម៉ោង ៩ ព្រឹក ដំណាលគ្នាជាទៀងរាល់ព្រឹកដែរ ។ ស្រាប់តែមានមួយព្រឹកនោះស៊ីក្លូមកដល់ផ្លូវកាច់ជ្រុងពេទ្យចិនយឺតជាងរទេះសេះ ១០ នាទី ។

សួរថា តើមូលហេតុអ្វីបានជាស៊ីក្លូមកដល់យឺតជាងរទេះសេះ ?

បញ្ជាក់ ៖ បើមានបញ្ហាអ្វីកើតឡើង វាត្រូវកើតឡើងចំពោះយានជំនិះទាំងពីរដូចៗគ្នា ។ អ្នកដែលឆ្លើយប្រស្នានេះត្រូវ មានហេតុផលល្អ នឹងបានទទួលរង្វាន់ទស្សនាវដ្តី មួយលេខ ដោយឥតគិតថ្លៃ ។

## *ចម្លើយ*

លោក អៀង សាយ បានសរសេរថា លោកបានទទួលចម្លើយយជាច្រើនដែលសុទ្ធតែខុសទាំងអស់ ។ មានតែចម្លើយមួយគត់ដែលទំនងជាងគេ ប៉ុន្តែក៏ខុសដែរ ។ គេបកស្រាយថា ដោយពេលនោះមានភ្លៀងធ្លាក់ អ្នកធាក់ស៊ីក្លូត្រូវបញ្ឈប់ស៊ីក្លូ ដើម្បីខ្លួនគាត់ចុះដាក់ដំបូល ។ ប៉ុន្តែ មានការបញ្ជាក់រួចមកហើយថា បើមានធ្វើអ្វី ត្រូវធ្វើដូចគ្នា បើស៊ីក្លូត្រូវដាក់ដំបូល រទេះសេះក៏ត្រូវដាក់ដំបូលដែរ ។ ឯចម្លើយត្រឹមត្រូវ គឺដល់ពាក់កណ្តាលផ្លូវ អ្នកធាក់ស៊ីក្លូរាន់បត់ជើងធំ, គាត់ត្រូវបញ្ឈប់ស៊ីក្លូរកព្រៃគុម្ពោតជិតៗនោះបត់ជើងធំ ។ ឯសេះក៏ជុះអាចម៍ដែរ តែវាជុះអាចម៍ផង បោលផងបាន ។

# សាស្ត្រាក្រមច្បាប់

## បទកាកគតិ

ចារចម្លងដោយសាមណេរ នាម « ផៃ »

ចារចប់ នៅថ្ងៃ ២ ។ ១២ [(១)]

៧

ក.ក.ន. សាស្ត្រា « ក្រមច្បាប់ » នេះ ពុទ្ធសាសនបណ្ឌិត្យបានទទួលពីវត្តកំពង់សំបួរ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ។ គួរឱ្យស្ដាយ ដោយយើងពុំបានស្គាល់នាមអ្នកនិពន្ធ និងកាលបរិច្ឆេទនៃការតែងនិពន្ធកំណាព្យនេះ ។ សូម្បីសាមណេរ « ផៃ » ដែលជាអ្នកចារចម្លងចេញពីសាស្ត្រាច្បាប់ដើមមកនោះ ក៏លោកពុំបានប្រាប់ពុទ្ធសករាជ ឬគ្រិស្តសករាជប៉ុន្មានៗ នោះដែរ ធ្វើឱ្យស្នាដៃអក្សរសាស្ត្រនេះស្ថិតក្នុងរាជិកំបាំងនៃពេលវេលា ។

យើងសង្ឃឹមថា អត្ថន័យនៃសាស្ត្រានេះនឹងបានជាទីគាប់ចិត្តដល់អ្នកអានពុំខាន, មិនមានសេចក្ដីវែងណាស់ណាទេ, ដូចតទៅនេះ គឺ :

នេះគឺក្រមច្បាប់ ព្រះលោកបង្គាប់ ទូន្មានអ្នកផង
កើតក្នុងលោកិយ ផែនដីនេះហោង ឱ្យបានបួសផង
គុណព្រះមាតា ។

បួសហើយលំអុត ចាំសីលស្រគត់ ចំរើនភាវនា
សង្វាតសូត្ររៀន របៀនអាត្មា ខ្មីឃ្មាតឧស្សាហ៍
កុំខ្ជិលឡើយហោង ។

(១) អានថាថ្ងៃ ច័ន្ទ ៧ រោជ ខែ កត្តិក

ប្ដួសជាសាមណេរ ប្រសើរពុំដែល ថយថោកផលផង
សង្ខាតបំរើ គ្រូបាធ្យាយហោង កុំធ្វើចិត្តឃ្នង
ឃ្មើសពុំខ្លាចគ្រូ ។
ដ្បិតអ្នកមានគុណ បំរើកុំឆ្អន់ ធ្វើចិត្តម្ងរទូ
នៀយហត់ប៉ុន្មាន ខំផ្គាប់ឱ្យគ្រូ អ្នកដែលនាំផ្លូវ
ដាក់ដល់សួគិនាយ ។
រីឯបុណ្យនោះ ប្រាកដចំពោះ ជូនទៅអ្នកម្ដាយ
ដ្បិតអ្នកមានគុណ ក្រាស់ក្រៃទូលាយ គុណគ្រូបាធ្យាយ
នោះទើបស្មើបាន ។
ប្ដួសពីតូចខំ រៀនលុះដល់ធំ បរិបូណ៌ហើយណា
ព្រះអភិធម្ម គុណគម្ពីរា តែងអាចផានា
នាំអស់សត្វផង ។
ប្ដួសហើយកុំនឹក ចិត្តចើកចង់សិក្ខ[១] ពីតូចឡើយណា
ខំឱនខំអត់ កាន់កត់ចិត្តចង ខំរួសរៀនផង
ដោយពុទ្ធវចនា ។
ខំរក្សាផ្នួស ដ្បិតខ្លួនបានប្ដួស សំណាក់សាសនា
ដូចអ្នកសុបិន កុមារប្ដួសជា សាមណេរនោះណា
មហាគាប់កន្លង ។
ម្ដាយអ្នកទូលទុក្ខ ធ្លាក់ទៅនរក លំបាករូបរង
ដ្បិតកូនចង់ប្ដួស ម្ដាយពុំព្រមផង ហេតុបាបនោះហោង
ដូចដល់អាត្មា ។

---

(១) ចាកសិក្ខាបទគឺ លាភេទពីសង្ឃមកជាគ្រហស្ថវិញ, ( អានថា សឹក ) ។

កូនខំទៅបួស រក្សាសីលផ្ទួស ជាសាមណេរណា
ដោះម្ដាយពីទុក្ខ បានសុខសួគ៌ា ហេតុផលសីលា
បានបួសប្រពៃ ។

រីឯឪពុក ស្លាប់ទៅនរក លំបាកពេកក្រៃ
កើតជាប្រេតប្រាណ តិរច្ឆានអប្រិយ អាហារចំណី
ពុំបានភោគ្គា ។

រហេមរហាម ស៊ីតែខ្ទុះឈាម លំបាកក្ដាត់ណា
ស្រែកទ្រហោយំ គគក់ឧរា ឱអត់អ្នកណា
ជួយដល់តិចនៃ ។

សុបិនកុមារ ដឹងអស់កិច្ចការ បិតាមានភ័យ
កាលខ្លួនបានបួស ជាសាមណេរនៃ នឹងយោងយកបិ-
តាពុំបានឡើយ ។

លុះអាយុអ្នក វីសតិវច្ឆរះ បានបរិបូណ៌ហើយ
ប្រដាប់បួសភិក្ខុ[១] អ្នកកុំគិតឡើយ គិតផ្ទួសជាត្រើយ
នឹងយោងបិតា ។

ទើបអ្នកសង្វាត ចេញទៅស្មឹងស្មាធិ៍[២] ចំរើនភាវនា
បានដោះឪពុក រួចពីទុក្ខា ទៅកើតសួគ៌ា
បុណ្យបរិបូណ៌ក្រៃ ។

នូវអ្នកផង មានកូនប្រុសហោង ហៅមានភ័ព្វក្រៃ[៣]

---

(១) ភិក្ខុ = អានថា « ភីក »
(២) ស្មាធិ៍ = សមាធិ = អានថា « ស្មាត » ។
(៣) ដើម្បីកុំឱ្យខ្លួននឹងប្រយោគមុន គួរដាក់ថា « មានភ័ព្វឥតបី » ដូច្នេះវិញល្អជាង

ខះខំរក្សា ជាអចិន្ត្រៃយ៍ ឱ្យបានដឹងក្តី
បរិបូណ៌ហើយណា ។
ដ្បិតកាលមកកើត នឹងយកកំណើត ក្នុងផ្ទៃមាតា
អង្វរព្រះយម ប្រាប់សូមក្រាបលា រកភពភារា
ក្នុងផ្ទៃឧទម្ពរ ។
លុះបានមកចាប់ បដិសន្ធិខ្ជាប់ ក្នុងព្រះឧទរ
ព្រះអភិធម្ម នានាំចេញចរ នូវអង្គអក្សរ
បង្កើតអាត្មា ។
ជាជើងជាដៃ កើតអស់សរសៃ សឹងតែអក្ខរា
ព្រះអភិធម្ម បង្កើតរូបា មាតាបិតា
អាស្រ័យផ្ទៃហោង ។
បើបានកើតមក ជាប្រុសពន្លក បរិបូណ៌ហើយហោង
ខំឱ្យបានបួស ស្អាងផ្នួសជាស្នង គុណម្តាយនោះហោង
កុំភ្លេចឡើយណា ។
បួសជាសាមណេរ សីលដប់ក្រាសក្រៃល សងគុណមាតា
លុះបានបួសភិក្ខុ(១) បរិបូណ៌ហើយណា សងគុណបិតា
ដូចសុបិនហោង ។
ធម្មតាអ្នកបួស ប្រសើរឯផ្នួស ពេកពន់កន្លង
មាតាបិតា មេបាញាតិផង កុំធ្វើឱ្យឆ្គង
អាក់អន់ចិន្តា ។
មិនដូចគ្រហស្ថ សីលព្រះថ្លៃណាស់ ស្ថិតលើសិរសា

(២) អានថា ភីក

កុំជេរវាយដំ ខិតខំបំពារ បាបនោះមហិមា
ធ្ងន់ក្រៃកន្លង ។
ខ្លះសោតផឹកស្រា បំបួសកូនជា ភិក្ខុសាមណេរហោង
ជេរពុំគិតបាប ដរាបប៉ុនល្អង ហៃមមហាជនផង
កុំធ្វើថ្មោះណា ។
បើធ្វើថ្មោះហើយ នឹងសូន្យសោះត្រើយ បាបដល់អាត្មា
រងទុក្ខលំបាក តោកយ៉ាកវេទនា នឹងកើតរោគា
ដំងឺបៀតផង ។
បើអ្នកឯណា បង្កើតបុត្រា ពុំឱ្យបួសសង
គុណព្រះមាតា ស្មើទោសទ្រើសឃ្នង ប្លន់ម្ដាយឯងហោង
បានបាបក្ដាត់ណា ។
ស្លាប់ទៅនរក លំបាករងទុក្ខ ម្នាក់ឯងកំព្រា
លន្លង់លន្លោច ត្រមោចឃើផ្សា ឥតមានអ្នកណា
ជួយដល់តិចឡើយ ។
បើបានបួសជា សាមណេរហើយណា ពុំបួសភិក្ខុឡើយ
ហៅពុំគ្រប់ការ អសារឥតត្រើយ លោកទុកជាឈ្លើយ
ចោរប្លន់បិតា ។
ស្លាប់ទៅនរក លំបាករងទុក្ខ ដោយកម្មវេរា
ហេតុពុំបានសង គុណព្រះបិតា ទើបដូច្នោះណា
មួយរយបាបហោង ។
ថាបើដូច្នោះ មានចិត្តស្មើគ្រស្មោះ បានបួសតបស្នង
ចិត្តចង់បួសភិក្ខុ ដោយនូវគន្លង ម្ដាយឪពុកបង

ប្អូនពុំមេត្តា ។
បាបនោះឯងកូវ អកុសលមកត្រូវ មាតាបិតា
ឃាត់ពុំឱ្យបួស ស្អាងផ្នួសសីលា ធ្ងន់ស្មើក្រឡា
ប្រថពីឯងហោង ។
បើបួសហើយចិត្ត កូននឹងចង់សឹក្ខ ឱ្យតាមចិត្តហោង
ឃាត់សោតពុំបាន មានបាបកន្លង ទើបព្រះលោកចង
ជាបទគាថា ។
បព្វជិតោ មាតាបិតុនោ បុរិសា
ឥតិអនុញ្ញាត ប្រុសស្រីក្តីណា គ្មានចិត្តចិន្តា
សទ្ធានោះហោង ។
គ្រូលោកបំបួស បានទទួលផ្នួស ស្រគត់ឥតហ្មង
ប្រដៅ ន មោ ក ខ ធមិផង គុណលោកនោះហោង
ធ្ងន់ក្រៃក្តាត់ណា ។
ថាបើសិក្ខទៅ កុំភ្លេចគ្រូនូវ មាតាបិតា
គុណនោះប្រសើរ ស្ថិតលើសិរសា ហើយអស់ទេវតា
សឹងចំរើនហោង ។
ស្មើបានដល់ត្រើយ ទុក្ខសោកធូរស្បើយ រីករាយកន្លង
គុណបុព្វការី អ្នកលៃតបស្នង បានស្រេចជាម្តង
ត្រីពិធសម្បត្តិ ។
កុំធ្វើបំពាន លោភោចង់បាន ចិត្តចោរកាចក្តាត់
លួចយកទ្រព្យគេ សម្លាប់បំបាត់ ចិត្តចោរពុំគិត
បុណ្យបាបឡើយណា ។

បើចង់បានទ្រព្យ ឱ្យរកដោយច្បាប់ ធ្វើស្រែចំការ
ជីកចូកជីដាំ ជំណាំដូងស្លា ដោយធម៌លោកថា
មហាគាប់ពេកក្រៃ ។
សម្បត្តិនោះគង់ អង្វែងយូរលង់ បរិបូណ៌ឥតបី
គ្មានខាតគ្មានខ្វះ កន្លះឡើយនៃ ពោរពេញសព្វថ្ងៃ
ឥតឯតណោនា ។
ខំរិះរកទ្រព្យ បានហើយប្រដាប់ សាងសង់វិហារ
បំបួសកូនចៅ នូវបុត្រភរិយា ទាសីទាសា
ខ្ញុំប្រុសស្រីផង ។
បើនឹងធ្វើបុណ្យ លះបង់ទ្រព្យធន ដូចក្តីបំណង
បរិបូណ៌នឹងបាន ពុំដែលឃ្លាតបោង បុណ្យបាបតាមប៉ង
ដូចក្តីប្រាថ្នា ។
ទៅបរលោកនាយ ភ្លឺផ្លេកព្រោងព្រាយ ស្មើទៅសួគ៌ា
ក្បៀមក្សាន្តស្រណុក ឥតទុក្ខភយា និងអស់ទេវតា
បរិពារទាំងឡាយ ។
បើអ្នកឯណា សិក្ខចេញទៅជា គ្រហស្ថរាយមាយ
ពុំនឹងគុណគ្រូ គុណឪពុកម្តាយ អ្នកនោះឯងឆ្ងាយ
នឹងលោកុត្តរ ។
អ្នកនោះពុំជា ខ្វាក់ខ្វិនពិការ លង់លុះដល់មរណ
ដ្បិតពុំនឹងគុណ គុណគ្រូអក្សរ អ្នកនោះពុំប-
(រិ)បូណ៌ជាមនុស្សឡើយ ។
បាបច្រើនជំពូក សិក្ខទៅពុំយក ច្បាប់នោះជាត្រើយ

ពាក្យគ្រូប្រដៅ  កុំឱ្យភ្លេចឡើយ  ព្រះគុណជាត្រើយ
ព្រះកែវនោះហោង ។
ស្លៀកសស្ពាយឆៀង[១]  ប្រតិបត្តិកុំល្មៀបង  ឱ្យមានហ្មត់ហ្មង
កុំធ្វើលេលាប់  នាំឱ្យឆ្គាំឆ្គង  រៀបចូកពាផង
ស្រគត់ឥន្ទ្រីយ៍ ។
វិទានភិរម្យ[២]  សមណគោត្តម  សរពេជ្ញមុនី
ក្រាបចុះងើបឡើង  អង្គុយស្មធី  សូមថ្វាយជីវី
ជីវិតព្រះហោង ។
ហើយថ្វាយបង្គំ  អស់ទាំងព្រះគប-  ម្តែងសង្ឃនោះផង
ខំឱនខំអត់  កាន់កត់ចិត្តចង  ក្រែងលោកនោះហោង
អាក់អន់ព្រះទ័យ ។
អង្គុយរៀងរាល់  សំភីស្តាប់ធមិ  ផ្ចិតផ្ចង់ស្មារតី
នូវបទគាថា  ចារពិសេចក្តី  សីលទានមានន័យ
ពិរោះពិសារ ។
វិទាននោះនៃ  មានឈ្មោះទីទៃ  ដោយជិតូកណា
មួយហៅសាមី  ផ្កាថ្លៃក្តាត់ណា  មួយនោះហៅថា
ទាសទានឯងផង ។

(១) ឃ្លាត្រង់នេះ អ្នកចំលងបានផ្លោះរំលងចោលជើងកាព្យជាច្រើនឃ្លា ខ្ញុំក៏បានបំពេញបន្ថែមឱ្យ ត្រូវទៅតាមក្បួនកាព្យ ដោយរក្សាអត្ថន័យនិងចុងចួន ។

(២) ត្រង់វគ្គនេះក៏មានខ្វកជើងកាព្យដោយលើសឃ្លា ខ្ញុំកែតម្រូវឱ្យស្របស្រួលតាមអត្ថន័យនិងចុងចួនវិញ ។

(៣) ត្រង់វគ្គនេះក៏មានការច្រឡូកច្របល់វគ្គឃ្លាទៀតដែរ ខ្ញុំក៏បានកែតម្រូវបន្ថែមឱ្យបានគ្រប់សេចក្តីឡើងវិញ ។

ហៅសហាយទាន ទាំងពីរពុំបាន មគ្គផលឡើយហោង
វិសាមីទាន បានផលកន្លង ព្រះអង្គលោកឆ្លង
ដល់ត្រើយនិព្វាន ។

បើបានទ្រព្យអ្វី សារពើចំណី គ្រាកាលក្រមាន
កុំបរិភោគឯង យកទៅឱ្យទាន ចង់ស៊ីប៉ុន្មាន
កុំស៊ីឡើយណា ។

រៀបរួចសព្វគ្រប់ បរិបូណ៌ស្រេចស្រាប់ យកទៅបូជា
ប្រគេនព្រះសង្ឃ គម្ពែងក្រឡា បានដូចប្រាថ្នា
ប្រាកដពុំឃ្លាត ។

នេះហោងសាមី ទានប្រសើរក្រៃ- ពេកយកជាខ្នាត
ព្រះសាងបារមី ក្នុងហាសិបជាតិ បរិបូណ៌ពុំឃ្លាត
បានត្រាស់ប្រាជ្ញា ។

រីឯទាសទាន កាលណាបើបាន ចំណីពិសារ
ស៊ីឯងឆ្អែតហើយ ទើបគិតនាំពារ សល់តែអាគ្នា
យកទៅឱ្យទាន ។

ស្មើឱ្យឆ្កែឆ្មា អសារទេណា សោះសូន្យពុំបាន
មគ្គផលឡើយហោង កុំឱ្យជាទាន ទាននោះពុំបាន
ដូចក្តីប្រាថ្នា ។

ដោយ មៀច ប៉ុណ្ណ
ចម្លងចេញពីសាស្ត្រាស្លឹករឹត
កែសម្រួលអក្ខរាវិរុទ្ធ និងសម្រួលជើងកាព្យត្រង់អន្លើខ្លះ

កំណាព្យ

# សិល្បៈចម្រៀងចាប៉ីខ្មែរ

( បទពាក្យ ៨ )

ឧបករណ៍តន្ត្រីចាប៉ីដងវែង ប្ញកនឹងសំឡេងចម្រៀងប្រគំ
សូរស័ព្ទកាព្យឃ្លោងពិរោះរងំ បំពេរអារម្មណ៍សក្តិសមស្រស់ស្រាយ ។
សិល្បករខ្មែរពូកែកំណាព្យ ជូនជាប់ដរាបច្រៀងបរិយាយ
ជារឿងកំប្លែងបានសើចសប្បាយ ឆ្លងឆ្លើយដោះស្រាយល្បាយល្បងបញ្ហា ។
បើមានដៃគូច្រើនច្រៀងបង្អាប់ សៀតសិកសាស័ព្ទរ៉ាយរ៉ាប់វោហារ
តបទៅតបមកខោកខំឥតរា សំដីផ្អែផ្កាចំអន់ឡៃ្បខាយ ។
រដូវទំនេររិះរេលំហែ ពន្លឺព្រះខែថៃ្ងចាំងត្រសាយ
អ្នកស្រុកអ្នកភូមិញាតិមិត្តជិតឆ្ងាយ ហេតុចង់សប្បាយមូលមកជួបជុំ ។
វាតទីដីកង់កណ្តាលទីធ្លា យាយតាមីងមាកំលោះក្រមុំ
ខ្លះឈររអង្គុយកន្លែងសមរម្យ ចាំស្តាប់ជិតជុំទ្រហឹងអឺងអាប់ ។
អ្នកច្រៀងតម្រូវទៅតាមបំណង ស្នើយោបល់ឆ្លងបំណងអ្នកស្តាប់
ចង់ស្តាប់ល្បែងល្បងឬចង់បង្អាប់ ឬមួយចង់ស្តាប់ស័ព្ទរឿងបុរាណ ។
ព្រលប់ផ្កាយព្រាតអធ្រាត្រផ្កាយជុំ សំឡេងរងំចាប៉ីចំណាន
បើកបទបង្គំតាមដោយដើមដាន គោរពសន្តានមីងមាយាយតា ។
ចាប់ចូលសាច់រឿងបុរាណកវី សូរស័ព្ទចាប៉ីផ្សំនឹងវាចា
បន្ទឺចម្រៀងក្រអួនវោហារ ថ្ងូចថ្ងូរវាចាពិរោះជាប់ចិត្ត ។

ត្រង់ឆាកព្រាត់ប្រាសនិរាសគូគាប់ អ្នកស្តាប់ស្រពាប់ស្រពោនអាណិត
ដល់តួរងគ្រោះបែកបាក់ស្នេហ៍ស្និទ្ធ ត្រូវយក្សបង្ខិតបង្ខំទៅឆ្ងាយ ។
ស្រីៗ អ្នកស្តាប់ដែលមានចិត្តទន់ ឃើញតួទារុណឈឺចាប់ចិត្តកាយ
សម្រក់ទឹកភ្នែកយំយែកសោកស្តាយ ស្រណោះអាល័យតួអង្គតួឯក ។
លុះដល់ឆាកប្រយុទ្ធជើងជាក់ ក្បត្រានិងយក្សខ្លាំងក្លាអនេក
ពលយក្សក្រៃក្រាស់ធំៗចម្លែក ងងឹតពេញមេឃបាំងសែងសុរិយា ។
កងទ័ពក្រុងមារកត់ត្រាមិនបាន មិនមែនវាល់ឡានដូចទ័ពមនុស្សា
វាល់នឹងសមុទ្រច្រើនផុតមាត្រា សាហាវហានក្លាដូចអសនី ។
ខ្លះកាន់លំពែងដាវវែងដំបង ខ្លះជិះលើខ្នងមហិសា-ដំរី
ខ្លះជាសេនារេហ៍ពលដើរដី ខ្លះហិចហោះខ្មីលើអាកាសា ។
ស្រែកហ៊ោសន្ធាប់ញាប់ញ័រប្រថពី វាសវាត់គ្រឿងអាវុធមុតថ្លា
សម្តុតសម្លឹងខឹងនឹងក្បត្រា ជាអង្គមនុស្សាឫទ្ធិក្លាហៅហាន ។
អ្នកច្រៀងធ្វើត្រាប់តាមកាយវិការ ជូនហាក់ឆ្លេឆ្លាជូនពើតពើងប្រាណ
គ្រវីចាប៉ីធ្វើតាមលំអាន យក្សយង់ក្បត្រក្បាន្តប្រឡូងថ្វីដៃ ។
មកដល់ត្រង់យក្សបាក់បាត់ចេស្តា ត្រូវអង្គក្បត្រាប្រហាក្សិណក្ស័យ
ស្តេចនាំនាងនាថវិលវឹងបុរី ឆ្លាស់ឆ្លងដងព្រៃជ្រលងបព្វតា ។
រាយរាប់រុក្ខជាតិព្រៃភ្នំក្រំថ្ម ជ្រោះជ្រងលំអដែនអរញ្ញវា
រៀបរាប់សត្វម្រឹគបក្សីបក្សា រាប់អស់មច្ឆាហែលតាមទឹកហូរ ។
រាប់ទាំងបុប្ផាគន្ធាសព្វសាយ ភ្មមរីទាំងឡាយក្រេបរសពិដោរ
ក្លិនរសាត់ឆ្ងាយភាយតាមវាយោ ហាក់ដូចជាស្នូរនៃតូរ្យតន្ត្រី ។
ឱ ! កវីខ្មែរពូកែបណ្តាច់ រចនាពាក្យពេចន៍ល្បិចល្បងល្បាញល្បី
ឱ ! អ្នកចម្រៀងច្រៀងលេងសំដី ដេញភ្លេងបំភ្លៃពិរោះភិរម្យ ។

ឱ ! រាត្រីខ្មែរខែរះភ្លឺថ្លា
ស្តែងស្តាប់ចម្រៀងបំពេសង្គម
នាំគ្នាការពារផៃវប្បធម៌ជាតិ
រក្សាគង់វង្សកេរពីបុរាណ

រីករាយចិន្តាអង្រ្គាព្រដាស់ទុំ
បបោសអារម្មណ៍សំងំសុខសាន្ត ។
កុំឱ្យរវាតទើបជាតិថ្កើងថ្កាន
តទៅសន្តានរៀងដរាបរើយ ។

ដោយ មៀច ប៉ុណ្ណ
ប្រធានការិយាល័យទំនៀមទម្លាប់ខ្មែរ
នៃពុទ្ធសាសនបណ្ឌិត្យ

វាមិនធ្លាប់ដែលមាន, វានឹងមិនមាន, ហើយឥឡូវនេះវាក៏មិនមានដែរ
មនុស្ស ដែលត្រូវគេរិះគន់តែរហូត ឬ
មនុស្ស ដែលត្រូវគេសរសើរតែរហូត ។

ធម្មបទ គាថាទី ២២៨ . ឃ.អ.

# ពិធីទទួលសៀវភៅ

## ជាអំណោយរបស់មូលនិធិសំរាប់មជ្ឈមណ្ឌលអាស៊ី របស់ជប៉ុន



លោក អាឡាំង ហ្វាំងស្ដែន ជូនសៀវភៅអំណោយរបស់មូលនិធិជប៉ុន សំរាប់អាស៊ី ជានិមិត្តរូប ចំពោះឯកឧត្តមរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

នៅថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ១៩៩៧ វេលាម៉ោង ៨ ព្រឹក ពុទ្ធសាសនបណ្ឌិត្យ បានរៀបចំប្រារព្ធពិធីទទួលសៀវភៅ ចំនួន ១២៨៥ ក្បាល ពីលោក អាឡាំង ហ្វាំងស្ដែន អ្នកសម្របសម្រួលខាងផ្លាស់ប្ដូរបញ្ញា តំណាងមូលនិធិសំរាប់អាស៊ី របស់ជប៉ុន ។

ពិធីនេះបានប្រព្រឹត្តទៅ នៅទីចាត់ការពុទ្ធសាសនបណ្ឌិត្យ វត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម ហៀង វណ្ណារ័ត្ន រដ្ឋលេខាធិការ ក្រសួង

ធម្មការ និងសាសនា, ដោយមានមន្ត្រីសង្ឃ, មន្ត្រីរាជការរបស់ក្រសួងធម្មការ និងសាសនា, មន្ត្រីតំណាងមកពីក្រសួងវប្បធម៌, ពីក្រសួងអប់រំ, ពីបណ្ណាល័យជាតិ និងមន្ត្រីតំណាងអង្គការជំនួយសូតូស្ហ៊ូជប៉ុន ចូលរួមផង ។

សៀវភៅទាំង ១២៨៥ ក្បាលនោះ រួមមាន សៀវភៅផ្នែកវប្បធម៌ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ និងសិល្បៈ បានមកតាមរយៈការខិតខំប្រឹងប្រែងរបស់លោកសាស្ត្រាចារ្យ អូណូ ហ្សាវ៉ា និងលោកសាស្ត្រាចារ្យ អ៊ីស៊ី ហ្សាវ៉ា នៃវិទ្យាស្ថានប្រវត្តិសាស្ត្រ និងនរវិទ្យា នៅសាកលវិទ្យាល័យ ត្សូគូបា និងសាកលវិទ្យាល័យ សូភិយ៉ា, ប្រទេសជប៉ុន ។

នៅក្នុងឱកាសប្រគល់សៀវភៅនោះ លោក អាឡាំង ហ្វាំងស្តែន បានថ្លែងថា មូលនិធិសំរាប់អាស៊ីរបស់ជប៉ុន បានជួយដល់ប្រទេសកម្ពុជា តាំងពីទសវត្ស ៨០ មកម្ល៉េះ ។ ចំពោះពុទ្ធសាសនបណ្ឌិត្យ មូលនិធិសំរាប់អាស៊ី របស់ជប៉ុន



សៀវភៅអំណោយពីមូលនិធិសំរាប់អាស៊ី របស់ជប៉ុន

បានជួយ ចាប់តាំងពីស្ថាប័ននេះ ត្រូវបានរៀបចំអោយដំណើរការឡើងវិញមកដែរ ដើម្បីឆ្លើយតបនូវអ្វីដែលជាសំណូមពររបស់វិទ្យាស្ថាននេះ ដែលធ្លាប់តែជាមជ្ឈ-មណ្ឌលឯកសារសមោធានមួយយ៉ាងធំរបស់ប្រទេសកម្ពុជានោះ ។ សៀវភៅទាំងអស់នេះ គឺជាប្រភពនៃវប្បធម៌, នៃពុទ្ធិ សំរាប់បំរើគុណប្រយោជន៍របស់ប្រជា-រាស្ត្រខ្មែរ ក្នុងសម័យបច្ចុប្បន្ន និងអនាគត ។

ថ្លែងស្វាគមន៍ក្នុងឱកាសនោះ ឯកឧត្តម ហៀន វណ្ណីរត្ន រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា បានសំដែងសេចក្តីសប្បាយរីករាយ ជាមួយនឹងអំណរគុណ និងការដឹងគុណដ៏ជ្រាលជ្រៅ ចំពោះមូលនិធិសំរាប់អាស៊ីរបស់ជប៉ុន ដែលបានផ្តល់អំណោយជាសៀវភៅយ៉ាងច្រើនដល់ពុទ្ធសាសនបណ្ឌិត្យ ដោយមានលោកអាឡាំង ហ្វាំងស្តែន តំណាងមូលនិធិ អញ្ជើញមកធ្វើពិធីប្រគល់ជាផ្លូវការ នៅក្នុងឱកាសនេះ ។ សៀវភៅទាំងនេះ មានសារសំខាន់ណាស់ សំរាប់ប្រជារាស្ត្រខ្មែរដែលកំពុងមានការខ្វះខាតឯកសារបង្កើតពុទ្ធិរបស់ខ្លួន ។ ជាមួយគ្នានេះ ឯកឧត្តមក៏បានថ្លែងអំណរគុណ និង ដឹងគុណចំពោះអង្គការនានារបស់ជប៉ុន មានអង្គការ



សៀវភៅអំណោយពីមូលនិធិសំរាប់អាស៊ី របស់ជប៉ុន



បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ

ជំនួយសូត្តស៊ូជប៉ុនជាដើម រួមទាំងមូលនិធិហោនិរិចបឹល របស់អាល្លឺម៉ង់ផង ដែលបានចំណាយថវិកាយ៉ាងច្រើន ជួយដល់ពុទ្ធសាសនបណ្ឌិត្យ ទាំងផ្នែកបោះពុម្ព ទាំងផ្នែកបណ្តុះបណ្តាល ដែលយើងខ្ញុំមានសង្ឃឹម និងជឿជាក់ថា នៅពេលអនាគត ពុទ្ធ-សាសនបណ្ឌិត្យ នឹងបានទៅជាមជ្ឈមណ្ឌលឯកសារសមោធានមួយដ៏សំខាន់ របស់ប្រទេសកម្ពុជា ដូចនៅក្នុងអតីតកាល ។

ឯកឧត្តមក៏បានធ្វើសំណូមពរសុំអោយមូលនិធិសំរាប់អាស៊ីរបស់ជប៉ុន, អង្គការជំនួយសូត្តស៊ូជប៉ុន និងអង្គការនានារបស់ជប៉ុន ជួយឧបត្ថម្ភបន្តទៅទៀត ទាំងសម្ភារៈ ទាំងហិរញ្ញវត្ថុ ដើម្បីពង្រឹងតួនាទីស្ថាប័ននេះអោយកាន់តែរឹងមាំ ។

បន្ទាប់មក ភ្ញៀវទាំងអស់បានអញ្ជើញទស្សនាសៀវភៅអំណោយ ដែលបានរៀបចំយ៉ាងរៀបរយដាក់ក្នុងទូ និងទស្សនាបណ្ណាល័យ ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល ។

ពុទ្ធសាសនបណ្ឌិត្យ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ប្រាសាទភ្នំបាគង កសាងនៅក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី ១ នាឆ្នាំ ៨៨១ នៃគ.ស

ឆ្នាំទី ៥១ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា

ព.ស ២៥៤១ គ.ស ១៩៩៧

ភ្នំពេញ

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ណារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **ឃី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហោខ លាខហោ**

លោក **ម៉ែន រដ្ឋាខ**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងាររបស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូត្តូស៊ូជប៉ុន (JSRC) ។

យើខ្ញុំអធិដ្ឋាន សូមអោយទស្សនាវត្តីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាពរវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្ប-ធម៌ និងសម្បត្តិសាសនារបស់ប្រជាជនកម្ពុជា ។

## Acknowledgement

The Kambuja Suriya Magazine is specilly printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# មាតិកាអត្ថបទ

**I.** អក្សរសិល្ប៍ពុទ្ធសាសនា ៖


- ធម៌ត្រីនៃពុទ្ធសាសនា ( ឈន អៀម ) ........ ១
- សីល ១០ សំរាប់គ្រហស្ថ ( ឱម ខៃម ) ........ ២៤


**II.** អក្សរសាស្ត្រទូទៅ ៖


- ពាក្យរណ្តំបរិវារស័ព្ទក្នុងភាសាអក្សរសិល្ប៍ខ្មែរ ( ឡុង សៀម ) ........ ៣៨
- សិលាចារឹកថ្មីមួយ នៅស្រុកព្រៃកប្បាស ( វង់ សុធារ៉ា ) ........ ៤៤
- វិស័យឧត្តមសិក្សា និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ( នេត បារ៉ុម ) ........ ៦១
- សុខភាពជាលាភដ៏ពិសិដ្ឋ ( ឱម ខៃម, ម៉ែន ប្រាង ) ........ ៨៣
- ការចិញ្ចឹមនាង ( មៀច ប៉ុណ្ណ ) ........ ៩១
- បទអក្សរសង្វាស ( ធន់ ហ៊ិន ) ........ ១០៤
- ថ្មចំណាស់មានតម្លៃ ( ខៀវ បញ្ញារ៉ុឌ្ឍ ) ........ ១០៨


**III.** កំណត់ និង ប្រវត្តិការណ៍ ៖


- រចនាសម្ព័ន្ធគ្រប់គ្រងគណៈសង្ឃ ( ម៉ី យ៉ាំ ) ........ ១១០

# ធមិគ្រឹះ នៃ ពុទ្ធសាសនា

ដោយ លោក ភីទ័រ ដ. សន្ទិនា

( By Peter D. Santina )

បកប្រែដោយ : **ឈន អៀម**

*ក.ក.ន. អត្ថបទតទៅនេះ គឺជាចង្កោមអត្ថបទឧទ្ទេសកថាចំនួនដប់ពីរ ( a series of twelve lectures ) ដែលបានសំដែងឡើងដោយលោក សន្ទិនា តាមការអញ្ជើញរបស់ព្រះ ន. សុមនថេរ នៅវត្តស្រីលង្ការាមយៈ ក្នុងប្រទេសសិង្ហបុរី នាឆ្នាំ ១៩៨៤ ។*

*អត្ថបទទាំងដប់ពីរ គឺជាអត្ថបទសំដែងដោយផ្ទាល់មាត់ ឬនិយាយម្យ៉ាងទៀតថា ជាអត្ថបទទេសនាដោយផ្ទាល់មាត់ ។ ដូច្នេះ ពាក្យពេចន៍ ឃ្លា ប្រយោគ ក៏ត្រូវបានបកប្រែសរសេរក្នុងរចនាបថមួយដ៏សាមញ្ញដែរ ដើម្បីរក្សានូវសម្រស់ឃ្លា ប្រយោគនិយាយផ្ទាល់មាត់ របស់លោកសន្ទិនា ។*

*ខ្ញុំផ្ទាល់ខ្លួន ក៏បានយល់ស្របតាមយោបល់របស់ព្រះសុមនថេរ នៅក្នុងអារម្ភកថានៃសៀវភៅ « ធមិគ្រឹះរបស់ពុទ្ធសាសនា » នេះដែរថា « អស់កាលដ៏យូរលង់ហើយ ពុទ្ធ-សាសនា គឺជាផ្នែកដ៏សំខាន់មួយនៃបេតិកភណ្ឌវប្បធម៌ នៃទ្វីបអាស៊ីភាគអាគ្នេយ៍ ។ ... វាជាការពិតណាស់ ប្រសិនបើពុទ្ធសាសនានៅតែបន្តជះឥទ្ធិពលជាវិជ្ជមានមកលើជំនាន់មនុស្សបច្ចុប្បន្ន និងអនាគត, នោះព្រះពុទ្ធសាសនាមិនអាចពេញចិត្តពេញថ្លើមតែនឹងសមិទ្ធផល ក្នុងអតីតកាលរបស់ខ្លួនទេ ។ ឧត្តមគតិសាសនា និងតម្លៃសីលធម៌របស់ព្រះពុទ្ធសាសនា ដែលបានបង្ហាញជាភស្តុតាងថា មានប្រយោជន៍ណាស់ចំពោះជំនាន់មនុស្សក្នុងអតីតកាល ត្រូវតែបានបន្តទៅឱ្យមនុស្សប្រុស-ស្រី ដែលកំពុងតែរស់នៅក្នុងពិភពលោកដ៏ប្រែប្រួលនេះ ។ ដើម្បីឱ្យគំនិតនេះអាចសំរេចបាន, ជាការសំខាន់ វាទាល់តែព្រះធម៌ ឬពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មានត្រៀមជាស្រេច សម្រាប់ឱ្យមនុស្សភាគច្រើនបានចេះដឹង » ។*

*ដោយមានគំនិតដូចនេះនៅក្នុងចិត្តហើយ ទើបខ្ញុំខិតខំបកប្រែអត្ថបទឧទ្ទេសកថា ឬធម៌ទេសនាដូចតទៅនេះ ទុកជាវិភាគទានដល់ការចេះដឹង ឬការត្រិះរិះរបស់អ្នកអានយើង ។*

# ពុទ្ធសាសនា : ទស្សនវិស័យសម័យថ្មី

យើងនឹងនិយាយគ្រូបដណ្តប់លើប្រធានបទ ដែលយើងអាចហៅថា *ពាក្យប្រៀនប្រដៅជាគ្រឹះរបស់ព្រះពុទ្ធ* តាមរយៈចង្កោមឧទ្ទេសកថាចំនួនដប់ពីរ ។ យើងនឹងនិយាយអំពីពុទ្ធជីវប្បវត្តិ, អរិយសច្ចៈបួន, អរិយមគ្គៈប្រាំបី, កម្ម, ការកើតទៀត, បដិសច្ចសមុប្បាទ, សាកលលក្ខណៈបី និងខន្ធប្រាំ ។ ប៉ុន្តែ មុននឹងចាប់ផ្តើមលើកយកឧទ្ទេសកថាទាំងឡាយមកសំដែង, ខ្ញុំសូមនិយាយថ្ងៃនេះ អំពីជំនឿនៃពុទ្ធសាសនា ក្នុងទិដ្ឋភាពអនាគតជាមុនសិន ។ មានបែបបទច្រើនណាស់ ដែលនៅក្នុងនេះ មនុស្សផ្សេងៗគ្នា រស់នៅក្នុងវប្បធម៌ខុសៗគ្នា បានសម្លឹងសញ្ជឹងគិតពីពុទ្ធសាសនា ហើយជាពិសេស, ខ្ញុំគិតថា យើងអាចបង្ហាញនូវភាពផ្ទុយគ្នានៃអាកប្បកិរិយាទំនើប ឬអាកប្បកិរិយាលោកខាងលិចចំពោះ *ពុទ្ធសាសនា* ទៅនឹងអាកប្បកិរិយាប្រពៃណីចំពោះពុទ្ធសាសនា ។ ហេតុផលគឺ : ហេតុអ្វីក៏ការសិក្សាទិដ្ឋភាពអនាគតប្រភេទនេះមានសារប្រយោជន៍, នោះក៏ពិព្រោះតែកាលណាយើងយល់ថាមនុស្សរស់ក្នុងវប្បធម៌ខុសៗគ្នា តើគេសម្លឹងសញ្ជឹងគិតពីអ្វីមួយ យ៉ាងដូចម្តេច, បន្ទាប់មក យើងក៏អាចចាប់ផ្តើមមើលឃើញកំរិតព្រំដែន ឬភាពឃើញតែមួយជ្រុងៗនៃទស្សនៈរបស់យើង ។

នៅក្នុងប្រទេសលោកខាងលិច *ពុទ្ធសាសនា* បានបំផុសឱ្យមានការជាប់ចិត្ត និងសមានចិត្តដ៏ទូលំទូលាយ ។ មានមនុស្សជាច្រើនដែលមានមុខមាត់សំខាន់ៗ

នៅក្នុងសង្គមលោកខាងលិចគឺ ជាអ្នកកាន់ពុទ្ធសាសនា ឬជាអ្នកមានសមានចិត្តរាប់អានពុទ្ធសាសនា ។ នេះគឺជាឧទាហរណ៍មួយដ៏ច្បាស់បំផុត តាមរយៈការកត់សម្គាល់របស់លោក អាលប៊ែត៍ អាយស្តាយ ( Albert Einstein ) នៅក្នុងជីវប្រវត្តិផ្ទាល់របស់លោក ។ កំណត់បានសរសេរថា លោកពុំមែនជាអ្នកជឿសាសនាទេ, ប៉ុន្តែប្រសិនបើលោកជឿវិញ, លោកនឹងជាអ្នកជឿពុទ្ធសាសនាម្នាក់ ។ នេះគឺជាការកត់សម្គាល់គួរឱ្យភ្ញាក់ផ្អើលមួយ, ហើយដោយពុំបានគិតទុកមុន យើងមិនគួរសង្ឃឹមថាមានការកត់សម្គាល់បែបនេះធ្វើឡើងដោយបិតានៃវិទ្យាសាស្ត្រទំនើបទេ ។ ប៉ុន្តែបើយើងក្រឡេកមើលសង្គមលោកខាងលិចសហសម័យ, យើងនឹងឃើញអ្នកតារាវូបវិទ្យាម្នាក់ ដែលជាអ្នកជឿពុទ្ធសាសនានៅប្រទេសបារាំង, យើងនឹងឃើញចិត្តវិទូដ៏ល្បីល្បាញម្នាក់ ដែលជាអ្នកកាន់ពុទ្ធសាសនា ធ្វើការនៅសាកលវិទ្យាល័យនៃក្រុងរ៉ូម, ហើយនៅពេលថ្មីៗនេះ ចៅក្រមម្នាក់មកពីប្រទេសអង់គ្លេស ក៏ជាអ្នកកាន់ពុទ្ធ-សាសនា ។ យើងនឹងពិចារណានូវហេតុ-ផល ដែលនាំឱ្យកើតមានការជាប់ចិត្តបែបនេះ ក្នុង *ពុទ្ធសាសនា* នៅប្រទេសលោកខាងលិចក្នុងពេលឥឡូវនេះ ។ ប៉ុន្តែ មុនយើងពិចារណារឿងនេះ, ខ្ញុំសូមប្រៀបធៀបស្ថានភាពនេះ ជាមួយស្ថានភាពដែលយើងធ្លាប់ឃើញមាននៅក្នុងផ្នែកនេះនៃពិភពលោក ។

នៅទ្វីបអឺរុបជាទូទៅ អាកប្បកិរិយាចំពោះ *ពុទ្ធសាសនា* គឺជាអាកប្ប-កិរិយាជឿនលឿនណាស់, ច្បាស់លាស់ណាស់ ហើយស្មុគស្មាញ និងល្អិតល្អន់ណាស់ ។ ដោយហេតុនេះ វាជាការខកចិត្តពេកណាស់ចំពោះខ្ញុំ នៅពេលខ្ញុំមកដល់សិង្ហបុរី ហើយបានឃើញថាមានមនុស្សជាច្រើននៅទីនេះបានមើលឃើញ និងចាត់ទុក *ពុទ្ធសាសនា* ថាជាសាសនាចាស់ហួសសម័យ, មិនសមហេតុ-ផល ហើយភ្ជាប់ខ្លួនយ៉ាងមាំទៅនឹងអប្បិយជំនឿ ។ នេះគឺជាអាកប្បកិរិយាមួយ ក្នុងបណ្តាអាកប្ប-កិរិយាពីរ ដែលកំពុងដើរបញ្ច្រាសគ្នា ក្នុងការវាយតម្លៃ *ពុទ្ធសាសនា* នៅទីនេះ ។

អាកប្បកិរិយាមួយទៀត យល់ថា *ពុទ្ធសាសនា* មានគម្ពីរភាពពេកណាស់, មានអរូបិយភាពណាស់ ទាល់តែគ្មាននរណាម្នាក់យល់ *ពុទ្ធសាសនា* បាន ។ នេះគឺជាការត្រឡប់បែរក្រោយទាំងស្រុងមួយ ។ នេះហើយគឺជាអ្វីដែលខ្ញុំចង់និយាយពីទស្សន-វិស័យ ( Perspective ) ពិព្រោះ នៅក្នុងទស្សនវិស័យរបស់លោកខាងលិច ពុទ្ធសាសនាមានរូបភាពបែបណាមួយ, ចំណែកនៅក្នុងទស្សនវិស័យជាប្រពៃណីវិញ យើងមានរូបភាពមួយផ្សេង ។ រូបភាពអវិជ្ជមាននេះ ដែលមនុស្សទាំងឡាយកំពុងតែមើលឃើញចំពោះ *ពុទ្ធសាសនា* នោះ, ត្រូវតែបានផ្លាស់ប្តូរ, មុនពេលមនុស្សទាំងឡាយនោះឈានដល់ការកោតសរសើរព្រះធម៌ ឬពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, និងមុនពេលមនុស្សទាំងនោះអាចចាប់យកបាននូវទស្សនវិស័យ ដ៏មានតុល្យភាពបែបណាមួយ ចំពោះ *ពុទ្ធសាសនា* ។

ទស្សនៈមួយក្នុងបណ្តាទស្សនៈទាំងឡាយដំបូងគេ ដែលអ្នកនៅប្រទេសខាងលិចម្នាក់កោតសរសើរពុទ្ធសាសនា នោះគឺពុទ្ធសាសនាមិនជាប់ជំពាក់ដោយវប្បធម៌, មិនជាប់ជំពាក់ដោយសង្គមពិសេសណាមួយ, ដោយពូជជាតិ ឬដោយក្រុមជនជាតិពិសេណាមួយឡើយ ។ មានសាសនាទាំងឡាយខ្លះ ដែលបានភ្ជាប់ខ្លួនទៅនឹងវប្បធម៌, ត្បូយ៉ាងសាសនាជូដាយ ( Judaism ) ។ ពុទ្ធសាសនាមិនដូច្នោះទេ ។ ដោយហេតុនេះ បើនិយាយតាមប្រវត្តិសាស្ត្រ យើងមានពុទ្ធសាសនិកឥណ្ឌា, ពុទ្ធសាសនិកថៃ, ពុទ្ធសាសនិកចិន, ពុទ្ធសាសនិកស្រីលង្កា, ពុទ្ធសាសនិកភូមា និងពុទ្ធសាសនិកជនជាតិឯទៀតៗ, ហើយយើងនឹងមាននៅក្នុងពេលខាងមុខដ៏ខ្លីនេះ ពុទ្ធសាសនិកអង់គ្លេស, ពុទ្ធសាសនិកបារាំង, ពុទ្ធសាសនិកអាមេរិកាំង និងពុទ្ធសាសនិកជាតិឯទៀតៗ ។ នេះក៏ព្រោះតែពុទ្ធសាសនាមិនជាប់ជំពាក់ដោយវប្បធម៌ ។ ពុទ្ធ-សាសនាចល័តចេញយ៉ាងងាយស្រួលណាស់ ពីវប្បធម៌មួយទៅវប្បធម៌មួយទៀត ពិព្រោះអត្ថរស (the emphasis) នៅក្នុង*ពុទ្ធសាសនា* គឺឋិតនៅលើការប្រតិ-

បត្តិខាងក្នុងជាជាងលើការប្រតិបត្តិខាងក្រៅ ។ អត្ថរសរបស់ពុទ្ធសាសនា ឋិតលើបែបបទដែលលោកអ្នកខិតខំធ្វើចិត្តរបស់លោកអ្នកឱ្យរីកចំរើន ជាជាងបែបបទដែលលោកអ្នកស្លៀកពាក់, ប្រភេទអាហារដែលលោកអ្នកបរិភោគ, បែបបទដែលលោកអ្នកកាត់សក់ ឬទុកសក់ ហើយនិងបែបបទផ្សេងទៀត ។

ចំណុចទីពីរ ដែលខ្ញុំសូមលើកមកនិយាយ គឺទាក់ទងលទ្ធផលនិយម [(១)] ( Pragmatism ) ឬភាពជាក់ស្តែងនៃពុទ្ធសាសនា ។ ជាជំនួសការយកចិត្តទុកដាក់ក្នុងអស្តិរូបវិទ្យា ( Metaphysics ) និងទ្រឹស្តីរៀនសូត្រក្នុងសាលា, ព្រះពុទ្ធបានលើកយកមកពិចារណាបញ្ហាជាក់ស្តែង ហើយរកវិធីដោះស្រាយបញ្ហាទាំងនោះ ក្នុងបែបបទមួយជាក់ស្តែង ។ នេះក៏ជាចំណុចមួយទៀត ដែលសមស្របពន់ពេកជាមួយមតិទាំងឡាយរបស់លោកខាងលិចស្តីពីប្រយោជន៍និយម ( Utilitarianism ) ។ វាមានន័យថា បើអ្វីមួយប្រើការបាន, ចូរប្រើប្រាស់វាទៅ ។ នេះគឺជាផ្នែកមួយ ដ៏ពិតជាក់ស្តែងនៃទស្សនវិជ្ជាខាងនយោបាយ, សេដ្ឋកិច្ច និងវិទ្យាសាស្ត្ររបស់លោកខាងលិច ។ អាកប្បកិរិយានៃលទ្ធផលនិយមនេះ ត្រូវបានសំដែងយ៉ាងច្បាស់ នៅក្នុងចូឡមលុង្ក្យាសូត្រ ដែលនៅក្នុងព្រះសូត្រនេះ គេបានប្រើប្រាស់ឧទាហរណ៍មនុស្សត្រូវរបួស ។ មនុស្សដែលត្រូវរបួសដោយព្រួញមួយ តើចាំបាច់ត្រូវដឹងថា នរណាបាញ់ព្រួញនេះ, ព្រួញនេះចេញមកអំពីទិសណា, តើក្បាលព្រួញធ្វើអំពីឆ្អឹង ឬអំពីដែក, តើដងព្រួញធ្វើអំពីឈើបែបនេះ ឬអំពីអ្វីផ្សេងទៀត, មុនពេលមនុស្សរបួសនោះ ត្រូវបានគេដកព្រួញចេញ ។ មនុស្សនេះ ដូចគ្នានឹងអ្នកទាំងឡាយណា ដែលប្រាថ្នាចង់ដឹងអំពីដើមកំណើតនៃចក្រវាឡថា តើពិភពលោកឋិតថេរជានិរន្តរ៍ ឬអត់, មានកំរិតព្រំដែន ឬអត់ មុនពេលមនុស្សទាំងនោះ នឹងចាប់ប្រតិបត្តិតាមសាសនាណា

(១) ជំនឿថា សច្ចៈ ឬតម្លៃរបស់ទ្រឹស្តីណាមួយក៏ដោយ អាចវិនិច្ឆ័យបានតែតាមលទ្ធផលជាក់ស្តែងរបស់ទ្រឹស្តីនោះ ប៉ុណ្ណោះ ។

មួយ ។ ដូចជាមនុស្សនៅក្នុងរឿងនិទាននេះដូច្នោះ គេនឹងស្លាប់ មុនពេលគេបានទទួលចម្លើយទាំងអស់ ដែលគេចង់ដឹងទាក់ទងនឹងដើមកំណើត និងធម្មជាតិ នៃព្រួញ, មនុស្សទាំងឡាយដូចនេះ នឹងស្លាប់មុនពេលគេនឹងទទួលបានចម្លើយទាក់ទងនឹងសំណួរដ៏ឥតមានសារសំខាន់ទាំងអស់របស់គេ ។ នេះជាឧទាហរណ៍បញ្ជាក់ នូវអ្វីដែលយើងហៅថា អាកប្បកិរិយាជាក់ស្តែងរបស់ព្រះពុទ្ធ ។ នៅមានរឿងច្រើនទៀត ដែលត្រូវនិយាយអំពីសំណួរទាំងមូល ស្តីអំពីអាទិភាព និងការដោះស្រាយបញ្ហា ។ យើងនឹងមិនមានវឌ្ឍនភាពដើម្បីធ្វើឱ្យបញ្ញារីកចំរើនបានទេ, ប្រសិនបើយើងចោទសំណួរខុស ។ ជាសំខាន់នោះ គឺសំណួរស្តីអំពីអាទិភាព ។ អាទិភាពមុនគេបង្អស់សម្រាប់យើងទាំងអស់គ្នា គឺបញ្ហានៃ *ទុក្ខ* ។ ព្រះពុទ្ធបានទទួលស្គាល់បញ្ហានេះ ហើយបានមានពុទ្ធដីកាថា វាគ្មានប្រយោជន៍អ្វីមួយសម្រាប់យើង ដើម្បីត្រិះរិះពិចារណា ថាតើពិភពលោកបិតថេរ ឬអត់ ពិព្រោះយើងទាំងអស់គ្នា ត្រូវបានព្រួញចាក់ជាប់ក្នុងទ្រូងរបស់យើងហើយ, ព្រួញនោះ គឺព្រួញនៃសេចក្តី *ទុក្ខ* ។ យើងត្រូវចោទសំណួរទាំងឡាយណា ដែលអាចនាំយើងទៅដល់ការដកយកព្រួញនោះចេញ ។ គេអាចបង្ហាញគំនិតនេះ នៅក្នុងបែបបទយ៉ាងសាមញ្ញបំផុតមួយទៀត ដូចតទៅនេះ ។ យើងអាចឃើញថា នៅក្នុងជីវភាពរាល់ថ្ងៃរបស់យើង, យើងតែងធ្វើការជ្រើសរើសជាប្រចាំ ដោយផ្អែកលើអាទិភាព ។ ឧទាហរណ៍ថា ប្រសិនបើយើងត្រូវស្ងោរសណ្តែកនៅលើចង្ក្រានហ្គាស ហើយយើងគិតថា នៅពេលគ្រាប់សណ្តែកកំពុងតែពុះ យើងត្រូវជូតបោសផ្ទះ, ហើយនៅពេលយើងកំពុងជូតបោសផ្ទះ យើងធុំក្លិនអ្វីមួយខ្លោច ។ ពេលនោះ យើងត្រូវធ្វើការជ្រើសរើស ថាតើត្រូវបន្តជូត បោសផ្ទះទៀត ឬត្រូវទៅមួលបន្ថយភ្លើងចង្ក្រានហ្គាសកុំឱ្យគ្រាប់សណ្តែកខ្លោច ។ ដូចគ្នានេះដែរ, ប្រសិនបើយើងចង់ឱ្យមានវឌ្ឍនភាពឆ្ពោះទៅរកការធ្វើឱ្យបញ្ញា រីកចំរើន, យើងត្រូវទទួលស្គាល់អាទិភាពទាំងឡាយរបស់យើង ហើយចំណុចនេះ ត្រូវបាន

លើកមកអធិប្បាយយ៉ាងច្បាស់លាស់ណាស់ហើយ នៅក្នុងរឿងនិទាន ស្តីពីមនុស្ស ត្រូវរបួសខាងលើ ។

ចំណុចទីបី ដែលខ្ញុំសូមលើកយកមកនិយាយ គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ស្តីពីសារប្រយោជន៍នៃការពិនិត្យពិចារណាតាមរយៈបទពិសោធន៍ ។ ចំណុចនេះត្រូវបានអធិប្បាយយ៉ាងច្បាស់នៅក្នុង *កេសបុត្តិយសូត្រ* ។ ពួកកាលាមៈ គឺជាមនុស្សដូចពួកយើង នៅក្នុងសម័យបច្ចុប្បន្ននេះ នៅពេលដែលយើងកំពុងតែប្រឈមមុខនឹងការប្រៀនប្រដៅសាសនាផ្សេងៗជាច្រើន ។ ពួកកាលាមៈទាំងនោះបាននាំគ្នាទៅរកព្រះពុទ្ធ ហើយបានទូលសួរព្រះអង្គថា : ព្រះអង្គអើយ មានគ្រូប្រដៅសាសនាផ្សេងៗច្រើនណាស់ ហើយគ្រូសាសនាទាំងអស់នោះប្រកាសថា ទ្រឹស្តីរបស់ពួកគេទើបពិត, តើពួកគាត់ ( កាលាមៈ ) យល់ដឹងដូចម្តេចបានទៅ ថាគ្រូប្រដៅសាសនាណាផ្សព្វផ្សាយប្រាប់ពាក្យពិត ( សច្ចះ ) ។ ព្រះពុទ្ធទ្រង់ប្រាប់អ្នកកាលាមៈទាំងនោះថា : ចូរអ្នកកុំទទួលជឿអ្វីមួយតាមការប្រើអាជ្ញា, កុំទទួលជឿអ្វីមួយពិព្រោះតែអ្វីនោះត្រូវបានសរសេរកត់ត្រាទុក, កុំទទួលជឿអ្វីមួយដោយសារតែការគោរពចំពោះគ្រូអាចារ្យរបស់ខ្លួន ឬដោយសារឮគេនិយាយ, ឬក៏ពិព្រោះតែអ្វីនោះស្តាប់ឮហើយហាក់មានហេតុ - ផល ។ ផ្ទុយទៅវិញ គេត្រូវតែពិនិត្យបញ្ជាក់ ឬពិសោធអ្វីមួយដែលពួកគេបានស្តាប់ បានឮក្រោមពន្លឺនៃបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ។ នៅពេលណាពួកគេដឹងច្បាស់ដោយខ្លួនគេ ថាអ្វីៗខ្លះបង្កឱ្យមានមហន្តរាយនោះ, បន្ទាប់មក ពួកគេគប្បីបោះបង់ចោលអ្វីៗនោះទៅ ។ កាលណាពួកគេដឹងដោយខ្លួនគេផ្ទាល់ ថាអ្វីៗខ្លះមានអត្ថប្រយោជន៍, នាំឱ្យកើតមានសុភមង្គល និងសុខក្សេមក្សាន្ត, បន្ទាប់មកពួកគេគប្បីប្រតិបត្តិតាមអ្វីៗនោះទៅ ។ ព្រះពុទ្ធផ្តល់ដំបូន្មាននេះថា : បុគ្គលត្រូវពិនិត្យបញ្ជាក់នូវអ្វីដែលបុគ្គលនោះស្តាប់ឮក្រោមពន្លឺនៃបទពិសោធន៍របស់ខ្លួន ។ នៅក្នុងបរិបទនៃការផ្តល់ដំបូន្មានរបស់ព្រះពុទ្ធ ចំពោះពួក

កាលាមៈ, ខ្ញុំគិតថា អ្វីដែលព្រះពុទ្ធបានទូន្មាន គឺដើម្បីឱ្យលោកអ្នកចេះប្រើខួរក្បាលផ្ទាល់របស់លោកអ្នកធ្វើជាបំពង់ពិសោធ ( the test-tube ) ។ លោកអ្នកអាចមើលឃើញដោយខ្លួនឯងផ្ទាល់ថា កាលណាមានលោភៈ និងទោសៈ, វានាំឱ្យមានទុក្ខ, សេចក្ដីឈឺចាប់, និងភាពមួរហ្មង ។ ហើយលោកអ្នកក៏អាចមើលឃើញដោយខ្លួនឯងផ្ទាល់ដែរថា កាលណា លោភៈ និងទោសៈ មិនមាននៅក្នុងចិត្តរបស់លោកអ្នកទេ, វានាំឱ្យមានសេចក្ដីស្ងប់, សុភមង្គល ។ នេះគឺជាការពិសោធន៍សាមញ្ញមួយដែលយើងទាំងអស់គ្នាអាចធ្វើបានដោយខ្លួនឯង ។ នេះគឺជាចំណុចមួយសំខាន់ពេកណាស់ ពិព្រោះអ្វីដែលព្រះពុទ្ធបានប្រៀនប្រដៅ នឹងមានប្រសិទ្ធភាពបាន, និងផ្លាស់ប្ដូរជីវភាពរបស់យើងដ៏ពិតប្រាកដបាន, លុះត្រាតែយើងអាចយល់បានច្បាស់នូវសច្ចៈនៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ តាមរយៈបទពិសោធន៍ផ្ទាល់របស់យើង ហើយពិនិត្យបញ្ជាក់នូវសច្ចៈនៃពាក្យប្រៀនប្រដៅនោះ តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើង ។ មានតែធ្វើយ៉ាងនេះទេ ទើបយើងអាចនិយាយយ៉ាងពិតប្រាកដបានថាយើងកំពុងមានការរីកចំរើននៅលើមាគ៌ាឆ្ពោះទៅរកការត្រាស់ដឹង ។

យើងអាចមើលឃើញនូវភាពស្របគ្នាដ៏ច្បាស់ក្រឡែតមួយ រវាងវិធីដោះស្រាយបញ្ហារបស់ព្រះពុទ្ធ ហើយនឹងវិធីដោះស្រាយបញ្ហារបស់វិទ្យាសាស្ត្រ ចំពោះបញ្ហានៃវិជ្ជា ។ ព្រះពុទ្ធសង្កត់លើសារសំខាន់នៃការពិនិត្យអង្កេតជាបរានុម័ត ។ ការពិនិត្យអង្កេត គឺនៅក្នុងន័យជាកូនសោរចំពោះវិជ្ជាវិធីរបស់ព្រះពុទ្ធ ។ គឺការពិនិត្យអង្កេតនេះហើយ ដែលផ្ដល់វិជ្ជាអំពីអរិយសច្ចៈទីមួយ ក្នុងបណ្ដាអរិយសច្ចៈទាំងបួន គឺ *ទុក្ខសច្ចៈ* ។ នៅដំណាក់ចុងក្រោយនៃមាគ៌ារបស់ព្រះពុទ្ធ គឺការពិនិត្យអង្កេតនេះទៀត ដែលកំណត់នូវការសម្រេចបញ្ចប់បាននូវទុក្ខទាំងស្រុង ។ ដូច្នេះ នៅខាងដើម, កណ្ដាល និងខាងចុងនៃមាគ៌ារបស់ព្រះពុទ្ធ, ការពិនិត្យអង្កេតដើរតួរសំខាន់យ៉ាងក្រៃលែង ។ នេះគឺដូចគ្នានឹងតួនាទីនៃការពិនិត្យអង្កេតជាបរានុម័តនៅក្នុងប្រពៃណីវិទ្យា-

សាស្រ្ត ដែលបង្រៀនថា កាលណាយើងពិនិត្យអង្កេតបញ្ហាអ្វីមួយ យើងត្រូវជាដំបូងបង្អស់រៀបចំទ្រឹស្តីទូទៅមួយភ្ជាប់ដោយសម្មតិកម្មមួយច្បាស់លាស់ ។ យើងបានឃើញហេតុការដូចគ្នាកើតមាននៅក្នុងពាក្យប្រៀនប្រដៅនៃអរិយសច្ចៈទាំងបួន ហើយនៅក្នុងទីនេះ ទ្រឹស្តីទូទៅថែងថា អ្វីៗទាំងអស់សុទ្ធតែមានហេតុ, ឯសម្មតិ-កម្មច្បាស់លាស់គឺ ហេតុទាំងឡាយនៃទុក្ខ គឺតណ្ហា និងអវិជ្ជា ។ សច្ចៈដែលថែងថា តណ្ហា និងអវិជ្ជាជាហេតុនៃទុក្ខ អាចត្រូវបានពិនិត្យបញ្ជាក់ដោយវិធីពិសោធន៍ ។ នៅក្នុងបរិបទនៃអរិយសច្ចៈទាំងបួន វិធីពិសោធន៍ គឺជាមាគ៌ា ។ តាមរយៈមាគ៌ានេះ, សច្ចៈនៃអរិយសច្ចៈទីពីរ (ទុក្ខសមុទយសច្ចៈ) ហើយនិងអរិយសច្ចៈទីបី (ទុក្ខនិរោធ-សច្ចៈ) ត្រូវបានពិនិត្យបញ្ជាក់ ពិព្រោះតាមរយៈវិធីអប់រំចិត្តរបស់មាគ៌ានេះ គេអាចកំចាត់បាននូវតណ្ហា និងអវិជ្ជា ។ ហើយតាមរយៈការកំចាត់បាននូវតណ្ហា និងអវិជ្ជា គេអាចបំបាត់បាននូវ *ទុក្ខៈ* ។ ពិសោធកម្មនេះ ( This experiment ) អាចធ្វើហើយធ្វើទៀត ឱ្យដូចជា ការធ្វើពិសោធន៍នៅក្នុងវិទ្យាសាស្រ្ត ពិព្រោះមិនគ្រាន់តែព្រះពុទ្ធអង្គឯងបានសំរេច នូវការបញ្ចប់ទុក្ខប៉ុណ្ណោះទេ, សូម្បីមនុស្សណាទាំងអស់ដែលបានដើរតាមមាគ៌ារបស់ព្រះអង្គ ក៏អាចបានដល់នូវទីបញ្ចប់នៃទុក្ខដូចព្រះអង្គដែរ ។

ហេតុនេះ បើយើងក្រឡេកមើលឱ្យដិតដល់នូវវិធីដោះស្រាយបញ្ហារបស់ព្រះពុទ្ធចំពោះបញ្ហានៃវិជ្ជា, យើងឃើញថាវិធីដោះស្រាយបញ្ហារបស់ព្រះអង្គ គឺដូចគ្នានឹងវិធីដោះស្រាយបញ្ហារបស់វិទ្យាសាស្រ្ត ហើយហេតុការណ៍នេះ បានបង្កើតឡើងនូវការជាប់ចិត្តយ៉ាងធំសម្បើមក្នុងប្រទេសលោកខាងលិច ។ យើងអាចចាប់ផ្តើមយល់បានហើយថា ហេតុអ្វីបានជាលោក អាយស្តាយ (Einstein) អាចធ្វើការកត់សម្គាល់ដូចដែលលោកបានធ្វើរួចមកហើយ ។ យើងនឹងឃើញយ៉ាងច្បាស់ថែមទៀតថា ហេតុអ្វីក៏ហេតុការណ៍នេះ មិនជាការភ្ញាក់ផ្អើល ដូចដែលអាចកើតមានពី

ខាងដើម, នោះក៏ពិព្រោះតែខ្ញុំចង់និយាយអំពីវិភាគវិធីរបស់ពុទ្ធសាសនា ហើយយើងចាប់ផ្ដើមមើលឃើញវិភាគវិធីនេះ អាចប្រើប្រាស់បានយ៉ាងច្បាស់ក្រឡែត, កាលណា យើងប្រៀបធៀបមើលវិធីដោះស្រាយបញ្ហារបស់ពុទ្ធសាសនា ទៅនឹងការពិ-សោធន៍ ។

ការពិសោធន៍ក្នុងពុទ្ធសាសនា មានសមាសភាគពីរគឺ សមាសភាគបរានុ-ម័ត និងសមាសភាគអត្តានុម័ត ។ និយាយម្យ៉ាងទៀតគឺ អ្វីៗនៅជុំវិញយើង ហើយនិងយើងជាអ្នកមើលឃើញ ។ ពុទ្ធសាសនាមានកេរ្តិ៍ឈ្មោះ ដោយសារវិភាគវិធីរបស់ខ្លួន នៅក្នុងវិស័យនៃទស្សនវិជ្ជា និងចិត្តវិជ្ជា ។ អ្វីដែលយើងចង់និយាយតាមន័យនេះ នោះគឺថា ព្រះពុទ្ធបានធ្វើការវិភាគបែងចែកបទពិសោធន៍ទៅជាធាតុ ផ្សេងៗ, ធាតុដ៏ជាគ្រឹះរឹងមាំបំផុត នៃធាតុផ្សេងៗទាំងនោះ គឺខន្ធទាំងប្រាំ ឬបញ្ចក្ខន្ធ : រូប (form), វេទនា (feeling), សញ្ញា ( perception ) , សង្ខារ ( mental-formation or volition ), និងវិញ្ញាណ ( consciousness ) ។ ខន្ធទាំងប្រាំនេះក៏អាចត្រូវបានវិភាគបែងចែកទៅជាធាតុដប់ប្រាំបីយ៉ាងថែមទៀត, ហើយយើងអាចធ្វើវិភាគបែងចែកយ៉ាងល្អិតល្អន់ច្រើនទៀតទាក់ទងនឹងធាតុទាំងចិតសិបពីរនេះ ។ វិធីនេះ ហៅថាវិភាគវិធី ដោយសារវិធីនេះបំបែកអ្វីៗ ទៅជាបំណែកល្អិតៗ ។ យើងមិនពេញចិត្តត្រឹមតែសញ្ញាណមិនភ្លឺស្វាងនៃបទពិសោធន៍នោះទេ, ប៉ុន្តែ យើងវិភាគវា, យើងពិនិត្យរង្កេតវា, យើងបំបែកវាទៅជាសមាសភាគរបស់វា, ប៊ីដូចជាយើងបំបែករទេះមួយទៅជាកង់ ទៅជាភ្លៅ ៘ ។ យើងធ្វើយ៉ាងនេះគឺដើម្បីរកឱ្យឃើញគំនិតថាតើអ្វីៗទាំងនោះប្រព្រឹត្តទៅយ៉ាងដូចម្ដេច ។ ជាឧទាហរណ៍ កាលណាយើងឃើញផ្កាមួយទង, ឬស្ដាប់ភ្លេងមួយបទ, ឬក៏ជួបមិត្តម្នាក់, បទពិ-សោធន៍ទាំងអស់នេះកើតចេញមក គឺជាលទ្ធផលនៃសមាសភាគទាំងឡាយ ។ នេះហើយដែលគេឱ្យឈ្មោះថា វិភាគវិធីដោះស្រាយបញ្ហា ( the analytical appro-

ach ), ហើយវិភាគវិធីដោះស្រាយបញ្ហានេះទៀត ក៏ពុំចម្លែកអ្វីសោះ ចំពោះវិទ្យា-សាស្ត្រទំនើប និងទស្សនវិជ្ជា ។ យើងឃើញវិភាគវិធីដោះស្រាយបញ្ហា ប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងវិទ្យាសាស្ត្រ ។ នៅក្នុងទស្សនវិជ្ជា យើងមើលឃើញវិភាគវិធីប្រហែលជាច្បាស់លាស់បំផុត នៅក្នុងស្នាដៃរបស់លោក ប៊ែរត្រង់ រុស្សែល (Bertrand Russell) ។ នៅក្នុងនោះ មានការសិក្សា ដែលធ្វើការប្រៀបផ្ទឹមយ៉ាងជោគជ័យនូវទស្សនវិជ្ជារបស់លោកប៊ែរត្រង់ រុស្សែល ជាមួយទស្សនវិជ្ជា នៅក្នុងអភិធម្មរបស់ពុទ្ធសាសនា ។ ដូច្នេះ នៅក្នុងវិជ្ជាសាស្ត្រ និងទស្សនវិជ្ជា របស់លោកខាងលិច, យើងបានរកឃើញនូវភាពស្របគ្នាដ៏ជិតស្និទ្ធបំផុត ជាមួយវិភាគវិធីរបស់ពុទ្ធសាសនា ហើយភាពស្របគ្នានេះទៀត គឺជាលក្ខណៈសាមញ្ញមួយ ដែលទាក់ទាញពួកទស្សនវិទូ និងសាស្ត្រាចារ្យលោកខាងលិច មករកពុទ្ធសាសនា ។ នៅក្នុងវិស័យចិត្តវិទ្យា, មានចិត្តវិទូជាច្រើន ឥឡូវនេះ កំពុងជាប់ចិត្តយ៉ាងខ្លាំងក្នុងការវិភាគរបស់ពុទ្ធសាសនា អំពីកត្តាផ្សេងៗនៃបទពិសោធន៍ ដូចជា វេទនា មតិ ទម្លាប់ -ល-។ អស់លោកទាំងនោះ កំពុងបែរទៅរកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ( ពុទ្ធធម្ម ) ដើម្បីទទួលបានការយល់ដឹងកាន់តែជ្រាលជ្រៅ នៅក្នុងមុខជំនាញរបស់លោកទាំងនោះផ្ទាល់ ។

ការជាប់ចិត្តកាន់តែធំឡើងៗ នៅក្នុងពុទ្ធសាសនានេះ ហើយនិងវិស័យជាច្រើនមានជាប់ទាក់ទងគ្នារវាងពាក្យប្រៀនប្រដៅ ( ព្រះធម៌ ) របស់ព្រះពុទ្ធ ហើយនិងទំនោរនៃវិទ្យាសាស្ត្រ, ទស្សនវិជ្ជា និងចិត្តវិជ្ជាសម័យទំនើប បានឡើងដល់កំពូល ហើយនៅពេលនេះ ក្នុងការផ្តល់មតិយោបល់ ដែលបច្ចុប្បន្ននេះ ត្រូវបានស្នើឡើងដោយរូបវិទ្យាក្វាន់ទុម * (quantum physics) ដ៏ជាការលូតលាស់ចុងក្រោយ

* ទ្រឹស្តីក្វាន់ទុម នៅក្នុងរូបវិទ្យា ផ្អែកលើសម្មតិកម្ម ដែលថា ក្នុងការជះចេញរស្មី ឋាមពលរបស់អេឡិចត្រុង មានអត្ថិភាពជាចង្កោមឯកតា ( in units ) ដែលមិនអាចបំបែក ឬបែងចែកបានឡើយ ។

ក្រោយបំផុត នៅក្នុងរូបវិទ្យាពិសោធទ្រឹស្តី ។ នៅក្នុងទីនេះដែរ យើងបានឃើញថា មិនមែនតែវិធីវិទ្យាសាស្ត្រដែលផ្អែកលើការពិនិត្យអង្កេត, ការសាកល្បង, និងការវិភាគប៉ុណ្ណោះទេ ដែលព្រះពុទ្ធបានរកឃើញមុនគេ, ប៉ុន្តែនៅមានសេចក្តីសន្និដ្ឋាន ដ៏ជាក់លាក់បំផុតខ្លះទៀត ស្តីអំពីធម្មជាតិរបស់មនុស្ស ហើយនិងចក្រវាឡ ដែលការរីកចំរើនចុងក្រោយបំផុតនៃរូបវិទ្យាក្វាន់ទុម បានរកឃើញនោះ ក៏ត្រូវបានព្រះពុទ្ធរកឃើញរួចហើយដែរ ។ ឧទាហរណ៍ ដូចជាសារសំខាន់នៃចិត្ត ។ អ្នករូបវិទ្យា ដ៏ល្បីល្បាញម្នាក់ ក្នុងពេលកន្លងទៅមិនយូប៉ុន្មាននេះ បានកត់សម្គាល់ថា ចក្រវាឡ គឺតាមពិតទៅជាអ្វីមួយ ដូចជាគំនិតដ៏អស្ចារ្យមួយ (a great thought) ដូច្នោះ ។ ហើយទស្សនៈនេះ ក៏មាននិយាយនៅក្នុងគម្ពីរធម្មបទថា ចិត្តតែងនាំមុខអ្វីៗទាំងអស់, ចិត្តជាអ្នកបង្កើតនូវស្ថានភាពខួរក្បាលទាំងអស់ ។ ដូចគ្នានេះដែរ, សាបេក្ខភាពនៃរូបធាតុ និងថាមធាតុ ( the relativity of matter and energy ) ក៏ត្រូវបានអធិប្បាយផងដែរ ។ ពុំមានការបែងចែកដាច់ស្រឡះរវាងចិត្ត និងរូបធាតុទេ ។ ការពន្យល់ទាំងអស់នេះ កំពុងត្រូវបានគេបកស្រាយជាលំដាប់លំដោយ តាមរយៈការរីកចំរើនថ្មីៗ នៃវិទ្យាសាស្ត្រ ។

ដូច្នេះ អ្វីដែលបានកើតឡើងនោះ គឺថា នៅក្នុងបរិបទប្រទេសលោកខាងលិច, សាស្ត្រាចារ្យ, ចិត្តវិទូ និងអ្នកវិទ្យាសាស្ត្រ បានរកឃើញនៅក្នុងពុទ្ធសាសនានូវប្រពៃណីមួយ ដែលមានភាពស្របស្រួលជាមួយនឹងគោលការណ៍គ្រឹះមួយចំនួននៃគំនិតវិទ្យាសាស្ត្រលោកខាងលិច ។ បន្ថែមពីលើនេះ, អ្នកប្រាជ្ញទាំងនោះបានរកឃើញថា ពុទ្ធសាសនាមានសារសំខាន់ជាពិសេស ពិព្រោះ ទោះបីជាវិធី និងការរកឃើញទាំងឡាយដូចគ្នាយ៉ាងច្រើន ទៅនឹងគោលការណ៍គ្រឹះរបស់ពុទ្ធសាសនា ក៏ដោយ, ក៏លោកអ្នកប្រាជ្ញទាំងនោះមើលឃើញថា នៅក្នុងវិទ្យាសាស្ត្ររហូតមកដល់ពេលនេះ មិនទាន់មានមាត្រា ឬវិធីណាមួយសំរេចឱ្យបាននូវការប្រែប្រួល ពួដ៏ផ្ទៃក្នុង

បានទេ ។ លោកអ្នកប្រាជ្ញទាំងនោះ មានវិធីសាងសង់ទីក្រុងល្អៗ និងផ្លូវរថភ្លើងស្អាតៗ ប៉ុន្តែ គេពុំមានប្រព័ន្ធណាមួយ ដែលធ្វើឱ្យគេអាចកសាងមនុស្សបានប្រសើរទេ ។ ដូច្នេះ មនុស្សនៅក្នុងប្រទេសលោកខាងលិច កំពុងបែរមករកពុទ្ធសាសនាហើយ ។ ក្នុងឋានៈជាប្រពៃណីបរមបុរាណមួយ, ពុទ្ធសាសនាមានទិដ្ឋភាពដែលប្រហាក់ប្រហែលគ្នាជាច្រើន ទៅនឹងការប្រតិបត្តិ ( ការអនុវត្តន៍ ) នៅក្នុងប្រពៃណីវិទ្យាសាស្ត្រលោកខាងលិច ហើយពុទ្ធសាសនាបានដើរទៅមុខយ៉ាងឆ្ងាយហួសលទ្ធិ-សម្ភារនិយម នៃប្រពៃណីលោកខាងលិច, ហួសព្រំដែននៃប្រពៃណីវិទ្យាសាស្ត្រទៅទៀត ។

***

## (I)

## ស្ថានភាព និង ព្រឹត្តិការណ៍កើតមានមុនពុទ្ធសាសនា ( THE PREBUDDHIST BACKGROUND)

ថ្ងៃនេះ យើងនឹងចាប់ផ្ដើមពិចារណាមើលស្ថានភាព នៅក្នុងប្រទេសឥណ្ឌា មុនការកើតមានពុទ្ធសាសនា ។ តាមធម្មតា វគ្គសិក្សាអំពីពុទ្ធសាសនាតែងចាប់ផ្ដើមដោយការសិក្សាអំពីពុទ្ធជីវប្បវត្តិ ។ យើងនឹងចាប់ផ្ដើមសិក្សាសម័យកាល មុនពុទ្ធជីវប្បវត្តិទៅទៀត ។ ដោយផ្ទាល់ខ្លួន ខ្ញុំគិតថា ការសិក្សានេះមានសារ-សំខាន់ណាស់ ពិព្រោះខ្ញុំយល់ថា វាជួយឱ្យគេយល់នូវជីវិត និងការប្រៀនប្រដៅរបស់ព្រះពុទ្ធ នៅក្នុងបរិបទប្រវត្តិសាស្ត្រ និងកំណាកំណើតគំនិតនៃជីវិត និងពាក្យប្រៀនប្រដៅនោះបានទូលំទូលាយ ហើយយល់ និងផ្ដល់តម្លៃយ៉ាងប្រសើរដល់ចរិតនៃពុទ្ធ សាសនា ហើយក៏ប្រហែលផ្ដល់តម្លៃដល់ទស្សនៈរបស់ឥណ្ឌា ជារួមផងដែរ ។

ខ្ញុំពុំបានដឹងទេថា តើអស់លោកប៉ុន្មាននាក់បានទៅធ្វើទស្សនៈកិច្ចប្រទេសឥណ្ឌា ។ នៅភាគខាងជើងប្រទេសឥណ្ឌាមាន មហានទី ( ទន្លេធំ ) ពីរ . មួយ គឺ *ទន្លេគង្គា* និងមួយទៀតគឺ *ទន្លេយមុនា* ។ មហានទីទាំងពីរនេះ មានប្រភពទឹកដោយឡែកពីគ្នានៅក្នុងតំបន់ភ្នំ ហិមាល័យ ហើយហូរចុះមកដោយឡែកពីគ្នា អស់មួយភាគយ៉ាងវែងនៃប្រវែងរបស់ខ្លួន ។ មហានទីទាំងពីរ បានជួបគ្នានៅក្នុងតំបន់ឦសាននៃប្រទេសឥណ្ឌា ។ ចាប់ពីទីនោះទៅ, ទន្លេធំទាំងពីរ ហូរចុះទៅជាមួយគ្នាដល់ឆកសមុទ្របេ៉នហ្គាល់ ។ តាមដំណើរនេះ, ភូមិសាស្ត្រនៃមហានទីទាំងពីរនេះ គឺជានិមិត្តរូបមួយនៃដើមកំណើត និងការរីកចំរើននៃសាសនា, ទស្សនវិជ្ជា, និងគំនិតរបស់ឥណ្ឌា ពិព្រោះ នៅក្នុងសាសនាឥណ្ឌា ក៏មានចរន្តធំពីរដែលផ្សេងគ្នាស្រឡះដោយប្រភព និងមានដើមកំណើតផ្សេងពីគ្នា ហើយដែលផ្តាច់ចេញពីគ្នាអស់រយៈពេលមួយយ៉ាងវែង ប៉ុន្តែមកដល់ចំណុចពេលមួយបានរួមបញ្ចូលគ្នា ហើយប្រព្រឹត្តទៅជាមួយគ្នារហូតមកដល់សព្វថ្ងៃនេះ ។ ប្រហែលជានៅពេលដែលខ្ញុំកំពុងឈានចូលទៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសឥណ្ឌា, យើងអាចចងចាំនៅក្នុងចិត្ត នូវរូបភាពនៃមហានទីទាំងពីរ ដែលផ្សេងពីគ្នាដោយប្រភព ប៉ុន្តែ មកដល់ចំណុចមួយបានរួមបញ្ចូលគ្នា ហើយហូរចុះទៅជាមួយគ្នាដល់សមុទ្រ ។

កាលណា យើងក្រឡេកមើលប្រវត្តិសាស្ត្រសម័យដើមបំផុតនៃប្រទេសឥណ្ឌា យើងឃើញថា នៅសហស្សវត្សទីបីមុនគ្រិះសករាជ មានអារ្យធម៌រីកចំរើនយ៉ាងត្រចះត្រចង់មួយបានកើតមានឡើងនៅក្នុងអនុទ្វីបឥណ្ឌា ។ អារ្យធម៌នេះ ចាស់ទុំស្មើនឹងអារ្យធម៌ទាំងឡាយដែលគេឱ្យឈ្មោះថា សម្បុកនៃវប្បធម៌, អារ្យធម៌របស់មនុស្សជាតិដូចជា អារ្យធម៌ទាំងឡាយរបស់អេហ៊្សីប និងបាប៊ីឡូន ដូច្នោះ ។ អារ្យធម៌នេះ បានកើតមានប្រហែលនៅចន្លោះឆ្នាំ ២៨០០ មុន គ.ស និង ១៨០០ មុន គ.ស ។ គេស្គាល់អារ្យធម៌នោះថា *អារ្យធម៌ជ្រលងទន្លេឥណ្ឌុស* ( The Indus

Valley Civilization ) ឬជួនកាលគេហៅថា *អារ្យធម៌ហារប្បា* ( the Harappa, Civilization ) ហើយអារ្យធម៌នេះបានលាតសន្ធឹងពីតំបន់ដែលជាប្រទេសប៉ាគីស្ថានខាងលិច ឥឡូវនេះ, នៅទិសខាងត្បូងចំណុចដែលនៅជិតក្រុងបុមបៃ ហើយឆ្ពោះទៅទិសខាងកើតដល់ចំណុចដែលនៅជិតខាងនៃទីដែលជាស្រុកស៊ីមឡា ( Simla ) ក្នុងតំបន់ជើងភ្នំហិមាល័យ ។ ប្រសិនបើលោកអ្នកមើលផែនទីប្រទេសឥណ្ឌា, លោកអ្នកនឹងដឹងបានថា អារ្យធម៌នេះ មានវិសាលភាពដ៏សម្បើមណាស់ ។ អារ្យធម៌នេះមិនគ្រាន់តែមានស្ថិរភាពអស់កាលមួយពាន់ឆ្នាំប៉ុណ្ណោះទេ, ប៉ុន្តែ ជាអារ្យធម៌មួយ រីកចំរើនខ្ពស់ពេកណាស់ ទាំងខាងសម្ភារៈ ទាំងខាងបញ្ញាស្មារតី ។ ខាងសម្ភារៈ, អារ្យធម៌ គឺជាអារ្យធម៌ខាងក្សេត្រសាស្ត្រ ។ គេស្ទាត់ជំនាញខាងធ្វើទំនប់ ប្រឡាយ និងធ្វើផែនការរៀបចំទីក្រុង ។ បន្ថែមលើនេះ, គេមានកំរិតវប្បធម៌ខាងបញ្ញារីកចំរើនខ្ពស់ណាស់ ។ ហេតុការណ៍នេះត្រូវបានបញ្ជាក់យ៉ាងច្បាស់តាមរយៈភ័ស្តុតាងបុរាណវត្ថុ ដែលគេបានរកឃើញនៅ *មោហេនដោដារោ* និង *ហារប្បា* ( Mehenjodaro and Harappa ) ។ មានភ័ស្តុតាងផងដែរ អំពីហេតុការណ៍ដែលថា មនុស្សទាំងនោះជាអក្ខរជន ។ គេបានអភិវឌ្ឍអក្សរសរសេរដែលយើងសោកស្តាយ ដោយមិនអាចអានអក្សរនោះបាន ។

ជីវិតដ៏សុខសាន្តនៃអារ្យធម៌នេះ ត្រូវបានកាត់ផ្តាច់គួរឱ្យសោកស្តាយ នៅប្រហែលក្នុងឆ្នាំ ១៨០០ ឬ ១៥០០ មុន គ.ស. ដោយសារការរាតត្បាតមួយ ដែលចេញមកពីទិសពាយ័ព្យ ។ ពួកអ្នករាតត្បាត ត្រូវបានគេស្គាល់ថាជាពួក *អារ្យ័ន* ហើយនេះគឺជាពាក្យមួយដែលគេបានសំដៅទៅរកពួកមនុស្សនៅទ្វីបអឺរ៉ុបខាងកើត ។ កំណើតដើមរបស់ពួកអារ្យ័ន គឺនៅក្នុងតំបន់វាលស្មៅ ដែលលាតសន្ធឹងពីប្រទេសប៉ូឡូញ ដល់ប្រទេសរុស្ស៊ីភាគខាងលិច ។ ពួកអារ្យ័ន គឺជាមនុស្សខុសគ្នាច្រើនណាស់ពីមនុស្សនៃអារ្យធម៌ជ្រលងទន្លេឥណ្ឌុស ពិព្រោះ ពួកអារ្យ័នជាទូទៅ គឺជាអ្នកគង្វាល

ចៀមសាត់អណ្តែត ។ ពួកនេះពុំមានអារ្យធម៌ទីក្រុងរីកចំរើនខ្ពស់ទេ ។ ពួកគេមានអារ្យធម៌ឈានមុខខាងចំណូលចិត្តធ្វើសង្គ្រាមវាតទី ដែលរស់រានមានជីវិតបានដោយសារជយភ័ណ្ឌ ទ្រព្យសម្បត្តិលួចប្លន់មួយភាគធំ ដែលពួកគេប្រមូលបានពីប្រជាជនដែលពួកគេច្បាំងឈ្នះក្នុងពេលចូលទៅកាន់កាប់ទីតាំង ។ ពេលដែលពួកអារ្យ៉ន បានមកដល់ប្រទេសឥណ្ឌា, ពួកគេបានបំផ្លាញអស់យ៉ាងឆាប់ណាស់ នូវអារ្យធម៌ជ្រលងទន្លេឥណ្ឌា ។ អារ្យធម៌ជ្រលងទន្លេឥណ្ឌុស បានដួលរលំយ៉ាងឆាប់ ក្រោមអំណាចយោធារបស់ពួកអារ្យ៉ន ។ អ្វីដែលនៅឋិតថេរ, ក្នុងប្រទេសឥណ្ឌាក្រោយការវាតត្បាតនោះ គឺអារ្យធម៌របស់ពួកអារ្យ៉ានអ្នកជិះជាន់ ។

ឥឡូវ យើងបានដឹងពីព្រឹត្តិការណ៍សង្ខេបទាក់ទងនឹងប្រវត្តិសាស្ត្រសម័យដើមនៃប្រទេសឥណ្ឌាហើយ ។ ម្តងនេះ, ចូរយើងក្រឡេកមើលទស្សនៈសាសនារបស់ប្រជាជន នៃអារ្យធម៌ជ្រលងទន្លេឥណ្ឌុស និងរបស់ប្រជាជននៃអារ្យធម៌អារ្យ៉ន ម្តងវិញ ដែលមានអត្ថប្រយោជន៍ដ៏ពិសេសចំពោះយើង ។ អារ្យធម៌ជ្រលងទន្លេឥណ្ឌុស មានអក្សរសរសេរដោយដៃ ដែលយើងមានការសោកស្តាយ ដោយពុំអាចអានបាន ។ ប៉ុន្តែ យើងបានទទួលពត៌មានទាក់ទងនឹងចរិតលក្ខណៈនៃអារ្យធម៌នេះអំពីប្រភពពីរ, ទីមួយអំពីការកកាយរកឃើញបុរាណវត្ថុនៅទីតាំង មោហេនជោដារោ និងហារប្បា, និងទីពីរ អំពីការកត់ត្រារបស់ពួកអារ្យ៉ន ដែលបានពិពណ៌នាអំពីអាកប្ប-កិរិយា និងជំនឿសាសនារបស់ប្រជាជន ដែលពួកគេបានច្បាំងឈ្នះ ។ អំពីភស្តុតាងវត្ថុបុរាណ, យើងឃើញមាននិមិត្តរូបមួយចំនួន ដែលមានអត្ថន័យសាសនា, ពោលគឺជានិមិត្តរូបចំពោះពុទ្ធសាសនាដោយផ្ទាល់ ៖ គឺដូចជានិមិត្តរូប នៃដើមពោធិព្រឹក្ស និងសត្វចតុប្បាទ ដូចជាដំរី និងក្តាន់ ។ ប្រហែលជាមានសារសំខាន់បំផុតនោះ គឺការរកឃើញរូបចម្លាក់ជាច្រើនអង្គុយពែនភ្នែន ដោយមានដៃដាក់លើក្បាលជង្គង់, ភ្នែករួមតូច, បិទពាក់កណ្តាល ជាភស្តុតាងយ៉ាងច្បាស់ក្នុងឥរិយាបថតាំងសមាធិ ។ ការរក

ឃើញវត្ថុបុរាណ ត្រូវបានអ្នកប្រាជ្ញសំខាន់ៗ ធ្វើការសិក្សា ហើយទាញសេចក្ដីសន្និដ្ឋានថា យើងអាចរកឃើញដានយ៉ាងច្បាស់លាស់នៃដើមកំណើត និងការប្រតិបត្តិធ្វើសមាធិ ចេញមកពីអារ្យធម៌ជ្រលងទន្លេឥណ្ឌុស ។ កាលណា យើងក្រឡេកមើលការពិពណ៌នាអំពីសាសនារបស់អារ្យធម៌ជ្រលងទន្លេឥណ្ឌុស អំពីអត្ថបទសរសេររបស់ពួកអារ្យ៉ន . ដែលហៅថាគម្ពីរវេទ . យើងបានឃើញតួអង្គឥសីពនេចរ ត្រូវបានគេនិយាយដល់ជាញឹកញយ ។ យើងបានឃើញថា ពួកគេប្រព្រឹត្តធ្វើសមាធិ, ពួកគេនៅលីវ ( គ្មានគូរស្រករ ), ពួកគេប្រកាន់យកជីវភាពតឹងរ៉ឹង, ពួកគេជួនកាលមានខ្លួនទទេឥតស្លៀកពាក់, ជួនកាលមានខ្លួនគ្របដណ្ដប់ដោយសំពត់យ៉ាងគ្រាតគ្រើម, ពួកគេត្រាច់រង្គាត់ដោយគ្មានលំនៅឋាន ហើយពួកគេប្រៀនប្រដៅនៅក្នុងគន្លងហួសពីការកើត និងការស្លាប់ទៅទៀត ។ ប្រសិនបើយើងដាក់បញ្ចូលគ្នា ភស្ដុតាងនៃការរកឃើញបុរាណវត្ថុ ហើយនិងភស្ដុតាងនៃអក្សរសាស្ត្ររបស់ពួកអារ្យ៉ន, យើងនឹងឃើញថា នៅក្នុងនេះមានលេចឡើង នូវរូបភាពមួយនៃសាសនារបស់ប្រជាជនទទួលអារ្យធម៌ជ្រលងទន្លេឥណ្ឌុស ដែលនៅក្នុងអារ្យធម៌នេះ មានធាតុសំខាន់ៗ ជាច្រើន ។ ដំបូងបង្អស់, គឺសមាធិ ឬការស្ងឹងស្មាធិ៍ចិត្ត ទីពីរ គឺអភិនេក្ខមៈ, ការលះបង់ជីវភាពជាគ្រហស្ថ, រស់នៅជាតាបសពនេចរ, ទីបី គឺយើងដឹងពីគំនិត ( conception ) នៃការកើតឡើងវិញក្នុងជាតិដ៏ច្រើន, ហើយទីបួន គឺយើងដឹងអំពីគំនិតស្ដីពីការទទួលខុសត្រូវខាងផ្លូវសីលធម៌ហួសពីជីវិតនេះទៅ, ជំនឿអំពីកម៌ះ (កម្ម), ហើយចុងក្រោយបង្អស់គឺយើងដឹងអំពីគោលដៅនៃជីវភាពសាសនា, គោលដៅនៃការរំដោះ ( វិមុត្តិ ) ។ ទាំងនេះគឺជាលក្ខណៈលេចធ្លោរបស់សាសនា នៃអារ្យធម៌សម័យព្រេងនាយរបស់ឥណ្ឌា ។

ផ្ទុយទៅវិញ, ហើយវាក៏ជាការពិបាកដើម្បីរកឱ្យឃើញទស្សនៈសាសនាពីរដែលខុសពីគ្នាយ៉ាងច្រើននោះ, ចូរយើងក្រឡេកមើលសាសនារបស់ពួកអារ្យ៉នម្ដង

វិញ ។ ឥឡូវ យើងឃើញសាសនានេះ មានការងាយស្រួលយ៉ាងច្រើនជាង ដើម្បីផ្សំផ្គុំជារូបភាពមួយ, ពិព្រោះយើងមានអក្សរសាស្ត្រគ្រប់គ្រាន់ទាក់ទងនឹងសាសនារបស់ពួកគេ ។ នៅពេលដែលពួកអារ្យ៉ានបានមកដល់ប្រទេសឥណ្ឌា ពួកគេមានសាសនាមួយរួចហើយ ដែលជាសាសនាលោកីយទាំងស្រុង ។ ពួកគេរស់នៅជាសង្គមមួយឈានមុខវាតទីទឹកដី ។ មានភាពស្របគ្នាដ៏ជិតស្និទ្ធយ៉ាងច្រើនរវាងសាសនារបស់ពួកអារ្យ៉ាន និងសាសនារបស់ជនជាតិក្រិក ។ ប្រសិនបើលោកអ្នកប្រទះឃើញការពិពណ៌នាអំពីពពួកអាទិទេពរបស់ក្រិក, លោកអ្នកនឹងឃើញភាពប្រហាក់ប្រហែលគ្នាដ៏គួរឱ្យចាប់អារម្មណ៍រវាងពពួកអាទិទេពរបស់ក្រិក និងពពួកអាទិទេពរបស់ពួកអារ្យ៉ាន ។ លោកអ្នកនឹងឃើញនៅក្នុងជំនឿរបស់អារ្យ៉ាននូវអាទិទេពមួយចំនួន ដែលជាតួអង្គតំណាងបាតុភូតធម្មជាតិ ។ ជាឧទាហរណ៍, គេមានព្រះឥន្ទ្រ ដែលជាអាទិទេពរន្ទះ និងផ្គរលាន់, គេមានព្រះអគ្គីជាអាទិទេពភ្លើង និងព្រះវារុណ ជាអាទិទេពទឹក ។ គេមានរចនាសម្ពន្ធខាងសាសនា ដែលនៅក្នុងនេះ អាចារ្យ (Priest) គឺជាតួអង្គសំខាន់បំផុត, ចំណែកនៅក្នុងអារ្យធម៌ជ្រលងទន្លេឥណ្ឌុសវិញ តាបស គឺជាតួអង្គសំខាន់បំផុត ។ នៅក្នុងអារ្យធម៌ជ្រលងទន្លេឥណ្ឌុស, ការលះបង់ចេញសាងផ្នួស គឺជាឧត្តមគតិនៃជីវភាពសាសនា, ចំណែកនៅក្នុងសាសនាអារ្យ៉ានវិញ ស្ថានភាពជាគំរូ គឺស្ថានភាពជាអ្នកគ្រប់គ្រងផ្ទះ ។ នៅក្នុងអារ្យធម៌ជ្រលងទន្លេឥណ្ឌុស, គេមិនស្រឡាញ់កូនប្រុស និងកូនទាំងឡាយនៃកូនប្រុសនោះទេ ( rejection of sons and offspring ), ចំណែកនៅក្នុងសាសនារបស់អារ្យ៉ានវិញ, កូនប្រុស គឺជាមនុស្សមានគុណធម៌ខ្ពស់បំផុត ។ នៅក្នុងអារ្យធម៌ជ្រលងទន្លេឥណ្ឌុសមានការប្រតិបត្តិធ្វើសមាធិ, ឯនៅក្នុងសាសនាអារ្យ៉ានមានប្រតិបត្តិធ្វើពិធីយញ្ញ . ពិធីយញ្ញគឺជាមធ្យោបាយដ៏សំខាន់មួយភ្ជាប់ខ្លួនជាមួយពពួកអាទិទេព, ធ្វើឱ្យសំរេចជោគជ័យនៅក្នុងចម្បាំង, សុំបានកូន-ចៅ, ទៅកាន់ស្ថានសួគ៌ ។ ចំណែកនៅក្នុងអារ្យធម៌

ជ្រលងទន្លេឥណ្ឌុស គេមានជំនឿក្នុងក្រឹត្យក្រមកម៌ និងការកើតទៀត, ឯនៅក្នុងអារ្យធម៌អារ្យ៉ែន គេគ្មានគំនិតយល់ដឹងពីការកើតទៀតសោះ ។ ដូចជានៅក្នុងអារ្យ-ធម៌ជ្រលងទន្លេឥណ្ឌុស គេមានជំនឿអំពីការទទួលខុសត្រូវខាងផ្លូវសីលធម៌ គ្រប ដណ្តប់ទៅលើជីវិតច្រើនជាតិ, នៅក្នុងអារ្យធម៌អារ្យ៉ែនវិញ, គេគ្មានជំនឿបែបនេះទេ ។ តាមពិត ឧត្តមគតិខ្ពង់ខ្ពស់បំផុត គឺសេចក្តីស្មោះត្រង់, តម្លៃទាំងឡាយណា ដែលផ្តល់វិភាគទានដល់អានុភាពសហគមន៍ ។ នៅទីបំផុត ក្នុងពេលដែលអារ្យធម៌ ជ្រលងទន្លេឥណ្ឌុសចាត់ទុកការរំដោះ ( វិមុត្តិ ) ជាគោលដៅនៃជីវភាពសាសនា, នៅក្នុងអារ្យធម៌អារ្យ៉ែនវិញ, គេចាត់ទុកឋានសួគ៌ជាគោលដៅនៃជីវភាពសាសនា ។ គំនិតដែលនិយាយថា ពួកគេបានដល់ឋានសួគ៌ គឺជាឋានសួគ៌មួយយកគំរូតាមរូបភាពដ៏សុក្រិត នៃជីវិតលោកីយនេះ ។ ដូច្នេះ ប្រសិនបើយើងចង់សង្ខេបឡើងវិញនូវភាពផ្សេងៗគ្នា រវាងសាសនាទាំងឡាយ នៃអារ្យធម៌ទាំងពីរនេះ, យើងអាចនិយាយថាខាងអារ្យធម៌ជ្រលងទន្លេឥណ្ឌុសឱ្យតម្លៃលើការលះបង់ចេញសាងផ្នួស, សមាធិ, ការកើតទៀត, កម៌ (កម្ម), គោលដៅនៃការរំដោះ (វិមុត្តិ), ខាងសាសនាអារ្យ៉ែនសង្កត់លើតម្លៃជីវិតបច្ចុប្បន្ន, សុខុមាលសម្ភារៈ, ទ្រព្យសម្បត្តិ, អំណាច, កិត្តិយស, និងពិធីបូជាយញ្ញទុកដូចជាមធ្យោបាយ នៃការសម្រេចគោលដៅទាំងនោះ ។ វាជាការពិបាក ដើម្បីរកឃើញនូវចង្កោមនៃអាកប្បកិរិយាសាសនាដែលផ្ទុយគ្នាស្រឡះខ្លាំងបែបនេះ ។ បន្ថែមលើនេះ វាមានធាតុដ៏សំខាន់ពីរទៀតនៃសាសនាអារ្យ៉ែន ដែលយើងរំលឹកឡើងវិញ គឺ *វណ្ណៈ*, ការបែងចែកសង្គម ជាស្រទាប់សង្គម និងជំនឿក្នុងអាជ្ញានៃគម្ពីរដែលមានអាទិទេពប្រទាន គឺ *គម្ពីរវេទ* ។ ធាតុទាំងពីរនេះ ពុំមាននៅក្នុងអារ្យធម៌ជ្រលងទន្លេឥណ្ឌុសទេ ។

ប្រវត្តិនៃសាសនាឥណ្ឌាចាប់ពីឆ្នាំ ១៥០០ មុន គ.ស មកដល់ឆ្នាំ ៦០០ ឬ ៥០០ មុន គ.ស, ជាសម័យកាលនៃព្រះពុទ្ធ, ប្រវត្តិសាស្ត្រមួយពាន់ឆ្នាំនេះ នៅក្នុង

ប្រទេសឥណ្ឌា គឺជាប្រវត្តិសាស្ត្រនៃអន្តរកម្មបន្តិចម្តងៗរវាងទ្រឹស្តីសាសនាពីរផ្ទុយគ្នាទាំងស្រុងនេះ ។ ដោយសារពួកអារ្យ៉ែនវាតទីកាន់តែធំឡើងជាលំដាប់ ហើយតាំងទីលំនៅពាសពេញលើអនុទ្វីបឥណ្ឌាដ៏ធំធេង, ដោយសារតែវីរសកម្មភាពឈានមុខរបស់គេកាន់តែថមថយចុះ, បន្តិចម្តងៗ ទ្រឹស្តីសាសនាទាំងពីរដែលផ្ទុយគ្នាទាំងស្រុងនេះ ក៏ចាប់ផ្តើមជះឥទ្ធិពលធ្វើប្រតិកម្មលើគ្នាទៅវិញទៅមក ហើយរលាយចូលគ្នា ។ នេះគឺជាការរលាយចូលគ្នា ដែលខ្ញុំនៅចាំ នៅពេលដែលខ្ញុំបាននិយាយអំពីការរួមចូលគ្នានៃទន្លេធំទាំងពីរ ។ ក្រោយមក, នៅសម័យកាលព្រះពុទ្ធគង់ធរមាននៅ, កើតមានសាសនាច្រើនខុសៗគ្នាពេកណាស់ ។ យើងអាចយល់ស្ថានភាពនេះបានយ៉ាងច្បាស់ ប្រសិនបើយើងក្រឡេកមើលព្រឹត្តិការណ៍មួយចំនួនក្នុងព្រឹត្តិការណ៍ទាំងឡាយ ដែលទាក់ទងដល់ជីវភាពរបស់ព្រះពុទ្ធ ។ ជាឧទាហរណ៍, យើងឃើញថា ពេលដែលព្រះពុទ្ធបានប្រសូតមកហើយ មានមនុស្សពីរក្រុមបានមកមើល ហើយធ្វើការទស្សន៍ទាយទាក់ទងនិងមហន្តភាព ( greatness ) អនាគតរបស់ព្រះអង្គ ។ ការទស្សន៍ទាយដំបូង ធ្វើឡើងដោយលោកអសីតៈ ។ លោកអសីតៈ គឺជាតាបសម្នាក់ ដែលបានរស់នៅក្នុងព្រៃភ្នំ, ប៉ុន្តែ ប្រភពផ្សេងៗបានឱ្យយើងដឹងផងដែរថា លោកជាព្រាហ្មណ៍, លោកមានវណ្ណៈអាចារ្យ ( Priest ) ។ ហេតុការណ៍នេះផ្ទាល់ គឺជាភស្តុតាងស្រេចទៅហើយ ស្តីពីអន្តរសកម្មនៃប្រពៃណីទាំងពីរ ។ នៅសម័យពុទ្ធកាល, ពួកព្រាហ្មណ៍បានចាប់ផ្តើមពីការចាកចេញពីផ្ទះបួសជាតាបស ។ ព្រឹត្តិការណ៍បែបនេះ គេពុំដែលបានឮទេ កាលពីមួយពាន់ឆ្នាំមុន ។ នៅពេលក្រោយបន្តិចមក គេបានប្រាប់ឱ្យដឹងថា មានព្រាហ្មណ៍ ១០៨ រូប ត្រូវបានអញ្ជើញមកចូលរួមក្នុងពិធីបុណ្យថ្វាយព្រះនាម ។ នៅក្នុងករណីនេះ យើងមានឧទាហរណ៍អំពីតួអាចារ្យ, ដែលមិនបានលះបង់ជីវភាពគ្រហវាស, ដ៏ជាឧទាហរណ៍មួយរបស់ស្ថាប័ន ដែលមានប្រភពចេញមកពីអារ្យធម៌អារ្យ៉ែនដោយផ្ទាល់ ។

យ៉ាងដូចម្តេចទៅ ប្រពៃណីទាំងពីរ គឺប្រពៃណីជ្រលងទន្លេឥណ្ឌុស និងប្រពៃណីអារ្យ៉ែន, ដែលកាលពីដើមទីផ្សេងពីគ្នាយ៉ាងច្រើន តែក្រោយមកអាចរលាយចូលគ្នាបាន ? ខ្ញុំគិតថា ចម្លើយចំពោះបញ្ហានេះ ឋិតនៅក្នុងការផ្លាស់ប្តូរប្រែប្រួលយ៉ាងជ្រាលជ្រៅ ដែលបានកើតមានឡើងនៅក្នុងជីវភាពរបស់ប្រជាជនឥណ្ឌានៅរវាងសហស្សវត្សទីពីរ មុន គ.ស. និងសម័យពុទ្ធកាល ។ ការវាតទីរបស់ពួកអារ្យ៉ែនត្រូវបានបញ្ចប់ នៅពេលដែលពួកនេះបានដណ្តើមកាន់កាប់ដែនដីទំនាបប្រទេសឥណ្ឌា ។ ការបញ្ចប់ការវាតទីកាន់កាប់ទឹកដីនេះ បាននាំមកនូវការប្រែប្រួលខាងសង្គម, ខាងសេដ្ឋកិច្ច និងខាងនយោបាយ ។ ដំបូងបង្អស់, សង្គមនយោបាយកុលសម្ពន្ធ បានវិវត្តទៅជាការបង្កើតឱ្យមានរដ្ឋគ្រប់គ្រងដែនដី ដើម្បីកុំឱ្យមានកុល-សម្ពន្ធ ដែលមានមនុស្សមានភក្តីភាពជិតស្និទ្ធផ្ទាល់ខ្លួន សម្រាប់ក្រុមមួយៗ តទៅទៀត ។ ឥឡូវ គេមានរដ្ឋគ្រប់គ្រងដែនដី ដែលនៅក្នុងរដ្ឋនេះ មានមនុស្សមកពីកុល-សម្ពន្ធផ្សេងៗ រស់នៅជាមួយគ្នា ។ ព្រះរាជាណាចក្រ *មគធៈ* ដែលគ្រប់គ្រងដោយព្រះបាទពិម្ពិសារ ក្នុងសម័យពុទ្ធកាល គឺជាឧទាហរណ៍មួយនៃរដ្ឋគ្រប់គ្រងដែនដីទើបកើតឡើង ។ ទីពីរ, បែបបទនៃការរស់នៅជាអ្នកគង្វាលចៀមសាត់អណ្តែតនេះ ត្រូវបានប្រែប្រួលបន្តិចម្តងៗទៅជាបែបបទរស់នៅតាំងទីជាប់លាប់ ដាំផលដំណាំនៅជាយក្រុងកាន់តែច្រើនឡើង ដើម្បីឱ្យប្រជាជនឥឡូវនេះបានរស់នៅក្នុងមណ្ឌលនានាជាយក្រុង ហើយរលាស់ខ្លួនផុតពីកំឡាំងធម្មជាតិ ដែលត្រូវបានគេប្រតិស្ឋជាតួអង្គអាទិទេពនានា ។ ខាងសេដ្ឋកិច្ចវិញ, ពាណិជ្ជកម្មបានក្លាយជាមានសារសំខាន់ ។ ដូច្នេះ តាំងតែពីពេលដំបូង នៃអារ្យធម៌អារ្យ៉ែនម្ល៉េះ, អាចារ្យ ( Priest ) និងអ្នកចំបាំងទាំងឡាយ គឺជាមនុស្សមានសារសំខាន់ ពិព្រោះអាចារ្យអាចនិយាយឆ្លើយឆ្លងជាមួយអាទិទេពទាំងឡាយបាន, អ្នកចំបាំងអាចធ្វើសង្គ្រាមប្រឆាំងសត្រូវ ហើយនាំយកជ័យភណ្ឌមកឱ្យសហគមន៍ . ប៉ុន្តែឥឡូវនេះ ពួកឈ្មួញបានក្លាយទៅជាមានសារ-

សំខាន់កើតឡើងជាងវិញ ។ យើងអាចឃើញព្រឹត្តិការណ៍នេះ នៅក្នុងសម័យកាលព្រះពុទ្ធ, សាវ័កដ៏មានកេរ្តិ៍ឈ្មោះទាំងឡាយ គឺជាឈ្មួញដូចជា អនាថបណ្ឌិកជាតួយ៉ាង ។ ការប្រែប្រួលខាងសង្គម, ខាងសេដ្ឋកិច្ច និងនយោបាយទាំងអស់នេះ បានផ្តល់វិភាគទានដល់ការបើកច្រកឱ្យពួកអារ្យ៉ានទទួលជឿទស្សនៈសាសនា នៃអារ្យធម៌ជ្រលងទន្លេឥណ្ឌុស ។ នៅពេលដែលពួកអារ្យ៉ានច្បាំងឈ្នះប្រជាជនរស់នៅតាមជ្រលងទន្លេឥណ្ឌុសតាមផ្លូវយោធា, រយៈពេលពី ១.០០០ ទៅ ២.០០០ ក្រោយមកគេឃើញពួកអ្នកឈ្នះទាំងនោះកាន់តែឋិតនៅជ្រៅទៅៗ ក្រោមឥទ្ធិពលនៃគំនិតទាំងឡាយដកស្រង់ចេញមកពីអារ្យធម៌ជ្រលងទន្លេឥណ្ឌុស ។ រហូតទាល់តែនៅក្នុងប៉ុន្មានសតវត្សដំបូងនៃយុគសម័យរស់នៅរួមគ្នា, គេកាន់តែមានការពិបាកខ្លាំងឡើងដើម្បីកំណត់សំគាល់ភាពផ្សេងគ្នារវាងប្រពៃណីអារ្យ៉ាន និងប្រពៃណីជ្រលងទន្លេឥណ្ឌុស ។ តាមពិត, ហេតុការណ៍នេះបានឋិតនៅបាតក្រោមនៃគំនិតយល់ខុស កាលណាគេនិយាយថា ពុទ្ធសាសនា គឺជាការតវ៉ាមួយប្រឆាំងលទ្ធិហិណ្ឌូ, ឬថាពុទ្ធសាសនាគឺជាសាខាមួយរបស់លទ្ធិហិណ្ឌូ ។

នៅក្នុងពុទ្ធសាសនា, យើងមានសាសនាមួយ ដែលទាញស្រូបយកគំនិតភាគច្រើន អំពីសាសនាជ្រលងទន្លេឥណ្ឌុស, ពោលគឺគំនិតទាំងឡាយស្តីពីការលះបង់ចេញសាងផ្នួស (អភិនិស្ក្រមណ៍), សមាធិ, កម៌ះ (កម្ម) និងការកើតទៀត, ការរំដោះផុតទុក្ខ ( វិបត្តិ ) នៅទីបំផុត ។ នេះជាគំនិតទាំងឡាយមានសារៈសំខាន់ចំពោះអារ្យធម៌ជ្រលងទន្លេឥណ្ឌុស ។ ព្រះពុទ្ធអង្គឯង បានចង្អុលប្រាប់នូវដើមកំណើតនៃទ្រឹស្តីរបស់ព្រះអង្គបានមកពីជ្រលងទន្លេឥណ្ឌុស នៅពេលដែលព្រះអង្គមានពុទ្ធដីកាថា មាគ៌ាដែលព្រះអង្គបានប្រៀនប្រដៅ គឺជាមាគ៌ាបុរាណ ហើយគោលដៅដែលព្រះអង្គបានចង្អុលប្រាប់ គឺគោលដៅបុរាណ ។ យើងជាពុទ្ធសានិក ក៏មានជំនឿក្នុង

ព្រះពុទ្ធទាំងប្រាំមួយ[១] ព្រះអង្គ ដែលបានត្រាស់ដឹងមុនព្រះពុទ្ធសក្យមុនី នៅក្នុងភទ្ទ-កប្បនេះ ។ ទាំងអស់នេះ ចង្អុលប្រាប់នូវនិរន្តរភាពរវាងប្រពៃណីនៃអារ្យធម៌ជ្រលងទន្លេឥណ្ឌុស និងពាក្យប្រៀនប្រដៅ ( ព្រះធម៌ ) របស់ព្រះពុទ្ធ ។ ប្រសិនបើយើងក្រឡេកមើលពុទ្ធសាសនា និងលទ្ធិហិណ្ឌូ យើងនឹងឃើញសមាមាត្រច្រើន ឬតិចនៃធាតុទាំងឡាយយកចេញមកពីប្រពៃណីណាមួយក្នុងបណ្ដាប្រពៃណីទាំងពីរ នៃអារ្យធម៌ជ្រលងទន្លេឥណ្ឌុស និងអារ្យធម៌អារ្យ៉ែន ។ ជាឧទាហរណ៍ ប្រសិនបើយើងក្រឡេកមើលពុទ្ធសាសនា, មានសមាមាត្រយ៉ាងធំ ត្រូវបានយកចេញមកពីអារ្យធម៌សាសនាជ្រលងទន្លេឥណ្ឌុស, មានសមាមាត្រតិចតួច យកចេញមកពីប្រពៃណីអារ្យ៉ែន ។ ព្រោះហេតុនេះហើយ, ទើបយើងឃើញមាននិយាយពីអាទិទេពអារ្យ៉ែននៅក្នុងគម្ពីរពុទ្ធសាសនា, បើទោះជាតួនាទីរបស់អាទិទេពទាំងនោះបន្ទាប់បន្សំក្ដី, ក៏ជាឧទាហរណ៍មួយនៃធាតុរបស់អារ្យ៉ែន នៅក្នុងប្រពៃណីពុទ្ធសាសនា ។ ម្យ៉ាងវិញទៀត បើយើងក្រឡេកមើលនិកាយខ្លះៗនៃសាសនាហិណ្ឌូ, យើងឃើញមានសមា-មាត្រដ៏ធំមួយនៃធាតុទាំងឡាយស្រង់ចេញមកពីប្រពៃណីអារ្យ៉ែន ហើយសមាមាត្រដ៏តិចតួចស្រង់ចេញមកពីអារ្យធម៌ជ្រលងទន្លេឥណ្ឌុស ។ យើងឃើញវណ្ណៈត្រូវគេឱ្យតម្លៃខ្ពស់, អាជ្ញានៃគម្ពីរដែលអាទិទេពប្រទានរបស់ពួកអារ្យ៉ែន-គឺគម្ពីរវេទ ត្រូវគេឱ្យតម្លៃខ្ពស់ និងពិធីបូជាយញ្ញក៏ត្រូវគេឱ្យតម្លៃខ្ពស់ ។ ជាមួយគ្នានេះ, យើងឃើញមានផ្នែកមួយនិយាយពីការលះបង់សាងផ្នួស, សមាធិ, កម្មៈ និងការកើតទៀត ផងដែរ ។

*( នៅមាន ត )*

---

(១) តាមការចងចាំរបស់ខ្ញុំ, ភទ្ទកប្បនេះមានព្រះពុទ្ធប្រាំអង្គត្រាស់ដឹង ។ មុនព្រះពុទ្ធគោតមបានត្រាស់ដឹង, មានព្រះពុទ្ធបីព្រះអង្គបានត្រាស់ដឹងហើយគឺ ព្រះពុទ្ធកស្សបៈ, ព្រះពុទ្ធកក្កុសន្ធៈ ព្រះពុទ្ធកោនាគមនៈ ។ នៅសល់ព្រះពុទ្ធមួយអង្គទៀត ដែលនឹងត្រាស់ដឹងក្នុងអនាគត គឺព្រះសិរិអារ្យមេត្រី ។ ឃ.អ. ។

# សីល ១០ សម្រាប់គ្រហស្ថ

ពុទ្ធបរិស័ទជាគ្រហស្ថដែលបានរក្សានិច្ចសីល និងឧបោសថសីលហើយ, កាលបើមានសទ្ធាជ្រះថ្លាល្អិតលាស់ ចង់រក្សាសីលឱ្យពិសេសជាងនោះទៅទៀត ក៏គួរសមាទានកាន់សីល ១០ ដែលជាអតិរេកសីលសម្រាប់គ្រហស្ថ តាមកាលកំណត់ដែលបានប្ដេជ្ញាថានឹងកាន់ត្រឹមតែប៉ុណ្ណោះ៧ថ្ងៃ ឬមានកំណត់ខែឆ្នាំ ឬក៏កាន់អស់មួយជីវិត តាមកម្លាំងសទ្ធា និងសមត្ថភាពចុះ ។ ពុំមែនដូចពាក្យបរម្បរាខ្លះថា « គ្រហស្ថកាន់សីល ១០ ពុំបាន » នោះទេ ។

មានរឿងតំណាលក្នុងធម្មបទដ្ឋកថាថា ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅ ( ក្នុងវត្តជេតពន ) ជិតក្រុងសាវត្ថី, មានសេដ្ឋីបុត្តម្នាក់ចង់រកឧបាយប្រតិបត្តិឱ្យរួចចាកទុក្ខ, ក៏បានសួរព្រះថេរៈមួយរូបជាកុលុបកៈ ( ជីតុន ) របស់ខ្លួន, ព្រះថេរៈនោះលោកបានពន្យល់ណែនាំសេដ្ឋីបុត្តនោះឱ្យធ្វើទាន មានសលាកភត្ត និងបក្ខិកភត្តជាដើម, លោកពន្យល់ឱ្យបែងសម្បត្តិជាបីចំណែកគឺ មួយចំណែកសម្រាប់ប្រកបការរបរ, មួយចំណែកសម្រាប់ចិញ្ចឹមបុត្រភរិយា, មួយចំណែកសម្រាប់ធ្វើទានក្នុងព្រះពុទ្ធ-សាសនា ; សេដ្ឋីបុត្តនោះក៏បានប្រតិបត្តិតាមឱវាទព្រះថេរៈ ។ លំដាប់កាលពីនោះមកសេដ្ឋីបុត្តបានសួរឧបាយក្រៅពីនេះទៅទៀត, ព្រះថេរៈលោកឱ្យទទួលព្រះត្រៃ-សរណគមន៍ ហើយឱ្យសមាទានកាន់សីល ៥, តពីនោះមកទៀត លោកឱ្យកាន់សីល ៨ ។ សេដ្ឋីបុត្តនោះចេះតែមានសទ្ធាល្អិតលាស់ឡើងទៀត ទើបព្រះថេរៈលោកឱ្យសមាទានកាន់សីល ១០ ។ ចាប់ដើមតាំងពីនោះមក ជនទាំងឡាយគេហៅសេដ្ឋីបុត្តនោះថា **អនុបុព្វសេដ្ឋីបុត្ត** « កូនសេដ្ឋីអ្នកបំពេញកុសលតាមលំដាប់កាល » ។ លុះចំណោរកាលតមកទៀត, សទ្ធាជ្រះថ្លាចេះតែល្អិតលាស់ចំរើនខ្លាំងឡើង, សេដ្ឋី-

បុត្តនោះចង់បួស, ព្រះថេរៈលោកក៏ឱ្យបួសក្នុងព្រះពុទ្ធសាសនា [១] ។

រឿងគ្រហស្ថកាន់សីល ១០ ក្នុងព្រះពុទ្ធសាសនា ពុំមែនមានតែសេដ្ឋីបុត្តម្នាក់ប៉ុណ្ណោះទេ នៅមានក្រៅពីនេះទៀត ប៉ុន្តែពុំបានស្រង់យកមកពណ៌នាក្នុងទីនេះឡើយ ។ ស្ត្រីភាព, ដោយក្នុងសម័យនេះ បើទុកជាចង់បួស ក៏បួសពុំកើត, គួរតែបញ្ចេញសទ្ធាជ្រះថ្លាសមាទានកាន់សីល ១០ សម្រាប់គ្រហស្ថ តាមកាលកំណត់ដែលបានប្ដេជ្ញា តាមកំលាំងសទ្ធា និងសមត្ថភាព ក៏រាប់ថាជាលាភធំក្រៃលែងរបស់ស្ត្រីជាឧបាសិកា, និងបានជាប់ជាឧបនិស្ស័យវាសនាឱ្យបានបរមសុខទៅក្នុងអនាគតកាលសមតាមគោលបំណងប្រាថ្នា ពុំឃ្លាតក្លាយទៅជាហេតុការណ៍ដទៃឡើយ ។ សីលពុំមែនសុំជាភាសាបាលីទេ គឺគេសុំជាសម្រាយតាមភាសារាល់ជាតិ, ប្រហែលជាគេសុំដោយពាក្យខ្លីៗ ថា " ខ្ញុំព្រះករុណាសូមសីល ៥ " ឬថា " សីល ៨, សីល ១០ " តែប៉ុណ្ណោះ ឬគេនិយាយថែមទៀតថា " សូមព្រះករុណាអនុគ្រោះឱ្យសីលដល់ខ្ញុំព្រះករុណា " បើគេសុំទាំងសរណគមន៍ ទាំងសីលផង គេក៏សុំតាមដោយគេត្រូវការនោះទៅ ឥតមានសូធ្យសូមជាភាសាបាលីទេ ។ ដោយហេតុនេះបានជាក្នុងគម្ពីរមិនឃើញមានរៀបរៀងបែបសុំសីលជាភាសាបាលីសោះ ។ លុះចំណេរកាលតមកអ្នកប្រាជ្ញពុទ្ធសាសនិកក្នុងនានាប្រទេស ដែលរាប់អានភាសាបាលីថាជាភាសាស័ក្តិសិទ្ធិគួរគោរព, ក៏បានរៀបរៀងបែបសុំសីលជាភាសាបាលីឡើង ផ្សេងៗគ្នាខ្លះ តាមសេចក្ដីពេញចិត្តរបស់អ្នករៀបរៀង, ប៉ុន្តែ គួរពុទ្ធបរិស័ទយល់ថា បែបសុំសីលទាំងនោះ ទោះផ្សេងគ្នាខ្លះក៏ដោយ សុទ្ធតែប្រើការបានដូចគ្នា ពុំមែនប្រសើរវិសេសអ្វីជាងគ្នាប៉ុន្មានទេ, សរុបសេចក្ដីខ្លីថា សុទ្ធតែសុំសីល៥, សីល៨, សីល១០, ដូចជាគ្នា ផ្សេងគ្នាខ្លះតែបែបសូធ្យសូមប៉ុណ្ណោះ ។

---

(១) សេចក្ដីពិស្ដារមានក្នុងធម្មបទដ្ឋកថាបាលីអក្សរខ្មែរ ប្តូភាគទី ២ ត្រង់ចិត្តវគ្គវណ្ណនា តាំងពីទំព័រ ២១៣ ដល់ ២១៧ ។

អ្នកសមាទានសីល ១០, មុននឹងសុំសីល ត្រូវនមស្ការរំលឹកគុណព្រះរត្ន-ត្រ័យសិន ហើយសូធ្យសូមជាភាសាបាលីថា :

**ឱកាស**[១]**, អហំ ភន្តេ, តិសរណេន សហ, ទស សីលានិ យាចាមិ, អនុគ្គហំ កត្វា, សីលំ ទេថ មេ ភន្តេ** " សូមគោរព, ទានប្រោស, ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ ១០, ព្រមទាំងព្រះត្រៃសរណគមន៍ផង, ទានប្រោស, សូមព្រះករុណាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា " ។

**ទុតិយម្បិ អហំ ភន្តេ, តិសរណេន សហ, ទស សីលានិ យាចាមិ, អនុគ្គហំ កត្វា, សីលំ ទេថ មេ ភន្តេ** " ទានប្រោស, គំរប់ពីរដងទៀត, ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ១០, ព្រមទាំងព្រះត្រៃសរណគមន៍ផង, ទានប្រោស, សូមព្រះករុណាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា " ។

**តតិយម្បិ អហំ ភន្តេ, តិសរណេន សហ, ទស សីលានិ យាចាមិ, អនុគ្គហំ កត្វា, សីលំ ទេថ មេ ភន្តេ** " ទានប្រោស, គំរប់បីដងទៀត, ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ១០, ព្រមទាំងព្រះត្រៃសរណគមន៍ផង, ទានប្រោស, សូមព្រះករុណាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា " ។

បើគ្នាច្រើនថា **មយំ ភន្តេ**, ថា **យាចាម** ( **មយំ** ប្រែថា " យើងខ្ញុំ

---

(១) ឧកាស ប្រែថា " សូមគោរព " ។ បើ ឱកាស ប្រែថា " សូមឱកាស " ។ បាលីទាំង ២ បែបនេះ មិនមានក្នុងព្រះត្រៃបិដក ឬអដ្ឋកថាដីកាណាមួយទេ ប៉ុន្តែបោរាណាចារ្យនិយមប្រើមកយូរហើយ, ដោយហេតុនេះ ចង់ប្រើក៏បាន មិនប្រើក៏បាន ។ អ្នកប្រទេសឥណ្ឌា, លង្កាទ្វីប និងភូមា ច្រើនប្រើ ឱកាស ។

ព្រះករុណា " ) ; ត្រង់ **មេ ភន្តេ** ត្រូវថា **នោ ភន្តេ** ( **នោ** ប្រែថា " ដល់យើងខ្ញុំព្រះករុណា " ) ។

កាលបើឧបាសកឧបាសិកា ស្ងូមសីល ព្រមទាំងព្រះត្រៃសរណគមន៍ផង ដូច្នេះហើយ, លោកអ្នកឱ្យសីលគួរពោលពាក្យថា **យមហំ វទាមិ, តំ វទេហិ** " អាត្មាពោលនូវពាក្យណា, អ្នកចូរពោលនូវពាក្យនោះ " ។

បើឧបាសកឧបាសិកាច្រើនគ្នា តាំងពីពីរនាក់ឡើងទៅ, លោកអ្នកឱ្យសីលត្រូវថា **យមហំ វទាមិ, តំ វទេថ** " អាត្មាពោលនូវពាក្យណា, អ្នកទាំងឡាយចូរពោលនូវពាក្យនោះ (១) " ។ អ្នកទទួលសីលត្រូវតបថា **អាម ភន្តេ** " ព្រះករុណាទានប្រោស " ។ រួចលោកអ្នកឱ្យសីល សូត្រថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ( បីដង ), រួចលោកឱ្យព្រះត្រៃសរណគមន៍ តាំងពី **ពុទ្ធំ សរណំ គច្ឆាមិ** រហូតដល់ **តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ**, អ្នកទទួលសីលត្រូវថាតាមលោកជាលំដាប់ៗ តាំងពី នមោ រហូតដល់ចប់ព្រះត្រៃសរណគមន៍ ហើយលោកប្រាប់ថា **តិសរណគ្គហណំ បរិបុណ្ណំ** " ការទទួលព្រះត្រៃសរណគមន៍ចប់បរិបូរណ៍ហើយ (២) " ។ ទទួលថា **អាម ភន្តេ** " ព្រះករុណា ទានប្រោស " ។ រួចលោកឱ្យសីល ១០ ដូចតទៅ :

---

(១) ពាក្យនេះពុំមែនជាសំខាន់ប៉ុន្មានក្នុងវិធីឱ្យសីលទេ ទោះឱ្យសីលសាមណេរក្តី ឱ្យសីល ៥ សីល ៨ ឬសីល ១០ ដល់គ្រហស្ថក្តី ត្រូវការថាក៏បាន មិនបាច់ថាក៏បាន ព្រោះគ្រាន់តែជាការប្រើសំដីឱ្យស្រឡះស្រឡំប៉ុណ្ណោះ, ឬបើត្រូវការនិយាយជាសម្រាយថា " ចាំថាតាមអាត្មា ", ទទួលថា " ព្រះករុណា " តែប៉ុណ្ណោះក៏បាន ។ (២) បើមិនថាជាភាសាបាលី គ្រាន់តែប្រាប់ជាសម្រាយថា " ការទទួលព្រះត្រៃសរណគមន៍ចប់បរិបូរណ៍ហើយ " ឬប្រាប់ថា " ព្រះត្រៃសរណគមន៍ចប់តែប៉ុណ្ណោះ, ត្រូវទទួលសីលតទៅទៀត " ដូច្នេះក៏បាន ។

១. **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការញុំាងសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺការសម្លាប់សត្វ ។

២. **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

៣. **អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការប្រព្រឹត្តនូវធម៌មិនប្រសើរ គឺមេថុនសេវនៈ ។

៤. **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការពោលនូវពាក្យកុហក ។

៥. **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

៦. **វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការបរិភោគនូវភោជនាហារក្នុងវេលាវិកាល ។

៧. **នច្ច-គីត-វាទិត-វិសូកទស្សនា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការរាំ-ច្រៀង-ប្រគំ និងការមើលល្បែងរបាំដែលជាសត្រូវដល់ព្រហ្មចរិយធម៌ ។

៨. **មាលា - គន្ធ - វិលេបន - ធារណ - មណ្ឌន - វិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការទ្រទ្រង់-ប្រដាប់-តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

៩. **ឧច្ចាសយន-មហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

១០. **ជាតរូប-រជតប្បដិគ្គហណា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការទទួលកាន់យកនូវមាស និងប្រាក់ ។

**ឥមានិ ទស សិក្ខាបទានិ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទទាំងឡាយ ១០ នេះ ( សូធ្យ ៣ ដង ) ។

លុះទទួលសីល ១០ ចប់ហើយ អ្នកសមាទានត្រូវពោលពាក្យប្ដេជ្ញាជាសម្រាយក៏បានហើយ ឱ្យលោកអ្នកឱ្យសីលបានដឹងនូវកាលបរិច្ឆេទ គឺការកំណត់កាល ថាខ្លួននឹងអាចរក្សាសីល ១០ ត្រឹមតែប៉ុន្មានថ្ងៃ ? ឬប៉ុន្មានខែ ? ប៉ុន្មានឆ្នាំ ? ឬក៏អស់មួយជីវិត, ដូចជាប្ដេជ្ញាថា " ខ្ញុំព្រះករុណានឹងរក្សាសីល ១០ នេះត្រឹមតែ ៣ ថ្ងៃ, ហើយនឹងត្រឡប់រក្សាសីល ៥, សីល ៨ ទៅវិញ " ។ល។ រួចលោកអ្នកឱ្យសីលគួរប្រាប់បញ្ជាក់ថា :

**ឥមានិ ទស សិក្ខាបទានិ អប្បមាទេន សម្មា រក្ខិតព្វំ** «អ្នកត្រូវរក្សាដោយប្រពៃនូវសិក្ខាបទទាំងឡាយ ១០ នេះ កុំបីធ្វេសប្រហែសឡើយ ! » ។ អ្នកសមាទានសីលត្រូវទទួលថា **អាម ភន្តេ** « ព្រះករុណា មាន

ប្រោស ! " ។

កាលបើចប់វិធីនេះហើយ, បន្ទាប់មក, គួរលោកអ្នកឱ្យសីលសំដែងអានិសង្សសីលដោយសង្ខេប ឬដោយពិស្តារ ឱ្យអ្នកសមាទានសីលស្តាប់តទៅទៀតតាមកាលដ៏គួរ, តាមតែសំដែងអានិសង្សសីលត្រង់ណាក៏បាន តាមសមត្ថភាពរបស់លោកអ្នកឱ្យសីល ។

## អានិសង្សសីលសង្ខេប

**សីលេន សុគតី យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតី យន្តិ តស្មា សីលំ វិសោធយេ ។**

*« សត្វទាំងឡាយ ទៅកាន់សុគតិភព ក៏ព្រោះសីល, បានបរិបូណ៌ដោយភោគទ្រព្យ ក៏ព្រោះសីល, ទៅកាន់ព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ អ្នករក្សាសីល ត្រូវសំអាតសីល (ឱ្យបរិសុទ្ធ) » ។*

**កិកីវ អណ្ឌំ ចមរីវ វាលធី**

**បិយំវ បុត្តំ នយនំវ ឯកកំ**

**តថេវ សីលំ អនុរក្ខមានកា**

**សុបេសលា ហោថ សទា សគារវា ។**

*« សត្វត្រដេវរ៉ិចរក្សានូវស៊ុតវា យ៉ាងណាមិញ, សត្វចាមរីរក្សានូវកន្ទុយវា យ៉ាងណាមិញ, មាតារក្សានូវកូនប្រុសតែមួយ យ៉ាងណាមិញ, ជនមានភ្នែកតែម្ខាងរក្សានូវភ្នែក យ៉ាងណាមិញ, អ្នកទាំងឡាយកំពុងរក្សាសីល ជាអ្នកមានសីលជាទីរាប់អានក្រៃលែង ចូរជាអ្នកប្រកបដោយសេចក្តីគោរពសីល*

*ឱ្យបានសព្វកាល ក៏យ៉ាងនោះដែរចុះ "។*

**សីលំ យោគិស្សលង្ការោ សីលំ យោគិស្ស មណ្ឌនំ**
**សីលេហិលង្កតោ យោគី មណ្ឌនេ អគ្គតំ គតោ ។**

*« សីលជាគ្រឿងអលង្ការរបស់យោគី (អ្នករក្សាសីល), សីលជាគ្រឿងប្រដាប់របស់យោគី (អ្នករក្សាសីល), យោគី (អ្នករក្សាសីល) ប្រដាប់តាក់តែងដោយសីលទាំងឡាយ បានដល់នូវភាវៈខ្ពង់ខ្ពស់ក្នុងការប្រដាប់ (រាងកាយ) » ។*

អធិប្បាយសង្ខេប

គ្រឿងប្រដាប់តាក់តែងស្អិតស្អាងរាងកាយរបស់បុរសស្ត្រីក្នុងលោក ទោះមានតម្លៃច្រើនប៉ុន្មានក្តី សុទ្ធសឹងជាគ្រឿងប្រើប្រាស់បញ្ឆោតចិត្ត ជួនកាលជ្រមុជចិត្តឱ្យលង់ឈ្លក់ងើបពុំរួចក៏មាន, ឯសីលមិនដូច្នោះទេ, សីលកើតមានឡើងព្រោះវិរតិចេតនា ឥតមានរូបរាងកាយ ក៏ពិតមែន, ប៉ុន្តែហាក់ដូចជាមានរូបរាងកាយជាក់ស្តែង ដ្បិតកាយ វាចា និងចរិយាសម្បត្តិ របស់អ្នកកាន់សីល ចេញជារូបរាងឱ្យគេឃើញ, ព្រោះហេតុនោះ ទើបពុទ្ធាទិបណ្ឌិតលើកយកសីលថាជាគ្រឿងអលង្ការ របស់យោគីអ្នកកាន់សីល ។ មិនតែប៉ុណ្ណោះ, សីលនោះលោករាប់ថាជា *អរិយទ្រព្យ* ជាទ្រព្យប្រសើរវិសេសថ្លៃថ្លាជាងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណ របស់បុរស-ស្ត្រីក្នុងលោក ។ សាធុជនអ្នកមានវិចារណញ្ញាណ គង់នឹងអាចរិះរេឃើញយល់បានដោយងាយៗ ។

**ន បុប្ផគន្ធោ បដិវាតមេតិ**
**ន ចន្ទនំ តគរមល្លិកា វា**
**សតញ្ច គន្ធោ បដិវាតមេតិ**

**សញ្ញា ធិសា សប្បុរិសោ បវាយតិ ។**

*« ក្លិនផ្កាបក់ផ្សាយច្រាសខ្យល់ពុំបានទេ, ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនក្រស្នាក្តី ក្លិន ផ្កាម្លិះវ្វតក្តី បក់ផ្សាយច្រាសខ្យល់ពុំបានទេ, មានតែក្លិននៃពួកសប្បុរស ( អ្នកមានសីល ) ទើបបក់ផ្សាយច្រាសខ្យល់បាន, សប្បុរស ( អ្នកមានសីល ) បក់ផ្សាយក្លិនសព្វទិសានុទិស ( ទាំងបណ្តោយខ្យល់ ទាំងច្រាសខ្យល់ ) » ។*

**ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី**

**ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។**

*« ខ្លឹមចន្ទន៍ក្តី ក្រស្នាក្តី ផ្កាឧប្បលក្តី ផ្កាម្លិះលាក្តី (សុទ្ធតែមានក្លិនក្រអូប), ប៉ុន្តែ ក្លិនសីលក្រអូបក្រៃលែងជាងគន្ធជាតទាំងនុ៎ះ (ឥតមានគន្ធជាតអ្វីក្រអូបដូចក្លិនសីលឡើយ) » ។*

គាថាប្រាប់អានិសង្សសីលមានប៉ុណ្ណេះជាដើមនេះ លោកអ្នកឱ្យសីលត្រូវការសំដែងគាថាណាឱ្យអ្នកសមាទានសីលស្តាប់ក៏បាន, ឬបើលោកអ្នកឱ្យសីលដែលជាអ្នកឈ្លាសប្រតិពលចេះចាំអានិសង្សសីលច្រើនជាងបែបខាងលើនេះទៅទៀត ក៏គួរសំដែងអានិសង្សនោះឱ្យអ្នកសមាទានសីល ៥ សីល ៨ ឬសីល ១០ បានស្តាប់រឿយៗ តាមកាលដ៏គួរចុះ, អ្នកស្តាប់នឹងមានសទ្ធាជ្រះថ្លាកាន់តែល្អពលាស់ចំរើនកើនឡើងទៀតតាមលំដាប់កាលតទៅ ទាំងនិងបានជាសីលានុស្សតិនាំឱ្យមានផលានិសង្សច្រើនថែមឡើងទៀតផង ។

## របៀបបធអ្នករក្សាសីល ១០

ឧបាសកឧបាសិកាអ្នករក្សាសីល ១០ ត្រូវកោរសក់, បើមានពុកមាត់ ពុកចង្កា ក៏ត្រូវកោរផងដែរ, ត្រូវកាត់ក្រចកដៃជើងឱ្យស្មើនឹងសាច់, ត្រូវស្លៀកពាក់ស

ឬពានាសំពត់សផងក៏បាន តាមគួរដល់ការលៃលកឱ្យសមរម្យ តាមសភាពបុរស និងស្ត្រី [(១)] ។

សីលកើតមានដោយសារវិរតិចេតនា ពុំមែនដោយសារកោរសក់ ស្លៀកពាក់សទេ ក៏ពិតមែនហើយ, ប៉ុន្តែ ការកោរសក់ ស្លៀកពាក់សនេះ ជាបវេណីមួយសម្រាប់គ្រហស្ថអ្នកកាន់សីល ១០ ក្នុងព្រះពុទ្ធសាសនា, ជាគ្រឿងសំគាល់ឱ្យឃើញប្លែកពីគ្រហស្ថទាំងពួង ទាំងជាភស្តុតាងដល់ផ្លូវចិត្តរបស់គ្រហស្ថអ្នកកាន់សីល ១០ នោះផងទៀត, ប៉ុន្តែ គួរកុំយល់ថា ដូចគ្នានឹងអ្នកដែលស្លៀកពាក់សតាមធម្មតា ឬអ្នកដែលកោរសក់ កោរពុកមាត់ពុកចង្កា តាមធម្មតា ឥតបានសមាទានកាន់សីលសោះនោះឡើយ ។ អ្នកកាន់សីល និងអ្នកមិនកាន់សីល មានសភាពផ្សេងផ្ទុយគ្នាដោយផ្លូវចិត្ត ដោយចរិយា និងគុណសម្បត្តិ, សូម្បីអ្នកកាន់សីលផងគ្នា ក៏គង់ផ្សេងទីទៃពីគ្នាដោយថ្នាក់សីលដែរ, ភិក្ខុមានថ្នាក់សីលខ្ពស់ជាងសាមណេរ, សាមណេរ

---

(១) នៅប្រទេសភូមា មានស្ត្រីអនាគារិកាពួកមួយ ហៅថា សីលវតី ខ្លះកាន់សីល ១០ ខ្លះកាន់សីល ៨ នាងកុមារីក្មេងៗ ជាសិស្សរៀនអក្សររៀនធម៌ ច្រើនតែកាន់សីល ៥, ទាំងចាស់ទាំងក្មេង សុទ្ធតែស្លៀកសម្លុយស្រុងៗ ពាក់អាវបំពង់ស្រុងៗដៃវែង ពានាសំពត់ធ្វេញឈើធំៗ សំពត់ទាំងនេះសុទ្ធតែជ្រលក់អម្ពូត់ពណ៌ខ្ចីផ្សេងទីទៃពីពណ៌ស្បង់ចីពររបស់ភិក្ខុសាមណេរ, ពាក់ស្បែកជើងសង្រែកដូចភិក្ខុសាមណេរដែរ ។ សីលវតីទាំងនេះ សុទ្ធតែមានវត្តអារាម តូចខ្លះ ធំខ្លះ ជាលំនៅដោយខ្លួនពីភិក្ខុសាមណេរ, ក្នុងវត្តទាំងនោះមានសាលារៀន មានសីលវតីជាគ្រូបង្រៀនអក្សរសាស្ត្រ បង្រៀនធម៌ព្រះពុទ្ធសាសនា មានការប្រឡងយកសញ្ញាបត្ររាល់ឆ្នាំ ។ល។ នៅលង្កាទ្វីប ក៏មានស្ត្រីអនាគារិកាស្លៀកពាក់ពានាសំពត់ជ្រលក់អម្ពូត់ពណ៌លឿងខ្ចីដែរ ។ ប៉ុន្តែ មិនមានចំនួនច្រើនរាប់រយរាប់ពាន់ដូចនៅប្រទេសភូមាទេ ។ ស្ត្រីអនាគារិកាទាំងនេះ, ទោះនាងដែលកាន់សីល ៥ ក៏ដោយ សុទ្ធតែវៀររាល់ថ្ងៃ មិនបរិភោគភោជនាហារក្នុងវេលាវិកាលដោយគេតាំងវិធានការជាទម្លាប់សម្រាប់ពួកនេះទាំងអស់គ្នា ដើម្បីកុំឱ្យមានកង្វល់ច្រើនក្នុងអាហារកិច្ច ។

មានថ្នាក់សីលខ្ពស់ជាងគ្រហស្ថអ្នកកាន់សីល ១០, គ្រហស្ថអ្នកកាន់សីល ១០ មានថ្នាក់សីលខ្ពស់ជាងអ្នកកាន់សីល ៨, អ្នកកាន់សីល ៨ មានថ្នាក់សីលខ្ពស់ជាងអ្នកកាន់សីល ៥ ; អ្នកកាន់សីលទាំងនេះ សុទ្ធតែគួរគោរពគ្នាតាមលំដាប់ថ្នាក់សីល, ទាំងតាមលំដាប់ថ្នាក់អាយុ វស្សាចាស់ក្មេង ហើយនិងគុណសម្បត្តិផងទៀត ទើបសមគួរតាមលំអានគន្លងគារវធម៌ក្នុងព្រះពុទ្ធសាសនា និងបោរាណកធម៌ក្នុងកាលព្រេងនាយ, សូម្បីសត្វតិរច្ឆានធំតូច ដូចយ៉ាងសត្វទទា ស្វា ដំរី ដែលចេះគោរពគ្នាតាមថ្នាក់អាយុចាស់ក្មេង ក៏អាចបានសុគតិភព ជាទិដ្ឋានុគតិឱ្យមនុស្សយកតម្រាប់តាមបានដែរ ។

## អារក្ខកម្មដ្ឋាន

កម្មដ្ឋានដែលពុទ្ធបរិស័ទបព្វជិត គ្រហស្ថ គួររក្សាទុក គឺគួរនឹករំពឹងរឿយៗ ហៅថា អារក្ខកម្មដ្ឋាន មាន ៤ យ៉ាង ។ ឧបាសកឧបាសិកាអ្នកកាន់សីល ៨ និងសីល ១០ គួរឆ្លៀតចំរើនអារក្ខកម្មដ្ឋាននេះ, គួរកុំឱ្យរាត្រីមួយៗ កន្លងទៅទទេៗ ដ្បិតការនឹករំពឹងទៅរកយថាភូតធម៌ គឺសភាវធម៌ដែលកើតមានតាមការណ៍ពិតនោះ ពុំមែនជាច់បង់ទ្រព្យធនអ្វីទេ គ្រាន់តែប្រើគំនិតគិតរំពឹងឱ្យឃើញការណ៍ពិតប៉ុណ្ណោះ ឱ្យចិត្តតាំងនៅស៊ប់ស៊ាំក្នុងអនុស្សតិធម៌ ដែលសាមញ្ញសត្វកម្រនឹកឃើញ ។ បាលីគាថាខាងក្រោមនេះ ប្រាប់ឈ្មោះអារក្ខកម្មដ្ឋាន ៤ យ៉ាង និងការរំពឹងនឹកឆ្ពោះត្រង់អារក្ខ-កម្មដ្ឋាននោះ ។

**ពុទ្ធានុស្សតិ មេត្តា ច អសុភំ មរណស្សតិ**
**ឥច្ចេតា ចតុរារក្ខា ភាវេតព្វា បុនប្បុនំ** [(១)] ។

---

(១) ជា អភិណ្ហសោ ក៏មាន ប្រែថា " រឿយៗ " ដែរ ។

*« អារក្ខកម្មដ្ឋាន ៤ យ៉ាងនេះគឺ ពុទ្ធានុស្សតិ ១ មេត្តា ១ អសុភៈ ១ មរណស្សតិ ១ គួរសាធុជនចំរើនរឿយ១ »* ។

ការរំលឹកគុណព្រះអរហន្តសម្មាសម្ពុទ្ធ ហៅថា ពុទ្ធានុស្សតិ ។ ការផ្សាយមេត្តាចិត្តទៅរកសត្វទាំងពួង ហៅថា មេត្តា ។ ការពិចារណារូបរាងកាយថាសុទ្ធតែមិនល្អ មិនស្អាត ហៅថា អសុភៈ ។ ការនឹកទៅរកសេចក្ដីស្លាប់ឱ្យឃើញថា ពុំអាចនឹងជៀសវាងបាន ហៅថា មរណស្សតិ ។ អារក្ខកម្មដ្ឋានមានត្រឹមតែ ៤ យ៉ាងប៉ុណ្ណោះ ប៉ុន្តែបាលីគាថាខាងក្រោមនេះឈោងដល់ធម្មានុស្សតិ និងសង្ឃានុស្សតិផង ។

**វន្ទាមិ ពុទ្ធំ គុណសាគរន្តំ ;**
**សត្តា សទា ហោន្តុ សុខី អវេរា ;**
**កាយោ ជិយញ្ញោ សភលោ ទុគន្ធោ ;** [១]
**គច្ឆន្តិ សព្វេ មរណំ គថាហំ**

*« ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសម្ពុទ្ធ ទ្រង់មានព្រះគុណដ៏ធំធេង ដូចសាគរ; សូមសត្វទាំងឡាយមានតែសេចក្ដីសុខ មិនមានពៀរនឹងគ្នា សព្វកាល; រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់; សព្វសត្វទាំងអស់ រមែងដល់នូវសេចក្ដីស្លាប់, ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ! »* ។

**វន្ទាមិ ធម្មំ សុគតេន ទេសិតំ ;**
**សត្តា សទា ហោន្តុ សុខី អវេរា ;**
**កាយោ ជិយញ្ញោ សភលោ ទុគន្ធោ ;**
**គច្ឆន្តិ សព្វេ មរណំ គថាហំ ។**

(១) តាមសំយោគវិធានជា ទុគ្គន្ធោ ប៉ុន្តែក្នុងទីនេះប្រើជា ទុគន្ធោ វិញ ព្រោះរក្សាសម្ពស្សឥន្ទវជិរច្ឆន្ទ ។

*« ខ្ញុំសូមថ្វាយបង្គំចំពោះព្រះធម៌ ដែលព្រះសុគតទ្រង់ត្រាស់សំដែងហើយ; សូមសត្វទាំងឡាយមានតែសេចក្តីសុខ មិនមានពៀរនឹងគ្នា សព្វកាល; រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់; សព្វសត្វទាំងអស់ រមែងដល់នូវសេចក្តីស្លាប់, ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ! »* ។

**វន្ទាមិ សង្ឃំ មុនិរាជបុត្តំ ;**
**សត្តា សទា ហោន្តុ សុខី អវេរា ;**
**កាយោ ជិគុច្ឆោ សកលោ ទុគន្ធោ ;**
**គច្ឆន្តិ សព្វេ មរណំ អហញ្ចា ។**

*« ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសង្ឃ ដែលជាបុត្រនៃព្រះសម្ពុទ្ធ ជាស្តេចនៃអ្នកប្រាជ្ញ; សូមសត្វទាំងឡាយមានតែសេចក្តីសុខ មិនមានពៀរនឹងគ្នា សព្វកាល; រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់; សព្វសត្វទាំងអស់ រមែងដល់នូវសេចក្តីស្លាប់, ទាំងខ្លួនអាត្មាអញ ក៏ដូច្នោះដែរ ! »* ។

## សិក្ខាបទ[១] ១០

១. វៀរមិនសម្លាប់សត្វ ;

២. វៀរមិនលួចទ្រព្យគេ ;

---

(១) សិក្ខាបទ ក៏គឺសីល, សីល ក៏គឺសិក្ខាបទ ប៉ុន្តែ បានជាហោថាសិក្ខាបទ ព្រោះជាមាត្រាសំរាប់សិក្សា, បានជាហៅថាសីល ព្រោះអ្នកសមាទានត្រូវវៀរតមដោយវិរតិចេតនា មិនឱ្យដាច់ មិនឱ្យធ្លុះពពាលពព្រុស ។

៣. វៀរមិនធ្វើមេថុនសេវនៈ ;

៤. វៀរមិននិយាយកុហក ;

៥. វៀរមិនផឹកទឹកស្រវឹង ;

៦. វៀរមិនបរិភោគភោជនាហារក្នុងវេលាវិកាល ;

៧. វៀរមិនរាំ ច្រៀង ប្រគំ មិនមើលល្បែងរបាំ ;

៨. វៀរមិនទ្រទ្រង់ប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ។

៩. វៀរមិនដេក ឬអង្គុយលើឧច្ចាសយនៈ និងមហាសយនៈ ;

១០. វៀរមិនកាន់មាសប្រាក់ ទាំងមិនត្រេកអរចំពោះមាសប្រាក់នោះផង[១] ។

**ឱម ខែម**

ដកស្រង់រៀបរៀង

ប្រភពដកស្រង់ :

- គិហិបដិបត្តិ ( ពុទ្ធសាសនបណ្ឌិត្យ )
- បព្វជ្ជឧបសម្បទា ( សម្ដេចព្រះសង្ឃរាជ ជួន ណាត )
- អធិប្បាយចតុប្បារិសុទ្ធិសីល ( ធម្មវិន័យ ថ្នាក់ត្រី )

---

(១) មានពុទ្ធានុញ្ញាត ឱ្យបព្វជិតត្រេកអរចំពោះទៅលើបច្ច័យ ៤ ដែលកើតពីមាសប្រាក់ជាកប្បិយៈ, ហាមមិនឱ្យត្រេកអរទៅលើមាសប្រាក់ឡើយ ។

# ពាក្យរណ្ដំបរិវារស័ព្ទ ក្នុងភាសាអក្សរសិល្ប៍ខ្មែរ

*( តពីទស្សនាវដ្ដី លេខ ២ . ១៩៩៧ ទំព័រ ៧២ )*

បណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម**
ព្រឹទ្ធសហការី បណ្ឌិត្យសភាវិទ្យាសាស្ត្រ
សហព័ន្ធរុស្ស៊ី ( វិទ្យាស្ថានបូព៌ាវិទ្យា )
សាស្ត្រាចារ្យសិលាចារឹកវិទ្យា និងភាសាវិទ្យា
នៅសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ

តទៅនេះ យើងសូមលើកយកមកបង្ហាញ នូវបរិវារស័ព្ទដ៏វែង គឺពាក្យរណ្ដំបរិវារស័ព្ទប្រកបដោយព្យាង្គបួន ។ ជាធម្មតា ពាក្យរណ្ដំបរិវារស័ព្ទរមែងមានពីរព្យាង្គ បីព្យាង្គ និងបួនព្យាង្គ ។ ពាក្យខ្មែរវែង ក៏រមែងមានបួនព្យាង្គ ។ យើងអាចសង្កេតឃើញថា ពាក្យរណ្ដំបរិវារស័ព្ទបួនព្យាង្គទាំងឡាយ បានកកើតមកដោយភាសាផ្សំនៃពាក្យកម្លាយពីរ ហើយពាក្យកម្លាយមួយមានន័យ, មួយទៀតគ្មានន័យពេញលេញ គឺជាពាក្យបរិវារ ។ ជួនកាលពាក្យរណ្ដំបរិវារស័ព្ទបួនព្យាង្គ ប្រកបដោយពាក្យកម្លាយដែលគេពុំអាចពន្យល់ន័យបាន ។ ប៉ុន្តែ គឺពាក្យរណ្ដំបរិវារស័ព្ទទាំងនេះហើយដែលអាចបង្កើតបាននូវរូបារម្មណ៍អក្សរសិល្ប៍ នូវភាពច្បាស់លាស់រស់រវើក ។

| | | |
|---|---|---|
| មមីងមមាំង | ត្រដាបត្រដួស | គ្រលឹងគ្រលោង |
| កណ្ដោចកណ្ដែង | ត្រណាត់ត្រណែង | ស្រងេះស្រងោច |
| អន្ទះអន្ទែង | អំពិលអំពែក | អណ្ដឺតអណ្ដក់ |

| | | |
|---|---|---|
| ក្រទីសក្រទាស | ច្រង៉ាប់ច្រងិល | ចចាមអារាម |
| រណែងរណោង | រណែងរណាង | រតេតរតូត |
| រង៉េករង៉ាក | របិញរបុញ | រប៉ាត់រប៉ាយ |
| ជំទើតជំទើង | រសេះរសោះ | រសេមរសាម |
| កន្ទ្រេកកន្ទ្រាក | ស្រពេចស្រពិល | ត្រមង់ត្រមោច |
| រងីសរងាស | គគ្រីសគគ្រូស | ងងីសងងូស |
| គ្រហីគ្រហើ | រម៉ាំងរម៉ោក | រណោងរណោង |
| រប៉ិលរប៉ូច | រម៉េះរម៉ោះ | រកេតរកូត |
| រកេករកាក | ទទីសទទាស | រកាក់រកុប |
| ក្រឡេកក្រឡាប់ | កខិបកខុប | រសាប់រសល់ |

| | | | |
|---|---|---|---|
| រញ៉ីរញ៉ូរ | ( < រញ៉ូរ ) | ក្រហេងក្រហូង | ( < ក្រហូង ) |
| បង្អែបង្អង់ | ( < បង្អង់ ) | ងងឹតងងល់ | ( < ងងឹត ) |
| តពាក់តពុប | ( < តពាក់ ) | ប្រសេចប្រសាច | ( < ប្រសាច ) |
| ប៉ប៉ិចប៉ប៉ោច | ( < ប៉ប៉ោច ) | ក្រហល់ក្រហាយ | ( < ក្រហាយ ) |
| ប្រមៃប្រមូល | ( < ប្រមូល ) | ពពាក់ពពូន | ( < ពពូន ) |
| ក្រមាច់ក្រមើម | ( < ក្រមាច់ ) | ក្រញេងក្រញង់ | ( < ក្រញ៉ង់ ) |
| ចចាក់ចចុច | ( < ចាក់ចុច ) | ស្រគត់ស្រគំ | ( < ស្រគំ ) |
| អណ្តែតអណ្តូង | ( < អណ្តែត ) | បណ្តុះបណ្តាល | ( < ដុះដាល ) |
| រញ៉េរញ៉ៃ | ( < រញ៉ៃ ) | ទទ្រេតទទ្រោត | ( < ទទ្រេត ) |
| គំរោះគំរើយ | ( < គំរើយ ) | ញញើតញញើម | ( < ញញើត ) |
| ញញឹមញញែម | ( < ញញឹម ) | ត្រដាបត្រដូស | ( < ត្រដាប ) |
| លំបាកលំបិន | ( < លំបាក ) | រវាសរវៃ | ( < រវាស ) |

| | | | |
|---|---|---|---|
| មមីមមើ | ( < មីមើ ) | ត្រឈឹងត្រឈៃ | ( < ត្រឈៃ ) |
| ត្រឡប់ត្រឡិន | ( < ត្រឡប់ ) | កំប៉ិកកំប៉ុក | ( < កំប៉ុក ) |
| ក្រញ៉េក្រញ៉ូវ | ( < ក្រញ៉ូវ ) | ប្រវេប្រវា | ( < ប្រវា ) |
| ប្រផិតប្រផើយ | ( < ប្រផិត ) | សស្រាក់សស្រាំ | ( < សស្រាក់ ) |
| រហេតរហូត | ( < រហូត ) | ក្រហេតក្រហាត | ( < ក្រហាត ) |
| កន្ត្រាក់កន្ត្រែង | ( < កន្ត្រាក់ ) | ចង្អៀតចង្អល់ | ( < ចង្អៀត ) |
| ចំណីចំណុក | ( < ចំណី ) | បន្តិចបន្តួច | ( < បន្តិច ) |
| ចំអែចំអន់ | ( < ចំអន់ ) | រកេតរកូត | ( < រកូត ) |
| រខេករខាក | ( < រខាក ) | សស្លាក់សស្លើត | ( < សស្លើត ) |
| បន្លែបន្លុក | ( < បន្លែ ) | លំដាប់លំដោយ | ( < លំដាប់ ) |
| បន្លែបន្លំ | ( < បន្លំ ) | គគ្រីមគគ្រើម | ( < គគ្រើម ) |
| ច្របូកច្របល់ | ( < ច្របល់ ) | បង្ហិនបង្ហោច | ( < បង្ហិន ) |
| កកូរកកាយ | ( < កកូរ + កកាយ ) | ទូលំទូលាយ | ( < ទូលាយ ) |
| ត្រអេកត្រអាល | ( < ត្រអាល ) | ណែនណាន់តាន់តាប់ | (<ណែន+តាន់) |
| ត្រដាបត្រដូស | ( < ត្រដាប ) | រងឹករងក់ | ( < ងឹកងក់ ) |
| ក្រអឺតក្រទម | ( < ក្រអឺត ) | រអាក់រអួល | ( < អាក់អួល ) |
| ពង្រាត់បង្រាស | ( < ព្រាត់ប្រាស ) | ប្រដែប្រដៅ | ( < ប្រដៅ ) |
| ប្រដាប់ប្រដារ | ( <ប្រដាប់+ប្រដារ) | ប្រកាច់ប្រកិន | ( < កាច់កិន ) |
| ប្រកៀកប្រកើយ | ( <កៀកកើយ ) | ពព្រើតពព្រាយ | ( < ពព្រើត ) |
| រំភើយរំភាយ | ( < រំភើយ ) | សន្ទឹងសន្ទៃ | ( < សន្ទឹង ) |
| សន្ទឹកសន្ទាប់ | ( < សន្ទឹក ) | ស្រមើស្រមៃ | ( < ស្រមៃ ) |
| ក្រហល់ក្រហាយ | ( < ក្រហាយ ) | កំព្រីកំព្រា | ( < កំព្រា ) |

បង្ខិតបង្ខំ ( < ខិតខំ )
បំភិតបំភ័យ ( < ភិតភ័យ )
រលករលេញ ( < រលក )
ទំនាក់ទំនង ( < ទាក់ទង )
កកេកកកោក ( < កកោក )
ងងឹតងងល់ ( < ងងឹត )
វិសេសវិសាល ( < វិសេស )
ពព្រាក់ពព្រើល ( < ពព្រើល )
សញ្ឆប់សញ្ឆឹង ( < សញ្ឆឹង )
ស្រងូតស្រងាត់ ( < ស្រងូត )
ទម្លុះទម្លាយ ( < ធ្លុះធ្លាយ )
ចចេចចច្ចូច ( < ចេចច្ចូច )
គ្រហឹមគ្រហែម ( < គ្រហឹម )
បំផ្លិចបំផ្លាញ ( < បំផ្លាញ )
ស្រមេមស្រមាម ( < ស្រមាម )
រដិបរដុប ( < រដុប )
រហេមរហាម ( < រហាម )
បណ្ដេតបណ្ដោយ ( < បណ្ដោយ )
រឡេះរឡោះ ( < ឡេះឡោះ )
ត្រមង់ត្រមោច ( < ត្រមោច )
ទទ្រេតទទ្រោត ( < ទ្រេតទ្រោត )
ទទ្រុឌទទ្រោម ( < ទ្រុឌទ្រោម )

ប្រយ័ត្នប្រយែង ( < ប្រយ័ត្ន )
រលីងរលោង ( < រលោង )
រលះរលាំង ( < រលះ )
កកៃកករ ( < កកៃ )
ងងឹងងើ ( < ងឹងងើ )
ចច្រេសចច្រាស ( < ចច្រាស )
កំប្លុកកំប្លែង ( < កំប្លែង )
ពង្រេចពង្រិល ( < ពង្រិល )
ស្រវាស្រទេញ ( < ស្រវា )
លន្លង់លន្លោច ( < លន្លោច )
គំនុំគុំគួន ( < គំនុំ+គុំ )
ត្រវីត្រវាត់ ( < វីវាត់ )
គគ្រិតគគ្រាត ( < គគ្រាត )
ននេលននល ( < ននល )
រញ៉ាំរញ៉ូវ ( < រញ៉ាំ )
រលីមរលាម ( < លីមលាម )
ក្រឡិចក្រឡុច ( < ក្រឡិច )
រហេចរហាច ( < រហាច )
តតេះតតះ ( < តតះ )
កន្ដេកន្ដី ( < កន្ដី )
ក្រឡេកក្រឡាប់ ( < ក្រឡេក )
ទទ្រឹកទទ្រើក ( < ទទ្រើក )

សំពឹងសំពោង ( < សំពោង )
ប្រហាក់ប្រហែល ( < ប្រហែល )
ក្រអូបក្រអែប ( < ក្រអូប )
គគឹកគគាក់ ( < គឹកគាក់ )
បំណែបំណុល ( < បំណុល )
ពព្រឹកពព្រាក ( < ពព្រាក )
ត្រដាបត្រដួស ( < ត្រដាប )
សម្លក់សម្លឹង ( <សម្លក់+សម្លឹង )
ញញឹមញញែម ( < ញញឹម )
ជជុះជជាយ ( < ជជុះ )
តម្អួញតម្អែ ( < តម្អួញ )
រកាំរកូស ( < រកាំ )
ក្រវេមក្រវាម ( < ក្រវាម )
កន្តិញកន្តុញ ( < កន្តុញ )
គីរគំរក់ ( < គំរក់ )
សន្ទោសន្ទៅ ( < សន្ទៅ )
កញ្ឆក់កញ្ឆែង ( < កញ្ឆក់ )
វង្វេងវង្វាន់ ( < វង្វេង )
កក្វូរកកាយ ( < ក្វូរ + កាយ )
ចិញ្ចាចចិញ្ចែង ( < ចិញ្ចាច )
លឡេះលឡះ ( < ឡេះឡះ )
រលីងរលោង ( < រលោង )

កក្អាកកក្អាយ ( < ក្អាកក្អាយ )
បង្អិនបង្អោច ( < បង្អិន )
គគុះគគុល ( < គគុល )
ចំរុងចំរើន ( < ចំរើន )
បង្កបង្កើត ( < កកើត )
ត្រជាក់ត្រជំ ( < ត្រជាក់ )
អំពើអំពាន់ ( < អំពើ )
សម្លសម្លក់ ( < សម្ល )
ទទាក់ទទាម ( < ទាក់ទាម )
ជំពាក់ជំពិន ( < ជំពាក់ )
ពង្វក់ពង្វី ( < វក់វី )
អង្គីរអង្គើរ ( < គីគើរ )
កញ្ឆក់កញ្ឆែង ( < កញ្ឆក់ )
បញ្ឆិតបញ្ឆៀង ( < ឆិត+ឆៀង )
ត្រសុំត្រសាយ ( < ត្រសាយ )
លលីមលលាម ( < លលាម )
កញ្ឆេតកញ្ឆុត ( < កញ្ឆុត )
អំណោះអំណាង ( < អះអាង )
លលីលលើ ( < លលើ )
បម្រែបម្រួល ( < ប្រែប្រួល )
រលេះរលាំង ( < រលេះ )
ពពីមពពើម ( < ពពើម )

រហោតរហូត ( < រហូត )
បញ្ឆើចបញ្ឆើ ( < បញ្ឆើច )
សង្រេងសង្រៃ ( < សង្រេង )
អារាត់អារាយ ( < រាត់រាយ )
រលុះរលាយ ( < រលុះ )
ក្រហល់ក្រហាយ ( < ក្រហាយ )
រយីងរយោង ( < រយោង )
ប្រយ័ត្នប្រយែង ( < ប្រយ័ត្ន )
ក្រឡៀក្រឡា ( < ក្រឡា )
ក្រឡិចក្រឡាច់ ( < ក្រឡិច )
តម្រែតម្រង់ ( < តម្រង់ )
ទង្គិចទង្គើ ( < ទង្គិច )
ចំអេសចំអាស ( < ច្អេសច្អាស )
បម្រើបម្រាស់ ( < បម្រើ )
រណោបរណាប ( < រណាប )

រហេងរហាង ( < ហេងហាង )
បន្ថែមបន្ថយ ( < ថែមថយ )
បញ្ចុះបញ្ចូល ( < ចុះចូល )
បង្ខាំងបង្ខៀវ ( < បង្ខាំង )
បង្ខកបង្ខាន ( < ខកខាន )
រយីករយាក ( < យីកយាក )
ស្រពាប់ស្រពោន ( < ស្រពោន )
ត្រហេបត្រហាប ( < ត្រហាប )
ក្រឡៀមក្រឡឹម ( < ឡៀមឡឹម )
ចចើងចចេស ( < ចចេស )
ទូលំទូលាយ ( < ទូលាយ )
មយីមយា ( < មយា )
ពភ្លើតពភ្លើន ( < ភ្លើតភ្លើន )
សម្រិតសម្រាំង ( < ស្រិតស្រាំង )
ទទឹងទទែង ( < ទទឹង )

***

*អក្សរសាស្ត្ររលត់ ជាតិរលាយ*
*អក្សរសាស្ត្រពន្លាយ ជាតិថ្កើងថ្កាន ។*

( បុរាណភាសិត )

# សិលាចារឹកថ្មីមួយ នៅអនុវិទ្យាល័យព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ

ដោយ **ខង់ សុធារ៉ា**

អតីតនិស្សិតប្រវត្តិវិទ្យា ជំនាន់ទី ១៣

*អំពីប្រវត្តិដើមនៃសិលាចារឹក*

បច្ចុប្បន្ន សិលាចារឹកនេះត្រូវបានគេរក្សាទុកនៅក្នុងបណ្ណាល័យនៃអនុវិទ្យាល័យព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ លោកនាយកអនុវិទ្យាល័យឈ្មោះ កង សារិទ្ធ បានរៀបរាប់ប្រាប់អោយយើងដឹងអំពីប្រភពនៃសិលាចារឹកនេះដូចតទៅ ៖

នៅសម័យ ប៉ុល ពត ក្នុងឆ្នាំ ១៩៧៨ អង្គការប៉ុល ពត បានបញ្ជាអោយអ្នកស្រុកជីករណ្ដៅធ្វើជីរ ។ ពេលនោះ លោកឌី ឡាយ, លោកអាត់ ខេង និងប្រជាជន ១៧ មេសា ម្នាក់ទៀត ( លោកមិនចាំឈ្មោះ ) ត្រូវបានគេបញ្ជាអោយជីករណ្ដៅជីរ នៅលើទួលមួយ ឈ្មោះទួលតាញឹម ស្ថិតនៅទិសអាគ្នេយ៍ទួលអង្គប្រមាណ ១៥០ ម ដែលតាំងនៅខាងកើតភូមិព្រៃកប្បាស ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ សព្វថ្ងៃ ។

ការជីករបស់លោកទាំងបីនាក់ បានប្រទះឃើញនូវសិលាចារឹកមួយផ្ទាំងធំមានចារអក្សរត្រឹមពាក់កណ្ដាលផ្នែកខាងលើ និងសំណាកព្រះបាទត្រឹមពាក់កណ្ដាលស្នងជើង ។ ឃើញដូច្នេះ លោកក៏បានផ្កាប់ផ្ទាំងថ្មភក់ចតុកោណកែង ដែលមានកម្រាស់ប្រមាណ ០,០៩ ម. នោះទៅលើដី ដើម្បីកុំអោយគេឃើញអក្សរ ព្រោះលោកយល់ថា កាលណាអង្គការឃើញ អាចបញ្ជាអោយអ្នកស្រុកបំផ្លាញចោល ។

នៅក្រោយឆ្នាំ ១៩៧៩ លោក ឌី ឡាយ បានប្រាប់ដំណឹងស្តីអំពីផ្ទាំងសិលាចារឹកនេះមកលោក កង សារិទ្ធ ដែលកាលនោះ លោកជាគ្រូបង្រៀនថ្នាក់បឋមសិក្សានៅឡើយ ។ បានដំណឹងភ្លាម លោកបានទៅដល់ទីកន្លែង ដើម្បីរកយកមករក្សាទុក ប៉ុន្តែវត្ថុទាំងពីរខាងលើត្រូវបាត់ ។

ក្រោយពីការព្យាយាមស៊ើបសួរអ្នកស្រុកនៅតំបន់នោះមក ទើបដឹងថាផ្ទាំងសិលាចារឹកដ៏ធំនោះ ត្រូវបានលោកតា ស៊ិន លោកយាយ ជា នៅភូមិព្រៃកប្បាស " គ " យកមកធ្វើជាកន្លែងសម្រាប់អង្គុយ ប្រៀបដូចជាកូនគ្រែតូចមួយ ។ ដោយមានអន្តរាគមន៍អំពីលោក ប៉ែន ហៀក ដែលជាអាជ្ញាធរមូលដ្ឋាន លោក កង សារិទ្ធ ដែលជាអ្នកផ្តើមគំនិតសុំយកសិលាចារឹកនេះដំបូងគេ ក៏បានសំរេចតាមបំណងរួចហើយគេបាននាំយកមកតំកល់ទុកនៅក្នុងមន្ទីរចាត់ការនៃសាលាអនុវិទ្យាល័យព្រៃកប្បាស រហូតមកដល់សព្វថ្ងៃនេះ ។

សូមបញ្ជាក់ថា លោក ឌី ឡាយ បច្ចុប្បន្ន ជានាយករងវិទ្យាល័យព្រៃល្វា លោក អាត់ ខេង បច្ចុប្បន្ន បំរើការងារនៅវិទ្យាល័យច្បារអំពៅ អតីតវិទ្យាល័យសាធារណរដ្ឋតូបា ។

កាលពីឆ្នាំ ១៩៩៥ លោក នាយក កង សារិទ្ធ បានមានប្រសាសន៍ថា ក្រុមនិស្សិតអក្សរសាស្ត្រជំនាន់ទី ១២ ដឹកនាំដោយ លោកប៉ូល ពីខូ លោកសោម អួន បានធ្វើការថតចម្លងយកមកសិក្សាម្តងរួចហើយ ។ ប៉ុន្តែ ក្នុងកំឡុងពេលប្រហែលមួយខែក្រោយមក ដោយមាននិស្សិតម្នាក់ ឈ្មោះប៊ុន ធឿន ជាអ្នកមានស្រុកកំណើតនៅភូមិស្នោរ ឃុំស្នោរ ស្រុកព្រៃកប្បាស បានអោយដឹងថា មានសិលាចារឹកមួយផ្ទាំងថ្មី កំពុងរក្សាទុកនៅអនុវិទ្យាល័យព្រៃកប្បាស ក្រុមនិស្សិតជំនាន់ទី ១៣ មហាវិទ្យាល័យប្រវត្តិវិទ្យាយើងខ្ញុំ ដឹកនាំដោយលោក អ៊ុង ថារិទ្ធ, រូបខ្ញុំ ( វង់-សុធារ៉ា ), លោកប៊ុន ធឿន, លោកឡឹក សាវណ្ណ, លោកម៉ាក មុយ, កញ្ញាសែ

សៅនិមល កញ្ញា ប៉េង សោភ័ណ បានធ្វើដំណើរទៅសុំការអនុញ្ញាតពីលោកនាយកសាលា ធ្វើការផ្តិតយកមកសិក្សាដែរ ។

ក្រោមការជួយណែនាំ និងបង្រៀនពីលោកបណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម យើងទាំងអស់គ្នាអាចយល់បានអំពីពាក្យនិមួយៗក្នុងអត្ថបទ ។ ប៉ុន្តែ ការមួយដែលខ្ញុំឆ្ងល់នោះ គឺចាប់តាំងពីយកសិលាចារឹកនេះមកដល់មហាវិទ្យាល័យអក្សរសាស្ត្រ ក៏ដូចជាប្រវត្តិសាស្ត្រ មិនទាន់ឃើញមាននិស្សិតណា ធ្វើការបកប្រែអត្ថបទ សិក្សាឆ្លុះបញ្ចាំងអំពីអត្ថន័យរបស់វានៅឡើយ ហេតុដូច្នេះ ទើបខ្ញុំគិតថាត្រូវតែធ្វើការសិក្សាលើអត្ថបទនេះ ដើម្បីបំពេញតាមសំណូមពររបស់លោកនាយកអនុវិទ្យាល័យព្រែកប្បាស ដែលលោកមានបំណងប្រាថ្នាចង់ដឹងអំពីអាថិកំបាំងនៃអត្ថបទសិលាចារឹកនេះ និងដើម្បីទុកជាឯកសារសំរាប់អ្នកសិក្សាទាំងឡាយ ព្រមទាំងកូនខ្មែរជំនាន់ក្រោយផង ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំជឿជាក់ថា ការសិក្សារបស់ខ្ញុំលើអត្ថបទនេះ ពិតជាមានការខ្វះខាតខ្លះ មិនអាចឈានដល់ក៏រិតឥតខ្ចោះនោះបានទេ ។ ដូច្នេះ ខ្ញុំសូមអភ័យទោសទុកជាមុន និងរង់ចាំការរិះគន់ស្ថាបនាពីអស់លោកអ្នកសិក្សាផ្នែកសិលាចារឹកទាំងអស់ ដោយសេចក្តីសោមនស្សរីករាយបំផុត ។

## ភិនភាគសិលាចារឹក

ជាអត្ថបទភាសាខ្មែរសម័យអង្គរ លក្ខណៈអក្សរជ្រៀង មាន ១៤ បន្ទាត់ចារនៅលើផ្ទាំងសិលាស្តម្ភ ( stèle ) មានកំពស់ ១,៣ម បណ្តោយអក្សរ ០,៥៩ម និងកំរាស់ ០,០៩ម. ។ ប៉ុន្តែ អក្សរមិនបានចារពេញលើផ្ទាំងមុខកាត់ទាំងស្រុងនោះទេ កំពស់នៃជួរអក្សរ មានប្រវែង ០,៥ម. ហើយផ្ទាំងចារឹក គឺជាប្រភេទថ្មភក់រឹង ។

បច្ចុប្បន្ន ផ្ទាំងអត្ថបទចម្លងពីផ្ទាំងថ្ម (អត្ថបទដើម) មានរក្សាទុកនៅក្នុង

ក្នុងបណ្ណាល័យសាកលវិទ្យាល័យភ្នំពេញ មណ្ឌល I និងមណ្ឌល II នៅមហាវិទ្យាល័យប្រវត្តិវិទ្យា ។

## អក្ខបធជាភាសាខ្មែរសម័យថ្មី

១. ៩៤៨ ឝក ឥតិ ម្ចាយិ កែតិ វៃឝាខ អាទិត្យវារ នុ អញ៉ែត ជ្នះវាប៊.

២. ស្ថាបនា ឝិវលិង្គ អាសន កម្រតេង៏ជគត៏ លិង្គប្វរ ទុក៏វ្រះ បយ្យ [ ក ]

៣. ត ទៅតកម្រតេង៏ជគត៏ លិង្គប្វរ ស្រុក ស្រេ ខ្ញុំ៤ សិ កញ្ស្យាវិ សិ [ កគត. ] តៃ កញ្ជ្វ តៃតិ

៤. ថិ ថ្នុវិ ៧ ចេះ ចិនិ ១ រត្នបរ២ ចាម្រ១ លំវេង៏១ ស្រជង៏១ មស៊ [ ស្លិ ង៏. ] ១... ២. នេះ ត អញ៉ នៅ

៥. ស្បង៏មនិឱយិ ត វ្រះកំម្រតេង៏អញ៉ ឝិវលិង្គ ជ្នះ ខ្ញុំកត៏ទុក៏វ្រះ [ បចិ រិង ] ជ្នះ វ្ទុម្រគ្រម ត ជ្វោនិ

៦. ខ្ញុំកន្តែ ១ វាប៊ អម្ទុ.គ្ទ[ក] ១ ឱយិខ្ញុំ៤ [ អវល្យវសំមយុគ ] វាប៊ ឝិវធាម្មិ នុ វាប៊ នះហ នុ .

៧. វាប៊ ភិម នុ វាប៊ និក នុវាប៊ ចៅ នេះ អ្នាក៏ នេះ ស្បង៏ ត ឱយិ

៨. តភ្វម្យ នេះ ត អញ៉ រង្កោ លិះ២ .. ២ ស្មេប្រតិបក្ស រ្វិ

៩. អាច្ឆិ មានិ នា អាយិ ត្វ ទៃ តិ លេង៏ កម្រតេង៏ ជគត៏ លិង្គ.

១០. ប្វរ នៅ អ្នាក៏ ត បិទេយិ ធាម្មិនេះ តវ៉ [ ទ ] ហនេះ ហ

១១. គេ ទៅត នរក នុសន្តាន ហោង៏ នៅ អ្នាក្ក [ ត ] ច្វលិ អង្គ.

១២. យិ ត ស្រុក៏នេះ តជ្នះវ្ទុម្រគ្រម ស្បង៏ ត បរិបាល ធាម្មិ

១៣. នេះ ឯ ស្រេ មនិ អញ៉ ឱយិជ្នះ ឝិវ ណាយវេ

១៤. តៃយិវ្រាហ្ម.

## Textes

1- 948 çaka ta gi mvāy kait vaiçākha ādityavāra nu añ ta jmaḥ vāp-

2- sthāpanā çivaliṅga āsana kamrateṅ jagat liṅga pūra duk vraḥ payya [ ka ]

3- ta dau ta kamrateṅ jagat liṅgapūra sruk sre khñuṃ 4 si kañyāv si [ kagata- ] tai kañcū tai ti-

4- rtha thmur 7 ceḥ cin 1 ratnapara 2 cāmra1 laṃveṅ 1 srajaṅ 4 masa [ sliṅ ] 1---- 2 neḥ ta añ nau

5- syaṅ man oy ta vraḥ kamrateṅ añ çivaliṅga gi jmaḥ khnuṃ kat duk vraḥ [ paci riṅa ] jmaḥ rudraçrama ta jvon

6- khñuṃ kantai 1 vāp-asmu-gma [ ka ] 1 oy khñuṃ 4 [ a va la vu sam mayuga ] vāp çivadhārmma nu vāp naḥha nu

7- vāp bhima nu vāp cau neḥ anāk neḥ syaṅ ta oy

8- ta bhumya neḥ ta añ raṅko liḥ 2 -- 2 sme pratipakṣa vvaṃ

9- āc ti mān nā āy tva dai ti leṅ kamrateṅ jagata liṅga

10- pūra nau [a]nāk ta pideya dhārmma neḥ ta [ d ] ai ha neḥ ha

11- ge dau ta naraka nu santāna hoṅ nau anāk [ ta ] cval aṅgva-

12- y ta sruk neḥ ta jmaḥ rudraçrama syaṅ ta paripāla dhārmma

13- neḥ e sre man añ oy jmaḥ çivaṇāyave.

14- tai vrāhma.

## សិលាចារឹកដើម



## សេចក្តីបកប្រែ

(១) មហាសករាជ ៩៤៨ ថ្ងៃមួយកើត ខែ ពិសាខ ត្រូវនឹងថ្ងៃអាទិត្យ ខ្ញុំឈ្មោះវាប. (២) បានស្ថាបនាអាសនសិវលិង្គ តំកល់នៅកម្រតេងជគត លិង្គបូរ ទុក ព្រះអយ្យកោទ្ធូត (៣) តទៅ នាព្រះវិហារលិង្គបូរ ដោយមានស្រុក ស្រែ

ខ្ញុំ ៤ នាក់ សិកញ្យាវ សិ [ កគត ] តៃកញ្ជូ តៃតិថិ (៤) គោ ៧ ក្បាល ចេះចិន១ វត្ទបរ២ ចាម្រ១ លំពែង១ ស្រជង១ មាស .. ស្លឹង .. ២ ទាំងនេះដល់ខ្ញុំ ។ នៅ (៥) សឹងមាន អោយដល់ព្រះអាទិទេពលិង្គបូរនេះ ឈ្មោះខ្ញុំបំរើកត់ទុកក្នុងព្រះបញ្ជី ជាក់លាក់ ឈ្មោះរុទ្រស្រម ។ ជំនួន (៦) ខ្ញុំបំរើស្រីម្នាក់ វាប. អម្ទ-ត្អក មួយបាន អោយខ្ញុំបំរើ ៤នាក់ វាបគិរធាម្មិ និង វាប នះហ និង (៧) វាប ភិម និងវាប និក និងវាបចៅ ទាំងអស់នេះ ជាអ្នកសឹង ដែលអោយដល់ (៨) ភូមិនេះ ដល់ខ្ញុំ នូវ អង្ករ ២ ល្អី ..។ អ្នកបំរើដោយខ្មែត ក៏ដូចគ្នានឹងអ្នកបំរើដោយរនោច ពុំ (៩) អាចមាននូវ អ្នកដទៃណាទៀត ដែលនៅក្នុងចំណោមខ្ញុំបំរើទាំងនេះ ឡើងទៅលើព្រះវិហារលិង្គ (១០) បូរឡើយ ។ ចំពោះអ្នកដែលបៀតបៀន ឈ្នានីសដល់ព្រះវិហារ ក៏ដូចជាទ្រព្យ សម្បត្តិទាំងនេះ តទៅសូមអោយ (១១) គេទាំងនោះ ទៅកើតក្នុងស្ថាននរក អស់ ទាំងសន្តានផង ។ ចំពោះអ្នកចូលមករស់នៅ (១២) ក្នុងស្រុកនេះ ដែលមានឈ្មោះថា" រុទ្រស្រម " សុទ្ធសឹងជាអ្នកថែរក្សាគាំពារព្រះវិហារ និងទ្រព្យ សម្បត្តិ ព្រះវិហារនេះ (១៣) រីឯស្រែមានខ្ញុំ អោយឈ្មោះថា " សិវណាយវេ " (១៤) តែ វ្រាហ្ម

## ពន្យល់ន័យពាក្យសំខាន់ក្នុងសិលាចារឹក

- ៩៤៨ ឝក : çaka គឺឆ្នាំ ៩៤៨ នៃមហាសករាជ ត្រូវនឹង គ.ស ១០២៦
- ម្វាយ៏កែត : mvāy kait : មួយកើត
- វៃឝាខ : vaiçākha : ខែពិសាខ
- អាទិត្យវារៈ ādityavāra : ថ្ងៃអាទិត្យ
- នុ : nu : នៅ, នូវ, និង
- អញ : añ : ខ្ញុំ ( បុរិសសព្វនាមរបស់ភាសាខ្មែរបុរាណ )

. ត : ta : ដល់, គឺជា, ដែល ( ជាឈ្មាប់ )

. ជ្មះ : jmaḥ : ឈ្មោះ

. វាបិ : vāp : ជាគោរម្យងារ[១]

. ស្ថាបនា : sthāpanā : បង្កើត, កសាង

. ឝិវលិង្គ : sivaliṅga : លិង្គរបស់ព្រះសិវ ឬព្រះឥសូរ[២]

. អាសន : āsana : ជាទីកន្លែង, ស្ថានសំរាប់អង្គុយប្រថាប់ . . .

. កម្រតេងជគតិ លិង្គបូរ : kamrateṅ jagat liṅgapūra : ពាក្យនេះ មកពីពាក្យ កម្រតេង ជគត មានន័យថា ទីកន្លែងជាទីគោរពបូជា របស់លោកៈ និង ពាក្យលិង្គបូរ មានន័យថា បុរី ឬទីក្រុង របស់ព្រះលិង្គ បានសេចក្តីថា ព្រះវិហារជាទីសក្ការបូជា ឈ្មោះ លិង្គបូរ[៣]

---

(១) គោរម្យងារមួយក្នុងចំណោមគោរម្យងារដ៏ច្រើនរបស់មន្ត្រីថ្នាក់តូចនៅសម័យអង្គរ ។ ដោយសារវាប ជាស្រទាប់មន្ត្រីថ្នាក់ទាបជាងគេ ដូច្នេះ ពួកគេក៏មិនសូវសំបូរធនធាន ស្តុកស្តម្ភណាស់ណាដែរ ។ ពាក្យនេះមានប្រភពមកពី ភាសាជ្វា ថា វ៉ះបះ ឬ វីប ប៉ីក (វប) ដែលមានន័យថា " ឪពុក " ។

(២) ជានិមិត្តរូបនៃ " ស្វយម្ភូ " ( svayambhu ) ឬកំណើតដោយឯកឯងនៃព្រះឥសូរ ។ ក្នុងសិល្បៈចម្លាក់ខ្មែរ គេបានឆ្លាក់លិង្គព្រះឥសូរពីថ្មវីងពណ៌ស ( ជួនកាលពណ៌ខ្មៅ ) អោយមានរាងជាបួនជ្រុងក៏មាន ជាប្រាំមួយជ្រុងក៏មាន ជាប្រាំបីជ្រុងក៏មាន ផ្នែកខាងលើ រាងមូលជានិច្ច ប្រៀបដូចចុងអង្រែ ហើយជានិច្ច-កាល តម្កល់នៅលើយោនីនាងទុគ៌ា ( មានឯកសារខ្លះទៀតថា តំកល់នៅលើយោនីនាងឧមា ) ដែលមានផលប្រយោជន៍ សំរាប់ប្រើជាជើងទ្រ (piédestal) មានរាងជាស្នូកប្រកបដោយចង្អូរព័ទ្ធជុំវិញ និងមានចំពួយមួយ សំរាប់បង្ហូរទឹកនៅពេលគេធ្វើពិធីសិវរាត្រី ។

សូមមើល : សរ សារុន " វប្បធម៌ និងអរិយធម៌ខ្មែរ " ភាគ ២ ភ្នំពេញ ឆ្នាំ ១៩៧០ ទំព័រ ១៧៩ ។

(៣) ជាព្រះវិហារធ្វើឡើងអំពីឥដ្ឋ ថ្មបាយក្រៀម ឬថ្មភក់ ។ ក្នុងសម័យសតវត្សទី ១១ កម្រតេង ជគត ស្ទើរតែទាំងអស់ស្ថាបនាអំពីថ្មភក់ ឬថ្មបាយក្រៀម ។ ភស្តុតាងមានអក្សរចារឹកនៅប្រាសាទព្រះខ័ន និងបន្ទាយក្តីជាដើម ។ ដើម្បីបញ្ជាក់ពីទីស្ថានមួយៗ ដែលគេកសាងឧទ្ទិសចំពោះអ្នកមានភក្តីភាពចំពោះគេៗត្រូវសរសេរថា " ព្រះកម្រតេង ជគត " នៅខាងចុង គេដាក់ឈ្មោះវរជន ដែលគេឧទ្ទិសអោយ ។ ដូច្នេះ នៅទីនេះ មន្ត្រីវាបបានកសាងប្រាសាទមួយដើម្បីឧទ្ទិសដល់ព្រះឥសូរ ដែលជាអ្នកបង្កើតសត្វលោក ។

- ទុកវ្រះបយ្យ (ក) : duk vraḥ payya [ ka ] : ទុកនូវព្រះអយ្យ-កោទូត ឬជីទូត

- តទៅតះ ta dau ta : តទៅដល់

- ស្រុក៑ : sruk : ស្រុកភូមិ, ជំរក, ប្រជុំទីលំនៅ

- ស្រេ : sre : ស្រែ

- ខ្ញុំ ៤ : khñuṃ 4 : ខ្ញុំបំរើ ៤ នាក់

- សិ កញ្សាវ៑ si kañyāv : ខ្ញុំបំរើប្រុស[១] ឈ្មោះ កញ្សាវ

- សិ [ កគត- ] si kagata- : ខ្ញុំបំរើប្រុស ឈ្មោះ កគត

- តៃ កញ្ចុ tai kañcu : ខ្ញុំបំរើស្រី[២] ឈ្មោះ កញ្ចុ

- តៃតិថ tai tirtha : ខ្ញុំបំរើស្រី ឈ្មោះ តិថ

តិថ មានន័យថា : ជានាមមួយ ក្នុងចំនោមជាច្រើនរបស់ព្រះសិវ និងម្យ៉ាងទៀតមានន័យថា : ផ្លូវ យាន ឬ មធ្យោបាយ

- ថ្មុរ៧ : thmur7 : គោចំនួន៧ក្បាល

- ចេះចិន១ : ceḥ cin 1 :

- រត្នបរ២ : ratnapara :

- ចាម្រ១ : cāmra1 :

- លំវេង៑១ : laṃveṅ1 : លំពែង១

- ស្រជង៑១ : srajaṅ1 :

- មស៑ ស្លិង៑- mas sliṅ- : មាស... ស្លឹង

- នេះតអញ : neḥ ta añ : ទាំងនេះចំពោះខ្ញុំ ឬ ដល់ខ្ញុំ

---

(១) នៅសម័យអង្គរ គោរម្យងាររបស់ពួកខ្ញុំបំរើប្រុស សំគាល់ដោយពាក្យខាងដើមថា "សិ"

(២) នៅសម័យអង្គរ គោរម្យងាររបស់ពួកខ្ញុំបំរើស្រី សំគាល់ដោយពាក្យខាងដើមថា "តៃ"

- នៅ : nau : នៅ
- ស្យង៑មន៑ : syaṅ maṅ : សឹងមាន
- ឱយ៑ ត : oy ta : អោយដល់
- វ្រះកម្រតេង៑អញ៑ ឝិវលិង្គ : vraḥ kammrateṅ añ ព្រះអាទិទេព ( ជាលិង្គរបស់ព្រះឥស្វរ ) ពាក្យថា : វ្រះកម្រតេងអញ គឺមានន័យថា អាទិទេព ( Dieu ) នៅក្នុងភាសាខ្មែរសម័យអង្គរ ។
- ជ្មះខ្ញុំ : jmaḥ khñuṃ : ឈ្មោះខ្ញុំបំរើ
- កត៑ ទុក៑ : kat duk : កត់ទុក
- វ្រះបចិរិង ជ្មះរុទ្រស្រម : vraḥ paci riṅa jmaḥ rudraçrama: ព្រះបញ្ជីឈ្មោះរុទ្រស្រម ដែលមិនអាចផ្លាស់ប្តូរបាន
- ជ្វោន៑ ខ្ញុំកន្តៃ១ : jvon khñuṃ kantai1 : ជូន ឬប្រគេនខ្ញុំបំរើស្រីម្នាក់
- វាប៑ : vāp : ជាឋានន្តរនាមមន្ត្រី
- វាប៑ ឝិវធាម្ម៑ : çivadhārmma : មន្ត្រីវាបឈ្មោះ ឝិវធាម្ម៑ ពាក្យសិវធាម្ម៑ មានន័យថា : អ្នកទ្រទ្រង់ព្រះសិវៈ ( បានដល់ទាំងអំពើល្អនិងទ្រព្យសម្បត្តិផងនានា ជារបស់ព្រះឥស្វរ )
- វាប៑ នះហ : naḥ ha. មន្ត្រីវាបឈ្មោះ នះហ
- វាប៑ ភិម : bhima : មន្ត្រីវាបឈ្មោះភិម ពាក្យភិម មានន័យថា : អស្ចារ្យ, ឬ ព្រះព្រហ្ម
- វាប៑ និក : nika : មន្ត្រីវាបឈ្មោះ នីក ពាក្យនីក (?)
- វាប៑ ចៅ : cau : មន្ត្រីវាបឈ្មោះចៅ ពាក្យចៅ : ចៅ
- នេះអ្នាក៑នេះស្យង៑ត ឧយ៑ត ភូម្យនេះ neḥ ªnāk neḥ syaṅ ta

oy ta bhumya neḥ ពួកអ្នកទាំងនេះ សុទ្ធតែធ្វើនូវអំណោយដីភូមិដ្ឋាននេះ

- ត អញ : ta añ : ដល់ខ្ញុំ
- រង្កោ លិះ២ : raṅko liḥ2 : អង្ករចំនួនពីរល្អី
- ស្មេប្រតិបក្ស : sme pratipakṣa : អ្នកបំរើទាំងខ្នើតទាំងរនោច[១]
- វ្វំ : vvaṃ :ពុំ, មិន
- អាច្ទិ មានិនាអាយិត្វទៃតិ : āc ti mān nā āy tva dai ti : ដីនៅទីនេះ អាចមានអ្នកផ្សេងទៀតចូលដល់
- លេង៑ : leṅ : លើង, លែង ( ឈប់, បោះបង់ចោល )
- ហនេះហ : ha neḥ ha : សូមឱ្យ
- បិទេយិ ធាម្មិ : pidey dhārmma : អ្នកបៀតបៀនឈ្មានីសដល់ទីបូជនីដ្ឋាន ជាទីសក្ការៈ
- ត(ទៃ) : ta (dai) : ដទៃ
- នរកនុសន្តានហោង៑ : naraka nu santāna hoṅ : ( ចុះ ) នរកអស់ទាំងញាតិសន្តាន ហោង ( បងប្អូនជាប់ខ្សែលោហិត )
- អ្នាក្ក ច្វលិ អង្គុយ :ªnakk cval aṅgvay : មនុស្សដែលចូលមករស់នៅ ( អង្គុយ : រស់នៅ )
- គេ : ge : ពួកគេ ( នៅសម័យមុនអង្គរ និង សម័យអង្គរពាក្យនេះ

---

(១) នៅសម័យអង្គរ ខ្ញុំបំរើដែលត្រូវនៅថែរក្សា សំអាតប្រាសាទ ឬព្រះវិហារជាទីសក្ការបូជា តែងតែបែងចែកវេនគ្នាយាមជាប្រចាំ ក្នុងមួយខែមានរយៈពេល ១៥ ថ្ងៃ ម្នាក់ យោងតាមប្រតិទិនចន្ទគតិ គឺក្រុមមួយបំរើនៅវេលាខ្នើត និងក្រុមមួយទៀតបំរើនៅវេលារនោច ។

cf. Inscriptions du Cambodge, K 224, 227, AIBL, TOME IV

ត្រូវបានប្រើជាពហុវចនៈ ខុសប្លែកគ្នាពីបច្ចុប្បន្ន )

- ស្រុកិនេះតជ្មះរុទ្រគ្រម : sruk neḥ ta jmaḥ rudraçrama : ស្រុកនេះមានឈ្មោះថា រុទ្រស្រម
- បរិបាលធាម្ម៌ : paripāla dhārmma : (អ្នក) ថែរក្សាការពារទ្រព្យសម្បត្តិរបស់វត្តអារាមកុំអោយមានការបាត់បង់ ឬទទួលនូវការ ខូចខាតដោយអំពើរលោភណាមួយ
- ឯស្រេ មនិ អញ ឱយ៏ជ្មះ : e sre man añ oy jmaḥ : រីឯស្រែទាំងឡាយមានខ្ញុំ[១] អោយឈ្មោះ
- ឝិវណាយវេ : çivaṇāyave : ឈ្មោះស្រែគរុភ័ណ្ឌរបស់អាស្រមលិង្គបូរនេះថា " ឝិវណាយវេ "
- តៃវ្រាហ្ម : tai vrāhma : ខ្ញុំបំរើស្រី ឈ្មោះ ព្រាហ្ម

## សេចក្តីសន្និដ្ឋាន

ការឆ្លុះបញ្ចាំងសង្គម-ប្រវត្តិ តាមរយៈសិលាចារឹកនៅក្នុងវិទ្យាល័យព្រែកប្បាស ។

អនុលោមតាមកាលបរិច្ឆេទនៃសិលាចារឹកឆ្នាំ ៩៤៨ ដែលត្រូវនឹងគ.ស ១០២៦ ពេលនេះ ប្រទេសកម្ពុជា ហៅថា " ចក្រភពកម្ពុទេស " ក្នុងរជ្ជកាលនៃព្រះបាទសូរ្យវរ្ម័នទី ១ ( ១០០២-១០៥០ គ.ស )[២] ។ តាមលោក ហ្សក សឺដេស និងបណ្ដាអ្នកសិក្សាផ្នែកសិលាចារឹកជនជាតិខ្មែរជាច្រើនរូបទៀត បានចាត់ទុកថា ព្រះបាទសូរ្យវរ្ម័នទី១ ជាមហាក្សត្រកាន់ព្រះពុទ្ធសាសនាមហាយាន មុនគេបង្អស់ នៅ

---

(១) គឺជាអ្នកផ្ដើមបុណ្យ (២) cf. Inscriptions du Cambodge K. 92, CV. 229

សម័យអង្គរ ពីព្រោះតែសក្តិភាពនៃមរណនាម ( រយសហាបឡាភទ ) របស់ព្រះអង្គថា" និវ្វានបទ" (៩) និងតាមកាលប្បវត្តិជាភាសាបាលី ដែលបានកត់ត្រាទុកនៅឆៀងម៉ៃ ។ អ្នកស្រាវជ្រាវទាំងនោះថា ទោះបីជាព្រះអង្គគោរពពុទ្ធសាសនាមហាយាន ក៏ព្រះអង្គមិនបានបំបិទសិទ្ធិសេរីភាពជំនឿលើព្រហ្មញ្ញសាសនាដែរ ជាពិសេស ពួកមន្ត្រី នាម៉ឺន សេនាបតី និងប្រជារាស្ត្រមួយភាគធំ នៅតែបន្តការគោរពសាសនា តាមជំនឿរបស់ ខ្លួនបាន ដោយគ្មានបញ្ហារើសអើងវណ្ណៈ ។

ត្រង់នេះ សិលាចារឹកនៅអនុវិទ្យាល័យព្រែកប្បាស អាចជាសក្ខីភាពមួយដែរ ថ្វីដ្បិតអត្ថបទមិនបានបញ្ជាក់អំពីព្រះរាជបញ្ញា របស់ព្រះមហាក្សត្រ បញ្ញត្តិឱ្យក-សាង ។

ពួកមន្ត្រី ដែលជាអភិជន សុទ្ធសឹងមានឋានន្តរនាម " វាប " បានចូលបច្ច័យរួមគ្នាផ្តួចផ្តើមកសាងអាសនៈ តំកល់សិវលិង្គនេះឡើង សំរាប់ជាទីគោរពបូជារបស់គេ ប្រៀបដូចជាពុទ្ធបរិស័ទខ្មែរបច្ចុប្បន្ន រួមវិភាគទានគ្នា បង្កបង្កើតវត្តអារាមសំរាប់ធ្វើសក្ការបូជា ចំពោះព្រះសម្មាសម្ពុទ្ធ ដូច្នោះដែរ ។

ដោយសារពួកវាបទាំងនេះ ជាអ្នកមានធនធានតាមក៏រិតនៅឡើយ ខុសពីពួកនាម៉ឺន មន្ត្រី ដទៃទៀត ដែលជាអភិជនជាន់ខ្ពស់ ក្នុងការកសាងព្រះវិហារព្រាហ្មណ៍មួយពួក គាត់បានវែរអង្គាសធនធានគ្នា មានទ្រព្យសម្បត្តិ ដូចជា ដីស្រែចំការ គោ ខ្ញុំបំរើ រតនវត្ថុ គ្រឿងឧបភោគបរិភោគ ដែលសុទ្ធសឹងជាមូលនិធិមួយសំរាប់ផ្គត់ផ្គង់ព្រះវិហារឱ្យមានស្វ័យភាពសេដ្ឋកិច្ច និងមានសកម្មភាពជាអចិន្ត្រៃយ៍ ។

នៅក្នុងសិលាចារឹក យ៉ាងហោចណាស់ ក៏មានមន្ត្រីវាប ចំនួន ៧ នាក់

---

(៩) cf. IC, K 91.12, CII, 126; K 235D.140, 43, 44, 46, 50 Dans'articles sur le pays Khmère'p.p 198 - 205

ដែលរួមគ្នាកសាងកម្រតែងជគតលិង្គបូរដែរ ។

អត្ថបទបានបញ្ញត្តិហាមប្រាមដល់ពួកខ្ញុំបំរើទាំងអស់ ឬអ្នកដទៃណា ជាមនុស្សស្ថិតក្នុងក្រុមជនស្រទាប់ក្រោមដែរនោះ មិនឱ្យឡើងទៅ ឬចូលទៅក្នុងអាសនៈតំកល់ព្រះសិវលិង្គបូរ ។

នេះជាភស្តុតាងមួយទៀត បញ្ជាក់អំពីការបែងចែកវណ្ណៈរបស់ព្រាហ្មណ៍សាសនា នៅកម្ពុជាសម័យអង្គរ ដោយហេតុតែគេយល់ថា ខ្ញុំបំរើជាវណ្ណៈមនុស្សថោកទាបនៅក្នុងសង្គម ប្រៀបបាននឹងប្រាសាទអង្គរវត្ត ផ្នែកកំពែងជាន់ទី ១ ( ស្ថានបាកាណ ) ក្រៅពីព្រះមហាក្សត្រ សេនាបតី នាម៉ឺន មន្ត្រី គ្មានរាស្ត្រខ្មែរណាមួយត្រូវពួកព្រាហ្មណាចារ្យ បុរោហិត អនុញ្ញាតឱ្យចូលទៅធ្វើសក្ការបូជាបានឡើយ ។

យើងមានការចាប់អារម្មណ៍ប្លែកគ្នា ពីការអះអាងរបស់អ្នកស្រាវជ្រាវមុនៗ នោះត្រង់ថា តើអស់លោកទាំងនោះ មានបានពិចារណាទៅលើព្រះរាជសកម្មភាព និងស្នាដៃជាច្រើន ដែលបន្សល់ទុកដោយព្រះបាទសូរ្យវរ្ម័នទី១ដែរឬទេ ?

យើងតែងតែបានសំគាល់ឃើញស្នាដៃរបស់ព្រះអង្គទាំងនោះ បង្ហាញតែទៅលើខ្លឹមសារ ដែលបានផុសចេញអំពីលទ្ធិព្រាហ្មណ៍និយម ។

ឯទស្សនៈរបស់លោកបណ្ឌិត ឡុង សៀម វិញ ក៏តែងតែរំលឹកអំពីបញ្ហានេះដែរ ។ មកដល់បច្ចុប្បន្ននេះ លោកបានអះអាងផ្ទុយទៅនឹងទឡ្ហីករណ៍ របស់លោក ប៉្សេក សីដេស ព្រមទាំងអ្នកស្រាវជ្រាវខ្មែរ ដែលបានចាត់ទុក" ព្រះបាទសូរ្យ-វរ្ម័នទី១ ជាព្រះមហាក្សត្រកាន់ព្រះពុទ្ធសាសនាមហាយានមុនគេ នៅសម័យអង្គរ " ។ ពីព្រោះ នៅពេលយើងធ្វើការពិចារណាទៅលើបុព្វកិច្ច និងរាជបញ្ហាផ្សេងៗ សុទ្ធសឹងបង្ហាញ នូវសមិទ្ធិកម្មផុសចេញពីជំនឿព្រហ្មញ្ញសាសនា ។

តាមរយៈសិលាចារឹក នៅប្រាសាទភិមានអាកាស នៅប្រាសាទឃ្លាំង(១)

(១) cf. Inscriptions du Cambodge, K. 292 CIII, 205. K. 467 C VI, 217

សុទ្ធសឹងជាអត្ថបទសម្បថរបស់មេតម្រូតពលរបស់ព្រះអង្គ ដើម្បីសំដែងនូវសេចក្តីស្វាមីភក្តិ មិនតែប៉ុណ្ណោះ ស្ទម្បីស្រទាប់ប្រជារាស្ត្រសាមញ្ញ ឬអភិជននានាទៀត ក៏ព្រះអង្គតម្រូវអោយធ្វើសច្ចាប្រណិធាន សំដែងសេចក្តីស្មោះត្រង់ដែរ និងមានសិលាចារឹកថ្មីមួយទៀត ដែលទើបនឹងរកឃើញ និងផ្ទិតចម្លងដោយក្រុមលោកសោម អូន (និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ ជំនាន់ទី ១២) អត្ថន័យសិលាចារឹកបានបង្ហាញពីការចេញរាជបញ្ញាអោយដកហូតយកទ្រព្យសម្បត្តិ ដីធ្លី របស់មន្ត្រី ឬប្រជារាស្ត្រកាន់ពុទ្ធសាសនា ដោយព្រះបាទសូរ្យវរ្ម័នទី ១ ។

ទាំងនេះបង្ហាញអោយឃើញថា ព្រះអង្គ ជាព្រះមហាក្សត្រ ពោរពេញដោយភាពហិង្សា ម៉ឺងម៉ាត់ ក្នុងការដឹកនាំ ។

តាមប្រសាសន៍លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ដដែលថា ព្រះបាទសូរ្យវរ្ម័នទី ១ ទ្រង់បានទតឃើញមហិទ្ធិរិទ្ធរបស់ព្រះឥសូរផ្ទាល់ព្រះនេត្រ ។ ដោយសារឃើញព្រះឥសូរនិម្មិតច្បុតចុះមកប្រថាប់លើខ្នងភ្នំដងរែក ដូច្នេះហើយ ទើបក្រោយមក កន្លែងនោះ ព្រះអង្គចេញព្រះរាជបញ្ញា អោយសាងសង់ប្រាសាទភ្នំព្រះវិហារ ដែលបន្សល់ទុករហូតសព្វថ្ងៃ ដើម្បីឧទ្ទិសដល់ព្រះសិវៈ ។

ក្រៅពីនេះ សមិទ្ធផលប្រាសាទជាច្រើនរបស់ព្រះអង្គ សំរាប់ឧទ្ទិសដល់ព្រះសិវៈដូចគ្នា មាននៅភ្នំជីសូរ ខេត្តតាកែវ ជាដើម ។

សរុបសេចក្តីមក បើយើងលើកយកគតិមានពីបណ្តាសិលាចារឹកនានាមកធ្វើទឡ្ហីករណ៍ក្នុងរឿងនេះ ព្រះបាទសូរ្យវរ្ម័នទី១ ពិតជាព្រះមហាក្សត្រ កាន់ព្រាហ្មណ៍សាសនាយ៉ាងពិតប្រាកដ និងគោរពបូជាចំពោះព្រះសិវៈ មុតមាំបំផុត ។

វិលមកបង្ហាញអំពីអត្ថន័យនៃអត្ថបទ ដែលបានកំពុងសិក្សានេះម្តងវិញមន្ត្រី ( វាប ) ទាំងប្រាំពីរនាក់ មានជំនឿមុតមាំណាស់ចំពោះព្រះសិវៈ បានជាលោកខំប្រឹងប្រែងធ្វើបុណ្យសន្សំកុសល តាមលទ្ធិព្រាហ្មណ៍ ដាក់បណ្តាសា ដល់ជនណា

ហ៊ានបៀតបៀនបូជនីយដ្ឋាន អោយធ្លាក់ទៅកើតស្ថាននរក ព្រមទាំងញាតិសន្តាន បញ្ញត្តិអោយអ្នកដែលមកចូលរស់នៅក្នុងស្រុករុទ្រស្រម ជួយថែរក្សា គាំពារសមិទ្ធ-ផលរបស់ខ្លួន ប្រការនេះធ្វើអោយយើងដឹងអំពីស្ថានភាពជំនឿរបស់អ្នកស្រុកនោះ គឺឯកភាពគ្នាគោរពព្រះសិវៈតែមួយ ។

តាមធម្មតា ក្នុងការកសាងទីសក្ការបូជា មានប្រាសាទ ឬព្រះវិហារ ឬវត្តអារាម តំរូវអោយធ្វើឡើងនៅលើទីមួយខ្ពស់ បើមិនបាននៅលើភ្នំ ឬទួលធម្មជាតិទេ ក៏បរិស័ទ ត្រូវលើកដីចាក់អោយខ្ពស់ឡើងជាខឿន ដើម្បីកសាងអាសនៈបូជាដែរ ។ នៅក្នុងសម័យកាលនៃសតវត្សទី ១០ នៅកម្ពុជា រាល់អាសនៈកម្រតែងជគតសុទ្ធសឹងស្ថាបនាអំពីឥដ្ឋ ថ្មបាយក្រៀម ឬថ្មភក់ ដូច្នេះ យើងជឿជាក់ថា ទីឋានដែលបានរកឃើញសិលាចារឹកនេះ ពិតជាទីតាំងប្រាសាទមួយ នៅសតវត្សទី ១០ ដែលសំណង់នោះ អាចធ្វើឡើងពីវត្ថុធាតុទាំងបីខាងលើ ។ ការបាត់បង់ទីស្ថាន និងអត្តសញ្ញាណនៃកេរដំណែលនេះ ប្រហែលជាបណ្តាលមកពីមហន្តរាយសង្គ្រាម ឬអំពើព្យាបាទរបស់ពួកខិលខូចណាមួយមិនខាន ។ យ៉ាងហោចណាស់ ដោយសារពេលវេលា ធ្វើអោយប្រាសាទ ដែលជាអាសនៈតំកល់សិវៈលិង្គ និងសិលាចារឹកនេះត្រូវអន្តរាយខ្ចាត់ខ្ចាយ បាត់បង់ទ្រង់ទ្រាយរបស់ខ្លួន ។ ដោយសារជំនឿ ធ្វើអោយមនុស្សខិតខំបង្កើនសមិទ្ធផល ដ៏មានតំលៃអស្ចារ្យ ការពិតអ្វីដែលគេស្រមៃថា នឹងទទួលអានិសង្សទៅកាន់ស្ថាននិព្វាន ឬស្ថានព្រហ្ម គឺជាអរូបី ។ បរិស័ទព្រាហ្មណ៍ខិតខំធ្វើបុណ្យ ដើម្បីរំដោះកម្មិន អោយមកជួបព្រហ្មន ដែលជាព្រលឹងដើម ដោយឆ្លងកាត់វដ្តសង្សារអនេកជាតិ បើគេបានសំរេចផលហៅថា " មោក្សៈ " គឺព្រហ្មនបានជួបនឹងកម្មិនវិញ គេនឹងទទួលនូវបរមសុខជារៀងរហូត ។ ចំណែកពុទ្ធសាសនិកខិតខំព្យាយាមធ្វើបុណ្យសន្សំកុសល ព្រោះតែមានបំណងសំរេចមគ្គបួន នឹងបានទៅកាន់ស្ថាននិព្វាន ដែលជាស្ថានបរមសុខរៀងរហូតដែរ ។

ម្យ៉ាងទៀតនោះ ក្នុងព្រាហ្មណ៍សាសនា គេក៏ប្រើពាក្យ " និរ្វាន " ដែរ ដើម្បីសំដៅបញ្ជាក់អំពីបរមសុខ ។

ដូចនេះ យើងយល់ថា គ្រាន់តែមរណនាមរបស់ព្រះបាទសូរ្យវរ្ម័នទី ១ តែមួយប៉ុណ្ណោះ មិនអាចអោយអ្នកសិក្សាបានសន្និដ្ឋានដល់និន្នាការសាសនា របស់ព្រះអង្គបានទេ ។

សិលាចារឹកនៅអនុវិទ្យាល័យព្រៃកប្បាស គ្រាន់តែជាភស្តុតាងបន្ថែមមួយទៀត សំរាប់បង្ហាញនូវគ្រឹះ ដ៏រឹងមាំនៃព្រហ្មញ្ញសាសនា នៅសម័យអង្គរ ។

នៅចុងបញ្ចប់នេះ យើងគ្រាន់តែសូមអំពាវនាវអោយបងប្អូនជនរួមជាតិខ្មែរទាំងអស់ មេត្តាយកចិត្តទុកដាក់ជួយថែរក្សា កេរ្តិ៍មរតកវប្បធម៌របស់យើង មានតែរបស់អស់ទាំងនេះទេ ដែលជាភស្តុតាងដែលមិនអាចប្រកែកបាន ស្តីអំពីអាទិភាពដ៏ខ្ពង់ខ្ពស់របស់ជាតិខ្មែរ ។

ប្រសិនបើបេតិកភណ្ឌជាតិទាំងអស់នេះ បាត់បង់អស់ទៅ បានន័យថាព្រលឹងជាតិខ្មែរ បុព្វបុរសខ្មែរដ៏ល្បីល្បាញ ក៏សាបសូន្យទៅដែរ ។ ទោះបីជាអ្នកមិនបានចេះដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនជ្រៅជ្រះ ក៏គួរគប្បីដឹងថា វត្ថុបុរាណទាំងអស់គឺជាព្រលឹង ជាវិញ្ញាណ ជាអត្តសញ្ញាណ ដែលបុព្វបុរសខ្មែរបន្សល់ទុកអោយដែរ ។

ចំពោះបញ្ហានៃទីតាំងដែលរកឃើញសិលាចារឹកនេះ ខ្ញុំក៏សូមជូនជាដំណឹងដល់ក្រសួងវប្បធម៌ ដែលជាអាណាព្យាបាលលើផ្នែកនេះ មេត្តាពិនិត្យលទ្ធភាពចុះទៅស្រាវជ្រាវអោយបានស៊ីជំរៅ និងបញ្ចូលទៅក្នុងបញ្ជីសារពើភណ្ឌបេតិកភណ្ឌជាតិខ្មែរផង ។

# ឧត្តមសិក្សា និង កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច កម្ពុជា ( Higher Education and Socio-economic Development of Cambodia )

ដោយបណ្ឌិត **នេត បារ៉ុម**
សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ

*__ក.ក.ន.__ តទៅនេះ គឺជាអត្ថបទនៃឧទ្ទេសកថាប្រចាំខែ ធ្វើឡើងដោយលោកសាស្ត្រាចារ្យ នេត បារ៉ុម នៃសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ តាមការអញ្ជើញរបស់ពុទ្ធសាសនបណ្ឌិត្យ ។ អត្ថបទនេះបានបង្ហាញនូវទិដ្ឋភាពអនាគតថ្មី សម្រាប់ឧត្តមសិក្សានៅកម្ពុជា ដែលត្រូវដើរតួដ៏សំខាន់នាំមុខគេក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរបស់ប្រទេស ។*

*ជាប្រពៃណីពីដើមរៀងមក « កម្ពុជសុរិយា » បានផ្សព្វផ្សាយតែធម៌អាថ៌, វប្បធម៌, អក្សរសាស្ត្រ, ប្រពៃណី និងទំនៀមទម្លាប់ជាតិ រួមទាំងអក្សរសាស្ត្រពុទ្ធសាសនា និងរបាយការណ៍សកម្មភាពរបស់ក្រសួង ។ រីឯអត្ថបទទាក់ទងនឹងការអភិឌ្ឍន៍សង្គម-សេដ្ឋកិច្ច ឬការអភិឌ្ឍន៍វិស័យអប់រំទូទៅ ពុំធ្លាប់ដែលបានយកមកចុះផ្សាយផងទេ ។*

*ឥឡូវ អត្ថបទប្រភេទថ្មីនេះ ត្រូវបានសំរេចយកមកចុះផ្សាយ ពីព្រោះ :*

*១. ចង់ទាញការយកចិត្តទុកដាក់របស់សាធារណជន រួមទាំងភិក្ខុ-សាមណេរ ដែលជាអ្នកសិក្សារៀនសូត្រផ្នែកពុទ្ធិកសិក្សាផងដែរ មកលើនិន្នាការថ្មីៗ ខាងវិស័យអប់រំ ដែលកំពុងតែវិវត្តក្នុងពិភពលោក ។*

*២. ចង់លើកឡើងជាប្រធានបទពិចារណា សម្រាប់ការកែទំរង់ពុទ្ធិកសិក្សា នៅកម្ពុជា សំដៅលើកស្ទួយកំរិតចេះដឹងរបស់ព្រះសង្ឃកម្ពុជា ប្រៀបផ្ទឹមទៅកំរិតចេះដឹងរបស់ព្រះសង្ឃ ក្នុងប្រទេសកាន់ពុទ្ធសាសនាដទៃ ។*

*៣. ចង់ទាញការត្រិះរិះពិចារណា ថាតើពុទ្ធិកសិក្សានៅកម្ពុជា អាចរួមវិភាគទានបណ្តុះបណ្តាលបញ្ញាញាណជាតិតាមវិធីបែបណា ដែលអាចមានចំណែកជួយអភិវឌ្ឍសង្គម-*

*ជាតិបាន ដោយពុំទាស់ខុសនឹងវិន័យពុទ្ធសាសនា ។*

*នៅក្នុងស្មារតីនេះហើយ ដែល « កម្ពុជសុរិយា » លេខនេះ បានចុះផ្សាយអត្ថបទដូចតទៅ ដើម្បីក្រាលផ្លូវទៅរកការកែទំរង់ពុទ្ធិកសិក្សានៅកម្ពុជា ដែលហាក់ដូចជាឃ្លាតឆ្ងាយពីរង្វង់គិតគូររបស់អ្នកអប់រំជាតិ និងអន្តរជាតិ ផងដែរ ។*

## ១. លំនាំដើម

នៅប្រទេសជាច្រើនលើសកលោក និងជាពិសេស ប្រទេសទាំងឡាយនៅតំបន់អាស៊ីប៉ាស៊ីហ្វិកយើងនេះ គេកំពុងប្រលងប្រណាំងគ្នាពង្រឹង និងពង្រីកវិស័យឧត្តមសិក្សារបស់គេ ដើម្បីបំរើការងារល្អិតលាស់ និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់ប្រទេសគេ ។ ការកែទំរង់ ឬស្តារសេដ្ឋកិច្ច និងសង្គម ដែលផ្តួចផ្តើមឡើងដោយរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ អាស្រ័យទៅនឹងកំលាំងពលកម្មមនុស្សមានសមត្ថភាព ដែលផលិតចេញពីប្រព័ន្ធឧត្តមសិក្សា ។ គេនាំគ្នាកំណត់ថា ចាប់ពី ២០ ភាគរយ នៃចំនួនប្រជាជនមានអាយុល្មមចូលរៀនឧត្តមសិក្សា បានចូលរៀនឧត្តមសិក្សាឡើងទៅ ជាចំណុចផ្តើមដែលប្រទេសនីមួយៗ ក្លាយជាប្រទេសអភិវឌ្ឍ [ 1 ] ។

ចំពោះយុគសម័យវិទ្យាសាស្ត្រ បច្ចេកទេសទំនើបបច្ចុប្បន្ននេះ កម្មវិធីកែទំរង់សេដ្ឋកិច្ចជាតិ នឹងកាន់តែទាមទារឱ្យមានកំលាំងមនុស្សដែលបានទទួលការអប់រំខ្ពស់ ហើយតម្រូវការសង្គមក្នុងកិច្ចអភិវឌ្ឍឧត្តមសិក្សា នឹងកាន់តែទាមទារឱ្យឆាប់រហ័សទៅទៀត ពីព្រោះ វាជាឃ្នាស់នៃកិច្ចអភិវឌ្ឍសេដ្ឋកិច្ច ។ ក៏ប៉ុន្តែសំរាប់ប្រទេសក្រីក្រ និងទើបងើបពីភ្នក់ភ្លើងសង្គ្រាមរ៉ាំរ៉ៃ ដូចកម្ពុជាយើងផង ការពង្រីកនូវតម្រូវការសង្គមចំពោះវិស័យឧត្តមសិក្សា មិនមែនជាការងាយស្រួល បានតាមចិត្តយើងចង់នោះទេ ។ បញ្ហាដែលប្រទេសនេះចោទព្រមៗគ្នាចំពោះមុខ គឺខ្វះខាតទាំងធនធានហិរញ្ញវត្ថុ ខ្វះខាតទាំងធនធានមនុស្សមានសមត្ថភាពសំរាប់ជំរុញ ។

គេសន្និតថា ពង្រីងពង្រឹកវិស័យឧត្តមសិក្សា និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច - សង្គមរបស់ប្រទេសនីមួយៗ ជាបញ្ហាពីរដែលផ្សារភ្ជាប់គ្នា និងជះឥទ្ធិពលទៅមក ។ គេមិនអាចពោលថា កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ដោយមិនចាំបាច់ពង្រីងវិស័យឧត្តមសិក្សាបានឡើយ ។ ការកែទំរង់សេដ្ឋកិច្ច និងសង្គមឱ្យសមស្របតាមកាលៈទេសៈរបស់ប្រទេសក្នុងតំបន់ និងអន្តរជាតិដោយឥតឈប់ឈរជាបញ្ហាចំបង ក៏ប៉ុន្តែអភិវឌ្ឍនិវិស័យឧត្តមសិក្សា ត្រូវបានកំណត់ថាជាបញ្ហាគន្លឹះ ដើម្បីដឹកនាំការកែទំរង់សេដ្ឋកិច្ច និងសង្គមខាងលើ ។ ក្រៅពីនេះ វិស័យឧត្តមសិក្សាវិញ ក៏ត្រូវឋិតនៅក្នុងភាពប្រជែងគ្នាជាមួយផ្នែកដទៃទៀតរបស់វិស័យអប់រំ ( បឋមសិក្សា មធ្យមសិក្សា បណ្តុះបណ្តាលវិជ្ជាជីវៈ ) និងជាមួយកម្មវិធីសុខុមាលភាពផ្សេងៗ លើមូលដ្ឋានប្រភពធនធានដ៏តិចតួច នៃប្រទេសកំពុងអភិវឌ្ឍក្នុងការថ្លឹងថ្លែងរកតុល្យភាព និងអាទិភាព ។

## ២. សង្ខេបព្រឹត្តិការណ៍ជុំវិញបញ្ហាសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា

ប្រទេសកម្ពុជាស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ និងនៅភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន គ្របដណ្តប់លើផ្ទៃដីទំហំ ១៨១.០៣៥ គ.ម$^{២}$ ។ ពីព្រំដែនខាងកើតទៅខាងលិច មានប្រវែង ៤៤០ គ.ម និងពីព្រំដែនខាងជើងទៅខាងត្បូង ប្រវែង ៥៦០ គ.ម ។ ព្រំដែនគោក មានប្រវែង ២.១០០ គ.ម និងព្រំដែនសមុទ្រ ប្រវែង ៤៣៥ គ.ម តាមបណ្តោយឈូងសមុទ្រថៃ [2] ។ ទូទាំងប្រទេសពីដើម មួយភាគធំគ្របដណ្តប់ដោយព្រៃឈើ ស្មើនឹង ៧៣ % នៃផ្ទៃដីសរុប (មុនឆ្នាំ ១៩៧០) បច្ចុប្បន្ននៅសល់មិនដល់ ៤០ % នៃផ្ទៃដីទេ [3] ហើយក្នុងនេះ ព្រៃក្រាស់នៅសល់តិចតួចណាស់ ។ តាមការប៉ាន់ស្មានរបស់អ្នកឯកទេស បើសភាពការណ៍កាប់ព្រៃឈើដូចសព្វថ្ងៃនេះ នៅតែបន្តទៅទៀត ១៥ ឆ្នាំខាងមុខ កម្ពុជានឹងលែង

មានព្រៃឈើ ហើយនេះជាគ្រោះមហន្តរាយដ៏អាក្រក់បំផុតសំរាប់ប្រជាជាតិកម្ពុជា ។

ថ្វីបើប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាប្រទេសកសិកម្មមួយ ប៉ុន្តែជាទូទៅ ស្ថានភាព និងគុណភាពដីធ្លី មិនសូវអំណោយផលដល់វិស័យកសិកម្មទេ លើកលែងតែដីដែលស្ថិតនៅតាមបណ្តោយទន្លេមេគង្គ និងដីខ្មៅមួយចំនួន ។ ដំណាំស្រូវដែលបានចាត់ទុកថាជាមុខព្រួញសេដ្ឋកិច្ចមួយ ក្នុងចំណោមមុខព្រួញសេដ្ឋកិច្ចទាំងប្រាំ ដែលមានស្រូវ កៅស៊ូ ព្រៃឈើ នេសាទ និងទេសចរណ៍ ប៉ុន្តែទិន្នផល និងបច្ចេកទេសផលិតនៅទាប ធៀបនឹងប្រទេសក្នុងតំបន់ [4] ។

តារាងប្រៀបធៀបទិន្នផល រវាងឆ្នាំ ១៩៩២ - ៩៤ (តោនក្នុង ១ ហិកតា)

| | |
|---|---|
| កម្ពុជា | ១,៣ ( ១,៧០ * ) |
| ឥណ្ឌូនេស៊ី | ៤,៣ |
| វៀតណាម | ៣,៥ |
| ម៉ាឡេស៊ី | ៣,១ |
| ហ្វីលីពីន | ២,៩ |
| ឥណ្ឌា | ២,៧ |
| ឡាវ | ២,៥ |
| ថៃ | ២,២ |

ប្រភពទឹក មានទន្លេមេគង្គហូរកាត់ប្រវែង ៥០០ គ.ម និងមានដៃខ្នាត់ខ្នែងបង្កើតជាប្រព័ន្ធផ្លូវទឹកមួយ ដែលមានប្រយោជន៍យ៉ាងសំខាន់ដល់សេដ្ឋកិច្ចជាតិ ។

(*) : តាមទិន្នន័យ ឆ្នាំ ១៩៩៥ ផ្សាយដោយលេខាធិការដ្ឋាន NHETF

សក្តានុពលភាពវារីអគ្គិសនី គួបផ្សំនឹងធារាសាស្ត្រ អាចមានច្រើន ប៉ុន្តែជារួម យើងពុំទាន់បានធ្វើអាជីវកម្មឱ្យបានអស់ពីលទ្ធភាពនៅឡើយ ។

តាមឯកសារស្រាវជ្រាវរបស់អន្តរជាតិ ប្រទេសកម្ពុជាឃើញមានធនធានរ៉ែដូចតទៅ ៖ ដែក មាស ប្រាក់ បុកស៊ីត ទង់ដែង ហ្វូសហ្វាត ស្ពាន់ធ័រ ស៊ីលីស្យូម ម៉ាញេស្យូម ម៉ង់ហ្គាណែស ត្បូងថ្មមានតំលៃ ប្រេងកាត ថ្មបង្ហ ... ។ ប៉ុន្តែភោគ-ទ្រព្យក្នុងដីទាំងនេះ ពុំផ្តល់នូវភាពងាយស្រួលដល់ការធ្វើអាជីវកម្ម និងអភិវឌ្ឍន៍ឧស្សាហកម្មទេ ដោយសារភាគរយនៃចំណុះរ៉ែមានតិច ហើយបរិមាណក៏តិចតួចដែរ [2] ។ រ៉ែខ្លះនៅប៉ាត់ប៉ាយពីគ្នា ពុំអំណោយផលដល់ការធ្វើយោបក (Extraction ) លើកលែងតែថ្មមានតម្លៃចេញ ។ ប្រជារាស្ត្រកម្ពុជា មាន ១០,៧ លាននាក់ គិតប៉ាន់ស្មានត្រឹមថ្ងៃ ២០ ខែមីនា ឆ្នាំ ១៩៩៦ ក្នុងនោះមានប្រុស ៤៧,៨% និងស្ត្រី ៥២,២% ។ សន្ទស្សន៍ប្រជាជនមានប្រមាណ ៥៩,១ នាក់ ក្នុងផ្ទៃដី ១ គ.ម² ។ ប្រជារាស្ត្រនៅតាមទីប្រជុំជនមាន ១៤,៤% និងនៅតាមជនបទ មាន ៨៥,៦% ។ អនក្ខរជនមាន ៣១,៣ % នៃចំនួនយុវជនសរុប [5] ។

ផលិតផលជាតិសរុបក្នុងមួយឆ្នាំ សំរាប់ប្រជាជនម្នាក់ នៅឆ្នាំ ១៩៩៦ គឺ ៣០០ ដុល្លារ US$ [6] បើប្រៀបធៀបនឹងវៀតណាម ១.០០០ US$ ( របាយ-ការណ៍កែតម្រូវ ) និងឥណ្ឌូនេស៊ី ៣.០០០ US$ នៅឆ្នាំ ១៩៩៤ [7] ។ អត្រាអតិផរណា ឆ្នាំ ១៩៩៥ - ៩៦ ៥% ក្នុងមួយឆ្នាំ ។

ចាប់តាំងពីឆ្នាំ ១៩៩១ មក គ្រោះធម្មជាតិទឹកជំនន់ និងរាំងស្ងួត កើតមាននៅតំបន់ជាច្រើនក្នុងប្រទេសរៀងរាល់ឆ្នាំ បង្កការលំបាកបន្ថែមទៀតដល់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជីវភាពប្រជារាស្ត្រ ។ ក្រៅពីនេះ យើងអាចសង្កេតឃើញនូវឧបសគ្គសំខាន់ៗដទៃទៀត ដែលធ្វើឱ្យលំបាកដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាតិដូចជា ៖

(១) កង្វះខាតកំលាំងពលកម្មមានសមត្ថភាព ។

(២) ខ្វះជំនាញការបច្ចេកទេស និងប្រភពទុន ដែលអាចធ្វើអាជីវកម្មផលិតកម្ម និងយោបក ( Extraction ) លើធនធានធម្មជាតិ ។

(៣) ការបន្តកាប់បំផ្លាញព្រៃឈើ និងបំផ្លាញបរិដ្ឋានធម្មជាតិ ។

(៤) ក្បាលម៉ាស៊ីនរដ្ឋបាល និងការងាររដ្ឋ ពុំសូវមានប្រសិទ្ធភាព មានតែបរិមាណ ហើយច្រើនលើសលប់ ។

(៥) ប្រជាជនភាគច្រើនលើសលប់ មានកំរិតអប់រំទាប ហើយជីវភាពក្រីក្រ ។ ជនពិការដោយសង្គ្រាមក៏មានច្រើនដែរ ។

(៦) សន្តិសុខ និងស្ថិរភាពនយោបាយ ពុំទាន់ធានាបាន ១០០ % ។

(៧) នៅសល់ចំការមីនជាច្រើនលើផ្ទៃប្រកបកសិកម្ម ។

ដើម្បីស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច - សង្គមកិច្ចឱ្យរីកលូតលាស់ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្រ្ត និងគោលនយោបាយរយៈពេលមធ្យម ៥ ឆ្នាំ (១៩៩៦ - ២០០០ ) ដូចតទៅ [8] :

(១) បន្ថយភាពក្រីក្រ តាមរយៈកិច្ចអភិវឌ្ឍជនបទ ដោយមានការចូលរួមពីសហគមន៍ ។

(២) បើកទូលាយលទ្ធភាពទទួលសេវាកម្មខាងផ្នែកសង្គមកិច្ច ។

(៣) កំណែទំរង់ផ្នែកសាធារណៈ ។

(៤) លើកកំពស់កំរិតជំនាញ ។

(៥) អភិវឌ្ឍន៍លើមូលដ្ឋានផលិតកម្ម ជាពិសេស តាមរយៈការបង្កើនទិន្នផលស្រូវ ជំរុញផលិតកម្មចិញ្ចឹមសត្វ និងធ្វើឱ្យមានលក្ខណៈសំបូរបែប ក្នុងផ្នែកកសិកម្ម ដែលមានលក្ខណៈពាណិជ្ជកម្ម ។

(៦) ប្រើប្រាស់ប្រភពធនធានឱ្យមានលក្ខណៈជានិរន្តរភាព ។

(៧) បង្កមុខរបរតាមរយៈកម្មន្តសាល ដែលប្រើប្រាស់កំលាំងពលកម្មច្រើន ដើម្បីផលិតទំនិញសំរាប់នាំចេញ ជំរុញសហគ្រាសទ្រង់ទ្រាយតូច និងការងារជាឯកត្តជន និងទេសចរណ៍ ។

(៨) សមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ ។

## ៣. ស្ថានភាពឧត្តមសិក្សាកម្ពុជា

ការជាក់ស្តែងបច្ចុប្បន្ន យើងមានគ្រឹះស្ថានឧត្តមសិក្សាចំនួន ១០ ដែលសកម្មភាពក្រោមស្ថាប័ន ៥ ដាច់ដោយឡែកពីគ្នា គឺ :

- សាកលវិទ្យាល័យបួន : សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សាកលវិទ្យា-ល័យភូមិន្ទកសិកម្ម, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, និងសាកលវិទ្យាល័យវេទមហា-ឫសី (អ.យ.ក. អប់រំយុវជន និងកីឡា កសិកម្ម, និងវប្បធម៌) ។
- មហាវិទ្យាល័យចំនួនបួន : មហាវិទ្យាល័យវេជ្ជសាស្ត្រ - ឱសថសាស្ត្រ និងទន្តសាស្ត្រ, មហាវិទ្យាល័យគរុកោសល្យ, មហាវិទ្យាល័យពាណិជ្ជសាស្ត្រ, មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អ.យ.ក និងសុខាភិបាល ) ។
- វិទ្យាស្ថានបច្ចេកទេសកម្ពុជា ( អ.យ.ក. ) , និង
- សាលាភូមិន្ទរដ្ឋបាល ( គណៈរដ្ឋមន្ត្រី ) ។

ធាតុពិត គ្រឹះស្ថានឧត្តមសិក្សាទាំងនេះ សុទ្ធតែមានទ្រង់ទ្រាយតូច ចំនួនមុខជំនាញបណ្តុះបណ្តាលតិច និងចំនួននិស្សិតក៏តិច ទោះបីខ្លះមានឈ្មោះជាសាកល

វិទ្យាល័យហើយក៏ដោយ ។ កំរិតសម្រូបឱ្យចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋក្នុងប្រទេស មានប្រមាណពី ២.០០០ - ៣.០០០ នាក់ ប៉ុណ្ណោះក្នុងមួយឆ្នាំ ហើយចំនួននោះអាចនឹងថយចុះមកវិញក្នុងប៉ុន្មានឆ្នាំខាងមុខ ដោយវិបត្តិពិបាករកការងារធ្វើឱ្យអ្នកជាប់សញ្ញាប័ត្រ ( ចំពោះប្រព័ន្ធក្រោយមធ្យមសិក្សា ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមធ្យមគ្មានកំរិត រដ្ឋអាចស្រូបបានប្រមាណ ២.០០០ នាក់បន្ថែមទៀត ក្នុងមួយឆ្នាំ ) ។ បរិមាណនិស្សិតដែលបានបញ្ជូនទៅបណ្តុះបណ្តាលនៅឯបរទេសក្នុងមួយឆ្នាំៗ បច្ចុប្បន្នក៏មានអត្រាទាបបំផុត ឆ្នាំសិក្សា ១៩៩៥ - ៩៦ ការបញ្ជូននិស្សិតទៅរៀននៅបរទេសទាំងកម្មករជំនាញ អ្នកបច្ចេកទេសមធ្យម ឧត្តម និងក្រោយឧត្តម មានចំនួន ១០៨ នាក់ ត្រូវជា ២ % នៃចំនួនអ្នកបណ្តុះបណ្តាលក្នុងស្រុក [9] ។

ពារាងចំនួននិស្សិតឧត្តមសិក្សាក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក
ក្នុងចំណោមប្រជាជន ១០០.០០០ នាក់ ( ប្រចាំឆ្នាំ ) [10] :

| | | | |
|---|---|---|---|
| អាហ្វហ្គានីស្ថាន | ១៤៧ (១៩៩០) | អ៊ីរ៉ង់ | ៩១១ (១៩៨៥) |
| អូស្ត្រាលី | ៣១៧៨ (១៩៩២) | អ៊ីរ៉ាក់ | ១០៦១ (១៩៩០) |
| ភូមា | ៤៨៩ (១៩៨០) | អ៊ីស្រាអែល | ២៧៤២ (១៩៨៥) |
| កម្ពុជា | ១៣២ (១៩៩៥) | ជប៉ុន | ២៧៩០ (១៩៩០) |
| ចិន | ១៩១ (១៩៩២) | ហុងរដានី | ២៤៩៧ (១៩៩០) |
| ស៊ីប | ៥៧៩ (១៩៨៥) | កូរ៉េខាងត្បូង | ៤២០៨ (១៩៩២) |
| យេម៉ែនប្រជាធិបតេយ្យ ១៧៧(១៩៨០) | | ឡាវ | ១៥០ (១៩៨៥) |
| ហ្វីស៊ី | ៣១៤ (១៩៩០) | ម៉ាឡេស៊ី | ៦៧៩ (១៩៩០) |

| | | | |
|---|---|---|---|
| ហុងកុង | ១៥៣៤ (១៩៩០) | ម៉ុងហ្គោលី | ១៤១៦ (១៩៩២) |
| ឥណ្ឌា | ៧៧៦ (១៩៨០) | នេប៉ាល់ | ៤៧៩ (១៩៩០) |
| ឥណ្ឌូនេស៊ី | ១០៣២ (១៩៩២) | នូវែលសេឡង់ | ៤២៣២ (១៩៩២) |
| ប៉ាគីស្ថាន | ៤៧៥ (១៩៨៥) | ហ្វីលីពីន | ២៧៣៨ (១៩៩០) |
| សឹង្ហបុរី | ៩៦៣ (១៩៨០) | ស្រីលង្កា | ៤៨៨ (១៩៩០) |
| ថៃ | ២០៦០ (១៩៩២) | សហព័ន្ធអារ៉ាប់ | ៦៣៧ (១៩៩២) |
| វៀតណាម | ៦៤៧ (១៩៩០) | ទួរគី | ១៥៦៩ (១៩៩២) |

កម្មវិធីបណ្តុះបណ្តាលឧត្តមសិក្សាមានរយៈពេលពី ៤ - ៧ ឆ្នាំ បច្ចុប្បន្ន ពុំទាន់មានគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសណាមួយ បណ្តុះបណ្តាលកម្មវិធីក្រោយឧត្តមសិក្សាទៀងទាត់នៅឡើយទេ ។ ការងារស្រាវជ្រាវវិទ្យាសាស្ត្រ ពុំទាន់បានជំរុញ និងលើកទឹកចិត្តបំផុសនៅឡើយ នៅតាមស្ថាប័ននីមួយៗ ។ សកម្មភាពស្រាវជ្រាវភាគច្រើនអនុវត្តតែតាមរយៈអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬគំរោងចំរុះក្រសួង និងអង្គការអន្តរជាតិ ។ អាចពោលថា គ្រឹះស្ថានឧត្តមសិក្សារបស់យើង ពុំទាន់បានយកចិត្តទុកដាក់អំពីតួនាទីស្រាវជ្រាវវិទ្យាសាស្ត្ររបស់ខ្លួន ដែលជាមុខងារមួយមិនអាចខ្វះបាននៅឡើយទេ ។ គ្រឹះស្ថានឧត្តមសិក្សាឯកជន ទើបតែចាប់ផ្តើមពន្លកឡើង ពុំទាន់មានសកម្មភាពទៀងទាត់ និងដើរតួនាទីសំខាន់ក្នុងពេលបច្ចុប្បន្ននៅឡើយ ។

គ្រឹះស្ថានឧត្តមសិក្សារដ្ឋរបស់យើង នៅមានលក្ខណៈខុសគ្នាពីមួយទៅមួយ ទាំងរចនាសម្ព័ន្ធចាត់តាំង និងខ្សែរយៈគ្រប់គ្រងរដ្ឋបាល និងសិក្សា ដែលបង្កការលំបាកដល់កិច្ចសហប្រតិបត្តិការ និងដល់ភាពស៊ីសង្វាក់គ្នា ក្នុងប្រព័ន្ធឧត្តមសិក្សា

ជាតិមួយទាំងមូល ។

ខាងក្រោមនេះ គឺជាសង្ខេបរបាយការណ៍បញ្ចប់របស់ក្រុមដឹកនាំការងារជាតិឧត្តមសិក្សា ដែលបានវាយតម្លៃសភាពការណ៍ឧត្តមសិក្សាកម្ពុជាបច្ចុប្បន្ន ដូចតទៅ [11] :

*ក. រចនាសម្ព័ន្ធ និងនីតិកម្ម*

ដូចបានពោលខ្លះពីខាងដើម ឧត្តមសិក្សារបស់យើង នៅពុំទាន់មានលក្ខណៈច្បាស់លាស់អំពីគោលដៅ និងគោលបំណងរបស់ខ្លួន ។ ពុំទាន់មានអង្គការណាមួយទទួលបន្ទុកសម្របសម្រួលវិស័យឧត្តមសិក្សាទាំងមូលឱ្យស៊ីសង្វាក់គ្នា និងរៀបចំគោលនយោបាយអភិវឌ្ឍន៍រួម ។

ការគ្រប់គ្រងជាខ្សែរយៈរដ្ឋបាល និងសិក្សាក្រៅ និងក្នុងស្ថាប័ន ពុំទាន់មាននីតិកម្ម និងការណែនាំអនុវត្តច្បាស់លាស់ ។ គ្រឹះស្ថានឧត្តមសិក្សាខ្លះ នៅក្រោមក្រសួង ឬស្ថាប័នខុសៗគ្នា ពិបាកក្នុងទំនាក់ទំនង និងសហប្រតិបត្តិការ ។

រចនាសម្ព័ន្ធ និងតួនាទីរបស់ស្ថាប័ន ជាន់ថ្នាក់ឧត្តមសិក្សា ពុំទាន់បានកំណត់ក្នុងនីតិបញ្ញត្តិ ហេតុនេះហើយទើបយើងឃើញមានភាពខុសគ្នា ចាប់តាំងពីឈ្មោះឡើងទៅ ខ្លះសាកលវិទ្យាល័យ ខ្លះមហាវិទ្យាល័យ ខ្លះវិទ្យាស្ថាន សាលាដេប៉ាតឺម៉ង់ ជាដើម ហើយដើរតួប៉ុនៗគ្នា ។

*ខ. កម្មវិធីសិក្សា*

អគ្រាធនធានមនុស្ស ដែលបានបញ្ចប់កិរិតឧត្តមសិក្សាកន្លងមកទូទាំងប្រទេស ការពិតនៅទាប ០,២% នៃចំនួនប្រជាជនសរុប (អតិបរមា ២ ម៉ឺននាក់) និងខ្វះខាត ហើយចំនួនមុខជំនាញមានតិច ( ៣៣-៣៥ មុខ ) ប៉ុន្តែមុខជំនាញខ្លះយើងបាន និងកំពុងបណ្តុះបណ្តាលលើសតម្រូវការ ។ នៅមានជំនាញចាំបាច់ជាច្រើនដែលយើងពុំទាន់មានលទ្ធភាពបើកបាន ។

កម្មវិធីសិក្សារបស់យើង ពុំទាន់ឆ្លើយតបបានទៅនឹងតម្រូវការប្រសិទ្ធភាពការងារ នៃផ្សារពលកម្ម ខ្វះលក្ខណៈបត់បែនបាន និងភាពប្លែកៗ ។ កម្មវិធីខ្លះពុំទាន់ប្រៀបធៀបបាននៅកំរិតតំបន់ និងអន្តរជាតិ ។ ការតាក់តែងកម្មវិធីបណ្តុះបណ្តាល ពុំទាន់មានសហការចូលរួមពីស្ថាប័នអ្នកប្រើប្រាស់ ។

បុគ្គលិកបង្រៀនភាគច្រើន នៅខ្វះគុណភាពជំនាញ និងចំណេះដឹងទូលាយ ហើយទទួលប្រាក់ឧបត្ថម្ភជីវភាពទាប ធ្វើឱ្យស្មារតីទទួលខុសត្រូវ និងគុណភាពបណ្តុះបណ្តាលចុះខ្សោយ ។

សម្ភារៈឧបទេស និងសេវាកម្មឧត្តមសិក្សា ( បណ្ណាល័យ ទីពិសោធ ការដ្ឋានអនុវត្ត ... ) នៅខ្វះខាត និងខ្សត់ខ្សោយ ។ វិធីសាស្ត្រប្រើប្រាស់ក្នុងការបង្រៀន និងរៀន ពុំមានប្រសិទ្ធភាព ។

*គ. អ្នកចូលរៀន និងជាប់សញ្ញាប័ត្រ*

និស្សិតចូលរៀនភាគច្រើន ( ជាង ៨០ % ) មកពីខេត្តទាំងបី : ភ្នំពេញ បាត់ដំបង និងកំពង់ចាម ។ របាយនិស្សិតឃ្លាតឆ្ងាយពីសមាមាត្រនៃចំនួនប្រជាជននៅតាមតំបន់ក្នុងប្រទេស ។

និស្សិតនារីនៅតាមឧត្តមសិក្សាមានអត្រាទាប ១៥ % ( ឡាវ ស្ថិតិនារីក្រោយមធ្យមសិក្សា ៣៧% [12] ) ពុំសមស្របទៅនឹងអត្រាក្នុងចំនួនប្រជាជនសរុប ( ៥២,២ % ស្ត្រី ) ដែលធ្វើឱ្យបាត់សមាសភាគកំលាំងពលកម្មសង្គមជំនាញមួយផ្នែកធំរបស់នារី និងបាត់តុល្យភាពក្នុងអភិវឌ្ឍន៍ប្រទេស ។ ភាគរយនិស្សិតនារីមធ្យមតាមតំបន់ចុះឈ្មោះចូលរៀនឧត្តមសិក្សានៅឆ្នាំ ១៩៨៩ [13] :

អាហ្វ្រិក ២៥ % អាស៊ី ៣៥ % មជ្ឈិមបូព៌ា ៣៦ % អាហ្វ្រិកខាងជើង ៣៦ % អាមេរិកឡាទីន ៤៧ % ។

នយោបាយផ្តល់អាហារូបត្ថម្ភដល់និស្សិតក្រីក្រ ខ្វះលទ្ធភាព ឬមកពីឆ្ងាយ រៀនពូកែ ពុំមានប្រសិទ្ធភាព ។ តម្លៃឧបត្ថម្ភតិចតួច ពុំអាចទ្រទ្រង់ ឬលើកទឹកចិត្តអ្វីកើត ។

លក្ខណៈវិនិច្ឆ័យជ្រើសរើសឱ្យចូលទៅរៀនពុំទាន់សុក្រឹត ៖ សង្កត់ធ្ងន់តែពេលប្រឡងចូលមួយគត់ សិស្សម្នាក់អាចជាប់បានពីរ បីកន្លែងតែឯង ។

អ្នកជាប់សញ្ញាប័ត្រមួយចំនួនធំ ខ្វះគុណភាព និងមានចំនួនលើសលប់ ពុំអាចស្រូបបានដោយតម្រូវការពលកម្មជាតិ ។ ៦០ % នៃអ្នកជាប់សញ្ញាប័ត្រ ប្រមូលផ្តុំរកការងារធ្វើ តែនៅរាជធានីភ្នំពេញ ។

ពុំមានតួលេខណាមួយ អាចប៉ាន់ស្មានបាននូវប្រភេទ និងចំនួនពលកម្មកំរិតឧត្តមនៃតម្រូវការទីផ្សារពលកម្មជាតិ ។

គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ លើកលែងតែសាកលវិទ្យាល័យវេទឫសីចេញ ប្រមូលផ្តុំតែក្នុងរាជធានីភ្នំពេញ ។

*ឃ. ការប្រើប្រាស់ភាសា*

យើងនៅពុំទាន់មានគោលនយោបាយណាមួយ បានកំណត់ភាសាយានប្រើប្រាស់នៅឧត្តមសិក្សា ទោះបីជាភាគច្រើនបានយកភាសាខ្មែរជាយានរួចមកហើយក៏ដោយ ។ គ្រឹះស្ថានឧត្តមសិក្សានីមួយៗ បានជ្រើសរើសភាសាប្រើប្រាស់ទៅតាមស្ថានភាពជាក់ស្តែងរបស់ខ្លួនផ្ទាល់ ។

ការប្រើបច្ចេកស័ព្ទជាភាសាជាតិ នៅពុំទាន់ឯកភាពគ្នា ។ ឯកសារស្រាវជ្រាវជាភាសាជាតិនៅខ្សត់ខ្សោយ និងពុំទាន់មានគោលនយោបាយលើកទឹកចិត្ត ការបកប្រែសៀវភៅបរទេសមកជាភាសាជាតិ និងអ្នកនិពន្ធសៀវភៅសិក្សាភាសាជាតិនៅឡើយ ។

ការសិក្សាភាសាបរទេសនៅឧត្តមសិក្សា ពុំទាន់មានកម្មវិធីកំណត់ច្បាស់

លាស់ និងខ្វះប្រសិទ្ធភាព ហើយករណីខ្លះវៀនតាមស្ទូគ្រ ។

*ង. ធនធាន*

ថវិកាជាតិទ្រទ្រង់ឧត្តមសិក្សានៅខ្សត់ខ្សោយ ហើយការគ្រប់គ្រងហិរញ្ញ-វត្ថុរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ពុំទាន់មានស្វយភាព និងភាពទទួលខុសត្រូវនៅឡើយ ។

កំរិតប្រាក់បៀវត្សរបស់បុគ្គលិកសិក្សាឧត្តមសិក្សារដ្ឋទាបខ្លាំង ពុំអាចផ្តល់លទ្ធភាពឱ្យគេទ្រទ្រង់គ្រួសារបាន ម្នាក់ៗចាំបាច់ត្រូវប្រកបរបរបន្ថែមខុសជំនាញដែលជាហេតុពុំអាចឱ្យគេពង្រីកសមត្ថភាពបន្តបាន ។

និស្សិតពុំទាន់បានរួមចំណែកទទួលខុសត្រូវ ក្នុងចំណាយលើការសិក្សារបស់គេ ចំពោះកម្មវិធីឧត្តមសិក្សានៅឡើយ ។

ក្របខ័ណ្ឌគ្រូឧត្តមសិក្សា និងឋានានុក្រមរបស់គេ នៅពុំទាន់បានរៀបចំបង្កើត ដើម្បីជំរុញតាមវិធានការសេដ្ឋកិច្ច រដ្ឋបាល និងស្មារតីនៅឡើយដែរ ។

មូលដ្ឋានសម្ភារៈបរិក្ខារ អគាររូបវ័ន មួយចំនួនទ្រុឌទ្រោម ពុំទាន់បានជួសជុលយូរឆ្នាំមកហើយ ខ្វះថវិកាទ្រទ្រង់ និងពង្រីក ។

*ច. ការងារគ្រប់គ្រងស្ថាប័ន*

ការងារគ្រប់គ្រងរបស់ស្ថាប័នទៅលើមុខងារហិរញ្ញកិច្ច បុគ្គលិក ការសិក្សា ការស្រាវជ្រាវ និងមូលដ្ឋានសម្ភារៈបរិក្ខារ អគាររូបវ័ន នៅទន់ខ្សោយអំពីសមត្ថភាព និងនីតិវិធី ។

ការងារគ្រប់គ្រងកម្មវិធីសិក្សា បទដ្ឋានសិក្សា និស្សិត និងឯកសារផ្សេងៗ គ្មានប្រសិទ្ធភាព ។

បុគ្គលិកគ្រប់គ្រងរដ្ឋបាលមានគុណភាពនៅទាប ទាមទារការបំពាក់បំប៉នតាមគ្រប់រូបភាព និងជាប្រចាំ ។ របៀបរបបធ្វើការងារនៅអន់ថយ អនុវត្តគ្មានផែន

ការកម្ម និងខ្វះពតិមានទៅវិញទៅមក ហើយគ្រប់គ្រងដោយខ្វះមូលដ្ឋានទិន្នន័យ ។

ការប្រើប្រាស់ជំនួយអន្តរជាតិ ពុំទាន់មានប្រសិទ្ធភាពល្អ ក្នុងការសម្របសម្រួល និងការគ្រប់គ្រង ។

ស្មារតី និងវិន័យរៀនសូត្ររបស់និស្សិត ពិនិត្យជារួមធ្លាក់ចុះ មិនបានសមាធិរៀនសូត្រឱ្យបានល្អ ដោយបាតុភាពព្រួយបារម្ភលើការរកការងារធ្វើពុំបានពេលអនាគត បាតុភាពលួចចម្លងក្នុងពេលប្រលង និងអស្ថិរភាពនយោបាយ ជាដើម ។

ទាំងនេះ ពុំមែនបានន័យថា កន្លងមកសុទ្ធតែគុណវិបត្តិទាំងនោះទេ វាជាសមិទ្ធផលមួយធំធេង និងមោទនភាពណាស់ ដែលក្រោយឆ្នាំ ១៩៧៩ មក វិស័យឧត្តមសិក្សារបស់យើងត្រូវបានស្តារពីបាតដៃទទេឡើងវិញ ចាប់តាំងពីអគារបាក់បែក សម្ភារៈបរិក្ខារត្រូវបំផ្លាញខ្ទេច និងធនធានមនុស្សជំនាញសំរាប់ឧត្តមសិក្សាអាចចាត់ទុកថាគ្មានសល់មួយនាក់ណាទេ នៅក្នុងប្រទេស ។ ការខិតខំលើមូលដ្ឋានគ្មានអ្វីសោះ និងប្រកបដោយជីវភាពលំបាកខ្វះខាត ខ្វះមធ្យោបាយសព្វបែបយ៉ាងថ្វីដ្បិតតែយើងពុំទាន់ធានាបាននូវគុណភាព ប៉ុន្តែបរិមាណវិញ វិស័យឧត្តមសិក្សារបស់យើងកន្លងមក បានរួមចំណែកឱ្យម៉ាស៊ីនរដ្ឋរបស់យើងបានដើរទៅមុខជានិច្ច ទោះបីថិតនៅក្នុងល្បឿនណាមួយនោះក៏ដោយ ។

ក្រោយពេលប្រទេសជាតិរបស់យើងត្រូវបានបង្រួបបង្រួមគ្នាវិញ យើងត្រូវការស្តារ និងអភិវឌ្ឍវាក្នុងសន្ទុះមួយថ្មីប្រកបដោយក្តីសង្ឃឹម និងការជឿជាក់លើអនាគត យើងត្រូវការបន្ថយនូវគម្លាតនៃសេដ្ឋកិច្ច - សង្គមកិច្ចរបស់ជាតិយើង ជាមួយនឹងប្រទេសជិតខាង ក្នុងតំបន់ និងលើសកលលោក ដែលគេបានឃ្លាតចាកចោលយើងឆ្ងាយដាច់សង្វែងណាស់មកហើយ ក្នុងពេលដែលយើងជាប់រវល់ធ្វើសង្គ្រាមនឹងជាតិសាសន៍ឯង ។ ជាប្រទេសប្រកាន់របបសេដ្ឋកិច្ចទីផ្សារសេរី និង

នយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស បើយើងមិនបានគិតដល់ការប្រកួតប្រជែង និងប្រៀបធៀបរវាងប្រជាជាតិយើង និងប្រជាជាតិគេដទៃទៀត ពលករគេ ទំនិញគេ វប្បធម៌គេ នឹងដណ្តើមទីផ្សារជាតិយើងអស់ ហើយយើងនឹងក្លាយទៅជាអាណានិគម ឬទាសករសេដ្ឋកិច្ចរបស់គេ សេដ្ឋកិច្ចជាតិរលំរលាយ និងទីបំផុតប្រជាជាតិយើងនឹងត្រូវអន្តរាយដោយសន្តិវិធី ។

## ៤. ចំណងទាក់ទងរវាងវិស័យឧត្តមសិក្សា និងអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច ។

អភិវឌ្ឍនវិស័យឧត្តមសិក្សា ត្រូវចំណាយហិរញ្ញវត្ថុថ្លៃណាស់ ហើយទាមទារការចាត់ចែងប្រតិបត្តិការមានលក្ខណៈសុក្រឹត និងមានផែនការកម្មជាយុទ្ធសាស្ត្រត្រឹមត្រូវ ។ បើគិតក្នុងចំណោមប្រជាជនកម្ពុជា សហគមន៍ឧត្តមសិក្សាទាំងបុគ្គលិក និងនិស្សិតមានចំនួនប្រមាណ ២ ម៉ឺននាក់ ត្រូវជា ០,២ % នៃចំនួនប្រជាជនសរុបប៉ុណ្ណោះ ប៉ុន្តែដើម្បីដំណើរការវា សំរាប់ប្រទេសអភិវឌ្ឍ គេចំណាយថវិកាជាតិរហូតដល់ ២ - ៤ % ហើយមិនត្រឹមតែប៉ុណ្ណោះ សាកលវិទ្យាល័យរដ្ឋខ្លួនឯង ក៏បានទទួលចំណូលពីប្រភពផ្សេងៗទៀត ដូចជា និស្សិតត្រូវបង់ថ្លៃសិក្សា ការឧបត្ថម្ភពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ កិច្ចសហប្រតិបត្តិការ និងបំរើសេវាកម្មផ្សេងៗ ។ វាជាការលំបាកបំផុតរបស់រាជរដ្ឋាភិបាល ដែលស្ថានភាពសេដ្ឋកិច្ចរបស់យើងនៅក្រីក្រ និងប្រភពចំណូលរបស់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ គ្មាន ត្រូវថ្លឹងថ្លែងជាមួយវិស័យសេដ្ឋកិច្ច វិស័យដទៃទៀត និងក្នុងចំណោមវិស័យរងរបស់អប់រំផ្សេងទៀត ដូចជា បឋមសិក្សា មធ្យមសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីកំណត់រកអាទិភាព និងតុល្យភាព ។ ដូចនេះ អភិវឌ្ឍនវិស័យឧត្តមសិក្សា ត្រូវតែផ្សារភ្ជាប់នឹងកិរិតរីកលូតលាស់របស់សេដ្ឋកិច្ចជាតិ ព្រោះក្នុងគ្រប់ប្រទេសទាំង

អស់ ឧត្តមសិក្សាពឹងពាក់យ៉ាងខ្លាំងទៅលើការផ្តល់មូលនិធិរបស់រដ្ឋាភិបាល ។ ពេលខ្លះ គេវាស់គុណភាពឧត្តមសិក្សាដោយសង្កត់ពិសេសទៅលើការចំណាយ ឬថ្លៃដើមបណ្តុះបណ្តាលក្នុងនិស្សិតម្នាក់ក្នុងមួយឆ្នាំសិក្សា ក៏ប៉ុន្តែ យើងដឹងហើយថា បើកន្លែង និងវិធីសាស្ត្រខុសគ្នា តម្លៃក៏អាចខុសគ្នាដែរ ពិបាករកមូលដ្ឋានសច្ចភាពណាស់ ។

បច្ចុប្បន្ននេះ យើងរស់នៅក្នុងពិភពលោកមួយ ដែលក្នុងនោះ ការស្រាវជ្រាវវិទ្យាសាស្ត្រ និងអភិវឌ្ឍន៍បច្ចេកវិទ្យា ដើរតួនាទីយ៉ាងសំខាន់ខ្លាំងក្លាដល់អភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច ។ បណ្តាញផ្សាយពត៌មាន ប្រព័ន្ធគមនាគមន៍ និងបច្ចេកវិទ្យាពត៌មាន បានធ្វើឱ្យយើង ដែលទោះបីកំពុងជាប្រទេសនៅក្រជាងគេបង្អស់ក៏ដោយ ក៏ចាំបាច់យកចិត្តទុកដាក់ដល់វិសមភាពជាមួយប្រទេសជិតខាង និងប្រើប្រាស់ប្រភពធនធានដ៏តិចតួចរបស់យើង ទៅលើវាខ្លះដែរ ។

ឧត្តមសិក្សារួមចំណែកដល់អភិវឌ្ឍន៍ធនធានមនុស្សតាមច្រើនបែប ។ វិនិយោគក្នុងឧត្តមសិក្សាអាចចាត់ទុកជាគន្លឹះមួយ រួមចំណែកដល់ការលូតលាស់សេដ្ឋកិច្ចរបស់ប្រទេស ។ ស្ថាប័នឧត្តមសិក្សាមានទំនួលខុសត្រូវសំខាន់បំផុត សំរាប់ការបណ្តុះបណ្តាលបុគ្គលិកវិជ្ជាជីវៈជំនាញរបស់ប្រទេស ដូចជា អ្នកគ្រប់គ្រង អ្នកវិទ្យាសាស្ត្រ វិស្វករ និងអ្នកបច្ចេកទេស ដែលចូលរួមក្នុងអភិវឌ្ឍន៍ ការយកលំនាំតាម និងផ្សព្វផ្សាយនូវអ្វីដែលប្លែកៗ ហើយថ្មី មានអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ ។

ស្ថាប័នទាំងនេះ គប្បីត្រូវបង្កើតនូវចំណេះដឹងថ្មី ឆ្លងតាមការស្រាវជ្រាវ និងបណ្តុះបណ្តាលជាន់ខ្ពស់ ដែលជាលក្ខណសម្បត្តិមួយសំរាប់ការផ្ទេរ ការយកលំនាំតាម និងផ្សព្វផ្សាយវិទ្យាសាស្ត្រ - បច្ចេកវិទ្យាដល់សង្គម [13] ។

មិនត្រឹមតែប៉ុណ្ណោះ ឧត្តមសិក្សាដើរតួនាទីយ៉ាងសំខាន់ដល់សង្គម ក្នុង

ការរក្សា និងលើកស្ទួយអត្តសញ្ញាណជាតិរបស់ប្រទេស និងផ្តល់កិច្ចការជួបប្រជុំគ្នាពិភាក្សាជាពហុភាគី និងជាអន្តរជាតិ ។

ការរីកលូតលាស់ឆាប់រហ័សនៃសេដ្ឋកិច្ច ការប្រើប្រាស់បច្ចេកវិទ្យាពត៌មាន ការកើនឡើងឆាប់រហ័យជាទូទៅនៃចំណេះដឹង សុទ្ធតែជាការនាំទៅរកការបង្កើននៃតម្រូវការសំរាប់អប់រំឧត្តមសិក្សា ។ សាកលវិទ្យាល័យចាំបាច់ត្រូវបានទទួលការគ្រប់គ្រងមួយដោយអតិបរមាកម្ម ដើម្បីប្រើជាឧបករណ៍មួយសក្តិសិទ្ធិសំរាប់អភិវឌ្ឍន៍ជាតិ ឆ្លងតាមការធ្វើឱ្យមានប្រសិទ្ធភាពឡើង អំពីទិដ្ឋភាពប្លែកៗ នៃមុខងាររបស់សាកលវិទ្យាល័យ ។ ដូចនេះ ការរៀបចំឡើងវិញចំពោះឧត្តមសិក្សា គឺសំរាប់ឈានទៅដល់បំលាស់ប្តូរការរីកលូតលាស់ និងអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច របស់ប្រទេស [14] ។

រាល់ការកែទំរង់ ឬទំនើបកម្មឧត្តមសិក្សា មានគោលដៅសំខាន់ដំបូងបង្អស់ គឺធានានូវគុណភាព ពង្រីកនូវគុណភាព និងបន្ទាប់មកបរិមាណ ។ នៅឧត្តមសិក្សា ការពង្រីកបរិមាណមិនអាចកាត់ផ្តាច់ចេញអំពីការធានាខុសត្រូវចំពោះគុណភាពបានទេ ។ ក្នុងរចនាសម្ព័ន្ធសង្គម សមាសភាគសហគមន៍ឧត្តមសិក្សា ថ្វីដ្បិតតែមានអត្រាតិចតួចប្រៀបធៀបទៅនឹងសង្គមទាំងមូល ប៉ុន្តែវាមានតួនាទីជាគន្លឹះមួយរួមចំណែកក្នុងការដឹកនាំ និងអនុវត្តឱ្យមានបំលាស់ប្តូរ និងអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច ថែរក្សា និងលើកស្ទួយវប្បធម៌ ប្រពៃណីជាតិឱ្យគង់វង្ស និងរីកលូតលាស់ ។

អ្នកនយោបាយជាន់ខ្ពស់របស់អូស្ត្រាលីម្នាក់ ( Kemp 1992 ) ពោលថា :

« ការអប់រំរបស់យើង ត្រូវតែគិតដល់ការប្រកួតប្រជែង ... បើយើងមិនបានគិតអំពីគុណភាពទេនុ៎ះ រាល់កំលាំង និងចំណាយរបស់យើងទាំង

អស់ នឹងគ្មានន័យ ព្រោះយើង មិនគ្រាន់តែធ្វើឱ្យវិនាសអន្តរាយដល់ជីវិតនិស្សិតយើងប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យខូចខាតដល់សមត្ថភាពរបស់យើង ដើម្បីដណ្ដើមរស់នៅក្នុងពិភពលោកមួយ ដែលមិនមែនចាំតែផ្ដល់ជីវភាពដល់យើងទេ ។ យើងមិនអាចមានកំរិតជីវភាពថ្នាក់ពិភពលោក និងសេដ្ឋកិច្ចថ្នាក់ពិភពលោកមួយបាន ដោយគ្មានកំលាំងពលកម្ម ថ្នាក់ពិភពលោក ដោយគ្មានការអប់រំថ្នាក់ពិភពលោកបានដែរ » ។

ទាំងនេះជាចំណងទាក់ទងបដិសំយោគរវាងវិស័យឧត្តមសិក្សារបស់ប្រទេស ជាមួយកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ជាតិ ។ ស្ថិតនៅក្នុងស្ថានភាពមួយដ៏លំបាក ខ្វះខាតសព្វសារពើ យើងត្រូវតែខិតខំកំណត់ឱ្យបាននូវគោលនយោបាយយុទ្ធសាស្ត្រមួយត្រឹមត្រូវ ដែលអាចនាំយើងតាមល្បឿនអភិវឌ្ឍន៍មួយអតិបរមា ប្រកបដោយការជឿជាក់ និងក្ដីសង្ឃឹមសំរាប់អនាគត ។

## ៥. សន្និដ្ឋាន

ក. បញ្ហាអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ចរបស់ប្រទេសជាតិ ជាគោលនយោបាយមួយចំបង និងសំខាន់ ។ ប៉ុន្តែវិស័យឧត្តមសិក្សារបស់ប្រទេស គឺជាគន្លឹះកំណត់មួយក្នុងការធ្វើឱ្យសំរេចដល់គោលដៅអភិវឌ្ឍន៍ខាងលើ ។

ខ. ឧត្តមសិក្សា គឺជានិមិត្តរូបនៃកំលាំងបញ្ញាជាតិ និងមុខមាត់របស់ប្រទេសលើឆាកអន្តរជាតិ ជាមជ្ឈមណ្ឌលវប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេសជាន់ខ្ពស់របស់ជាតិ និងមានតួនាទីឈានមុខគេលើវិស័យទាំងនេះក្នុងសង្គម ។ ស្ថានភាព និងទិដ្ឋភាពឧត្តមសិក្សា ត្រូវតែនាំមុខ និងដឹកនាំសង្គម មិនមែនរត់តាមសង្គម ឬដើរក្រោយសង្គមនោះទេ ។ វាជារោងចក្រផលិតអ្នកបញ្ញវន្តជាតិ ដែលអាចឆ្លើយតបជានិច្ច និងទាន់ពេលវេលាបាន នូវតម្រូវការផ្លាស់ប្ដូរសង្គម [15] ។

គ. ក្នុងលក្ខណសម្បត្តិ ដែលសេដ្ឋកិច្ចជាតិមានកង្វះខាត និង ជួបការលំបាក នៅមានវិធីជាច្រើនដែលនៅតែអាចកែទំរង់ និង អភិវឌ្ឍវិស័យឧត្តសិក្សារបស់ប្រទេសបាន មិនឱ្យយើងអស់សង្ឃឹម ដូចជា [13] :

• លើកទឹកចិត្តអភិវឌ្ឍន៍គ្រឹះស្ថានឧត្តមសិក្សាឯកជន និងអភិវឌ្ឍន៍កម្ម-វិធីបណ្តុះបណ្តាលប្លែកៗច្រើនបែប ដូចជា ស្ថាប័នពាក់កណ្តាលសាកលវិទ្យាល័យ កម្មវិធីបណ្តុះបណ្តាលក្រៅប្រព័ន្ធអប់រំពីចម្ងាយ និងការសិក្សាបើកទូលាយ ... ។

• ផ្តល់លទ្ធភាពទាក់ទាញចិត្តចំពោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ឱ្យពង្រីកប្រភពចំណូលថវិកាផ្ទាល់ខ្លួន ដូចជា និស្សិតរួមចំណែកបង់ថ្លៃសិក្សាខ្លះ សេវាកម្មឯកជន សហប្រតិបត្តិការ ហើយរដ្ឋផ្តល់ថវិកា តាមលទ្ធផលដែលស្ថាប័នសំរេចបាន ។

• កំណត់ឡើងវិញ អំពីនាទីរដ្ឋាភិបាលក្នុងឧត្តមសិក្សា :

រៀបចំគោលនយោបាយជាតិឧត្តមសិក្សាឱ្យមានភាពស៊ីសង្វាក់គ្នា បង្កើនស្វយភាពដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ រដ្ឋផ្តល់គ្រឿងលើកទឹកចិត្តដល់ការអនុវត្តគោលនយោបាយ ដូចជារអាហារូបករណ៍និស្សិត និងឱ្យនិស្សិតខ្ចីប្រាក់ចំណាយលើការសិក្សា ជាដើម ។

• បញ្ចូលគោលនយោបាយ ដោយផ្តល់អាទិភាពក្នុងការលើកស្ទួយគុណ-ភាព និងសមធម៌ :

បង្កើនគុណភាពបណ្តុះបណ្តាល និងស្រាវជ្រាវ ឆ្លើយតបទៅនឹងតម្រូវការផ្លាស់ប្តូរសេដ្ឋកិច្ច និងគិតគូរដល់សមធម៌ មានបញ្ហាភេទ ភាពក្រីក្រ តំបន់ដាច់ស្រយាល និងជនជាតិភាគតិច ជាដើម ។

ចំពោះការកែទំរង់ សំដៅពង្រឹងឧត្តមសិក្សាកម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច ផែនការសកម្មភាពជាតិ ដែលរៀបចំដោយ

ក្រុមដឹកនាំការងារជាតិឧត្តមសិក្សា និងមានផ្សព្វផ្សាយជាសាធារណៈ នៅខែមិថុនា ១៩៩៧ ខាងមុខ ក្រោយពេលគណៈរដ្ឋមន្ត្រីបានអនុម័ត ។

ឃ. ដោយ

- មូលហេតុខឿនសេដ្ឋកិច្ចជាតិយើងនៅទន់ខ្សោយ និង
- ចង់ពង្រីកនូវបរិមាណអប់រំឱ្យបានទូលាយទូទាំងប្រទេសផង ដើម្បី ៖

- ធានាបាននូវគុណភាពកំលាំងពលកម្ម ឬគុណភាពអប់រំ និង

- អាចមានទីតាំងឈរបាន ឬមានជីវភាពមួយដ៏សមរម្យនឹងគេក្នុងតំបន់ និងពិភពលោកនេះ ។

នៅវិស័យអប់រំ រដ្ឋាភិបាលគួរជំរុញបង្កើតសាលាគំរូ ឬសាលាឈានមុខ តាមចំនួនណានោះ ដើម្បីអនុវត្តរបៀបជ្រើសរើសតែសិស្ស និស្សិតណា ដែលលេចធ្លោឱ្យចូលរៀន មានកម្មវិធី និងសេវាកម្មពិសេស សំរាប់ត្រៀមជាអ្នកវិទ្យាសាស្ត្រ និងខួរក្បាលមួយដ៏ល្អរបស់ជាតិ ដែលអាចជាកំលាំងស្នូលជះឥទ្ធិពលពង្រឹងគុណភាពដល់គ្រប់ផ្នែកនៃវិស័យអប់រំ និងប្រលងប្រណាំងជាមួយប្រទេសដទៃលើសកលលោកបាន ។ ក្នុងស្ថានភាពសព្វថ្ងៃ គួរកំណត់យកស្ថាប័នឧត្តមសិក្សា ដែលអាចដើរតួជាស្នូលប្រមូលផ្តុំកំលាំងបញ្ញវន្តទូទាំងប្រទេស និងបង្កលក្ខណៈឱ្យគេអភិវឌ្ឍរួមទៅតាមមុខជំនាញនីមួយៗ ។ ចៀសវាងការរាយប៉ាយមនុស្សសំខាន់ៗ ឱ្យបំពេញសកម្មភាពជាបុគ្គលដោយឡែកៗ ដូចសព្វថ្ងៃនេះ ។

ង. គ្រឹះស្ថានឧត្តមសិក្សារដ្ឋ គប្បីជ្រើសរើសតំបន់ ឬទីកន្លែងអភិវឌ្ឍន៍គំរូរបស់ខ្លួន ( ទីក្រុង ឬជនបទ ) ហើយផ្នែកជំនាញនីមួយៗរបស់សាកលវិទ្យាល័យត្រូវធ្វើការសិក្សាស្រាវជ្រាវ លើកជាគំរូអភិវឌ្ឍន៍ និងប្រតិបត្តិការរៀងខ្លួន នៅកន្លែងនោះ ។ នេះគឺជាគំនិតផ្តួចផ្តើមមួយ ដើម្បីឱ្យគ្រឹះស្ថានឧត្តមសិក្សារដ្ឋរបស់យើងទទួលខុសត្រូវ រួមចំណែកក្នុងការអភិវឌ្ឍទាំងសេដ្ឋកិច្ច និងសង្គមកិច្ច ផ្សារ

ភ្ជាប់ការសិក្សាស្រាវជ្រាវទៅនឹងការជាក់ស្តែងនៃតម្រូវការរបស់សង្គម ។ រាជរដ្ឋាភិ-បាល និងអង្គការអន្តរជាតិ ជាអ្នកជួយបង្កលក្ខណៈ និងសម្រួលលក្ខខណ្ឌក្នុងដំណើរការនេះ ។ ធ្វើយ៉ាងនេះ ដើម្បីបន្ថយនូវសកម្មភាពគម្ពីរនិយមរបស់ឧត្តមសិក្សាយើង និងចៀសវាងគំនិតអភិវឌ្ឍខ្វះនិរន្តរភាពវិទ្យាសាស្ត្រ ។

*ខែធ្នូ ឆ្នាំ ១៩៩៦*

## ឯកសារពិគ្រោះ


[1] Tong-In Wongsothorn and Wang Yibing 1995. Private Higher Education in Asia and the Pacific.UNESCO- PROAP and SEAMEO-RIHED, Bangkok ។

[2] ជា ចាន់តូ ១៩៩៥ បញ្ហាមួយចំនួនដើម្បីកំណត់ទិសដៅអភិវឌ្ឍន៍កម្ពុជាក្នុងរយៈពេល ១០ ឆ្នាំ ខាងមុខ ១៩៩១ - ២០០០ ។

[3] UNTAC. 1993. Seminar of Cambodia's forest reserves.

[4] World Bank. 1996. Cambodia, From Recovery to sustained Development.

[5] National Institute of Statistics, Ministry of Planning 1996 Demographic Survey of Cambodia 1996 - General Report.

[6] Ministry of Economy and Finance, 1996. Economic and Financial Review N 2, 2nd Quarter.

[7] David O. Dapice, Jonathan Haughton and Dwight H.

Perkins, 1994. In Search of the Dragon's Trail : Economic Reform in Vietnam. HIID, Massachusetts.

[8] ព្រះរាជាណាចក្រកម្ពុជា, ១៩៩៦ ខ្លឹមសារសង្ខេប ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ ឆ្នាំលើកទី ១ ( ១៩៩៦ - ២០០០ ) ។

[9] ស្ថិតិនាយកដ្ឋានឧត្តមសិក្សា និងសិក្សាឯកទេស ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ១៩៩៥ - ៩៦ ។

[10] Grant Harman, 1996. Quality Assurance for Higher Education UNESCO-PROAP, Bangkok ។

[11] NHETF, 1996. Final Report of the National Working Group.

[12] Khon Kaen University and SEAMEO-RIHED,1995. The Role of Universities in the Development of the Mekong River Basin. Khon Kaen, Thailand.

[13] World Bank, 1994. Higher Education -The lessons of Experience. Washington, D.C.

[14] SEAMEO & UNESCO-PROAP, 1996. Reengineering of Higher Education for the 21st Century, Malaysia.

[15] នេត បារ៉ុម ១៩៩៥ និង ៩៦, គួរយល់ដឹងពីសាកលវិទ្យាល័យ, ទស្សនាវដ្ដី អក្សរសាស្ត្រ - មនុស្សសាស្ត្រ ស.ភ.ព. ។

***

# សុខភាព ជាលាភដ៏ពិសិដ្ឋ

**ជីវិត** គឺការរស់នៅ ។ ដើម្បីរស់នៅបាន ត្រូវមានវត្ថុធាតុ និងសម្ភារៈសំរាប់ទ្រទ្រង់ ។ ជីវិតមនុស្ស ត្រូវការបរិក្ខារផ្គត់ផ្គង់ច្រើនជំពូក ស្ទើររាប់មិនអស់ ប៉ុន្តែជាមូលដ្ឋាន មនុស្សត្រូវការអាហារ ជម្រក សំលៀកបំពាក់ ថ្នាំសង្កូវ ។ ដើម្បីបានវត្ថុទាំងនេះយកមកបំពេញសេចក្តីត្រូវការនៃជីវិត មនុស្សត្រូវតែធ្វើការងារដោយយកកម្លាំងកាយ និងកំលាំងបញ្ញាទៅប្រយុទ្ធនឹងធម្មជាតិ ។ កំលាំងកាយក្តី កំលាំងបញ្ញាក្តី រមែងដុះដាលបាន ដោយសារតែបុគ្គលមានសុខភាពបរិបូណ៌ ។ តើមនុស្សត្រូវមានកាតព្វកិច្ចយ៉ាងណាខ្លះ ដើម្បីអោយមានសុខភាព ?

តាមវិទ្យាសាស្ត្រ, គេបានវិភាគឃើញច្បាស់ថា « ដើម្បីអោយរាងកាយខ្លួនមានសុខភាព មនុស្សត្រូវមានចំណីអាហារប្រកបដោយអនាម័យ, លំនៅស្ថានមានអនាម័យ និងលំហាត់ប្រាណ - កីឡា » ។

១- *ចំណីអាហារ* : មនុស្សរស់នៅបានដោយសារអាហារ ។ អាហារដែលត្រូវបរិភោគនោះ មិនគ្រាន់តែជួយទ្រទ្រង់ជីវិតអោយគង់វង្សប៉ុណ្ណោះទេ វាថែមទាំងជួយផ្តល់សុខភាព ផ្តល់កំលាំងពលំ និងធ្វើអោយប្រាជ្ញាប៉ាធិដុះដាលទៀតផង ប្រសិនបើវាមានអនាម័យ, មានគុណភាព និងមានជីវជាតិ ។ ចំណីអាហារមានច្រើនប្រការ ដូច : បាយ ទឹក ត្រី សាច់ បន្លែ ផ្លែឈើ - ល - ហើយវាមានមុខងារទ្រទ្រង់រាងកាយ តាមមុខសញ្ញារបស់វា ។ អាហារសំរាប់ទ្រទ្រង់ជីវិត មាន ៣ ប្រភេទ គឺ :

- អាហារសាងសង់រាងកាយ ( Aliment de construction ) មាន : ត្រី, សាច់, ស៊ុត, ...

• អាហារសំរាប់ការពាររាងកាយ ( Aliment de protection ) មាន : បន្លែ, ផ្លែឈើ, ...

• អាហារសំរាប់ផ្តល់ថាមពលរាងកាយ ( Aliment énergétigue ) មាន : បាយ, ស្ករ, ...

អាហារដែលត្រូវបរិភោគ ត្រូវយោលទៅតាមសុខភាព វ័យ អាកាសធាតុ និងពេលវេលា ។ នៅប្រទេសណា ដែលមានអាកាសធាតុត្រជាក់ខ្លាំង គេច្រើនតែបរិភោគសាច់សត្វអោយបានច្រើន ព្រោះសាច់មានគុណភាពជីវជាតិច្រើន និងធ្វើអោយរាងកាយមានតុល្យភាព ។ ចំណីអាហារដែលមានរោគ ឬជូរ ផ្អូម ជាហេតុធ្វើអោយខូចសុខភាព ។

ទឹកជាវត្ថុធាតុដ៏សំខាន់មួយ សំរាប់ទ្រទ្រង់រាងកាយ ។ ដូច្នេះ ទឹកដែលបរិភោគ ប្រើប្រាស់ ត្រូវតែពិនិត្យពិច័យអោយបានសមស្រប តាមលក្ខណៈអនាម័យ ។ ទឹកត្លុក ត្រពាំង ស្រះ ស្ទឹង ទន្លេ បឹងបួរ ទឹកនេះមានគ្រឿងសៅហ្មងច្រើនណាស់ ហើយតែងមានមេរោគកំណាចជាច្រើនពួកអាស្រ័យនៅ ។ ប៉ុន្តែ យើងពុំអាចមើលវាឃើញដោយភ្នែកទទេបានឡើយ លុះណាតែឆ្លុះបញ្ចាំងមើលតាមអតិសុខុមទស្សន៍ ទើបឃើញច្បាស់ ។ ដើម្បីបង្ការមេរោគទាំងនោះ គេត្រូវទទួលទានទឹកឆ្អិន ឬទឹកបរិសុទ្ធ ។

ប្រជាជននៃប្រទេសកំពុងលូតលាស់ (Pays en développement) ដែលមិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍នៃអនាម័យ ច្រើនតែជួបប្រទះនឹងជំងឺតម្កាត់ផ្សេងៗ ។ រីឯប្រជាជនយើងខ្លះៗ ក៏មិនទាន់បានយល់ច្បាស់ និងអនុវត្តតាមវិធីអនាម័យក្នុងការទទួលទានទឹក និងចំណីអាហារដែរ ។ គេច្រើនបរិភោគអាហារទៅតាមចំណូលចិត្ត ឆ្ងាញ់អីហូបនោះ ឬហូបអោយតែឆ្អែតធ្ងន់ពោះ - តឹងពោះ កុំអោយឃ្លានប៉ុណ្ណោះ ។ គេមិនយល់ថាចំណីអាហារបែបណា ទើបផ្តល់ជីវជាតិច្រើន និង

ធ្វើឱ្យរាងកាយមានសុខភាពឡើយ ។ អ្នកខ្លះហូបអាហារដែលមានតែបរិមាណ ហើយមានគុណភាពជីវជាតិតិចតួចបំផុត ឬអាហារដែលមានទំនាស់ដល់សុខភាព ទៀតផង ។ ការហូបអាហារខ្វះជីវជាតិ ឬអាហារមិនគ្រប់គ្រាន់ តាមសេចក្ដីត្រូវការ នៃរាងកាយ អាចធ្វើអោយខូចសុខភាព ច្រើនជួបប្រទះនឹងជំងឺតម្កាត់ផ្សេងៗ ដូចជា ស្លឹក រោយ ស្រពន់ ស្លេកស្លាំង បាក់កំលាំងជាដើម ព្រោះកាលណាយើងខ្សោយ មេរោគងាយស្រួលចូលជ្រៀតជ្រែក បណ្ដាលអោយយើងឈឺថ្កាត់ឆាប់រហ័ស និង ធ្ងន់ធ្ងរទៀតផង ។

ឯការទទួលមានទឹក ក៏យើងមិនទាន់បានអនុវត្តអោយបានត្រឹមត្រូវតាម វិធីអនាម័យគ្រប់ៗគ្នាដែរ ។ អ្នកខ្លះ ពេលស្ទូងដកនៅតាមស្រែ ច្រើនតែផឹកទឹកដែល ដក់ក្នុងត្លុកត្រពាំង ស្នាមជើងគោ ក្របី ដោយឥតគិតបារម្ភថា ទឹកនោះកករ ល្អក់ មានស្លែ មានជាតិជីតីមី ឬមានមេរោគចង្រៃអ្វីខ្លះ អាចបណ្ដាលអោយឈឺថ្កាត់ ចុក រាគមួលអ្វីឡើយ ។ ទឹកមិនស្អាត ឬទឹកមានមេរោគ ដែលគេផឹកចូលទៅក្នុងពោះ នោះ គឺពិតជាបណ្ដាលអោយមានគ្រោះថ្នាក់ បើមិនធ្ងន់ ក៏ស្រាលដែរ ។ ដូច្នេះ ប្រជាជនយើងត្រូវតែយល់ដឹង និងភ្ញាក់រលឹកជានិច្ចថា : " ទឹកឆ្អិន ទឹកបរិសុទ្ធ នាំ អោយមានសុខភាព " ។

២. *លំនៅស្ថាន* : ដើម្បីបាននូវសុខភាព មនុស្សមិនមែនមានត្រឹមតែ អនាម័យចំណីអាហារប៉ុណ្ណោះទេ គឺត្រូវមានទីជម្រកប្រកបដោយអនាម័យទៀត ផង ។ ពីដើម ពេលដែលមនុស្សមិនទាន់យល់ពីអនាម័យនៅឡើយ គេបានជ្រក អាស្រ័យនៅតាមព្រៃភ្នំក្រំថ្ម ក្រោមម្លប់ឈើផ្ទាល់នឹងដី ។ ក្រោយមក គេចេះធ្វើខ្ទម ផុតពីដី ដើម្បីការពារសត្វសាហាវបៀតបៀន ។ ចំណោរកាលតមកទៀត គេចេះធ្វើ ផ្ទះសម្បែងសមរម្យ រហូតដល់សំណង់ធំៗ សំខាន់ៗ ទៀតផង ។ ប្រជាជនយើង ក៏

មានទេពកោសល្យក្នុងការសាងសង់លំនៅស្ថាននេះដែរ ។ ផ្ទះយើងច្រើនសង់លើចន្ទល់ខ្ពស់ពីដី ធ្វើពីឈើ ប្រក់ស្បូវ ស្លឹក ក្បឿង ឬស័ង្កសី ហើយផ្ទះខ្លះទៀត សង់ពីថ្ម - ឥដ្ឋលាយកំបោរ - ស៊ីម៉ង់ ។

ផ្ទះប្រជាជនយើងដែលមានចរិតជាតិ ជាលំនៅស្ថានមានអនាម័យ ប៉ុន្តែយើងមិនទាន់បានយកចិត្តទុកដាក់ទៅលើការសំអាតនៅឡើយ ។ ផ្ទះខ្លះមានធូលីអម្រែងភ្លើង ស្មោកគ្រោក ។ ផ្ទះខ្លះទៀត គេចងគោ ក្របី, គេពាំងទ្រុងមាន់-ទាខាងក្រោមផ្ទះ ហើយមិនបានបោសច្រាសទៀងទាត់ បណ្តាលអោយមានភក់ជ្រាំធុំក្លិនស្អុយ ។ ជុំវិញផ្ទះ មិនទាន់បានរៀបចំ និងសំអាតអោយត្រឹមត្រូវ ច្រើនមានសំរាម និងត្លុកក្រហេងក្រហូង ដក់ទឹក មានស្មៅដុះទ្រុបទ្រុល ជាទីជម្រកនៃសត្វល្អិត ។ លំនៅស្ថាន ត្រូវមានបង្គន់អនាម័យ ហើយមិនត្រូវបន្ទោរបង់លាមកចោលផ្តេសផ្តាស តាមគុម្ពោតព្រៃ ឬទីកៀនកោះ ជាហេតុបណ្តាលអោយកើតរោគ ។ ក្នុងបរិវេណផ្ទះ ត្រូវដាំដើមឈើហូបផ្លែ និងផ្កាក្លិនក្រអូប ។ ដើមឈើមានអត្ថ-ប្រយោជន៍ច្រើនប្រការ ៖ បឺតស្រូបយកក្លិនអាក្រក់ ធ្វើអោយធាតុអាកាសមានតុល្យភាព មិនក្តៅពេក ត្រជាក់ពេក ។ សំរាម ឬស្លឹកឈើ ត្រូវប្រមូលកប់ ឬដុតធ្វើជាជី ។ លាមកសត្វត្រូវប្រមូលដាក់ក្នុងរោងមួយឃ្លាតពីផ្ទះ ដើម្បីជាប្រយោជន៍ដល់ការបង្កបង្កើនផលផង និងដើម្បីធ្វើអោយមានអនាម័យដល់លំនៅស្ថានយើងផង ។ ចាស់ទុំរបស់យើង តែងណែនាំយើងអោយចេះសំអាតផ្ទះសម្បែង ព្រោះទីកន្លែងស្អាត ទើបមានសិរីសួស្តី ទើបទេព្តារក្សា ។ កវីប្រជាប្រិយ៍របស់យើង តែងអប់រំថា *" ដំណេកដេកជាខ្នាត អោយសំអាតសំអាងជា ទើបទេព្តារក្សា ចំរើនសុខស្រីសួស្តី "* ។ ...

ទន្ទឹមនឹងអនាម័យលំនៅស្ថាន យើងក៏ត្រូវយកចិត្តទុកដាក់ទៅលើអនា-

ម័យសម្លៀកបំពាក់ដែរ ។ ការស្លៀកពាក់ ត្រូវមានលក្ខណៈសមស្របនឹងអនាម័យ ទើបរាងកាយយើងមានសុខភាព ។ ការប្រើប្រាស់សម្លៀកបំពាក់ ត្រូវយោលទៅតាមទីកន្លែង ពេលវេលា និងធាតុអាកាស ។ ទីណាមានធាតុអាកាសក្តៅ ស្អុះស្អាប់ គេប្រើសម្លៀកបំពាក់មានសាច់ស្តើង ឬខោអាវខ្លី ។ កន្លែងណាមានធាតុអាកាសត្រជាក់ខ្លាំង គេប្រើប្រាស់សម្លៀកបំពាក់មានសាច់ម៉ដ្ឋក្រាស់ ឬខោអាវវែង ។ ពេលយប់ គេប្រើមុង-ភួយ សម្រាប់ការពារសត្វល្អិត ចុច ខាំ ឬដណ្តប់កុំអោយរងាខ្លាំងពេក ។ ប្រដាប់ប្រដាទាំងនេះ ត្រូវសំអាតជានិច្ច កុំអោយសៅហ្មង ប្រឡាក់ប្រឡូសទៅដោយមន្ទិល ក្អែលក្អក ជាហេតុធ្វើអោយកើតកមរមាស់ ប៉ះពាល់ដល់សុខភាព ។ សម្លៀកបំពាក់ ប្រដាប់ប្រដាអ្នកកើតជំងឺឆ្លង មិនគប្បីយកមកស្លៀកពាក់ ប្រើប្រាស់ ដោយមិនបានបោកគក់ ស្រុះស្រោរ អោយស្អាតជាមុនឡើយ ព្រោះវាអាចបណ្តាលអោយយើងកើតជំងឺ ។

៣. *លំហាត់ប្រាណ និងកីឡា* ៖

តើលំហាត់ប្រាណ និងកីឡាមានអត្ថប្រយោជន៍អ្វីខ្លះ ដល់អ្នកប្រព្រឹត្ត ?

លំហាត់ប្រាណ អាចធ្វើអោយរាងកាយមានសុខភាព ។ លំហាត់ប្រាណមានច្រើនប្រភេទ ៖ លើកដៃ លើកជើង ពត់ខ្លួនទៅឆ្វេង ពត់ខ្លួនទៅស្តាំ ពត់ខ្លួនទៅក្រោយ តន្ត្រំជើងមួយកន្លែង ដើរ រត់ . ល . ។ កាយវិការទាំងនេះ សុទ្ធតែធ្វើអោយរាងកាយមានចលនាចេញញើស និងធ្វើអោយឈាម ខ្យល់ កំដៅ រត់ផ្សព្វផ្សាយស្មើល្អ ។ ការប្រព្រឹត្តលំហាត់ប្រាណទៀងទាត់ ត្រឹមត្រូវតាមក្បួនខ្នាត ជាហេតុធ្វើអោយរាងកាយរហ័សរហួន មានកំលាំងពលំ មិនស្ពឹកស្រពន់ និងមានសុខភាពបរិបូណ៌ ។

រីឯកីឡា ក៏ជាផ្នែកមួយដ៏សំខាន់ ក្នុងការធ្វើអោយមានសុខភាពដែរ ។

កីឡាមានច្រើនប្រភេទ ៖ កីឡាបាល់ទះ បាល់ទាត់ បាល់បោះ ប៉េងប៉ុង លោតកំពស់ លោតចម្ងាយ ឡើងពួរ ចោលថាស ‑ ល ‑ ។ កីឡាទាំងនេះ សុទ្ធតែមានអត្ថប្រ‑យោជន៍ធ្វើអោយអ្នកប្រព្រឹត្តមានរាងកាយស្វាហាប់ មាំមួន រឹងប៉ឹង រហ័សរហួន ។ កម្មករ បញ្ញវ័ន្ត អ្នកបច្ចេកទេស‑វិទ្យាសាស្ត្រ ដែលបញ្ចេញពលកម្មដោយបញ្ញាច្រើន ក្នុងការត្រិះរិះពិចារណា ពិនិត្យស្រាវជ្រាវ បើកាលណាបានប្រព្រឹត្តកីឡាទៀងទាត់ នោះនឹងធ្វើអោយរាងកាយចេញញើសឧស្ម័នកខ្វក់មកក្រៅ បំបាត់ការតឹងតែង ចង្អៀតចង្អល់ និងធ្វើអោយខួរក្បាលធូរស្រាល ភ្លឺថ្លា វាងវៃ មិនស្មុគស្មាញ ។ ពីបូរាណ ប្រជាជនយើងក៏មានរបៀបរបបលេងកីឡាដែរ ។ បណ្តាកីឡាទាំងនោះ មានកីឡាខ្លះមានលក្ខណៈជាល្បែងប្រជាប្រិយ៍ ដូចជា ៖ កូនគោល សី ឈូង លាក់កន្សែង លោតអន្ទាក់ដៃជាដើម ។ ឥឡូវ ល្បែងប្រជាប្រិយ៍ទាំងនេះ គេមាននៅលេងតិចតួចណាស់ ហើយមានលេងកំសាន្តតែក្នុងរយះពេលចូលឆ្នាំថ្មីម្តងៗប៉ុណ្ណោះ ។

ល្បែងប្រជាប្រិយ៍របស់ខ្មែរយើង មានគោលការណ៍អប់រំល្អណាស់ វាធ្វើអោយអ្នកលេងមានភាពទន់ភ្លន់ រហ័សរហួន ។ ដូច្នេះ គួរតែប្រជាជនយើង ពិសេស យុវជនយើងសម័យនេះ នាំគ្នាស្រាវជ្រាវ ហើយណែនាំ ពន្យល់អ្នកស្រុកអោយស្គាល់គោលការណ៍អប់រំរបស់ល្បែងប្រជាប្រិយ៍ទាំងនេះ ដើម្បីញ៉ាំងអ្នកស្រុកអោយចូលចិត្តនិយមកំសាន្តល្បែងបុរាណយើងឡើងវិញ ។

*៤‑ ការព្យាបាល និងថ្នាំសង្កូវ ៖*

វិធានការការពារសុខភាព ជាកាតព្វកិច្ចចាំបាច់បំផុតរបស់មនុស្សម្នាក់ៗ និងរបស់សង្គមជាតិទូទៅ ព្រោះការពារមុនប្រសើរជាងព្យាបាល ។ ប៉ុន្តែ ក្នុងករណីណាដែលជំងឺកើតមានជាយថាហេតុ ឬជៀសមិនរួចនោះ យើងក៏ត្រូវមានវិធីព្យា‑

បាល ដើម្បីជួសជុលអោយរាងកាយមានប្រក្រតីភាពឡើងវិញដែរ ។ ដូច្នេះហើយបានជាមានថបនភ័ណ្ឌសុខាភិបាល ( ឱសថ ឧបករណ៍បច្ចេកទេសពេទ្យ បរិក្ខារពេទ្យ ) ។ បច្ចុប្បន្ន វិទ្យាសាស្ត្រមានការរីកចំរើនយ៉ាងខ្លាំងក្លា ការព្យាបាលតាមវិធីវេជ្ជសាស្ត្រទំនើប មានប្រសិទ្ធភាពសក្តិសិទ្ធិបំផុត ជាហេតុរុញច្រាននូវអបិ្បយជំនឿឬគ្រូហ្មហួសសម័យ ។ ប៉ុន្តែ នៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ដែលបណ្តាញសុខាភិបាល មិនទាន់បានប្រទាក់ក្រឡាគ្រប់ច្រកល្ហកដល់ចុងកាត់មាត់ញកនោះ ប្រជាជននៃប្រទេសនោះ នៅពឹងផ្អែកលើអបិ្បយជំនឿ ។ កង្វះថបនភ័ណ្ឌសុខាភិបាល មានផលវិបាកច្រើនប្រការ ៖ ប្រជាជនមិនស្គាល់លក្ខណៈរោគ មិនមានសញ្ញាណវេជ្ជសាស្ត្រ មិនយល់ពីអត្ថប្រយោជន៍នៃវេជ្ជសាស្ត្រ ហើយបែរទៅនិយមអបិ្បយជំនឿ ។

រាងកាយមនុស្សម្នាក់ ប្រៀបដូចជានគរមួយ ។ នគរណាគ្មានខ្មាំងសត្រូវក្នុង-ក្រៅបៀតបៀន នគរនោះឈ្មោះថាមានសន្តិសុខ ។ យ៉ាងណាមិញ, រាងកាយណាដែលគ្មានរោគយាយី រាងកាយនោះឈ្មោះថាមានសុខភាព ។ ដូច្នេះ ដើម្បីកំចាត់រោគពីរាងកាយ យើងត្រូវតែស្វែងរកឱសថព្យាបាល ។ ឱសថស្លឹកឈើ ឫសឈើ ថ្នាំបុក ថ្នាំស្ងួន ថ្នាំស្លូ . ល . សុទ្ធតែជាថ្នាំឱសថមានប្រសិទ្ធភាពក្នុងការព្យាបាលកំចាត់រោគ ប្រសិនបើផ្សំវាត្រឹមត្រូវតាមរូបមន្ត និងប្រើត្រូវចំសមុដ្ឋាននៃរោគនោះ ។ ចំពោះរោគដែលមានឥទ្ធិពលខ្លាំង ជួនអីអំណាចនៃឱសថបូរាណនេះ មិនអាចរំងាប់វាបានសក្តិសិទ្ធិទេ ត្រូវនាំអ្នកជំងឺទៅមន្ទីរពេទ្យ ដើម្បីព្យាបាលដោយវិធីវេជ្ជសាស្ត្រទំនើប ទើបធានាបាននូវសុខភាពរាងកាយ ។ ប៉ុន្តែ គួរអោយស្តាយណាស់ ! មនុស្សមួយចំនួន ដែលមិនយល់ពីសមុដ្ឋានរោគ និងឥទ្ធិពលរោគ បែរជាពេលឈឺថ្កាត់ម្តងៗ រត់ទៅរកបន់ស្រន់ខ្មោច ទេព្រក្ស អារក្ស អ្នកតា . ល . ព្រោះគេយល់ថា ពួកអមនុស្សទាំងនេះ បណ្តាលអោយគេឈឺថ្កាត់ទៅវិញ ។ គេរត់ទៅរក

គ្រូហោរទាយ ព្រោះគេយល់ថា គ្រូហោរនេះ-នោះ ពូកែស័ក្តិសិទ្ធិ ទាយត្រូវ ថាមិនខុស ... ត្រូវសង្គ្រោះអ្នកជំងឺតាមរបៀបនេះ តាមរបៀបនោះ ជាដើម ។

ផឹកទឹកស្អាត, ហូបស្អាត និងរស់នៅស្អាត ទាំងបីប្រការនេះ គឺជាវិធានការ ដ៏មានប្រសិទ្ធភាពបំផុត សម្រាប់ទ្រទ្រង់សុខភាពរូបកាយយើង ។ ដូច្នេះ ប្រជាជន យើងគ្រប់មជ្ឈដ្ឋាន គប្បីភ្ញាក់រលឹកអនុវត្តតាមវិធានការ « ស្អាតបីយ៉ាង » នេះ អោយបានគ្រប់គ្នា និងទាន់ពេលវេលា ។ ពេលមានជំងឺភ្លាម ត្រូវប្រញាប់ប្រញាល់ ស្ទុះស្ទារកឱសថព្យាបាល ឬទៅមន្ទីរពេទ្យ ដើម្បីសុំពិគ្រោះពិនិត្យព្យាបាលអោយទាន់ សភាពការណ៍ កុំអល់ឯក រារែកទៅរកអបិ្បយជំនឿ នាំអោយមានគ្រោះថ្នាក់ដល់ អាយុជីវិត ។

រៀបរៀងដោយ

**ឱម ខែម** និង **ម៉ែន ប្រាជ**

**អរោគ្យា បរមា លាភា**

*ការមិនមានរោគ ជាលាភដ៏ក្រៃលែង ។*

" ធម្មបទ "

# អំពីការចិញ្ចឹមដង្កូវនាង
# ( LE VER A SOIE )

នៅក្នុងតំបន់ជាច្រើននៃប្រទេសកម្ពុជា នាអតីតកាល ស្ត្រីកសិករខ្មែរបានប្រកបមុខរបរចិញ្ចឹមនាងយកសូត្រធ្វើសម្លៀកបំពាក់ មានហូល ផាមួង ជាដើម ដ៏ជាសម្លៀកបំពាក់ល្អប្រណីត ប្រើក្នុងពិធីមង្គលការ ក្នុងពិធីបុណ្យសាសនា និងក្នុងពិធីបុណ្យជាតិ របស់ខ្មែរ ។ ចំណីចាំបាច់របស់ដង្កូវនាង គឺស្លឹកមន ។

លោកយាយ អ៊ូច អ៊ឹ និងលោកយាយ ឈុន ធ នៅភូមិខ្ទារ ឃុំព្រៃពក ស្រុកគីរីវង្ស ខេត្តតាកែវ បានរៀបរាប់ប្រាប់យើងអំពីរបៀបចិញ្ចឹមនាងយកសូត្រដូចតទៅ :

*១ / ការជ្រើសរើសពូជ*

- រើសយកតែសំបុកនាងណាដែលថ្លោសល្អ,
- រើសយកពូជញីច្រើនជាងពូជឈ្មោល ។

គេអង្រួនសំបុកស្តាប់ បើឮ ខ្លុក១ធ្ងន់ នោះគេសំគាល់ថា វានឹងញាស់ចេញជាមេអំបៅញី បើអង្រួនឮ ខ្លុក១ស្រាល នោះគេសំគាល់ថា វានឹងញាស់ចេញជាមេអំបៅឈ្មោល ។ គេយកសំបុកនាងសំរាប់ធ្វើពូជនេះ ទៅរាយដាក់លើចង្អេរហាលសំដិលនៅកណ្តាលវាល ។ ក្នុងរយៈពេល ៧ ថ្ងៃ មេអំបៅញាស់ចេញមកក្រៅ កាត់ទម្លុះសំបុកដោយផ្សើមនឹងទឹកមាត់វា ។ នៅរាត្រីទី ៧ មេអំបៅទាំងអស់ញាស់ចេញពីសំបុករៀង១ខ្លួន ។ សំបុកនាងដែលជ្រើសរើសបានល្អ គឺញាស់ចេញមកល្អ មានរូបរាងថ្លោសទ្រលុក១ សម្បុរសល្អក់បន្តិច ។ វាមានស្លាបខ្លី១ ហើយទទះស្លាបវេរំកិលរកញី - ឈ្មោល ដើម្បីបន្តពូជតាមក្រឹត្យក្រមធម្មជាតិ ។ អ្នកចិញ្ចឹមនាង បាន

ជួយរៀបចំអោយមេអំបៅឈ្មោល ជាន់មេអំបៅញី តាមរបៀបរៀបរយ រហូតដល់មេអំបៅញីទាំងអស់ ត្រូវបានឈ្មោលជាន់គ្រប់ឥតមានសល់ ។

*២/ ការបំពងមេអំបៅ ឬវិធីធ្វើអោយមេអំបៅពង*

បួនប្រាំម៉ោងក្រោយមក គេបេះមេអំបៅញីផ្ដាច់ចេញពីមេអំបៅឈ្មោល ហើយដាក់ទៅក្នុងថ្ដិលមួយ ។ គេវែង ត្រវិតិច១ ធ្វើអោយមេអំបៅវិលមុខ ហើយទទះស្លាបយ៉ាងញាប់ ឮសូរច្រែត១ ។ ( គេត្រវិផង ពោលផងថា : គ្រាយ ! គ្រាយ ! គ្រាយ ! [១] ។ គេមានធ្វើពិធីមួយទៀត ក្នុងគោលបំណងអោយមេអំបៅពងបានច្រើន នោះគឺ ពិធីលោតកន្លងពីលើមេអំបៅ ។ គេអោយក្មេងប្រុសអាយុពី ៤ ឆ្នាំទៅ ១០ ឆ្នាំ លោតកន្លងថ្ដិលដែលដាក់មេអំបៅញីនោះ ៣ ដង ហើយពោលថា គ្រាយ ! គ្រាយ ! គ្រាយ ! ដូចមុន ។ ) លុះធ្វើយ៉ាងនេះរួចហើយ គេយកមេអំបៅញី ទៅដាក់តម្រៀបគ្នា លើក្រណាត់ស ឬក្រដាសសស្អាត ហើយគ្របចានគោមពីលើ ។ ព្រឹកឡើង គេបើកចានគោម ឃើញពងមេអំបៅល្អិត១ ពណ៌សក្រាស់ឃ្មឹក មានរាងមូលតាមសណ្ឋានរាងមាត់ចាននោះ ។ បន្ទាប់មក គេរើសមេអំបៅញីចេញពីក្រណាត់ ឬក្រដាសដែលវាពងហើយ អោយឈ្មោលជាន់ជាលើកទីពីរ ។ តែលើកនេះ ពងមិនសូវក្រាស់ដូចលើកទីមួយទេ ។ បន្ទាប់ពីនេះទៅ មេអំបៅញីឈ្មោលទាំងអស់ លែងមានប្រយោជន៍អ្វីទៀតហើយ ។ គេបោះវាចោលអោយមាន់ស៊ីទាំងអស់ ។

អ្នកចិញ្ចឹមនាងយកចិត្តទុកដាក់ថែទាំ ការពារពងមេអំបៅទាំងពីរលើកនេះ មិនអោយស្រមោចស៊ី ។ ចាប់ពីថ្ងៃទីបីទៅ ពងមេអំបៅប្រែពណ៌ពីសទៅខ្មៅប្រផេះវិញ ហើយនៅថ្ងៃទី ៦ ឬទី ៧ ពងក៏ញាស់ចេញជាដង្កូវតូច១ ពណ៌ខ្មៅស្រអាប់ ហើយ

---

(១) ភាសាចិញ្ចឹមសត្វ នៅតាមតំបន់ខ្លះ មានន័យថា « សាយកូនអោយបានច្រើន » ។ នៅតំបន់ដទៃទៀត គេមិនមានពិធីអ្វីទេ ។

កំរើកខ្លួនរេក្បាលចុះឡើងរកចំណី, វាមានទំហំតូចល្អិតប៉ុនដង្កូវទឹក ។ គេចងមុងហ៊ុំព័ទ្ធដង្កូវនាង ដើម្បីការពារកុំអោយរុយទិច ឬម្ចូសខាំ ។ ម្យ៉ាងទៀត គេធ្វើត្រឡោកដាក់ទឹកមានទំពក់ សំរាប់ព្យួរចង្អេរ ការពារកុំអោយស្រមោចវារចុះតាមខ្សែ មកខាំដង្កូវនាងផងដែរ ។

ស្លឹកមន ជាចំណីតែមួយគត់របស់ដង្កូវនាង ។ ដង្កូវនាងដែលទើបនឹងញាស់ វាមិនអាចស៊ីស្លឹកមនទាំងមូលបានទេ ។ គេត្រូវហាន់ស្លឹកមនជាសរសៃឆ្មារល្អិតអោយវាស៊ី ដោយប្រើជ្រញ់ធ្វើពីស្បែកដីរ, ស្នូកអណ្តើក ឬស្នូកកន្ធាយ ។ គេត្រូវអោយចំណីនាងមួយថ្ងៃបីដង ។ ពីមួយថ្ងៃទៅមួយថ្ងៃ ដង្កូវនាងចេះតែធំធាត់ ជាលំដាប់ ។ កាលណាដង្កូវនាងនេះធំធាត់ គេត្រូវផ្ទេរបំបែកពីកញ្ជ្រែង ដាក់ទៅចង្អេរអុំ ឬបំបែកពីមួយចង្អេរអុំទៅពីរ ឬបីចង្អេរអុំ តាមបរិមាណតិចច្រើន របស់ដង្កូវនាង ។ ប្រសិនបើការអោយចំណីអាចធ្វើបានក្នុងមួយថ្ងៃបី ឬបួនដង ហើយដង្កូវនាងមានសុខភាពល្អផងនោះ វាធំធាត់ឆាប់រហ័សណាស់ ។ នៅរវាងថ្ងៃទី៨ ឬទី៩ ដង្កូវនាងប្រែពណ៌ពីខ្មៅប្រផេះ ទៅជាពណ៌ក្រហមព្រឿងៗ ។ ពេលនោះ វាមិនសូវស៊ីចំណី ដូចពេលធម្មតាឡើយ ។ វាច្រើនសំងំនៅស្ងៀម មិនសូវកំរើកទេ, មាត់វាហាក់ដូចជារួមតូច, វាច្រើនចុះទៅពួនសំងំនៅក្នុងអាចម៍របស់វា ។ ពេលនោះ ដង្កូវនាងចាប់ផ្តើមដេកជាលើកទីមួយ ដែលភាសាអ្នកចិញ្ចឹមនាង ហៅថា « ដេកមួយ » ពោលគឺ ជាដំណាក់កាលដែលដង្កូវនាងសកជាលើកទីមួយ ។ នៅពេលនេះ សុខភាពដង្កូវនាងខ្សោយណាស់ ពោលគឺ វាងាយនឹងទទួលរងជំងឺផ្សេងៗណាស់ ។ ស្ត្រីអ្នកចិញ្ចឹមនាង ត្រូវរវៀសរវៃ រវាំងមើលថែទាំ យ៉ាងយកចិត្តទុកដាក់បំផុត ការពារកុំអោយរុយ ម្ចូស ឬស្រមោច ចូលមករាតត្បាតបាន ។ ទោះបី នៅពេលដែលវាដេកនេះ វាមិនសូវស៊ីចំណីក៏ដោយ ក៏គេនៅតែដាក់ចំណីអោយវាស៊ីជាដរាប តែគេរាយស្លឹកមនស្តើងៗជាងពេលធម្មតា ។ រំលងបី ឬបួនថ្ងៃ ក្រោយមក ដង្កូវនាងភ្ញាក់ពី

ដេកមួយ ។ ពេលនោះ គេឃើញខ្លួនវា ដូចជារីកធំប្លែកជាងប៉ុន្មានថ្ងៃមុន ។ ពេលរលឹក (ភ្ញាក់) ពីដេកនេះ រូបរាងដង្កូវនាងដែលកាន់តែរីកធំធាត់ប្លែកនោះ គេត្រូវផ្ទេរពីចង្អេរអុំ ទៅដាក់នៅចង្អេរគ្រាងវិញ ( ចង្អេរធំ ) ។ គេបកយកតែស្រទាប់លើទាំងដង្កូវនាង ទាំងកាកសំណល់មន ទៅដាក់នៅចង្អេរធំ ។ ចំណែកខាងអាចម៍ដង្កូវនាងនៅបាតចង្អេរ គេយកទៅចោល ឬអោយគោស៊ី ។ កាលណាផ្ទេរនាងពីចង្អេរអុំទៅដាក់ក្នុងចង្អេរគ្រាង គេលែងព្យួរចង្អេរនឹងទំពក់ត្រឡោក ដូចមុនទៀតហើយ គេដាក់ចង្អេរគ្រាងផ្ទុកដង្កូវនាងនោះនៅលើធ្នើរ ឬខ្នែង ។ បើកាលណាគេមានដង្កូវនាងច្រើន គេក៏ត្រូវធ្វើខ្នែងនេះច្រើនដែរ ព្រោះខ្នែងមួយ អាចដាក់ដង្កូវនាងបានមិនហួសពី ៤ ចង្អេរឡើយ ។ ហើយដើម្បីការពារសុវត្ថិភាពដង្កូវនាង គេនៅតែប្រើមុងហ៊ុំការពារវាជាដរាប ។ នៅគ្រប់បង្គោល (សសរ) ខ្នែងទាំង ៤ គេយកចានដែលមានទឹកមកទ្រ ដើម្បីការពារកុំអោយស្រមោចឡើងរោម ឬខាំដង្កូវនាងបាន ។ រយៈពេលពី ៨ ទៅ ១០ ថ្ងៃ បន្ទាប់ពី « ដេកមួយ » ដង្កូវនាង ក៏ជួបនឹងបាតុភូត ដូចមុនទៀត គឺវាប្រែពណ៌ ពីស-ខៀវ ទៅជាពណ៌ក្រហមព្រឿងៗ ហើយមិនចង់ស៊ីចំណី និងមិនចង់ធ្វើចលនាអ្វីឡើយ ។ នេះគឺជាដំណាក់កាលដេកជាលើកទីពីរ ដែលគេនិយមហៅថា «ដេកពីរ» ។ ដំណាក់កាលដេករបស់នាងមានបួន ប៉ុន្តែ មិនបានរៀបរាប់ហួរហែពីដេកមួយទៅដេកបួនទេ ព្រោះនេះជាបាតុភូតដដែលៗ ដូចគ្នា ។ យើងគ្រាន់តែបញ្ជាក់ជូនថា រយៈពេលពីដេកមួយលើកទៅមួយលើកទៀត រហ័ស ឬយឺត អាស្រ័យដោយការថែទាំ ផ្គត់ផ្គង់ចំណីបរិបូរ ឬអន់ខ្សោយ ។ បើអោយចំណីបរិបូរ មួយថ្ងៃ ៤ លើក ហើយដង្កូវនាងមានសុខភាពល្អនោះ ចន្លោះពេល ពីដេកលើកទី១ ទៅលើកបន្តបន្ទាប់ មានរយៈពេលមិនហួសពី ៧ ទៅ ៨ ថ្ងៃឡើយ ។

នៅរដូវប្រាំង គេប្រោះទឹកពីលើស្លឹកមនអោយត្រជាក់សិន មុននឹងដាក់រាយអោយដង្កូវនាងស៊ី ។ គេហាមដាច់ខាត មិនអោយអ្នកជក់បារីទៅជិតដង្កូវនាង

ឡើយព្រោះខ្លាចដង្កូវនាងពុល ។

### ៣/ អំពីជំងឺ និងសត្រូវរបស់ដង្កូវនាង

ជំងឺដែលកើតឡើងម្តងម្កាលចំពោះដង្កូវនាង មានពីរយ៉ាងជាសំខាន់គឺ ជំងឺឃ្លង់ និងជំងឺទ្រនិចរុយ ។ ឯសត្វចង្រៃដែលបំផ្លាញដង្កូវនាង មាន : រុយ ជីងចក់ មូស ស្រមោច ។

ក/ អំពីជំងឺឃ្លង់

កាលដង្កូវនាងនៅតូច គឺកាលដែលវាភ្ញាក់ពីដេកមួយ ឬដេកពីរនោះ វាមិនកើតជំងឺឃ្លង់នេះទេ ។ ចាប់ពីដេកបីទៅដេកបួន គឺពេលដែលដង្កូវនាងធំពេញជំទង់នោះ ជំងឺនេះអាចរាតត្បាតដង្កូវនាង ធ្វើអោយវាឈឺ ហើយងាប់យ៉ាងច្រើន ឬស្ទើរតែទាំងអស់ ។ គេកំណត់បានថា ដង្កូវនាងកើតជំងឺឃ្លង់ ដោយពិនិត្យឃើញភិនភាគចម្លែក ដូចខាងក្រោម :

- សម្បុរវា លែងភ្លឺថ្លាសក្បុស ដូចពេលវាមានសុខភាពល្អនោះឡើយ
- ខ្លួនវាឡើងកន្ទួល១ កន្ទិល តាំងពីក្បាលដល់កន្ទុយ
- វាមិនសូវធ្វើចលនា ( កំរើក វេខ្លួនចុះឡើង ) ដូចសព្វដងឡើយ គឺវាសំកុក សំងំស្ងៀម ។
- មិនសូវស៊ីចំណី ស៊ីតិចតួច ហើយដល់វាឈឺកាន់តែធ្ងន់ វាលែងស៊ីទាល់តែសោះ ហើយស្លាប់ស្អុយពាសពេញចង្អេរ ។ អ្នកចិញ្ចឹមភ័យខ្លាចជំងឺឃ្លង់នេះ ខ្លាំងណាស់ ។ គេចាត់ទុកថា ជាជំងឺអាសន្នរោគរបស់ដង្កូវនាង ព្រោះជំងឺនេះឆ្លងរាលដាល ធ្វើអោយដង្កូវនាងកើតជំងឺនេះងាប់អស់ ឥតមានសល់ ។

អំពីមូលហេតុដែលនាំអោយដង្កូវនាងកើតជំងឺឃ្លង់ គឺបណ្តាលមកពី :

- ស្លឹកមនក្តៅ ដែលញាត់ក្នុងបាវ ឬការុងណែនពេកនោះ ទៅអោយនាង

ស៊ីភ្លាមៗ ដោយមិនបានយកទៅសំដិល ( ហាល ) អោយត្រូវខ្យល់ត្រជាក់សិន ។

- មុងដែលហ៊ុំកុំអោយមូស រុយ ជីងចក់ ទិច ខាំវានោះ មានក្លិនអាក្រក់ជះទៅលើវា ។ គេគ្មានវិធីណាអាចជួយព្យាបាលជំងឺឃ្លង់នេះបានឡើយ ។

ខ / អំពីជំងឺទ្រនិចរុយ

ជំងឺទ្រនិចរុយនេះ បណ្តាលមកពីរុយ ឬមូស ទិច ខាំដង្កូវនាង ។ កាលណាដង្កូវនាងណាមួយ ត្រូវមូស ឬរុយ ទិច ខាំហើយ គេឃើញមានស្នាមចំណុចខ្មៅលេចឡើងច្បាស់នៅលើខ្លួនដង្កូវនាង ។ ក្រោយពីបានរងគ្រោះមក ដង្កូវនាងមិនសូវធំធាត់រីកខ្លួន ដូចដង្កូវនាងឯទៀតឡើយ ។ វាបាត់បង់ចលនាក្លៀវក្លា មិនសូវស៊ីចំណីហើយច្រើនតែសំកុកសំងំស្ងៀម ។ ប៉ុន្មានថ្ងៃក្រោយមក ដង្កូវនាងក៏ស្លាប់ទៅ ។ អ្នកចិញ្ចឹមនាង ត្រូវតែយកចិត្តទុកដាក់ថែទាំរៀងរាល់ថ្ងៃ អោយបានម៉ត់ចត់ ។ បើកាលណា ឃើញមានដង្កូវនាងណាកើតជំងឺទ្រនិចរុយនេះ គេត្រូវរើសបោះចោលភ្លាម ។ ប៉ុន្តែ ជំងឺទ្រនិចរុយនេះ មិនសូវរាតត្បាត បំផ្លិចបំផ្លាញដង្កូវនាងជាទ្រង់ទ្រាយធំ ដូចជំងឺឃ្លង់ឡើយ ។ ជាទូទៅ ជំងឺនេះកើតនៅលើដង្កូវនាងមួយចំនួនតូចប៉ុណ្ណោះ ។ ប្រសិនបើអ្នកចិញ្ចឹមថែទាំ ដាក់មុងត្រឹមត្រូវ នោះវាអាចជៀសផុតពីជំងឺនេះបាន ។

### *៤/ អំពីវឌ្ឍនាការរីកចំរើនរបស់ដង្កូវនាង*

ក្នុងជីវិតរបស់វា ដង្កូវនាងត្រូវឆ្លងកាត់ ៧ ដំណាក់កាល គឺ :

- ការញាស់ចេញជារូបរាងដង្កូវនាង
- ដេកមួយ ( សកលើកទី ១ )
- ដេកពីរ ( សកលើកទី ២ )
- ដេកបី ( សកលើកទី ៣ )
- ដេកបួន ( សកលើកទី ៤ )

- ដង្កូវនាងទុំ
- ដង្កូវនាងព័ទ្ធសំបុក

ដូចបានជម្រាបពីខាងលើស្រាប់ បន្ទាប់ពីដង្កូវនាងរលីក ( ភ្ញាក់ ) ពីដេកមួយ ប្រមាណ ៧ ឬ ៨ ថ្ងៃ ដង្កូវនាង ក៏ត្រូវចូលដល់ដំណាក់កាលមួយទៀត គឺ « ដេកពីរ » ។ ពេលរៀបដេកម្តងៗ ដង្កូវនាងបានបង្ហាញនូវហេតុភេទដែលអាចកត់សំគាល់បានដូចៗគ្នា គឺសម្បុរវាឡើងក្រហាមព្រឿង មិនសូវធ្វើចលនា មិនសូវស៊ីចំណី ចុះទៅ ជ្រកសំងំនៅក្នុងអាចម៍វា ។ គេកត់សំគាល់បានថា ពេលភ្ញាក់ (រលីក-ក្រោក) ពីដេកជាបន្តបន្ទាប់ ខ្លួនវារីកធំ មាត់វាក៏រីកធំលើសពីពេលមុនជាដរាប ឬវាមានភាពក្លៀវក្លា ស៊ីចំណីយ៉ាងសកម្ម ។ នៅពេលក្រោក (រលីក-ភ្ញាក់) ពីដេកបួន ដង្កូវនាងដែលមានសុខភាពល្អ ហើយដែលបំប៉នចំណីគ្រប់គ្រាន់, វាមាន :

- ទំហំប៉ុនគល់ចង្កឹះ ឬធំជាង,
- ប្រវែងប្រមាណ ៦ ឬ ៧ សង់ទីម៉ែត្រ,
- សម្បុរសភ្លឺរលោងចាំង
- កង់ (ថ្នាំង = anneau) វែងៗ រហូតជាង ១ សង់ទីម៉ែត្រ ក្នុងមួយកង់ ( ថ្នាំងៗ ) ។

*៥/ ដង្កូវនាងទុំ*

នៅពេលដែលដង្កូវនាងរលីកពីដេកបួននេះ អ្នកចិញ្ចឹមបានបង្កើនការបំប៉នចំណី ពោលគឺ គេដាក់ស្លឹកមនអោយដង្កូវនាងស៊ីក្នុងមួយថ្ងៃ ៣ ឬ៤ ដង ដើម្បីអោយដង្កូវនាងធំធាត់ពេញទំហឹង ហើយផ្តល់នូវទិន្នផលជាទីពេញចិត្ត ។ បួនឬប្រាំថ្ងៃក្រោយមក គេឃើញដង្កូវនាងទុំមួយៗ ដែលគេនិយមហៅថា « ទុំគយ » ។ គេរើសដង្កូវនាងទុំយកទៅដាក់រាយលើបាច់ ឬឃ្នាបមែកឈើ ដែលមានស្លឹកស្ងួត ដែលគេ

ចងព្យួរនៅទីណាដែលស្រឡះ មានខ្យល់អាកាសល្អ ។ គេជៀសវាងមិនដាក់សង្រែក ស្លឹកឈើស្ងួត ឬបាច់ស្លឹកឈើស្ងួតនេះហាលថ្ងៃក្តៅឡើយ ។ ពីរឬបីថ្ងៃជាបន្តបន្ទាប់មកទៀត ដង្កូវនាងទុំកាន់តែច្រើន ឬទុំទាំងអស់ ។ ពេលនេះ មនុស្សទាំងប៉ុន្មានក្នុងគ្រួសារត្រូវរវល់ទាំងអស់គ្នា ។ គឺគេនាំគ្នារើសដង្កូវនាងទុំដាក់ចានផើង យកទៅរាយអោយទំលើឃ្នាបមែកឈើ ស្លឹកឈើ ដែលបានរៀបចំទុកជាស្រេច ។ លុះរាយដង្កូវនាងដាក់សព្វពាសពេញឃ្នាបអស់ហើយ គេយកឃ្នាបទៅពាក់ព្យួរដង្ហៃគ្នា ទុកចន្លោះល្មមពន្លឺ និងខ្យល់អាកាសចេញ-ចូលបានស្រួល ។

*៦/ ដង្កូវនាងព័ទ្ធសំបុក*

នៅពេលដែលបានទំនៅលើទ្រនិស្រួលបួលហើយ ដង្កូវនាងរេក្បាលចុះឡើងបញ្ចេញសរសៃសូត្រយ៉ាងតូចឆ្មារពីមាត់វា ហើយយកសរសៃនេះទៅទាក់ព័ទ្ធស្លឹកឈើ ឬមែកឈើដែលនៅជិតខាងខ្លួនវា ។ បើគេដើរទៅជិតឃ្នាបទាំងឡាយដែលគេថ្ពក់ព្យួរហូរហែជិតៗគ្នា គេនឹងឮសូរសំឡេងរួមមួយ ដែលបន្លឺឡើងឮសូរ « ឆ » ដោយដង្កូវនាងបញ្ចេញសូត្រពីមាត់ធ្វើសំបុកព័ទ្ធជុំវិញខ្លួនវា ។ អស់រយៈពេលមួយថ្ងៃ ដង្កូវនាងធ្វើសំបុកបានហើយស្រេចជាស្ថាពរ ។ ដង្កូវនាងទុំដែលមានសុខ-ភាពល្អថ្លោស ធ្វើសំបុកបានធំប៉ុនមេដៃ រាងពងក្រពើវែងបន្តិច ប្រវែងប្រមាណ ៣,៥០ ស.ម ពណ៌លឿងឆ្អិន ហើយក្រាស់ ។ ព្រឹកឡើង អ្នកចិញ្ចឹមបេះសំបុកចេញពីមែកឈើក្នុងឃ្នាប, គេបន្ទុំវាដាក់ក្នុងកញ្ជើ ហើយគេយកសំបុកទៅចាក់សំដិលលើចង្អេរគ្រាង ដែលតាំងនៅទីកន្លែងមានពន្លឺព្រះអាទិត្យ មានខ្យល់ចេញចូលបរិបូរ ។ ក្នុងរយៈពេល ៣ ឬ ៤ ថ្ងៃ ការបន្ទុំនាង ការបេះសំបុកទុក បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។ គេធ្លាប់ចំណាំថា ដង្កូវនាងមួយចង្អេរ អាចផលិតបានសំបុកពីរចង្អេរ ។ អ្នកចិញ្ចឹម ត្រូវរើសសំបុកដែលថ្លោស ក្រាស់ ពណ៌លឿងស្រស់ល្អ ទុកដោយឡែក

សំរាប់ធ្វើពូជផ្ទាល់ខ្លួននៅពេលក្រោយទៀត ឬទុកសំរាប់លក់ដូរអោយអ្នកដែលមករកទិញ ឬដូរដោះយកពូជទៅចិញ្ចឹម ។ ក្រៅពីនេះ សំបុកនាងទាំងប៉ុន្មាន ត្រូវទុកសំរាប់ស្រាវយកសូត្រ ដែលគេនិយមហៅថា « ស្រាវសំបុក » ។

*៧/ ការស្រាវសំបុកនាងយកសូត្រ*

ដំបូងឡើង គេយកថ្លាងធំមួយដាក់ទឹកពេញទៅដាំអោយពុះ ។ គេយកកូនជើងរទេះជាឧបករណ៍ស្រាវសូត្រមកដាក់ពីលើមាត់ថ្លាងទាំងសងខាង ហើយគេចងភ្ជាប់ចុងដងរទេះផ្នែកខាងលើទៅនឹងរនូត ឬរនាបផ្ទះ ។ ស្ត្រីអ្នកស្រាវសំបុកអង្គុយលើត្បាល់ផ្កាប់ក្បែរចង្ក្រាន នៅចន្លោះកុង និងថ្លាងដាំទឹក ។ នៅក្បែរនោះទៀត មានកញ្ជើមួយដាក់សំបុកនាងត្រៀមទុកបំរុងស្រាវ ។ កាលណា ទឹកពុះល្អហើយ ស្ត្រីអ្នកស្រាវសំបុកនាងដែលអង្គុយនៅលើត្បាល់ផ្កាប់ ឬជើងម៉ាធម្មតាច្បាមសំបុកនាងមួយដៃធំដាក់ទៅក្នុងថ្លាង ។ ដៃឆ្វេងកាន់ដំបៀតសង្កត់សំបុកនាងអោយលិចទៅក្នុងទឹក រួចគ្រវីបន្តិច១ ដើម្បីអោយសរសៃសូត្ររលាចេញពីសំបុកនីមួយ១ ផ្គុំគ្នាកើតបានជាសរសៃរួមមួយ ។ គេទាញសរសៃសូត្ររួមនោះ អោយវែងឆ្ពោះទៅកាន់កង់ជើងរទេះ រួចព័ទ្ធមួយជុំកងរទេះ ហើយទាញទៅចងនៅកាំណាមួយរបស់កុង ។ ស្ត្រីអ្នកស្រាវសូត្រ ត្រូវតែវាងវៃទាំងខួរក្បាល ទាំងចលនាដៃទាំងពីរយ៉ាងរស់រវើកផង ទើបអាចធានាធ្វើការស្រាវសូត្រនេះបាន ។ ដៃឆ្វេងគ្រវីទ្រាបពីលើសំបុកនាងនៅក្នុងថ្លាង ដៃស្តាំបង្វិលកុងអោយវិលក្នុងសង្វាក់មួយ ដែលមានល្បឿនសមស្របទៅនឹងសរសៃសូត្រតូច១ ដែលចេញពីសំបុកនានាត្របាញ់បញ្ចូលគ្នា ឆ្លងកាត់កងជើងរទេះ ហើយត្រូវព័ទ្ធទៅលើកាំកុងបន្ថែមទៅលើសរសៃមុន១ ។

សរសៃសូត្រដែលស្រាវចេញបានមក មានបីប្រភេទ គឺ :

- សូត្រក្បាល

- សូត្រសាច់
- សូត្រដៃ

ក/ ប្រភេទសូត្រក្បាល

មុននឹងបានសូត្រសាច់ គេត្រូវតែផលិតយកសូត្រក្បាលជាមុនសិន ដែលគេនិយមហៅថា បកក្បាលសូត្រ ។ ដើម្បីបកក្បាលសូត្រ គេស្រាវយកសរសៃសូត្រដែលស្ថិតនៅស្រទាប់ក្រៅ ប្រហែលមួយភាគបី ចេញពីសំបុក ។ ក្បាលណាស្រាវដល់ត្រឹមកំរិតនេះ គេដួសសំបុកដែលបកក្បាលចេញពីថ្លាង ហើយបង់សំបុកថ្មី ទៅក្នុងថ្លាង រួចស្រាវតាមរបៀបនេះជាបន្តទៀត ដរាបទាល់តែអស់សំបុកដែលត្រូវស្រាវ ។ ទោះបីសូត្រក្បាល ឬក្បាលសូត្រ មានសរសៃធំ គ្រើម មិនស្មើល្អក្តី ក៏គេប្រើប្រាស់វាបាន ទៅតាមប្រភេទគុណភាពរបស់វា គឺ :

- ត្បាញទៅជាក្រម៉ា ឬសារុងសូត្រក្រាស់ៗ
- វេញបញ្ចូលផ្លូងធ្វើជាខ្សែខ្លែងស្និតជាប់ល្អ
- វេញធ្វើជាកន្លះគោ ប្រឡៅគោ ឬខ្សែគោ ( ខ្សែគោសំរាប់បរប្រណាំងក្នុងសម័យមុន ) ។

ខ / ប្រភេទសូត្រសាច់

សូត្រសាច់មានសម្បុរលឿងថ្លា ( ភ្លាវ ) មានសរសៃស្មើល្អណាស់ គ្មានតូច គ្មានធំ ឬគ្មានក្រម៉ឡើយ ។ គេចាត់ទុកសូត្រសាច់ជាប្រភេទសូត្រជំរើស សម្រិតសម្រាំងយ៉ាងល្អប្រណីត ។ ដើម្បីផលិតចេញជាសូត្រសាច់ ដំបូង អ្នកស្រាវសូត្រត្រូវដកយករបុំ ឬរមូសរសៃសូត្រក្បាលចេញពីកុង ។ បន្ទាប់មក គេបង់សំបុកដែលបកក្បាលចេញអស់ ១/៣ (មួយភាគបី) នោះ ទៅក្នុងថ្លាងទឹកពុះ រួចយកដំបៀតកូរគ្រវីគ្រវាស ធ្វើអោយសរសៃសូត្រឆ្មារៗចេញពីគ្រប់សំបុក បង្កើតបានជាសរសៃរួមគ្នាមួយមូល ហើយស្មើល្អ ។ អ្នកស្រាវចាប់យកសរសៃរួមនេះហូតអោយវែង យក

ទៅព័ទ្ធរុំនឹងកង់ជើងរទេះមួយជុំ រួចទើបទាញសរសៃសូត្រនេះបន្តទៅចងនៅកាំកុង ( ធ្វើដូចកាលស្រាវសូត្រក្បាលដែរ ) ហើយក៏យកដៃឆ្វេងកាន់ដំបៀតគ្រវីគ្រវាស នៅលើសំបុកក្នុងថ្លាងទឹកពុះ ធ្វើអោយសរសៃសូត្រឆ្មារចេញពីគ្រប់សំបុក រួមគ្នាជាសរសៃតែមួយរត់ឆ្លងកាត់កង់ជើងរទេះបន្តទៅរុំព័ទ្ធកុង តាមចលនាវៃរបស់ស្ត្រីអ្នកស្រាវសូត្រ ។ កាលណាសំបុកភាគច្រើន ចេញសរសៃសូត្រអស់ហើយ គេចាប់យកសំបុកពីល្អើបង់ទៅក្នុងថ្លាង លៃយ៉ាងណាអោយសរសៃសូត្រមានស្មើនឹងលើកមុន ។ គេចេះតែបង់សំបុកនាងបន្ថែមយ៉ាងនេះ ហើយចេះតែបន្តស្រាវទៅទៀត រហូតដល់អស់សំបុកនាង សំរាប់ស្រាវយកសូត្រក្នុងថ្ងៃនេះ ។

គ/ អំពីប្រភេទសូត្រដៃ

សូត្រដៃជាប្រភេទសូត្រលេខពីរ ដែលមានសរសៃតូចជាងសូត្រក្បាល ហើយធំជាងសរសៃសូត្រសាច់ ។ ចំពោះអ្នកដែលពុំមានគម្រោងធ្វើសំពត់ហូលផាមួង សារុង ចរបាប់ ក្រម៉ា រំយោល ឬកន្សែងច្បុចល្អប្រណីតទេនោះ គេផលិតសូត្រដៃ ដែលងាយស្រួលក្នុងការស្រាវសូត្រ គឺ :

- ពុំមានការកំប៉ិកកំប៉ុកស្មុគស្មាញ ធ្វើពីរដងឡើយ ។
- អាចនឹងត្បាញធ្វើជាសំពត់ ក្រម៉ា ឬសម្លៀកបំពាក់ធុនមធ្យម សំរាប់ប្រើប្រាស់ប៉ុកប៉ិនក្នុងការងារស្រែចំការ ។

សូត្រដៃមានសរសៃមិនសូវស្មើល្អទេ ជួនតូច ជួនធំ ជួនមានក្រម៉ ជួនគ្មាន វាមានសម្បុរលឿងភ្លាវជាងសូត្រក្បាល តែលឿងចាស់ជាងសូត្រសាច់ ។ ដើម្បីផលិតសូត្រដៃ គេច្បាមសំបុកនាងពីក្នុងកញ្ជើដាក់ទៅក្នុងថ្លាងទឹកពុះ ហើយធ្វើដូចរបៀបមុន គឺយកដំបៀតទៅទ្រាបសង្កត់សំបុកនាងបង់ថ្មីអោយលិចទៅក្នុងទឹកពុះ រួចគ្រវីគ្រវាសថ្នមៗ ធ្វើអោយសរសៃសូត្រតូចឆ្មារ រលាចេញពីសំបុកនាងនីមួយៗ ហើយផ្តុំគ្នាជាសរសៃតែមួយ ដែលស្ត្រីអ្នកស្រាវនោះទាញយកទៅព័ទ្ធមួយជុំកង់ជើង

រវេះ រួចទាញសរសៃសូត្រដដែលនេះ ទៅចងកាំកុង រួចបង្វិលកុងក្នុងល្បឿនមួយសមស្របទៅនឹងលទ្ធភាពដែលសំបុកនាងក្នុងថ្លាងអាចបញ្ចេញសរសៃសូត្រទាន់ទៅតាមចង្វាក់នៃកុង ។ កាលណាសំបុកមួយចំនួនចេញសរសៃសូត្រអស់ ឬជិតអស់ ដឹកដឿក៏ធ្លាក់ទៅបាតថ្លាងជាបន្តបន្ទាប់ ។ ស្ត្រីអ្នកស្រាវសូត្រ ចាប់យកសំបុកនាងថ្មីពីកញ្ជើបង់ជំនួសសំបុកនាងដែលចេញសរសៃសូត្រអស់ ហើយគេចេះតែបន្តស្រាវសូត្ររហូតទាល់តែអស់សំបុកនាងដែលត្រូវស្រាវ ។ គេយករបុំ ឬរមូសរសៃសូត្រចេញពីកុងដូចរបៀបមុន ។ សូត្រគ្រប់ប្រភេទដែលដោះចេញពីកុងភ្លាម១ វានៅមានជាតិសើម ដោយទើបនឹងស្រាវចេញមកពីថ្លាងដែលផ្ទុកដោយទឹកពុះ ។ គេត្រូវយកសូត្រសើមនេះទៅពាក់ព្យួរនៅរបៀង ហាលថ្ងៃអោយស្ងួតល្អ ទើបយកមកទុកត្រៀមគេះយកក្រម៉ចេញ រួចប្រមោកអោយចេញពណ៌លឿង ហើយក្លាយទៅជាពណ៌ស សំរាប់ធ្វើអ្វីទៅតាមចំណង់របស់ស្ត្រីអ្នកចិញ្ចឹមនាង ។

*៨/ អំពីដឹកដឿ ( chrysalide )*

ជីវិតជុំខួប (la vie cyclique) របស់ដង្កូវនាង គឺផ្តើមចេញពីមេអំបៅកាត់ចេញពីសំបុក ញាស់ជាដង្កូវតូច១ ឆ្លងកាត់ដំណាក់កាលដេកមួយ ( សកលើទី១ ) ដេកពីរ ( សកលើកទី២ ) ដេកបី ( សកលើកទី៣ ) ដេកបួន ( សកលើកទី៤ ) និងលើកចុងក្រោយ ដំណាក់កាលទុំ ដំណាក់កាលព័ទ្ធសំបុក ( ធ្វើសំបុក ) ដំណាក់កាលក្លាយទៅជាដឹកដឿ និងដំណាក់កាលក្លាយទៅជាមេអំបៅវិញ ។ នៅពេលដែលដង្កូវនាង ត្រូវឆ្លងចូលដល់ដំណាក់កាលស្រាវសូត្រនោះ ដង្កូវនាងដែលនៅក្នុងសំបុក បានក្លាយទៅជាដឹកដឿ ។

គេច្រើនយកដឹកដឿប្រើធ្វើជាម្ហូប គឺ :

- ស្លធ្វើជាម្ហូបរួមជាមួយនឹងបន្លែផ្សេង១ មានស្លកក្វូរ ប្រហើរ,

- លីងលាយជាមួយនឹងចំណិតល្ហុងខ្ចី បង់អំបិល ឬទឹកត្រីបន្តិច១,
-ឆាជាមួយនឹងស្លឹកគូឆាយ
- លីងអោយក្រៀមសំរាប់ទុកបរិភោគបានយូរថ្ងៃ
- ញាំជាមួយប្រក្រុងលាយជាមួយម្ទេសផ្លែពង្រចាស់ ឬផ្លែក្រសាំងចាស់ ដោយមានលាយទឹកប្រហុកខាប់ ។ នេះជាអាហារជាទីគាប់ចិត្តរបស់កសិករ នៅជនបទ ស្រុកស្រែ ចំការយើង ។

*ផលប្រយោជន៍នៃការចិញ្ចឹមនាង*

គេទទួលផលបានបីមុខពីការចិញ្ចឹមនាងគឺ :

- សរសៃសូត្រ សំរាប់ធ្វើសម្លៀកបំពាក់ប្រណីត ប្រើក្នុងពិធីសំខាន់១ និងសម្លៀកបំពាក់សំរាប់ធ្វើការងារប្រចាំថ្ងៃ,
- ដឹកដឿ សំរាប់ធ្វើជាម្ហូបអាហារបរិភោគ,
- សំបុកកាត់ សំរាប់លក់អោយឈ្មួញយកទៅផលិតម្ជូកសំបុក ។

បច្ចុប្បន្ននេះ ការចិញ្ចឹននាងនៅក្នុងប្រទេសកម្ពុជាយើង មានចំនួនមិនច្រើន ដូចនៅក្នុងអតីតកាលទេ ។ យើងសង្ឃឹមថា នៅពេលអនាគត មុខរបរនេះ នឹងកើតមាន ហើយរីកដុះដាលឡើងវិញ ជាពុំខាន ។

ដោយ **មៀច ប៉ុណ្ណ**

# បទអក្សរសង្វាស

*វាចារំឭក :*

បទអក្សរសង្វាសដែលលោកអ្នកនឹងបានអាននៅក្នុងទំព័រជាបន្តទៅនេះ ត្រូវបានលោកកវីនិពន្ធ អៀង សាយ ចងក្រងឡើង នៅក្នុងសៀវភៅរបស់លោក ឈ្មោះ « មេកាព្យ » ។ ខ្ញុំបានអានកំណាព្យនេះ នៅក្នុងទសវត្សទី ៦០ ហើយក៏នៅចាំរត់មាត់តាំងពីពេលនោះរហូតមកដល់សព្វថ្ងៃ ។

ដើម្បីកុំឱ្យបាត់បង់នូវស្នាដៃដ៏មានតម្លៃនេះ ខ្ញុំសូមកត់កំណាព្យបទអក្សរសង្វាស របស់លោកកវីនិពន្ធ អៀង សាយ ទុកក្នុងទស្សនាវដ្ដីកម្ពុជសុរិយានេះ គ្រាន់ជាគំរូនៃបទ និងជាការអានកំសាន្ត សម្រាប់ជនានុជនស្នេហាវប្បធម៌ជាតិ ។

បទអក្សរសង្វាស ជាបទកំណាព្យខ្មែរ ពាក្យ ៧ ចែកចេញជា ៤ ឃ្លា ហើយនៅក្នុងឃ្លានីមួយៗ ពាក្យ ឬ ព្យាង្គពីរម៉ាត់នៅដើមឃ្លា ត្រូវមានស្រៈ និងប្រកបដូចគ្នា ពាក្យ ឬព្យាង្គពីរម៉ាត់នៅចុងឃ្លា ត្រូវមានស្រៈ និងប្រកបដូចគ្នា ។



ព្រមជាមួយនឹងកំណាព្យបទអក្សរសង្វាសនេះ ខ្ញុំក៏សូមចម្លងទុកផងដែរ នូវប្រស្នាមួយ អមដោយចម្លើយផង ដែលលោក អៀង សាយ បានចងក្រងឡើង គ្រាន់ជាការកំសាន្តលេង និងជាការល្បងប្រាជ្ញា ។

ថ្ងៃទី ២០ ឧសភា ១៩៩៧

**ធន់ ហ៊ិន**

## បទអក្សរសព្វាស ទី១

បើដើរទៅប្រាប់គេនឹងដឹង ពាមស្នាមដំណឹងនឹងមករក
បាត់ស្វាត់ប្រយ័ត្នក្រែងមកជ្រក សុខទុក្ខគេភ្នកករាយមាយ ។
រត់ហាត់បត់រកឃើញបាត់ស្វាត់ ប្រឹងខឹងខំកាត់ទំនាយទាយ
បានស្មានថាស្មោះជាព្រាយវាយ គីឈឺមិនងាយទើបបាត់ស្វាត់ ។

## បទអក្សរសព្វាស ទី២

បងប៉ងយូរហើយនឹកថាការ បានប្រាណកាលណានឹងបីស្រី
ច្រៀងផ្ទៀងបំពេរបទថ្មីខ្មី ថ្នមបមបោសបីស្រីសល្អ ។
ពៅទៅមិនបានប្រាប់បងផង ចិត្តគិតប៉ុនប៉ងគូស្រេករ
ប្ដីសីមានទៀតឆ្លៀតត្រដរ គេចភ្លេចបងក្រអូនឃ្លានមាន ។

***

ទំព័រកំសាន្ត

## ប្រស្នា

ក្នុងឆ្នាំ ១៩៦២ នៅពេលដែលមនុស្សម្នាផងទាំងឡាយកំពុងកំសាន្តសប្បាយជាមួយព្រះរាជពិធីបុណ្យតាំងតុនៅក្នុងព្រះបរមរាជវាំង ខ្ញុំបានធ្វើឆ្នោតវត្ថុលក់ ចំនួនទាំងអស់ ៥ សន្លឹក ដែលមួយសន្លឹក១ ថ្លៃតែ ១ រៀល ។ ឆ្នោតទាំង ៥

សន្លឹកនោះ សុទ្ធតែត្រូវបានរង្វាន់ទាំងអស់ ដូចតទៅ :

ឆ្នោតទី ១ ត្រូវ ស្បែកជើង « ១ គូរ »

ឆ្នោតទី ២ ត្រូវ ឈើគូស ១ សុង

ឆ្នោតទី ៣ ត្រូវ ជក់លាបពណ៌ ១ ប្រអប់

ឆ្នោតទី ៤ ត្រូវ កាត់ខោអាវឱ្យតាមចិត្តស្រឡាញ់

ឆ្នោតទី ៥ ត្រូវ អកកំបោរ

ខ្ញុំដាក់ឆ្នោតទាំង ៥ សន្លឹកនោះ ក្នុងកញ្ជ្រែងតូចមួយ រួចដើរប្រកាសផ្សព្វផ្សាយឱ្យគេទិញ ។ មានអ្នកខ្លះគេមិនជឿថា ឆ្នោតខ្ញុំនោះត្រូវទាំងអស់ទេ ។ ខ្ញុំក៏ឱ្យគេបើកមើល ។ គេឃើញថាត្រូវទាំង ៥ សន្លឹកនេះមែន ។ ខ្ញុំប្រមូលឆ្នោតដាក់ក្នុងកញ្ជ្រែងវិញ រួចឱ្យគេទិញម្នាក់ ១ សន្លឹក ចាប់យកតាមការផ្សងសំណាង ។ មិនបានប៉ុន្មាននាទីផង គេក៏ដណ្ដើមគ្នាទិញអស់ ។ លុះដល់ពេលផ្ទៀង ខ្ញុំក៏បើករង្វាន់ជូនគេរៀងៗ តាមដែលគេត្រូវ ។ ទីបំផុតខ្ញុំចំណេញបាន ៥ រៀល ។ សួរថាតើខ្ញុំធ្វើដូចម្ដេច ?

## ចម្លើយ

១. អ្នកត្រូវស្បែកជើង « ១ គូរ » . ខ្ញុំហុចក្រដាសតូចមួយដែលខ្ញុំបត់ជាពីរផ្ទត់ទៅឱ្យគាត់ ។ គាត់សួរខ្ញុំថា « ឯណាស្បែកជើង ? » ។ ខ្ញុំឆ្លើយទៅគាត់ថា « លាក្រដាសហ្នឹងមើលទៅ មានឃើញអ្វីឬទេ ? » ។ លុះគាត់លារួច គាត់ឆ្លើយថា « ឃើញមានរូបស្បែកជើងមួយ តែជាគំនូរ » ។ ខ្ញុំក៏ឆ្លើយទៅវិញថា « បាទ ! ស្បែកជើងមួយហ្នឹង ខ្ញុំជាអ្នកគូរ . នេះគឺស្បែកជើង ១ គូរ » ។

២. អ្នកត្រូវបានឈើគូស « ១ សុង » . ខ្ញុំហុចកញ្ចប់ក្រដាសតូចមួយឱ្យគេ ទាំងប្រាប់គេថា បើកមើលក្នុងកញ្ចប់នោះទៅ « តើមានឃើញអ្វីឬទេ ? » ។

លុះគេលោកញ្ចប់នោះទៅ គេប្រាប់មកខ្ញុំវិញថា « ឃើញមានឈើមួយដុំ ប៉ុនម្រាមដៃ » ។ ខ្ញុំសួរទៅគាត់វិញថា « មានឃើញស្នាមខ្មៅបន្តិចឬទេ ពីព្រោះខ្ញុំបានយកធ្យូងគូសវា ? » ។ គាត់ឆ្លើយថា « ឃើញ » ។ ខ្ញុំថា « ហ្នឹងហើយឈើគូស » ។ រីឯ « សុង » ជាពាក្យចិន ប្រែមកថា កញ្ចប់ ។

៣. អ្នកត្រូវបានជក់លាបពណ៌ « ១ ប្រអប់ » . ខ្ញុំឱ្យជក់កញ្ចាស់មួយដែលគេបោះចោល ហើយខ្ញុំរើសបាន មានទាំងប្រឡាក់ទឹកថ្នាំពណ៌ផ្សេងៗផង ដាក់ក្នុងប្រអប់កញ្ចាស់មួយដែលខ្ញុំរើសបានដែរ ឱ្យទៅអ្នកដែលត្រូវរង្វាន់នោះ ។ ខ្ញុំបញ្ជាក់ប្រាប់គាត់ថា « បើជក់នៅថ្មី គឺវាមិនទាន់មាននរណាលាបពណ៌ឱ្យវារអញ្ចឹងទេ » ។

៤. អ្នកត្រូវបានរង្វាន់កាត់ខោអាវឱ្យតាមចិត្តស្រឡាញ់ . ខ្ញុំមានកន្ត្រៃមួយ ។ ខ្ញុំទាញកន្ត្រៃនោះចេញមក ហើយសួរជននោះថា « តើចង់ឱ្យខ្ញុំកាត់ខោ និងអាវ ដែលលោកកំពុងស្លៀកពាក់នេះឱ្យទៅជាយ៉ាងម៉េច ? ខោជើងវែង កាត់ឱ្យទៅជាខ្លី ? ហើយអាវហ្នឹងដៃខ្លីស្រាប់ កាត់ឱ្យនៅត្រឹមណា ? » បុរសនោះធ្វើមុខញឹមៗ មិនចេញស្តីថាអ្វីឡើយ ។ ខ្ញុំបន្ថែមទៀតថា « កាត់រួចអត់ដេរទេណ៎ា ! ព្រោះនៅក្នុងឆ្នោត អត់មានថាដេរទេ » ។ បុរសនោះសើចញឹមៗ ក៏ចេញទៅបាត់ទៅ ។

៥. អ្នកត្រូវអកកំបោរ . ខ្ញុំមានកំបោរមួយកញ្ចប់ ប្រហែលមួយក្តាប់ ។ ខ្ញុំហៅអ្នកដែលត្រូវបានរង្វាន់នោះឱ្យមកជិត ហើយឱ្យគេហាមាត់ផង ដើម្បីខ្ញុំនឹងច្រកកំបោរដាក់ក្នុងមាត់គេ ។ ប៉ុន្តែ បុរសនោះមិនព្រមមក ចេះតែសើចៗ ហើយដើរកាន់តែឆ្ងាយទៅៗ ។

***

# ថ្មចំណាស់មានតម្លៃ

- កណ្ដោចកណ្ដែងក្នុងព្រៃជ្រៅ ត្រូវភ្លៀងហាលក្ដៅស្មៅព័ទ្ធជុំ
  កណ្ដាលស្មសានស្ងាត់ជ្រងំ សំងំពួនយំតែម្នាក់ឯង ។
- ខ្លួនចាស់ខ្លាចប្រាសព្រាត់ពូជពង្ស ចង់បន្តវង្សពង្សពាក់ពែង
  ធ្លាប់រស់មានយសគេកោតក្រែង គេស្ញប់គេស្ញែងឫទ្ធិអំណាច ។
- ឆ្លងកាត់វាលវដ្តច្រើនតំណ ទោះខ្លួនជាថ្មអាចប្រាញប្រាជ្ញ
  រៀបរាប់រឿងរ៉ាវកាលក្នុងរាជ្យ ចេស្ដាអំណាចគ្រងផែនដី ។



ក្រុមប្រាសាទសម្បូរ ស្រុកសម្បូរ ខេត្តកំពង់ធំ

• ល្វើសានបុរះរាជធានី[១] ក្រុងចាស់ទីពីរជាសាក្សី
ល្វើសានវង្វើនស្តេចចក្រី តាំងធានីថ្មីពីចេនឡា ។
• សាងសង់ជាច្រើនរចនាបថ ឥដ្ឋស្មើសាច់ម៉ដ្តល្អអស្ចារ្យ
ថ្មភក់ធ្វើផ្តែរំយោលផ្កា ដូចដុំសិលាបុប្ផារាំ ។
• រចនាបថសម្បូរព្រៃគុក[២] រស់ឆ្លងកាត់យុគច្រើនជោគជាំ
គេជីកគេកាប់ដាប់ខ្ទេចខ្ទាំ ខាំមាត់ស៊ូទ្រាំទាំងទឹកភ្នែក ។
• ប្រាសាទសម្បូរសម្បត្តិខ្មែរ គួររក្សាថែកុំរាវែក
ជាទីក្រុងចាស់ថ្លៃស្មើភ្នែក កុំរាកុំវែកកុំបង្អង់ ។
• វិញ្ញាណនៅរស់ជាប់នឹងថ្ម នៅចាំជាប់ល្អថ្មផ្ទូរផង់
ស្នាដៃចំណានបានសាងសង់ កិត្តិស័ព្ទត្រចង់ល្បីរន្ទឺ ។
• ស្តាប់ថ្មអង្វរគួរអាណិត សូមកុំងងឹតក្នុងទីភ្លឺ
ថ្មថ្ងូរថ្មស្រែកខ្ញុំបានឮ ថ្មដួលថ្មឈឺខ្ញុំរន្ធត់ ។
• ខ្ញុំបានទៅជួបថ្មផ្ទាល់ភ្នែក ឃើញថ្មបាក់បែកថ្មទុរគត
ស្តាប់ថ្មរៀបរាប់សែនស្រយុត បើខ្មែរមើលផុតខ្មែរបាត់ពូជ ។

**ខៀវ បញ្ញាឧត្តម**
អនុប្រធានការិយាល័យស្រាវជ្រាវ
នៅពុទ្ធសាសនបណ្ឌិត្យ ផ្នែកសោតទស្សន៍

---

(១) ឯកសារខ្លះ សរសេរថា « ឥសានបុរះ » ។ (២) ឯកសារខ្លះ សរសេរថា « គុហ៍ » ។

# របនាសម្ព័ន្ធគ្រប់គ្រងគណៈសង្ឃពុទ្ធសាសនិក ខាងគណៈមហានិកាយ នៃ ព្រះរាជាណាចក្រកម្ពុជា

---------

ការគ្រប់គ្រងគណៈសង្ឃខាងគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា តាំងពីអតីតកាល មកដល់បច្ចុប្បន្នកាល មានការវិវត្តន៍សម្រួលតាមកាលៈទេសៈ ដូចតទៅនេះ :

១. ពីក្នុងរជ្ជកាលព្រេងនាយ, ក្នុងខេត្តនីមួយៗ វត្តអារាមជាលំនៅរបស់សង្ឃមានចំនួនតិច ឋិតនៅដាច់ឃ្លាតពីគ្នាឆ្ងាយៗ ១០ គីឡូម៉ែត្រឡើងទៅ ។ ដូច្នេះការគ្រប់គ្រងសង្ឃជាភារកិច្ចរបស់ព្រះឧបជ្ឈាយ៍ ព្រោះសម័យនោះ ព្រះឧបជ្ឈាយ៍ក៏មានកំណត់, ក្នុងខេត្តនីមួយៗមិនច្រើនដែរទេ ។ ព្រះឧបជ្ឈាយ៍ទាំងនោះ សម្តេចព្រះសង្ឃរាជ ឬសម្តេចព្រះសង្ឃនាយកជាប្រមុខសង្ឃ ដែលគង់នៅក្នុងរាជធានីជាអ្នកតែងតាំង និងគ្រប់គ្រងផ្ទាល់ ដោយមានព្រះរាជាគណៈ ( ឯក - ទោ - ត្រី - ចត្វា ) និងឋានានុក្រមជាសហការីខ្លះទៀត ជួយសម្រេចសង្ឃកិច្ចគ្រប់យ៉ាង ក្នុងព្រះរាជាណាចក្រទាំងមូល ។

២. លុះចំណេរកាលតមក, វត្តអារាមមានចំនួនកាន់តែច្រើន ព្រះឧបជ្ឈាយ៍មួយអង្គ ពីរអង្គ ក្នុងខេត្តនីមួយៗ ពុំអាចគ្រប់គ្រងគណៈសង្ឃគ្រប់គ្រាន់បាន ទើបសម្តេចព្រះសង្ឃរាជ ឬសម្តេចព្រះសង្ឃនាយកជាប្រមុខសង្ឃ បានប្រជុំប្រឹក្សាជាមួយនឹងព្រះរាជាគណៈ ឋានានុក្រម, ព្រមព្រៀងគ្នាធ្វើលិខិតថ្វាយព្រះពរសូមព្រះរាជានុញ្ញាតពីព្រះមហាក្សត្រ ដើម្បីរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងគណៈសង្ឃពុទ្ធសាសនិកជាថ្មីទៀត គឺខេត្តនីមួយៗ ឱ្យមានព្រះមហាថេរមួយរូប ដែលមានសមត្ថភាព ឱ្យធ្វើជាមេគណខេត្ត មានសមណសក្តិទីឋានានុក្រម ហើយមានឋានន្តរ៍

គឺងារផ្សេងៗ ពីគ្នា សម្រាប់គ្រប់គ្រងត្រួតត្រាលើគណៈសង្ឃក្នុងខេត្តរៀងៗ ខ្លួន ។ ឯព្រះរាជាគណៈ - ឋានានុក្រមជាសហការីផ្ទាល់របស់សម្ដេចព្រះសង្ឃរាជ - សម្ដេចទ្រង់ចាត់ក្នុងមួយខេត្ត ប៉ុន្មានអង្គ ? អង្គណាខ្លះ ? ឱ្យជួយទទួលភារៈត្រួតត្រាសង្ឃកិច្ច តាមខេត្តធំ ឬតូច ដែលហៅថាកំណាន់ខេត្ត ។ លុះដល់ហោមរដូវរៀងរាល់ឆ្នាំ ចាប់ពីថ្ងៃ ១ រោច ខែផល្គុន នៅថ្ងៃណាមួយក៏បាន, ព្រះគ្រូមេគណគ្រប់ខេត្ត ត្រូវចូលមកជួបនឹងព្រះរាជាគណៈ ជាកំណាន់ខេត្តរបស់ខ្លួន, - ហើយកំណាន់ខេត្តនេះត្រូវនាំព្រះគ្រូមេគណនោះ ចូលក្រាបបង្គំគាល់សម្ដេចព្រះសង្ឃរាជ ឬសម្ដេចព្រះសង្ឃនាយក ដើម្បីរាយការណ៍ថ្វាយពីការរីកចម្រើន, សុខទុក្ខ, លំបាក - ស្រួល ក្នុងឆ្នាំកន្លងមក និងទូលស្នើកិច្ចការសាសនា ដែលត្រូវអនុវត្តតទៅទៀត ព្រមទាំងទទួលព្រះឱវាទផ្សេងៗផង ។ ការដែលព្រះគ្រូមេគណ ចូលមកក្នុងមួយឆ្នាំម្ដងនេះ ហៅថា « ឡើងគណ » ។

៣- ក្រោយមកទៀត, វត្តអារាមកាន់តែកើនច្រើនឡើង ទៅតាមចំនួនគ្រហស្ថពុទ្ធសាសនិកដែលកើនឡើង កាន់តែច្រើនភូមិ - ឃុំ - ស្រុក - ខេត្តនោះ សម្ដេចព្រះសង្ឃរាជបានប្រជុំពិភាក្សាគ្នាជាមួយមន្ត្រីសង្ឃ ដែលមានមកស្រេចស្រាប់ និងមន្ត្រីក្រសួងធម្មការ ព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ ធ្វើសំណូមពរថ្វាយព្រះមហាក្សត្រ ដើម្បីសូមព្រះរាជានុញ្ញាត រៀបចំរចនាសម្ព័ន្ធផ្នែកខាងពុទ្ធចក្រ ឱ្យស្របនឹងអាណាចក្រ ។ ព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យព្រះរាជានុញ្ញាត តាមសំណូមពរ ។ សម្ដេចព្រះសង្ឃរាជ និងក្រសួងធម្មការ មួយអន្លើដោយព្រះមហាថេរដទៃទៀត ក៏បានប្រជុំរៀបចំរចនាសម្ព័ន្ធផ្នែកពុទ្ធចក្រ ជាបួនថ្នាក់ គឺ :

ថ្នាក់ទី ១ គណៈសង្ឃវត្ត មាន ៣ អង្គ

ថ្នាក់ទី ២ គណៈសង្ឃស្រុក មាន ៥ អង្គ

ថ្នាក់ទី ៣ គណៈសង្ឃខេត្ត មាន ៦ អង្គ

ថ្នាក់ទី ៤ គណៈសង្ឃនាយក មានច្រើនអង្គ

- គណៈសង្ឃវត្ត ៣ អង្គគឺ ចៅអធិការ, គ្រូសូត្រស្តាំ, គ្រូសូត្រឆ្វេង ;

- គណៈសង្ឃស្រុក ៥ អង្គ គឺ អនុគណ, វិន័យធរអនុគណ, ធម្មធរអនុគណ, សមុហ៍អនុគណ, អនុលេខាធិការអនុគណ ;

- គណៈសង្ឃខេត្ត ៦ អង្គ គឺ មេគណ, បាឡាត់គណ, វិន័យធរគណ, ធម្មធរគណ, សមុហ៍គណ, លេខាធិការគណ ;

- គណៈសង្ឃនាយក មានព្រះសង្ឃនាយក ឬព្រះសង្ឃរាជ និងព្រះរាជាគណៈ - ឋានានុក្រមមួយចំនួនទៀត លែលកតាមទំហំការងារ ។

ព្រះសង្ឃនាយក ឬព្រះសង្ឃរាជ មានឋានន្តរ៍ជាព្រះមហាសុមេធាធិបតី ។ ព្រះសង្ឃនាយក ឬព្រះសង្ឃរាជ អាចព្រះមហាក្សត្រទ្រង់ប្រគេនព្រះឋានៈដ៏ខ្ពង់ខ្ពស់ជាសម្តេចព្រះសង្ឃនាយក ឬសម្តេចព្រះសង្ឃរាជ តាមសព្វព្រះរាជហឫទ័យ ។

ឯព្រះរាជាគណៈ ចែកជា ២ ផ្នែកគឺ :

- ព្រះរាជាគណៈក្នុងតំណែង

- ព្រះរាជាគណៈកិត្តិយស

*ក). ព្រះរាជាគណៈក្នុងតំណែង* ចែកជា ៤ថ្នាក់ គឺ : ឯក - ទោ - ត្រី - ចត្វា និងមានឋានន្តរ៍ គឺងារផ្សេងៗគ្នា ដូចតទៅ :

• ព្រះរាជាគណៈថ្នាក់ឯក មាន ៣ គឺ :

១. ព្រះធម្មលិខិត

២. ព្រះពោធិវង្ស (១)

៣. ព្រះវនរ័ត (២)

(១) ព្រះពោធិវង្ស មានសំយោគសញ្ញា អានថា « វាំង » ។ (២) រ័ត : ប្រែថា រីករាយ ។

• ព្រះរាជាគណៈថ្នាក់ទោ មាន ៦ គឺ ៖

១. ព្រះមហាវិមលធម្ម
២. ព្រះពុទ្ធឃោសាចារ្យ
៣. ព្រះធម្មឃោសាចារ្យ
៤. ព្រះឃោសធម្ម
៥. ព្រះសាសនមុនី
៦. ព្រះមុនីកោសល

• ព្រះរាជាគណៈថ្នាក់ត្រី មាន ៦ គឺ ៖

១. ព្រះសិរីសម្មតិវង្ស
២. ព្រះពុទ្ធវង្ស
៣. ព្រះសាក្យវង្ស
៤. ព្រះឧបាលិវង្ស
៥. ព្រះញាណវង្ស
៦. ព្រះសុមេធវង្ស

• ព្រះរាជាគណៈថ្នាក់ចត្វា មាន ២០ គឺ ៖

១. ព្រះធម្មវិបស្សនា
២. ព្រះសមាធិធម្ម
៣. ព្រះញាណកោសល
៤. ព្រះសិរីសង្គាមមុនី
៥. ព្រះសិរីវិសុទ្ធិ
៦. ព្រះធម្មវង្សា
៧. ព្រះញាណសំវរ

៨. ព្រះវិន័យសំវរ

៩. ព្រះឥន្ទមុនី

១០. ព្រះទេពមុនី

១១. ព្រះវិន័យមុនី

១២. ព្រះទេពសត្ថា

១៣. ព្រះសីលសំវរ

១៤. ព្រះគម្ភីរត្ថេរ

១៥. ព្រះអរិយមគ្គញ្ញាណ

១៦. ព្រះវិភទ្ធញ្ញាណ

១៧. ព្រះបវរសត្ថា

១៨. ព្រះញាណវិសុទ្ធិវង្ស

១៩. ព្រះធម្មវិសុទ្ធិវង្ស

២០. ព្រះបិដកធម្ម

ព្រះរាជាគណៈទាំង ៤ ថ្នាក់នេះ ព្រះមហាក្សត្រទ្រង់តែងតាំងដោយព្រះក្រឹត្យ តាមព្រះសំណើររបស់សម្តេចព្រះសង្ឃនាយក ឬសម្តេចព្រះសង្ឃរាជ តាមរយៈក្រសួងធម្មការ ជាអ្នកក្រាបបង្គំទូលថ្វាយ ។

ភិក្ខុសង្ឃដែលអាចស្នើតែងតាំងជាព្រះរាជាគណៈបាន ត្រូវប្រកបដោយលក្ខណសម្បត្តិ ៤ យ៉ាងគឺ :

១. វិជ្ជាសម្បត្តិ

២. សីលសម្បត្តិ

៣. មានវស្សាភិក្ខុពី ២០ ឆ្នាំ ឡើងទៅ

៤. មានឋានន្តរស័ក្តិទីឋានានុក្រមជាព្រះបាឡាត់ ឬព្រះគ្រូ មកដល់

បច្ចុប្បន្ន ។

ព្រះរាជាគណៈ ត្រូវស្នើតែងតាំងតាមលំដាប់ថ្នាក់គឺ ពីថ្នាក់ចត្វា ទៅថ្នាក់ត្រី, ពីថ្នាក់ត្រី ទៅថ្នាក់ទោ, ពីថ្នាក់ទោ ទៅថ្នាក់ឯក ។

ព្រះរាជាគណៈក្នុងតំណែងគ្រប់ថ្នាក់ អាចស្នើសុំតែងតាំងសហាការីផ្ទាល់អង្គ តាមការចាំបាច់បាន ២ អង្គ គឺ ទីជាឋានានុក្រមព្រះបាឡាត់ ១ អង្គ, ព្រះសមុហ៍ ១ អង្គ ។

ដោយឡែក សម្តេចព្រះសង្ឃនាយក ឬសម្តេចព្រះសង្ឃរាជ ត្រូវមានសហាការីផ្ទាល់ ៨ អង្គ គឺ ព្រះគ្រូសង្ឃសត្ថា ១, ព្រះគ្រូសង្ឃសុមេធ ១, ព្រះវិន័យធរ ១, ព្រះធម្មធរ ១, ព្រះបាឡាត់សង្ឃវង្ស ១, ព្រះបាឡាត់សង្ឃរ័ក្ខ ១, ព្រះសមុហ៍សុមេធាចារ្យ ១, ព្រះសមុហ៍បណ្ណរ័ក្ខ ១ ។

*ខ). ព្រះរាជាគណៈកិត្តិយស :*

ព្រះរាជាគណៈកិត្តិយស ត្រូវបានតែងតាំងប្រគេនចំពោះព្រះថេរះអង្គណាដែលមានគុណបំណាច់ដល់ជាតិ និងសាសនា ដែលសម្តេចព្រះសង្ឃនាយក ឬសម្តេចព្រះសង្ឃរាជ យល់ថាគួរលើកទឹកព្រះទ័យ ហើយលើកសំណើថ្វាយព្រះមហាក្សត្រ តាមរយៈក្រសួងធម្មការ ដើម្បីចេញព្រះក្រឹត្យពិសេសប្រគេនជាកិត្តិយស ។

ចំណែកមន្ត្រីសង្ឃខេត្ត-ស្រុក ក៏សុទ្ធតែមានឋានន្តរ៍ គឺងារផ្សេងៗគ្នាដែរដូចតទៅ :

## ឋានន្តរ៍មន្ត្រីសង្ឃទីមេគណ

| | |
|---|---|
| ១. ខេត្តបាត់ដំបង | ព្រះសង្ឃកិច្ចកោសល |
| ២. ខេត្តកណ្តាល | ព្រះវិមលវេទី |
| ៣. ខេត្តកំពង់ចាម | ព្រះនាគមុនី |

| | |
|---|---|
| ៤. ខេត្តកំពត | ព្រះជលធីវាសី |
| ៥. ខេត្តព្រៃវែង | ព្រះមុនីរក្ខិតវង្សា |
| ៦. ខេត្តកំពង់ឆ្នាំង | ព្រះធម្មាវង្សាធិបតី |
| ៧. ខេត្តតាកែវ | ព្រះមង្គលទិព្វលោករង្សី |
| ៨. ខេត្តស្វាយរៀង | ព្រះវង្សាបតីធម្មធារ |
| ៩. ខេត្តកំពង់ធំ | ព្រះសត្ថាបារមី |
| ១០. ខេត្តសៀមរាប | ព្រះសុមង្គលសីលាចារ្យ |
| ១១. ខេត្តក្រចេះ | ព្រះសុគន្ធសីលសារ |
| ១២. ខេត្តកំពង់ស្ពឺ | ព្រះមុនីសត្ថាចារ្យកោសល |
| ១៣. ខេត្តពោធិសាត់ | ព្រះពោធិវង្សាវិមល |
| ១៤. ខេត្តស្ទឹងត្រែង | ព្រះធម្មកោសលហ្លួកខាំ |
| ១៥. ខេត្តកោះកុង | ព្រះទីបរ័ក្ខសត្ថាចារ្យ ( ថ្មី ) |
| ១៦. ខេត្តព្រះវិហារ | ព្រះសីមាវិជិត ( ថ្មី ) |
| ១៧. ខេត្តរតនគិរី | ព្រះរតនសោភិត ( ថ្មី ) |
| ១៨. ខេត្តមណ្ឌលគិរី | ព្រះមណ្ឌលសោភ័ណ ( ថ្មី ) |
| ១៩. ក្រុងព្រះសីហនុ | ព្រះវិមលសាគរ ( ថ្មី ) |
| ២០. ខេត្តបន្ទាយមានជ័យ | ព្រះវិជ័យមុនី ( ថ្មី ) |
| ២១. ក្រុងភ្នំពេញ | ព្រះរាជាគណៈមានងារស្រាប់ |

## ឋានន្តរ៍មន្ត្រីសង្ឃទីព្រះបាឡាត់គណ

| | |
|---|---|
| ១. ខេត្តបាត់ដំបង | ព្រះបាឡាត់ វិមលមុនី |
| ២. ខេត្តកណ្ដាល | ព្រះបាឡាត់ វេទីវង្សា |
| ៣. ខេត្តកំពង់ចាម | ព្រះបាឡាត់ នាគសត្ថា |

| | | |
|---|---|---|
| ៤. ខេត្តកំពត | ព្រះបាឡាត់ | សាគររង្សី |
| ៥. ខេត្តព្រៃវែង | ព្រះបាឡាត់ | ព្រហ្មប្បញ្ញា |
| ៦. ខេត្តកំពង់ឆ្នាំង | ព្រះបាឡាត់ | សធម្មចារី |
| ៧. ខេត្តតាកែវ | ព្រះបាឡាត់ | ទិព្វលោកមុនី |
| ៨. ខេត្តស្វាយរៀង | ព្រះបាឡាត់ | គម្ពីរធម្មសត្ថា |
| ៩. ខេត្តកំពង់ធំ | ព្រះបាឡាត់ | បារមីធម្មបាល |
| ១០. ខេត្តសៀមរាប | ព្រះបាឡាត់ | វិមលប្បញ្ញា |
| ១១. ខេត្តក្រចេះ | ព្រះបាឡាត់ | វិន័យមេធា |
| ១២. ខេត្តកំពង់ស្ពឺ | ព្រះបាឡាត់ | សត្ថាភិរក្ខិត |
| ១៣. ខេត្តពោធិសាត់ | ព្រះបាឡាត់ | វិចិត្រព្រហ្មធម៌ |
| ១៤. ខេត្តស្ទឹងត្រែង | ព្រះបាឡាត់ | បវរិទ្ធ |
| ១៥. ខេត្តកោះកុង | ព្រះបាឡាត់ | ទីបធម្មាភិបាល ( ថ្មី ) |
| ១៦. ខេត្តព្រះវិហារ | ព្រះបាឡាត់ | សីមានុចារី ( ថ្មី ) |
| ១៧. ខេត្តរតនគីរី | ព្រះបាឡាត់ | រតនានុរ័ក្ខ ( ថ្មី ) |
| ១៨. ខេត្តមណ្ឌលគីរី | ព្រះបាឡាត់ | មណ្ឌលានុរ័ក្ខ ( ថ្មី ) |
| ១៩. ខេត្តបន្ទាយមានជ័យ | ព្រះបាឡាត់ | វិជយានុរ័ក្ខ ( ថ្មី ) |
| ២០. ក្រុងព្រះសីហនុ | ព្រះបាឡាត់ | សាគរានុរ័ក្ខ ( ថ្មី ) |
| ២១. ក្រុងភ្នំពេញ | ព្រះបាឡាត់ | សិរីវង្សាចារ្យ ( ថ្មី ) |

## ឋានន្តរមន្ត្រីសង្ឃទីអនុគណខ័ណ្ឌ-ស្រុក

• រាជធានីភ្នំពេញ មានអនុគណ ៧

| | |
|---|---|
| ១. ខ័ណ្ឌដូនពេញ | ព្រះគ្រូធម្មបាលមុនី |
| ២. ខ័ណ្ឌ ៧ មករា | ព្រះគ្រូរតនវង្សាចារ្យ |

៣. ខ័ណ្ឌចំការមន ព្រះគ្រូញាណវិបុល
៤. ស្រុកមានជ័យ ព្រះគ្រូវិជ័យមេធា
៥. ខ័ណ្ឌទួលគោក ព្រះគ្រូនាគាភិរក្ខ
៦. ស្រុកដង្កោ ព្រះគ្រូសុមេធធានី
៧. ខ័ណ្ឌឫស្សីកែវ ព្រះគ្រូរតនបជ្ជោតិ

• ខេត្តកណ្តាល មានអនុគណ ១១

១. ស្រុកតាខ្មៅ ព្រះគ្រូធម្មចរិយាមុនី
២. ស្រុកអង្គស្នួល ព្រះគ្រូឧទ័យវង្សា
៣. ស្រុកពញាឮ ព្រះគ្រូចរិយាកោសល
៤. ស្រុកខ្សាច់កណ្តាល ព្រះគ្រូញាណវិមល
៥. ស្រុកមុខកំពូល ព្រះគ្រូមង្គលរង្សី
៦. ស្រុកកៀនស្វាយ ព្រះគ្រូវិសុទ្ធិវង្សា
៧. ស្រុកល្វាឯម ព្រះគ្រូបញ្ញាសិរី
៨. ស្រុកកណ្តាលស្ទឹង ព្រះគ្រូវិន័យវេទី
៩. ស្រុកលើកដែក ព្រះគ្រូមុនីកោវិទ
១០. ស្រុកស្អាង ព្រះគ្រូវិជិតមេធា
១១. ស្រុកកោះធំ ព្រះគ្រូបញ្ញានុរក្ខិត

• ខេត្តកំពង់ចាម មានអនុគណ ១៥

១. ស្រុកកំពង់សៀម ព្រះគ្រូសំវរមុនី
២. ស្រុកព្រៃឈរ ព្រះគ្រូវជីរវិទូ
៣. ស្រុកជើងព្រៃ ព្រះគ្រូសង្ឃរ័ក្ខវិញ្ញូ
៤. ស្រុកកោះសូទិន ព្រះគ្រូវិទូទីបបាល

| | |
|---|---|
| ៥. ស្រុកត្បូងឃ្មុំ | ព្រះគ្រូមធុរធម្មរង្សី |
| ៦. ស្រុកក្រូចឆ្មារ | ព្រះគ្រូសិរីវិសាល |
| ៧. ស្រុកមេមត់ | ព្រះគ្រូវិសុទ្ធធម្មបាល |
| ៨. ស្រុកស្ទឹងត្រង់ | ព្រះគ្រូវិសាលធម្មទស្សី |
| ៩. ស្រុកស្រីសន្ធរ | ព្រះគ្រូសិរីវិជ្ជា |
| ១០. ស្រុកកងមាស | ព្រះគ្រូបញ្ញារង្សី |
| ១១. ស្រុកចម្ការលើ | ព្រះគ្រូសិរីធម្មរក្ខិត |
| ១២. ស្រុកពញាក្រែក | ព្រះគ្រូសិរីធម្មធារ |
| ១៣. ស្រុកតំបែរ | ព្រះគ្រូវិភត្តិធម្មោ |
| ១៤. ស្រុកអូររាំងឪ | ព្រះគ្រូសទ្ធានុចារី |
| ១៥. ស្រុកបាធាយ | ព្រះគ្រូវិន័យកោសល |

• ខេត្តកំពត មានអនុគណ ៧

| | |
|---|---|
| ១. ស្រុកកំពត | ព្រះគ្រូសាគរសោភ័ណ |
| ២. ស្រុកកំពង់ត្រាច | ព្រះគ្រូវិសុទ្ធគីរី |
| ៣. ស្រុកបន្ទាយមាស | ព្រះគ្រូសុវណ្ណរង្សី |
| ៤. ស្រុកអង្គរជ័យ | ព្រះគ្រូវិជ័យមុនី |
| ៥. ស្រុកឈូក | ព្រះគ្រូបទុមគាមរក្ខ |
| ៦. ស្រុកដងទង់ | ព្រះគ្រូសិរីធម្មធារ |
| ៧. ស្រុកជុំគីរី | ព្រះគ្រូគីរីសត្ថាចារ្យ |

• ខេត្តព្រៃវែង មានអនុគណ ១១

| | |
|---|---|
| ១.ស្រុកព្រៃវែង | ព្រះគ្រូទីឃវ័នមេធា |
| ២. ស្រុកកំចាយមារ | ព្រះគ្រូមារានុវិជ័យ |

៣. ស្រុកពារាំង ព្រះគ្រូសំវរវិន័យ
៤. ស្រុកស៊ីធរកណ្ដាល ព្រះគ្រូវិជ័យមុនី
៥. ស្រុកបាភ្នំ ព្រះគ្រូមេត្តាធម្មធរ
៦. ស្រុកកំពង់ត្របែក ព្រះគ្រូបវរវេទី
៧. ស្រុកកញ្ជ្រៀច ព្រះគ្រូមុនីមង្គល
៨. ស្រុកព្រះស្ដេច ព្រះគ្រូចរិយាសោភ័ណ
៩. ស្រុកពាមជរ ព្រះគ្រូឧត្តមមេធា
១០. ស្រុកស្រុកពាមរក៍ ព្រះគ្រូវិចិត្តមេធា
១១. ស្រុកមេសាង ព្រះគ្រូមុនីសោភិត

• ខេត្តកំពង់ឆ្នាំង មានអនុគណ ៧

១. ស្រុករលាប្អៀរ ព្រះគ្រូធម្មានុវត្ត
២. ស្រុកបរិបូណ៌ ព្រះគ្រូអភិរត័សីលធមិ
៣. ស្រុកកំពង់លែង ព្រះគ្រូសាក្យបុត្តសំវរ
៤. ស្រុកកំពង់ត្រឡាច ព្រះគ្រូធម្មធរជិនបុត្ត
៥. ស្រុកទឹកផុស ព្រះគ្រូវិសុទ្ធសីលគុណ
៦. ស្រុកសាមគ្គីមានជ័យ ព្រះគ្រូវិសាលសីលគុណ
៧. ស្រុកជលគិរី ព្រះគ្រូជលធីរវង្សា

• ខេត្តតាកែវ មានអនុគណ ១០

១. ស្រុកដូនកែវ ព្រះគ្រូរតនវង្សាចារ្យ
២. ស្រុកទ្រាំង ព្រះគ្រូធម្មវិមល
៣. ស្រុកគិរីវង្ស ព្រះគ្រូមង្គលកេសរ

( នៅមាន ត )

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ




ទិដ្ឋភាពរួមនៃសិក្ខាសាលាតំបន់ ស្ដីពី
« ដំណើរឆ្ពោះទៅរកអភិសមាចារបរិដ្ឋាន ក្នុងទ្វីបអាស៊ីអាគ្នេយ៍ »

ឆ្នាំទី ៥១ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ
ព.ស ២៥៤១ គ.ស ១៩៩៧
ភ្នំពេញ

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ណារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **ឃី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហោច លាចហោ**

លោក **ម៉ែន ប្រាច**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងាររបស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនានិងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើខ្ញុំអធិដ្ឋាន សូមអោយទស្សនាវត្តីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាពរវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្ប-ធមិ និងសម្បត្តិសាសនារបស់ប្រជាជនកម្ពុជា ។

## Acknowledgement

The Kambuja Suriya Magazine is specilly printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ធម៌ត្រីនៃពុទ្ធសាសនា - ត ( ឈន អៀម ) ........ ១
- វជ្ជទស្សនកថា ( គង់ វេទ ) ........ ២៦


II. អក្សរសាស្ត្រទូទៅ :


- វចនស័ព្ទវិទ្យា នៃភាសាខ្មែរបច្ចុប្បន្ន ( ឡុង សៀម ) ........ ៣៦
- ប្រវត្តិតាត្រសក់ផ្អែម ( វង់ សុធារ៉ា ) ........ ៥៣
- អំពីទង់ : ទង់ពុទ្ធសាសនា និងទង់ជាតិ ( ឈន អៀម ) ........ ៦៧
- រឿងក្អែក និង សំពោច ( សុត្តន្តប្រីជា ឥន្ទ ) ........ ៧៦
- ល្បិចចៅក្រម ( ជួន ណាត ) ........ ៧៩
- បទថយក្រោយ ( ធន់ ហ៊ិន ) ........ ៨២
- វាចាឈើប៊ីដងវែង ( ខៀវ បញ្ញារុឌ្ឍ ) ........ ៨៦
- ដើមជ្រៃ ( ខៀវ បញ្ញារុឌ្ឍ ) ........ ៨៨
- ចម្លើយកំណាព្យប្រស្នា ( វណ្ណ ស៊ុនហេង ) ........ ៩០
- * កំណាព្យប្រស្នា ........ ៩២


III. កំណត់ និង ប្រវត្តិការណ៍ :


- រចនាសម្ពន្ធគ្រប់គ្រងគណៈសង្ឃ - តចប់ ( ម៉ី យ៉ាំ ) ........ ៩៣
- សិក្ខាសាលាតំបន់ ស្តីពី « ដំណើរឆ្ពោះទៅរកអភិសមាចារបរិដ្ឋាន ក្នុងទ្វីបអាស៊ីអាគ្នេយ៍ » ........ ១០០

# ធម៌គ្រឹះ នៃ ពុទ្ធសាសនា

( ក )

ដោយ លោក ភីទ័រ ដ. សន្តិនា
( By Peter D. Santina )
បកប្រែដោយ : ឈន អៀម

( II )

## ពុទ្ធជីវប្បវត្តិ

ថ្ងៃនេះ ខ្ញុំសូមចំណាយពេលបន្តិចនិយាយពីជីវិតរបស់ព្រះពុទ្ធ ។ ខ្ញុំមិនចង់ចំណាយពេលច្រើនពេកទៅលើជីវភាព និងសកម្មភាពរបស់ព្រះពុទ្ធទេ ពិព្រោះជីវប្បវត្តិភាគច្រើន ( របស់ព្រះពុទ្ធ ) ច្រើនជារឿងនិទាន ។ ប៉ុន្តែ ខ្ញុំសូមឆ្លៀតយកឱកាសថ្ងៃនេះ បំបែរអារម្មណ៍មករកតម្លៃដ៏មានសារសំខាន់មួយចំនួនរបស់ពុទ្ធសាសនា ដែលឃើញកើតមានយ៉ាងគួរឱ្យចាប់អារម្មណ៍នៅក្នុងជីវិតរបស់ព្រះពុទ្ធ ។

កាលពីសប្តាហ៍កន្លងទៅ, ខ្ញុំបាននិយាយអំពីប្រពៃណីពីរបែប ហើយថាតើប្រពៃណីទាំងពីរបែបនេះ ដែលកាលពីដើមទីផ្សេងស្រឡះពីគ្នា បានចាប់ផ្តើមមានអន្តរកម្មបន្តិចម្តងៗ ហើយបានរលាយចូលគ្នាជាយថាហេតុ នៅក្នុងប្រទេសឥណ្ឌាយ៉ាងណានោះ, ហើយយើងក៏បាននិយាយថា ការចាប់ផ្តើមនៃដំណើរអន្តរកម្មនេះ អាចត្រូវបានកំណត់ប្រហែលនៅសម័យពុទ្ធកាល ។ តាមពិតទៅ នៅសម័យពុទ្ធកាល, យើងអាចឃើញការចាប់ផ្តើមនៃអន្តរកម្ម ហើយវាជាអភិក្រមមួយដែលបាន

បន្តរហូតមកដល់មួយពាន់ឆ្នាំក្រោយ នៅពេលដែលប្រពៃណីទាំងពីររលាយចូលគ្នា ហើយក្លាយទៅជាពិបាកវែកញែកអោយឃើញផ្សេងពីគ្នាបាន ។ នេះប្រហែលមិនមែនជាចៃដន្យទេ ដែលមានតំបន់មួយក្នុងបណ្តាតំបន់ពីបុរាណ, ដែលមានប្រពៃណីពីរបានមកជួបគ្នាយ៉ាងសកម្មបំផុត, ហើយបានប្រព្រឹត្តទៅនៅក្នុងតំបន់ដែលគេស្គាល់ថាជា*មជ្ឈមប្រទេស* ។ នេះគឺជាតំបន់ ដែលនៅជុំវិញនេះ មានឧត្តរប្រទេស (Uttar Pradesh) ភាគខាងកើត និងប៊ីហារ ( រដ្ឋប៊ីហារ ) ឥឡូវនេះ ។ តំបន់នេះត្រូវបានពួកព្រាហ្មណ៍ចាត់ទុកជាតំបន់មួយប្រណាំងប្រជែងចំពោះអារ្យធម៌អារ៉្យន ។ ជាការចៃដន្យ កាលដែលប្រពៃណីពីរមានចរិតបែបនេះបានមកជួបគ្នា, វាបង្កើតឡើងនូវបរិយាកាសមួយ ដែលនៅក្នុងនេះ មានមហាសក្តានុពលមួយ បណ្តុះឡើងនូវទិសសាសនាថ្មី ។ យើងអាចឃើញជីវិត និងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ នៅក្នុងបរិបទនេះដោយភាគច្រើន ។ បន្ថែមពីលើអន្តរកម្មនៃប្រពៃណីសាសនាទាំងពីរ, នៅមានការប្រែប្រួលយ៉ាងសំខាន់ផងដែរខាងសង្គម, ខាងសេដ្ឋកិច្ច និងខាងនយោបាយ ដែលបានកើតឡើង ហើយដែលយើងបាននិយាយរួចហើយ ពីសប្តាហ៍មុន ។ ព្រឹត្តិការណ៍ទាំងអស់នេះ បានជួយលើកកំពស់មនសិការ ខាង សាសនា ។ ជានិច្ចកាលក្នុងពេលមានការច្របូកច្របល់ខាងនយោបាយ និងសង្គម, វាតែងកើតមានទស្សនៈថា មនុស្សតែងសម្លឹងជញ្ជីងរកពំនឹង, ហើយមនុស្សតែងងាកមករកសាសនា ។ កាលណា គេឃើញស្ថាប័នទាំងឡាយ ដែលបុព្វបុរសរបស់គេបានប្រកាន់ជឿជាប់លាប់មិនរង្គោះរង្គើ ប្រែប្រួល, វាតែងមានទំនោរជាធម្មជាតិមួយ ងាកទៅរកសាសនា, ហើយហេតុការណ៍នេះ ផ្តល់វិភាគទានដល់ការលើកកំពស់មនសិការ និងសកម្មភាពសាសនា ។ ព្រឹត្តិការណ៍នេះ គឺជាករណីកើតឡើងញឹកញយណាស់ នៅក្នុងសតវត្សទី ៦ មុនគ្រឹស្តសករាជ ។

តម្លៃទាំងឡាយ ដែលលេចធ្លោចេញពីជីវិតរបស់ព្រះពុទ្ធ ដែលខ្ញុំចង់

ពន្យល់បំភ្លឺ មានជាសំខាន់បីយ៉ាង, តម្លៃទាំងបីយ៉ាងនោះគឺ *អភិនិស្រ្កមន៍ ( ការលះបង់ជីវភាពគ្រហស្ថចេញសាងផ្នួស ), មេត្តា និងករុណា* ហើយនិង*បញ្ញា* ។ តម្លៃទាំងបីនេះ លេចធ្លោយ៉ាងច្បាស់តាមរយៈឧបកថា ( Episode ) នៅក្នុងជីវិតផ្ទាល់របស់ព្រះពុទ្ធ ។ ឧប្បត្តិហេតុនេះ ពុំមែនជាការចៃដន្យទេ ដែលគុណសម្បត្តិទាំងបីយ៉ាងនេះ មានតម្លៃស្មើនឹងការដល់ព្រះនិព្វាន ពិព្រោះ ដូចអស់លោកដឹងហើយថាមានកិលេស (សភាពមន្ទិលសៅហ្មង) បីយ៉ាង ដែលជាហេតុធ្វើឱ្យយើងកើតហើយកើតទៀត . នោះគឺ រាគៈ (desire), ព្យាបាទៈ (ill-will), និងអវិជ្ជា (ignorance) ។ នៅក្នុងបរិបទនេះ, យើងអាចចងចាំបានដែរថា អភិនិស្រ្កមណ៍ គឺជាគ្រឿងបំបាត់រាគៈ, មេត្តា និងករុណា គឺជាគ្រឿងបំបាត់ព្យាបាទ, ហើយបញ្ញា គឺជាគ្រឿងបំបាត់អវិជ្ជា ។ តាមរយៈការបណ្តុះនូវគុណធម៌បីយ៉ាងនេះ, បុគ្គលមានសមត្ថភាពកំចាត់នូវកិលេស ហើយសំរេចបាននូវការត្រាស់ដឹង ។ ដូច្នេះ វាពុំមែនជាការចៃដន្យទេ ដែលគុណធម៌ទាំងបីត្រូវបានលេចត្រដែតឡើងយ៉ាងច្បាស់ នៅក្នុងជីវិតរបស់ព្រះពុទ្ធ ។

ឥឡូវ ចូរយើងពិនិត្យមើលគុណធម៌ទាំងបីនោះម្តងមួយៗ ហើយចូរយើងចាប់ផ្តើមជាមួយអភិនិស្រ្កមណ៍ (renunciation) ។ ដូចដែលតែងកើតមានញឹកញយ, ភស្តុតាងខ្លះៗ នៃភស្តុតាងជាដំបូងៗ នៃការលះបង់ ដើម្បីចេញសាងផ្នួសរបស់ព្រះពុទ្ធបានស្តែងយ៉ាងច្បាស់ នៅពេលដែលព្រះអង្គមានវ័យក្មេង នៅឡើយ ។ ការលះបង់ដើម្បីចេញសាងផ្នួស គឺជាគ្រឹះនៃការទទួលស្គាល់ថា ជីវិតទាំងអស់គឺជាទុក្ខ ។ កាលណាបុគ្គលទទួលស្គាល់ហេតុការណ៍ ដែលថាជីវិតទាំងអស់ជាទុក្ខហើយ, វារមែងនាំមកនូវអ្វីដែលយើងអាចហៅថា ការបែរមុខទៅរកទិសថ្មី, និយាយម្យ៉ាងទៀត, គឺការឃើញថា ជីវិតនេះពោរពេញទៅដោយទុក្ខ ទើបបុគ្គលចាប់ផ្តើមស្វែងរកអ្វីមួយប្រសើរជាង ។ ព្រោះហេតុនោះ ទុក្ខ គឺជាអរិសច្ចៈទីមួយ ។

ការទទួលស្គាល់ថា ជីវិតជាទុក្ខ គឺជាខ្លឹមសារនៃការលះបង់ដើម្បីចេញសាងផ្នួស ។ អស់លោកអាចដឹងអំពីការយាងទតពិធីច្រត់ព្រះនង្គ័លប្រចាំឆ្នាំ របស់ព្រះអង្គម្ចាស់សិទ្ធាថ៌ នៅពេលព្រះអង្គមានព្រះជន្មប្រាំពីរវស្សា ។ គឺនៅទីនោះហើយ ពេលព្រះអង្គកំពុងតែទតមើលការភ្ជួរ, ព្រះអង្គបានទតឃើញជន្លេនមួយ ដែលនង្គ័លបានកាយឡើង ហើយត្រូវបានសត្វស្លាបមួយចឹកហែកស៊ី ។ ការទតឃើញនេះ បាននាំអោយព្រះអង្គម្ចាស់ពិចារណាឃើញការពិតនៃជីវិត, ស្គាល់ច្បាស់ហេតុពិតដែលថា សព្វសត្វមានជីវិត តែងសម្លាប់គ្នាទៅវិញទៅមកធ្វើជាអាហារ ហើយប្រការនេះ គឺជាប្រភពដ៏ធំនៃទុក្ខ ។ នៅពេលមានវ័យក្មេងខ្ចីក្នុងជីវប្បវត្តិរបស់ព្រះពុទ្ធ យើងឃើញរួចស្រេចហើយ នូវការចាប់ផ្តើមនៃការស្គាល់ច្បាស់ថា ជីវិត គឺជាទុក្ខ ។ ប្រសិនបើយើងមើលមកក្រោយបន្តិច, នៅក្នុងជីវិតរបស់ព្រះពុទ្ធ, យើងនឹងឃើញមានឧបកថាដ៏ល្បីល្បាញ ស្តីពីទស្សនីយភាពបួនយ៉ាង ដែលបានធ្វើអោយព្រះអង្គម្ចាស់មានព្រះទ័យតក់ស្លុត រហូតដល់លះបង់ជីវភាពជាគ្រហស្ថ ហើយប្រកាន់យកជីវភាពជាតាបស ដើម្បីស្វែងរកសច្ចធម៌ ។ ការឃើញវ័យជរា, ព្យាធិ, មរណៈ និងអ្នកបួសបាននាំអោយព្រះអង្គពិចារណាថា ព្រោះហេតុអ្វីបានជាព្រះអង្គត្រូវមានព្រះទ័យរសាប់រសល់, នោះក៏ព្រោះតែតាមការពិត ព្រះអង្គឯងផ្ទាល់ ក៏គេចមិនផុត ហើយត្រូវឋិតក្រោមវ័យជរា, ព្យាធិ និងមរណៈដែរ ។ ការពិចារណានេះ បានដឹកនាំព្រះអង្គអោយពង្រីកព្រះទ័យផ្តាច់ខ្លួនអំពីសេចក្តីសប្បាយ, នាំព្រះអង្គអោយស្វែងរកសច្ចធម៌ តាមមធ្យោបាយអភិនិក្ខ្រមណ៍ (ឬការលះបង់ចេញបួស) ។ គេត្រូវកត់សំគាល់ថា អភិនិក្ខ្រមណ៍របស់ព្រះអង្គម្ចាស់សិទ្ធាថ៌ មិនមែនជាការចេញបួសកើតមកពីការអស់សង្ឃឹមនោះទេ ។ ព្រះអង្គបានសេពសោយសុភមង្គលដ៏ធំធេង, ប៉ុន្តែ លុះបានទតឃើញនូវទុក្ខសោកនៃជីវិត, យល់ច្បាស់ថាបើទោះជាបុគ្គលសេពសោយសេចក្តីសប្បាយរីករាយ តាមផ្លូវវិញ្ញាណធំធេងប៉ុណ្ណា ក៏ដោយ ( កាមសុខល្លិកានុយោគ )

បុគ្គលក៏នឹងត្រូវប្រឈមមុខជាយថាហេតុ ចំពោះសេចក្ដីទុក្ខសោកដែរ ។ ដោយយល់ច្បាស់នូវរឿងនេះ, ព្រះអង្គបានមានព្រះទ័យតក់ស្លុត រហូតដល់លះបង់ជីវភាពជាគ្រហស្ថ ហើយស្វែងរកការត្រាស់ដឹង ដើម្បីជាគុណប្រយោជន៍ដល់សព្វសត្វមានជីវិត ។

បន្ទាប់មក ចូរយើងក្រឡេកមើលគុណសម្បត្តិនៃមេត្តា និងករុណា ។ ក្នុងទីនេះទៀត យើងអាចឃើញគុណសម្បត្តិនេះស្ដែងឡើងយ៉ាងឆាប់ពេកណាស់នៅក្នុងជីវិតរបស់ព្រះពុទ្ធ ។ ឧទាហរណ៍ដ៏គួរអោយចាប់អារម្មណ៍នេះ គឺឧបកថា ស្ដីពីសត្វហង្សត្រូវរបួស ។ យើងបានដឹងថា ព្រះអង្គហើយនិងទេវទត្ត ជាបងប្អូនជីដូនមួយរបស់ព្រះអង្គ កំពុងតែយាងលំហែនៅក្នុងសួនព័ទ្ធជុំវិញវាំង នៅពេលនោះ ទេវៈទត្តបានបាញ់ទម្លាក់សត្វហង្សមួយដោយស្នា និងព្រួញរបស់លោក ។ កុមារទាំងពីរបានរត់សំដៅទៅកន្លែងដែលហង្សបានធ្លាក់, ប៉ុន្តែ កុមារសិទ្ធាថិជាអ្នករត់លឿនជាងក៏បានមកដល់កន្លែងដែលសត្វហង្សត្រូវរបួសដេកនៅ ។ ព្រះអង្គរើសសត្វបក្សី ឱបក្នុងព្រះហស្ថ ហើយយកសត្វបក្សីនោះទៅចិញ្ចឹមថែទាំ, ប៉ុន្តែ អំពើនេះបានបង្កើតអោយមានប្រតិកម្មអំពីកុមារទេវទត្ត ដែលបានតវ៉ាថា សត្វបក្សី ត្រូវតែជារបស់ផងលោក ពិព្រោះលោកជាអ្នកបានបាញ់វាអោយធ្លាក់ ។ កុមារទាំងពីរអង្គ បាននាំជម្លោះនេះទៅជូនលោកអ្នកប្រាជ្ញខាងតុលាការ ដែលបានកាត់សេចក្ដីថា តាមច្បាប់ ជីវិតជារបស់អ្នក ណាដែលបានថែរក្សាវា, មិនមែនជារបស់អ្នកណាដែលបានបំផ្លាញវាទេ ។ ក្នុងទីនេះ យើងមានឧទាហរណ៍ដ៏ជាទីចាប់អារម្មណ៍ អំពីអាកប្បកិរិយានៃមេត្តា និងករុណារបស់ព្រះពុទ្ធ ។ អាកប្បកិរិយានេះ ដុះចេញដោយផ្ទាល់អំពីការយល់ដឹងច្បាស់ថា ធម្មជាតិនៃជីវិត គឺ *ទុក្ខ* ។ ពេលក្រោយមក បន្ទាប់ពីបានត្រាស់ដឹង, ព្រះពុទ្ធបានបន្តលាតត្រដាងនូវគុណសម្បត្តិនេះ, ដូចមានឧទាហរណ៍នៅក្នុងឧបកថាដ៏ល្បីល្បាញដែលនៅក្នុងនេះ ព្រះពុទ្ធបានចិញ្ចឹមបីបាច់ភិក្ខុតិស្សៈដែលមានអាពាធ ហើយអាពាធ

របស់លោកមានក្លិនអសោចិ៍ណាស់ រហូតដល់សមាជិកឯទៀតៗនៃសង្ឃ បានគេច ចេញពីលោក ។

ចូរយើងពិនិត្យមើល *បញ្ញា* ដែលជាគុណសម្បត្តិមួយ ក្នុងបណ្តាគុណៈ សម្បត្តិទាំងបីយ៉ាង ។ បញ្ញា គឺជាគុណធមិ ដ៏មានសារសំខាន់បំផុត ក្នុងចំណោម គុណសម្បត្តិទាំងបី ពិព្រោះ នៅទីបំផុតទៅគឺ *បញ្ញា* នេះហើយ ដែលបានរំលើងឫស គល់អវិជ្ជា ដ៏ជាមូលហេតុដេកត្រាំនៅនៃ *ទុក្ខ* ។ គេនិយាយថា បីដូចជាបុគ្គលកាត់ ផ្តាច់មែកនិងដើមនៃឈើមួយដើម ប៉ុន្តែ បើឫសរបស់ឈើនោះ មិនត្រូវបានគាស់ រំលើងទេ, មែកនិងដើមរបស់ឈើនោះនឹងដុះឡើងវិញ ។ ដូចគ្នានេះដែរ, បុគ្គល អាចបំបាត់រាគៈ (desire) តាមរយៈអភិនិស្រ្កមណ៍ ( ការលះបង់ទ្រព្យសម្បត្តិ លោកីយចេញសាងផ្នួស ), បំបាត់ព្យាបាទ' តាមរយៈមេត្តា និងករុណា, ប៉ុន្តែដរាប ណា អវិជ្ជាមិនទាន់បំបាត់បានទេ, រាគៈ និងព្យាបាទ អាចកើតមានឡើងវិញបាន ។

បញ្ញា អាចធ្វើឱ្យសំរេចបានជាបឋមតាមរយៈការធ្វើសមាធិ ។ យើងមាន ឧបកថាមួយទៀត ទាក់ទងនឹងជីវិតខាងដើមរបស់ព្រះពុទ្ធ ដែលនៅក្នុងនេះ យើង ឃើញមានការរីកចំរើនពីដំបូងអំពីជំនាញប្រមូលផ្តុំចិត្ត ហើយតាមពិតទៅ ឧបកថា នេះ បានកើតមានឡើងដំណាលគ្នានឹងព្រឹត្តិការណ៍ ដែលយើងបានពិចារណាមួយ ខណៈពេលកន្លងទៅទាក់ទងនឹងសត្វបក្សីហើយនិងជន្លេន ។ គេបាននិយាយថា ក្រោយពេលបានទតឃើញសត្វបក្សីហែកហួរស៊ីជន្លេន, ក្រោយពេលបានយល់ ច្បាស់នូវធម្មជាតិអពមង្គលនៃជីវិត, ព្រះយុវក្សត្រទ្រង់គង់ក្រោមម្លប់ដើមឈើមួយ ហើយចាប់ផ្តើមស្នឹងស្មាធិ៍ដោយសយម្ភូត ( ដោយឯកឯង ) ។ ព្រះអង្គបានសំរេច សមាធិថ្នាក់ទីមួយ តាមរយៈការប្រមូលផ្តុំចិត្តលើដំណើរដង្ហើមចូល និងដង្ហើម ចេញ ។ ដូច្នេះ យើងឃើញមានបទពិសោធន៍សមាធិនេះ តាំងពីនៅក្នុងជីវភាពដំបូង របស់ព្រះពុទ្ធម្ល៉េះ, ហើយពេលក្រោយមក ព្រះអង្គបានលះបង់ជីវភាពជាគ្រហស្ថ រួច

ធ្វើដំណើរស្វែងរកសច្ចធម៌ ។ មុខវិជ្ជាដំបូងមួយ ដែលព្រះអង្គបានខិតខំស្វែងរក គឺមុខវិជ្ជាប្រមូលផ្ដុំចិត្តហ្នឹងឯង ។ គេបាននិយាយថា ព្រះអង្គបានរៀនសូធ្យក្នុងសំណាក់គ្រូល្បីល្បាញពីររូបនៃសម័យកាលនោះគឺ អាឡារះកាលាមះ និងឧទកះរាមបុត្រ ។ ព្រះអង្គបានរៀនអំពីគ្រូទាំងពីរ នូវវិធីប្រមូលផ្ដុំចិត្ត ។ កាលពីសប្ដាហ៍មុនយើងបាននិយាយថា ក្នុងចំណោមវត្ថុដែលបានរកឃើញនៅមោហេន ជោដារោ និងហារប្ប៉ា គឺរូបភាពនៃបដិមាអង្គុយក្នុងឥរិយាបថធ្វើសមាធិ ។ យើងមានហេតុផលគ្រប់គ្រាន់ដើម្បីជឿថា វិធីធ្វើការប្រមូលផ្ដុំចិត្ត បានកើតមានតាំងតែពីសហស្សវត្សទី ៣ មុនគ.ស.ម្ល៉េះ ហើយគេសង្ស័យណាស់ថា គ្រូទាំងពីររូបនោះ គឺជាអ្នកជំនាញខាងប្រពៃណីប្រមូលផ្ដុំចិត្តនេះឯង ។ ប៉ុន្តែ យើងឃើញថាព្រះអង្គម្ចាស់បានចាកចោលគ្រូទាំងពីររូប ពិព្រោះ ព្រះអង្គបានយល់ថា សមាធិតែឯង មិនអាចបញ្ចប់ទុក្ខបានជារៀងរហូតទេ ។ ទស្សនះនេះ សំខាន់ណាស់ ពិព្រោះ ទោះបីនៅក្នុងពុទ្ធ-សាសនា គេបានអោយតម្លៃលើការធ្វើចិត្តអោយរីកចំរើនក៏ដោយ ក៏ពុទ្ធសាសនានៅតែឋិតរឹងមាំនៅក្នុងប្រពៃណីនៃអារ្យធម៌ជ្រលងទន្លេឥណ្ឌុស, ហើយព្រះពុទ្ធបានយាងទៅហួសប្រពៃណីធ្វើសមាធិសុទ្ធសាធថែមទៀត ។ នេះគឺជាកត្តាដែលធ្វើអោយពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខុសប្លែកពីពាក្យប្រៀនប្រដៅរបស់និកាយសាសនាឥណ្ឌាផ្សេងៗទៀតជាច្រើន, ជាពិសេស ពាក្យប្រៀនប្រដៅនៃប្រពៃណីយោគៈ ។ នេះទៀត ក៏ជាកត្តាមួយ ដែលធ្វើអោយពុទ្ធសាសនា ខុសប្លែកពីប្រពៃណីស្មឹងស្មាធិ៍របស់សាសនាផ្សេងៗខ្លះ, ពិព្រោះ ក្នុងព្រះពុទ្ធសាសនា សមាធិតែឯកឯងពុំទាន់គ្រប់គ្រាន់ទេ ។ សមាធិ គឺប្រៀបដូចការសម្រួចខ្មៅដៃ, ឯការសម្រួចចិត្តក៏ដូច្នោះដែរ ។ កាលណាយើងសម្រួចខ្មៅដៃមួយ យើងសម្រួចវាសម្រាប់គោលបំណងមួយ គឺដើម្បីយើងអាចសរសេរដោយខ្មៅដៃនោះបាន, ដូចគ្នានេះដែរ ក្នុងការសម្រួចចិត្ត យើងមានគោលបំណងមួយ ហើយគោលបំណងនោះគឺ ដើម្បីបាន

បញ្ញា ។ មានពេលខ្លះ ទំនាក់ទំនងរវាងសមាធិ និងបញ្ញានេះ ត្រូវបានប្រៀបជាឧទាហរណ៍ដោយភ្លើងចន្លុះ ។ ចូរសន្មតថា យើងចង់មើលរូបភាពមួយ នៅក្នុងបន្ទប់ងងឹតមួយដោយប្រើពន្លឺភ្លើងចន្លុះ ។ ប្រសិនបើមានចរន្តខ្យល់ច្រើនបក់ចូលទៅក្នុងបន្ទប់, យើងនឹងឃើញថា ពន្លឺចន្លុះនឹងពព្រិចភ្លឹបភ្លែតៗ ។ ដូចគ្នានេះដែរ, ប្រសិនបើដៃរបស់យើងញ័រទទ្រើក, ពន្លឺជះចេញពីភ្លើងចន្លុះ នឹងមិននៅនឹងនបានទេ, ហើយយើងក៏មិនអាចមើលឃើញរូបភាពបានច្បាស់ដែរ ។ តាមគន្លងនេះដូចគ្នា ប្រសិនបើយើងចង់ចាក់ធ្លុះទៅក្នុងធម្មជាតិពិតនៃវត្ថុទាំងឡាយ, ប្រសិនបើចិត្តរបស់យើងមិននឹងន, រាយមាយ, វិលវល់ ដោយបណ្ដាលមកពីវិបត្តិផ្លូវអារម្មណ៍, ពេលនោះ យើងនឹងមិនអាចចាក់ធ្លុះទៅក្នុងធម្មជាតិពិតនៃវត្ថុទាំងឡាយបានទេ ។ ព្រះពុទ្ធបានអនុវត្តការរកឃើញនេះ នៅក្នុងរាត្រីនៃការត្រាស់ដឹងរបស់ព្រះអង្គ នៅពេលដែលគេនិទានប្រាប់យើងថា ដោយព្រះអង្គមានព្រះទ័យប្រមូលផ្ដុំបានល្អ, មុតស្រួច ហើយបត់បែនបានតាមរយៈសមាធិ, ព្រះអង្គបានតម្រង់ព្រះទ័យឆ្ពោះទៅរកការស្វែងយល់នូវធម្មជាតិនៃសេចក្ដីពិត ហើយបានចាក់ធ្លុះទៅក្នុងធម្មជាតិពិតនៃវត្ថុទាំងឡាយ ។ ដូច្នេះ ការត្រាស់ដឹងរបស់ព្រះពុទ្ធ គឺជាលទ្ធផលផ្ទាល់ នៃការផ្សំផ្គុំសមាធិ និងបញ្ញានេះឯង ពោលគឺ ការប្រមូលផ្ដុំចិត្ត (សមថៈ) និងការយល់ចាក់ធ្លុះ (វិបស្សនា) ។

យើងឃើញផងដែរ នូវទិដ្ឋភាពផ្សេងៗទៀតនៃបញ្ញា ដែលស្ដែងឡើងនៅក្នុងជីវភាពនៃព្រះពុទ្ធ, ហើយទិដ្ឋភាពមួយ ក្នុងបណ្ដាទិដ្ឋភាពសំខាន់ៗបំផុត គឺមជ្ឈិមបដិបទា (ផ្លូវកណ្ដាល) នោះឯង ។ ថ្ងៃនេះ យើងមិនមានពេលដើម្បីពិចារ-ណាអត្ថន័យគ្រប់កំរិតផ្សេងៗ នៃមជ្ឈិមបដិបទាបានទេ, ប៉ុន្តែ គ្រាន់តែនិយាយថាខ្លឹមសារនៃមជ្ឈិមបដិបទា ដ៏ជាមូលដ្ឋានបំផុតនោះ គឺការវៀរចាកអច្ចន្តភាព (the extreme) នៃការត្រេកត្រអាលក្នុងសេចក្ដីសប្បាយតាមផ្លូវវិញ្ញាណ (senses) (កាមសុខល្លិកានុយោគ), និងអច្ចន្តភាពនៃការធ្វើអោយរូបកាយឈឺចាប់ (អត្តកិល-

មថានុយោគ) ។ មជ្ឈិមបដិបទា ឬផ្លូវកណ្ដាល ត្រូវបានបង្ហាញជាឧទាហរណ៍ នៅក្នុងជីវិតរបស់ព្រះពុទ្ធ តាមការពិសោធន៍ផ្ទាល់របស់ព្រះអង្គនៅក្នុងជីវភាពដ៏ប្រណីតជាព្រះអង្គម្ចាស់មួយអង្គ និងតាមការប្រព្រឹត្តតបះ (ascetism) យ៉ាងតឹងរ៉ឹងអស់ពេលប្រាំមួយឆ្នាំ ដែលព្រះអង្គបានអនុវត្ត ក្រោយពេលព្រះអង្គបានចាកចោលប្រាសាទរបស់បិតាព្រះអង្គ ។ បន្ទាប់ពីបានជ្រាបច្បាស់នូវភាពឥតខ្លឹមសារនៃអច្ចន្ត-ភាពក្នុងការពិសោធន៍ផ្ទាល់របស់ព្រះអង្គហើយ, បន្ទាប់មក ព្រះអង្គក៏បានរកឃើញមាគ៌ាកណ្ដាល (មជ្ឈិមបដិបទា) ដែលជៀសវាងបានពីអច្ចន្តភាពទាំងពីរនោះ ។

នៅមានឧបកថាសំខាន់ៗជាច្រើនទៀត ទាក់ទងនឹងជីវភាពរបស់ព្រះពុទ្ធ ។ ប៉ុន្តែ ប្រសិនបើយើងអាចផ្ដើមមើលឃើញ និងយល់បាននូវជីវិតរបស់ព្រះពុទ្ធទុកជាមេរៀនមួយ ហើយមិនមែនជាជីវិតសាមញ្ញ ទុកដូចជាជីវប្បវត្តិមួយមានឈ្មោះ មានទីកន្លែងមួយចំនួននោះទេ, ប្រសិនបើយើងអាចផ្ដើមកោតសរសើរតម្លៃ និងគុណ-សម្បត្តិទាំងឡាយដែលជាគំរូ ឬឧទាហរណ៍ នៅក្នុងជីវិតរបស់ព្រះពុទ្ធនោះ, យើងនឹងសន្សំបាននូវទស្សនៈយល់ដឹងដ៏ធំធេងនៅក្នុងអត្ថន័យពិតនៃជីវិតរបស់ព្រះពុទ្ធ ។

* * *

( III )

## អរិយសច្ចៈបួន . ភាគទី ១

នេះគឺជាឧទ្ទេសកថាទីបី នៅក្នុងចង្កោមឧទ្ទេសកថាទាំងឡាយ ហើយយើងកំពុងចូលមកក្នុងខ្លឹមសារពិត នៃពុទ្ធសាសនាជាមួយនឹងឧទ្ទេសកថាថ្ងៃនេះពិព្រោះ នៅក្នុងពេលប្រហែលមួយម៉ោងក្រោយនេះ ខ្ញុំសូមនិយាយរៀបរាប់អំពីអរិយសច្ចៈបួន ។

អរិយសច្ចៈបួន គឺជាទិដ្ឋភាពមួយ ដ៏មានសារសំខាន់ណាស់ នៃព្រះធម៌ (ពាក្យប្រៀនប្រដៅ) របស់ព្រះពុទ្ធ ។ សារសំខាន់របស់អរិយសច្ចៈបួន ត្រូវបានព្រះពុទ្ធអង្គសំដែងក្នុងពុទ្ធដីកាយ៉ាងច្បាស់លាស់ ។ ព្រះអង្គទ្រង់មានពុទ្ធដីកាថា គឺដោយសារតែយើងមិនអាចយល់ដឹងនូវអរិយសច្ចៈទាំងបួននោះហើយ ទើបយើងបានត្រាច់រង្គាត់អស់កាលដ៏យូរលង់ នៅក្នុងវដ្តសង្សារនៃការកើតនិងស្លាប់ ។ ពុទ្ធដីកានេះចង្អុលប្រាប់ថា តើអរិយសច្ចៈទាំងបួនមានសារសំខាន់យ៉ាងណា ចំពោះការយល់ដឹងនូវព្រះធម៌របស់ព្រះពុទ្ធ និងចំពោះការដឹងច្បាស់នូវគោលដៅនៃព្រះធម៌របស់ព្រះពុទ្ធ ។ ដូចគ្នានេះដែរ វាពុំមែនជាការចៃដន្យទេ ដែលនៅក្នុងការទេសនាដំបូងរបស់ព្រះពុទ្ធ គឺធម្មចក្កប្បវត្តនសូត្រ ចំពោះភិក្ខុទាំងប្រាំអង្គ (បញ្ចវគ្គិយភិក្ខុ) នៅឱទ្យានសត្វក្ដាន់ ជិតក្រុងប៉េណារ៉េស (Benares), ព្រះពុទ្ធទ្រង់បានទេសនាជាដំបូង នូវអរិយសច្ចៈបួន និងមជ្ឈិមបដិបទា ។ នៅទីនោះ, យើងឃើញមានការកត់សំគាល់ ដ៏សំខាន់ពីរយ៉ាងស្ដីពីសារសំខាន់ នៃអរិយសច្ចៈទាំងបួន ។ អរិយសច្ចៈបួនក្នុងន័យនេះ គឺជាសេចក្ដីសង្ខេបនៃព្រះធម៌របស់ព្រះពុទ្ធ អំពីទស្សនវិស័យនៃទ្រឹស្ដី ហើយនិងអំពីទស្សនវិស័យនៃការអនុវត្តន៍ ឬការប្រតិបត្តិ ។ ដូច្នេះ នៅក្នុងទីនេះ អរិយសច្ចៈបួន គឺមានសច្ចៈនៃទុក្ខ (ទុក្ខសច្ចៈ), សច្ចៈអំពីហេតុនៃទុក្ខ (ទុក្ខសមុទយសច្ចៈ), សច្ចៈអំពី

ការបញ្ចប់ទុក្ខ (ទុក្ខនិរោធសច្ចៈ), និងសច្ចៈអំពីផ្លូវនាំទៅរកការបញ្ចប់ទុក្ខ (មគ្គសច្ចៈ), យើងមានគ្រឹះនៃព្រះធម៌របស់ព្រះពុទ្ធ សម្រាប់ការយល់ដឹង និងការអនុវត្តន៍ ។

មុនយើងពិចារណាអំពីអរិយសច្ចៈទាំងបួនដោយឡែក១ពីគ្នា, ខ្ញុំសូមនិយាយបន្តិចអំពីចរិតនៃការរៀបចំបួង់ ដែលអរិយសច្ចៈទាំងបួនត្រូវបានរៀបរាប់, ហើយនៅក្នុងបរិបទនេះ ប្រហែលជាយើងអាចនឹកឃើញថា វិទ្យាសាស្ត្រខាងពេទ្យបានទទួលនូវការរីកចំរើនមួយចំនួនណានោះរួចហើយ នៅក្នុងប្រទេសឥណ្ឌាសម័យបុរាណ ។ រចនាសម្ពន្ធមួយ ក្នុងបណ្តារចនាសម្ពន្ធទាំងឡាយដែលបានទទួលការរីកចំរើនដោយវិទ្យាសាស្ត្រខាងពេទ្យនៅក្នុងប្រទេសឥណ្ឌាបុរាណ នោះគឺរចនាសម្ពន្ធបួនយ៉ាងស្តីពី : រោគ, រោគវិនិច្ឆ័យ, ការជាសះស្បើយ និងការព្យាបាល ។ ឥឡូវ បើលោកអ្នកគិតគូរដោយល្អិតល្អន់ អំពីជំហានបួនយ៉ាងនេះ នៅក្នុងការអនុវត្តន៍របស់វេជ្ជសាស្ត្រ, ពោលគឺ ការអនុវត្តន៍វិធីព្យាបាលជំងឺ, លោកអ្នកនឹកឃើញថា ជំហានបួនយ៉ាងសម្រាប់អនុវត្តន៍ក្នុងវេជ្ជសាស្ត្រនោះ គឺស្របគ្នាបេះបិទទៅនឹងអរិយសច្ចៈទាំងបួន ។ និយាយម្យ៉ាងទៀត, ទុក្ខៈ ស្របទៅនឹងរោគ ឬជំងឺ, ហេតុនៃទុក្ខ ស្របគ្នានឹងរោគវិនិច្ឆ័យ, ពោលគឺ ការកំណត់ដឹងច្បាស់នូវមូលហេតុជំងឺ, ការបញ្ចប់នូវទុក្ខស្របគ្នានឹងការជាសះស្បើយ, ហើយមាគ៌ានាំទៅកាន់ការបញ្ចប់ទុក្ខ ស្របគ្នានឹងការព្យាបាល តាមរយៈការព្យាបាលនេះ អ្នកជំងឺបានជាសះស្បើយចាករោគាពាធ ។

ឥឡូវ ក្រោយពេលបាននិយាយរួចហើយ អំពីចរិតនៃវិធីព្យាបាលរោគរបស់អរិយសច្ចៈបួន ហើយនិងដំណាក់ទាំងឡាយ ដែលអរិយសច្ចៈទាំងបួនតំណាង, ខ្ញុំសូមនិយាយអំពីអ្វីមួយដែលមានចរិតជាទ្រឹស្តីបន្តិច ប៉ុន្តែថា វាមានសារសំខាន់ណាស់ សម្រាប់ការយល់ដឹងត្រឹមត្រូវនូវអរិយសច្ចៈទាំងបួន ។ កាលដែលសារីបុត្រជាសាវ័កមួយអង្គ ក្នុងបណ្តាសាវ័កដ៏សំខាន់បំផុតរបស់ព្រះពុទ្ធ បានជួបព្រះអស្សជិត ( ដែលជាភិក្ខុមួយអង្គ ក្នុងក្រុមបញ្ចវគ្គិយភិក្ខុ ដែលព្រះពុទ្ធទ្រង់បានសំដែងបឋម-

ទេសនាប្រោស ), ហើយបានសួរចំពោះព្រះអស្សជិតអំពីព្រះធម៌របស់ព្រះពុទ្ធ ។ ព្រះអស្សជិតមានថេរដីកាតបថា : « អាត្មាភាព មិនអាចប្រាប់លោកអោយល្អិតល្អន់បានទេ ពិព្រោះអាត្មាភាព ក៏ជាអ្នកថ្មីចំពោះព្រះធម៌ដែរ តាមការប្រៀបធៀប, ប៉ុន្តែអាត្មាភាព នឹងប្រាប់លោកដោយសង្ខេបខ្លីបាន » ។ ឮដូច្នោះ សារីបុត្រក៏បានពោលថា « ល្អហើយ, សូមលោកម្ចាស់ប្រាប់មកខ្ញុំព្រះករុណាដោយសង្ខេបចុះ, » ហើយព្រះអស្សជិត ក៏មានថេរដីកាតបវិញជាមួយនឹងសេចក្តីសង្ខេបដ៏ខ្លីនៃព្រះធម៌ របស់ព្រះពុទ្ធ ដែលមានដូចតទៅនេះ : - បណ្តាវត្ថុទាំងឡាយដែលកើតចេញមកពីហេតុ, ហេតុរបស់វា ព្រះតថាគតបានសំដែងប្រាប់ហើយ, ឯការបញ្ឈប់របស់វា ក៏ព្រះតថាគតទ្រង់បានសំដែងប្រាប់ហើយដែរ ។ ដោយប្រការដូច្នេះ, ព្រះមហាមុនីទ្រង់បានប្រៀនប្រដៅ ។ សារីបុត្របានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះសេចក្តីសង្ខេបនេះ, ហើយក៏បានដើរទៅរកមោគ្គល្លាន ដ៏ជាមិត្តរបស់ខ្លួន, រួចអ្នកទាំងពីរ នៅពេលក្រោយបន្តិចមក បានចូលបួសក្នុងជួរសង្ឃ ហើយប្រែក្លាយជាសាវ័កដ៏លេចធ្លោរបស់ព្រះពុទ្ធ ។ សេចក្តីសង្ខេបនៃព្រះធម៌របស់ព្រះពុទ្ធនេះ ប្រាប់ដល់យើងនូវអ្វីមួយអំពីបញ្ញត្តិ ( គំនិត ) ស្នូល ដែលកប់នៅពីក្រោយអរិយសច្ចៈទាំងបួន ។ វាចង្អុលប្រាប់នូវសារសំខាន់នៃទំនាក់ទំនងរវាងហេតុ និងផល ។ គំនិតស្តីពីហេតុ និងផល ឋិតនៅជាស្នូលនៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយក៏ឋិតនៅជាស្នូលនៃអរិយសច្ចៈទាំងបួនដែរ ។ ឥឡូវ តើនៅក្នុងន័យដូចម្តេច ? និយាយដោយចំទៅ វាមានចំណុចចាប់ផ្តើមមួយ, គឺបញ្ហានៃទុក្ខ ។ បញ្ហានេះ កើតចេញមកពីហេតុទាំងឡាយ ។ នៅទីអវសាន ដោយសារថា វាមានទុក្ខ, វាមានហេតុនៃទុក្ខ, ដូច្នេះ វាក៏មានទីបំផុតនៃទុក្ខ និងមានហេតុដើម្បីបញ្ចប់ទុក្ខដែរ ។ នៅក្នុងករណីនេះ វាមានដំណើរមួយបញ្ច្រាសទិសទៅវិញ ។ វាមានន័យថា, ពេលណាហេតុនៃទុក្ខ ត្រូវបានគេយកចេញ, ពេលនោះ ទុក្ខក៏ចប់ដែរ ។

ប្រសិនបើលោកអ្នកក្រឡេកមើលអរិយសច្ចៈបួន លោកអ្នកអាចឃើញថា អរិយសច្ចៈបួន ចែកចេញជាពីរក្រុមទៅតាមចរិតធម្មតា ។ អរិយសច្ចៈពីរដំបូងគេ គឺ ទុក្ខ និងហេតុនៃទុក្ខ ( ទុក្ខសមុទយៈ ) ឋិតនៅក្នុងក្រុមកើត និងស្លាប់ ។ ជានិមិត្ត-រូប, កើត និងស្លាប់ អាចត្រូវបានបង្ហាញអោយឃើញជារង្វង់មូល, ក្នុងន័យថា ការកើត និងការស្លាប់ មានចលនាមូល ។ ហេតុនៃទុក្ខ នាំទៅរកទុក្ខ, ទុក្ខបង្កើតអោយមានហេតុនៃទុក្ខ, ហេតុនៃទុក្ខបង្កើតអោយមានទុក្ខជាថ្មីទៀត ។ ទុក្ខ និងហេតុនៃទុក្ខ មានចលនារង្វង់មូល ។ ទាំងពីរនេះជារបស់សង្សារ ។ អរិយសច្ចៈពីរខាងក្រោយ គឺការបញ្ចប់ទុក្ខ និងមាគ៌ាបញ្ចប់ទុក្ខ អាចបង្ហាញជានិមិត្តរូប ក្នុងរូបភាពជាចលនាស្ពៀរ៉ាល់ ( spiral ) ។ ចលនាលែងទៅជាចលនាមូលទៀតហើយ ។ ឥឡូវ, ចលនា នេះតម្រង់ទិសឡើងលើ ។ ប្រសិនបើយើងរក្សាទុកនូវរចនាសម្ពន្ធនេះ ( structure ), គឺគំនិតស្ដីពីហេតុ និងផល នៅខាងក្នុងចិត្តរបស់យើង កាលណាយើងក្រឡេកមើលអរិយសច្ចៈបួន, ខ្ញុំគិតថា យើងអាចឃើញអរិសច្ចៈទាំងបួនងាយស្រួលយល់បានជាង ។ ដូចគ្នានេះដែរ, ប្រសិនបើយើងចងចាំគោលការណ៍នៃហេតុ និងផល, វានឹងមានតម្លៃយ៉ាងធំសម្រាប់យើង នៅពេលយើងបន្តការសិក្សាព្រះធម៌របស់ព្រះពុទ្ធ កាលណាយើងត្រូវពិចារណាអំពីកម្ម និងការកើតទៀត ឬកាលណាយើងត្រូវពិចារណាអំពីបដិច្ចសមុប្បាទ ( Dependent origination ) ។ និយាយដោយខ្លីទៅ, ព្រះធម៌របស់ព្រះពុទ្ធតាំងដើមដល់ចប់ យើងនឹងឃើញថា គោលការណ៍ហេតុ និងផល តែងរត់ទៅមុខដូចជាចេសដូច្នេះ ។

ឥឡូវ ចូរយើងពិនិត្យអរិយសច្ចៈទីមួយ ក្នុងចំណោមអរិយសច្ចៈបួន គឺទុក្ខសច្ចៈ ។ អ្នកមិនកាន់ពុទ្ធសាសនា ហើយសូម្បីតែអ្នកកាន់ពុទ្ធសាសនាជាច្រើន ក៏មានអារម្មណ៍ទើសទាល់ ដោយសារការជ្រើសរើសយក ទុក្ខ ធ្វើជាអរិយសច្ចៈទីមួយក្នុងបណ្ដាអរិយសច្ចៈទាំងបួនដែរ, ហើយមនុស្សជាច្រើន បាននិយាយថា នេះគឺជា

សញ្ញានៃទុទិដ្ឋិនិយម ។ ខ្ញុំតែងជួបពួកអ្នកមិនជឿពុទ្ធសាសនានិយាយមកកាន់ខ្ញុំជាញឹកញាយថា « ហេតុអ្វីក៏ពុទ្ធសាសនាទុទិដ្ឋិនិយមម្ល៉េះ ? ហេតុអ្វីក៏ពុទ្ធសាសនាចាប់ផ្តើមពីទុក្ខ ហើយផ្តោតលើទុក្ខ ? » មានចម្លើយមួយចំនួនចំពោះសំណួរនេះ ។ ក្នុងចំណោមអស់លោក, មានអ្នកខ្លះអាចស៊ាំនឹងការវែកញែកអោយឃើញប្លែកគ្នារវាងទុទិដ្ឋិនិយម, សុទិដ្ឋិនិយម, ហើយនិងតថនិយម ( ពិតនិយម ) រួចហើយ ។ ឥឡូវចូរយើងនិយាយបែបនេះវិញ ។ ប្រសិនបើអ្នកណាមួយមានទុក្ខដោយសារជំងឺហើយគេប្រកែកមិនទទួលស្គាល់ការណ៍ពិតថា គេមានជំងឺ, នេះមិនមែនជាសុទិដ្ឋិ-និយមទេ, នេះគឺជាមនុស្សឆ្កួតសុទ្ធសាធ ។ រឿងនេះ ដូចគ្នានឹងសត្វអូទ្រីសកប់ក្បាលវានៅក្នុងដីខ្សាច់ដូច្នោះ ។ ប្រសិនបើមានបញ្ហាណាមួយ, រឿងតែមួយគត់ ត្រូវយកចិត្តគិតគូរធ្វើគឺ ទទួលស្គាល់បញ្ហា ហើយពិចារណាមើលថា តើត្រូវធ្វើអ្វីដើម្បីបំបាត់បញ្ហានោះ ។ ទីពីរ, ប្រសិនបើព្រះពុទ្ធបានបង្រៀនតែសច្ចៈនៃទុក្ខតែប៉ុណ្ណោះ ហើយទ្រង់បានបញ្ឈប់ត្រឹមប៉ុណ្ណោះ, បន្ទាប់មកវាអាចមានការពិតខ្លះក្នុងការចោទប្រកាន់ថា ព្រះធម៌របស់ព្រះពុទ្ធជា ទុទិដ្ឋិនិយម ។ ប៉ុន្តែព្រះធម៌របស់ព្រះពុទ្ធមិនបានបញ្ចប់ត្រឹមសច្ចៈនៃទុក្ខទេ, ពិព្រោះ ព្រះពុទ្ធបានប្រៀនប្រដៅមិនត្រឹមតែសច្ចៈនៃទុក្ខទេ ប៉ុន្តែព្រះអង្គបានប្រៀនប្រដៅអំពីសច្ចៈនៃហេតុរបស់វា ហើយសំខាន់ជាងនេះទៀត នៅក្នុងបរិបទនេះ គឺសច្ចៈនៃការបញ្ចប់ទុក្ខថែមទៀត ។

ខ្ញុំជឿថា, យើងទាំងអស់, ប្រសិនបើយើងស្មោះត្រង់ចំពោះខ្លួនយើង, ត្រូវហ៊ានទទួលថា យើងមានបញ្ហាជាមូលដ្ឋានជាមួយជីវិត ។ ហេតុការណ៍ទាំងឡាយមិនមែនសុទ្ធតែដូចជាវាអាចនឹងកើតមានទេ ។ ហេតុការណ៍ខ្លះ នៅក្នុងទីកន្លែងខ្លះមិនមែនសុទ្ធតែត្រឹមត្រូវទេ ។ ហើយបើទោះជាយើងខិតខំយ៉ាងណាដើម្បីរត់ចេញពីបញ្ហា, នៅពេលណាមួយក៏ដោយ, អាចនៅពេលពាក់កណ្តាលអធ្រាត្រ, ឬអាចនៅក្នុងហ្វូងមនុស្ស, ឬក៏អាចនៅក្នុងពេលគេកំពុងធ្វើការ, យើងក៏នៅតែប្រឈមមុខ

ផ្ទាល់ចំពោះខ្លួនយើងផងដែល, ការដឹងច្បាស់ថា ហេតុការណ៍ទាំងឡាយ មិនមែនសុទ្ធតែទាំងអស់ វាដូចតែវានឹងអាចកើតមាននោះឡើយ, ហេតុការណ៍ខ្លះ អាចនឹងខុសនៅត្រង់ចំណុចណាមួយ ។ នេះហើយ គឺជាអ្វីដែលតាមការពិត, តម្រូវអោយមនុស្សខិតខំស្វែងរកការដោះស្រាយ ។ មនុស្សអាចខំស្វែងរកការដោះស្រាយក្នុងហេតុការណ៍ផ្នែកសម្ភារៈខ្លាំងជាង ឬគេអាចស្វែងរកការដោះស្រាយនៅក្នុងវិធីព្យាបាលផ្សេងៗវិញ ។

នៅក្នុងពុទ្ធសាសនា, ជាពិសេស សច្ចៈនៃទុក្ខ អាចត្រូវបានគេបែងចែកចេញជាពីរប្រភេទ, និយាយដោយទូលំទូលាយទៅ, គឺរូបកាយ និងចិត្ត ( physical and mental ) ។ ក្នុងទីនេះ, សេចក្តីទុក្ខខាងរូបកាយ គឺជាសេចក្តីទុក្ខ បណ្តាលមកពីការកើត ( ជាតិ ), វ័យចាស់គ្រាំគ្រា ( ជរា ), ជំងឺតម្កាត់ ( ព្យាធិ ), ការស្លាប់ ( មរណៈ ) ។ លោក - អ្នកអាចរំលឹកឃើញថា កាលពីសប្តាហ៍មុន យើង ក៏បាននិយាយអំពីព្រះពុទ្ធ បានប្រទះឃើញ ព្យាធិ, ជរា, និងមរណៈ នៅក្នុងទ្រង់ទ្រាយនៃទិដ្ឋភាពបីយ៉ាងគឺ : - មនុស្សឈឺ, មនុស្សចាស់គ្រាំគ្រា និងសាកសព ។ ក្នុងទីនេះយើងឃើញមានទុក្ខទីបួន គឺទុក្ខនៃការកើត ( ជាតិទុក្ខ ) ។ ការកើត គឺជាទុក្ខដោយសារការឈឺចាប់ខាងផ្លូវកាយដែលទារកត្រូវទទួល ហើយដោយសារការកើតតម្រូវអោយកើតមានសេចក្តីទុក្ខព្រួយដទៃទៀត ។ ការកើតក្នុងន័យជាច្រកទ្វារនាំទៅកាន់សេចក្តីទុក្ខព្រួយដទៃទៀតនៃព្យាធិ, ជរា, និងមរណៈ ដែលហូរតាមមកចៀសមិនផុតក្រោយការកើត ។ ខ្ញុំគិតថា គេស្ទើរតែមិនចាំបាច់ចំណាយពេលច្រើន ស្តីពីសេចក្តីទុក្ខដោយជំងឺ, ជរា និងមរណៈទេ ។ ភាគច្រើននៃយើងទាំងអស់គ្នា ធ្លាប់មានបទពិសោធន៍នៃសេចក្តីទុក្ខដោយជំងឺ ហើយយើងក៏បានសង្កេតឃើញដែរ នូវសេចក្តីទុក្ខ នៃជំងឺនៅក្នុងខ្លួនប្រាណមិត្តភ័ក្តិ និងញាតិសន្តានរបស់យើង ។ យើងទាំងអស់គ្នាបានសង្កេតឃើញសេចក្តីទុក្ខនៃវ័យជរា, គឺអសមត្ថភាពដើម្បីធ្វើ

ការងារ, ដើម្បីបំពេញមុខងារ និងដើម្បីត្រិះរិះដោយឥតភ្លេចភ្លាំង ។ យើងទាំងអស់គ្នាបានសង្កេតឃើញសេចក្ដីទុក្ខនៃការស្លាប់, ការឈឺចាប់ និងការភិតភ័យ ដែលអ្នកជិតស្លាប់បានទទួល ។ សេចក្ដីទុក្ខសោកទាំងអស់នេះ គឺជាផ្នែកមួយនៃជីវិត ដែលមិនអាចគេចផុត ។ បើទោះជាជីវិតរបស់យើងជួបប្រទះនឹងសុភមង្គល និងសេចក្ដីសប្បាយប៉ុណ្ណាក៏ដោយ, សេចក្ដីទុក្ខនៃការកើត, វ័យចាស់គ្រាំគ្រា, ជំងឺតម្កាត់ និងសេចក្ដីស្លាប់ យើងពុំអាចគេចផុតជាដាច់ខាត ។

បន្ថែមពីលើសេចក្ដីទុក្ខខាងរូបកាយនេះទៀត នៅមានសេចក្ដីទុក្ខខាងផ្លូវចិត្តទៀត ។ វាមានសេចក្ដីទុក្ខបណ្ដាលមកពីការព្រាត់ប្រាសពីមនុស្សទាំងឡាយជាទីស្រឡាញ់របស់យើង, ការព្រាត់ប្រាសកើតមកពីហេតុផលនៃការងារ ឬពីព្រោះមនុស្សទាំងនោះ ដែលយើងស្រឡាញ់បានស្លាប់ ឬក៏ពីព្រោះមនុស្សដែលយើងស្រឡាញ់ទាំងនោះ បានធ្វើដំណើរទៅឆ្ងាយ, ឬក៏ពីព្រោះយើងត្រូវចាកចេញឆ្ងាយពីគេទាំងនោះ ។ រួចមក ក៏មានសេចក្ដីទុក្ខនៃការរស់នៅជាមួយមនុស្សដែលយើងមិនចូលចិត្ត ឬស្អប់ ឬមនុស្សដែលមិនចូលចិត្ត ឬស្អប់យើង ។ យើងអាចលើកយកទ្រង់ទ្រាយតូចតាចមួយចំនួន ដូចជា អ្នករួមការងារម្នាក់ ដែលជាអ្នកប្រឆាំងយើង ហើយយើងក៏ភ័យខ្លាចមិនចង់ហ៊ានទៅធ្វើការ ពិព្រោះយើងដឹងថា មនុស្សនេះដែលយើងមិនចូលចិត្តដោយប្រការណាមួយនោះ, តែងតែចង់ស្វែងរកកំហុសចំពោះយើងជានិច្ច ។ យើងអាចលើកយកទ្រង់ទ្រាយធំដុំមួយចំនួន ដូចជាការធ្វើទុក្ខបុកម្នេញ, ធ្វើទារុណកម្មជាអាទិ៍ ។ ជាទីអវសាន, វាមានសេចក្ដីទុក្ខដោយភាពខុសបំណង, ពេលណាយើងមិនអាចបាននូវអ្វីដែលយើងចង់បាន, កាលណាយើងមិនអាចបានការងារនោះ, ឋានៈនោះដែលយើងចង់បាន, កាលណាយើងមិនអាចយកឈ្នះបានលើមនុស្សនេះ, ឬមនុស្សនោះ ។ សេចក្ដីទុក្ខខាងផ្លូវរូបកាយ និងចិត្តនេះបានត្របាញ់ចាក់ស្រេះចូលគ្នាទៅជាបណ្ដាញនៃអត្ថិភាព ( ជីវិត ) របស់យើង ។

ប៉ុន្តែ ចុះសុភមង្គលវិញយ៉ាងម៉េចដែរ ? តើគ្មានសុភមង្គល ឬសេចក្ដីសប្បាយរីករាយក្នុងជីវិតទេឬ ? តាមពិត គឺមាន ។ ប៉ុន្តែសេចក្ដីសប្បាយ ឬសុភមង្គលដែលយើងបានក្រេបនៅក្នុងជីវិតនេះ គឺមិនឋិតថេរទេ ( គឺជាអនិច្ចៈ ) ។ យើងអាចក្រេបសេចក្ដីសប្បាយអំពីស្ថានភាពជាទីរីករាយ, យើងអាចក្រេបសេចក្ដីសប្បាយអំពីការកំដររបស់មនុស្សណាមួយដែលយើងស្រឡាញ់, យើងអាចក្រេបសេចក្ដីសប្បាយនៃយុវ័យ និងសុខភាពល្អ, ប៉ុន្តែទ្រង់ទ្រាយទាំងអស់នេះ នៃសុភមង្គល គឺជាអនិច្ចៈ ។ ឆាប់ ឬយូរ យើងនឹងទទួលរងនូវទុក្ខ ។

ប្រសិនបើយើងប្រាថ្នាដោយពិតប្រាកដ ដើម្បីធ្វើអ្វីមួយជុំវិញបញ្ហាទុក្ខ, ដើម្បីដោះស្រាយបញ្ហានៃទុក្ខ, យើងត្រូវកំណត់អោយបានច្បាស់នូវហេតុរបស់វា ។ ប្រសិនបើភ្លើងអគ្គិសនីរលត់ ហើយយើងចង់ធ្វើវាអោយភ្លឺឡើងវិញ, យើងត្រូវកំណត់អោយបានច្បាស់នូវហេតុរបស់វា ។ យើងត្រូវរកអោយឃើញថា តើវាជាការដាច់ចរន្ត ឬដាច់ខ្សែហ៊្វុយហ្ស៊ីប ឬក៏ប្រហែលជាការផ្ដល់ថាមពល ត្រូវបានគេកាត់ផ្ដាច់ ។ ដូចគ្នានេះដែរ កាលណាយើងស្គាល់ច្បាស់នូវបញ្ហានៃទុក្ខ យើងត្រូវស្វែងរកមើលហេតុ ។ គឺដោយការយល់ដឹងនូវហេតុនៃទុក្ខនេះហើយ ទើបយើងអាចធ្វើអ្វីមួយដើម្បីដោះស្រាយបញ្ហា ។ តើអ្វីជាហេតុនៃទុក្ខតាមការប្រៀនប្រដៅរបស់ព្រះពុទ្ធ ? ព្រះពុទ្ធបានប្រៀនប្រដៅថាតណ្ហា គឺជាហេតុចំបងមួយនៃទុក្ខតណ្ហា ( គឺចំណង់ខ្លាំងក្លា ) ដើម្បីទទួលអារម្មណ៍រីករាយ, តណ្ហាដើម្បីបានវត្ថុជា សម្ភារៈ, តណ្ហាដើម្បីបានជីវិតអមតៈ និងតណ្ហាដើម្បីបានមរណភាពជានិរន្តរ៍ ។ យើងទាំងអស់គ្នា សប្បាយរីករាយបរិភោគអាហារឆ្ងាញ់, យើងទាំងអស់គ្នាសប្បាយរីករាយស្ដាប់ភ្លេងពិរោះ, មានអ្នកហែហមជាទីពេញចិត្ត ។ យើងសប្បាយជាមួយវត្ថុ ទាំងអស់នេះ ហើយយើងកាន់តែចង់បានវត្ថុទាំងនេះច្រើនឡើងៗ ។ យើងខិតខំបន្លាយពេលទទួលអារម្មណ៍រីករាយទាំងនេះអោយបានវែង ។ យើងខិតខំប្រមូលសេចក្ដី

សប្បាយទាំងនេះអោយបានកាន់តែច្រើនឡើង១ ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏យើងនៅតែមិនពេញចិត្តទាំងស្រុងសោះឡើយ ។ យើងអាចឃើញថា យើងពេញចិត្តចំពោះអាហារពិសេសណាមួយ ហើយយើងបរិភោគអាហារនោះម្តងហើយ ម្តងទៀត រហូតដល់យើងធុញទ្រាន់នឹងអាហារនោះ ។ យើងខិតខំរកអាហារមួយមុខថ្មីទៀត ។ យើងពេញចិត្តអាហារក្រោយនេះ, សប្បាយបរិភោគអាហារក្រោយនេះហើយយើងក៏ធុញទ្រាន់នឹងអាហារនេះម្តងទៀត ។ យើងបន្តស្វែងរកអ្វីមួយផ្សេងទៀត, យើងធិនឆ្អន់នឹងបទភ្លេងសំណាប់ចិត្តរបស់យើង ។ យើងធិនឆ្អន់នឹងមិត្រភក្តិរបស់យើង ។ យើងស្វែងរកកាន់តែច្រើនឡើង១ ។ ជួនកាល ការប្រដេញតាមរកអារម្មណ៍រីករាយ នាំយើងទៅដល់ទ្រង់ទ្រាយនៃការប្រព្រឹត្តដ៏អវិជ្ជមានបំផុត ដូចជាប្រមឹកស្រា និងល្បួក់វង្វេងគ្រឿងញៀន ។ ទាំងអស់នេះ គឺជាតណ្ហា ពោលគឺចំណង់ខ្លាំងក្លា ដើម្បីបំពេញចំណង់របស់យើងស្វែងរកអារម្មណ៍រីករាយ ។ គេនិយាយថា ការខិតខំបំពេញចំណង់របស់ខ្លួន ដើម្បីបានក្រេបអារម្មណ៍រីករាយ គឺដូចជាការផឹកទឹកប្រៃ កាលណាគេស្រេកទឹក ។ បើគេផឹកទឹកប្រៃដើម្បីបំបាត់ការស្រេកទឹករបស់គេ, ការស្រេកទឹករបស់គេ, មិនត្រឹមតែមិនបានស្ងប់ទេ, គឺថែមទាំងកើនឡើងទៀត ។

យើងមិនគ្រាន់តែស្រេកឃ្លានចង់បានអារម្មណ៍រីករាយប៉ុណ្ណោះទេ, ប៉ុន្តែយើងស្រេកឃ្លានចង់បានវត្ថុជាសម្ភារៈផងដែរ ។ យើងអាចឃើញសភាវៈនេះយ៉ាងច្បាស់នៅក្នុងកូនក្មេង ។ ខ្ញុំមានកូនប្រុសម្នាក់អាយុប្រាំឆ្នាំ ។ ចូរនាំវាទៅក្នុងហាងលក់តុក្កតាមើល, វានឹងចង់បានតុក្កតាទាំងអស់នៅក្នុងហាង ។ ហើយប្រហែលវានឹងទិញតុក្កតាមួយ ។ គ្រាន់តែវាបានទិញតុក្កតានោះភ្លាម, វាក៏ចាប់ផ្តើមបាត់ការជាប់ចិត្តនឹង តុក្កតានោះភ្លាម, ហើយមិនខុសទេ ក្នុងរង្វង់ពីរបីថ្ងៃ តុក្កតាត្រូវបានទុក ចោលនៅជ្រុងបន្ទប់ ហើយវាចង់បានតុក្កតាផ្សេងទៀត ។ នៅពេលដែលបាតុភាពនេះ

អាចត្រូវបានគេឃើញយ៉ាងច្បាស់នៅក្នុងក្មេងតូចៗ តើយើងមានអ្វីប្លែកពីនេះដែរទេ ? ក្រោយពេលយើងបានទិញរថយន្តថ្មីនោះហើយ តើយើងមិនចង់បានរថយន្តថ្មីមួយទៀតទេឬ ? ក្រោយពេលយើងមានផ្ទះថ្មីមួយហើយ តើយើងមិនគិតថា : « អើ, ផ្ទះនេះល្អមែនហើយ, ប៉ុន្តែវាកាន់តែល្អជាងទៀត ប្រសិនបើខ្ញុំមានផ្ទះថ្មីមួយគ្រាន់បើជាង, គឺជាផ្ទះមួយមានសួនច្បារតូចមួយ, ឬផ្ទះមួយមានបួនបន្ទប់, ឬជាអគារមួយធំ មានល្វែង និងមានជាន់ច្រើន ឬក៏ជាផ្ទះនៅក្នុងប្លុកនៃផ្ទះអាប៉ាតឺម៉ង់ (A condominium) » ។ រួចហើយវាចេះតែបន្តរជីកទៅ ថាតើជារទេះភ្លើងមួយខ្សែ ( ល្បែងក្មេង ), ឬជាទោចក្រយានមួយគ្រឿង, ឬក៏កាម៉េរ៉ាថតវីដេអូមួយគ្រឿង, ឬក៏ជារថយន្តម៉ែរសីដេសមួយគ្រឿង ។ គេនិយាយថា ចំណង់ដើម្បីបានសម្បត្តិទ្រព្យមានជាប់ទាក់ទងនឹងទុក្ខដ៏ចម្បង ឬបញ្ហាចម្បងបីយ៉ាង ។ បញ្ហាទីមួយគឺបញ្ហាបានសម្បត្តិទ្រព្យនោះ ។ លោកអ្នកត្រូវធ្វើការ ហើយសន្សំប្រាក់អោយបានគ្រប់គ្រាន់ដើម្បីទិញរថយន្តនោះ ឬផ្ទះនោះ ។ ទីពីរ គឺមានទុក្ខលំបាក ដើម្បីរក្សាការពាររថយន្ត ឬផ្ទះនោះ ។ លោកអ្នកព្រួយកង្វល់ថា ក្រែងអ្នកណាមួយដើរមកទាត់រថយន្តរបស់លោកអ្នក, លោកអ្នកព្រួយបារម្ភថា ក្រែងផ្ទះរបស់លោកអ្នកត្រូវភ្លើងឆេះ ឬត្រូវខូចខាតដោយទឹកភ្លៀង ។ នៅទីបំផុត វាមានទុក្ខដោយការបាត់បង់ទ្រព្យសម្បត្តិទាំងនោះ ពិព្រោះយូរ ឬឆាប់សម្បត្តិទ្រព្យនោះៗ នឹងត្រូវអន្តរាយ ។

ចំណង់ខ្លាំងក្លាចង់មានអត្ថិភាព ឬចង់មានជីវិតជានិរន្តរ៍ ( ភវតណ្ហា ) គឺជាហេតុនៃទុក្ខ ។ យើងទាំងអស់គ្នា មានចំណង់ខ្លាំងក្លាចង់មានកំណើត ( ភវ-តណ្ហា ) ។ យើងទាំងអស់គ្នា មានចំណង់ខ្លាំងក្លាចង់មានជីវិតរស់នៅ ។ ទោះបីជាជីវិតមានការឈឺចាប់ ( ទុក្ខ ) និងការខកចិត្តវិនាសព្រាត់ប្រាសយ៉ាងណាក្តី ក៏យើងទាំងអស់គ្នានៅតែមានចំណង់ខ្លាំងក្លាចង់មានជីវិតរស់នៅដែរ ។ ហើយគឺចំណង់ខ្លាំងក្លា ( តណ្ហា ) នេះហើយដែលជាហេតុនាំអោយយើងកើតហើយ កើតទៀតនោះ ។

បន្ទាប់មក វាមានចំណង់ដើម្បីអោយមានភាពសាបសូន្យ, គឺចំណង់មិនអោយមានកំណើត ( វិភវតណ្ហា ) ដែលយើងហៅថា ចំណង់ដើម្បីមានមរណភាពជានិរន្តរ៍ ។ ចំណង់នេះស្តែងឡើងច្បាស់នៅក្នុងឧច្ឆេទទិដ្ឋិ ( Nihilism ) និងការធ្វើអត្ត-ឃាត ។ ចំណង់ខ្លាំងក្លាដើម្បីមានអត្ថិភាព ( ភវតណ្ហា ) គឺជាអច្ចន្តភាពមួយ ( One extreme ) ។ ចំណង់ខ្លាំងក្លាដើម្បីអនត្ថិភាព ( វិភវតណ្ហា ) គឺជាអច្ចន្តភាពមួយផ្សេងទៀត ។

លោកអ្នកអាចសួរថា « ចំណង់ ឬតណ្ហាតែឯង គឺជាហេតុគ្រប់គ្រាន់ នៃទុក្ខ ឬទេ ? តើតណ្ហាតែឯង ល្មមពន្យល់នូវទុក្ខបានឬទេ ? តើចម្លើយសាមញ្ញដូចនេះឬ ? គឺឆ្លើយថា ទេ ។ វានៅមានអ្វីមួយដែលជ្រាលជ្រៅជាងតណ្ហាទៅទៀត ។ វាមានអ្វីមួយ ដែលនៅក្នុងន័យជាគ្រឹះនៃតណ្ហា ។ ហើយអ្វីនោះ គឺអវិជ្ជានេះឯង ។

អវិជ្ជាមិនមែនជាការមើលឃើញវត្ថុទាំងឡាយដូចជាវាស្តែងឡើងអោយឃើញនោះទេ, ឬការមិនយល់តថភាព នៃបទពិសោធន៍ ឬតថភាពនៃជីវិតនោះទេ ។ មនុស្សទាំងអស់ដែលបានទទួលការសិក្សាអប់រំល្អ អាចមានអារម្មណ៍មិនស្រួលចំពោះពាក្យពោលថា គេទាំងឡាយនោះជាមនុស្សអវិជ្ជា ( ឬមនុស្សល្ងង់ ) ។ ខ្ញុំអាចរំលឹកឡើងវិញនូវពាក្យរបស់លោកសាស្ត្រាចារ្យ ឡង់កាស្ទ័រ ( Lancaster ) ។ ពេលអញ្ជើញទៅទស្សនកិច្ចនៅឯប្រទេសសិង្ហបុរីប៉ុន្មានខែកន្លងទៅ, លោកបាននិយាយទាក់ទងដល់រឿងនេះ ។ លោកបាននិយាយថា នេះគឺជារឿងមួយដ៏ពិបាកបំផុតដើម្បីពន្យល់ដល់និស្សិតសាកលវិទ្យាល័យនៅក្នុងសហរដ្ឋអាមេរិក ពេលដែលគេផ្តើមរៀននៅក្នុងថ្នាក់សិក្សាពីពុទ្ធសាសនា ពិព្រោះពួកគេទាំងអស់គ្នារីករាយណាស់ហើយមានមោទនភាពណាស់ដោយបានមករៀននៅសាកលវិទ្យាល័យ ។ នៅទីនោះបើលោកអ្នកនិយាយប្រាប់គេថា ពួកគេជាមនុស្សអវិជ្ជា ( ល្ងង់ ) ។ លោកសាស្ត្រាចារ្យនិយាយថា ភ្លាមនោះពួកគេលើកដៃឡើងលើច្រូងជាដរាប, « តើយើងខ្ញុំជា

មនុស្សអវិជ្ជាយ៉ាងដូម្តេច ? ក្នុងន័យយ៉ាងណាដែលយើងខ្ញុំជាមនុស្សអវិជ្ជា ? » ឥឡូវ សូមទុកអោយខ្ញុំជម្រាបអំពីរឿងនេះ ។ បើគ្មានលក្ខណសម្បត្តិត្រឹមត្រូវ, គ្មានការបណ្តុះបណ្តាលត្រឹមត្រូវ និងគ្មានឧបករណ៍ត្រឹមត្រូវ យើងមិនអាចមើលឃើញអ្វីៗ ដូចដែលវាមានពិតប្រាកដទេ ។ គ្មាននរណាម្នាក់ក្នុងចំណោមយើងនេះ អាចដឹងបានពីរលកអាកាសវិទ្យុបានទេ ប្រសិនបើយើងគ្មានប៉ុស្តិ៍វិទ្យុទទួលសំឡេង ។ គ្មាននរណាម្នាក់ក្នុងចំណោមយើងនេះ អាចដឹងបានអំពីវេត្រាណូ (Bacteria) នៅក្នុងតំណក់ទឹកបានទេ ប្រសិនបើយើងគ្មានអតិសុខុមទស្សន៍, ហើយគ្មាននរណាម្នាក់ក្នុងចំណោមយើងនេះដឹងពីរចនាសម្ពន្ធម៉ូលេគុល ( Molecular structure ) បានទេ ប្រសិនបើយើងគ្មានបច្ចេកទេសដ៏ថ្មីបំផុតសម្រាប់ពិនិត្យដោយអតិសុខុមទស្សន៍អេឡិចត្រុង ( Electron microscopy ) ។ ហេតុពិតទាំងអស់នេះ អំពីពិភពលោកដែលយើងកំពុងរស់នៅត្រូវបានគេដឹង និងត្រូវបានគេសង្កេតឃើញបានដោយសារតែបានទទួលការបណ្តុះបណ្តាលពិសេស, ដោយសារតែមានលក្ខណ-សម្បត្តិពិសេស និងដោយសារតែមានឧបករណ៍ពិសេសប៉ុណ្ណោះ ។ កាលណាយើងនិយាយថា អវិជ្ជាគឺជាការបរាជ័យដើម្បីមើលឃើញអ្វីៗ ដូចដែលវាមានពិតប្រាកដ, អ្វីដែលយើងសំដៅដល់ គឺថា ដរាបណាគេមិនបានធ្វើអោយបញ្ញា របស់គេរីកចំរើនដើម្បីប្រមូលផ្តុំចិត្ត និងអារម្មណ៍បានទេ ដរាបនោះគេជាមនុស្សអវិជ្ជា ពោលគឺមិនដឹងនូវធម្មជាតិពិត នៃវត្ថុទាំងឡាយ ។ យើងធ្លាប់បានជួបនឹងការភ័យខ្លាច ដែលយើងបានទទួល កាលណាយើងឃើញទ្រង់ទ្រាយបែបណាមួយនៅក្នុងទីងងឹតក្បែរផ្លូវនៅពេលយើងដើរទៅផ្ទះម្នាក់ឯង នៅពេលយប់ជ្រៅ ។ ទ្រង់ទ្រាយនៅក្បែរផ្លូវនោះអាចជាដង្គត់ឈើមួយ ។ គឺដោយសារអវិជ្ជារបស់យើងនោះហើយ ដែលបណ្តាលអោយយើងបោះជំហានយ៉ាងញាប់, ប្រហែលបាតដៃរបស់យើងក៏ចាប់ផ្តើមចេញញើសដែរ, យើងអាចទៅដល់ផ្ទះដោយសេចក្តីតក់ស្លុត ។ ប្រសិនបើមានពន្លឺភ្លើង

វិញ នោះគ្មានសេចក្ដីភ័យខ្លាច ហើយក៏គ្មានទុក្ខដែរ ពិព្រោះវានឹងពុំមានអវិជ្ជាទេ ។ យើងអាចនឹងបានឃើញដង្កត់ឈើ ដូចដែលវាមានប្រាកដមែន ។

នៅក្នុងពុទ្ធសាសនា ជាពិសេស, យើងកំពុងនិយាយអំពីអវិជ្ជាទាក់ទងនឹងអាត្មន ( the self ) ដោយចាត់ទុកអាត្មន ដូចជាសភាវៈពិត ។ នេះគឺជាមូលហេតុនៃទុក្ខ ។ យើងចាត់ទុកខ្លួន ឬគំនិត ឬក៏អារម្មណ៍របស់យើងថាជាអាត្មន, ថាជាអាត្មាមួយពិត ឯករាជ បីដូចជាយើងទុកដង្កត់ឈើថា ជាសត្រូវដ៏គ្រោះថ្នាក់ ។ ពេលណាយើងមានគំនិតពីអាត្មននេះ យើងមានគំនិតមួយអំពីអ្វីមួយដែលជាសភាវៈក្រៅ ឬផ្សេងពីខ្លួនយើង ។ កាលណាយើងមានគំនិតអំពីអ្វីមួយនោះ ដែលជាសភាវៈក្រៅ ឬផ្សេងពីខ្លួនយើង, កាលនោះគំនិតនោះអាចជាជំនួយ ឬជាសត្រូវ ។ វាជាសភាវៈរីករាយ ឬជាសភាវៈមិនរីករាយចំពោះខ្លួនយើង ។ ចាប់ពីសញ្ញាណនៃអាត្មននេះទៅ យើងក៏មានតណ្ហា និងព្យាបាទ ។ ពេលណាយើងជឿក្នុងអត្ថិភាពពិតនៃខ្លួនយើង, គឺ « យើង » កើតមាននៅក្នុងតថភាព, ដោយឯករាជ, ក្រៅពីអ្នកដទៃទាំងអស់, ក្រៅពីវត្ថុជារូបវន្តទាំងអស់ ដែលនៅជុំវិញយើង, យើងអន្ទះអន្ទែងប្រាថ្នាចង់បានវត្ថុទាំងនោះ ដែលមានប្រយោជន៍ដល់យើង ហើយយើងស្អប់ខ្ពើមវត្ថុទាំងនោះ ដែលមិនផ្ដល់ប្រយោជន៍ដល់យើង, ដែលបង្កអន្តរាយដល់យើង, និងដែលមិនផ្ដល់ជំនួយដល់យើង ។ ដោយសារតែការបរាជ័យក្នុងការមើលឃើញថា នៅក្នុងខ្លួនប្រាណ និងចិត្តនេះ, វាគ្មានអាត្មនណាមួយឯករាជ តាំងនៅឋិតថេរនោះ, តណ្ហា និងព្យាបាទរមែងដុះដាលដោយចៀសមិនផុត ។ មែកធាងនៃតណ្ហារមែងដុះចេញពីឫស និងពីដើមនៃអវិជ្ជា, រាគៈ, លោភៈ, ព្យាបាទ, កោធៈ, ទោសៈ, ឥច្ឆា, ឈ្នានីស, មានះ និងបាបធម៌ដទៃទៀត ។ មែកធាងទាំងអស់នេះ ដុះចេញមកពីឫស និងពីដើមនៃអវិជ្ជា ហើយមែកធាងទាំងនេះបង្កើតចេញជាផ្លែផ្កានៃទុក្ខ ។ ដូច្នេះ, នៅក្នុងទីនេះ អវិជ្ជាគឺជាមូលហេតុដេកត្រាំនៅខាងក្រោម ហើយតណ្ហា, ព្យាបាទ, លោភៈ និងកោធៈ គឺជាហេតុ

ទីពីរ ឬហេតុបន្តក្រោយមក ។

ក្រោយពីបានកំណត់ច្បាស់នូវហេតុនៃទុក្ខហើយ, គេត្រូវត្រៀមខ្លួនដើម្បីបញ្ចប់នូវទុក្ខ ។ បីដូចជា ពេលណាគេបានកំណត់ដឹងច្បាស់នូវហេតុនៃជំងឺនោះនៅក្នុងភាគខាងក្រោមផ្ចិតពោះខាងឆ្វេងរបស់គេ គឺរោគពោះវៀនដុះខ្នែង, ពេលនោះគេត្រូវត្រៀមខ្លួនវះកាត់យកហេតុនៃជំងឺនោះចេញ ។ គេអាចបញ្ចប់នូវទុក្ខដោយបំបាត់នូវហេតុនៃទុក្ខ, ដោយបំបាត់តណ្ហា, ព្យាបាទ និងអវិជ្ជា ។ ឥឡូវ យើងបានមកដល់អរិយសច្ចៈទីបី គឺសច្ចៈនៃការបញ្ចប់នូវទុក្ខ ។

ក្នុងការពិចារណានូវសច្ចៈនៃការបញ្ចប់ទុក្ខ ( ទុក្ខនិរោធសច្ចៈ ), ឧបសគ្គដំបូងដែលយើងត្រូវជំនះ គឺសេចក្ដីសង្ស័យ ដែលកើតមាននៅក្នុងចិត្តថា តើការបញ្ចប់នូវទុក្ខអាចធ្វើទៅបានដោយពិតប្រាកដឬទេ ។ តើគេអាចបញ្ចប់ទុក្ខដោយពិតមែន, ឬតើគេអាចជាសះស្បើយចាករោគដោយពិតមែន ។ គឺនៅក្នុងបរិបទនេះហើយដែលទំនុកចិត្ត ឬសទ្ធាដើរតួដ៏សំខាន់នៅក្នុងពុទ្ធសាសនា ។ កាលណាយើងនិយាយអំពីទំនុកចិត្ត ឬសទ្ធា យើងមិននិយាយពីសទ្ធាក្នុងន័យនៃការទទួលជឿដោយល្ងិតល្ងង់នោះទេ ។ យើងនិយាយពីសទ្ធាក្នុងន័យទទួលស្គាល់ ឬយល់ព្រមជឿលទ្ធ-ភាព នៃការសំរេចគោលដៅនៃការបញ្ចប់ទុក្ខ ។ ប្រសិនបើលោកអ្នកមិនជឿថា វេជ្ជ-បណ្ឌិតអាចព្យាបាលអោយលោកអ្នកជាសះស្បើយពីជំងឺនោះនៅក្នុងពោះរបស់លោកអ្នកបានទេ, លោកអ្នកនឹងមិនទៅរកលោកវេជ្ជបណ្ឌិតទេ, លោកអ្នកនឹងមិនទទួលទានថ្នាំ ឬទទួលនូវការវះកាត់ទេ ហើយជាលទ្ធផល លោក អ្នកអាចស្លាប់ដោយជំងឺនោះ ដែលអាចព្យាបាលអោយជាបាន ។ ដូច្នេះ ទំនុកចិត្ត ជំនឿក្នុងលទ្ធភាព នៃការព្យាបាលអោយជាសះស្បើយ គឺជាល័ក្ខខ័ណ្ឌចាំបាច់ណាស់ ។ ក្នុងទីនេះដែរ, ក៏ដូចជាក្នុងករណីដទៃទៀត, គេអាចនិយាយថា « តើខ្ញុំអាចជឿក្នុងលទ្ធភាព នៃនិព្វានយ៉ាងដូម្ដេច ? តើខ្ញុំអាចជឿថា ការបញ្ចប់នៃទុក្ខប្រាកដជាអាចធ្វើបានឬទេ នៅពេល

ដែលខ្ញុំមិនដែលពិសោធន៍ទាល់តែសោះ ? » មែនហើយ, ដូចខ្ញុំបាននិយាយមួយរយៈកន្លងទៅហើយ គ្មាននរណាម្នាក់ក្នុងចំណោមក្រុមយើងនេះធ្លាប់បានពិសោធនូវរលកអាកាសវិទ្យុទេ បើសិនជាគ្មានការរីកចំរើននៃវិទ្យុទទួលសំឡេង, ហើយក៏គ្មាននរណាម្នាក់ក្នុងចំណោមយើងនេះ ធ្លាប់បានពិសោធនូវជីវិតអតិសុខុមប្រាណប្រសិនបើគ្មានការបង្កើតឡើង នៃអតិសុខុមទស្សន៍ ។ សូម្បីឥឡូវនេះ ក៏គ្មានអ្នកណាម្នាក់ក្នុងចំណោមយើងនៅទីនេះ វៀរលែងតែមានលោករូបវិជ្ជាវិទូណាម្នាក់នៅក្នុងបន្ទប់នេះចេញ, បានសង្កេតឃើញអេឡិចត្រុងដោយជាក់ស្ដែងដែរ ប៉ុន្តែយើងទទួលស្គាល់អេឡិចត្រុងទាំងនោះ ពិព្រោះតែមានក្នុងចំណោមយើងនេះ អ្នកដែលបានទទួលការបណ្ដុះបណ្ដាលពិសេស ដោយមានឧបករណ៍ពិសេសដែលបានមើលឃើញអេឡិចត្រុង ។ ដូចនេះ នៅក្នុងទីនេះដែរ ចំពោះលទ្ធភាពនៃការបញ្ចប់ទុក្ខ និងលទ្ធភាពនៃការសំរេចបាននូវនិព្វាន, យើងមិនគប្បីបដិសេធលទ្ធភាពនៃការសំរេចបាននូវនិព្វានយ៉ាងកំបុតដូច្នោះ ដោយសារតែយើងមិនបានពិសោធនិព្វាននោះ, ដោយសារតែយើងមិនបានឃើញនិព្វាននោះដោយខ្លួនយើងផ្ទាល់ ។ អស់លោកជាច្រើននាក់អាចធ្លាប់ស្គាល់រឿងព្រេងបុរាណស្ដីពីអណ្ដើក និងត្រី ។ ថ្ងៃមួយអណ្ដើកបានចាកចេញពីត្រពាំងហើយចំណាយពេលពីរបីម៉ោងនៅលើគោកមាត់ត្រពាំង ។ នៅពេលវាត្រឡប់ចុះទៅក្នុងទឹកវិញ វានិយាយប្រាប់ត្រីអំពីបទពិសោធន៍របស់វា នៅលើគោកមាត់ត្រពាំង ។ ត្រីអាចមិនជឿវាទេ ។ ត្រីអាចមិនជឿថា មានកន្លែងមួយដែលជាទីដីគោក ពិព្រោះវាខុសពីគ្នាទាំងស្រុងទៅនឹងអ្វីដែលត្រីធ្លាប់ដឹង, អ្វីដែលត្រីធ្លាប់នៅជាអចិន្ត្រៃយ៍ ។ ត្រីអាចមិនជឿថា មានកន្លែងមួយ ដែលសត្វទាំងនោះអាចដើរបានមិនបាច់ហែលទេ, ដែលគេដកដង្ហើមយកខ្យល់អាកាស មិនមែនដកដង្ហើមក្នុងទឹកទេ, . ល . ។ មានឧទាហរណ៍ប្រវត្តិសាស្ត្រជាច្រើនស្ដីពីនិន្នាការនៃការច្រានចោលពតិមាននេះ ដែលមិនសមស្របជាមួយនឹងអ្វីដែលយើងបានជឿរួច

ហើយ, ឬអ្វីដែលយើងធ្លាប់ស្គាល់ ដឹងរួចហើយ ។ នៅពេលលោក ម៉ារកូ ប៉ូឡូ ( Marco Polo ) បានត្រឡប់ទៅកាន់ប្រទេសអ៊ីតាលី ពីដំណើររបស់លោកទៅកាន់ចុងបូព៌ាប្រទេស, លោកត្រូវបានគេចាប់ដាក់គុក ពិគ្រោះសេចក្តីរៀបរាប់របស់លោកអំពីធម្មជាតិ នៃចក្រវាឡមិនបានសមស្របទៅនឹងអ្វីដែលគេធ្លាប់បានជឿនៅសម័យនោះ ។ នៅពេលដែលលោក កូពែរនិក ( Copernicus ) បានបញ្ចេញទ្រឹស្តីថា ព្រះអាទិត្យមិនមែនគោចរជុំវិញផែនដីទេ, ប៉ុន្តែតាមពិតគឺ ផែនដីទេដែលគោចរជុំវិញព្រះអាទិត្យ ។ លោកត្រូវបានគេអស់ជំនឿ ហើយសើចចំអក ។ យើងគួរប្រុងប្រយ័ត្នចំពោះការផាត់ចោលលទ្ធភាព នៃការបញ្ចប់ទាំងស្រុងនៃទុក្ខ ឬលទ្ធភាពនៃការសំរេចបាននិព្វាន ដោយគ្រាន់តែយើងមិនធ្លាប់បានពិសោធករណីនេះដោយផ្ទាល់ខ្លួន ។ ពេលណា យើងទទួលជឿថា ទីបញ្ចប់នៃទុក្ខអាចធ្វើបាន, ជឿថាយើងអាចព្យាបាលអោយជាសះស្បើយពីជំងឺបាន, បន្ទាប់មកយើងអាចផ្តើមដំណើរការជាជំហាន១ ដែលចាំបាច់ ដើម្បីសំរេចអោយបាននូវការជាសះស្បើយ ។ ប៉ុន្តែ វៀរលែង និងដរាបណាយើងជឿថា ការជាសះស្បើយនេះអាចធ្វើទៅបាន, នោះវាគ្មានបញ្ហាអំពីការសំរេចដោយជោគជ័យនូវការព្យាបាលទេ ។ ហេតុនេះ ដើម្បីសំរេចអោយបាននូវដំណើរជឿនលឿនលើមាគ៌ា, សំរេចអោយបានជាយថាហេតុនូវការបញ្ចប់ទុក្ខ, គេត្រូវតែមានយ៉ាងហោចណាស់ទំនុកចិត្តក្នុងលទ្ធភាពនៃការសំរេចបាននូវគោលដៅ, គឺក្នុងលទ្ធភាពនៃការបានដល់ព្រះនិព្វាន ។

*( នៅមាន ត )*

# វជ្ជទស្សនកថា

## ពុទ្ធឱវាទស្ដីពីការមិនមើលទោសអ្នកដទៃ

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

មុននឹងបកស្រាយនូវ *វជ្ជទស្សនកថា* គឺកថា ស្ដីពីការមិនមើលទោសអ្នកដទៃ សូមលើកយកពុទ្ធគាថាមួយក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយ ដែលព្រះសាស្ដាទ្រង់សំដែងប្រារព្ធចំពោះមេណ្ឌកសេដ្ឋី ។ ពុទ្ធគាថាដែលសំដែងពាក់ព័ន្ធនឹងមេណ្ឌកសេដ្ឋីនោះ មានរឿងនិទាន ដោយសេចក្ដីបំព្រួញថា ៖

ក្រោយពីមេណ្ឌកសេដ្ឋី បានដាក់បាត្រថ្វាយព្រះបច្ចេកពុទ្ធ ដែលទើបនឹងចេញពីនិរោធសមាបត្តិថ្មីៗ ដោយអង្ករមានជាចុងក្រោយបំផុត (អស់រលីង) នោះមក, ទិដ្ឋធម្មិកផល គឺផល ឬអានិសង្សហុចមកភ្លាមៗ ក៏កើតមានឡើងដល់សេដ្ឋី ។

បន្ទាប់ពីនោះមក, មេណ្ឌកសេដ្ឋី បានទទួលដំណឹងថា ព្រះលោកនាថ នឹងស្ដេចយាងមក ។ សេដ្ឋី ក៏ធ្វើដំណើរចេញទៅទទួលស្វាគមន៍ព្រះសម្ពុទ្ធ ។ ដើរដល់កណ្ដាលផ្លូវ លោកបានជួបនឹងពួកនិគ្រន្ថ ។ ពួកនោះបានសួរសេដ្ឋីថា « លោកគហបតី អញ្ជើញទៅណា ? » ។ សេដ្ឋី ឆ្លើយថា « ខ្ញុំទៅទទួលដំណើរយាងមករបស់ព្រះសម្មាសម្ពុទ្ធ » ។

ពួកគេមានការមិនសប្បាយចិត្ត ដោយបញ្ចេញអាការៈមុខស្មើ ( ព្រោះច្រណែនខ្លាចបាត់បង់លាភ ) ហើយពោលថា « បុគ្គលអ្នកកិរិយវាទ រស់នៅក្នុងធម៌ (ច្បាប់) ប្រហែលដូចលោក មានប្រយោជន៍អ្វីក្នុងការទៅកាន់សំណាក់សមណគោតម ដែលជាមនុស្សអកិរិយវាទ ( មិនមានធម៌ មិនមានច្បាប់ )នោះ ? » ។ ទោះបីពួកនិគ្រន្ថ ពោលឃាត់យ៉ាងនេះក្ដី ក៏សេដ្ឋីមិនព្រមស្ដាប់ នៅតែជំនះទៅដរាប

ដល់បានក្រាបបង្គំគាល់ព្រះបរមសាស្តា ។ ពេលនោះ ព្រះមានព្រះភាគទ្រង់សំដែង អនុបុព្វិកថា ( ការថ្លែងពីប្រវត្តិតាមលំដាប់កំណើតរបស់សេដ្ឋី ) ។ នៅពេលចប់ព្រះសទ្ធម្មទេសនា សេដ្ឋីបានសម្រេចសោតាបត្តិផល, រួចហើយក៏ក្រាបបង្គំទូលសួរព្រះសាស្តាពីការលើកទោស ( ចំពោះព្រះអង្គ ) ដែលពួកតិរ្ថិយ៍ទាំងនោះបានពោល និងហាមឃាត់ខ្លួនមិនអោយមកជួបគាល់ព្រះអង្គ (*) ។

ព្រះសក្យមុនីទ្រង់ត្រាស់ថា « ម្នាលគហបតី ! ពួកគេទាំងនោះ (និគ្រន្ថ) មិនដែលមើលឃើញទោសរបស់ខ្លួន ទោះបីធំប៉ុនណាក៏ដោយ, តែបើទោសរបស់អ្នកដទៃវិញ សូម្បីតិចតួច ឬមិនមានសោះ ក៏គេតែងមើលឃើញ ឬគេអាចបំភ្លៃអោយកើតមានបានដែរ ។

ដូចនេះ, ការសម្លឹងទោសប្រកបដោយសេចក្តីច្រណែនខ្លាចបាត់លាភ និងការប្រកាន់បក្សពួករបស់គេទាំងនោះ នឹងត្រូវទទួលផលវិបាកមកវិញ ពុំខុសអ្វីពីបុគ្គលបាចអង្កាមបញ្ច្រាសខ្យល់ឡើយ ។

រួចហើយ, ព្រះភគវន្តមុនីទ្រង់ត្រាស់បំភ្លឺពីការឃើញទោសអ្នកដទៃរបស់ពួកតិរ្ថិយ៍ទាំងនោះ ដោយព្រះគាថា យ៉ាងនេះថា :

*« សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ*
*បរេសំ ហិ សោ វជ្ជានិ ឱបុនាតិ យថា ភុសំ*
*អត្តនោ បន ឆាទេតិ កលឹវ កិតវា សឋោ »* ។

ទោសរបស់អ្នកដទៃ មើលឃើញដោយងាយ, ឯទោសរបស់ខ្លួនឯងវិញ

---

(*) សូមបញ្ជាក់ថា និគ្រន្ថ អចេលក៍ អាជីវកទាំងនោះ ជាបព្វជិតមួយពួកក្រៅពុទ្ធសាសនា ប្រកាន់លទ្ធិថា ខ្លួនបានជម្រះកិលេសស្អាតអស់ហើយ ។ ពួកនោះ មានគំនិតមិនស៊ីសង្វាក់នឹងពុទ្ធសាសនាទេ ។ ម្ល៉ោះហើយ ការរមិលមើលទោស ទម្លាក់កំហុសមកលើសាសនាព្រះពុទ្ធរបស់ពួកគេ តែងមានជានិរន្តរ៍, ដូចសត្វខ្លែងតែងរំពៃរកឆាបកូនមាន់ ឬដូចហ្វូងក្អែករមិលរកឆក់ពងមាន់អ្នកស្រុក ដូច្នោះដែរ ។

មើលឃើញដោយលំបាក, ព្រោះថា ការមើលឃើញតែទោសអ្នកដទៃ ( ផលវិបាកនៃការមើលឃើញនោះ ) ពុំខុសអ្វីពីបុគ្គលបាចអង្កាមបញ្ច្រាសខ្យល់ឡើយ ។ មួយទៀត, បុគ្គលអ្នកបិទបាំងទោសខ្លួនឯង ( ដោយបំណងចង់បានលាភ ) ក៏ពុំខុសគ្នានឹងព្រានប្រមាញ់ ( ចង់សម្លាប់សត្វ ) ដោយពួនលាក់ខ្លួននឹងមែកឈើ ដូច្នោះដែរ ។

បំភ្លឺន័យ : ការសម្លឹងទោសអ្នកដទៃ មានន័យថា ពិតពិលរមិលមើល គយគន់រំពៃ ស្វែងទោស រករឿង បង្កហេតុ តាមដាន ស្រាវជ្រាវ និងស៊ើបការណ៍រកឱ្យឃើញទោស, កំហុសអ្នកដទៃ ដោយគំនិតច្រណែនលាភ ច្រណែនយសនោះ, គេនឹងឃើញបានដោយងាយ ។

រីឯទោសរបស់ខ្លួនវិញ, ទោះបីមានទំហំធំប៉ុនណា ទម្ងន់យ៉ាងណាៗ ក៏ត្រូវខ្លួនលាក់បំបាំងបាត់ មិនងាយនឹងមើលឃើញឡើយ ។

ចូលដល់ព្រះពុទ្ធឱវាទត្រង់ចំណុចនេះ យើងនឹកឃើញដល់ច្បាប់ទូន្មានមួយចំនួនរបស់បុព្វបុរសយើង, យ៉ាងណាមិញ

- ច្បាប់សាស្ត្រាមហាជន : « ពាក្យចាស់ ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់ ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ » ។

- សុភាសិត : « ផ្លែល្វា លាក់មមង់ ទឹកថ្លាយង់ លាក់កករ » ។

- ពាក្យស្លោក : « ដីរងាប់ យកចង្អេរគ្រប » ( គ្របមិនជិតទេ ) ។

« ផោមក្នុងទឹក ម្ដេចគង់ពុចទឹក » ( លាក់មិនបាត់ )

« លាក់តែមុខ គូថកណ្ដាលវាល » ។

- អដ្ឋកថា : « ព្រានប្រមាញ់ ចាំបាញ់សត្វ ក្ដីក្ដួលក្ដាត់ ប៉ងប្រាថ្នា
យកសាច់ជាអាហារ ស្ងោរ អាំង ឆា សម្រាប់ខ្លួន ។
ប្រើកលដែលត្រូវធ្វើ បាំងមែកឈើលាក់បំពួន
ដូចទោសរបស់ខ្លួន ដុំកំភួនជីកកប់បាត់ » ។

ដូចនេះ, ការឃើញទោសក្តី ការលាក់ទោសក្តី ដែលសុទ្ធតែមានបង្កប់នូវក្តីប្រាថ្នានោះ, តើមានធម៌អ្វី ជាប្រភពនាំឱ្យកើត ? - ធម៌ជាប្រភពគឺ លោភៈ ។ លោភធម៌នេះ បានដុះក្នុងចិត្ត ជំរុញទាក់ទាញចិត្តឱ្យផុងជ្រៅទៅក្នុងអន្លង់ គឺសេចក្តីប្រាថ្នាចង់បាន រហូតដល់បាត់បង់សតិស្មារតី ភ្លេចអស់សេចក្តីអៀនខ្មាសជាអាទិ៍ ។

បន្ថែមលើនេះទៀត, អកុសលមូលនេះ កាលបើចាក់ឫសជិតជាប់ក្នុងចិត្តហើយ, វានឹងចេញពន្លកដុះក្បៀងជាច្រើនទៀត ៖ អភិជ្ឈាវិសមលោភៈ ឬមហិច្ឆតា, តណ្ហា, ឥច្ឆា នឹងរាលដាលដល់ទៅកើតហឹសា ផងទៀត ។

ធម៌ជាសាខារបស់លោភៈទាំងនេះ សុទ្ធតែបានសម្បយុត្ត វេញព្រតបាញ់ ឬឋិតនៅក្រោមអានុភាពនៃមោហៈ អវិជ្ជា ដែលអាចបញ្ឆោចិត្តអោយល្មោភចង់បានលែងស្គាល់ខុស-ត្រូវ ។

• មហិច្ឆតា - សន្ទុះចិត្តប្រាថ្នាធំទូលាយ រាប់មុខមិនអស់ គឺល្មោភចង់បានដោយឥតព្រំដែន ។

* - ល្មោភលាភ ៖ ជីវិតបានរស់គ្រប់គ្រាន់ហើយ គេចង់បានប្រាក់, បានប្រាក់ហើយ ចង់បានមាស, បានមាសហើយ ចង់តម្លើងឱ្យដល់ពេជ្រ និងអ្វី១ទៀត ដែលមនុស្សនិយមលើកតម្កើង ។

* - ល្មោភយស ៖ ចង់បានតួនាទី ឋានៈ មុខមាត់ កិត្តិយស អំណាចទឹកមាត់ប្រៃ ៖ ជាមន្ត្រី រដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី រហូតដល់ប្រធានាធិបតី ឬស្តេចចក្រពត្តិ ... ។ បានខ្លួនឯងហើយ ចង់បន្តដល់កូន ចៅ បក្សពួក និងញាតិសន្តានទៀត ។ បានមួយតំណែហើយ ចង់បាន ២ - ៣ តំណែបន្ថែមទៀត ដែលជាមហិច្ឆតាធំល្ងីងល្ងើយ ឥតកោះត្រើយ ។

• តណ្ហា - ( តសតិ បាបំ ឥច្ឆតីតិ > តណ្ហា ) ធម្មជាតិណា ញ៉ាំងចិត្តអោយប្រាថ្នានូវរបស់បាប ( របស់បានមកដោយមិនត្រូវតាមគន្លងធម៌, មាគ៌ាច្បាប់ )

ដូចជាការភូតកុហក បោកប្រាស់ កេងប្រវ័ញ្ច កិបកេង ក្លែងបន្លំ លួចលាក់ ឆក់ប្លន់ រំលោភបំពារបំពាន គាបសង្កត់ គម្រាមយករបស់គេទាំងខុសច្បាប់ ខុះសីលធម៌ និង យុត្តិធម៌សង្គម គួរអោយស្អប់ខ្ពើម និងព្រឺរន្ធត់ ។

ឃើញច្បាស់នូវថាមពលនៃតណ្ហាដ៏មហិមាដូចនេះហើយ, ទើបព្រះបរមគ្រូទ្រង់ត្រាស់បញ្ជាក់ថា « តណ្ហា អតិត្តោ » ចំណង់ គឺតណ្ហា តែងជំរុញចិត្តសត្វលោកអោយលោភលន់មិនចេះឆ្អែត មិនចេះឆ្អន់ មិនចេះល្មម មិនចេះពេញ និង មិនចេះស្កប់ស្កល់ គឺថា វាធ្វើអោយខ្វះជានិច្ច កន្លះរហូត ( គ្មានឱកាសនឹងពេញ ) ដូចជាមហាសមុទ្រ, ទោះបីបណ្តាញជលមាគ៌ាទូទាំងពិភពលោក ហូរនាំធារទឹកទៅបញ្ចូលមានកម្រិតធំច្រើនប៉ុនណា ក៏ពុំអាចញ៉ាំងមហាសមុទ្រអោយពេញបានម្តងណាឡើយ ។

• ឥច្ឆា ឬឥស្សា - សេចក្តីច្រណែន ឈ្នានីស ។ ព្រោះលោភ ទើបមានការច្រណែន, បន្ទាប់ពីច្រណែន អាចឈានដល់ឈ្នានីសថែមទៀត ។

* - ច្រណែននឹងភាពសុខសាន្ត : ឃើញគេមិនចេះឈឺ មិនមានគ្រោះថ្នាក់ មិនមានការបាត់បង់ ខូចខាតទ្រព្យសម្បត្តិ និងការរស់នៅជាសុខដុមនឹងគ្រួសារគេ ក៏កើតក្តីច្រណែនមិនចង់ឱ្យគេបានសុខ ... ។

* - ច្រណែនឃើញគេកាក់កបជាង រកបានជាង ចំណេញជាង ធូរធារជាង គ្រាន់បើជាង សម្បូរជាង និងស្តុកស្តម្ភជាង ក៏កើតច្រណែន មិនចង់អោយគេមានបានគ្រាន់លើសខ្លួន ... ។

* - ច្រណែននឹងចំណេះដឹង : ឃើញគេរៀនពូកែ, ពិន្ទុល្អ, គ្រូសរសើរ, ប្រឡងមិនដែលធ្លាក់, មានកិត្តិយស, ល្បីឈ្មោះក្នុងសាលា និងទូទាំងប្រទេសថាជាបញ្ញវន្ត បានជាទំពាំងស្នងឫស្សីសម្រាប់ប្រទេសជាតិ ... ក៏កើតចិត្តច្រណែន មិនចង់ឱ្យគេគ្រាន់លើសខ្លួន ។

* - ច្រណែននឹងបុណ្យស័ក្តិ ៖ ឃើញគេមានកិត្តិយស មុខមាត់ខ្ពស់សម្បូរដោយប្រជាប្រិយភាព ( ការស្រឡាញ់ និយមរាប់រកច្រើនជាង ) សម្បូរលាភជាង មានឋានៈខ្ពស់ជាង ប្រាក់បៀវត្សច្រើនជាង ... ក៏តាំងច្រណែនដោយឥតពិចារណា មិនចង់ឱ្យគេមានតួនាទីខ្ពស់ខ្ពង់ជាងខ្លួន ... ។ ល ។

• ហឹសា ការបៀតបៀន ប្រទូសរ៉ាយ ។ បន្ទាប់ពីច្រណែន ឈានដល់ឈ្នានីស ។ ឈ្នានីស មានន័យថា បំផ្លាញ ក្តិចត្រួយ បៀតបៀន ប្រទូស្តធ្វើឱ្យវិនាសអន្តរាយ ។ ដូចនេះ ហឹសា និងឈ្នានីស មានន័យតែមួយ ។ ក្នុងអភិធម្ម លោកប្រាប់ថា « លោភចិត្ត មិនមានលទ្ធភាពបង្កើតហឹសាបានទេ, ព្រោះបើមានចិត្តលោភ គេមិនអាចធ្វើការបៀតបៀន ឬប្រទូសរ៉ាយបានឡើយ ។ ពិតមែន, គេមិនដែលចង់បានផ្ទះ ហើយយកភ្លើងទៅដុតផ្ទះចោលទេ ។ ព្រោះហឹសា វាជាតួដំបងព្រនង់ កាំបិត ពូថៅ សស្ត្រាវុធ និងជាដុំភ្លើង ។ ប៉ុន្តែ, បើនិយាយតាមន័យ ដែលស្មើនឹងពាក្យឈ្នានីស ឬយោលទៅតាមការរាលដាលជាចំហាយ ដែលជះចេញពីលោភៈ វា, នឹងអាចកើតឡើងបាន ។

ជាក់ស្តែង, ដូចជារឿងធនញ្ជ័យ កាលនៅពីកុមារ ... កាលបើមិនបានអំបុកពេញល្អិដូចបំណង ក៏តាំងចងពៀរ ប្រើឧបាយកលប្រទូសរ៉ាយ ធ្វើសេដ្ឋីអោយដល់នូវក្តីវិនាសអន្តរាយ ... ។ ដូចជាក្រុមចោរចិត្តខ្មៅ លោភទ្រព្យសម្បត្តិគេប្លន់យកមាសបានហើយ សម្លាប់ម្ចាស់ទ្រព្យទៀត ... ។ មើលភិក្ខុទេវទត្តចិត្តធំលោភចង់ដណ្តើមយកតំណែងជាព្រះពុទ្ធ ក៏ខំព្យាយាមបៀតបៀន ធ្វើអោយព្រះពុទ្ធស្លាប់ នឹងបានឡើងធ្វើជាព្រះពុទ្ធ ។ ការបៀតបៀន គឺហឹសានេះ, គេឃើញភិក្ខុទេវទត្ត លែងដីរចុះប្រេងអោយព្រេចព្រះអង្គ, ប្រមៀលដុំថ្មអោយកិនសម្លាប់រហូតដល់កើតលោហិតុប្បាទ .... ។ ល ។

តើការសម្លាប់ម្ចាស់ទ្រព្យ, ការព្យាយាមធ្វើអោយសេដ្ឋីដល់នូវក្តីអន្តរាយ

ការព្យាយាមតាមយាយីសម្លាប់ព្រះពុទ្ធ ដោយប្រការផ្សេងៗទាំងនោះ ពិតជាបានចេញពីលោភៈ ឬទេ ? ហើយចាត់ទុកការបៀតបៀនទាំងនោះថាជាហឹសា បានឬទេ ? បើពុំអាចចាត់ទុកករណីទាំងនេះពេញលក្ខណៈបាន ក៏គួរសម្រួបដោយការអនុលោមបានដែរ ។

សត្វលោក មានការភ័យរន្ធត់ណាស់ចំពោះហឹសា, ព្រោះហឹសាជាដុំភ្លើង និងជាប្រធាននៃភយន្តរាយ វិនាសទ្រព្យសម្បត្តិ សមិទ្ធិនានា ការបង្ហូរនូវសមុទ្រទឹកភ្នែក និងនិរាសព្រាត់ប្រាសក្រុមគ្រួសារ រហូតដល់បាត់បង់ជីវិត ស្លាប់គរដើងលើគ្នា ដ៏គួរឱ្យព្រឺស្រៀវក្រៃលែង ។

ដូចនោះ, ទើបព្រះសម្ពុទ្ធទ្រង់ព្យាយាមអប់រំសត្វលោកឱ្យចិញ្ចឹមអំណត់ គឺខន្តី ដែលជាមាតានៃអហឹសា ( ការមិនបៀតបៀនគ្នានោះឯង ) ។

មានកំណាព្យទូន្មានបុរាណមួយ ដែលស្របនឹងព្រះបន្ទូលអប់រំនោះថា :

« អំណត់ ( ខន្តី ) កើតអំណាច ហឹសាពេក កើតទោសា<br>
ប៉ោចៗ អាប់ប្រាជ្ញា យូរៗថា ថ្លៃដូចមាស ! » ។

ក្នុងភក្តីភាពដ៏ជ្រាលជ្រៅចំពោះអហឹសានេះ, មហាបណ្ឌិត « មហាត្មៈគន្ធី » ជាបិតានៃប្រទេសឥណ្ឌា, លោកមានការពេញចិត្តយ៉ាងស្អិត ជឿយ៉ាងស៊ប់ គោរពប្រតិបត្តិយ៉ាងហ្មត់ចត់ និងចិញ្ចឹមបីបាច់យ៉ាងបូរជីវិតនូវឧត្តមធម៌ គឺអហឹសា ។

សូមដកស្រង់យកភាសិតចិន្តា ឬកំណាព្យវិប្បយោគខ្លះៗ របស់លោកមកបង្ហាញជូន ដូចតទៅនេះ :

- « ឱ អហឹសា ! ខ្ញុំស្រឡាញ់អ្នកណាស់ ថ្វីបើអ្នកមានរូបរាងជាទឹក តែជាទឹកនៃទន្លេគង្គា ដែលតែងហូរឥតរាក់ធ្លាក់ចុះមកពីផ្នូងសក នៃព្រះឥសូរ » ។
- « ឱ អហឹសា ! អ្នកមានកម្លាំងខ្សោយតែសំបកក្រៅប៉ុណ្ណោះ, ចំណែកខាងក្នុងអ្នកបានកប់ទុកនូវបណ្តូលដែកថែប ដែលខ្ញុំជឿថា ពុំមានកម្លាំងអ្វីក្នុងលោក

អាចពត់អ្នកបានទេ » ។

- « ឱ អហឹសា ! អ្នកគ្មានសំឡេងទេ ជនទាំងឡាយរកអ្នកពុំឃើញទេ ព្រោះអ្នកពុំបានប្រកាសហៅញាតិមិត្តឱ្យមកស្គាល់ ហើយបានស្តាប់នូវសព្ទសំឡេងរបស់អ្នក ។ ជនណាជឿប្រព្រឹត្តតាមលទ្ធិរបស់អ្នក ទើបបានស្គាល់នូវសូរកណ្តឹងមាស ១ ពាន់ ដែលព្យួរនៅកដីរី « ព្ធរាវតា » ។

- « ឱ អហឹសា ! អ្នករំលត់ពិភពលោក អាស្រ័យភ្លើងកំហឹងរបស់ព្រះសិវៈចុះ ។ ចំណែកខ្ញុំបានរំលត់ចិន្តាទៅតាមទស្សនៈអហឹសា ក៏ដូចជាខ្ញុំបានមុជទឹកអម្រឹតលាងបាបកម្ម ដែលកើតមានឡើងរបស់ពិភពលោកដែរ » ។

អាស្រ័យមហាពលិកម្ម ចិញ្ចឹមបីបាច់នូវអហឹសាដ៏សែនភក្តីនេះ, មហា-បុរស « មហាត្មគន្ធី » អាចទទួលបាននូវបដិការ ( អានិសង្ស ) ដ៏ច្រើន និងកម្របំផុត :

* - លោកបានរួចចាក : ការស្អប់ខ្ពើម ព្យាបាទ សងសឹក និងការប្រទូស្តតបពីជនដទៃ ។ លោករស់នៅជាសុខក្សេមក្សាន្តក្នុងជីវិត ដោយពុំមានការព្រួយបារម្ភ ។

* - លោកបានទទួលនូវប្រិយភាពដ៏ពិសិដ្ឋរហូតដល់ប្រជាជាតិឥណ្ឌា ឈប់ប្រើកម្រាលព្រំ តែគេទទួចសុំបូជា « បាច់សក់នារី » ដែលបោះក្រាលទល់គ្នា ជាកម្រាលទ្រូបាទាលោក នៅគ្រប់ពេលប្រជុំ និងពេលចូលវិហារសូត្រធម៌ ។

* - ព្រះរាជបុត្រអហឹសានេះ អាចធ្វើនយោបាយយកឯករាជ្យពីចក្រភពអង់គ្លេសបានដោយសន្តិវិធី ជូនមាតុប្រទេសលោក ។

* - នៅពេលទទួលអនិច្ចកម្ម, លោកបានទទួលនូវសមុទ្រទឹកភ្នែក ពីមហាជនរហូតដល់ « នេហ៍រុ » ខ្ទប់មុខយំនៅចំពោះមុខជាតិ និងអន្តរជាតិ ហើយបន្លឺថាៈ « ព្រះអាទិត្យលែងរះបំភ្លឺលោកទៀតហើយ ! ស្តាយណាស់ ! ស្តាយណាស់ ! » ។

ប៉ុណ្ណេះជាអាទិ៍ ជាមហាផលនៃអហឹសា ដែលជាកុសលធមិដ៏ឧត្តម គួរយើងបណ្តុះដាំអោយបានគ្រប់ៗគ្នា ។ អហឹសា ផ្ទុយពីហឹសា ដែលជាលាមកធមិគួរយើងព្យាយាមកោសសំអាត កម្ចាត់ចេញពីខន្ធសន្ដានកុំបីប្រមាទ ! ។

ព្រះសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវគុណវិបត្តិ នៃការឃើញទោស និងការលាក់ទោស ដែលបានបង្កប់ស្នូល ពោលគឺ លោភៈ ហើយលោភៈ អាចបណ្តុះនូវធមិជាអកុសលធមិដទៃទៀត មាន ៖ អភិជ្ឈា មហិច្ឆតា តណ្ហា ឥច្ឆា នឹងរាលដាលដល់ទៅកើតបានហឹសា ផងទៀត, ទើបទ្រង់សំដែងអប់រំ ណែនាំសត្វលោកឱ្យចេះវិធី-សាស្ត្រពីរគឺ ៖ បញ្ចេញ និងបញ្ចូល ។ ពួកធមិខ្មៅ ( អកុសល ) គួរបញ្ចេញ ។ ពួកធមិ ស ( កុសល ) គួរបញ្ចូលឱ្យបានច្រើនកុំពន្យារពេល ! ។ ដោយឡែក, ព្រះសាស្តាទ្រង់ទទួចបំភ្លឺលោកឱ្យមានភក្តីភាព និងបណ្តុះដាំនូវបារមីដ៏ឧត្តម គឺខន្តី ( អំណត់ ) ដែលជាមាតានៃអហឹសា ។

អហឹសា បានប្រដាប់ដោយអង្គការជាច្រើន ដ៏គួរឱ្យចាប់អារម្មណ៍ ញញឹមរកគ្នា មើលមុខគ្នាចំ ស្រឡាញ់រាប់រកគ្នា សន្តោសប្រណីគ្នា ជឿទុកចិត្តគ្នា សង្ឃឹមគ្នា ពិសេស មានចិត្តស្មោះត្រង់នឹងគ្នា ... ។ តែកុំលោភពេក កុំច្រណែនគ្នា កុំមើលទោសគ្នា កុំញុះញង់គ្នា កុំចាក់រុកគ្នា និងកុំបៀតបៀន ប្រទូសរ៉ាយគ្នា ... ។

អហឹសា មិនបៀតបៀនគ្នា នេះហើយដែលញ៉ាំងរដ្ឋបុរសមហាត្មគន្ធិ ឱ្យទទួលនូវឧត្តមប្រយោជន៍ និងជោគជ័យដ៏ធំធេង ដូចជាឈប់ប្រើកម្រាលព្រំ តែត្រូវប្រើដោយ « បីសាច់សក់នារី » ជំនួសវិញ ។ ប្រជាប្រិយភាពរហូតដល់មហាជនហ៊ានប្តូរជីវិតស្លាប់ជំនួស ។ ទាមទារយកឯករាជ្យដោយសន្តិវិធី ឥតបង្ហូរឈាម ... ។ ល ។

អហឹសា ជាទឹកអម្រឹតដ៏ត្រជាក់ដក់ដោយសុខ សន្តិភាព ដែលជាទីប្រាថ្នាដ៏ស្រួចស្រាល់ ជាទីស្រេកឃ្លានដ៏ធំធេង និងទន្ទឹងរង់ចាំយ៉ាងអន្ទះសា របស់សង្គម

មនុស្ស ទេវតា ។

បើអម្រឹតគឺ សុខសន្តិភាព ឬសន្តិលោក កើតមានហើយ, យើងអាច មានលទ្ធភាពកសាង សន្សំនូវនាថករណធម៌ទាំងពួង បានជាយានទៅកាន់ត្រើយព្រះនិព្វានបានដូចៗគ្នា ពុំអស់សង្ឃឹមឡើយ ! ។

សំដែងអំពី វដ្ដទស្សនកថា ចប់តែប៉ុណ្ណេះ ។

ទីបំផុតនៃធម្មទេសនានេះ សូមផ្សាយកុសលបុញ្ញរាសី ដល់អស់លោកអ្នកទាំងឡាយ នៅក្នុងកម្ពុជរដ្ឋទាំងមូល អោយបានសេចក្ដីសុខចំរើនគ្រប់ប្រការ ។

*ពុទ្ធាទិអានុភាវេន ឧបទ្ទា ចេ ឧបទ្ទវា*

*រោគាចេវន្តរាយា ច វិនស្សន្តុ អសេសតោ ។*

ដោយអានុភាពនៃព្រះរតនត្រៃ មានពុទ្ធរតនៈជាដើម និងអានុភាពនៃធម្មទេសនានេះ បើឧបទ្រព និងរោគ និងអន្តរាយទាំងឡាយកើតមានហើយ ក៏សូមអោយវិនាសបាត់ទៅ កុំបីនៅមានសេសសល់ឡើយ ។

បញ្ចសហស្សសំវច្ឆរំ តិដ្ឋតុ ពុទ្ធសាសនំ !

**គង់ វេង**

អតីតបុគ្គលិកមន្ទីរធម្មការ ខេត្តកំពង់ចាម

## សព្វទានំ ធម្មទានំ ជិនាតិ

*ធម្មទាន ឈ្នះអស់ទានទាំងពួង*

# វចនសំព្ទវិទ្យា នៃ ភាសាខ្មែរបច្ចុប្បន្ន
# Lexicologie du Khmer Moderne

(ត)

## II. *ឡិចសែមខ្មែរដើម ( ពាក្យខ្មែរដើម ) និងដែនសេម៉ង់ទិករបស់វា ក្នុងភាសាខ្មែរ* (១)

យើងចាត់ទុកពាក្យឡិចសែម ជាឯកតាតូចបំផុត មានអត្ថន័យក្នុងវាក្យ-វិទ្យា ឬពាក្យស័ព្ទវិទ្យា ។ ក្នុងភាសាខ្មែរ ឡិចសែម ឬពាក្យខ្មែរដើមទាំងឡាយ បង្កបង្កើតដោយធម្មតា ឬឫសដើម ។ តាមរូបទម្រង់ខាងក្រៅ ឡិចសែមដើម អាចមានទ្រង់ទ្រាយជាស្រះ ជាក្រុមព្យញ្ជនៈ ជាស្រះប្រកបនឹងព្យញ្ជនៈចុង ។ គេអាចទទួលស្គាល់ឡិចសែមដើមជាធាតុរួម ដោយយោលទៅតាមការប្រៀបធៀបជាមួយសន្ទានពាក្យមួយក្រុមៗ ក្នុងសន្ទានរបស់ពាក្យ ។

យើងអាចយកសន្ទានពាក្យមួយក្រុមមកធ្វើជាឧទាហរណ៍ ដូចជាពាក្យ ផ្អែម / pha-aem / ល្ហែម / lhaem / (សម្ដី) បង្អែម / pan-aem / ស្រអែម /sra-aem/ លែម លែម /laem laem / ( ផ្អែមតិចៗ ) ។

---

(១) អត្ថបទស្ដីអំពីឡិចសែម និង ដែនសេម៉ង់ទិកនៅក្នុងភាសាខ្មែរ បានត្រូវបោះពុម្ពជាភាសាបារាំង ( Les lexèmes primaires dans la langue khmère ) ក្នុង « ឯកសារនៃមហាសន្និបាតអន្តរជាតិខាងបូពិវិទ្យា » ភាគ II បារីស គ.ស ១៩៧៦ និងជាភាសារុស្ស៊ី ក្នុងសៀវភៅទី ២៩ របស់អ្នកនិពន្ធ ឡុង សៀម ឈ្មោះ « សិក្សាកថា នៃនិរុត្តិវិទ្យាភាសាខ្មែរ » មូស្គូ គ.ស ១៩៧៥ ។

តាមការប្រៀបធៀបពាក្យទាំងនេះ យើងឃើញថា ឡិចសែមដើម "អែម" /aem/ សម្រាប់សម្គាល់អ្វីដែលផ្អែមស្រទន់ ។ ហេតុនេះ ក្រុមពាក្យទាំងនេះកើតឡើងដោយសំណុំពាក្យ ដែលមានប្រភព និងដែនសេម៉ង់ទិក ដែលជាទំហំនៃនិយមន័យគ្របដណ្តប់លើសន្តានពាក្យមួយក្រុមៗ ។

ក្នុងការសិក្សារបស់លោក វ. ស្មិត W. Schmidt ទៅលើស្លាកស្លាមនៃកំណើតដំបូងនៃភាសាអូស្ត្រូអាស៊ី និងភាសាមន-ខ្មែរ លោកបានកត់សម្គាល់ថាព្យញ្ជនៈចុងនៃភាសាទាំងនេះ គឺជាអតីតផ្នត់ចុង ( suffixes ) ដែលភ្ជាប់ជាមួយគ្នាទៅនឹងឫសស្រះ ។ តាមទស្សនៈរបស់លោក W. Schmidt ឫសដើមអាចផ្សំជាមួយព្យញ្ជនៈ ឬជាមួយស្រះ ។

នៅក្នុងជំពូកវិធីបង្កើតពាក្យតាមកម្លាយសំនួរ ក្នុងសៀវភៅរបស់គាត់ស្តីអំពី « វេយ្យាករណ៍នៃភាសាខ្មែរ » លោក យ. ហ្គូតហ្គោនីវ Y. Gorgoniew ពន្យល់ថា អត្ថិភាពនៃឫសបង្កបង្កើតដោយក្រុមព្យញ្ជនៈផ្ញើជើង ដូចជាក្រុមព្យញ្ជនៈ ឈ្ល /jhl/ ឈ្ន /jhn/ ខ្ទ /kht/ ខ្ញ /khñ/ ស្ត /st/ ស្គ /sg/ ស្ង /sñ/ អាចបង្កើតជាសន្តានពាក្យ ស្ថិតក្នុងដែនសេម៉ង់ទិកសំខាន់បាន ។

ដោយឡែក លោក ជ. ហ្គេសដុង J.Guesdon បានផ្តុំក្រុមសេម៉ង់ទិកនានា តាមឫសដើម ជាលំដាប់លំដោយរបស់វា នៅក្នុង « វចនានុក្រមខ្មែរ-បារាំង » របស់លោក ក៏ប៉ុន្តែ លោកពុំបានពន្យល់អត្ថន័យរបស់ពាក្យទាំងនេះអោយច្បាស់លាស់ទេ ។

ការសិក្សាដ៏ជ្រៅជ្រះនានា លើការបង្កើតពាក្យផ្នូន ឬពាក្យរណ្តំបរិវារស័ព្ទក្រោមឥទ្ធិពលនៃការផ្នូន ឬរណ្តំព្យញ្ជនៈ និងស្រះនៃភាសាខ្មែរ អាចសំដែងចេញនូវសញ្ញាសេម៉ង់ទិកជាក់លាក់ ។ ការសិក្សានេះ អាចអោយយើងធ្វើចំណាត់ថ្នាក់នៃឡិចសែមដើមរបស់ភាសាខ្មែរ ។ ការវិភាគឡិចសែមដើមទាំងនេះ ធ្វើអោយយើង

ឈានទៅដល់ការកំណត់និយមន័យនៃសញ្ញា ដែលស្រះ និងព្យញ្ជនៈនីមួយៗមាន ។

ឡិចសែមដើមនានាដែលការសិក្សាបានលើកយកមកពិភាគ គឺឡិចសែមមួយចំនួន តាមរូបមន្ត ស្រះ + ស្រះ និងស្រះ + ព្យញ្ជនៈ ហើយឡិចសែមដើមទម្រង់ទាំងនេះហើយ ដែលត្រូវបានចាត់ទុកជាមូលដ្ឋានក្នុងការបង្កើតពាក្យខ្មែរ មួយចំនួនធំ ។ ចំណែកឡិចសែមដើមដែលបង្កើតដោយក្រុមព្យញ្ជនៈ ឬបង្កើតដោយស្រះ មានចំនួនមិនច្រើនប៉ុន្មានទេ ប៉ុន្តែបានដើរតួដ៏សំខាន់ក្នុងការបង្កបង្កើតពាក្យនៃភាសាខ្មែរ ។ តទៅនេះ យើងនឹងសិក្សាអំពីទម្រង់ខាងនិយមន័យរបស់ឡិចសែមទាំងឡាយ ព្រមទាំងពាក្យឫស ឬពាក្យដើម ដែលបានមានកំណកំណើតចេញអំពីឡិចសែម ទាំងឡាយនោះ ។

*១. ឡិចសែមដើមដែលកើតឡើងដោយស្រះ + ព្យញ្ជនៈចុង :*

1- អក់ / ak / សំដែងគំនិតបញ្ជាក់នូវអ្វីដែលទាក់ទងនឹងការអាក់ដំណើរ ។ ពាក្យទាំងនេះ គឺជាពាក្យប្រកបដោយស្រះខ្លីកន្ត្រាក់ [ អ ] និងព្យញ្ជនៈបំពង់ក [ ក ] ដែលជាព្យញ្ជនៈប្រកបដោយសន្ទុះខ្យល់ចេញ ។

ហក់ / hak' / ( ទឹក )

ខក់ / khak' / ( ស្ទះបំពង់ក )

ក្អក / ka-ak / ( ក្អកក្រដាស )

ស្អក / sa-ak / ( មិនច្បាស់លាស់ )

តក់ / tak' / ( ពាក្យគ្រាប់តំណក់ទឹក

2- អន់ ~ អួន / an / / un / ( សំដែគំនិតបញ្ជាក់នូវអ្វីដែលមានសភាពតូច ឬខ្សោយ ឬថយកម្លាំង )។

ឆ្អន់ /cha-an'/ ( ឆ្អែត )
ស្រន់ /sran'/ ( ធូរស្រាល )
ស្នូរ [ អិប់ ] [ អិល់ ] ។
កូន /kun/ ( តូច )
ប្អូន /pa-un/ ( បន្ទាប់ )

3- អប់ អល់ /ap'/ /al'/ សំដែងគំនិតបញ្ឈាក់នូវអ្វីដែលទាក់ទងនឹង ឧបសគ្គ ភាពទាល់ច្រក ភាពស្ទះ ។ ក្នុងកាលៈទេសៈខ្លះ ស្រៈខ្លី [ អ៊ ] ប្រកបដោយ ស្នូរ [ អិប់ ] [ អិល់ ] ។

ថប់ /thap'/ ( ស្ទះដង្ហើម )
ហប់ /hap'/ ( ណែន )
កប់ /kap'/ ( កប់ក្នុងដី )
ងប់ /nap'/ ( ឱនមុខ )
ទប់ /dap'/ ( រាំង )
ឈប់ /jhap'/ ( ឈប់ )
ទល់ /dal'/ ( ទ្រ )
ជល់ /jal'/ ( បុក )
ញល់ /ñal'/ (ជន្ល )
កល់ /kal'/ ( ធ្វើអោយនឹង )
វល់ /val'/ ( ក្រពុលមុខ )
ហល់ /hal'/ ( ឆ្អែត )

4- អប /ap/ សំដែងគំនិតបញ្ជាក់នូវអ្វីទាក់ទងនឹងភាពជិតជិត ឬអ្វីដែលបកត្រឡប់មកពីទិសខាងដើមវិញ ។ ស្រៈ [ អ ] អាចត្រូវជំនួសដោយស្រៈ[ អ៊ ] ។

តប /tap/ ( ឆ្លើយ )

កប /kap/ ( ផ្ទាំសក្តិសិទ្ធិ )

រប /rap/ ( ចងភ្ជាប់ )

ស្រប /srap/ ( យល់ព្រម )

ប្រប /prap/ ( ចំក្បែរ )

5- អស់ / ah / សំដែងគំនិតបញ្ជាក់នូវអ្វីដែលមានភាពកំសោយ ថយកម្លាំង ។ ព្យញ្ជនៈចុងព្យាង្គ ជាព្យញ្ជនៈខ្យល់ [ ហ ] ។

សោះ /sah'/ ( អស់កំលាំង, ទទេ )

លោះ /lah'/ ( បំបែក )

តោះ /tah'/ ( សោះអង្គើយ ) ក្នុងពាក្យ «តោះតើយ» /tah'toey/

ផ្អស់ /pha-ah'/ ( រំលែងមានកម្លាំង )

ខ្សោះ /khsah'/ ( ដង្ហក់, ឬហេវ )

6- អាក់ ~ អ៊ាក់ /ak/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលជាឧបសគ្គ ជាចលនាបញ្ឈប់ ឃាត់ឃាំង ។ ឡិចសែម [ អាក់ ] កកើតដោយការផ្សំស្រៈខ្លីខាងមុខ [ អា ] + ព្យញ្ជនៈ [ ក ] ដែលជាព្យញ្ជនៈស្ទះ ។ គេតែងឃើញនូវផលិតភាពនៃការប្រើព្យញ្ជនៈ [ ក ] ក្នុងការបង្កើតពាក្យតាមវិធីផ្នត់នីយកម្ម ( affixation ) ។

កាក់ /kak'/ ( នៅស្អាក់ស្ទើរ )

ទាក់ /dak'/ ( ទើសទែង )

ពាក់ /pak'/ ( ពាក់ )

វាក់ /vak'/ ( នៅងឿងឆ្ងល់ )

7- អាយ ~ អ៊ាយ /ay/ /'a:y/ បញ្ជាក់នូវអ្វីដែលឃ្លាតចេញពីទីដៅ អ្វីដែលចាកចេញឆ្ងាយ ។ ឡិចសែម [ អាយ ] កើតឡើងដោយការផ្សំស្រះវែង [ អា ] + នឹងព្យញ្ជនៈ [ យ ] ដែលជាព្យញ្ជនៈខ្យល់យឺត ) ។

កាយ /kay/ ( កាយដី )

សាយ /say/ ( ពង្រាយ )

ផាយ /phay/ ( ពោល )

រាយ /ray/ ( រាយពាយ )

ភាយ /bhay/ ( ចោលក្លិន )

នាយ /nay/ ( ឯនាយ ainay: លោកខាងមុខ )

8- អិត ~ អ៊ិត [ it ] [ 'it ] ( សំដែងគំនិតបញ្ជាក់នូវអ្វីដែលជិតជាប់ ដែលស្អិត ។ ពាក្យសរសេរ [ ឥដ្ឋ ] ជាពាក្យខ្មែរសុទ្ធ ។ ឡិចសែម [ អិត ] កើតមកពីស្រះបិទតូច [ អិត ] + ព្យញ្ជនៈធ្មេញ [ ត ] ។

កិត /kit/ ( កកិត )

ចិត /cit/ ( កាត់តឿងៗ )

ឆិត /chit/ ( ជិតៗ )

ជិត /jit/ ( ជិតស្លុង, កៀរ )

បិទ /pit/ ( បិទ, មិនមែនពាក្យខ្ចីពីភាសាបាលី )

សិត /sit/ ( រំលីងដែក, ឬចាក់ទឹកតិចៗ )

ស្អិត /s-it/ ( ជាប់ជិត )

9- អិច ~ អ៊ិច /ic/ /'ic/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលមានភាពតូចតិច ស្រួច និងភាពរហ័ស ។ ឡិចសែម [ អិច ] កកើតដោយការផ្សំស្រៈខ្លីបិទតូច [ អ៊ិច ] ក្នុងព្យញ្ជនៈខ្យល់ក្រអូម [ ញ ] ។

តិច /tic/ ( បន្តិច )

ទិច /dic/ ( ទិច )

កិច /kic/ ( ងាកបន្តិច )

ញិច /ñic/ ( សង្រ្កិប )

ប៉ិច /pic/ ( ដូចដុះ )

បិច /bic/ ( ច្បិច )

ប្រិច /pric/ ( ហើរយ៉ាងរហ័ស )

ព្រិច /bric/ ( បិទបើក )

ស្រិច /sric/ ( ភ្លៀងស្រិចៗ )

10. អុក ~ អ៊ុក /uk/ /'uk/ អុះ, អ៊ុះ /uh/ /'uh/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលមានចលនាពីលើចុះក្រោម ចលនាពីឆ្វេងទៅស្តាំ និងបញ្រ្ចាសមកវិញ ។

បុក /puk'/ ( ចុក )

រុក /ruk'/ ( រុក )

លុក /luk'/ ( រុករាន )

ចុះ /cuh/ ( ចុះ )

ពុះ /buh/ ( កាប់ )

រុះ /ruh/ ( រុះ )

ជុះ /juh/ ( បត់ជើង )

ជ្រុះ /jruh/ ( ធ្លាក់ )

ធ្លុះ /dhluh/ ( ធ្លុះ, ធ្លាយ )

ច្រុះ /cruh/ ( ដាំបង្គោល )

11- អុញ ~ អ៊ុញ /uñ/ /'uñ/ សំដែងគំនិតបំព្រួញបញ្ចាក់នូវអ្វី ដែលមានភាពបំព្រួញ ភាពអង្កុញ ។ ឡិចសែម [ អុញ ] កកើតដោយការផ្សំស្រះខ្លី [អុ] + ព្យញ្ជនៈក្រអូមចុងព្យាង្គ [ ញ ] ។

សុញ /suñ/ ( ទាល់គំនិត )

កុញ /kuñ/ ( ពាក្យបញ្ចាក់ពីចលនាបត់ជើង )

ចុញ /cuñ/ ( ឧទានស័ព្ទសំដែងការភ្ញាក់ )

តុញ /tuñ/ (ធាត់ហើយទា ប)

ការវិភាគពាក្យបង្កើតលើមូលដ្ឋានឡិចសែម /uk/ , /uh/ , /uñ/ អាចអោយយើងមានគំនិតទូទៅមួយ ដែលសំដែងបញ្ចត្តិទាក់ទងនឹងអ្វីដែលមានចលនាជាទូទៅ ពីលើមកក្រោម និងពីម្ខាងទៅម្ខាងទៀត ។

12- អុំ ~ អ៊ុំ /um/ /'um/ សំដែងគំនិតបញ្ចាក់នូវអ្វីដែលទាក់ទងនឹងភាពប្រមូលផ្តុំ និងអ្វីដែលមានសណ្ឋានមូល ។ ឡិចសែម [ អុំ ] [ អ៊ុំ ] អាចមានកាឡារូប (variante) ជា [ អុំ ] ~ [ អំ ] នៅក្នុងពាក្យខ្លះៗ ហើយឡិចសែម

ទាំងនេះ បិទដោយព្យញ្ជនៈច្រមុះ និងបបូរមាត់ [ ម ] ដែលច្រើនតែសំដែងគំនិតបង្រួបបង្រួមនៅក្នុងកិរិយាស័ព្ទ ។

ក៉ុំ /kum/ ( ផ្ដុំ )

រ៉ុំ /rum/ ( ស្រោប, ច្រក )

ជុំ /jum/ ( រួមគ្នា )

ឃុំ /ghum/ ( ឃុំឃាំង )

ផ្សំ /phsam/ ( បង្រួម )

13- អួង ~ អ៊ួង /un / /'u:n/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលមានជម្រៅ មានប្រហោង ។ ឡិចសែមនេះ កើតឡើងដោយការផ្សំស្រះវែង [ អូ ] [ អ៊ូ ] និងព្យញ្ជនៈច្រមុះ [ ង ] ។

ឈ្ងូង /jhun/ ( ឆក )

អណ្ដូង /antun/ ( អណ្ដូងទឹក )

14- អួច ~ អួញ /uoc/ /ouñ/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលទាក់ទងនឹងការបំព្រួញទៅនឹងភាពក្រហួច ។ ត្រូវសម្គាល់ថាការបន្លឺស្រះផ្សំ [ អួ ] /uo/ ធ្វើតាមចលនាបំព្រួញតាមចុងបបូរមាត់ទាំងពីរ អោយក្រហួចស្រួចទៅខាងមុខ ត្រូវគ្នានឹងរូបភាពបញ្ជាក់ដោយន័យរបស់ពាក្យ ។ គេអាចសម្គាល់បាតុភូតនេះ ក្នុងឡិចសែមដើម មួយចំនួនធំ ។

ហួច /huoc/ ( បញ្ចេញខ្យល់ច្រៀង )

ខួច /khuoc/ ( ស្នាមខូងលើថ្គាល់ )

ដួច /tuoc/ ( ផ្ដួចផ្ដើម )

ក្ងួច /kuoc/ ( ខ្យល់ក្ងួច )
ទ្ងួញ /duoñ/ ( យំស្រែក )
រ្ងួញ /ruoñ/ ( រ្ងួញ )
ជ្រួញ /jruoñ/ ( ជ្រួញ )
ព្រួញ /bruoñ/ ( ព្រួញ )

15- អើ ~ អ៊ើ /oe/ , /'a / ~ / / សំដែងគំនិតបញ្ជាក់នូវអ្វីដែលទាក់ទងនឹងចលនាឡើងលើ ទាក់ទងវឌ្ឍនាការ ឬអ្វីជាវិជ្ជមាន ។ ឡិចសែម [អើ] កកើតឡើងដោយការផ្សំស្រះ [ a + ] ដែលការបន្លឺសំឡេងបន្ទាញអោយមានការបង្ហើបមាត់ឡើងលើ ដែលជាចលនាស្របទៅនឹងនិមិត្តរូបនៃនិយមន័យរបស់ពាក្យខ្មែរជាច្រើន ដែលបានកើតឡើងដោយស្រះ [ អើ ] [ អ៊ើ ] ។ ឡិចសែមនេះ អាចបង្កើតឡិចសែមដទៃទៀត ដោយការផ្សំព្យញ្ជនៈដើមព្យាង្គ និងព្យញ្ជនៈចុងព្យាង្គ ដែលបានបង្ហាញនៅក្នុងឡិចសែមកម្លាយពី អើ គឺ អើក_អើង_អើត_ ) ។

ឡិចសែម អើ / អ៊ើ ជាពាក្យដែលមានផលិតភាពជាងគេ ដោយហេតុថាឡិចសែមនោះ បានប្រកបដោយដែនសេម៉ង់ទិកដ៏ទូលំទូលាយ គ្របដណ្តប់លើវាក្យវាក្យស័ព្ទ ដែលជាពាក្យសមាស ចំនួនជាងមួយរយ ហើយនេះមិននិយាយអំពីពាក្យកម្លាយ ហើយនិងពាក្យសមាស ឬពាក្យរណ្តំបរិវារស័ព្ទដែលបានកើតឡើងពីពាក្យដើមទាំងអស់នេះឡើយ ។

តទៅ យើងធ្វើគំនូសសេម៉ាមួយដែលកើតចេញពីឡិចសែម អើ / អ៊ើ ដែលបញ្ជាក់អំពីពាក្យដើមទាំងឡាយមានចំនួនជាងមួយរយ ។ គំនូសសេម៉ានេះ អាចប្រើប្រាស់សំរាប់បញ្ជាក់អំពីផលិតភាពនៃឡិចសែមដទៃទៀត ព្រោះជាគំនូសសេម៉ាធ្វើឡើងស្របតាមបែបបទ និងទម្រង់នៃពាក្យខ្មែរដើមទាំងឡាយ ដែលជា

ពាក្យឯកព្យាង្គ ។ គួរគប្បីបញ្ជាក់ផងដែរថា នៅក្នុងក្រឡានីមួយៗ អាចមានពាក្យដើមមួយ ហើយពាក្យដើមណាមានគំនូសគ្រេពីខាងមុខ គឺថា ពាក្យទាំងនោះមានន័យមិនច្បាស់លាស់ ហើយស្ថិតនៅក្នុងសមាសភាពនៃពាក្យកម្លាយ ។

ឧទាហរណ៍ ពាក្យ អើក ស្ថិតនៅក្នុងសមាសភាពនៃពាក្យកម្លាយត្អើក ។

( **ជាក់គំនូសសេម៉ា** )

15-1- អើ /oek/ , /'a k/

| | | |
|---|---|---|
| លើក | /loek/ | ( កាន់ឡើងលើ ) |
| ពើក | /poek/ | ( កំរើកឡើងលើ ) |
| បើក | /boek/ | ( បើក ) |
| គ្រើក | /kroek/ | ( រញ្ជួយ ) |
| ត្អើក | /ta-oek/ | ( ក្អក ) |

ក្នុងពាក្យដូចបានលើកខាងលើ អត្ថន័យសំដែងចេញឡើងរបស់ព្យញ្ជនៈបពង់ក /k/ បញ្ជាក់ការសំដែងការកំរើក ការរញ្ជួយ ។

15-2- អើង ~ អ៊ើង /oen/ /'a n/

| | | |
|---|---|---|
| ប៉ើង | /poen/ | ( អណ្តែតលើអាកាស ) |
| ពើង | /boen/ | ( ពើងទ្រូង ) |
| ឡើង | /loen/ | ( ឡើង ) |
| ថ្កើង | /thkoen/ | ( កើន ) |

15-3- អើត ~ អ៊ើត /oet/ , /'a t/

តើត /toet/ ( ចំតើតជើង )

កើត /koet/ ( កើត )

ឆើត /choet/ ( មានសកម្មភាពខ្ពស់ )

ផើត /phoet/ ( ឡើងតិចៗ )

ពើត /boet/ ( ចាប់ឈើ )

ក្រៅពីពាក្យកើតដោយឡិចសែមដើម /oek/ , /oen/ , oet/ , នៅមានពាក្យមួយចំនួនធំទៀត ប្រើផ្សំជាមួយស្រៈផ្សំ " oe" ប្រកបជាមួយព្យញ្ជនៈចុងដទៃទៀត ។ ក្នុងចំនួនពាក្យនៃចំណោមពាក្យចំនួន ៨០ នៃក្រុមនេះ ស្រង់ចេញពីវចនានុក្រមខ្មែរ យើងឃើញថា ស្ទើរគ្រប់ពាក្យ សំដែងពីសញ្ញាណសេម៉ង់ទិកដដែលៗនៃការដំឡើងនៃកំណើនចលនាឡើងលើ ។ ពាក្យនីមួយៗ អាចបង្កើតជាសន្តានពាក្យកម្លាយ ឬសមាស ឬរណ្ដំបរិវារស័ព្ទដ៏ច្រើនសន្ធឹកសន្ធាប់ ។

យើងលើកពាក្យមូលដ្ឋានមួយផ្សំជាមួយឡិចសែមដើម លើ /loe/ យើងរកបានកម្លាយពាក្យមួយចំនួន បង្កើតលើមូលដ្ឋាននៃពាក្យ [ លើ ] ហើយដែលបង្កើតបាននូវសន្តានពាក្យនៃពាក្យនេះ ។

លើក /loek/ ( លើក )

លើស /loes/ ( លើស )

ឡើង /loen/ ( ឡើង )

លើយ /loey/ ( លើយ )

ភ្លើ /bhloe/ ( រាយមាយ )

រលើ /raloe/ ( ព្រហើន )

រលើង /raloen/ ( រដក )

រំលើក /ramloek/ ( រំលើក )

រំលើង /ramloen/ ( ធ្វើអោយរលើង )

ដំឡើង /tamloen/ ( បន្ថែម )

បំភ្លើស /pambhloes/ ( និយាយហួសពីការព ត)

ល្មើស /lmoes/ ( ល្មើសច្បាប់ )

លើ្បក /lpoek/ ( រឿងប្រឌិត )... ។ ល ។

16-អៀ /ie/ / 'i / សំដែងគំនិតបញ្ជាក់នូវអ្វីដែលមានភាពមិនត្រង់តាមលំនាំនៃទីដើម នូវអ្វីដែលល្អៀង ឃ្លៀងឃ្លាតពីទីដើម ។ ឡិចសៃមប្រកបដោយស្រះសំយោគ [ អៀ ] /'i / ច្រើនជាព្យាង្គបិទដោយព្យញ្ជនៈ [ ក ] [ ង ] [ ច ] [ ត ] [ ស ] ។ រីឯស្រះសំយោគ [ អៀ ] គឺជាស្រះវែងខាងមុខ កើតដោយការផ្សំស្រះ [ អិ + អេ / អើ ] ហើយការបន្លឺសំឡេងបន្ទាញអោយមានការលំអៀងគ្រឿងបំពងសំឡេងមកកម្រិតទាប ។

16-1 អៀក ~ អៀត /iek/ /iet/ បញ្ជាក់នូវអ្វីដែលទាក់ទងនឹងអ្វីដែលចង្អៀត ដែលរវាតពីទីដើម ។

កៀក /kiek/ ( កាន់ដៃ )

បៀក /biek/ ( បៀកម្ហូ )

គៀប /giep/ ( កៀប )

ច្រៀក /criek/ ( កាត់ជាចំរៀកតូចៗ )

ត្បៀត /tpiet/ ( ឈរជ្រៀត )

ថ្គៀប /thgiep/ ( ឈាក់, គៀប )

សៀត /siet/ ( ស៊កនៅខាង )
បៀត /piet/ ( ជិត )
ជៀប /jiep/ ( ជៀបមាត់ ) ។

16-2- អៀង /ien/ /'i n/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលមានភាពទេរ ទ្រេតពីទីដើម ។

កៀង /kien/ ( ប្រមូលហ្វូងសត្វ
ឆៀង /chien/ ( ងាក )
វាង /vien/ ( ដើរវាង )
ល្អៀង /la-ien/ ( ងាក )
ជ្រៀង /crien/ ( ទ្រេត )
ស្រលៀង /sralien/ ( ភ្នែកស្រលៀង )

16-3-អៀច ~ អៀស /iec/ ~ /ies/ ~ /'iec/ /'ieh/ សំដែងគំនិត បញ្ជាក់នូវអ្វីដែលមានភាពលំអៀង ។

វៀច /viec/ ( ងាក, រមួល )
គៀច /giec/ ( គេច )
ញៀច /ñiec/ ( មួលត្រចៀក )
កៀស /kies/ ( អោយឃ្លាតដោយដៃ )
ចៀស /cies/ ( ជៃងផ្លូវ )
ភៀស /bhies/ ( ចេញពីប្រទេស )

17- អឹង ~ អ៊ឹង /in/ /'in/ ឡិចសែមដើមនេះ មានលក្ខណៈពិសេសសំរាប់ត្រាប់សំឡេង និងប្រភពពាក្យត្រាប់ដែលសំដែងគំនិត បន្តឹងសំឡេងលំញ័រចលនា ។ ឡិចសែម [ អឹង ] កកើតឡើងដោយការផ្សំស្រៈបិទខាងមុខ [អិ] និងព្យញ្ជនៈខ្ទរខ្ទារខ្យល់ច្រមុះ [ ង ] ។

តឹង /tin/ ( តឹង )
រឹង /rin/ ( រឹង )
ប្រឹង /prin/ ( ប្រឹង )
ម៉ឹង /min/ ( ត្រាប់សម្លេងលោហៈ )
ណឹង /nin/ ( ត្រាប់សម្លេងជួង )
អឹង /in/ ( ចំពោះអឹងអាប់ " in-ap " កងរំពង )

18- អែ ~ អ៊ែ /ae/ /'ae/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលបែកចេញពីទីដើម ឬអ្វីដែលបែងចែក ។ ស្រៈផ្សំ [ អែ ] ជានិបាតស័ព្ទបញ្ជាក់ទីកន្លែងដែលស្ថិតនៅឃ្លាតពីទីដើម ។ ផលិតភាពនៃស្រៈផ្សំ [ អែ ] ក្នុងការបង្កើតពាក្យ និងលេចមានឡើង កាលណាស្រៈនេះប្រកបជាមួយព្យញ្ជនៈចុងព្យាង្គ [ក] និង [ង] ។

កែ /kae/ ( ប្រែ )
តែ /tae/ ( ប៉ុន្តែ )
បែរ /bae/ ( ងាកទៅម្ខាង )
ឡែ /lae/ (ឡែឡប់ )
កែក /kaek/ ( ស្មែងកែក )
ចែក /caek/ ( បែងចែក )
បែក /baek/ ( ឃ្លាត , បែក )

ប៉ែក /paek/ ( ផ្នែក )
លែក /laek/ ( ផ្សេង )
ហែក /haek/ ( រហែក )
រែក /reak/ ( រែកលើស្មា )
វែក /vaek/ ( វែកញែក )
ជែក /jaek/ ( ជៀសទៅមុខ )
កែង /kaen/ ( កែងផ្លូវ )
បែង /paen/ ( បែងចែក )
អែង /aen/ ( ឯង, គេឯង )
ចែង /caen/ ( បញ្ចេញពន្លឺ ( ព្រះអាទិត្យ )
ជែង /jaen/ ( ផ្នែក )
លែង /laen/ ( លះលែង )
រែង /raen/ ( រែងអង្ករ )
សែង /saen/ ( សែងទឹក )

19- អោង /aon/ /'aon/ សំដែងគំនិតបញ្ញាក់ចលនា និងភាពកោង ( ទៅលើ ឬទៅក្រោម ឬទៅខាង ) ។ ឡិចសែម [ អោង ] ផ្សំដោយស្រៈសំយោគ [ អោ ] ហើយការបន្លឺសំឡេងបន្ទាញអោយអណ្ដាតមានរាងកោង ។ គឺជារូបារម្មណ៍ដែលកើតមានក្នុងនិយមន័យរបស់ពាក្យប្រកបដោយស្រៈ [ អោ ] មួយចំនួនដែលជាកិរិយា ឬគុណស័ព្ទ ។

កោង /kaon/ ( មិនត្រង់ )
ទោង /daon/ ( យោលទោង )

ពោង /baon/ ( ពោងពាយ )

ប៉ោង /paon/ ( ប៉ោង )

តោង /taon/ ( ភ្ជាប់ខ្លួនទៅនឹងដែក ឬនឹងខ្សែ )

20- អាំង ~ អ៊ាំង /an/ /an/ / an/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលទាក់ទងនឹងឧបសគ្គ ការបិទ ឬការឈប់ ។ ឡិចសែម [ អាំង ] [ អ៊ាំង ] កើតឡើងដោយការផ្សំស្រះ [ អា ] ឬស្រះ [ អ៊ា ] / a/ + ព្យញ្ជនៈខ្យល់ [ ង ] ។

គាំង /gan/ ( ឈប់ឥតដឹងមុន )

វាំង /van/ ( ហ៊ុំព័ទ្ធដោយរបង )

ពាំង /ban/ ( រាំងផ្លូវ )

ឃាំង /ghan/ ( បិទច្រក )

រាំង /ran/ ( បិទផ្លូវ, ឈប់ភ្លៀង )

បាំង /pan/ ( លាក់ )

21- អេះ ~ អែះ /eh/ /aeh/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលទាក់ទងនឹងផុយ ឬរបេះចេញពីទីដើម ។ ឡិចសែម [ អេះ ] [ អែះ ] កកើតឡើងដោយការផ្សំស្រះសំយោគ [ អែ ] ទាំងព្យញ្ជនៈមិនស្ទះ ហើយហូរខ្យល់ [ ហ ] បញ្ជាក់នូវអារម្មណ៍ បញ្ជាក់នូវអ្វីដែលអន់ខ្សោយធ្លាក់ចុះ ។

*( នៅមានត )*

# ប្រវត្តិតាត្រសក់ផ្អែម

តាមការនិទានរបស់លោកតា ក្រូច ទេព [១]

រឿងតាត្រសក់ផ្អែម ត្រូវបានអ្នកស្រាវជ្រាវ ចាត់ជារឿងប្រវត្តិសាស្ត្រមួយ ។ រឿងនេះ មានការទាក់ទងយ៉ាងអាចិកំបាំងនៅឡើយ ទៅនឹងព្រឹត្តិការណ៍តំណរាជវង្ស " វ្ម័ន " នៅសម័យអង្គរ ។ ប៉ុន្តែ ទោះជាយ៉ាងណា ក៏អ្នកស្រាវជ្រាវទាំងជនជាតិបារាំង ទាំងជនជាតិខ្មែរ បានចាត់ទុកតាត្រសក់ផ្អែម ជាស្តេចខ្មែរមួយអង្គដែលបានឡើងសោយរាជ្យ នៅក្នុងកំឡុងឆ្នាំ ១៣៣៦ ដល់ ១៣៤០ នៃ គ.ស. ។

អ្វីជាការយកចិត្តទុកដាក់ របស់អ្នកស្រាវជ្រាវនោះ គឺថា រឿងតាត្រសក់ផ្អែមនេះ មាននៅក្នុងរឿងព្រេងប្រទេសភូមាផង ប្រទេសថៃផង ប្រទេសឡាវផង និងប្រទេសកម្ពុជាផង ។ ទាំងបួនប្រទេស តែងតែចាត់ទុករឿងនេះ ជារឿងព្រេងប្រចាំជាតិរៀង១ខ្លួន ។ បើនិយាយពីនៅកម្ពុជាវិញ រឿងនេះ ត្រូវបានគេនិទានឡើង ដោយមានការទាក់ទងទៅនឹងទីតាំង ស្ថាននាម និងព្រះមហាក្សត្រ ។

កន្លងមក យើងធ្លាប់ៗ ធ្លាប់អានរឿងនេះ តាមរយៈអត្ថបទអក្សរសិល្ប៍ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅប្រជុំរឿងព្រេង ហើយស្នាដៃទាំងនោះ មានភាពស្រដៀង១គ្នា ។ ចំណែកពេលនេះ ខ្ញុំនឹងបង្ហាញជូននូវរឿងព្រេងនិទាន ស្តីពីប្រវត្តិតាត្រសក់ផ្អែមមួយទៀត ដោយមានការទាក់ទងទៅនឹងប្រវត្តិទីតាំង ស្ថាននាម មួយ

---

(១) លោកតាក្រូច ទេព អាយុ ៧២ ឆ្នាំ មានដើមកំណើតនៅភូមិប្រដាកខាងកើត ឃុំប្រដាក ខេត្តសៀមរាប ។ ខ្ញុំនិងមិត្តភក្តិចំនួន ១០ នាក់ទៀត បានជួបសម្ភាសន៍ជាមួយគាត់ នៅថ្ងៃទី ០៥ .១១. ១៩៩៥ វេលាម៉ោង ២ និង ៤៥ នាទីរសៀល ។ គាត់ប្រហែលជាជនជាតិសំរែ ដែលរស់នៅតំបន់នេះច្រើនតំណមកហើយ ។

ចំនួន នៅតំបន់អង្គរភាគខាងជើង និងខាងកើត ដែលត្រូវបានរក្សា រហូតដល់សព្វថ្ងៃនេះ ។ ហេតុផលនៃការលើកយករឿងនេះមកអធិប្បាយ ក្នុងគោលបំណងតែមួយគត់ គឺ " រក្សាមរតកអក្សរសិល្ប៍ខ្មែរ " ។ ពីព្រោះថា រឿងនេះមានលក្ខណៈប្លែកគ្នាពីរឿងមុនៗ ត្រង់ថា វាមានទាក់ទងទៅនឹងស្ថាននាមនៅតំបន់អង្គរ ហើយយើងក៏ធ្លាប់សរសេរក្នុងសៀវភៅ " ដប់ថ្ងៃនៅទីក្រុងអង្គរ " តំកល់ទុកនៅមហាវិទ្យាល័យប្រវត្តិវិទ្យាដែរ ។ សៀវភៅនោះ ត្រូវបានរៀបរៀងឡើងដោយនិស្សិតប្រវត្តិវិទ្យាចំនួន ១១ នាក់ រួមទាំងខ្ញុំផង ប៉ុន្តែ ការផ្សាយមិនមានលក្ខណៈទូលំទូលាយ ។

ដូច្នេះហើយទើបខ្ញុំសម្រេចចិត្ត ចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយានាពេលនេះ ជូនមិត្តអ្នកអានពិចារណា ប៉ុន្តែ សូមមិត្តអ្នកអានយល់ថា នេះពុំមែនជារឿងប្រវត្តិសាស្ត្រជាក់ស្តែងនោះទេ វាគ្រាន់តែជារឿងព្រេងនិទាន ដែលប្រជារាស្ត្រខ្មែរចេះចាំ ហើយនិទានតៗគ្នា តែប៉ុណ្ណោះ ។

មយ៉ាងទៀត ចំពោះចំណោទមួយដែលបានចោទសួរថា បើរឿងព្រេងតាត្រសក់ផ្អែម ត្រូវបានជនជាតិ ៤ ប្រទេសចាត់ទុកថាជារឿងរបស់ខ្លួន រៀងៗខ្លួននោះ តើយើងអាចរិះរកញែករកហេតុផលមកពន្យល់បានទេ ?

ចំពោះទស្សនៈខ្ញុំ យល់ថា បាន, ទោះបីជារឿងតាត្រសក់ផ្អែមរបស់ភូមាគេថាបានចាប់កំណើតឡើងតាំងពីសតវត្សទី ១០ ក៏ដោយ ។

យើងត្រូវសង្កេតពិនិត្យរកទីតាំងជាក់លាក់ ដែលមានទាក់ទងក្នុងដំណើររឿង ។ បានសេចក្តីថា យើងត្រូវធ្វើការសិក្សាស្ថាននាមដែលមានទាក់ទងក្នុងរឿង ។ ខ្ញុំក៏ជឿជាក់ថា រឿងព្រេងតាត្រសក់ផ្អែម គឺជារឿងរបស់ខ្មែរពិតៗ ព្រោះវាមានទាក់ទងទៅនឹងស្ថាននាម ព្រឹត្តិការណ៍សង្គម ជីវភាពរបស់ខ្មែរ នៅចុងសម័យអង្គរ ។

ពេលនេះ ខ្ញុំសូមទាញអារម្មណ៍មិត្តអ្នកអាន ពិចារណាទៅលើប្រវត្តិតាត្រសក់ផ្អែម របស់អ្នកស្រុកប្រដាក ដូចតទៅនេះ ៖

កាលដើមឡើយ មានឥសីមួយអង្គ គង់ចង្រ្កមភាវនានៅក្នុងព្រៃមួយ ។ សម័យថ្ងៃមួយ មានសត្វចាបមួយគូ ហើររកកន្លែងធ្វើសំបុកសំរាប់ពង ។ ចាបទាំងគូហើររកកន្លែង[១] ពងមិនបាន ក៏ទៅជួបតាឥសីកំពុងសមាធិ ។ ដោយឃើញពុកចង្ការ[២] តាឥសី ទំនងអាចឱ្យខ្លួនងាយស្រួលកាច់សំបុក ចាបទាំងគូក៏ចាប់សរសៃពុកមាត់ចាក់ជាសំបុក ។ ក្រោយមក ចាបញីក៏ពងដាក់ក្នុងសំបុកវា រួចហើរទៅទំលើមែកឈើមួយ នៅជិតទីនោះ ។ ចាបទាំងពីរនិយាយសាសងគ្នាថា : អឺ, ឯងអើយ ! ថាយើងចុះជាសត្វតិរច្ឆាន ក៏គង់នៅមានកូនតពូជពង្ស រួចចុះតាឥសីនោះវិញ[៣] ទៅអនាគត[៤] មានអ្នកណាបន្តពូជពង្ស ?[៥] ចាបនិយាយតែប៉ុណ្ណោះ តាឥសីចាប់ភ្លឹកកើតពិចារណាថា : ឱ អញអើយ ! បើអាត្មាអញមិនចាកសិក្ខាបទ ស្វែងរកប្រពន្ធម្ល៉េះសមអញកំបុតឆ្លុយត្រឹមនេះ គ្មានកូនចៅតទៅមុខទៀតទេ ។

ក្រោយពេលពងចាបញាស់ កូនៗចេះហើរ ហើរចេញអស់ទៅ តាឥសីឈប់តាំងសីល[៦] រួចត្រឡប់មកអាស្រមវិញ ចាកសិក្ខាបទ ដើម្បីចាកចេញទៅរកភរិយា ។ ក្រោយពេលស្វែងរកអស់រយៈពេលយ៉ាងយូរមក អតីតតាឥសីបានទៅជួបនឹងយាយរិ[៧] ដែលរស់នៅក្បែរស្រះដូនរិ ( សព្វថ្ងៃ ស្រះដូនរិ ស្ថិតនៅឃុំត្បែង ខេត្តសៀមរាប ដូនកាលគេហៅថា " ស្រះខ្វារ " ) ។

អ្នកទាំងពីរបានយកគ្នាជាប្តីប្រពន្ធតរៀងមក ។ នៅពេលមានគ្រួសារហើយអតីតតាឥសីបានខិតខំប្រឹងប្រកបរបររកស៊ីចិញ្ចឹមជីវិតជាធម្មតា ក្នុងតួនាទីជា

---

(១) សំដីអ្នកស្រុកប្រដាកថា « បន » ( កន្លែង ) ។ (២) ពុកចង្កា រ អ្នកស្រុកប្រដាក ថា « មាសចង្ការ » ។ (៣) តពូជពង្ស អ្នកស្រុកប្រដាក ថា « តសាសនា » ។ (៤) ចុះតាឥសីនោះវិញ លោកតា គ្រួច ទេព ថា « ចុះអ្នកសមុទតនោតនោះវិញ » ។ (៥) អ្នកស្រុកប្រដាក ថា « បានអុយតសាសនា » ។ (៦) តាគ្រួច ទេព ថា « ចង្រ្កម » ។ (៧) តាគ្រួច ទេព ថា « ដូនរិ » ឬ « យេរិ » គាត់ថាពូជសំរែ ហៅថា « ដូន » ។

មេគ្រួសារ ។ មិនយូរប៉ុន្មាន យាយរិ មានគភ៌ ហើយគភ៌ចេះតែចំរើនវ័យ ប្តីយាយក៏កាន់តែខិតខំប្រឹងរកអដ្ឋបរិក្ខារយ៉ាងគ្រប់គ្រាន់ទុកឱ្យ ។ ពេលនោះ បុត្រយាយរិ មិនទាន់ប្រសូតនៅឡើយទេ តែប្តីរបស់យាយ ក៏លាយាយទៅសាងផ្នួសវិញ ។

គ្រប់ទសមាស យាយរិប្រសូតបានបុត្រមួយ ហើយបុត្រនេះក៏មិនទាន់មានឈ្មោះជាអ្វីដែរ ។ ទារកចេះតែចំរើនវ័យបន្តិចម្តងៗ រហូតដល់ពេលវាចេះនិយាយ ។ ថ្ងៃមួយ កុមារតូច ក៏សួរទៅម្តាយថា ៖ ម៉ែ, ឯណាឪពុក[១] ខ្ញុំ ?

ម្តាយឆ្លើយថា ៖ អឺ ! ឪពុកឯង នៅឆ្ងាយណាស់ អញប្រាប់ឯងឥឡូវនេះមិនបានទេ ចាំឯងធំសិនចាំអញប្រាប់ !

ពេលវេលាចេះតែកន្លងផុតទៅយ៉ាងយូរ ចំណែកគ្រួសារយាយរិ ប្រកបរបររកស៊ីធ្វើស្រែចំការជាធម្មតា ។ បុត្រយាយរិ ចំរើនវ័យបាន ១៨ ឬ ១៩ ឆ្នាំហើយក៏នៅតែមិនទាន់មានឈ្មោះនៅឡើយ ។ ថ្ងៃមួយ បុរសកំលោះក៏បានសួរម្តាយម្តងទៀតថា ៖ ម៉ែ ឪពុកកូនជានរណា ? គាត់នៅឯណា ?

ម្តាយក៏ឆ្លើយទៅប្រាប់កូនវិញថា ៖ ឪពុកកូន ជាតាឥសី គាត់នៅឯភ្នំ (មិនដឹងថាឈ្មោះភ្នំអ្វី ) ។ កូនសួរទៀតថា ៖ បើដូច្នោះទៅរកម្តេចឃើញ !

ម្តាយឆ្លើយថា ៖ អឺ កូនអើយ ! ដើរតាមផ្លូវគេកាច់តម្រុយនោះទៅឃើញហើយ !

ក្រោយមក កូនប្រុសយាយរិ ក៏ចាកចេញដំណើរតាមផ្លូវដែលម្តាយបង្ហាញ ។ គាត់ដើរទៅដើរទៅ នៅតែមិនជួប នៅតែមិនឃើញ ស៊ីក៏មិនឃើញៗ[២] គាត់ក៏នៅតែដើរទៅមុខជានិច្ច រហូតដល់អស់កំលាំង[១] ។ អ្នកកំលោះបានប្រាស់ខ្លួនដេកនៅក្រោមដើមឈើមួយ ។ នៅពេលគាត់ដេកលក់ តាឥសីបានយកគ្រាប់

(១) តាក្រូច ទេព ថា " អាពុ " ។

(២) គាត់ថា ( តាក្រូច ទេព ) " ស្អុយក៏មិនឃើញ " ។

ត្រសក់មួយបង្វេច កាំបិតមួយ [២] និងបាយមួយកញ្ចប់ រួចនិម្មិតប្រាប់បុត្ររបស់ខ្លួនកំពុងដេកលក់ ប៉ុន្តែ លោកមិនបានឱ្យឃើញរូបឡើយ ។ រួចរាល់កិច្ចហើយ តាឥសីបាននិមន្តទៅកាន់កន្លែងចង្ក្រមភាវនា [៣] វិញ ។ លុះបុរសភ្ញាក់ពីដេក បានឃើញវត្ថុដូចគ្នានឹងនិម្មិត [៤] បានប្រាប់មែន ។ ដោយមានសេចក្ដីស្រេកឃ្លានផង បុរសលាកញ្ចប់បាយបរិភោគយ៉ាងប្រញាប់ រួចម្នីម្នារិលត្រឡប់មកផ្ទះវិញ តាមបំរាប់និម្មិត ។

មកដល់ផ្ទះ បុរសបានជួបម្ដាយ ហើយជំរាបថា ៖ ម៉ែ ! ខ្ញុំបាទ [៥] ឥតបានឃើញតាឥសីជាឪពុកទេ ។ ប៉ុន្តែ ពេលខ្ញុំបាទដេកលក់ទៅ មាននិម្មិតប្រាប់ចំណែករូបរាងក៏មិនបានឃើញដែរ ។

ម្ដាយក៏សួរទៅវិញថា ៖ តើនិម្មិតប្រាប់យ៉ាងដូចម្ដេច [៦] ?

កូនឆ្លើយ ៖ ប្រាប់ថា មានគ្រាប់ត្រសក់នេះមួយកញ្ចប់ កាំបិតនេះមួយ និងបាយមួយកញ្ចប់ ប៉ុន្តែ បាយខ្ញុំបាទហូបអស់ហើយ ។ លោកប្រាប់ទៀតថា បើបានវត្ថុនេះកាលណា សូមយកត្រឡប់ទៅផ្ទះវិញ ហើយទៅរកត្រួសត្រាយចំការនៅឯភ្នំ ( ក្រោយមក ភ្នំនេះមានឈ្មោះថា ភ្នំចំការ ) ដើម្បីដាំត្រសក់ ព្រមទាំងបណ្ដាំមួយទៀត នៅពេលត្រសក់ផ្លែទុំដំបូង កុំឱ្យស៊ី គប្បីបេះយកទៅថ្វាយស្ដេចនៅក្រុងអង្គរធំ កុំខាន ។

ព្រឹកឡើង បុរសឱ្យម្ដាយធ្វើម្ហូបអាហារឱ្យខ្លួន វេចខ្ចប់យកទៅហូប នៅពេលទៅត្រួសចំការ ។ គាត់បានទៅដល់ភ្នំមួយតាមនិម្មិត ដែលបានប្រាប់ ។ ដល់

---

(១) អស់កំលាំង គាត់ថា " សោរ " ។ (២) កាំបិត គាត់ថា " កាមិត " ។
(៣) កន្លែងចង្ក្រមភាវនា គាត់ថា " ក្រឡា " ។ (៤) និម្មិត គាត់ថា សំឡេងអាថិកំបាំងមួយដែលស្រែកប្រាប់មនុស្សកំពុងដេកលក់ ។ (៥) ខ្ញុំបាទ គាត់ថា " កម្បាត " ។
(៦) យ៉ាងដូចម្ដេច គាត់ថា " លម៉េច ឬ ល្មេច "

ហើយ គាត់បានត្រួសត្រាយកាប់ឆ្ការ អស់ពេលមួយថ្ងៃ (១) ដោយត្រួសត្រាយ កាប់ឆ្ការតាមកំលាំងធម្មតា ដែលខ្លួនអាចធ្វើទៅបាន (២) លុះថ្ងៃល្ងាចបន្តិច គាត់វិលត្រឡប់មកផ្ទះវិញ ។

ព្រឹកឡើង បុរសឱ្យម្ដាយធ្វើបាយឱ្យខ្លួនទៀត ដើម្បីនឹងយកទៅចម្ការ ។ ពេលទៅដល់ ចំការនោះត្រូវបានគេកាប់ឆ្ការរួចអស់ (៣) បុរសក៏ត្រឡប់មកផ្ទះវិញ ប្រាប់ម្ដាយថា ៖ ម៉ែ ចំការត្រូវគេត្រួសត្រាយរួចហើយ ។ ប៉ុន្តែ ថ្ងៃស្អែក ខ្ញុំបាទនឹងទៅកាប់ចិញ្ច្រាំឱ្យវារាប (៤) ។

ស្អែកឡើង ម្ដាយដាំបាយខ្ចប់ម្ហូបឱ្យកូនទៅចំការទៀត ។ ពេលទៅដល់ ឃើញចំការត្រូវគេកាប់ចិញ្ច្រាំពង្រាបរួចទៅទៀត ។ បុរសយើងក៏ត្រឡប់មកផ្ទះប្រាប់ម្ដាយវិញថា ៖ ម៉ែ ! ចំការកាប់ពង្រាបរួចអស់ទៀតហើយ ។

ម្ដាយក៏ប្រាប់ទៅកូនវិញថា ៖ នែកូន, ចាស់បុរាណលោកថា ចំការត្រួសត្រាយកាប់ឆ្ការថ្មីដូច្នេះ ចាំកន្លះខែក្រោយសឹមទៅដុត (៥) ។

លុះចាំដល់វេលាបានកន្លះខែ បុរសក៏ទៅដុតព្រៃងាប់ដែលខ្លួនឆ្ការរួច ។

ពេលទៅដល់ព្រៃដែលងាប់នោះ ឆេះអស់មុនគាត់ដុត ។ ឃើញដូច្នេះ បុរសក៏ដាំគ្រាប់ត្រសក់ នៅចំការនោះតែម្ដង ។ ដាំរួច គាត់វិលត្រឡប់មកផ្ទះវិញ ។

ក្រោយពេលភ្លៀងធ្លាក់ម្ដង បុរសទៅមើលចំការត្រសក់របស់ខ្លួន ស្រាប់តែឃើញដើមត្រសក់ដុះចេញ វារពេញដីរួចជាស្រេច ។

ពេលគាត់ត្រឡប់មកផ្ទះវិញយប់នោះ ស្រាប់តែមាននិម្មិតប្រាប់ទៀតថា ៖ កាលណាត្រសក់មានផ្លែទុំល្មម ដំបូងគេ កុំហូប ត្រូវអ្នកបេះយកទៅថ្វាយស្ដេចនៅ

---

(១) មួយថ្ងៃ គាត់ថា " ម៉ាងៃ " ។ (២) គាត់ថា " កាប់យកកំលាំងយើងជា មនុស្ស " ។ (៣) កាប់ឆ្ការរួចអស់ គាត់ថា " កាប់បាត់ទៅអស់ " ។ (៤) កាប់ចិញ្ច្រាំ ឱ្យវារាប គាត់ថា " មន្លាស់ " ។ (៥) ទៅដុតព្រៃ គាត់ថា " ទៅរុជព្រៃ " ។

ក្រុងអង្គរធំ ។

ពេលត្រសក់ចាប់ផ្ដើមផ្លែ បុរសជាម្ចាស់ ទៅដេកចាំចំការជាធម្មតា ។ មិនយូរប៉ុន្មាន ផ្លែត្រសក់ក៏ទុំរបេះចេញពីទង ។ ឃើញត្រសក់ទុំហើយ បុរសក៏ធ្វើតាមបណ្ដាំនិមិត្តដែលប្រាប់ឱ្យយកផ្លែត្រសក់នេះទៅថ្វាយស្ដេច ។

ដោយហេតុខ្លួនជាអ្នកក្រីក្រ គ្មានអ្វីផ្សេងទៀតជាដង្វាយ ក៏យូរតែផ្លែត្រសក់ទុំធំមួយ សំដៅទៅរាជវាំង ។

ប្រជារាស្ត្រប្រុសស្រីដទៃទៀត គេនាំយកដង្វាយផ្សេងៗ មានដូងផ្អែមៗ(១) ចេកអំបូង ចេកពងមាន់(២) ។ ល ។ អ្នកទាំងនោះបានត្មះតិះដៀលបុរសយើងថា ៖ បុរសនេះ យកតែត្រសក់ធំ(៣) ទៅថ្វាយស្ដេចដូច្នេះ មិនសមសោះ ព្រោះស្ដេចមិនដែលសោយត្រសក់ទុំផង ។ ទៅដល់រាជវាំង បុរសក៏យកត្រសក់ខ្លួនដាក់ថ្វាយស្ដេចដូចប្រជារាស្ត្រដទៃទៀតដែរ ។ រួចហើយគាត់ក៏ថយខ្លួនទៅអង្គុយប្រណាម្យរង់ចាំព្រះរាជឱង្ការ ដែលព្រះអង្គត្រាស់ទៅកាន់ប្រជារាស្ត្រ ដែលនាំដង្វាយមកថ្វាយទ្រង់ ។ លុះចាំយូរពេក ព្រះអង្គមិនមានព្រះឱង្ការចំពោះដង្វាយខ្លួន គ្រាន់តែទ្រង់ទទួលហើយទុកចោល ។ ឃើញព្រះអង្គនៅស្ងៀមស្ងាត់បែបនេះ បុរសក៏ថ្វាយបង្គំលាត្រឡប់មកផ្ទះវិញ ។ ក៏ប៉ុន្តែ មុនគាត់ចាកចេញមក គាត់បានទូលព្រះអង្គថា ៖ បើព្រះអង្គមិនសព្វព្រះរាជហឫទ័យទេ ក៏សូមឱ្យព្រះអង្គសោយតែមួយម៉ាត់ចុះ ។ ទូលព្រះបង្គំលាហើយ ។ បន្ទាប់មក បុរសយើងបានត្រឡប់មកផ្ទះវិញបាត់ទៅ ។

ចំណែកព្រះរាជា ព្រះអង្គពិតជាមិនសព្វព្រះទ័យនឹងដង្វាយនោះមែន ។ ប៉ុន្តែ នៅវេលាយប់នោះ ព្រះអង្គបានសុបិននិមិត្តប្រាប់ឱ្យព្រះអង្គភ្លក្សត្រសក់ដែលជាដង្វាយពីថ្ងៃ ។ ដោយសារមាននិមិត្តប្រាប់ដូច្នេះ ព្រឹកឡើង ព្រះរាជា

(១) ដូងផ្អែម គាត់ថា « ដូងឯម » ។ (២) ចេកពងមាន់ គាត់ថា « ចេកពង » ។
(៣) ត្រសក់ធំ គាត់ថា « ត្រសក់ង្វង » ។

ត្រាស់បង្គាប់ឱ្យស្រីស្នំចិតត្រសក់ទុំនោះភ្លក្សមើល ក្នុងហឫទ័យឆ្ងល់ ថាតើវាឆ្ងាញ់យ៉ាងណា ! សោយកើត ឬមិនកើត នឹងសោយឱ្យបានតែមួយម៉ាត់ ។

វេលាស្នំចិតរួច ក៏យកទៅថ្វាយព្រះអង្គមួយចំណិត ព្រះអង្គសោយមួយចំណិតនោះអស់ទៅ បង្គាប់ឱ្យស្នំចិតថ្វាយទៀត ពីរចំណិត បីចំណិត ក៏ព្រះអង្គនៅតែសោយអស់ រហូតអស់ត្រសក់ធំមួយនោះ ។ ប្រការនេះ ធ្វើឱ្យស្រីស្នំឆ្ងល់ថា : ឱ ! ត្រសក់នេះ យ៉ាងម៉េចអីចេះ ទើបធ្វើឱ្យព្រះរាជាសព្វព្រះទ័យខ្លាំងម្ល៉េះ សោយអស់រលីងយ៉ាងនេះ ? ព្រោះជាការចំឡែកមួយសំរាប់ពួកភីលៀង ។ ចម្ងល់នេះនាង១ បានជញ្ជាប់យករសជាតិ នៃសំបកត្រសក់ ពេលយកវាទៅបោះចោល ទើបដឹងថា : ត្រសក់នេះល្វីងឆ្ងាញ់ណាស់ ។ ពួកនាងក៏បោះសំបកត្រសក់នោះចោលទៅ ។

ក្រោយមកស្តេចប្រើ ឯកអាមាត្យប៉ាវគង វាយឃ្មោះ ស៊ើបសួររកបុរសដែលបានយកត្រសក់ទៅថ្វាយព្រះអង្គកាលពីថ្ងៃមុន ។ ក្រោយមក ពួកអាមាត្យបានរកឃើញគាត់ កំពុងរស់នៅក្បែរស្រះដូនរិ ៗ អាមាត្យបាននាំបុរសមកកាន់រាជវាំងដើម្បីថ្វាយបង្គំគាល់ព្រះរាជា ។ ព្រះរាជាត្រេកអរណាស់ ទ្រង់បានប្រទានរង្វាន់គ្រប់មុខគ្រប់បែបដល់បុរស មានតាំងពីសំលៀកបំពាក់ ។ សម្តេចបានឃាត់បុរសមិនទាន់ឱ្យត្រឡប់មកវិញភ្លាម១ទេ ព្រះអង្គឱ្យបុរសរង់ចាំយកលំពែង ដែលព្រះអង្គបានត្រាស់បង្គាប់ឱ្យជាងដំដែកធ្វើ ។ ព្រះអង្គឱ្យលំពែងដល់បុរសទុកជាអាវុធសំរាប់ការពារចំការ កុំឱ្យជនដទៃចូលលួចបេះយកផ្លែត្រសក់ទុំដ៏ឈ្ងុយឆ្ងាញ់នេះ គឺទុកសម្រាប់តែព្រះអង្គ មួយអង្គឯងប៉ុណ្ណោះ ។

ពេលព្រះរាជាប្រទានលំពែងរួចហើយ បុរសក៏ថ្វាយបង្គំលាត្រឡប់មកលំនៅវិញ ។ គាត់បានប្រតិបត្តិតាមបណ្តាំព្រះរាជា ទៅដេកចាំចំការត្រសក់របស់ខ្លួនទាំងថ្ងៃ ទាំងយប់ ដោយមិនធ្វេសប្រហែសឡើយ ។

ជាការចំឡែកមួយទៀត គឺចាប់តាំងពីបានលំពែងកាលណា រាល់ពេល

បុរសដេកលក់ នៅក្នុងខ្ទមឯចំការត្រសក់ គាត់តែងតែស្រម៉ុកឮសូរ : អ្ហ៎ក ខ៎ ខ្ហ៎ ... ឯត្បូងបុសពង្រ ចាក់កាប១ !!! (១) ហើយនៅពេលដែលបុរសភ្ញាក់ពីដេក តែងតែមានភាពស្ងប់ស្ងាត់ជាធម្មតា ។

ថ្លែងអំពីព្រះរាជា ដោយសារបាត់ចៅត្រសក់ផ្អែមយូរ មិនឃើញយកដង្វាយត្រសក់ទុំទៅថ្វាយ មានព្រះទ័យអត់ទ្រាំពុំបាន មានព្រះចិន្តាចង់ចេញពីព្រះរាជ-វាំង យាងទៅកាន់ចំការត្រសក់ដោយព្រះអង្គឯង ។ ស្ដេចក៏បបួលឯកអាមាត្យទៅលួចបេះត្រសក់ដល់ចំការ ។ ឯកអាមាត្យទាំងបួននាក់ បានយកគ្រែស្នែងសែងព្រះរាជាចេញពីវាំងដោយស្ងាត់កំបាំង ។ ពួកគេសែងព្រះអង្គ ទៅដល់ភូមិពាក់ស្នែងខាងលិច (២) ក៏ដោះដងស្នែងមួយពាក់ចោលនៅទីនោះ ។ ពួកគេត្រូវសែងព្រះអង្គ តែគ្នាពីរនាក់ ដើរមុខក្រោយ ព្រោះដល់កន្លែងដែលមានផ្លូវដើរតែមួយ ឬគេហៅថា «ផ្លូវជើង» ។

លុះសែងមកដល់ភូមិពាក់ស្នែងខាងកើត (៣) ព្រះរាជាបញ្ជាឯកអាមាត្យឱ្យដាក់ស្នែងចុះឈប់នៅទីនោះ ហើយត្រាស់បញ្ជាទៅឯកអាមាត្យពីរនាក់ទៀត យកស្នែងត្រឡប់ក្រោយវិញ ។ ដោយសារផ្លូវដែលព្រះអង្គត្រូវបន្តដំណើរទៅមុខទៀតត្រូវរុកព្រៃ ដូច្នេះអាមាត្យ មិនអាចសែងព្រះអង្គបានទេ ។

នៅពេលព្រះអង្គបន្តដំណើរដោយថ្មើរជើងទៅដល់ចំការត្រសក់ ជួនជាពេលយប់ ម្ចាស់ចំការក៏ដេកលក់ដែរ ។ ប៉ុន្តែ ដោយសារព្រះអង្គពុំបានជ្រាបថា ម្ចាស់

---

(១) សំឡេងស្រម៉ុក ... ចាក់កាប១ មានន័យថា « ចាក់កាប់១ » ។ (២) ឈ្មោះភូមិនេះទើបតែកើតមានក្រោយព្រឹត្តិការណ៍នេះប៉ុណ្ណោះ ។ នៅពេលជាមួយគ្នានេះ តំបន់ភូមិពាក់ស្នែងខាងលិច មិនទាន់មានភូមិករនៅឡើយ ។ សព្វថ្ងៃភូមិនេះ នៅខាងជើងភ្លង់ ខាងជើងក្រុងអង្គរធំ ស្ថិតក្នុងឃុំលោងដៃ ខេត្តសៀមរាប ។ (៣) ឈ្មោះនេះ ក៏ទើបតែកើតឡើងនៅពេលក្រោយពីមានព្រឹត្តិការណ៍ ។ នៅពេលភូមិនេះ មានមនុស្សមករស់នៅ គេក៏ដាក់

ចំការនេះ បើភ្ញាក់ពីដំណេក មិនមានឮសូរមាត់អ្វីទាំងអស់ តែបើដេកលក់វិញ តែងតែស្រម៉ុកឮដូចជាមនុស្សកំពុងស្រែកប្រកួកប្រកាស ។ ហេតុនេះហើយ ទើបពេលទៅដល់ចំការ ព្រះអង្គប្រាប់អាមាត្យថា ម្ចាស់ចំការមិនទាន់ដេកលក់ទេ រង់ចាំគេដេកលក់សិន ។

ព្រះរាជា និងអាមាត្យ រង់ចាំរហូតដល់ស្ងាត់មាត់ បាត់ឮសូរស្រម៉ុក ទើបទ្រង់បញ្ជាឱ្យចូលទៅក្នុងចំការ ។

បុរសម្ចាស់ចំការ កាលដឹងខ្លួនកាលណាក៏ក្រោកពីដំណេក ដើរទៅយកលំពែងលីក្រវែលមើលចំការខ្លួនមួយជុំ ដូចសព្វមួយដង ។ ព្រះរាជា ស្តេចអត់ដឹង (១) នៅពេលចូលដល់ចំការ ក៏ឃើញបុរសដើរលីលំពែងតំរង់មកដូច្នោះ ក៏ប្រាស់គេចទៅពួនរវៀង១ខ្លួនបាត់ទៅ ។

បុរសម្ចាស់ចំការ ក៏មិនបានដឹងថា មានមនុស្សកំពុងចូលក្នុងចំការរបស់ខ្លួនឡើយ ។ ក្រោយពីគាត់ដើរមួយជុំចំការហើយ មិនឃើញមានអ្វីប្លែក ក៏ត្រឡប់ទៅកន្លែងដេកវិញ ។ មុននឹងឡើងទៅដេក គាត់បានយកលំពែងខ្លួនទៅបោះចូលកន្លែងដែលធ្លាប់លាក់ដូចសព្វដង ក៏ត្រូវនឹងស្តេចកំពុងពួន មួយផ្លែលំពែង ។ ព្រោះព្រះអង្គបានទៅពួនចំកន្លែងលាក់លំពែង (២) របស់ម្ចាស់ចំការត្រសក់ ។ ពេលដែលត្រូវរបួសហើយ ព្រះរាជាក៏មិនបានស្រែកអោយដឹងថាមានការឈឺចាប់អ្វីដែរ ព្រះអង្គនៅតែសំងំស្ងៀម ។ បុរសយើងក៏គ្មានបានដឹងជាមុន គ្មានចេតនាធ្វើគត់ស្តេច (១) ព្រោះជាកន្លែងធ្លាប់លាក់ ទុក (២) ជាធម្មតា ។ នៅពេលបុរសម្ចាស់ចំការឡើងទៅលើខ្ទមបាត់ទៅ ស្តេចបានបញ្ជាអាមាត្យឱ្យសែងព្រះអង្គត្រឡប់ក្រោយវិញ ។ មកដល់ពាក់កណ្តាលផ្លូវ ឯករាមាត្យទូលសួរព្រះអង្គថា : ព្រះអង្គម្ចាស់ ! តើឱ្យខ្ញុំព្រះករុណា យកព្រះអង្គទៅណាវិញ ? ព្រះរាជាត្រាស់ថា : ទេ អាមាត្យ

---

(១) អត់ដឹង គាត់ថា " អត់ដេញ " ។ (២) កន្លែងលាក់លំពែង គាត់ថា " បនពក់លំពែង ។

អញខ្មាសអៀនណាស់ (៣) កុំយកអញទៅនគរ (៤) ឬក៏ទៅប្រាសាទវិញធ្វើអ្វី ?

អាមាត្យម្នាក់ទៀត ទូលសួរទៀតថា : បើអញ្ជើងឱ្យទូលបង្គំនាំព្រះអង្គយកទៅណា ?

ព្រះអង្គត្រាស់ថា : ទៅនៅឯកើតអង្គរ ដើម្បីសំរាកព្យាបាលនៅទីនោះ ។ ហេតុនេះហើយទើបអាមាត្យទាំងពីរ សែងព្រះអង្គយកទៅដាក់នៅត្រង់គោក ពូន នៅ (៥) ខាងកើតស្រះស្រង់ ។ មុខរបួសនោះ ទោះជាអាមាត្យខំព្យាបាលយ៉ាងណាក៏មិនបានជាសះស្បើយឡើយ រហូតធ្វើឱ្យព្រះរាជាចូលទិវង្គតនៅក្នុងព្រៃនោះទៅ ។

អាមាត្យម្នាក់ផ្តើមគំនិតថា យកសពព្រះរាជាទៅកប់ក្រោមដើមភ្លូ ក្រោមមែកធំមួយខាងទិសឦសាន ។ ចំណែកអាមាត្យម្នាក់ទៀត ផ្តើមគំនិតថា យើងត្រូវរកបន្ទះថ្មមួយមកសរសេរចារឹក ហើយកប់សង្កត់ពីលើផ្នូររួចសិន សឹមនាំគ្នាត្រឡប់ទៅផ្ទះរៀង១ខ្លួន ។ ថ្មដែលអាមាត្យចារឹកអក្សរនោះ មានកំរាស់ (៦) មួយតឹក បន្ទាប្រាំពីរតឹក បណ្តោយមួយម៉ែត្រ ។ អាមាត្យទាំងពីរបំពេញកិច្ចការរួចរាល់ហើយ ក៏បែកផ្លូវគ្នាទៅកាន់លំនៅទីទៃៗ ។

ផ្លែងពីហ្វូងប្រជារាស្ត្រក្នុងនគរ និងរាជវង្សានុវង្ស មន្ត្រី នៅក្នុងវាំង នាំគ្នាដើររកព្រះរាជាដោយសេចក្តីខ្វល់ខ្វាយអនេក ។ ព្រោះអវត្តមានព្រះអង្គយូរពេក មិនដឹងជាព្រះអង្គយាងទៅណាមកណា ។ ក្រោយមក ទើបមានអាមាត្យម្នាក់ចូលទៅប្រាប់ថា : ព្រះរាជាសុគតហើយ ព្រោះត្រូវលំពែងបុរសចំការត្រសក់ ។ ដោយមិន

---

(១) គាត់ថាគ្មានចេតនាបោះយកស្តេច ។ (២) កន្លែងធ្លាប់លាក់ទុក គាត់ថា « បនបានលក់ទុ » ។ (៣) ខ្មាសអៀនណាស់ គាត់ថា « អៀលណាស់ » ។ (៤) នគរ ជាពាក្យសំស្ក្រឹត មានន័យថា « ទីក្រុង ឬរាជធានី » ។ (៥) គោក ពូន នៅក្រោយមក ក្លាយជាឈ្មោះស្ថានមួយ ជាទួលដែលព្រះរាជាពូននៅព្យាបាលរបួស ។ សព្វថ្ងៃ នៅខាងកើតស្រះស្រង់ ។
(៦) កំរាស់ គាត់ថា កន្រាស់ " ។

ដឹងថាត្រូវធ្វើយ៉ាងដូចម្ដេចទៀត គេសម្រេចថា ហៅហោរាទាំងបួនមកទស្សន៍ទាយ គន់គូររកអ្នកឡើងស្នងរាជ្យសិន មុននឹងធ្វើអ្វីៗទៀត ។ ដើងលេខរបស់ហោរាទាំងបួន ឆ្លើយថា : ត្រូវបុរសម្ចាស់ចំការត្រសក់ឡើងសោយរាជ្យ ។ ប៉ុន្តែ គាត់ជាសាសន៍សំរ៉ែ ព្រោះម្ដាយគាត់ ជាសំរ៉ែតាំងពីកំណើត ។

ពេលបុរសម្ចាស់ចំការត្រសក់ផ្អែម ឡើងសោយរាជ្យជាស្ដេចផែនដី លោកមានព្រះនាមត្រឹមត្រូវ ប៉ុន្តែ លោកតា ក្រូច ទេព មិនបានចាំឈ្មោះនោះទេ ។

ក្រោយពីបានឡើងសោយរាជ្យ ស្ដេចតាត្រសក់ផ្អែម បានចាត់ចែងធ្វើបុណ្យឱ្យស្ដេច មុនដែលបានចូលទិវង្គតដោយសារត្រូវនឹងលំពែងរបស់ខ្លួន ។

ព្រះអង្គបានចាត់ឱ្យមនុស្សមួយនគរ ទៅគាស់រកព្រះអដ្ឋិ ។ គេនាំគ្នាគាស់រហូតរលើងដើមធ្លកមួយ កើតជាដីវាល ២ ហិកតា បួនជ្រុង នៅតែរកធាតុមិនឃើញ ។ ការពិត អ្នកគាស់ទាំងអស់នោះមិនបានជីកខុសកន្លែងកប់នោះទេ ប៉ុន្តែ ធាតុនិងផ្ទាំងថ្មដែលសង្កត់មិនដឹងជាបាត់ទៅទីណា ។

ឃើញដូច្នោះ អាមាត្យ ដែលបានបញ្ចុះព្រះសព និយាយថា : បើយើងរកធាតុមិនឃើញទេ យើងនាំគ្នាដើរគាស់រកថ្មដែលមានកំរាស់មួយតឹក បន្ទាប្រាំពិលតឹកបណ្ដោយមួយម៉ែត្រ ដែលមានចារឹកអក្សរវិញ ។

អ្នកនគរទាំងអស់ ក៏ដើរជីកគាស់រកថ្ម តាមភិនភាគនេះបន្តទៅទៀត បន្ទាប់មក គេបានរកឃើញថ្មបន្ទះ និងព្រះអដ្ឋិធាតុ នៅកន្លែងលាក់លំពែងរបស់ម្ចាស់ចំការត្រសក់ទៅវិញ ។

ប្រជានុរាស្ត្រ បានដង្ហែព្រះអដ្ឋិធាតុយកទៅធ្វើបុណ្យតាមប្រពៃណី ដែលពេលនោះគេយកធាតុទៅបូជានៅប្រាសាទមួយធ្វើអំពីឥដ្ឋ តាំងនៅខាងត្បូងទំនប់បារាយណ៍ខាងកើត ធ្វើឱ្យគេហៅឈ្មោះប្រាសាទនេះថា ប្រាសាទប្រែរូប (១) ចាប់

(១) សាកសពទាំងរស់ ឬព្រះអដ្ឋិធាតុទាំងអស់ ក្រោយពីបានបូជា តែងតែឆេះសុសអស់ ➡

តាំងពីពេលនោះមក ។ រោងបុណ្យ គេធ្វើនៅខាងមុខប្រាសាទមួយសង់អំពីឥដ្ឋដែរ នៅខាងជើងប្រាសាទប្រែរូប នៅក្នុងបារាយណ៍ខាងកើត ឬយសោធរតដាក ចាប់តាំងពីពេលនោះមក អ្នកស្រុកនាំគ្នាហៅប្រាសាទនោះថា ប្រាសាទមេបុណ្យ ខាងកើត ពីព្រោះតែទីនោះជាទីស្នាក់ការធំក្នុងការធ្វើបុណ្យ ដូចបានពោលខាងលើ ។

ក្រោយពីធ្វើបុណ្យសព្វរួចរាល់ហើយ ហោរា បុរោហិត នាម៉ឺន សព្វមុខមន្ត្រី បានបើកអង្គប្រជុំធំមួយ ដើម្បីជំនុំពិភាក្សាគ្នាអំពីបញ្ហាព្រះរាជដំណាក់របស់ស្ដេចតាត្រសក់ផ្អែម នៅក្នុងប្រាសាទមួយធ្វើអំពីថ្មភក់ តាំងនៅខាងលិចមាត់ស្រះស្រង់ និងទិសនិរតីនៃប្រាសាទប្រែរូប ដើម្បីកាត់សេចក្ដីថា ព្រះអង្គត្រូវអនុញ្ញាតឱ្យគង់ប្រថាប់នៅក្នុងបរិវេណក្រុងអង្គរធំ ឬយ៉ាងណា ? ដោយហេតុថា ព្រះអង្គជាសាសន៍សំរែ តាំងពីបុរាណកាលមក ស្ដេចក្រុងនេះ សុទ្ធសឹងជាជនជាតិខ្មែរ ការនេះបើព្រះអង្គគង់នៅក្នុងព្រះនគរ ឃើញថា ខុសគ្នានឹងបវេណី ។ ដូច្នោះហើយ ទើបគេសម្រេចថា ឱ្យជាងសំណង់រាជ្យ សាងសង់ព្រះដំណាក់ និងរាជវាំងថ្មីមួយ នៅតំបន់ភាគខាងកើតដែរ ដើម្បីឱ្យព្រះបាទត្រសក់ផ្អែម គង់ប្រថាប់ និងសាងប្រាសាទថ្មមួយ

---

←

សល់តែឆ្អឹងបន្តិចបន្តួច គឺផ្លាស់ពីរូបបុគ្គលម្នាក់ ទៅជាគ្មានរូបរាង ។ ដូច្នេះ កិច្ច មុនពេលគេប្រមូលធាតុ អាចារ្យ ឬព្រាហ្មណ៍ បុរោហិត តែងអនុវត្តទំនៀមមួយ គឺគេគូរគំនរផេះ ជារូបរាងមនុស្សដេក រួចយកស្លឹកចេកគ្រប ពេលគេបើកស្លឹកឡើង អាចារ្យ ឬព្រាហ្មណ៍ម្នាក់បានសួរទៅអកនៅជុំវិញខ្លួនថា « រូបនេះ តើពិតជារូបរបស់ ... មែន ឬមិនមែន ? » បន្ទាប់មក អ្នកនៅជុំវិញឆ្លើយថា « មិនមែនទេ » អាចារ្យក៏លុបគំនូសនោះចោល រួចគូរសាជាថ្មីដោយប្ដូរទីតាំង ។ ទាល់តែដល់គំរប់លើកទីបី ទើបអ្នកនៅជុំវិញឆ្លើយថា « ពិតជារូបរបស់ ... ពិតមែនហើយ » ក្រោយមក ទើបអាចារ្យ ឬព្រាហ្មណ៍ និងបងប្អូន កូនចៅញាតិមិត្ត នាំគ្នារើសអដ្ឋិធាតុដាក់ក្នុងកញ្ជើ ឬកោដិ ។ ម្យ៉ាងទៀត ប្រាសាទប្រែរូប មានឡពីរសំរាប់ដុតសាកសព ដែលជារាជវង្សានុវង្ស ឬព្រះមហាក្សត្រ ។

សំរាប់ព្រះអង្គធ្វើសក្ការបូជា ។ ចំណេរកាលក្រោយមក ប្រាសាទនេះ មានឈ្មោះថា ប្រាសាទបន្ទាយសំរេ៉ (១) ជាប់រហូតមកដល់សព្វថ្ងៃ ។

ស្ថាននាមមួយទៀត ដែលបានប្រតិស្ឋានជាប់រហូតដល់សព្វថ្ងៃ តាមរយៈរឿងនេះ នៅមានទីកន្លែងដែល បុរោហិត ហោរា មន្ត្រី សេនាបតី តែងតែប្រជុំជំនុំគ្នាអំពីកិច្ចការព្រះនគរទាំងពីរលើក គឺលើកទី ១ កាត់សេចក្តីឱ្យម្ចាស់ចំការត្រសក់ដែលបានសម្លាប់ព្រះរាជាដោយអចេតនា បានឡើងសោយរាជ្យ និងលើកទី ២ ក្រោយពីបានធ្វើបុណ្យរំលាយព្រះសព្វរួចហើយ គេប្រជុំគ្នាកាត់សេចក្តីឱ្យស្តេចតាត្រសក់ផ្អែមទៅគង់ប្រថាប់នៅខាងក្រៅក្រុងអង្គរធំ ក្បែរប្រាសាទបន្ទាយសំរេ៉ សព្វថ្ងៃ ។ ប្រាសាទដែលជាទីប្រជុំនេះ បានជាប់ឈ្មោះថា « ប្រាសាទបន្ទាយកាត់ក្តី » ប៉ុន្តែ លុះពេលក្រោយមក ការហៅនេះបានរួញមកត្រឹម « ប្រាសាទបន្ទាយក្តី » វិញ ។

***

(១) ជាប្រាសាទដ៏សក្តិសិទ្ធិមួយ នៅតែត្រូវបានប្រជារាស្ត្រនៅស្រុកប្រដាក គោរពបូជា ។ ដូចជានៅពេលជួបគ្រោះរាំងស្ងួត គេតែងនាំគ្នាប្រារព្ធធ្វើបុណ្យនៅខាងមុខបរិវេណប្រាសាទ ( ទិសខាងកើត ) ដើម្បីសុំទឹកភ្លៀង ។ ការធ្វើបុណ្យបែបនេះ គេមិនធ្លាប់ទទួលការខកចិត្តម្តងណាឡើយ ។ ពោលគឺ លោកសូត្រធម៌មិនទាន់បានចប់ផង ... ភ្លៀងតែងតែបង្អុរចុះមកយ៉ាងជោគជាំ ។

# អំពីធង់ :
# ទង់ពុទ្ធសាសនា និង ទង់ជាតិ

តាមធម្មតា ទង់ត្រូវបានគេធ្វើឡើងពីផ្ទាំងសំពត់ ឬចម្រៀកសំពត់ ដែលដេរអោយមានសណ្ឋាន និងពណ៌ ឬរូបភាពផ្សេងៗ សម្រាប់ប្រើជាកិត្តិយស ឬជានិមិត្តរូបក្នុងប្រទេសនិមួយៗ, ឬប្រើសម្រាប់សំគាល់តាមសណ្តាប់សាសនានិមួយៗ ឬក៏ប្រើជាគ្រឿងបូជាក៏មាន ។ ទង់ធ្វើដោយក្រដាស ឬពីសម្ភារៈផ្សេងដូចសំពត់ ក៏ហៅថាទង់ដែរ ។ ដោយអនុលោមទៅតាមសណ្ឋាន និងទ្រង់ទ្រាយរបស់វា, ទង់ត្រូវបានគេអោយឈ្មោះផ្សេងៗគ្នា ដូចជា ទង់ជាតិ, ទង់ជ័យ, ទង់សាសនា, ទង់ផ្កាឈោ, ទង់ប្រចាំកង, .... ។ ស័ព្ទភាសាបាលី ដែលគេចំណាំប្រើសំគាល់ទង់គឺ ធជះ ( សំ. ធ្វជះ ), បដាកៈ, និង កេតុ ។

កំណើតដើមរបស់ទង់ ប្រហែលជាមានប្រភពមកពីសញ្ញាសំគាល់ត្រកូល ឬសំគាល់កុលសម្ពន្ធរបស់មនុស្សពីសម័យដើម ។ ការប្រើប្រាស់ទង់ពីដំបូងទី គឺដើម្បីបង្ហាញអត្តសញ្ញាណ, ឧត្តមភាព, ឬជ័យជំនះរបស់ខ្លួន ប៉ុន្តែ ចាប់តាំងពីបុព្វកាលរៀងមក ទង់ត្រូវបានគេនិយមប្រើទាំងសម្រាប់គោលបំណងផ្លូវលោក ទាំងសម្រាប់គោលបំណងសាសនា ។

មានភស្តុតាងជាច្រើននៅក្នុងអក្សរសាស្ត្រសាសនា, ដែលបានបញ្ជាក់ថា ទង់ទាំងឡាយត្រូវបានគេប្រើនៅក្នុងប្រទេសឥណ្ឌា សម្រាប់គោលបំណងនេះតាំងតែពីបុរាណកាលរៀងមក ។ គម្ពីរ *អថព្វវេទ* បាននិយាយយោងដល់ *សូរ្យកេតុ* ( ទ្រង់ព្រះអាទិត្យ ) ។ គម្ពីរ *មហាភារតៈ* បាននិយាយទាក់ទងដល់ *វានរកេតុ* ( ទង់ពានរ ), ចំណែកពាក្យ វ្ឫសភ-ធ្វជៈ ( ទ្រង់គោឧសភរាជ ) ត្រូវបានគេប្រើជាគុណ-បទ សម្រាប់សំដែងលក្ខណៈរបស់ព្រះសិវៈ ។

អត្ថបទអក្សរសាស្ត្រពុទ្ធសាសនា ក៏មានពាក្យពេចន៍យ៉ាងច្រើនយោងដល់ទង់ ដែលប្រើនៅក្នុងពិធី ឬឱកាសផ្សេងៗ ទាំងសម្រាប់ផ្លូវលោក ទាំងសម្រាប់ផ្លូវសាសនា ។ មានសេចក្ដីយោងច្រើនទៀត បាននិយាយពីការប្រើទង់នៅក្នុងសមរភូមិ ។ គេប្រើទង់ជានិមិត្តរូបសំគាល់រាជរថរបស់ក្សត្រ ពិព្រោះ កាលណាគេមើលឃើញពីចម្ងាយនូវទង់លើចុងផ្តោលរាជរថ, គេអាចកំណត់បានថាជាព្រះរាជរថរបស់ស្ដេចអង្គណានោះហើយ ។ គេប្រើទង់ មិនមែនគ្រាន់តែជាសញ្ញាសំគាល់កងទ័ព ឬជាសញ្ញាសំគាល់ក្បាលទ័ពប៉ុណ្ណោះទេ, ប៉ុន្តែ គេប្រើសម្រាប់លើកទឹកចិត្តកងទ័ពផងដែរ ។ នៅក្នុងអត្ថបទអក្សរសាស្ត្រសាសនា គេបានពិពណ៌នាអំពីដំណើររឿងធ្វើសង្គ្រាមរវាងពួកទេពតា និងពួកអសុរថា : សេចក្ដីភិតភ័យក្នុងចំណោមពពួកទេពតាត្រូវបានរលាយបាត់ទៅ នៅពេលដែលគេក្រឡេកឃើញពីចម្ងាយ នូវទង់របស់ព្រះឥន្ទ្រាធិរាជ និងទង់របស់ទេវតាសំខាន់ៗដទៃទៀត ដែលបានលេចប្រាកដឡើងក្នុងចក្ខុវិស័យរបស់គេ ដែលកំពុងប្រយុទ្ធយ៉ាងជាប់ដៃនៅក្នុងសមរភូមិ ។ ដោយបានការលើកទឹកចិត្តនេះ ទេពតាទាំងឡាយ ក៏បានដេញពួកអសុរអោយរត់ខ្ចាត់ខ្ចាយអន្តរធានទៅ ។

គេបានប្រើទង់នៅក្នុងពិធី ឬព្រឹត្តិការណ៍សំខាន់ផងដែរ នៅក្នុងប្រទេសឥណ្ឌាបុរាណកាល ហើយអត្ថបទអក្សរសាស្ត្រសាសនា ក៏បាននិយាយដល់ឱកាសបែបនោះដែរ, ដូចជានៅពេលព្រះនាងមហាមាយាយាងទៅកាន់ព្រះរាជត្រកូលរបស់ព្រះនាង ដើម្បីប្រសូតព្រះរាជបុត្រ, ផ្លូវចាប់តាំងពីក្រុងកបិលព័ស្តុ ទៅដល់ក្រុងទេវទហៈ ត្រូវបានគេតុបតែងលំអដោយទង់ និងបដា ថ្វាយពរសព្ទសាធុការដល់ព្រះនាងមហាមាយា ។ គម្ពីរវិមានវត្ថុ អដ្ឋកថា បាននិយាយថា មេផ្ទះទាំងឡាយបានសង់ និងតុបតែងពន្លា, បណ្ដូប ដោយទង់ និងបដា ដើម្បីទទួលព្រះសម្មាសម្ពុទ្ធ និងសាវ័កទាំងឡាយរបស់ព្រះអង្គ ។ គម្ពីរអបទាន បានកត់ត្រាទុកនូវព្រឹត្តិការណ៍ទាំងឡាយ

ដែលនៅក្នុងព្រឹត្តិការណ៍នោះ គេបានរៀបរាប់ពីការប្រើប្រាស់ទង់ទាំងឡាយ សម្រាប់តុបតែងលំអ និងផ្តល់កិត្តិយសដល់ដើមពោធិព្រឹក្ស និងព្រះពុទ្ធអង្គ ។ គម្ពីរនោះបានរៀបរាប់ពីបព្វជិតពីរអង្គ, មួយអង្គគោរពបូជាពោធិព្រឹក្សរបស់ព្រះពុទ្ធបទុ-មុត្តរៈ ហើយមួយអង្គទៀត ធ្វើកិច្ចនមស្សការចំពោះព្រះពុទ្ធតិស្សៈ ដោយគ្រឿងសក្ការៈទាំងឡាយគឺ ទង់ ។ បព្វជិតទាំងពីរអង្គនោះ ត្រូវបានគេនិយាយយោងដល់ដោយសេចក្តីគោរពថាជា ធ្វជទាយកៈ គឺអ្នកថ្វាយទង់ ។

## អំពីទង់សាសនា

ទង់ពុទ្ធសាសនា ដែលកំពុងប្រើប្រាស់នៅក្នុងវត្តអារាមទាំងឡាយ នៃប្រទេសកម្ពុជា និងនៅក្នុងប្រទេសនានាកាន់ពុទ្ធសាសនាក្នុងពិភពលោក, មានកំណើតចេញមកពីប្រទេសស្រីលង្កា ។ នៅទីនោះ ដំបូងឡើយ គេបានច្នៃបង្កើតទង់សាសនាឡើង ទុកជានិមិត្តសញ្ញា ឬជានិមិត្តរូបរបស់ពុទ្ធសាសនិកជនស្រីលង្កា ។ ទង់នោះត្រូវបានបង្ហូតឡើង ដើម្បីប្រើប្រាស់ជាសាធារណៈជាលើកដំបូង និងយ៉ាងឱឡារិកនៅវត្តទីបទុត្តរារាម, ស្រុកកោតហេន ដោយព្រះថេរៈមិគេត្តុវត្តេ គុណានន្ទៈ ក្នុងថ្ងៃពិសាខបូជា ត្រូវនឹងថ្ងៃទី ២៨ ខែមេសា ឆ្នាំ ១៨៨៥ ។ ការបង្កើតទង់នោះឡើង គឺជាលទ្ធផលប្រយោលមួយ ចេញមកពីចលនាតស៊ូរបស់ពួកអ្នករៀបចំ និងដឹកនាំពុទ្ធសាសនាអោយមានជីវិតរស់ឡើងវិញ នាអំឡុងអឌ្ឍភាគទីពីរ នៃសតវត្សទី ១៩ ក្នុងប្រទេសស្រីលង្កា ។ ការបង្កើតទង់នោះឡើង គឺជាសកម្មភាពប្រកួតប្រជែងមួយ តទល់នឹងសកម្មភាពរាតត្បាត របស់បេសកជនផ្សព្វផ្សាយសាសនាគ្រីស្ត នៃលោកខាងលិច នៅលើកោះស្រីលង្កា ។

គំនិតបង្កើតអោយមានទង់សាសនាគឺដើម្បីបង្ហាញជានិមិត្តរូបនូវឯកភាព

របស់ពុទ្ធសាសនិកជន និងជោគជ័យរបស់ចលនាតស៊ូនៃពួកអ្នករៀបចំដឹកនាំពុទ្ធ-សាសនា អោយរស់រានឡើងវិញ ។ គំនិតនេះត្រូវបានប្រមូលផ្តុំគាំទ្រ និងបង្កបង្កើតឡើង ដោយសមាជិកនៃគណៈកម្មាធិការកូឡុំបូ ដែលបានរៀបចំបុណ្យវិសាខបូជាក្នុងឆ្នាំ ១៨៨០ ។ សមាសភាពគណៈកម្មាធិការ មាន ៖

- ព្រះថេរៈ ហិក្កទុវេ ស្រីសុមង្គល ប្រធាន
- ព្រះថេរៈ មិគេត្តុវត្តេ គុណានន្ទៈ សមាជិក
- លោក ដុន ការ៉ូលីស ហេវិថារណៈ - ដ -
- លោក មុហិន្ទិរាមៈ - ដ -
- លោក អា. ប. ធមិគុណាវទេនៈ - ដ -
- លោក វីលីយ៉ាម ដឺ អាព្រូ - ដ -
- លោក ការ៉ូលីស បុជិថៈ គុណាវទេនៈ - ដ -
- លោក ឆាល អ. ដឺ ស៊ីលវ៉ា - ដ -
- លោក ន. ស. ហ្វៀរណាង់ដូ - ដ -
- លោក ភីធ័រ ដឺ អាព្រូ - ដ -
- លោក ហ. វីលីយ៉ាម ហ្វៀរណាង់ដូ - ដ -

លោក វរសេនីយឯក ហេនរី ស្ទីល អូលកូត ( Col. Henry Steel Olcott ) បាននិយាយថា ៖ « គឺនៅពេលនោះហើយ ដែលសហសេវិករបស់យើងនៅក្រុងកូឡុំបូ ផ្តើមគំនិតគិតគូរបង្កើតទង់សាសនា ដែលត្រូវប្រជាជាតិកាន់ពុទ្ធ-សាសនាទាំងអស់អបអ ទទួលយកទុកជានិមិត្តរូបសាកលនៃជំនឿរបស់គេ ។ បងប្អូនរបស់យើងនៅក្រុងកូឡុំបូ បានរកឃើញគំនិតល្អឯក ដោយបានបញ្ចូលទៅក្នុងទង់សាសនា នូវពណ៌ទាំងប្រាំមួយ ( ឆព្វណ្ណរង្សី ) ដែលគេធ្លាប់បានឃើញនៅក្នុងរង្វង់រស្មី ផ្សាយចេញពីព្រះកាយព្រះពុទ្ធ ។

ទង់ពុទ្ធសាសនា កើតបានជារូបរាងប្រាកដឡើង នៅថ្ងៃទី ១៧ មេសា ១៨៨៥ នៅពេលដែលទង់នេះ ត្រូវបានគេបង្ហាញជាលើកដំបូង នាថ្ងៃនោះ នៅក្នុងសារពិតមាន « សរសវី សន្ទរេស » ។ ក្នុងការបង្ហាញនេះ គេពុំបានប្រាប់ឈ្មោះអ្នកច្នៃបង្កើតទង់នោះទេ ។ ប៉ុន្តែ គេបាននិយាយយោងដល់អ្នកច្នៃបង្កើតថាមានច្រើនរូប ។ ដូចលោក ក.ហ.ម. សុមឋិបាល បានធ្វើសេចក្តីសង្កេតថា : « ប្រហែលជាគំនិតគិតធ្វើទង់នេះឡើង ចេញមកតែគំនិតរបស់មនុស្សម្នាក់ ហើយពណ៌ទាំងឡាយរបស់ទង់ ចេញមកពីគំនិតមនុស្សផ្សេងៗគ្នា » ។ ពុទ្ធិកសមាគមខាងទេវិជ្ជា នៅក្នុងសៀវភៅឧទ្ទិសចំពោះខួបមួយរយឆ្នាំរបស់ខ្លួន ក្នុងឆ្នាំ ១៩៨០ បានសរសេរសំដែងអភិវន្ទនកិច្ចចំពោះលោក ការ៉ូលីស ប្វជិថៈ គុណាវទេិន ដែលជាលេខាធិការនៃគណៈកម្មាធិការក្រុងកូឡំបូ ថាជាអ្នកច្នៃបង្កើតទង់សាសនា ។ នៅឆ្នាំ ១៩២៨ សារពតិមាន « សុនទមីនៈ » ក៏បាននិយាយយោងដល់ហេតុការណ៍ដដែលនេះដែរ, ប៉ុន្តែគេបានទទួលស្គាល់ថា សមាជិកទាំងឡាយរបស់គណៈកម្មាធិការកូឡំបូ តែងតាំងឡើងអោយរៀបចំបុណ្យពិសាខបូជា ក្នុងឆ្នាំ ១៨៨៥ ត្រូវបានគេជឿថា បានច្នៃបង្កើតទង់ពុទ្ធសាសនានេះ ។

កាលចេញផ្សាយក្នុងឆ្នាំ ១៨៨៥ នោះ ទង់ពុទ្ធសាសនាមានពណ៌ប្រាំមួយ គឺ ខៀវ ( នីលៈ ), លឿង ( បីតៈ ), ក្រហម ( លោហិតៈ ), ស ( ឱទាតៈ ), ហង្សបាទ ( មាញ្ជេស្ថៈ ) និងពណ៌ចម្រុះទាំងប្រាំ ដែលតាងពណ៌ផ្លេកដូចពន្លឺពេជ្រ ( បភាស្វរៈ ) ។ ដើមកំណើតពណ៌ទាំង នោះ ត្រូវបានគេយកតាមពណ៌រស្មីទាំងប្រាំមួយ ចាំងចេញពីព្រះកាយព្រះពុទ្ធ បង្កើតជាមណ្ឌលមូល ទំហំប្រមាណ ១,៨០ ម ។ យោងតាមសំដីលោកវរសេនីយឯក អូលកូត ពណ៌ដដែលនេះ ត្រូវបានគេប្រើនៅក្នុងទង់របស់លោកសង្ឃទីបេត៍ ដែលមានឈ្មោះថា ដាឡៃឡាម៉ា ។ សណ្ឋានទង់នោះ គឺរាងបួនជ្រុង ទ្រវែង ។

ក្នុងពេលដែលពុទ្ធសាសនិកជនស្រីលង្កា បានប្រារព្ធធ្វើបុណ្យពិសាខបូជាជាលើកដំបូង ក្រោមអាណានិគមអង់គ្លេស, កាលនោះ លោកវរសេនីយឯក អូលកុត កំពុងឋិតនៅក្នុងប្រទេសឥណ្ឌា ។ លោកបានត្រឡប់ទៅកាន់កោះស្រីលង្កាវិញ នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៨៨៦ ។ លោកបានឃើញទង់ពុទ្ធសាសនាជាលើកដំបូង នៅវត្តទីបទុត្តរារាម, ស្រុកកោតហេន ។ លោកបានកត់ទុកនូវការចាប់អារម្មណ៍ដំបូងរបស់លោកអំពីទង់ពុទ្ធសាសនា ដូចតទៅថា : « នៅពេលគណៈកម្មាធិការកូឡំបូ បានព្រាងទង់, គឺទង់មានសណ្ឋានកន្ទុយស្រួច ដូចមេលឹម ( Fanion ) របស់កុប៉ាល់ ដែលពុំសមស្របសម្រាប់ការដង្ហែក្បួនបុណ្យ ឬក៏ដោតជាកិត្តិយសដល់ពិធីបុណ្យនៅតាមគេហដ្ឋាន » ។ បន្ទាប់មក លោកបានផ្តល់យោបល់ថា ទង់គួរតែធ្វើអោយមានរាងរៅធម្មតា និងទំហំប៉ុនទង់ជាតិ, ហើយពេលណា គំរូទង់ធ្វើបានហើយ ត្រូវដាក់សុំយោបល់យល់ព្រមអោយប្រើពីព្រះសង្ឃជាន់ខ្ពស់ផង ។ យោងតាមសំណូមពរនេះ ទង់ពុទ្ធសាសនាត្រូវបានកែសម្រួល ហើយត្រូវបានចេញបង្ហាញខ្លួន នៅក្នុងកាសែត « សរសវី កន្ទរេសៈ » នៅថ្ងៃទី ៨ មេសា ១៨៨៦ ។ ទង់ពុទ្ធសាសនា កែសម្រួលនេះ ត្រូវបានគេបង្ហូតឡើងត្រដែត នៅថ្ងៃបុណ្យពិសាខបូជា ក្នុង ឆ្នាំ ១៨៨៦ នៅក្នុងវត្តអារាមស្ទើរតែទាំងអស់ ហើយនិងនៅតាមលំនៅស្ថានជាច្រើន នៅក្នុងប្រទេសស្រីលង្កា ។

ទង់ពុទ្ធសាសនានេះ ក៏បានបញ្ចូលយកទៅប្រើនៅប្រទេសជប៉ុន ក្នុងឆ្នាំ ១៨៨៩ ដោយលោកអនាគារិក ធម្មបាល និងលោក វរសេនីយឯក ហេនរី ស្ទីល អូលកូត, ហើយក្រោយមក ក៏បាននាំយកមកប្រើនៅប្រទេសភូមា ។ ទង់ពុទ្ធ-សាសនាត្រូវបានគេទទួលស្គាល់ជាផ្លូវការ ទុកជាទង់របស់ពុទ្ធសាសនិកជនពិភពលោក តាមសេចក្តីស្នើសុំរបស់សពលោកសាស្ត្រាចារ្យម៉ាឡាឡាសេកេរៈ និងត្រូវបានពុទ្ធិកសមាគមពិភពលោក ក្នុងសម័យប្រជុំមួយ នៅទីក្រុងកូឡំបូ ក្នុងឆ្នាំ ១៩៥០ អនុម័ត

ទទួលយល់ព្រមប្រើផង ។ ឥឡូវនេះ ទង់ពុទ្ធសាសនាបានទទួលឋានៈជានិមិត្តរូបរបស់ពុទ្ធសាសនាអន្តរជាតិហើយ ។ ប្រទេសកម្ពុជា បានទទួលយកទង់ពុទ្ធសាសនាមកប្រើចាប់ពីឆ្នាំ ១៩៥០ រៀងមក ។

## អំពីទង់ជាតិខ្មែរ

ទង់ជាតិប្រទេសកម្ពុជា មានសណ្ឋានបួនជ្រុងទ្រវែង តាមខ្នាតទង់អន្តរៈជាតិ ហើយមានពណ៌ខៀវអមពណ៌ក្រហមឆ្នូតបណ្ដោយ ស្របគ្នាលើផ្ទៃទង់ គឺពណ៌ខៀវឆ្នូតលើគែមសងខាង ទំហំនិមួយៗប្រមាណ ១/៤ អមពណ៌ក្រហមដែលមានទំហំប្រមាណជិត ២/៤ នៅកណ្ដាល ។ នៅលើផ្ទៃពណ៌ក្រហមនេះ មានរូបប្រាសាទអង្គរវត្តពណ៌ស ឋិតនៅចំកណ្ដាល ។

ក្នុងបណ្ដាពណ៌ទាំងបីនេះ ពណ៌និមួយៗត្រូវបានគេបកស្រាយ និងផ្ដល់អត្ថន័យនិមិត្តរូបផ្សេងៗគ្នា ឬល្អៀងពីគ្នា ទៅតាមទស្សនៈយល់ឃើញរៀងៗខ្លួន ។ ប៉ុន្តែ ជារួម គេនិយមអោយអត្ថន័យដូចតទៅនេះ : ពណ៌ខៀវ តាងសេចក្ដីរុងរឿងថ្លៃថ្នូរ សុចរិត យុត្តិធម៌ ស្មោះត្រង់របស់ជាតិ, រីឯពណ៌ក្រហម តាងសេចក្ដីអង់អាចក្លាហាន ឆន្ទៈមោះមុតរបស់ជាតិ ហ៊ានប្រយុទ្ធ និងធ្វើពលិកម្មគ្រប់យ៉ាង ដើម្បីការពារ ជាតិនិងមាតុភូមិ ដែលតាងដោយប្រាសាទអង្គរ ពណ៌ស ដ៏ជានិមិត្តរូបនៃសេចក្ដីបរិសុទ្ធ បញ្ញាញាណ ទេពកោសល្យត្រដុងត្រដោម អរិយធម៌ត្រចះត្រចង់បូរណភាពទឹកដី ឯករាជ្យ អធិបតេយ្យរបស់ជាតិ ។

យើងពុំទាន់បានរកឃើញឯកសារណាបញ្ជាក់ថា ទង់ជាតិរបស់យើងបច្ចុប្បន្ននេះ ចាប់ផ្ដើមកើតមាន និងដាក់អោយប្រើជាផ្លូវការ នៅថ្ងៃ ខែ ឆ្នាំណាពិតប្រាកដទេ ។ យើងគ្រាន់តែបានដឹងខ្លះថា ទង់ជាតិរបស់យើង កើតមាន និងដាក់

អោយប្រើនៅពេលមុនអាណានិគមបារាំងដាក់អាណាព្យាបាលលើប្រទេសកម្ពុជា ក្នុងឆ្នាំ១៨៦៣ ក្នុងរាជ្យព្រះបាទអង្គឌួង ។ ព្រះអង្គបានជ្រើសយករូបប្រាសាទអង្គរវត្ត ដ៏ជាទីសក្ការៈរបស់ខ្មែរ ទុកជាប្រភពបញ្ញាញាណជាតិ និងជានិមិត្តសញ្ញាបោះពុម្ពលើប្រាក់កាក់ និងជានិមិត្តសញ្ញាលើទង់ជាតិ ។

ចំណោរកាលក្រោយមក ទោះបីប្រទេសជាតិមានវិបត្តិ ហើយមេដឹកនាំខ្មែរមាននិន្នាការនយោបាយផ្សេងៗពីគ្នា ឈានទៅដល់ច្នៃបង្កើតទង់ជាតិថ្មីប្រចាំក្រុមរបស់ខ្លួនក៏ដោយ ក៏មេដឹកនាំនយោបាយទាំងនោះ នៅតែមានគំនិតមួយដូចគ្នា គឺត្រង់យកស្មារតីចងចាំ នៃយុគសម័យអង្គរវត្ត ពោលគឺ យករូបប្រាសាទអង្គរវត្ត ធ្វើជាគោលបំណងនយោបាយរបស់ខ្លួន ។ ការជ្រើសយកពណ៌ទង់ផ្សេងគ្នា ឬរចនាបថប្រាសាទប្លែកគ្នា ដូចជា ខ្លះយកប្រាសាទកំពូលបី, ខ្លះយកប្រាសាទកំពូលប្រាំ ខ្លះទៀតយកប្រាសាទកំពូលបីដែរ តែថែមរូបផ្កាយ ធ្វើជានិមិត្តសញ្ញានៃទង់ជាតិប្រចាំក្រុម ឬរបបគ្រប់គ្រងរបស់ខ្លួនក៏ដោយ, ប៉ុន្តែចំណុចរួមគឺ រូបប្រាសាទអង្គរវត្តតែមួយ ។ ឯភាពផ្សេងគ្នានៃទង់ជាតិ គឺមានមូលហេតុចេញមកពីបដិបក្ខខាងនយោបាយ ហើយមនោសញ្ចេតនាស្នេហាជាតិ មាតុភូមិ ក៏ផ្អែកលើមូលដ្ឋានបដិបក្ខនេះដែរ ។

ក្រៅពីទង់ជាតិ ដែលជានិមិត្តសញ្ញាសំគាល់ជាតិ, គេបានប្រើគ្រឿងលំអខ្លះទៀត ដើម្បីផ្តល់កិត្តិយស និងឧឡារិកភាពនៅក្នុងព្រះរាជពិធីដង្ហែរក្បួនធំៗ ដូចជា ចាមរ, សែនត្ងួន, បៃមន់, ក្លស់, អភិរម្យជាដើម ។

សែនត្ងួន គឺជាឆ្លីតមានសណ្ឋានមូលធ្វើអំពីសំពត់ផ្កាមាស ឬផ្កាប្រាក់ ជាដើម មានដងកូក់ខាងចុង ប្រើសម្រាប់ជាគ្រឿងបាំងកំដៅថ្ងៃ មិនអោយចាំងត្រូវ ។

បៃមន់ គឺជាគ្រឿងប្រដាប់មួយប្រភេទ មានសណ្ឋានដូចស្លឹកមន មានដងស្រដៀងនឹងចាមរដែរ, ប៉ុន្តែត្រង់កំពូលមានរាងស្រួច វៀវ ហើយវេចកូក់ងាកទៅខាងបន្តិច ។

អភិរម្យ ឬ អភិរំ គឺជាឆត្រត្រូវតមានរំភាយដូចក្លស់ សម្រាប់ជាគ្រឿងរុងរឿង, វិឯចាមរ គឺជាគ្រឿងមួយប្រភេទ មានសណ្ឋានដូចផ្លិតសម្រាប់មន្ត្រីសង្ឃទីរាជាគណៈដូច្នោះ, ប៉ុន្តែ គ្មានកំពូល និងឆែក១ជុំវិញទេ, ហើយមានដងវែង ។ គ្រឿងប្រដាប់ទាំងប៉ុន្មានប្រភេទនេះ ឃើញមានប្រើដើម្បីលើកកិត្តិយស និងសេចក្តីរុងរឿង នៅក្នុងព្រះរាជពិធីហែក្បួនធំៗ ដូចជាក្នុងព្រះរាជពិធីរាជាភិសេកជាដើម ។

---


ឯកសារពិគ្រោះ

1 - Encyelopeadia of Buddhism, Vol V, Fascicle 2
1991 - Sri Lanka - p.p. 250 - 252

2 - The World Fellowship of Buddhists - 4oth Anniversary
1950 - 1990 - General Conference - Seoul, Korea 1990

3 - បណ្ឌិត . ប៊ិត ស៊ាងលីម, ពូជអ្នកចំបាំង, បោះពុម្ពឆ្នាំ ១៩៩៧

4 - ព្រះសង្ឃរាជ ជ. ណាត, វចនានុក្រមខ្មែរ, បោះពុម្ព ១៩៦៧

# រឿងក្អែក និង សំពោច

សុត្តន្តប្រីជា ឥន្ទ

កាកគតិពែង

ដំណាលដំណែង ដំណើរបក្សា
ក្អែកគោកមួយនៅ លើចុងរុក្ខា
សែនសុខជាស្ថា- ពរពិតឥតមោះ ។

ថ្ងៃមួយបក្សី

ចេញស្វែងចំណី តាមភូមិក្បៀនកោះ
ឃើញអ្នកនិគម ហាលនំទឹកដោះ
ក្អែកអរហើយផ្លោះ ចុះចោះចឹកបាន ។

កាងស្លាបហើរស្ទៅ

តម្រង់ត្រង់ទៅ សំដៅស្មសាន
ដល់ហើយចុះទំ ទ្រនំនៃប្រាណ
បែរមើលទីឋាន ដានដែលឃាត្រា ។

កាលនោះមានសត្វ

សំពោចមួយផាត់ ស្វែងរកភោគ្គា
មកដល់យល់ក្អែក ទំមែករុក្ខា
មាត់ពាំនំប្រា- កដជាចំណី ។

សំពោចគិតថា

អញនឹងចរចា បញ្ឆោរបក្សី
ឱ្យវាបាត់ ភ្ញាក់ផ្អាក់ចំណី
ជ្រុះមកដល់ដី បានអញវិញណា ។

គិតហើយទើបពោល

ជាពាក្យបញ្ឆោរ ទៅកាន់ក្អែកថា
ក្អែកអើយអ្នកក្អែក រូបឯងសោភា
ចំពុះដូចជា ខ័នកែវមរកត ។

រោមស្លាបស្រស់ស្រិល

រលង់ដូចនិល រលើបហ្មត់ចត់
ចង្កេះសមទ្រង់ ជង្គង់សមបទ
វង់មុខសមមាត់ សមមានលក្ខណា ។

រូបអ្នកឧត្តម

បើតាមក្បួនខ្ញុំ ទំនាយទាយថា
នឹងបានសម្រេច ជាស្តេចបក្សា
តែសព្ទសរា ពុំទានប្រត្យក្ស ។

បើសិនអ្នកស្រែក

ខ្ញុំឮសម្រែក សូរសមចំសក្តិ
ខ្ញុំប៉ានទំនាយ ទាយថាអ្នកជាក់
បានជាចមចាក់ កំពូលបក្សា ។

ក្អែកឡើងអំនួត

ឮគេបង្អួត សរសើរអាត្មា

ចង់ឱ្យគេស្ដាប់ សូរស័ព្ទសរា
ទើបឈរឡើងហា- មាត់ស្រែកចេញស្ដី ។
ឯនំពាំនោះ
ធ្លាក់ពីចំពុះ ជ្រុះមកដល់ដី
សំពោចស្រុះស្រួល ទទួលចំណី
ហើយបែរស្រដី ចំអកបក្សា ។
ក្អែកអើយចៅក្អែក
អ្នកឯងបែងចែក ចំណីនេះណា
យើងពេញគាប់ចិត្ត ដ្បិតអ្នកយល់ថា
យើងជាហោរា ទទួលខ័ខៅ ។
ថាហើយចៅក្អែក
ប្រព្រឹត្តនេះឯក ឥតមានហ្មងសៅ
អ្នកឯងទៅរក មកទៀតណាចៅ
ពីថ្ងៃនេះទៅ យើងបានពឹងផង ។
ថាហើយសំពោច
ប្រែប្រាណស្ទុះផ្លូច ចូលព្រៃដូចប៉ង
កាកោបង់នំ ក្រំចិត្តកន្លង
ពុំដឹងទំនង ខ្មោចលេងភក្សា ។

***

# ល្បិចចៅក្រម

( ល្បិចរបស់ចៅក្រមអ្នកជំរះក្តី )

ក្នុងសតវត្សរ៍ទី ២៣ នៃពុទ្ធសករាជ ត្រូវគ្នានឹងសតវត្សរ៍ទី ១៧ នៃគ្រីស្តសករាជ *ព្រះបាទសម្តេចព្រះជ័យចេស្តា ព្រះមហាក្សត្រិយ៍នៃប្រទេសកម្ពុជា* ទ្រង់ព្រះរាជបញ្ញាអោយពួកបណ្ឌិតរៀបចំរបៀបជាល្បិចនៃចៅក្រមអ្នកជម្រះក្តី អោយបានទៀងទាត់ តាមសុចរិតយុត្តិធម៌ អោយងាយពិនិត្យពិភាក្សាការណ៍ពិត ដោយល្បិច ៤ យ៉ាង ដែលហៅជាពាក្យបាលីសន្មតថា *មន្ទលេន, សេនបទ, មណ្ឌុកជ, សីហលោ* ។

ល្បិចចៅក្រមទាំងបួនយ៉ាងនេះ មានសេចក្តីអធិប្បាយថា ៖

*១. មន្ទលេន* ( អានថា ៖ មន់-ទះលេន ) ( បា. ស. *មន្ទ* « ទន់, ទន់ភ្លន់, ស្រទន់, សន្សឹមៗ, តិច » + *លេន* « សន្ទុះ, ល្បឿន, ការស្ទាបស្ទង់ » ) ។

ល្បិចឈ្មោះ *មន្ទលេន* នេះ មានអត្ថន័យថា ចៅក្រមត្រូវពិចារណានូវអធិករណ៍ គឺរឿងក្តី តាមពាក្យចោទ និងចម្លើយ ដែលស្ទាបស្ទង់ឃើញថា មុនបង្អស់មិនគួរកញ្ឆក់កញ្ឆែងទេ ក៏ប្រើល្បិចសុភាព ទន់ភ្លន់ សន្សឹមៗ ប្រៀបប្រដូចនឹងទឹកហូររិញ្ចៗ មិនហូរគំហុកខ្លាំង ហូរធ្លាក់ចុះទៅក្នុងស្រះ ឬត្រពាំង ដក់បានជាទឹកពេញទីនោះគួរដល់ការប្រើប្រាស់បានដូច្នេះឯង, បើចៅក្រមប្រើល្បិចនេះទៅឃើញការណ៍ពិតសព្វគ្រប់ហើយ ក៏សម្រេចសេចក្តីអោយអធិករណ៍នោះចប់ស្រេចដោយប្រពៃបានត្រឹមប៉ុណ្ណោះទៅ ។

*២. សេនបទ* ( អានថា ៖ សេន៉ះបត់ ) (បា. *សេន* « សត្វខ្លែង + *បទ* « ដំណើរ, ផ្លូវ, គន្លង, ហេតុ, ឧបាយ, ...) ។

ល្បិចឈ្មោះ *សេនបទ* នេះ មានន័យថា ចៅក្រមត្រូវពិនិត្យពិចារណានូវរឿងក្តី តាមពាក្យចោទ និងចម្លើយ ដោយប្រើល្បិចស្ទាបស្ទង់មើលយកតម្រាប់តាមសត្វខ្លែង ដែលវាឆាបអ្វីៗ មានកូនមាន់ជាដើម ជាចំណីរបស់វា, ធម្មតា សត្វខ្លែង មុននឹងឆាបកូនមាន់ជាដើម វាត្រូវហើរវេរាៗ គេលកុង ស្ទង់មើលសិន លុះតែឃើញមានទំនងឱកាសល្មមឆាបឆក់បាន ទើបវាសម្លបស្លាបឆាបចុះ ហើយវាហើរប៉េវឡើងទៅ, បើចៅក្រមយល់ឃើញថា ត្រូវប្រើល្បិចរិះរេបែបសត្វខ្លែង ហើយត្រញិចសម្រេចសេចក្តីអោយអធិករណ៍បានចប់ ដោយសុចរិត យុត្តិធម៌ហើយ ក៏ទុកជាស្រេចត្រឹមប៉ុណ្ណោះទៅ ។

៣. *មណ្ឌុកជ* ( អានថា ម័ន-ឌុកត់ ឬមន់ - ) ( បា. *មណ្ឌុក* ឬ *មណ្ឌូក* « កង្កែប » + *កត* > *កជ* « ដែលធ្វើ គឺការលោត » ) ។

ល្បិចឈ្មោះ *មណ្ឌុកជ* នេះ មានអត្ថន័យថា ចៅក្រមត្រូវពិនិត្យពិចារ-ណានូវអធិករណ៍ តាមពាក្យចោទ និងចម្លើយ ដែលលៃស្ទង់មើលឃើញថា រឿងនេះត្រូវប្រតិបត្តិតាមតម្រាប់កង្កែបលោត, ធម្មតាកង្កែប វាមិនលោតឥតឈប់បង្អង់សោះទេ, វាតែងតែលោតផ្លោតៗ ហើយឈប់បង្អង់ម្តងៗ បន្តិចៗ ហើយទើបវាលោតផ្លោតៗតទៅទៀត ។ ចៅក្រមក៏ត្រូវធ្វើយ៉ាងនោះដែរ គឺត្រូវស្ទាបស្ទង់មើលកុំប្រញាប់ប្រញាល់រួសរាន់ពេក, បើអធិករណ៍ហុចដំណើរអោយមកឃើញថា គួរវិនិច្ឆ័យបានហើយ សឹមសម្រេចសេចក្តីអោយរឿងនោះចប់ស្រេច ដោយសុចរិតយុត្តិធម៌ត្រឹមប៉ុណ្ណោះទៅ ។

៤ . *សីហលោ* ( អានថា : សីហៈលោ ) ( បា. *សីហ* « សត្វសីហៈ » + *លោ* < លា « កាត់, កាត់ផ្តាច់, កាន់, កាន់យក » ជា បា. ស. ថា *សីហលោ* )

. ល្បិចឈ្មោះ *សីហលោ* នេះមានអត្ថន័យថា កាលបើចៅក្រមពិនិត្យពិចារណាឃើញរឿងនោះ មានភស្តុតាងច្បាស់ក្រឡែត មិនគួរអោយសង្ស័យទេ

ប៉ុន្តែ បុគ្គលអ្នកជាប់ចោទអរង់អាចរបឹងរបាញ ក្លែងក្លាងហួសហេតុពេក មិនព្រម សារភាពតាមការណ៍ពិតសោះ, ចៅក្រមត្រូវប្រើអាការគំរាមសម្លុតតាមមាត្រាច្បាប់ អោយបុគ្គលនោះស្លុតតាំងកៀងក្រទាំង ហើយឆ្លើយអោយការណ៍តាមពិតត្រង់ ដោយចៅក្រមយកតម្រាប់តាមសីហៈ ដែលវាបន្លឺសីហនាទស្រែកសន្ធាប់ម្រឹគ ហើយវាខាំសម្លាប់យកជាចំណីវាដូច្នោះដែរ, ហើយចៅក្រមវិនិច្ឆ័យសំរេចសេចក្តី ដោយសុចរិតយុត្តិធម៌ អោយចប់ស្រេចត្រឹមប៉ុណ្ណោះទៅ ។

ល្បិចចៅក្រមទាំង ៤ យ៉ាងនេះ ហៅថា *ល្បិចព្រះជ័យចេស្តា ឬច្បាប់ ព្រះជ័យចេស្តា* ។ ល្បិចចៅក្រមនេះ មិនមែនសម្រាប់តែចៅក្រមគ្រហស្ថទេ ទោះ ទាំងចៅក្រមបព្វជិត ក៏គួរប្រើល្បិចចៅក្រមទាំង ៤ យ៉ាងនេះបានដែរ ។

ខាងក្រោមនេះ គឺជាកាព្យសម្រាប់អោយងាយចាំ ។

## ល្បិចចៅក្រម

មន្ទលេន សេនបទ ទាំងមណ្ឌុកដ និងសីហលោ
ទាំងបួននេះជា រាជោវាទោ នៃក្សត្រសេដ្ឋោ ព្រះជ័យចេស្តា ។
មហាក្សត្រខ្មែរយើង ស្តេចមានឫទ្ធិថ្កើង ទ្រង់បានប្រាប្តា-
ភិសេកហើយស្រេច ស្តេចទ្រង់បញ្ជា អោយប្រាជ្ញព្រឹទ្ធា តែងល្បិចចៅក្រម ។
ជាពាក្យបាលី សន្មតសេចក្តី ដោយការផ្សែផ្សំ
ក្រឹត្យទុកជាច្បាប់ សម្រាប់ចៅក្រម កាត់ក្តីអោយសម នឹងយុត្តិធម៌ ។

ដកស្រង់ពី វចនានុក្រមខ្មែរ ភាគទី ២
ពោះពុម្ព ១៩៦៧ . ១៩៦៨ . ជ. ណ
ទំព័រ ១១៣៧ . ៣៨

# បទថយក្រោយ

## *វាចារំឭក*

*អត្ថបទកំណាព្យដែលលោកអ្នកនឹងត្រូវបានអាននៅក្នុងទំព័រជាបន្តទៅនេះ មានឈ្មោះថា បទថយក្រោយ ។ បទនេះត្រូវបានលោកកវីនិពន្ធ អៀង សាយ ចងក្រងឡើងនៅក្នុងសៀវភៅរបស់លោកឈ្មោះ " មេកាព្យ " ។ ខ្ញុំបានអានកំណាព្យនេះ នៅក្នុងទសវត្សទី ៦០ រួចហើយក៏នៅចាំបទនេះរត់មាត់រហូតមកដល់សព្វថ្ងៃ ។ ដើម្បីកុំអោយបាត់បង់នូវស្នាដៃ ដ៏មានតម្លៃនេះ ខ្ញុំសូមកត់កំណាព្យបទថយក្រោយរបស់លោកកវីនិពន្ធ អៀង សាយ ទុកក្នុងទស្សនាវដ្ដីកម្ពុជសុរិយាលេខនេះ គ្រាន់ជាគំរូនៃបទ និងគ្រាន់ជាការអានកំសាន្ត សម្រាប់ជនានុជនស្នេហាវប្បធម៌ជាតិ ។*

*បទថយក្រោយ គឺជាបទកំណាព្យពាក្យ ៧ មានបួនឃ្លា ដែលគេអានដោយចាប់ផ្ដើមពីពាក្យទី ១ នៃឃ្លាទី ១ ទៅមុខរហូតដល់ពាក្យចុងបញ្ចប់នៃឃ្លាទី ២ រួចអានពាក្យចុងបញ្ចប់នៃឃ្លាទី ២ ដដែលនេះត្រឡប់វៀងគ្នា ម្ដងមួយពាក្យៗ ថយមកក្រោយវិញ រហូតដល់ពាក្យទី ១ នៃឃ្លាទី ១ ។*

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | ក | ខ | គ | ឃ | ង | ច | ឆ |
| 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | | | | | | | | | | | | | |
| ក | ខ | គ | ឃ | ង | ច | ឆ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

*ព្រមជាមួយនឹងបទថយក្រោយនេះ ខ្ញុំក៏សូមចម្លងទុកផងដែរនូវប្រស្នាមួយ ភ្ជាប់ដោយចម្លើយផង ដែលលោក អៀង សាយ បានចងក្រងឡើងគ្រាន់ជាការកំសាន្ត និងការល្បងប្រាជ្ញា ។*

មិថុនា ១៩៩៧ ចន់ ហ៊ិន

## បទជយក្រោយ ទី ១

ព្រួយចិត្តព្រោះក្រនាំតូចទាប ខូចឈ្មោះបាត់លាភគ្មានគេដូច
ដូចគេគ្មានលាភបាត់ឈ្មោះខូច ទាបតូចនាំក្រព្រោះចិត្តព្រួយ ។
ប្រាក់មាសមានរីកមុខមួយគ្រា ជួយយិតយោងគ្នាមានទ្រព្យត្រួយ
ត្រួយទ្រព្យមានគ្នាយោងយិតជួយ គ្រាមួយមុខរីកមានមាសប្រាក់ ។

## បទជយក្រោយ ទី ២

បងបានអូនមកដល់ធូរចិត្ត ស៊ូទ្រាំផ្ដេកផ្ដិតគិតគ្រងតួ
តួគ្រងគិតផ្ដិតផ្ដេកទ្រាំស៊ូ ចិត្តធូរដល់មកអូនបានបង ។
ស្មោះស្ម័គ្រចិត្តពិតគិតប៉ងជាប់ សងសូមរៀបរាប់តាមស្នេហ៍ស្នង
ស្នងស្នេហ៍តាមរាប់រៀបសូមសង ជាប់ប៉ងគិតពិតចិត្តស្ម័គ្រស្មោះ ។

កំសាន្ត

# ប្រស្នា

នៅក្នុងអង្គប្រជុំមួយ ដែលមានមន្ត្រីរាជការជាច្រើនរូបចូលរួម គេបានបញ្ចូលរបៀបវារៈកំសាន្តមួយ ។ ខ្ញុំត្រូវគេអញ្ជើញអោយឡើងសំដែងរហាសកម្មជូនអង្គប្រជុំទស្សនាលេងកំសាន្ត ។ ខ្ញុំស្ទៀកពាក់ខោអាវធំឡើងលើ « ឆាក » ដែលមានតុមួយដាក់នៅចំកណ្ដាល ។

ខ្ញុំប្រកាសសួររកអ្នកណា ដែលស្មគ្រចិត្តអោយក្ងួនកន្សែងដៃមកខ្ញុំមួយ « ខ្ញុំនឹងសំដែងប៉ាហ៊ីអោយមើល » ។ ស្រាប់តែមានបុរសម្នាក់ ងើបឈរឡើងដក យកក្ងួនកន្សែងដៃមួយពីក្នុងហោប៉ៅខោ កាន់វលាស់ៗបង្ហាញខ្ញុំ ខណៈដែលអ្នកខ្លះ ទៀត ហាក់ដូចជាចង់អោយដែរ តែចិត្តនៅរារែក ។ ខ្ញុំក៏ប្រញាប់ទៅយកក្ងួនកន្សែង ដៃពីអ្នកស្ម័គ្រចិត្តទីមួយ ។ ខ្ញុំលាតត្រដាងក្ងួនកន្សែងដៃជូនទស្សនិកជនមើល ឃើញ មានឆ្នូតបីជុំវិញ មានពណ៌ខុសៗគ្នា គឺខៀវ ស ក្រហម ថែមទាំងមានស្នាមប្រឡាក់ ទឹកខ្មៅប៉ុនម្រាមដៃនៅក្បែរជ្រុងមួយ ។

ខ្ញុំជម្រាបទស្សនិកជនអោយពិនិត្យអោយបានច្បាស់ ថាតើក្ងួនកន្សែងដៃ នេះ មានអ្វីខ្លះជាសំគាល់ ។

បន្ទាប់ពីនោះ ខ្ញុំក៏យកឈើគូសចេញមក ហើយជម្រាបទស្សនិកជនថា « ចាំមើលណា៎ ! ខ្ញុំដុតក្ងួនកន្សែងនេះអោយឆេះអស់ » ។ លុះឆេះអស់ហើយ ខ្ញុំក៏ ប្រមូលកំទេចផេះដាក់មួយដុំតូច ។ ស្រាប់តែរំពេចនោះ ខ្ញុំធ្វើបានជាក្ងួនកន្សែងដៃ «ដដែល» នោះ មកលាតត្រដាងអោយគេមើល ឃើញមានការកត់សំគាល់ដូចគ្នា ទាំងអស់ យកទៅសងម្ចាស់គេវិញ ។ ទស្សនិកជននាំគ្នាទះដៃបោ៉ា និងសើចយ៉ាង រីករាយ ។

តើខ្ញុំធ្វើដូចម្ដេច ?

## ចម្លើយ

ល្បែងនេះជាការបន្លំភ្នែកដោយសុទ្ធសាធ ។ ម្ចាស់ក្ងួនកន្សែងដៃ និងខ្ញុំ យើងទាំងពីរនាក់បានត្រូវរ៉ូវគ្នាពីមុនមករួចជាស្រេច ប៉ុន្តែមិនអោយអ្នកណាម្នាក់ដឹង ឡើយ ហើយយើងត្រូវកាន់អាកប្បកិរិយាដូចជាមិនដែលស្គាល់គ្នាអញ្ចឹង ។

ខ្ញុំបានទៅទិញកូនកន្សែងដៃពីរ ម៉ាកតែមួយ នៅក្នុងប្រអប់តែមួយ ដោយរើសយកអាពីរណាដែលមានពណ៌ និងឆ្នូតដូចគ្នាបេះបិទ ។ ខ្ញុំដាក់កូនកន្សែងទាំងពីរត្រួតអោយចំពីលើគ្នា រួចបន្តក់ទឹកខ្មៅមួយដំណក់ដាក់ក្បែរជ្រុងមួយ ។ ដូច្នេះ កូនកន្សែងដៃទាំងពីរប្រឡាក់ទឹកខ្មៅនៅត្រង់កន្លែងមួយដូចគ្នា ។ ខ្ញុំអោយមួយទៅដៃគូខ្ញុំ ។

គឺនៅពេលដែលខ្ញុំធ្វើជាកំពុងប្រមូលផេះនេះហើយ ដែលខ្ញុំប្រើល្បិចដោយបែរខ្នងបាំងមួយភ្លែត កុំអោយគេមើលដៃខ្ញុំឃើញ ហើយខ្ញុំត្រូវឆក់ឱកាសនេះអោយបានឆាប់បំផុត ដើម្បីហូតយកកូនកន្សែងដៃនៅល្អ ដែលខ្ញុំបានលាក់ទុករួចជាស្រេចនៅក្នុងដៃអាវខ្ញុំ ។ បើពេលនោះដៃគូរបស់ខ្ញុំ គេមិនអោយកូនកន្សែងដៃនោះមកអោយខ្ញុំទេ ឬក៏គេក្រហុចអោយពេក ហើយបណ្តាលអោយអ្នកណាផ្សេងអោយកូនកន្សែងផ្សេងវិញ ក៏ល្បែង " បន្លំ " ភ្នែកនេះ មិនអាចសំដែងកើតដែរ ។

* * *

បុរាណភាសិត

អំណាត់ ( ខន្តី ) កើតអំណាច
ហឹង្សាពេក កើតទោសា
ប៉ោច១ អាប់ប្រាជ្ញា
យូ១ថា ថ្លៃដូចមាស ។

# វាចាឈើប៉ីដងវែង (១)

( បទពាក្យ ប្រាំបួន )

- ខ្ញុំឈើប៉ី ដងមិនខ្លី អាយុវែង
ចិត្តចំបែង រស់កណ្ដែង សែនអភ័ព្វ
ក្មេងៗថ្មី មិនបេតី ពិបាកផ្ដាប់
ព្រោះមិនធ្លាប់ ស្ដាប់រៀបរាប់ រឿងបុរាណ ។

- ឈើប៉ីចាស់ ឆ្លងប្រាំម្ចាស់ គ្មានមន្ទិល
ស្នូកសីកវិល រលោងស្រិល សព្វទាំងប្រាណ
ខ្នង់ខ្លះខ្នង ដាច់ក្រហូង នៅដេញបាន
ប្រាប់សន្ទាន ស្ងួមកុំស្មាន ថាចាស់អន់ ។

- ចាស់ខ្ញុំពិត ស្មើជីវិត ប្រាំតំណ
អារម្មណ៍ល្អ រស់កំដរ មិនដែលឆ្អន់
ញាតិជិតឆ្ងាយ ចង់សប្បាយ ចង់ស្រាកស្រន់
លាបំណន់ ឬចង់បន់ បានទាំងអស់ ។

- និយាយពិត ម្ចាស់ជំនិត ងងឹតភ្នែក
សំឡេងឯក ច្រៀងមិនបែក គួរស្រណោះ
ច្រៀងម្នាក់ឯង ដេញត្រែងៗ មិនក្រៀមក្រោះ
ញាតិទាំងអស់ ទាំងស្រីប្រុស សើចពព្រាយ ។

---

(១) ចាប៉ីដងវែង តាមឯកសារដើម ហៅ « ឈើប៉ីដងវែង » ។ អ្នកនិពន្ធប្រើពាក្យ « ឈើប៉ី » ព្រោះចង់បម្រើ អារម្មណ៍រវើរវាយ ដែលខ្លួនបានឮឈើប៉ីដងវែងចំណាស់មួយចេះនិយាយ ។

- ពេលខ្លះជោរ ខ្ញុំស្រែករោទ៍ តាមម្ចាស់ដេញ
ស្នូររលេញ សំឡេងដេញ តាមព្រះពាយ
គ្មានមីក្រូ តែខ្ញុំថ្ងូរ ស្នូរឮឆ្ងាយ
ភូមិឯនាយ ក៏សប្បាយ ជាមួយដែរ ។

- ម្ចាស់ប្រសប់ ច្រៀងរៀបរាប់ គ្រប់តួអង្គ
គាត់ច្រៀងខ្ជង់ មិនបោះបង់ ទំនៀមខ្មែរ
មានរឿងលោក មានរឿងធមិ មានរឿងប្រែ
ស្តាប់បានល្ហែ កែអោយល្ហើយ ស្បើយទុក្ខា ។

- ឥឡូវម្ចាស់ ទ្រុឌទ្រោមណាស់ ម្ចាស់ខ្ញុំផ្សង
រកអ្នកស្នង អ្នកចងក្រង ព្រេងវាសនា
ឈើប៉ុមួយ លោកសែនព្រួយ ស្មើសង្ខារ
តើលោកណា អាចរក្សា រូបខ្ញុំបាន ។

- ខ្ញុំបម្រើ តាមលោកប្រើ មិនគិតចាស់
ពីរោះណាស់ ខ្ញុំស្គាល់ច្បាស់ ព្រេងបុរាណ
ខ្ញុំអោយស្នូរ ខ្ញុំថ្ងូរថ្ងូរ មិនអោយល្ហាន
ខ្ញុំស៊ូបាន ទោះបីប្រាណ ចាស់ជរា ។

- សូមដង្ហោយ កូនខ្មែរក្រោយ កុំចោលខ្ញុំ
ប្រមូលផ្តុំ ខ្មែរអើយកុំ បាត់ពូជធា
បាត់សម្បុរ ប្រពៃណី ពង្សសាវតារ
សូមរក្សា ទុកសង្ខារ ខ្ញុំសាក្សី ។

ខៀវ បញ្ញាឧត្ត

# ដើមជ្រៃ

( បទពាក្យប្រាំពីរ )

សាយណ្ហរនោចទោចស្រែកទ្ធូញ ពុះជ្រៃកដោយព្រួញទំនួញរៃ
ព្រឹកព្រាងសេកជៀងត្នែករំពៃ ឆាបចឹកផ្លែជ្រៃជាអាហារ ។
ឫសខ្ញុំរឹរឹតត្បួប្រាសាទ ត្រួយផ្កាស្រស់ស្អាតជ្រៃកសិលា
ពត់ពេនដូចពស់ពឹងសក្តា គន់គាប់នេត្រាសង្ហាក្រៃ ។



ប្រាសាទ នៅក្នុងស្រុកសំបូរ ខេត្តកំពង់ធំ

ហ្វូងមេអំបៅកន្លង់ឃ្មុំ ស្និទ្ធស្នាលនឹងខ្ញុំរៀងរាល់ថ្ងៃ
ពេញចិត្តលំអងបុប្ផាជ្រៃ ឃ្មុំយកមែកច្នៃធ្វើបង្គង ។
នៅក្បែរបង្គាបបង្គួយគន់ សម្លឹងមើលរន្ធកណ្ដូបពង
កំប្រុករត់ប្រូចលោតរំលង ពីងពាងរាយមងក្បែរមែកពុក ។
ជាជ្រៃមានន័យថ្លៃស្មោះស បាននៃបនិត្យថ្នថាកទុក្ខ
រងភ្លៀងកំដៅខ្យល់បោកបុក ថ្នរស់សែនសុខម្លប់សាខា ។
ក្រោយភ្លៀងចាបច្រៀងថ្ងៃរៀបលិច ពណ៌មាសរំលេចលើវេហាស៍
សោភ័ណប្រាសាទស្អាតក្រៃណា ជ្រៃខ្ញុំជ្រះថ្លាក្នុងអារម្មណ៍ ។
អាយុយឺនយូរមិនដែលព្រួយ តែក្នុងថ្ងៃមួយខ្ញុំក្រៀមក្រំ
មនុស្សម្នាមកជិតសម្លឹងចំ ចង់ប្រល័យខ្ញុំសង្គ្រោះថ្ន ។
ម្ដេចមិនពិឃាតកាលនៅតូច បើខ្លាចថ្នខូចថ្នមិនល្អ
ឥឡូវខ្ញុំធំសូមអង្វរ ខ្ញុំស្រឡាញ់ថ្នដូចអ្នកដែរ ។
ធ្លាប់ល្អល្អកល្អឺនម្ដេចព្រាត់ប្រាស ខ្ញុំស្រឡាញ់ណាស់ពេញចិត្តថែ
ខ្ញុំក៏ជាជ្រៃលើដីខ្មែរ តើអ្នកស្ដាយដែរជីវិតខ្ញុំ ។
បើស្លាប់សូមកប់ខ្ញុំអោយល្អ កុំអោយប៉ះថ្នទោះមួយដុំ
ព្រោះថ្នជាពេជ្រចំពោះខ្ញុំ ថ្នអើយថ្នកុំបាត់ទៅណា ។

**ខៀវ បញ្ញាវុឌ្ឍ**

# ចម្លើយកំណាព្យប្រស្នា

ក្នុងទស្សនាវដ្ដី « កម្ពុជសុរិយា » លេខ ១ ឆ្នាំ ១៩៩៧

( បទពាក្យ ៧ )

- នេះហ្នឹងបរិយាយស្រាយបំភ្លឺ    បន្លិចពន្លឺពិពណ៌នា
ប្រាំពីរពាក្យពិតគិតឃ្លោងឃ្លា    ជូនជាចម្លើយឆ្លើយរឿងបាយ ។
- កំណាព្យប្រស្នាការណ៍កលកិច្ច    ដាក់ល្បោយដោយល្បិចលេងលែបខាយ
ខ្លឹមសារចំណោទចោទពីបាយ    ដែលមនុស្សទាំងឡាយស៊ីគ្រប់គ្នា ។
- *« ថាមានឈ្មោះបាយគេស៊ីបាន    ស៊ីអស់រាប់ចានក៏ពុំជា*
*ក្រៀមក្ដោកពោះស្ងិតចិត្តគ្រាំគ្រា    ស៊ីច្រើនចាក់ធារនៅតែឃ្លាន »* ។
- មិនដឹងថាបាយស្អីខុសគេ ?    ក្នុងលោកគ្មានទេសួរបំពាន
បាយម្ហូបស្រស់ស្រួបឱ្យរស់រាន    ស៊ីហើយបាត់ឃ្លានជាធម្មតា ។
- ដំបូងខ្ញុំសូមដាស់ពញ្ញាក់    ពិនិត្យឱ្យជាក់ពាក្យប្រស្នា
រាប់តែឈ្មោះបាយតាមអក្ខរា    ទើបដឹងដល់អាថ៌ន័យបង្កប់ ។
- បាយកកបាយខុនដល់បាយអ    បាយឡុកបាយឡទីបញ្ចប់
ឃើញឈ្មោះ «បាយខុំ»ល្បែងរន្ធដប់    ប្រស្នាបន្ទប់ថាបាយស៊ី ។
- ព្រោះល្បែងបាយខុំខ្ញុំធ្លាប់លេង    ដំណែលព្រឹទ្ធព្រេងគ្រាប់សែពីរ
ពេលដើររាយគ្រាប់ជាប់តទី    អស់គ្រាប់ខ្វះស៊ីទុកខាងខ្លួន ។
- ស៊ីទៅស៊ីមកយកចាញ់ឈ្នះ    រីឯក្រពះពុំជួបជួន
ឆ្អែតមានកំលាំងខ្លាំងមាំមួន    មានតែទ្រមខ្លួនរីតតែឃ្លាន ។

- នេះឯងល្បែងឈ្មោះបាយខុំ កាព្យប្រស្នាខ្ញុំផ្សំនិទាន
ល្បែងលេងក្មេងខ្មែរថែធរមាន ស៊ីមិនបាត់ឃ្លានវាយគ្រាប់ស៊ី ។
- លេងគ្នាពីរនាក់បញ្ជាក់ន័យ មានមនុស្សដទៃរោមមើលមី
វាយគ្រាប់រន្ធដប់គ្រប់សែពីរ ចុងបញ្ចប់ទីអស់គ្រាប់ដើរ ។
- អ្នកឈ្នះគឺអ្នកស៊ីគ្រាប់ច្រើន ប្រមូលបានច្រើនយកពីគ្លើ[1]
ពិន័យអ្នកចាញ់តាមដំណើរ ឱ្យផ្លិបង្ហើរសុំគ្រាប់វិញ ។
- គ្រាប់នេះច្រើនយកសំបកខ្យង រឹងរណ្ដៅ ១០ នោះមិញ
ជីកដីប៉ុនពែងព័ទ្ធជុំវិញ ក្បាលមឿងបំពេញដាក់គ្រាប់ប្រាំ[2] ។
- សល់ខានប៉ុន្មានដាក់បួន១ ទំនៀមច្បាប់ក្បួនកត់ចំណាំ
អាចដើរពីឆ្វេង ឬពីស្ដាំ ចាស់១ចងចាំនាំក្មេងផង ។
- ត្បិតល្បែងបាយខុំមិនអស់ប្រាក់ ត្រឹមពិន័យផាកសើចអឹងកង
ឱ្យផ្លិសុំគ្រាប់ជាសំណាង ចាញ់ឈ្នះឥតហ្មងល្បែងសន្តិភាព ។

**ចណ្ណា ស៊ុនហេង**

---

(១) គ្លើ គឺដៃគូលេងជាមួយគ្នា

(២) ក្បាលមឿង មានពីរនៅពីឆ្វេងដៃរៀងខ្លួន

# កំណាព្យប្រស្នា

គណៈកម្មការនិពន្ធ មានកិត្តិយសចុះផ្សាយកំណាព្យប្រស្នាមួយទៀត របស់ឯកឧត្តម វណ្ណ ស៊ិនហេង អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង នៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៤ ឆ្នាំ ១៩៩៧ នេះ ។ ចម្លើយទាំងឡាយណាដែលត្រូវនឹងខ្លឹមសារប្រស្នា នឹងបានទទួលរង្វាន់ តាមកិរិតនៃចំណាត់ថ្នាក់ ។

គណៈកម្មការនិពន្ធ សូមអញ្ជើញលោកអ្នកអានទាំងឡាយ ដែលស្រឡាញ់អក្សរសាស្ត្រខ្មែរ មេត្តាចូលរួមសាកល្បងឆ្លើយអោយបានច្រើនជាអតិបរមា ។

បទកាកគតិ

* បូរាណបានស្ដី មនុស្សមានភ្នែកបី រស្មីសោភា
ទោះទីងងឹត ឆ្ងាយជិតពុំជា ក៏អាចគណនា
មើលឃើញប្រាកដ ។

* ប៉ុន្តែគួរស្ដាយ មនុស្សលោកគ្រប់កាយ ធម្មជាតិកំណត់
មានភ្នែកត្រឹមពីរ ខ្លះសោតគ្មានអត់ ម្ដេចលោកសន្មត
ថាមានភ្នែកបី ។

* តើភ្នែកអ្វីខ្លះ ដែលភ្លឺត្រចះ ឃើញគ្មានទើសអ្វី
ឃើញនាយសួគ៌ា ឃើញនាលោកិយ មនុស្សមានភ្នែកបី
មានមែនឬទេ ? ។

* សូមអស់សន្តាន រួមកែកំសាន្ត ជូនពេលទំនេរ
ខ្ញុំម្ចាស់ប្រស្នា មិនទាន់ថាទេ ចាំស្ដាប់ប្រាជ្ញគេ
គ្រាន់ចេះចាំផង ។

**វណ្ណ ស៊ិនហេង**

# របនាសម្ព័ន្ធគ្រប់គ្រងគណៈសង្ឃពុទ្ធសាសនិក ខាងគណៈមហានិកាយ នៃ ព្រះរាជាណាចក្រកម្ពុជា

( ត ចប់ )

---------

• ខេត្តតាកែវ មានអនុគណ ១០

| | |
|---|---|
| ៤. ស្រុកកោះអណ្ដែត | ព្រះគ្រូរតនបញ្ញវរ |
| ៥. ស្រុកបាទី | ព្រះគ្រូធម្មសរមុនី |
| ៦. ស្រុកសំរោង | ព្រះគ្រូឧត្តមមេធា |
| ៧. ស្រុកព្រៃកប្បាស | ព្រះគ្រូវិជ្ជាវេទី |
| ៨. ស្រុកត្រាំកក់ | ព្រះគ្រូធីរវង្សាចារ្យ |
| ៩. ស្រុកអង្គរបុរី | ព្រះគ្រូឧត្តមចរិយា |
| ១០. ស្រុកបុរីជលសា | ព្រះគ្រូជលវាសីមុនី |

• ខេត្តស្វាយរៀង មានអនុគណ ៦

| | |
|---|---|
| ១. ស្រុកស្វាយរៀង | ព្រះគ្រូធម្មបាលវង្សា |
| ២. ស្រុករំដួល | ព្រះគ្រូនាថាភិរក្ខិត |
| ៣. ស្រុកស្វាយទាប | ព្រះគ្រូវិន័យកោវិទ |
| ៤. ស្រុករមាសហែក | ព្រះគ្រូបរិត្តវិទ្ធ |
| ៥. ស្រុកចន្ទ្រា | ព្រះគ្រូវិមលចន្ទ្រា |
| ៦. ស្រុកកំពង់រោទ៍ | ព្រះគ្រូធម្មកោវិទ |

• ខេត្តកំពង់ធំ មានអនុគណ ៨

| | |
|---|---|
| ១. ស្រុកកំពង់ស្វាយ | ព្រះគ្រូវិរិយធម្មគុត្ត |

២. ស្រុកសណ្ដាន់ ព្រះគ្រូវិសុទ្ធសត្ថា
៣. ស្រុករវៀង ព្រះគ្រូសោភណបញ្ញា
៤. ស្រុកបារាយណ៍ ព្រះគ្រូចរិយានុរ័ក្ខ
៥. ស្រុកស្ទោង ព្រះគ្រូបវិត្តកោសល
៦. ស្រុកសន្ទុក ព្រះគ្រូនិមលធម្មល័ក្ខណ៍
៧. ស្រុកប្រាសាទសំបូរ ព្រះគ្រូអរញ្ញិកសិទ្ធិស័ក្តិ
៨. ស្រុកប្រាសាទបល្ល័ង្ក ព្រះគ្រូរដ្ឋានុរក្ខកោសល

• ខេត្តសៀមរាប មានអនុគណ ៩

១. ស្រុកសៀមរាប ព្រះគ្រូបាសាទរង្សី
២. ស្រុកពួក ព្រះគ្រូសិរីវេទី
៣. ស្រុកក្រឡាញ់ ព្រះគ្រូសង្ឃមុនី
៤. ស្រុកសូទ្រនិគម ព្រះគ្រូគម្ពីរធម្មាចារ្យ
៥. ស្រុកជីក្រែង ព្រះគ្រូសារធម្មបាល
៦. ស្រុកសំរោង ព្រះគ្រូវិសាលបញ្ញា
៧. ស្រុកស្រីស្នំ ព្រះគ្រូសិរីធម្មបាល
៨. ស្រុកអង្គរធំ ព្រះគ្រូបាសាទវិជ័យ
៩. ស្រុកអង្គរជុំ ព្រះគ្រូសិរីរដ្ឋា

• ខេត្តបាត់ដំបង មានអនុគណ ១១

១. ស្រុកស្វាយប៉ោ ព្រះគ្រូពុទ្ធរស្មី
២. ស្រុកមោងឫស្សី ព្រះគ្រូធម្មរង្សី
៣. ស្រុកសង្កែ ព្រះគ្រូបញ្ញារង្សី
៤. ស្រុកបាត់ដំបង ព្រះគ្រូសិរីសត្ថា

៥. ស្រុកបវិល ព្រះគ្រូសំវរសត្ថា

៦. ស្រុកបាណន់ ព្រះគ្រូសង្ឃបញ្ញា

៧. ស្រុកឯកភ្នំ ព្រះគ្រូសិរីវុឌ្ឍិ

៨. ស្រុករតនមណ្ឌល ព្រះគ្រូវជិរបញ្ញា

៩. ស្រុកសំឡូត ព្រះគ្រូបញ្ញាសិរី

១០. ស្រុកកំរៀង ព្រះគ្រូបារមីឫទ្ធិ

១១. ស្រុកសំពៅលូន ព្រះគ្រូសង្ឃមុនី

• ខេត្តក្រចេះ មានអនុគណ ៥

១. ស្រុកក្រចេះ ព្រះគ្រូសីលគន្ធបជ្ជោត

២. ស្រុកសំបូរ ព្រះគ្រូវិសោធបញ្ញា

៣. ស្រុកស្នួល ព្រះគ្រូវិសុទ្ធមេធា

៤. ស្រុកឆ្លូង ព្រះគ្រូគង្គាឧទ័យសីលធមិ

៥. ស្រុកព្រែកប្រសប់ ព្រះគ្រូបទុមរតនវង្សា

• ខេត្តកំពង់ស្ពឺ មានអនុគណ ៧

១. ស្រុកសំរោងទង ព្រះគ្រូវិន័យវេទិ

២. ស្រុកគងពិសី ព្រះគ្រូមុនីវង្សា

៣. ស្រុកថ្ពង ព្រះគ្រូអរិយសត្ថា

៤. ស្រុកឧដុង្គ ព្រះគ្រូបញ្ញាឧត្តម

៥. ស្រុកភ្នំស្រួច ព្រះគ្រូព្រហ្មគិរីធម្មបាល

៦. ស្រុកបសេដ្ឋ ព្រះគ្រូសេដ្ឋានុចារី

៧. ស្រុកឱរ៉ាល់ ព្រះគ្រូគិរីវរភក្តិ

• ខេត្តពោធិសាត់ មានអនុគណ ៤

១. ស្រុកកណ្ដៀង ព្រះគ្រូធម្មមេធា
២. ស្រុកបាកាន ព្រះគ្រូឧត្តមសត្ថា
៣. ស្រុកក្រគរ ព្រះគ្រូសុធីរញ្ញាណ
៤. ស្រុកភ្នំក្រវ៉ាញ ព្រះគ្រូមេត្តាវិបការី

• ខេត្តស្ទឹងត្រែង មានអនុគណ ៦

១. ស្រុកស្ទឹងត្រែង ព្រះគ្រូធម្មាភិរត
២. ស្រុករ៉ុនសែ ព្រះគ្រូសុភទ្ទចរិយា
៣. ស្រុកថះឡាបរិវ៉ត ព្រះគ្រូវិនយានុរ័ក្ខ
៤. ស្រុកសៀមប៉ាង ព្រះគ្រូធម្មានុចារី
៥. ស្រុកសៀមបូក ព្រះគ្រូគាមានុវិជិត
៦. ស្រុកសេសាន ព្រះគ្រូសាគរសោភ័ណ

• ខេត្តកោះកុង មានអនុគណ ៦

១. ស្រុកកោះកុង ព្រះគ្រូទីបរក្ខវាសី
២. ស្រុកមណ្ឌលសីមា ព្រះគ្រូសីមានុរ័ក្ខ
៣. ស្រុកថ្មបាំង ព្រះគ្រូសិលានុរង្សី
៤. ស្រុកស្រែអំបិល ព្រះគ្រូសិរីសោភិត
៥. ស្រុកគិរីសាគរ ព្រះគ្រូវិជិតមេធា
៦. ស្រុកបទុមសាគរ ព្រះគ្រូពិសិដ្ឋមុនី

• ខេត្តបន្ទាយមានជ័យ មានអនុគណ ៤

១. ស្រុកសិរីសោភ័ណ ព្រះគ្រូសោភ័ណវិមល
២. ស្រុកមង្គលបុរី ព្រះគ្រូសិរីមង្គល

៣. ស្រុកភ្នំស្រុក ព្រះគ្រូបរិត្តមេធា

៤. ស្រុកអូរជ្រៅ ព្រះគ្រូកោសលមេធី

• ខេត្តព្រះវិហារ មានអនុគណ ៦

១. ស្រុករវៀង ព្រះគ្រូសោភ័ណបញ្ញោ

២. ស្រុកជ័យសែន ព្រះគ្រូជ័យឫទ្ធី

៣. ស្រុកឆែប ព្រះគ្រូរដ្ឋានុរក្ខកោសល

៤. ស្រុកជាំក្សាន្ត ព្រះគ្រូអាញ្ញិកសិទ្ធិស័ក្ក

៥. ស្រុកសង្គមថ្មី ព្រះគ្រូធម្មកិរីវង្សា

៦. ស្រុកត្បែងមានជ័យ ព្រះគ្រូវិជ័យមេធា

• ខេត្តរតនគិរី មានអនុគណ ៤

១. ស្រុកលំផាត់ ព្រះគ្រូសំវរមេធា

២. ស្រុកវីនសៃ ព្រះគ្រូសុភទ្ទចរិយា

៣. ស្រុកបកែវ ព្រះគ្រូរតនរង្សី

៤. ស្រុកឡាបានសៀក ព្រះគ្រូវិរិយបញ្ញោ

• ខេត្តមណ្ឌលគិរី មានអនុគណ ២

១. ស្រុកកោះញែក ព្រះគ្រូសំវរសីលោ

២. ស្រុកសែនមនោរម្យ ព្រះគ្រូបវរវិជ្ជា

សូមបញ្ជាក់ថា បណ្ដាមេគណគ្រប់ក្រុង-ខេត្ត សុទ្ធតែត្រូវបានទទួលឋានន្តរ៍ជាព្រះរាជាគណៈកិត្តិយសទាំងអស់ ត្រូវប្រើប្រាស់ងារដូចខាងលើនេះ ។ ប៉ុន្តែ ព្រះមេគណក្រុង-ខេត្ត ខ្លះ ដែលបានទទួលឋានន្តរ៍ជាព្រះរាជាគណៈក្នុងតំណែង ក៏អាចប្រើប្រាស់តាមនោះ ។

ព្រះរាជាគណៈគ្រប់ថ្នាក់ ទោះក្នុងតំណែងក្ដី ជាកិត្តិយសក្ដី ត្រូវប្រើពាក្យ « ព្រះ » នាំមុខទាំងអស់ មិនត្រូវប្រើពាក្យ « ព្រះគ្រូ » នាំមុខទេ ។ ឯអនុគណគ្រប់ខ័ណ្ឌ-ស្រុក សុទ្ធតែជាឋានានុក្រមសង្ឃ មានឋានន្តរ៍ជា « ព្រះគ្រូ ... » ឧ. ព្រះគ្រូធម្មបាលមុនី ជាដើម ។ ប៉ុន្តែ អនុគណខ្លះ ដែលមានឋានន្តរ៍ជាព្រះរាជាគណៈស្រាប់ក៏ប្រើប្រាស់តាមនោះ ។

ចំណែកលក្ខការណ៍ជ្រើសតាំងគឺ :

១. ព្រះសង្ឃនាយក ត្រូវព្រះរាជាគណៈ និងព្រះមេគណគ្រប់ក្រុង - ខេត្ត បោះឆ្នោតជ្រើសរើសបណ្ដាព្រះរាជាគណៈថ្នាក់ឯក ។

២. ព្រះរាជាគណៈ-ឋានានុក្រមដទៃទៀត ស្រេចនឹងសម្ដេចព្រះសង្ឃ-នាយក ឬសម្ដេចព្រះសង្ឃរាជ សព្វព្រះទ័យស្នើជ្រើសតាំង ។

៣. ព្រះមេគណ ត្រូវព្រះគ្រូអនុគណគ្រប់ខ័ណ្ឌ - ស្រុក បោះឆ្នោតជ្រើសរើសបណ្ដាព្រះគ្រូអនុគណក្នុងក្រុង - ខេត្ត របស់ខ្លួន ។

៤. ព្រះគ្រូអនុគណ ត្រូវលោកគ្រូចៅអធិការគ្រប់វត្ត បោះឆ្នោតជ្រើសរើសបណ្ដាចៅអធិការក្នុងខ័ណ្ឌ - ស្រុក នីមួយៗ ។

៥. លោកគ្រូចៅអធិការ, គ្រូសូធ្យស្ដាំ - ឆ្វេង ត្រូវភិក្ខុ - សាមណេរក្នុងវត្តនីមួយៗ បោះឆ្នោតជ្រើសរើសព្រះថេរៈក្នុងវត្តនោះ ។

៦. សហការីព្រះមេគណ និងព្រះគ្រូអនុគណ, ត្រូវព្រះមេគណ ព្រះគ្រូអនុគណ ឯកភាពជាមួយមន្ត្រីរាជការ ជ្រើសរើសដោយពុំមានការបោះឆ្នោតទេ ។

ចំណែកលក្ខការណ៍ជ្រើសរើសមន្ត្រីសង្ឃថ្នាក់ព្រះមេគណ - ព្រះគ្រូអនុគណ និងលោកគ្រូចៅអធិការ គ្រូសូធ្យស្ដាំ - ឆ្វេង ខ្ញុំបានស្រាវជ្រាវរៀបចំ តាំងពីឆ្នាំ ១៩៩០ ដូចមានក្នុងសារាចរលេខ ០៧/៩០ ក.ជ.រ.ស ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៩៩០ ស្ដីពីការរៀបចំរចនាសម្ព័ន្ធពុទ្ធសាសនា ដែលយើងបានអនុវត្ត

និងបន្ត អនុវត្តតទៅរួចហើយ ។

ក្រោយពីការរៀបចំនេះបានល្អហើយ, ការឡើងគណក៏ប្រែក្លាយមកជាអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃវិញ គឺក្នុង ១ ឆ្នាំ មាន ១ ដង ធ្វើនៅដើម ខែមករា ថ្ងៃណាត្រូវគ្នានឹងថ្ងៃ ១៤ កើត ខែបុស្ស ដើម្បីឱ្យមន្ត្រីសង្ឃទាំងអស់បានជួបជុំធ្វើឧបោសថកម្មរួមគ្នាផង ។ រយៈវេលានៃការធ្វើអនុសំវច្ឆរមហាសន្និបាតនេះ ឆ្នាំខ្លះ ៣ ថ្ងៃ ឆ្នាំខ្លះ ៧ ថ្ងៃ តាមការងារតិច ឬច្រើន ។ ឯសមាជិកអង្គមហាសន្និបាត មានព្រះរាជាគណៈ ឋានានុក្រម, មេគណទាំងអស់ អនុគណ ព្រមទាំងសហការីមេគណ អនុគណមួយចំនួន មួយអន្លើដោយព្រះថេរានុត្ថេរៈខ្លះទៀត ជាអ្នកសង្កេតការណ៍ផង, ជារួមក្នុងឆ្នាំនីមួយៗ មានពី ៣០០ ទៅ ៥០០ អង្គ ។

ភ្នំពេញ, ខែសីហា ឆ្នាំ ១៩៩៧

អ្នកស្រាវជ្រាវ និងរៀបចំ

**ម៉ី យ៉ាំ**

អនុប្រធាននាយកដ្ឋានធម្មការ និង សាសនា

# សិក្ខាសាលាតំបន់ ស្ដីពី « ដំណើរឆ្ពោះទៅរកអភិសមាចារបរិដ្ឋាន ក្នុងទ្វីបអាស៊ីអាគ្នេយ៍ »



ស្ដាប់សេចក្ដីថ្លែងយោបល់បន្តបន្ទាប់របស់ប្រតិភូមកពីប្រទេសនានា

សិក្ខាសាលាតំបន់ ស្ដីពី « ដំណើរឆ្ពោះទៅរកអភិសមាចារបរិដ្ឋានក្នុងទ្វីបអាស៊ីអាគ្នេយ៍ » ត្រូវបានរៀបចំឡើងដោយពុទ្ធសាសនបណ្ឌិត្យ កាលពីថ្ងៃទី ៥ ដល់ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៩៧ នៅមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា ព្រែកហូរ ក្នុងស្រុកតាខ្មៅ ខេត្តកណ្ដាល ។ សិក្ខាសាលានេះ គឺជាសកម្មភាពអន្តរជាតិដំបូង

ក្នុងចង្កោមសកម្មភាពអន្តរជាតិទាំងឡាយ របស់ពុទ្ធសាសនបណ្ឌិត្យ, ហើយបានកើតជារូបរាងឡើង ដោយសារការឧបត្ថម្ភដ៏ថ្លៃថ្លា ទាំងថវិកា ទាំងស្មារតី អំពីព្រះករុណាជាអម្ចាស់ សម្ដេចព្រះនរោត្តម សីហនុ និងអំពីអង្គការសប្បុរស មានជាអាទិ៍ កម្មវិធីផ្ដល់ជំបូន្មានបច្ចេកទេសបរិដ្ឋានរបស់ យូ.អិន.ឌីភី (UNDP/ ETAP), អង្គការជំនួយស្ងួតស្ងួជប៉ុន ( JSRC ) និងមូលនិធិកាណាដា នៅសិង្ហបុរី ។ លោកស្រីបណ្ឌិត ហេម៉ា គូណាតេលកេ, តំណាងប្រទេសរបស់អង្គការហិនរិចបឹល អាល្លឺ-ម៉ង់ ដែលកំពុងធ្វើសហប្រតិបត្តិការជាមួយពុទ្ធសាសនបណ្ឌិត្យ, និងលោកបណ្ឌិត ភីធ័រ ហ៊ីរ្សាល័យ-ភាព ទីប្រឹក្សាអប់រំបរិដ្ឋាន របស់កម្មវិធីផ្ដល់ជំបូន្មានបច្ចេកបរិដ្ឋាន នៃកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP/ETAP) ជាអ្នកជួយសម្របសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃសិក្ខាសាលានេះ ។

គោលបំណងនៃសិក្ខាសាលា គឺដើម្បីរួមចំណែកដល់ការចងក្រងនូវក្រមអភិសមាចារបរិដ្ឋានវិទ្យា ( Ecòlogy ) ហើយដែលដកស្រង់ចេញមកពីប្រពៃណី, ជំនឿ, សាសនា និងវប្បធម៌របស់ប្រជាជនម្ចាស់ស្រុក នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ វិធីស្វែងរកដំណោះស្រាយវិបត្តិបរិដ្ឋាន តាមរយៈក្រមសីលធម៌បរិដ្ឋាន ដែលនឹងចងក្រងបាននេះ នឹងជួយអ្នកអប់រំ, អ្នកនយោបាយ, អ្នកជំនួញ, អ្នកបង្រៀន, សាស្ត្រាចារ្យ, សាធារណជនអោយបានយល់អត្ថន័យ និងសារសំខាន់ ស្ដីពីការព្រួយបារម្ភចំពោះបរិដ្ឋាន ដែលត្រូវបានគេចាត់ទុកថាជាមាត៌ាមួយនៃជីវិត ។

ទស្សនាវដ្ដី « កម្ពុជសុរិយា » មានសេចក្ដីសោកស្ដាយ ដោយពុំមានលទ្ធភាពចុះផ្សាយខ្លឹមសារនៃអត្ថបទទាំងឡាយ របស់ប្រតិភូមកពីប្រទេសនានា ក្នុងតំបន់ ក្នុងលេខនេះបាន ។ នៅលេខក្រោយ ក្នុងឆ្នាំ១៩៩៨, យើងនឹងខិតខំដកស្រង់ខ្លឹមសារខ្លះៗ ចុះផ្សាយក្នុងលេខជាបន្តបន្ទាប់ ។

ពុទ្ធសាសនបណ្ឌិត្យ